ក្រុមជំនុំនៃទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

ធម្មសវនីយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៦ ខែមករា លេខ ១

ព.ស. ២៤៩៦ – គ.ស. ១៩៥៤



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— បធានកថា	ព្រះទេពមុនី យូរ- ប៊ុណ្ណា	៣
— មនុស្សយើងមិនដុតពីទុក	លោកប៊ូ - ប៊ូ	១៤
ផ្នែកអក្សរសាស្ត្រ		
— ភាពរភាពខាងពុទ្ធសាសនា	លោក ប៊ូ - ប៊ូ	១៩
— ព្រះរាជោវាទ	អ្នកស្រី ឆាំ - ដុំ	២៤
— ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ឹង - ប៊ម ...	៣០
— រឿងសាមកុក (តមក)	ឧកញ៉ា ន្ធូ - កន	៣៦
— នាលៈនឹងទមយន្តី	អ្នកស្រី ស្រ៊ិន សារីយ៉ាន់	៤៦
— រឿងចិញ្ចៀនទិព្យ (តចប់)	អ្នកស្រី ស្រ៊ិន សារីយ៉ាន់	៥១
— រឿងប៉ូលនឹងវីរ៍ស៊ីនី (តចប់)	លោក ផេង - ជ្រីវ	៦៦
កំណត់ទឹកប្រវត្តិការណ៍		
— បុណ្យឈាបនកិច្ចសពឧបាសិកា រ៉ុត ...	ព្រះគ្រូសង្ឃសត្ថា ប៊ុណ្យ - សម្ភាដ	៧៩

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដាវ ២០០ រៀល

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE

— Padhanakatha	*Vén. YOU-PONN*	3
— L'homme ne peut se libérer de la souffrance	*M. BOU-PO*	14

PARTIE LITTERAIRE

— La Solidarité selon la religion bouddhique	*M. BOU-PO*	19
— Brah Rajovada	*Mme CHHAM-CHHOM*	24
— Education morale (suite) . .	*Vén. PEUNG-PAM*	30
— Histoire de SAMKOK (suite) . .	*Oknha NOU-KAN*	36
— Nala et Damayanti	*Mme SRIN-SARIS-YANN* . . .	46
— La bague magique (suite et fin)	*Mme SRIN-SARIS-YANN* . . .	51
Paul et virginie (suite et fin) .	*M. PHENG-CHRIEU*	66

NOTES ET CHRONIQUES

— Incinération de Mme RITH . . .	*Vén PONN-SOMPHEACH* . . .	78

Prix d'abonnement annuel (comprenant 12 numéros): 200$00

ព្រះទេពមុនី យ្ហរ-ប៉ុណ្ណា ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះអរហំសម្មាសម្ពុទ្ធដ៏មានជោគព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្តីគោរព) ។

វេលានេះ និងសំដែងអំពីបជានកថា តបស្នងធ្វើសទ្ធានៃសាធុជនអ្នកជ្រះថ្លាក្នុងព្រះបវរពុទ្ធសាសនា ដូចតទៅនេះ ៖

បជាន: ប្រែថា "សេចក្តីព្យាយាម" គឺព្យាយាមញុំាងសាធារណប្រយោជន៍ទាំងបច្ចុប្បន្នទាំងបរលោក ឬញុំាងប្រយោជន៍ផ្ទាល់ខ្លួនឲ្យកើតឲ្យមានឡើង ហៅថា បជាន: ។

បជាន: នោះមាន ៤ យ៉ាងគឺ

១— សំវរប្បជាន: *ព្យាយាមប្រយ័ត្នមិនឲ្យបាបកើតឡើង*

២— បហានប្បជាន: *ព្យាយាមលះបាបដែលកើតឡើងហើយ*

៣— ភាវនាបជាន: *ព្យាយាមធ្វើកុសលឲ្យកើតមានឡើង*

៤- អនុរក្ខណាបជាន: ព្យាយាមរក្សាកុសលដែលកើតឡើងហើយ ។

បធាន: ខាងលើ ៤ យ៉ាងនេះ ចើសំដែងរួបរួមដោយកិច្ចមាន ២ យ៉ាងគឺ:

១- បហាណកិច្ច កិច្ចដែលត្រូវលះបង់

២- ភាវនាកិច្ច កិច្ចដែលត្រូវចំរើន ។

អធិប្បាយ: បហាណកិច្ច "កិច្ចដែលត្រូវលះបង់" នោះគឺលះបង់នូវអំពើបាប; ពាក្យថាបាប សំដៅយកអំពើអាក្រក់៣យ៉ាងគឺ កាយទុច្ចរិត៣ វចីទុច្ចរិត៤ មនោទុច្ចរិត៣ ។ តម្លៃដ៏ណាមកខាង ៣ នេះសុទ្ធតែជាបាបខាងអស់ ។ តែបាលីមានសំដែងពីបាប ៣ ពួកនេះច្រើនជាងចំណែកដទៃ ព្រោះបាបអម្បាលនេះ ជាប្រធានរបស់បាបខាងពួង; សូម្បីបាបដទៃ ក៏រួមចូលក្នុងបាប៣ពួកនេះដែរ ។

បណ្តាបាបខាងប៉ុន្មានដែលបានពោលមកនេះ ឥតមានចំណែកណាមួយដែលជារបស់គួរធ្វើ គួរប្រព្រឹត្តសោះឡើយ ។ សមដូចព្រះពុទ្ធដីកានៃព្រះតថាគតក្នុងមុនីដែលត្រាស់ទៅកាន់ព្រះអានន្ទថា "ម្នាលអានន្ទ! តថាគតហៅ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ថាជាកិច្ចដែលបុគ្គលមិនគួរធ្វើដោយជាច់ខាត" ។ កាលបើបុគ្គលណាមួយជ្រុលធ្វើអកុសលកិច្ចនោះដោយ កាយ វាចា ចិត្ត ហើយ ត្រូវដឹងខ្លួនចុះថាមុខជានឹងមានទោសពុំខាន ។

ឯទោសប្រព្រឹត្តទុច្ចរិតនោះ មាន ៩ យ៉ាងគឺ

១ – សូម្បីខ្លួនឯងក៏តិះដៀលខ្លួនឯងដែរ

២ – លោកអ្នកចេះដឹងរិះគន់មើល រមែងតិះដៀលបាន

៣ – ក្តើរឈ្មោះអាក្រក់ រមែងល្បីខ្ចរខ្ចាយទៅសព្វទិស

៤ – រវែងរកែចស្មារតីកងពេលដែលធ្វើបស្ចាប់

៥ – ខាងមុខអំពីទំលាយខន្ធទៅ រមែងទៅកើតកងទុគ្គតិ ។

បុគ្គលណាធ្វើបាបដូចបានពោលមកនេះ រមែងក្តៅក្រហាយកង លោកទាំងពីរ គឺកងលោកនេះ កើតទុក្ខក្តៅក្រហាយដោយគិតថា អាត្មាអញបានធ្វើបាបដូច្នោះ ។ លុះច្យុតចាកលោកនេះទៅហើយ រឹងតែតែក្តៅក្រហាយជាងនេះទៅទៀត ។

ព្រោះហេតុនោះ បានជាព្រះអរហំសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា បាបនេះជាអំពើមិនគួរធ្វើ មិនគួរប្រព្រឹត្តឡើយ ។

ភាវិនាកិប្ប "កិច្ចដែលគួរចំរើន" នោះ គឺកម្មដែលកំចាត់បង់នូវសេចក្តីអាក្រក់ ហៅថាកុសល, ការដែលព្យាយាមធ្វើកុសលឲ្យកើតឲ្យមានឡើងហៅថា បំពេញកុសលឲ្យចំបូណ៌ ។ កុសលនោះ បើសំដែងដោយឫសគល់ បានដល់ អលោភោ ការមិនចំពាក់ចិត្តនឹងទ្រព្យសម្បត្តិ គឺមិនបង់បានទូវទ្រព្យសម្បត្តិរបស់អ្នកដទៃ មិនលួចបំណាក់ឆក់ដណ្តើមបំបាត់ប្រពន្ធ័ សង្កត់សង្កិនបែជាន់យកទ្រព្យសម្បត្តិរបស់តែ

ដោយឥតមេត្តា, អ៊ីទ្ធោសៅ មិនប្រពុស្ត គឺមិនខឹងមិនរករឿងរកហេតុអ្នក ដទៃឲ្យគេដល់នូវសេចក្តីវិនាស, អ៊ីម្ហោហ្យោ មិនវង្វែងក្លេចស្មារតី ដោយអ្នកដទៃគេគម្រាម កំហែង បំភាន់គំនិតជាដើមឡើយ ។

មួយទៀត កុសលនេះបើសំដែងដោយទីកើតមាន ១០ ប្រការ គឺ

๑ - ការឲ្យនូវវត្ថុដ៏គួរដល់បុគ្គលដែលគួរឲ្យដោយសេចក្តីសង្រ្គោះ ឬបូជាគុណមានឲ្យដល់មនុស្សកំសត់ទុគ៌ត ឬបូជាដល់អ្នកមានសីលធម៌ នឹងមាតាបិតាជាដើម ហៅថា ទាន: ។

๒ - ការវៀរចាកអំពើអាក្រក់ដែលកើតអំពី កាយ វាចា មានវៀរបញ្ចៀវជាដើម ហៅថា សីល: ។

๓ - ការធ្វើចិត្តឲ្យស្ងប់រម្ងាប់ចាកអកុសលធម៌ មាននីវរណធម៌ជាដើម ដោយសមថវិធីនឹងវិបស្សនាវិធី ហៅថា ភាវនា ។

๔ - ការទំនុកទំពេរមអស្ថិមាន:ដែលកើតមានក្នុងចិត្ត ដោយសេចក្តីគោរពក្រែងចំពោះបុគ្គលដែលគួរគោរពក្រែង គឺជនដែលចំរើនដោយជាតិ ដោយវ័យ ដោយគុណ ហៅថា អបចាយន: ។

๕ - ការជួយទ្រលំទ្រាយក្នុងកិច្ចការកុសល ហៅថា វេយ្យាវច្ច: ។

๖ - ការឲ្យនូវចំណែកបុណ្យដែលខ្លួនបានធ្វើហើយ ដល់អ្នកដទៃដោយមេត្រីចិត្ត ដើម្បីឲ្យគេត្រេកអរតាម ហៅថា បត្តិទាន: ។

๗ ការអនុមោទនា គ្រែតអរតាមនូវសេចក្តីល្អរបស់អ្នកដទៃដែលគេបានធ្វើហើយ ដោយចិត្តដែលជ្រះថ្លាសចេញសេចក្តីប្រែណនឈ្មោនីសហៅថា បត្តានុមោទនា ។

๘ - ការណែនាំបង្ហាត់បង្រៀនប្រៀនប្រដៅអ្នកដទៃ ឲ្យចេះចំណេះវិជ្ជាដែលឥតទោស ឬពន្យល់ជ្រាបក្នុងផ្លូវលោកផ្លូវធម៌ ឲ្យស្គាល់កិច្ចគួរធ្វើ នឹងមិនគួរធ្វើ . ដែលប្រព្រឹត្តទៅដើម្បីសេចក្តីសុខ - ចំរើនក្នុងបច្ចុប្បន្ននេះ រហូតដល់សម្បត្តិសួគ៌ សម្បត្តិព្រះនិព្វានជាទីបំផុតហៅថា ធម្មទេសនា ។

๙ - ការតាំងចិត្តស្តាប់ធម៌ ស្តាប់ពាក្យនៃពេ ពាក្យប្រៀនប្រដៅដោយប្រុងឲ្យចេះចាំស្ទាត់ធ្វើកើត និយាយបាន ហៅថា ធម្មស្សវនៈ ។

๑๐ - ការធ្វើទិដ្ឋិ គឺសេចក្តីយល់ឃើញរបស់ខ្លួនឲ្យត្រូវតាមគន្លងធម៌ដែលពិតមែន ហៅថា ទិដ្ឋិជុកម្មៈ ។

អំពើទាំង ๑๐ ប្រការនេះ ហៅថាបុញ្ញកិរិយាវត្ថុ គឺជាទីកន្លែងសម្រាប់កើតបុណ្យ ។ បុគ្គលណាបានធ្វើកុសលដូចបានពោលមកនេះ, បុគ្គលនោះរមែងបាននូវអានិសង្ស ๕ យ៉ាង គឺ:

๑ - សូម្បីខ្លួនឯងក៏សរសើរខ្លួនឯង

๒ - អ្នកប្រាជ្ញទាំងឡាយលោកពិចារណាឃើញតាមការពិតហើយលោករមែងសរសើរ

៣- មានកិត្តិស័ព្ទពីកេះល្បីខ្ចរខ្ចាយទៅសព្វទិស

៤ - មិនវង្វែងក្តៅចស្មារតីកង់ពេលធ្លុះមរណកាល

៥ - រមែងទៅកើតក្នុងសុគតិ ។

បហានកិច្ច ទឹង តាវនាកិច្ចដែលបានសំដែងមកនេះ ជាដំណើរខាងផ្លូវធម៌ បើជាខាងផ្លូវលោកវិញ សំដៅយកការលះបង់នូវបុគ្គល មានយោគអាក្រក់ ក្រអឺតក្រអោង កោងកាច ឱ្លិលច្រអូស ដើរលេងស៊ីផឹក ចាយវាយទ្រព្យសម្បត្តិឥតប្រយោជន៍ ឥតសណ្តាប់ធាប់ ធ្វេចោរកម្មលួចប្លន់ធ្លាក់ដណ្តើម រឹបជាន់សង្កត់សង្កិនយកធនធានអ្នកដទៃជាដើម ។ អំពើអស់នេះ សុទ្ធតែជាអំពើនាំឲ្យថោកថាបង្ខាន់ខ្សោយឲ្យអាប់រស្មីដល់ខ្លួនឯង ទឹងប្រទេសជាតិ មាតុភូមិ ជាអំពើនាំឲ្យលោកតិះដៀល; បុគ្គលអ្នកស្រឡាញ់សេចក្តីល្អគួរលះបង់ចោល ។

ព្រោះហេតុនោះ យើងកើតមកជាមនុស្សម្នាក់ៗ ក្នុងលោកសន្និវាសនេះ មានអាយុវែងគ្រប់គ្រាន់ មិនកំលសវិការៈ ដោយអាយតនៈណាមួយ គួរតែមានព្យាយាមបំពេញកិច្ចរបស់ខ្លួនឲ្យគ្រប់គ្រាន់ កុំពឹងផ្អែកទៅលើរូបបុគ្គលណាមួយឲ្យគេចិញ្ចឹមខ្លួននោះ មិនបានសម្រេចប្រយោជន៍ទេ, ព្រោះរូបនីមួយៗសុទ្ធតែមានសេចក្តីសុខទុក្ខជាប់ជាក់ខឹងដោយកាយ, ឬក៏មានកាយជាទីអាស្រ័យនៅនៃសេចក្តីសុខទុក្ខ ដូចជាគេហដ្ឋានជាទីអាស្រ័យនៅនៃមនុស្ស, ជីវិតសោតទៀតដែលទឹងតាំង

នៅបាន កំព្រាអាស្រ័យពាងកាយ ការគ្រប់គ្រងចិញ្ចឹមពាងកាយឲ្យ
បានជាត់ធំមាំមួនខ្លាំងពូកែនៅបាន កំព្រាអាស្រ័យសេចក្តីព្យាយាម
ស្វែងរកអាហារ, កាលបើប្រាសចាកអាហារហើយ សន្តតិរូបតឺរូប
ដែលចំរើនជាប់តទៅក៏ឈប់ចំរើន ពាងជីវិតសោតទៀត ក៏តាំងនៅបាន
ដោយកម្រ ។ អាហារនេះជារបស់សំខាន់បំផុត សម្រាប់បម្រុងជីវិត
ឲ្យប្រព្រឹត្តទៅ, សមដូចប្រាសីថា សព្វេសត្តា អាហារដ្ឋិតិកា
"ពួកសត្វភាល់រូបដែលមានជីវិតរស់នៅបាន ក៏ព្រោះអាហារ" ។ វត្ថុ
ឯទៀត ។ ក្រៅពីអាហារនោះមានច្រើន ដូចយ៉ាងលំនៅជាទីជ្រកកោន
សំពត់សម្រាប់ស្លៀកដណ្តប់ ថ្នាំសម្រាប់កែពេគកង្វក់ពេលដែលត្រូវការ
ប៉ុណ្ណោះជាដើម, វត្ថុទាំងអម្បាលនេះ សុទ្ធតែជារបស់ជួយឧបត្ថម្ភចម្រើន-
ចល់ជីវិតទាំងអស់, បើប្រាសចាករបស់ណាមួយហើយ ជីវិតរមែងតាំង
នៅបានដោយលំបាក ។

សូមតាញរឿងមហាជនកមកសំដែងក្នុងទីនេះ ដើម្បីឲ្យឃើញ
អានិសង្សនៃសេចក្តីព្យាយាម ។

ព្រះពោធិសត្វព្រះនាម មហាជនក កាលលាមាតាចុះសំពៅទៅជួញ
ជាមួយនឹងពួកឈ្មួញ, លុះដល់កណ្តាលមហាសមុទ្រ សំពៅក៏ធ្លុះធ្លាយ
ទៅដោយត្រូវខ្យល់ព្យុះខ្លាំង, ពួកឈ្មួញទាំងអស់ក៏ស្លាប់អស់ទៅ ។
ចំណែកខាងព្រះពោធិសត្វ មិនកំយកតែតក់ស្លុតនឹងសេចក្តីស្លាប់ឡើយ,

លោកនឹកដល់គុណមាតាបិតា នឹង គុណសីលដែលធ្លាប់បានប្រតិត្តមក
ហើយក៏លោតចេញអំពីសំពៅប្រឹងហែលសំដៅទៅរកត្រើយម្ខាង អស់
ចំនួន ៧ ថ្ងៃ, លុះដល់ថ្ងៃទុំបោសថ លោករក្សានូវទុំបោសថសីលតាំង
កំពុងព្យាយាមហែលក្នុងមហាសមុទ្រ ។

ពេលនោះ មានទេពធីតា ១ អង្គឈ្មោះ មណិមេខលា នៅរក្សា
មហាសមុទ្រ បានឃើញព្រះពោធិសត្វប្រឹងព្យាយាមហែលមិនមានឈប់
យ៉ាងនេះ ក៏ស្រែកសួរថា:

"អ្នកណានេះ កាលបើមិនឃើញនូវកោះត្រើយសោះ ម្តេច
ក៏ខំប្រឹងហែលក្នុងកណ្តាលមហាសមុទ្រ តើអ្នកដឹងនូវប្រ-
យោជន៍ដូចម្តេច បានជាខំប្រឹងព្យាយាមហែលម៉្លេះ?" ។

ព្រះជនកពោធិសត្វតបថា:

"ម្នាលទេវតា! ខ្ញុំពិចារណានូវវត្តនៃសត្វលោក នឹងអានិសង្ស
នៃសេចក្តីព្យាយាម ព្រោះហេតុដូច្នោះ ខ្ញុំបើទុកជាមិនឃើញ
នូវកោះត្រើយក៏ដោយចុះ ក៏នៅតែប្រឹងព្យាយាមហែលក្នុង
កណ្តាលមហាសមុទ្រ (ទុកជាតម្រាំមដល់លោក ស្លាប់ពេល
ណាឈប់ពេលនោះ មិនលះបង់នូវសេចក្តីព្យាយាមទេ)" ។

នាងទេពធិតាពោលថា:

"ត្រើយមហាសមុទ្រជ្រៅរកប្រមាណមិនបាន មិនច្បាស់ដល់អ្នកណា ការព្យាយាមតាមកម្លាំងបុរស ក៏ជាការឥតអំពើដល់អ្នកនោះ អ្នកមិនដល់ត្រើយទេមុខជានឹងស្លាប់ ក្នុងកណ្តាលមហាសមុទ្រនេះពុំខានឡើយ" ។

ព្រះជនកតបថា:

"បុគ្គល (កំពុងព្យាយាម សូម្បីនឹងស្លាប់) ក៏បានឈ្មោះថាជាអ្នកមិនមានបំណុល គឺពួកញាតិពួកទេវតានឹងមាតាបិតាមិនបានតិះដៀលឡើយ បុគ្គលនោះ កាលបើបានធ្វើកិច្ចរបស់បុរសហើយ រមែងមិនក្តៅក្រហាយក្នុងពេលខាងក្រោយឡើយ" ។

នាងទេពធីតាពោលទៀតថា:

"ការងារណាមិនសម្រេចដោយសេចក្តីព្យាយាមទេ ការងារនោះទៅជារបស់ឥតផល មានតែសេចក្តីលំបាកជាកម្រៃ សេចក្តីស្លាប់រមែងសម្រេចដល់បុគ្គលណា បុគ្គលនោះនឹងមានប្រយោជន៍ដូចម្តេច ដោយការព្យាយាមនោះ" ។

ព្រះជនកតបថា

ម្នាលទេវតា! បុគ្គលណាដឹងច្បាស់ថា ការងារមានទីបំផុតត្រែពេកមិនសម្រេចទេ ហើយលះបង់ចោលបែរជា

រក្សាដំរីតរបស់ខ្លួនទៅវិញ ក៏បន្តយន្តូវសេចក្តីព្យាយាមចេញ
ចេញ, បុគ្គលនោះគង់នឹងដឹងនូវផលនៃសេចក្តីឱ្យច្រើនអ្វីស
នោះពុំខាននឡើយ ។ ម្នាលទេវតា ! បុគ្គលពួកខ្លះក្នុងលោកនេះ
កាលបើឃើញនូវផលនៃសេចក្តីច្បាស់ហើយ រមែងច្រកបន
នូវការងារធំធ្ងន់ឡាយ ការងារធំធ្ងន់នោះ ទោះបីសម្រេចក្តីមិន
សម្រេចក្តី គួរតែខំប្រឹងព្យាយាមកុំខាន ។ ម្នាលទេវតា !
ក្រែងអ្នកបានឃើញនូវផល នៃសេចក្តីព្យាយាមជាក់ច្បាស់
ដោយខ្លួនឯងដែរឬ ? ជនធំធ្ងន់ឡាយឯទៀត ។ លិចចុះក្នុង
មហាសមុទ្រអស់ហើយ មកពីមិនមានសេចក្តីព្យាយាម,
ឯខ្ញុំតែម្នាក់ឯងទេដែលកំពុងហែលឆ្លងក្នុងមហាសមុទ្រ ពាំង
បានឃើញអ្នកដែលស្ថិតនៅក្នុងទីជិតខ្ញុំ, ខ្ញុំនេះនឹងព្យាយាម
តាមសមគួរដល់សេចក្តីអង់អាច នឹងសមគួរដល់កំឡាំង,
កាលបើខ្ញុំបានដល់ត្រើយនៃមហាសមុទ្រហើយ ខ្ញុំនឹងធ្វើនូវ
សេចក្តីព្យាយាមដែលបុរសគប្បីធ្វើនោះ ឲ្យបានសម្រេចជា
តំយ្យាកាត ។

លុះព្រះជនកពោធិសត្វពោលតែប៉ុណ្ណេះហើយ, ទេពធីតាក៏ស្ទុះទៅ
ចាប់ដៃព្រះពោធិសត្វ តើចទាញនាំយកទៅដាក់ដល់មិថិលានគរ, មិន
យូរប៉ុន្មាន ព្រះពោធិសត្វក៏បានសោយភោគក្នុងនគរនោះឯង ។

នាំរឿងក៏រមែកប៉ុណ្ណេះដើម្បីឲ្យឃើញថា គុណសម្បត្តិនៃសេចក្តីព្យាយាមនេះ អាចឲ្យសម្រេចផលដល់បុគ្គលអ្នកមានសមត្ថភាព ។ បុគ្គលណា កាលបើមានសេចក្តីពេញចិត្តក្នុងការបំពេញកិច្ចរបស់ខ្លួនហើយព្យាយាមបំពេញកិច្ចនោះ ក៏ចាន់ឈ្មោះថាប្រសើរជាទីបំផុត ។ ខ្លួនស្ងាប់ចាត់ទៅមែនតែកេរ្តិ៍ឈ្មោះនៅល្អ, ខ្លួនស្ងាប់ទៅបុះ កុំឲ្យតែស្ងាប់ៈសេចក្តីព្យាយាម ។ សមដូចពុទ្ធភាសិតថា រូបំ មិយ្យតិ មច្ចានំ នាមគោត្តំ ន មិយ្យតិ រូបនៃសត្វទាំងឡាយរមែងស្ងាប់ទៅ តែនាមនឹងគោត្រមិនស្ងាប់ឡើយ ។ រីឯង ទុក្ខមញ្ញេតិ គេត្រូវដឹងនូវសេចក្តីទុក្ខបានដោយសេចក្តីព្យាយាម ។

សំដែងអំពីបទានកថាចប់តែប៉ុណ្ណេះ, ។

សូមថ្វាយព្រះពរជ័យសួស្តីចំពោះព្រះករុណាជាម្ចាស់ជីវិត សូមព្រះអង្គស្ថិតនៅក្នុងសិរីរាជសម្បត្តិអស់កាលដ៏យូរអង្វែងទៅ! ទីឆ្ងាសូមឲ្យអស់លោកជាពលរដ្ឋធំ-តូច ព្រមទាំងពុទ្ធបរិស័ទទាំងឡាយក្នុងកម្ពុជរដ្ឋទាំងមូល ជួបសេចក្តីសុខចំរើនជាកំយ៉ាកាត! ។

មនុស្សយើងមិនដុតពីទុក្ខ(១)

ឬបណ្ណាផ្សុំក្បួ-ប្ប័ រៀបរៀង

ជីវិតរបស់យើងតាំងឡាយដែលមិនសប្បាយរីករាយមិនស្រស់បស់នោះ ជាគ្រឿងចង្អុលបង្ហាញឲ្យដឹងថា "យើងកាល់គ្នាវង់ទុក្ខ" ។

ហេតុអ្វីបានជាយើងវង់ទុក្ខ?

ហេតុតែជីវិតរបស់យើងគ្មានឥស្សរភាព ។

ហេតុអ្វីបានជាជីវិតរបស់យើងគ្មានឥស្សរភាព?

ហេតុតែយើងជាប់ចំណង ១០ ប្រការ ។ ចំណងតាំង ១០ នោះ ចងគ្រឹកយើងជាប់ណាស់ ប៉ុន្តែវាបន្ធូរឲ្យវែងបណ្តោយឲ្យយើងដើរតាចៅបានតាមទំនើងចិត្ត តែកុងកំរែងធំខ្សែដែលអនុញ្ញាតឲ្យយើងដើរប៉ុណ្ណោះ យើងនឹងដើរឲ្យហួសចេញក្រៅកំរែងខ្សែនោះទៅទៀតមិនបានទេ ប្រៀបដូចគោដែលគេចងនឹងស្នឹងហើយចេះតែដើរក្បឹងដុំវិញស្នឹងដូច្នោះ ។

ចំណងតាំង ១០ នោះ គេវេញបញ្ចូលគ្នាជាខ្សែ ១ ធ្លុង បុងខ្សែម្ខាងចងគ្រឹកខ្លួនយើងជាប់ បុងខ្សែម្ខាងទៀតចងភ្ជាប់នឹងបង្គោលគ្រាក់មួយដ៏រឹងមាំមួនក្រៃលែង បើខ្សែនោះមិនទាន់សឹកជាប់ដរាបណា ជីវិត

---

១ អធិប្បាយអំពីធម៌ ១០ ជាគ្រឿងចងគ្រឿកមនុស្ស (សំយោជនៈ ១០) តាមប្បាប់ពុទ្ធសាសនា លេខ ម. ៤៣៥ ទំព័រ ៦០៦... ។

របស់យើងក៏គ្មានឥស្សរភាពដែរដូចនោះដែរដាច់ខាត ហេតុនេះហើយបានជា យើងមិនផុតពីទុក្ខ នេះជាភាក្យធ្វើយតបនឹងប្រស្នាខាងដើម ។

ឯចំណែកខាងទី១០ប្រការនោះ ក៏ចេះធ្វើទុក្ខយកលន្លែងយ៉ាងណាស់ ក៏ចង់យើងមិនឲ្យដឹងខ្លួនសោះ ក៏ចេះធ្វើមាយាប្រលោមលួងលោមយើងឲ្យស្ទុះចិត្តទៅតាមក៏ ក៏ចេះឆ្ពិនភ្នែកយើងឲ្យមើលឃើញខ្លួនឯងថាជាខ្សែមាសសង្វាតឆ័តន់ដាំសុទ្ធតែត្បូងពេជ្រ យើងគើតចិត្តប្រតិព័ទ្ធស្មើហានឹងក៏ក្លេចស្មារតីស៊ប្បុរជីវិត លុះក៏ដឹងថាយើងក្លេចខ្លួនហើយក៏ទន់ភាញយើងសន្សឹមៗ បន្តិចម្តងៗ ឲ្យយើងធ្លាក់ខ្លួនទៅជាអ្នកទោសរបស់ក៏ ឲ្យយើងទៅជាទាសកាតរបស់ក៏ ហេតុនេះហើយបានជាជីវិតយើងគ្មានឥស្សរភាព ។

ចំណែកខាងទី១០ប្រការនោះ លោកអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាឲ្យឈ្មោះតាមភាសាបាលីថា សំយោជនៈ ប្រែថា "គ្រឿងចងមនុស្សសត្វ", មាន ១០ប្រការគឺ ៖

បឋមទី ១.— សេចក្តីសំគាល់ខុសក្នុងរាងកាយទាំងមូលថា រូបរាងកាយនេះមានខ្លឹមសារ នឹង សំគាល់ថាខ្លួនយើងមានអំណាចពេញលេញ អាចបង្កាប់បញ្ជារូបរាងកាយខ្លួនឯងឲ្យបានដូចចិត្តប្រាថ្នារបស់ខ្លួន ហើយប្រកាន់យករាងកាយទាំងមូលនោះថាជារបស់ខ្លួនជាដើម, តាមការពិត គំនិតដែលសំគាល់ដូច្នោះខុសស្រឡះទាំងអស់ ។

ខ្សែនេះភាសាបាលីហៅថា សក្កាយទិដ្ឋិ "សេចក្តីយល់ឃើញថា ភឆកាយជារបស់ខ្លួនយើង" ។

បំណាងទី ២.— សេចក្តីសង្ស័យថា ការរើខ្លួនឲ្យផុតពីការដេកលក់ គឺសេចក្តីប្រមាទស្រេចឬ, សេចក្តីល្អប្រពៃដែលអាចជាប់ជីវិតឲ្យស្រស់ថ្លាបាន, ការធ្វើដំណើរជីវិតត្រង់ទៅកាន់វិថីនៃសេចក្តីបរិសុទ្ធិមានពិតមែនឬ ឬក៏គ្មានទេ ។ ខ្សែនេះភាសាបាលីហៅថា វិចិកិច្ឆា "សេចក្តីសង្ស័យ" ។

បំណាងទី ៣.— ការមិនយល់ច្បាស់លាស់ ចូលចិត្តមិនត្រង់ មិនត្រូវក្នុងការខ្ជួនខ្ជាន ហាត់ពត់កាយវាចាឲ្យល្អបរិសុទ្ធ នឹងមិនយល់ច្បាស់នូវសេចក្តីរៀបរយដែលជាប់ទាក់ទងនឹងការហាត់ពត់កាយវាចា ត្រឡប់ជាវង្វេងយល់ខុសថា អំពើនោះ ។ ជាអំពើឲ្យកើតឫទ្ធីខ្លាំងពូកែ ឲ្យមានសេចក្តីសក្តិសិទ្ធិ ឯខ្លួននឹងស្អាតបរិសុទ្ធបាន ក៏ព្រោះតែសេចក្តីសក្តិសិទ្ធិនោះឯងជាដើមចម ។ ខ្សែនេះភាសាបាលីហៅថា សីលពតូបរាមាសៈ "ការបៅសអង្អែលកន្ទុយសីលនឹងវត្ត" ។

បំណាងទី ៤.— ដំរេកក្នុងអារម្មណ៍ជាទីស្រឡាញ់ ដែលមានកំដៅយ៉ាងខ្លាំងក្លា ព្រះពុទ្ធជាម្ចាស់ទ្រង់ហៅថា ភគគ្គិ "ភ្លើងគឺរាគ" ។ ខ្សែនេះភាសាបាលីហៅថា កាមរាគៈ "សេចក្តីដំរេកក្នុងកាម" ។

បំណាងទី៥.— សេចក្តីចាំឆ្ងាក់នៃចិត្តកន្លងកាលមានសេចក្តីត្រេកអរ ចូលមកត្រួបសង្កត់ ។ ខ្សែនេះគាសាចាលីហៅថា បីតិ: "សេចក្តីខ្ពើមឬចាំឆ្ងាក់នៃចិត្ត" ។

បំណាងទី៦.— ចិត្តដែលជាប់ដំណាក់ក្នុងរូបធម៌ឬរូបកត្តជ្រុលហួសទៅ តាល់តែឃើញថារូបនោះជារបស់គួរត្រេកអរហើយក៏មានចិត្តជាប់ស្អិត ។ ខ្សែនេះគាសាចាលីហៅថា រូបរាគ "ជំរេកក្នុងរូប" ។

បំណាងទី៧.— ចិត្តជាប់ដំណាក់ក្នុងអារម្មណ៍ដែលមិនមានរូបច្បាកដ គ្រាន់តែមានឈ្មោះជាគ្រឿងដឹង តាល់តែឃើញថាអារម្មណ៍ទាំងនោះគួរត្រេកអរហើយជាប់ចិត្តស្អិតទៅ ។ ខ្សែនេះគាសាចាលីហៅថា អរូបរាគ "ជំរេកក្នុងអរូប" ។

បំណាងទី៨.— សេចក្តីសំគាល់ខ្លួនឯងថា ខ្លួនយើងជាមនុស្សម្នាក់ដែរ ហើយយកខ្លួនទៅប្រៀបធៀបអ្នកដទៃ ជាហេតុឲ្យលើកតំលៃខ្លួនថាខ្ពស់ជាងគេឬថាស្មើនឹងគេ ឬក៏ជាក់ខ្លួនថាថោកទាបជាងគេ ។ ខ្សែនេះគាសាចាលីហៅថា មានៈ "សេចក្តីប្រកាន់ខ្លួន" ។

បំណាងទី៩.— សេចក្តីអណ្តែតអណ្តូងនៃចិត្តទៅតាមអារម្មណ៍នោះ ។ សេចក្តីពយាយក្នុងអារម្មណ៍ ។ ខ្សែនេះគាសាចាលីហៅថា ឧទ្ធច្ច "សេចក្តីអណ្តែតអណ្តូង" ។

បំណាងទី ១០.— សេចក្តីមិនដឹងខ្លួន មិនដឹងប្រមាណ ការដឹងមិនទាន់ យល់មិនទាន់ ។ ខ្សែនេះតាមភាសាបាលីហៅថា អវិជ្ជា "សេចក្តីមិនដឹង" ។

មនុស្សយើងជាបុថុជ្ជនអ្នកគ្រាសដោយកិលេស អាចនឹងកាត់ខ្សែបំណងទាំង ១០ ប្រការដាច់ដែរឬទេ ?

អាចនឹងកាត់ដាច់បាន ប៉ុន្តែមិនមែនកាត់តែម្តងដាច់អស់ទាំង ១០ ទេ ត្រូវតែមានព្យាយាមកាត់ ១ សរសៃឬ ២ សរសៃខ្លះ ដរាបដល់ដាច់អស់ទាំង ១០ ទើបយើងផុតពីទុក្ខ បើយើងកាត់ដាច់អស់ ៩ សរសៃហើយ នៅសល់តែ ១ សរសៃប៉ុណ្ណោះ ក៏យើងមិនទាន់ផុតពីទុក្ខដែរ ហេតុនេះយើងត្រូវតែព្យាយាមកាត់ឲ្យដាច់អស់គ្រប់ទាំង ១០ សរសៃ កុំឲ្យនៅសល់ ១ សរសៃឡើយ ។

ព្រះបរមគ្រូនៃយើងទ្រង់ត្រាស់ប្រាប់ថា "មនុស្សនឹងផុតចាកទុក្ខបាន ព្រោះសេចក្តីព្យាយាម" គឺព្រះអង្គទ្រង់បង្គាប់ឲ្យយើងមានព្យាយាមកាត់កិលេសទាំងអស់ មានសំយោជន៍ ១០ ប្រការនេះជាដើម ទើបយើងនឹងផុតចាកទុក្ខ ក្រោយពីបុថុជ្ជនទៅជាព្រះអរិយៈបាន នេះជាពាក្យធ្វើយតបនឹងប្រស្នាដែលតាំងទុកខាងដើម ។

ចប់

បរិយាយ ពីការរាប់អានគ្នាជួបជងប្លន្តកងផ្លូវពុទ្ធសាសនា

លោក ប៊ូ-ប៊ូ រៀបរៀង

ភាពនៃការរាប់អានគ្នាជួបជងប្លនរបស់មនុស្សក្នុងលោក តាមភាសាបាលីហៅថា "ភាតរភាព" ។

ភាតរភាពមានច្រើន, តែរួមជា ២ ប្រភេទ គឺភាតរភាពកងផ្លូវលោក ១ ភាតរភាពកងផ្លូវសាសនា ១ ។

ការរាប់អានគ្នា តាមភាពជាជនជាតិជាមួយគ្នា ជាវង្សត្រកូលជាមួយគ្នា ជាមិត្តសំឡាញ់ជងគ្នា ចាត់ជាភាតរភាពកងផ្លូវលោក ។

ការរាប់អានគ្នា តាមភាពជាអ្នកកាន់សាសនាជាមួយគ្នា ចាត់ជាភាតរភាពកងផ្លូវសាសនា ។

សូមបរិយាយចំពោះតែភាត ភាពកងផ្លូវព្រះពុទ្ធសាសនាម្យ៉ាង ។

មនុស្សមានជាតិផ្សេងគ្នាទាំងប្រទេសក៏ផ្សេងគ្នា ប៉ុន្តែកាន់សាសនាព្រះពុទ្ធជាមួយគ្នា ដូចជនជាតិឥណ្ឌា លង្កា ភូមា ថៃ លាវ ជប៉ុន ចិន យួន ទឹងខ្មែរយើងជាដើម (ទោះបីផ្សេងនិកាយ) ក៏ហៅថា "មនុស្សពុទ្ធសាសន៍" ឬ "ពុទ្ធបរិស័ទ" ដូចគ្នា ។

ពុទ្ធបរិស័ទគ្រប់ប្រទេសកាន់ព្រះពុទ្ធសាសនា បានយល់ឃើញថា ទាំងមនុស្សទាំងសត្វកងសាកលលោកសុទ្ធតែខ្វាចខ្ពក្ខចន្ទីសុខ, ខ្វាចស្លាប់

ចង់រៀនគ្រប់រូប ។ ដោយគេយល់ឃើញដូច្នេះបានជាគេត្រូវផ្សាយមេត្តាចិត្តអាណិតមនុស្សសត្វទូទៅ ទើប ត្រូវធ្វើការកុសលនានា គឺកាន់សីលមានវៀរចាកការបៀតបៀនការសម្លាប់ ការលួចជាដើម ព្រមទាំងបរិច្ចាគទានមានសាងវត្តអារាមវិហារ សាលារៀន មន្ទីរពេទ្យជាដើម តាំងប្រទេសរៀងខ្លួន ។ ចំពោះព្រះសង្ឃជាពុទ្ធដំណើរសទាំង ៤ ទិស គឺព្រះសង្ឃជាតិខ្មែរចូលទៅសំណាក់ក្នុងវត្តលោកសង្ឃជាតិឥណ្ឌា ថៃ ភូមា លង្កា លាវ ជប៉ុន ចិន យួនក៏បាន, លោកសង្ឃជាតិទាំងនោះចូលមកសំណាក់ក្នុងវត្តលោកសង្ឃជាតិខ្មែរក៏បាន តតប្រកាន់ឡើយ ។

នេះជាអំពើវិតចំណង់ភាតរភាពរវាងមនុស្សពុទ្ធសាសន៍ដូចគ្នា ឲ្យចាក់ស្រែះជាប់គ្នាជាជរាបទៅ ។

នៅបច្ចុប្បន្នកាលនេះ ពួកពុទ្ធបរិស័ទនៅទ្វីបអាស៊ីខ្លះ អឺរុបខ្លះ បានរួមគ្នាបង្កើតសមាគមពុទ្ធសាសនាឡើងហៅថា "ពុទ្ធិកសមាគមពិភពលោក" មានទីសំណាក់ការធំនៅលង្កាទ្វីប ។ ប្រទេសខ្មែរយើងក៏បានរួមជាមួយផង, ហើយរៀងៗលំប្រទេសបានបង្កើតពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគ ជាសាខានៃពុទ្ធិកសមាគមពិភពលោកទៀត ដើម្បីជួយឧបត្ថម្ភសមាគមនេះឲ្យរឹងប៉ឹងនឹងឲ្យរីកសាយទូទៅ ។ ប្រទេសកម្ពុជាយើងក៏បានបង្កើតដូចគេ ហៅថា "ពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ" មានទីសំណាក់ការបណ្ដោះអាសន្នៅមហាកុដិវត្តឧណ្ណាលោមក្រុងភ្នំពេញ ។

ពុទ្ធិកសមាគមទាំងនេះ ជាសមាគមពង្រីកការគោរពខាងព្រះពុទ្ធ-សាសនាឲ្យកែងធំទូលាយ ។ ការពង្រីករបស់សមាគមនេះមានន័យផ្សេង ។ គឺសាងវិជ្ជាហានសម្រាប់បង្រៀនពុទ្ធវចនៈជាភាសាបាលីភាសាសំស្ក្រឹតនឹងភាសាបរទេស, រៀបរៀងពុទ្ធវចនៈទុកជាក្បួនច្បាប់សម្រាប់បង្រៀនប្រជាជន. បញ្ជូនគណៈធម្មទូតទៅផ្សាយ ព្រះពុទ្ធសាសនានៅនានាប្រទេសទូទៅទាំងពិភពលោក; បញ្ជូនទិស្សិតទៅរៀនពុទ្ធវចនៈជាភាសាបរទេសនៅនានាប្រទេស ដើម្បីឲ្យបេះរបៀបផ្សាយនូវព្រះពុទ្ធសាសនាដោយភាសាផ្សេង ។ ដូចប្រទេសខ្មែរយើងបានបញ្ជូនឲ្យទៅរៀននៅប្រទេសឥណ្ឌា លង្កា កូមា ជប៉ុនជាដើម ។

អាស្រ័យដោយព្រះពុទ្ធសាសនា ជាសាសនាមានរសតែមួយ គឺវិមុត្តិរសដូចមហាសមុទ្រដែលមានរសតែមួយ៉ាង គឺរសប្រៃ ហើយដោយពុទ្ធបរិស័ទ្ធពួកគ្នាពង្រីក នឹងតែសម្ពន្ធភាតរភាពខាងព្រះពុទ្ធសាសនាដូចថ្ងៃមកនេះថែមទៀត ក៏មានប្រជាជនទៅអាស៊ីនឹងអ៊ឺរ៉ុបជិះថ្ងាកាន់តាមកាន់តែច្រើនឡើងជាលំដាប់ ។ ការបើដូច្នេះ ភាតរភាពខាងព្រះពុទ្ធសាសនាក៏មានច្រើនឡើងតាមគ្នា ។

ចំណែកប្រទេសកម្ពុជាយើង ជាប្រទេសមានជាតិ សាសនា មហាក្សត្រ តាំងពីសម័យគោកធ្មកព្រៃនាយមក មិនដែលអាក់ខានទេគ្រាន់

តែសម័យមុន គេកាន់ព្រហ្មញ្ញសាសនា, សម័យកណ្តាលគេកាន់ពុទ្ធសាសនាថែបមហាយាន សម័យឥឡូវគេកាន់ពុទ្ធសាសនាថែបហីនយានប៉ុណ្ណោះ, ភាតរភាពរវាងជាតិ សាសនា មហាក្សត្រ របស់ខ្មែរក៏ចេះតែមានជាប់ជាដរាបមកទល់សព្វថ្ងៃនេះ ។

ព្រោះហេតុនេះ ឃានជាហេតុណាកបណ្ឌិតជាតិខ្មែរ ឃានតាំងគ្រឹះសរណដ្ឋាន ៣ ប្រការគឺ ... ជាតិ សាសនា. មហាក្សត្រ" ទុកជាឃ្លាបទនាសម្រាប់ទូន្មានបច្ចាជនតាជនក្នុងកម្ពុជរដ្ឋ ឲ្យគោរពនូវប្រពៃណីរៀងខ្លួនដើម្បីសេចក្តីសុខ - ចម្រើនទំនឹងរុងរឿងដល់កម្ពុជប្រទេស ។ ប្រជាជនជាតិខ្មែរទាំងពួងក៏ឃានស្វាធ្យាយឃាវបទានេះចេះចាំសឹងគ្រប់គ្នា ។

ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ រ័ន ព្រះឋាប្រទេសកម្ពុជាជាអម្ចាស់ដ៏វិសេសលើត្បូងរបស់យើងសព្វថ្ងៃនេះ ទ្រង់ប្រកបដោយគ្រឹះសរណដ្ឋានទាំង ៣ ប្រការនេះ គឺ

១) ទ្រង់មានព្រះជាតិជាខ្មែរ ជាព្រះមហាក្សត្រអគ្គប្រមុខជាតិខ្មែរ ទ្រង់ស្នេហាទំនឹងគោរពជាតិខ្មែរ ;

២) ទ្រង់ស្នេហាទំនឹងគោរពព្រះមហាក្សត្រ ជាបុព្វបុរសរបស់ខ្មែរ;

៣) ទ្រង់ស្នេហាទំនឹងគោរពព្រះពុទ្ធសាសនា ជាសាសនាផ្លូវការរបស់ប្រទេសខ្មែរ ។

ព្រោះតែព្រះអង្គស្នេហាទំនឹងគោរព ជាតិ សាសនា មហាក្សត្រនេះហើយ ឃានជាទ្រង់សុំប្តូរព្រះជន្មចំពេញព្រះរាជបេសកកម្ម តាមការឯក

ពាក្យបរិបូណ៌ដោយភ្លាហានខ្លាំងដោយសន្តិវិធី ដូនប្រទេសជាតិមាតុភូមិ ដោយមិនខ្លាំព្រះវិតក្កដល់ការនឿយហត់ ដូចយើងបានដឹងឮឃើញ ច្បាស់ជាក់ច្បាស់គ្រានេះ ឲ្យប្រទេសជាតិបានឧត្តមភាពឯកពាក្យសម្បូណ៌ ដូចបុរាណសម័យ រហូតដល់កល្បាវសាន ។

ព្រះពាក្យណីយកិច្ចទាំងនេះ ត្រូវបានតំកុកក្នុងប្រវត្តិសាស្ត្ររបស់ ប្រទេសកម្ពុជាថាជាកល្យាណកិច្ចប្រសើរវៃក្រៃលែង បណ្តាលឲ្យប្រជាជន រួមជាតិ សាសនា មហាក្សត្រជាមួយព្រះអង្គ ស្នេហាស្វាមីភក្តីសក្ការៈ គោរពព្រះអង្គជាទីបំផុត ទាំងគោរពតាមផែនការព្រះអង្គដែលសន្តតនាមថា "ផែនការព្រះសីហនុ" ដោយរាមគ្គិភាពដ៏ភ្លាហាន ដូចខ្មែរបុរាណ សម័យព្រៃឯនាយ ។

មួយទៀត ដែលព្រះប្រិយមហាក្សត្រយេីង ព្រះអង្គបាន ទទួលការស្នេហា - សក្ការៈ - គោរព អំពីប្រជាជនរួមជាតិដូចថ្ងៃនេះ អាស្រ័យដោយភាតរភាពរវាងជាតិ - សាសនា - មហាក្សត្រ ដែល ប្រទេសខ្មែរធ្លាប់មានជាបវេណីអំពីបុរាណរៀងមកផង, ដោយព្រះអង្គ បានបំពេញនូវភាតរភាពនោះ ឲ្យរឹងតែតែខ្លាំងក្លាថែមទ្បើងផង ។

អ្នកស្រី ធាំ-ធុំ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែពីទស្សនាវដ្តី « ហ្រ្វង់ . អាស៊ី » ខែឧសភា ឆ្នាំ ១៩៥៣

កន្លងអតីតកាលដ៏អង្វែងឆ្ងាំទៅហើយ មានព្រះមហាក្សត្រ ១ ព្រះអង្គ ទ្រង់ព្រះនាម ព្រះបាទព្រហ្មទត្ត សោយរាជ្យនៅនគរពារាណសី ជា ស្តេចមហាអំណាចក្នុងលោក ។ ព្រះបរមពោធិសត្វទេវបុត្រយាងចាកតុសិតសួគ៌ចូលមកចាប់បដិសន្ធិ ក្នុងផ្ទៃនៃអគ្គមហេសីនៃព្រះបាទព្រហ្មទត្ត ។ លុះគ្រប់ទសមាស ព្រះពោធិសត្វប្រសូតចាកផ្ទៃព្រះមាតាដោយសួស្តី ។ ក្នុងថ្ងៃទី ៣ អំពីថ្ងៃប្រសូតនោះ ព្រះមាតាបិតាទ្រង់ព្រះរាជទានធ្វើនាមគហណាមង្គលថ្វាយព្រះនាមព្រះពោធិសត្វថា ព្រហ្មទត្តកុមារ ។ ព្រះពោធិសត្វលុះចំរើនវ័យវុឌ្ឍនាការ បានព្រះជន្ម ១៦ វស្សា ទ្រង់យាងទៅរៀនសិល្បទ្រង់វិទ្យាសាស្ត្រគ្រប់យ៉ាង ឯនគរតក្កសិលា ។

កាលព្រះពោធិសត្វរៀនចប់សព្វសិល្បសាស្ត្រហើយ ក៏ស្តេចយាងត្រឡប់មកកាន់ប្រទេសជាមាតុភូមិវិញ ។ លុះព្រះរាជបិតាព្រះអង្គទ្រង់ទីវង្គតទៅ ព្រះពោធិសត្វទ្រង់គង់លើសេតច្ឆត្រ សោយរាជសម្បត្តិជាដំណអំពីព្រះរាជបិតា គេថ្វាយព្រះនាមថាព្រះបាទព្រហ្មទត្ត ។ ចាប់តាំងអំពីព្រះអង្គសោយរាជ្យមក ទ្រង់ប្រព្រឹត្តទសពិធរាជធម៌ ទ្រង់មានតេជានុភាពច្រើន ទ្រង់ចាត់ចែងតុលាការ ឆ្ងាយចាកអគតិទាំងពួង ។ ដោយសារ

តែព្រះបរមពោធិសត្វគ្រប់គ្រងផែនដីដោយសីលធម៌ នាម៉ឺនមុខមន្ត្រីចាំង-ឡាយក៏តាំងនៅក្នុងសុចរិតយុត្តិធម៌ ក្នុងការនិច្ឆ័យនៃកិច្ចការចាំងពួង ។

សេចក្តីវិវាទ រាជអាមាត្យចាំងឡាយនិច្ឆ័យតាមលំអាននៃសុចរិត, គ្មានវិវាទដែលប្រព្រឹត្តអំពើល្មើស ក៏នាសសាបសូន្យ លែងមានក្នុងព្រះនគរ ។ ការច្រូលច្របល់អំពីកិត្តិក៏ស្ងាត់សូន្យឈឹង ។ រាល់ថ្ងៃនាម៉ឺនមុខមន្ត្រីចាំងអស់មកប្រជុំនៅក្រសួងតុលាការ តែឥស្សរជនចាំងនោះ ឥតបានឃើញគូវក្តីដល់ម្នាក់មកប្តឹងផ្តល់ទៀតទេ ហេតុនេះ សាលាក្រសួងតុលាការក៏គេបិទទ្វារអស់ ។

ខណៈនោះ ព្រះបរមពោធិសត្វទ្រង់ព្រះតំរិះថា "អាត្មាអញសោយរាជ្យ ប្រកបដោយទសពិធរាជធម៌ហើយ បានជាគ្មាននរណាម្នាក់មកប្តឹងឲ្យជំនុំដំរះសោះ, ដំណោះផ្សេងៗក៏រលាយបាត់បង់អស់, ក្រសួងតុលាការក៏បិទទ្វារសាលា ដោយគ្មានការធ្វើ, សព្វថ្ងៃនេះ នៅសល់តែការនិច្ឆ័យខ្លួនអាត្មាអញប៉ុណ្ណោះទេ បើអាត្មាអញនៅប្រព្រឹត្តទាស់ខុសត្រង់បទណា នោះត្រូវតែអញនិច្ឆ័យត្រង់បទនោះឲ្យជ្រះស្រឡះចេញ ហើយប្រកបដីវភាពឲ្យសមគៅតាមគុណធម៌" ។

ព្រះបរមពោធិសត្វលុះទ្រង់ព្រះរាជតំរិះដូច្នោះហើយ ទើបទ្រង់ត្រាស់សួរទៅរាជមន្ត្រីចាំងអស់ថា "អស់លោកចាំងឡាយ លោកណាបានឃើញកំហុសខ្ញុំដែរ?" ។ រាជមន្ត្រីចាំងឡាយបានក្រាបទូលតាម

ការណ៍ពិតរឿងខ្លួន តែសេចក្តីក្រាបទូលទាំងនោះ សុទ្ធតែសេចក្តីសរសើរព្រះអង្គតែម្យ៉ាង ។ ព្រះមហាក្សត្រីយ៍ទ្រង់ព្រះតម្រិះទៀតថា "កយាគតិធ្វើឲ្យឥស្សរជនទាំងនេះ មិនហ៊ានគោលពីកំហុសអញទេដឹង ទើបនាំគ្នាសរសើរអញទៅវិញ" ។ ព្រះរាជាទ្រង់សន្និដ្ឋានថា "ព្រះរាជ-ប្អូននេះ ទុកជាមិនបានលួងលៃឡើយ" ទើបទ្រង់សួរទៅបណ្តាក្រសួតទៅទៀត ។ ចាប់តាំងពីជនានុជនដែលនៅក្នុងព្រះបរមរាជវាំង នៅទីក្រុង រហូតដល់និគមជនបទ ក៏ឆ្លើយតបព្រះរាជសំនួរតាមដោយន័យដដែល ។ សូម្បីតែជនដែលនៅជិតទ្វារក្រុងទាំង ៤ ក៏គ្មាននរណាម្នាក់ពោលអំពីចរិយាមិនប្រពៃរបស់ព្រះអង្គដែរ ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ឮប្បាសតែអំនួតចំពោះព្រះរាជចរិយាដែលប្រាសចាកទូវដំនៀលផ្សេងៗ ទើបទ្រង់ព្រះតំរិះថា "បើដូច្នោះ គួរតែអញចេញទៅសួរបណ្តាជនក្នុងស្រុកវែងទៀត" ។

ព្រះបាទព្រហ្មទត្តទ្រង់ប្រគល់ការផែនដីទៅព្រះរាជវង្សាគតិបាល រួចស្តេចយាងគង់លើព្រះទីនាំងរាជរថ ជាមួយនឹងនាយសារថីម្នាក់ ។ ព្រះរាជាក្លែងកេរព្រះអង្គជាជនធម្មតា ទ្រង់យាងចេញពីទីក្រុងទៅសួរអ្នកនៅក្រៅទីក្រុង រហូតដល់ប្រទេសជិតខាង តែគ្មានឮពាក្យអ្នកណាថាព្រះអង្គមានកំហុសសោះ ។ ព្រះបាទព្រហ្មទត្ត លុះឮតែពាក្យសរសើរព្រះអង្គដូច្នោះ ក៏យាងត្រឡប់ចូលព្រះនគរវិញ ទ្រង់ស្តេចមកតាមមាគ៌ាដ៏ធំមួយ ។

ក្នុងសម័យនោះ ព្រះមហាក្សត្រិយ៍ប្រទេសកោសល ព្រះនាមព្រះបាទមល្លិកៈ (Mallika) សោយរាជ្យដោយសុចរិតយុត្តិធម៌ ។ ព្រះរាជអគ្គមហេសីរបស់ព្រះអង្គនោះ ក៏ទ្រង់សព្វព្រះរាជហឫទ័យចង់ជ្រាបនូវកំហុសព្រះអង្គដែរ ។ ព្រះបាទមល្លិកៈទ្រង់ត្រាស់សួរបណ្តាជនទៅក្នុងព្រះបរមរាជវាំងរហូតដល់ស្រុកស្រែចំការ, តែពាក្យក្រាបទូលនៃជនទាំងនោះគ្មានសេចក្តីតាមព្រះរាជបំណងឡើយ ទើបទ្រង់យាងដោយរាជរថមកដល់ផ្លូវដែលព្រះបាទព្រហ្មទត្ត ទ្រង់ស្តេចយាងត្រឡប់មកនោះ ។ ព្រះមហាក្សត្រទាំងពីរព្រះអង្គជួបគ្នាត្រង់ផ្លូវចង្អៀតមួយ នាំឲ្យរាជរថទាំងពីរចៀសគ្នាមិនរួច ។

ទើបនោះ នាយសារថីខាងព្រះបាទមល្លិកៈ និយាយទៅកាន់នាយសារថីខាងព្រះពោធិសត្វថា "អ្នកចូរបររថទៅអ្នក ចុះយកចេញពីផ្លូវនេះទៅ" ។ នាយសារថីនៃព្រះពោធិសត្វតបវិញថា "ខ្ញុំមិនចុះទេព្រោះព្រះចៅផែនដីក្រុងពារាណសីព្រះនាមព្រហ្មទត្ត ប្រថាប់ក្នុងរថនេះនេះ, ត្រូវអ្នកឯងចុះយករថទៅវិញ" ។ សារថីព្រះបាទមល្លិកៈតបវិញថា "ខ្ញុំក៏មិនត្រូវចុះយករថទេដែរ ព្រោះព្រះមហាក្សត្រសោយរាជ្យនៅនគរកោសល ព្រះនាមព្រះបាទមល្លិកៈ ទ្រង់គង់ក្នុងរថនេះ ដូច្នេះចូរអ្នកចុះយករថទៅចេញទៅ ទុកផ្លូវថ្វាយព្រះករុណាជាអម្ចាស់របស់ខ្ញុំវិញ" ។

នាយសារថីនៃព្រះបាទព្រហ្មទត្តគិតថា "ក្នុងរថនេះខាងណោះពិតជាមានព្រះមហាក្សត្រប្រថាប់មែន ចុះអញត្រូវគិតធ្វើដូចម្តេច" ។ លំដាប់

តមក នាយសារថីនោះគិតឃើញថា "មានតែទុជ្ឈាយមួយទេ គឺអញត្រូវ
សួរពីព្រះជន្មវស្សានៃស្តេចនោះ បើព្រះពាជាអង្គណាមានព្រះជន្មតិចជាង
នោះត្រូវឲ្យព្រះពាជរថនៃព្រះពាជាអង្គនោះថយចេញ ទុកផ្លូវឲ្យព្រះពាជរថ
នៃព្រះពាជាដែលមានព្រះជន្មច្រើនបរទៅ" ។ នាយសារថីនៃព្រះពោធិ-
សត្វ កាលប្តេជ្ញាដូច្នេះហើយ ក៏សួរពីព្រះជន្មាយុនៃព្រះចុទមល្លិក:
ប៉ុន្តែព្រះពាជាទាំងពីរព្រះអង្គមានព្រះជន្មដំណាលគ្នា ។ នាយសារថីនៃ
ព្រះពោធិសត្វ យកវិញ្ញាទុភាព ព្រះពាជសមវត្តិព្រះកិត្តិនាម ទីឆ័ន្ទវង្សត្រកូល
នៃព្រះពាជាទាំងពីរព្រះអង្គមកធៀបគ្នាទៀត ក៏ឃើញស្មើគ្នា យក
ទំហំផែនដីក្នុងព្រះពាជអាណាចក្រនៃស្តេចទាំងពីរព្រះអង្គ មកប្រមាណ
មើលទៀត ក៏ឃើញមានទំហំ ៣០០ យោជន៍ដូចគ្នា ។

នាយសារថីនៃព្រះចុទព្រហ្មទត្តប្តេជ្ញាទៀតថា "ចូរយើងទុកផ្លូវ
ថ្វាយព្រះពាជាអង្គណាដែលមានគុណធម៌ក្នុងព្រះអង្គ ហេតុនេះអ្នកចូរ
ជ្រាប់ខ្ញុំមក តើព្រះពាជារបស់អ្នកឯង មានគុណធម៌យ៉ាងណាខ្លះ"? ។

នាយសារថីព្រះចុទមល្លិក: ក៏សូត្រពាក្យកាព្យថ្លែងនូវគុណ
ដែលស្មានថាជាគុណធម៌របស់ព្រះពាជានៃខ្លួន ដូច្នេះថា:

អ្នកក្រែជខ្លាំង ស្តេចតតាំង ដោយក្រែជត,
អ្នកឥតធម៌ ចិត្តមិនល្អ ទ្រង់មិនល្អតប,
អ្នកកំណាញ់ ស្តេចផ្តាលផ្តាញ់ ដោយកំណាញ់ស្រប,
ទ្រង់ប្រកប ពាក្យមិនពិត ផ្តាញ់មុសា ។

ខណៈនោះ នាយសារថីព្រះពោធិសត្វក៏ស្រែកយ៉ាងខ្លាំងៗថា «នែអ្នក! អំបាញ់មិញនេះ អ្នកពោលអំពីគុណធម៌របស់ព្រះពាជានៃអ្នកឬ?» ។ – «បាទ» ។ – បើចរិយាបែបនេះ ហៅថា គុណធម៌ ចុះកំហុសស្តេចរបស់អ្នកឯងយ៉ាងណាទៅវិញ?» ។ សារថីព្រះបាទមល្លិកៈពោលតបថា «បើចរិយានេះ ទុកជាខុស, ចុះកុងរឿងនេះ តើព្រះពាជានៃអ្នកប្រព្រឹត្តចរិយាបែបណា ដែលចាត់ថាជាគុណធម៌?» ។

នាយសារថីនៃព្រះបាទព្រហ្មទត្តឆ្លើយតបថា «ចូរអ្នកចាំស្តាប់ចុះ ខ្ញុំនឹងថ្លែងអំពីគុណធម៌របស់ស្តេចខ្ញុំឥឡូវនេះ» រួចហើយក៏សូត្រនូវភាសិតថា :

អ្នកស្រែកខ្លាំង ស្តេចតតាំង ដោយមិនស្រែកឥត,
អ្នកឥតធម៌ ចិត្តមិនល្អ ទ្រង់ល្អតប,
អ្នកកំណាញ់ ស្តេចផ្តាលផ្តាញ់ ដោយមិនកំណាញ់ស្រេប,
ទ្រង់ប្រកប ពាក្យជ័ពិត ផ្តាញ់មុសា ។

ព្រះបាទមល្លិក ឮដំណាយសារថីរបស់ព្រះអង្គ លុះបានស្តាប់នូវភាសិតជាសុភាសិតនេះហើយ ក៏ចុះពីរទេះ ដោះសេះចេញ ហើយអូសរទេះថយ ទុកផ្លូវថ្វាយព្រះបាទព្រហ្មទត្តឲ្យស្តេចយាងទៅ ។

ចប់

ព្រះមហាឧត្តមវិជ្ជា ផលញ្ញោណោ ប៊ុង-ប៉ម

អាចារ្យសាលោងាលីវង់ វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌានុរក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តមក)

ការចេះធ្វើជានាយចៅហ្វាយលើខ្លួនឯងនេះ មានការចេះបង្ក្រាប់បញ្ជាខ្លួនឯង, ការចេះទូន្មានខ្លួនឯង នឹងការចេះបង្ហាត់បង្វឹកខ្លួនឯងជាលក្ខណៈ: មានការស្គាល់ខុស ត្រូវ អាក្រក់-ល្អ រៀបចាកការដែលគួរវៀរ ប្រព្រឹត្តការដែលគួរប្រព្រឹត្ត នឹងរៀបចាកអាក្រក់ប្រព្រឹត្តល្អបានខ្លួនឯង នេះជាគោលនៃការចេះគ្រប់គ្រងខ្លួនឯង ។ អ្នកដែលស្គាល់ខុស ត្រូវ អាក្រក់ ល្អ ដោយវិធីបង្ក្រាប់បញ្ជាខ្លួនឯង ទូន្មានខ្លួនឯង, នឹងហ្វឹកហ្វឺនខ្លួនឯង នេះចាត់ថាចេះគ្រប់គ្រងខ្លួនឯងបាន ។ អ្នកគ្រប់គ្រងខ្លួនឯងបាន មិនប្រព្រឹត្តអាក្រក់ថោកទាបយ៉ាងនេះ រមែងប្រព្រឹត្តល្អគ្រប់វិស័យ មិនប្រែពីកាយដែលខ្លួនបានមកដោយកម្រនោះឲ្យឆើតឆាយ ។ គឺធ្វើតែតាមឆន្ទៈដែលជាសុចរិត និយាយសំដីសុចរិត នឹងគិតរឿងដែលជាសុចរិត មិនគិតរៀបរៃ ឬលួងបញ្ឆោតអ្នកណា សូម្បីសេពគប់ដំណើរភក្តីភាពក្នុងសេចក្តីយុត្តិធម៌ មិនយកគ្រៀបមិត្តភក្តី ប្រព្រឹត្តខ្លួនជាមនុស្សពិត មនុស្សត្រង់

មនុស្សយុត្តិធម៌ ឬខឹងត្រង់ជាងិយ ។ អ្នកដែលចេះបង្អាប់បញ្ជាខ្លួនខ្លួនឯង បង្ហាត់ខ្លួន ឱ្យជាអ្នកមានទឹកចិត្តល្អរៀបរយស្គាល់ខុស - ត្រូវ-អាក្រក់ ល្អ - ខាប ខុស ដូច្នេះ សូម្បីនៅក្នុងការគ្រប់គ្រងរបស់អ្នកដទៃ ក៏គង់តែសូប់សៀមរៀបរយជារបៀបរបបសា, មិនមានការចលាចលក្រវល់ក្រវាយ មិនមានការភ្ញាក់ផ្អើលស្ទុតចិត្តរហូតដល់កើតហេតុ, មិនមានការញាប់ញ័រដោយអណ្តាតរបស់មនុស្សព្រ្យោះញើចាក់រុកក្នុងផ្លូវខុស ទឹងមិនមានសេចក្តីរំកើបចិត្តចំពោះហេតុខាងក្រៅបន្តិចបន្តួចឡើយ ។

អ្នកមានការស្គាល់ខុស - ត្រូវនោះ សូម្បីទឹងប្រព្រឹត្តល្មើសដោយកាយ - វាចា - ចិត្ត, ដើលតាយចេសប្រមៀសចំពោះអំណាចទឹងបុគ្គលដោយមិនមានស្មារតីឃុំគ្រង ឬប្រព្រឹត្តខុសឬឆ្គងម្តាចដែលក្រឹមត្រូវដោយមានចេតនា ឬមិនមានចេតនា កាលបានដឹងថាខ្លួនខុសហើយ ក៏សម្តែងសេចក្តីក្តៅក្រហាយ អង្វរការសូមលន់តួឧទ្ទេសសារគាពាសតែម្តង មិនបាច់នរណាបន្ទុំ ដែលចាត់ថាជាផ្លូវនាំឱ្យបានឧទ្ទេសសេចក្តីកុណាអត់ទុនចំពោះកំហុសតាមសាសនាទោស ឬកាលមានអ្នកដទៃធ្វើខុសចំពោះខ្លួន ក៏ឱ្យអភ័យ មិនប្រកាន់ទោស ដែលចាត់ថាជាការកំចាត់បង់សេចក្តីខុសឱ្យសាបសូន្យមិនគិតយកឈ្នះ តែតាមអំពើចិត្តដែលចាត់ជាគ្រឿងបង្អាកទោសទឹងសេចក្តីខុសឱ្យចំរើនតែក្រៃលែងឡើង ។

ពិតមែន ការព្រមទទួលលើកទោសឱ្យដល់អ្នកដែលមានកំហុសចំពោះខ្លួនយើង ឈ្មោះថាយើងធ្វើសេចក្តីល្អយ៉ាងក្រៃលែងចំពោះគេ

ជាឧបាយឲ្យគេធ្វើសេចក្តីល្អតបវិញ នឹងជាឧបាយធ្វើឲ្យអ្នកដែលខាស់ចិត្តទៅជាមិត្តនឹងគ្នាបាន ចាត់ថាជាសេចក្តីល្អចំពោះខ្លួនយើងយ៉ាងខ្លាំងគុណ ។ បើយើងនាំគ្នាស្គាល់ខុស-ត្រូវ អាក្រក់-ល្អដូចគ្នាទាំងអស់ហើយ មុខជាមិនមានការធ្វើទោសចំពោះគ្នានឹងគ្នាឡើយ ព្រោះអ្នកទាំងសងខាង មានសេចក្តីករុណានឹងលើកទោសឲ្យដល់គ្នានឹងគ្នាឯង ។ ឯការត្រមៃឲ្លួសសារគោពកំហុស នឹងការអត់ទោសចំពោះគ្នានោះ ចាត់ថាជាការធ្វើទោសនឹងការលើកលែងទោសចំពោះខ្លួនដោយខ្លួនឯង ។

អ្នកមិនស្គាល់ខុស-ត្រូវ មិនទាន់ឈ្មោះថា ជាមនុស្សចេះគ្រប់គ្រងខ្លួនឯងឡើយ ព្រោះបណ្តាយឲ្យទំនើយអាក្រក់ចូលមកជាប់ភាពជាធំក្នុងខ្លួនឯងបាន ធ្វើខ្លួនឯងឲ្យធ្លាក់ទៅក្នុងអំណាចទាំងបាប គឺលោភ, ក្រោធ, វង្វេង, ឥច្ឆា, ឫស្យា, ញ៉ាចាទ, ខ្ជាចក្រែង នឹងការញាប់ញ័រចិត្តចំពោះហេតុកើតផ្សេង។ មានអំណាចទាំងការការពារខ្លួនតិចតួចតូចតាបណាស់មិនល្មមនឹងគ្រប់គ្រងខ្លួនឯងដោយហេតុផលបានឡើយ រមែងបរាជ័យធ្លាក់ខ្លួនទៅជាឈ្លើយ របស់សេចក្តីអាក្រក់យ៉ាងងាយ។ ហើយនឹងត្រូវខំលាក់ខ្លួនចុះទៅកាន់សេចក្តីវង្វេងវិលវល់ខ្សោយកម្លាំង មានចិត្តរៀបទៅរៀបមកតាមអំណាចទាំងតាប ចាត់ថាជាមនុស្សបណ្តាយខ្លួនឯងឲ្យល្ងង់ខ្លៅថោកតាប ប្រកបការងារឡើងតាមបង្គាប់សេចក្តីថោកតាបគ្រប់យ៉ាង ចូលចិត្តតែក្នុងការខំលាក់បំផ្ទាញមនុស្សដទៃ ដើម្បីប្រយោជន៍សុខរបស់ខ្លួនឯង ។

ថ្ងៃនេះ បើប្រសិនណាជាលោក-អ្នកគ្រប់គ្រងខ្លួនឯងបាន លោក-អ្នកក៏អាចនឹងបានទទួលសុភមង្គល មានៈស្មី, មានពាសី នឹងមានប្រជាឈ្មោសរាងវៃឡើងជាងកាល ៥ ឆ្នាំដែលកន្លងមកហើយ ។ ពិតមែនកាលបើយើងមិនអាចបង្គាប់បញ្ជាខ្លួនឯងបានហើយ សូម្បីមនុស្សដែលយើងមិនអាចនឹងបង្គាប់បញ្ជាឲ្យនៅក្នុងសំដីរបស់យើងបានដែរ សូម្បីនឹងបង្គាប់បញ្ជា ដោយឲ្យរបស់ជាទីគាប់ចិត្ត, ដោយសេចក្តីកុណា, ដោយប្រតិបត្តិល្អតប, ដោយទទួលធ្វើការឲ្យបានយ៉ាងល្អបំផុត, ដោយនីតិធម៌ កំបង្គាប់បញ្ជាមិនបានតាំងអស់ ។ ចំណែកខ្វះសារនៃការគ្រប់គ្រងខ្លួនឯងមានតែម្យ៉ាង គឺនឹងខ្លួនក្នុងការដឹងខុស-ត្រូវ មិនធ្វើអ្វីតាមតែសេចក្តីគាប់ចិត្ត មិនទទួលរបស់អ្វីអំពីនរណាមួយ បើមិនមានហេតុផលល្មមសមគួរ, មិនធ្វើ, មិននិយាយ, មិនគិតរឿងអ្វីៗ ដែលមិនសមហេតុ សមផល ។ ពិតមែនហើយ យើងនឹងធ្វើអ្វីក៏ធ្វើបានតាមចិត្ត តែត្រូវប្រយ័ត្នកុំធ្វើតែតាមគាប់ចិត្តកន្លងផ្លូវខុស ដែលជាហេតុជំរុញខ្លួនឯងឲ្យជ្រាក់ទៅកន្លែងជ្រោះជ្រៃ គួរដំណើរខ្លួនតាមហេតុផលវៀរចោកការធ្វើតាមគាប់ចិត្ត កន្លងរបស់ដែលគ្មានហេតុផល នឹងធ្វើតាមគាប់ចិត្តតែកន្លងវត្ថុដែលមានហេតុមានផល ដោយការដឹងខុស-ត្រូវរបស់ខ្លួនឯង ។

អ្នកដែលត្រូវគ្រប់គ្រងខ្លួនឯងនោះ មិនត្រូវទៅតៀមសុភដើម្បីបរិភោគឲ្យស្រែរឹងរហួតដល់ទប់ស្មារតីមិនជាប់ មិនត្រូវធ្វើអត្តនិធិបាតកម្ម

ដោយបាញ់ខ្លួនសម្លាប់ ឬចង់តសម្លាប់ ឬក៏លេបថ្នាំសម្លាប់ឡើយ ត្រូវ
តែខំដោយការបណ្តុះនិស្ស័យបង្គាប់បញ្ជាខ្លួន. ខ្លួនខ្លួនទើបបង្គាប់ខ្លួន
ឯងឲ្យនៅក្នុងអំណាចនៃការដឹងខុសត្រូវរបស់ខ្លួនឯង. ព្យាយាមធ្វើចិត្ត
ឲ្យរឹងប៉ឹង លើកខ្លួនឡើងធ្វើជានាយចៅហ្វាយលើហេតុការណ៍ ដែល
ចូលមកឡុកឡឺយ នាំឲ្យកើតសេចក្តីច្រែបច្រួលកង្វល់ សៅហ្មង ឬរួញរា
ដុំទិសនោះឡើង ត្រូវគ្រប់គ្រងខ្លួនឲ្យចេះពិចារណាឃើញច្បាស់ដល់អ្នក ឬ
គ្រប់យ៉ាង ឲ្យស្អប់ខ្ពើមគំនិតក្នុងផ្លូវដែលមិនល្អ ឲ្យជ្រាស់ចិត្តមកគិតតែរក
ដែលចំរើនវិញវឌ្ឍន៍ធំរបស់ដែលល្អ ទើបឲ្យចេះស្គាល់លំដាប់ការងារ.
ត្រូវចូលទៅពិនិត្យមើលក្នុងកាលដែលធ្វើការងារណាមួយ មិននាំរឿង
ដទៃចូលមកច្របាក់ច្របូស ត្រូវព្យាយាមៈឈ្លាតធ្វើតែការងារដែល
កំពុងធ្វើឲ្យសម្រេច ។

ការគ្រប់គ្រងខ្លួនឯង រមែងត្រូវការសេចក្តីជាប់ ដូច្នេះ ត្រូវទម្លាប់
ខ្លួនឲ្យចេះរម្ងាប់សេចក្តីអាក្រក់ដែលមាននៅក្នុងខ្លួន ទើបហាមឃាត់ការ
ពារក្សាខ្លួនកុំឲ្យភ្លាត់ទៅកាន់សេចក្តីអាក្រក់ ដែលសេចក្តីឆ្ងួសប្រហែស
ឬសេចក្តីរេរង់នាំកូលមក សូម្បីគ្រាដំបូងក៏ត្រូវទប់ខ្លួន ត្រូវទប់ស
សេចក្តីគិតចិត្ត គិតកាយ លំបាកធ្ងន់ក៏ដោយ កាលៈបើព្យាយាមដំនរធ្វើ
ជាប់តគ្នាទៅរហូតដល់ចាត់ផ្តត់ហើយ ក៏ស្រួចនឹងងាយដើរឆ្ពោះស្រួលបាន ។ ឯការគ្រប់គ្រងខ្លួនឯងដែលងាយស្រួលនោះ មិនត្រូវខំប្រឹង
សង្គ្រោះតែខ្លួនឯងឲ្យច្រើនពេកទេ ។ ការធ្វាប់នេះពេលថាជាទបការៈ

ជាធំ របស់សេចក្តីប្រព្រឹត្តិខ្លួនៗ តែត្រូវប្រព្រឹត្តខ្លួនឲ្យផ្ទាប់កន្លងវត្តដែលល្អ កុំបណ្តោយឲ្យខ្លួនមានសេចក្តីផ្ទាប់កន្លងវត្តដែលអាក្រក់ឡើយ ។ ព្រោះសេចក្តីផ្ទាប់នោះ បើជាឧបការៈកន្លងសេចក្តីល្អ ហាក់ដូចជាមានព្រះមកប្រោស, បើជាឧបការៈកន្លងផ្លូវអាក្រក់វិញ ក៏ដូចជាមានមារជិះជមកផ្តាញ់ ។ លោកអ្នកចូលទំលាប់ខ្លួនតែកន្លងវត្តដែលល្អដែលទុកដូចជាព្រះមកប្រោស កុំទម្លាប់ខ្លួនកន្លងវត្តដ៏អាក្រក់ដែលទុកដូចជាមារជិះជមកផ្តាញ់ឡើយ ។

តាមពិត អ្នកចង់ចាយកឈ្នះសេចក្តីអាក្រក់ បើគ្មានការគ្រប់គ្រងប្តូរផ្ទាប់ខ្លួនឯងឲ្យបានបន្តាំដំបូងទេ ក៏មិនមានឧកាសនឹងយកឈ្នះសេចក្តីអាក្រក់បានដែរ, នេះមិនមែនជារឿងក្បាក់ចិត្តទេ គឺជារឿងប្រែប្រួលខ្លួន ។ មនុស្សណាដែលដម្រុញខ្លួនឡើងទៅទៅក្នុងឋានៈជាន់ខ្ពស់ មនុស្សនោះគឺជាអ្នកប្រែខ្លួន ដើម្បីឋានៈនោះដោយការគ្រប់គ្រងខ្លួនឯង, ដោយការសិក្សា ទន្ទឹងដោយការប្រតិបត្តិទំលាប់ខ្លួនមកជាយូរឆ្នាំហើយ ។ ដូចេះបូរប្រែងប្រៀបខ្លួនឲ្យស្រេច ដើម្បីធ្វើតាមច្បាប់នេះគឺបូរធ្វើ, និយាយតិតែកន្លងវត្តដែលមានហេតុផល ដែលបង្ហូលបង្ហាញថាជាសេចក្តីល្អចំពោះខ្លួនទើមមនុស្សជវៃ ទន្ទឹងប្តូរឱ្យាតផ្លាស់ពីធ្លីនៃការធ្វើ, ការនិយាយ, ការគិត របស់លោកអ្នកទៅតាមដំណឹង (សេចក្តីដឹង) កន្លងកាលដែលដឹងថាខុស ប្តូរទៅតៈមមតិមនុស្សជវៃ ដែលអាចបង្ហូលកំហុសនៃវិធីការរបស់លោកអ្នកបាន ។

(មានត)

កណ្ឌទី ១៧

ឧកញ៉ាវិបុលរាជសេនា ង្វៃ-កង ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ធំងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

កាលចូតូបានស្រុកឈើដីរហើយ ក៏តាំងស្តាប់ដំណឹងនឹងប្រៀបប្រែងសេនាគាហានឲ្យមានកម្លាំងត្រមត្រៀងគ្នា រួចបង្គាប់គាហានថា យើងត្រូវលើកទ័ពទៅតាមចាប់លីចោ"ឯស្រុកហែហ្វីទៀត ។ ធៀយ"កទ័ពក្បត់ឆ្លើយថា ដែលមហាឧបរាជនឹងលើកទៅវាយស្រុកហែហ្វីគ្រានេះ ខ្ញុំយល់ថាលីចោ"នោះប្រៀបដូចសុនខាល់ច្រក ក៏នឹងស៊ូច្បាំងគ្រាតែអស់ដំរេះនឹងកម្លាំង ប្រសិនលីចោ"រត់ចេញទៅបាន មុខជានឹងទៅរកអួនសុតបើលីចោ"នឹងអួនសុតគប់គិតគ្នាជាពួកមួយហើយ ក៏នឹងបានជាកងទ័ពធំបើដូច្នេះ សុំឲ្យមហាឧបរាជចាត់គាហានដែលមានថ្វីដៃ លើកទ័ពមួយ

បែកទៅចាំស្កាត់ផ្លូវទៅខាងមាត់កំពង់ស្រុកហួយណាំ បើលីៈចា"ទឹងត់ទៅ
រកអួនសុតវិលណា គង់តម្រង់ត្រង់ទៅលើទីនោះយើងនឹងបានស្កាត់ទុក
កុំឲ្យចេញទៅបាន ប្រសិនបើអួនសុតនឹងលើកទ័ពមកដួយលីចៅ"វិញក៏
គង់នឹងមកមិនរួច មួយយ៉ា"ងទៀត ស៊ុនគួន, អ៊ុនឡេ, ងីខុន, សៀងហ៊ូ
ដែលជាមេចោរបែកទ័ពពីគាន់សៀគួនទៅនោះ ក៏មិនបានដឹងច្បាស់ជា
ទៅតាំងនៅតំបន់ណា ខ្លាចក្រែងវាលើកមកដួយលីចៅ" ដូច្នេះសុំឲ្យ
មហាឧបាជលើកទៅកំចាត់ពួកចោរចេញសិន ។

ចូឆួថា យើងនឹងឲ្យឡៅតាទៅចាំស្កាត់អួនសុតនៅកំពង់ហួយណាំ
តាមផ្លូវដែលពួកចោរនឹងលើកគ្នាមកដួយលីចៅ"នោះ អ្នកកុំវិតក្កឡើយ
យើងនឹងទទួលធានាគិតរឿងនេះឲ្យបានស្រួល ។

ឡៅតាបានឮចូឆួថាដូច្នោះក៏ទទួលថា ដែលនឹងទៅចាំស្កាត់លីចៅ"
នឹងអ្នួនសុត ខ្ញុំនឹងសុំទទួលយកអាសា ។ ចូឆួក៏ទទួលយល់ព្រម ។
លុះវេលាព្រឹកឡើង ឡៅតាក៏ចាត់ឲ្យបុត្តនឹងកាន់យុ"ងទៅរក្សាគ្រប់គ្រួ,
ខ្លួនឡៅតា, កូនអ៊ិ. តៀវហ៊ុយ ស៊ុនឧខ្ញែន ក៏លើកទាហានទៅតាំងទ័ពទៅ
កំពង់ស្រុកហួយណាំ, ឯចូឆួក៏លើកទ័ពទៅវាយស្រុកហៃហ្វឺ ។

កាលលីចៅ"ទៅតាំងទ័ពទៅក្នុងស្រុកហៃហ្វឺនោះ ស្បៀងអាហារក៏
បរិបូណ៌គ្រប់គ្រាន់ គូស្នាមក្លោះផ្ទុំវិញស្រុកក៏ជ្រៅទឹកដក់ពេញ កាលដឹង
ថាចូឆួលើកទ័ពតាមមក លីចៅ"មិនបានគិតនឹងចេញតច្បាំងនឹងចូឆួគ្រាន់តែ

ច្រើនប្រៀបរៀបសេនាឥហានទើនគ្រឿងសស្ត្រាវុធ ឡើងយាមលើសើន
បន្តាយជាមាំមួន ។ តាន់កុងនិយាយទើលប៉ោ៉ាថា ឥឡូវចូរឆ្លើកទ័ព
មក មិនទាន់ឃានទីស្នាក់ជាមាំមួនទេ ហេតុម្តេចក៏លោកនៅស្ងៀមមិន
ចេញទៅច្បាំងនឹងចូរឆ្ល ចើបង្អង់ឲ្យចូរឆ្លតាំងចន្តាយជាមាំមួនហើយ យើង
ក៏ធ្វើការលំបាក ។ លីប៉ោ៉ាថា ៖យើងធ្លើសង្រ្គាមចាញ់ប្រៀបចូរឆ្លច្រើនក្តារ
ហើយ គ្រានេះយើងត្រូវបង្អង់តាំងខ្លួនឲ្យខ្ជាប់ខ្ជួននៅក្នុងស្រុកសិន ចាំ
កាលណាចូរឆ្លលើកឥហានឆ្លងគ្លួចូលមកដល់ដើងកំពែង សឹមយើងចេញ
តទល់ គង់តែចូរឆ្លនឹងចាញ់ប្រៀបយើងជាក្រុកជ ។

កាលចូរឆ្លលើកទ័ពមកដល់ស្រុកហៃហ្វឺ ក៏តាំងទ័ពនៅជិតកំពែងស្រុក
ប្រហែល ១០សិន (៤០០ម.) ចូរឆ្លក៏ឡើងជិះសេះឆ្លងគ្លួចូលទៅដល់ដើង
កំពែង ហើយស្រែកហៅលីប៉ោ៉ាថា កាលគ្រាតាំងតុប្រែចិត្តក្បត់ផែនដី
អ្នកឯងរិះគិតនឹងសម្លាប់តាំងតុចេញ គ្រានោះ ឈ្មោះអ្នកឯងមានសេចក្តី
គាប់ប្រសើរល្អនឹងពជការជាច្រើន ឥឡូវអ្នកឯងត្រឡប់មកចូលតំនិតនឹង
អ្នកសុត ដែលជាមនុស្សក្បត់ផែនដីវិញ កិត្តិស័ព្ទក៏ជ្រុតជ្រាបទៅដល់ព្រះ
ស្រោតព្រះកាណីនៃព្រះចៅហ្វ៊ុនតេ ឃានជាទ្រង់ព្រះពិរោធត្រាស់ប្រើ
យើងឲ្យលើកទ័ពមក បើវេលានេះអ្នកឯងលះបង់មិនទៅចូលតំនិតនឹងអ្នក
សុតទេ គឺមានចិត្តសុចរិតត្រង់នឹងផែនដីវិញ ក៏ចូរប្រញាប់ចេញមករក
យើងដោយស្រួល យើងនឹងឃានដួយកែវគ្រាបពិតទូលព្រះចៅហ្វ៊ុនតេ

ឲ្យខ្ញុំអនុញ្ញាតទោស ហើយបញ្ចូមឲ្យធ្វើជានាហ្នឹងត ៧ យើងឯង
មិនចេញមករកយើងដោយស្រួលទេ តែយើងបានយកស្រួលទេ ហើយ
អ្នកឯងត្រូវដឹងខ្លួនជាប្រកដកន្លងទោសដ៏មហន្ត ដែលខ្លួនបានធ្វើ
ខុកមកពីមុននោះ ។

លីប៉ាស្រែកតបថា បើប្រសិនមហាឧបាសកមានសេចក្តីករុណាដល់
ខ្លួនខ្ញុំមែន ឲ្យលើកទឹកថយទៅវិញឲ្យអស់សិនចុះ ខ្ញុំនឹងបានជួបជុំ
ពិគ្រោះនឹងទីប្រឹក្សាជាក្រោយ ។

កាលបច្ចូនឹងលីប៉ាធ្វើយន្តនោះ តាន់កុងឈរពីក្រោយខ្នងលីប៉ា
បានឮកំពីងពែងត្រឡប់លើកឆ្ងល់មកបច្ចូហើយបាញ់តម្រង់ទៅ ព្រួញ
ក៏ត្រូវបំណុកបច្ចូ ។ ក្រឡេកឃើញតាន់កុងឈរពីក្រោយខ្នងលីប៉ា ក៏ស្រែក
ថា "អញសម្លាប់គាងឯងឲ្យបាន អាងឯងមិនរួចពីដៃអញទេ" ហើយក៏បំផាយ
សេរីលមកដេញតាហានឲ្យលើកសន្ធឹញចូលទៅព័ទ្ធស្រុកហៃហ្វីដុំវិញ ។
តាន់កុងនិយាយនឹងលីប៉ាថា បច្ចូលើកកងទ័ពមកពីស្រុកហ្គីតោយរួចទៅ
ហើយ តាហានក៏បានសេចក្តីហត់ទៀយណាស់ សុំឲ្យលោកបែងចែកសេរី
តាហានយើងចេញទៅក្រៅស្រុក ខ្លួនខ្ញុំបានទឹងខ្លួលនៅរក្សាត្រួតត្រា
ខាងក្នុង បើបច្ចូលើកទ័ពមកវាយស្រុកវិលាណា ត្រូវលោកព្រួតវាយ
ខ្ទប់ពីខាងក្រោយទ័ពបច្ចូ . ខ្ញុំបានទឹងតល់ពីខាងមុខ បើបច្ចូវិលទៅតទឹង
លោកវិញ ខ្ញុំបានលើកតាហានវាយសន្ធឹញពីខាងក្រោយទៅ សេចក្តី

ដែលយើងធ្វើកលបញ្ឆោតយ៉ាងនេះ តង់តែចូធូនឹងការកែបែកខ្វែកគងខ្ចាត
ត្រឡប់ជាជាប់ស្បៀងអាហារគង់នឹងបាត់ជ័យមិនខាន ។ លីចាំយល់ត្រូវ
ផង កំចាត់ចែងសេនាឥហានទុកព្រម ហើយចូលទៅនិយាយនឹងនាង
ធឿមស៊ីជាការិយា ពាណិនារឿងរ៉ាវឲ្យស្តាប់តាមគំនិតដែលតាន់កុងគិត
នោះត្រប់ប្រការ ។

នាងធឿមស៊ីឆ្លើយថា ដែលលោកនឹងលើកទ័ពចេញទៅត្រាស្រុក
នោះ ប្រសិនជាអន្តរាយ ធ្វើម្តេចខ្ញុំនឹងបានព្យាបាលរក្សាលោក ។ លីចាំ
បានស្តាប់ការិយាថាដូច្នោះ កំទន់ចិត្តអាណិតការិយាពុត្រមិនដឹងជាគិតប្រ-
ការម្តេច កំមិនបានចេញនិយាយការពាធការដល់ ៣ ថ្ងៃ ។ តាន់កុងកំចូល
ទៅជួបនឹងលីចាំនិយាយថា ចូធូលើកទ័ពក្រុកពន្ធន្លានចូលមកដល់ដើង
កំពែងហើយ ម្តេចឡើយកំលោកមិនអើពើនៅស្ងៀមដូច្នេះ ស្រុកនេះមិន
អន្តរាយដោយចូធូទេឬ? ។ លីចាំថា ដែលយើងគិតការពុកនោះយើញ
នាំឲ្យត្រយុទទេទៅ ត្រូវតែយើងរិះគិតរក្សាស្រុកពុកឲ្យមាំមួនទៅចុះ
យើញស្រួលជាជាង ។ តាន់កុងថា ខ្ញុំបានពុកថាស្បៀងអាហារ
កងគងទ័ពចូធូនៅសល់ចេះស្តើងណាស់ទៅហើយ តទ្បាំចូធូប្រើបំរើទៅនាំ
ស្បៀងពីក្រុងហ៊ូតោទៀត សុំឲ្យលោកលើកទៅចាំស្កាត់ដណ្តើមស្បៀង
ចូធូ យើញនឹងខូចការដោយស្មាដៃរបស់យើង ។ លីចាំយល់ត្រូវក៏ចូល
ទៅប្រឹក្សានឹងនាងធឿមស៊ីទៀត ។ នាងធឿមស៊ីឆ្លើយថា "ដែលលោក

ខ្ញុំកចិត្តតាន់កុដឲ្យទៅរក្សាស្រុកនោះ ខ្ញុំយល់ថាតាន់កុដតស៊ូនឹងបច្ចូមិនបានទេ បើលោកទៅហើយ កិច្ចការដែលនឹងរក្សាស្រុកខាងក្រោយ គង់នឹងអន្តរាយ ខ្ញុំនឹងបែរមុខទៅសង្ឃឹមអ្នកឯណា កាលគ្រាលោកចេលខ្ញុំខ្ញុកកុដស្រុកទៀងអាននោះ កុំតែបានចាំងស៊ីជួយរិះគិតបញ្ជូនខ្លួនខ្ញុំឲ្យចេញមកដល់លោកក៏ខ្ញុំមិនរួចខ្លួន ឥឡូវខ្ញុំមិនបានឃើញអ្នកឯណាដែលនឹងទីពឹងបាន បើលោកលើកទ័ពចេញទៅគ្រានេះ នោះនឹងបានលាភសក្ការៈប៉ុន្មានក៏ត្រូវលោកគិតដល់ខ្លួនខ្ញុំ ដែលជាគូកំសត់កម្រនឹងគ្នានោះសិនចុះ" និយាយហើយក៏សោកាតិលាបនុបជាទលីចោ" ។ ក៏មានចិត្តអាណិតអាណាថពន់ប្រមាណណាស់ មិនដឹងបើនឹងរិះគិតកែប្រែយ៉ាងណា ក៏ចូលទៅកនាងតៀវសៀនដែលជាកុំយាបន្ទាប់ ហើយអធិប្បាយកាយវឿងឲ្យនាងតៀវសៀនស្តាប់ ។ នាងតៀវសៀនក៏ហាមឃាត់អង្វរការលីចោ" ជូបនាងដើមស៊ីគ្រប់ប្រការ ។ នាងតៀវសៀនឧបជាទលីចោ"សោកាខ្លាំងយំ ។ លីចោ"ក៏បញ្ចាសអង្អែលថា "នាងកុំរិតក្តដាខ្លួនឯងឡើយ ទោះបីយ៉ាងណាបងក៏មិនចោលប្អូនឲ្យមានសេចក្តីអន្តរាយទេ នឹងខ្វាចថ្វីដំណូចប៉ុនបច្ចូនោះ ខ្លួនឯងសេះបងក៏មានកំឡាំងច្រើនបងនឹងតាំងត្រួតត្រាស្រុកនេះឲ្យមាំមួន មិនឲ្យបច្ចូចូលមកបាន" ហើយលីចោ"ក៏ត្រឡប់ចេញមកនិយាយនឹងតាន់កុដថា ដែលបច្ចូប្រែទាហានចូលទៅនាំយកស្បៀងអាហារពីក្រុងហ៊ូគោនោះ គឺពង្រើបញ្ជូត

យើងជាកូនៗចាយឲ្យយើងលើកទ័ពទៅចាំដណ្តើមស្បៀង បើកាលណាយើងទៅឯណោះ វាដឹងនឹងលើកទ័ពមកវាយយកស្រុកឯណោះ ងាយបានដោយងាយ ហេតុនេះ ខ្ញុំយល់ថានឹងលើកទ័ពទៅតាមពាក្យអ្នកនោះ ក៏គង់នឹងចោះការជាក្រោកដ ។

តាន់កុងឮលីចោ៉ាថាដូច្នោះ ក៏មិនបានតបឆ្លើយថាដូចម្តេច គ្រាកុងចេញដើរទៅក្រៅ ហើយនិយាយប្រាប់សេនាគាហានទាំងពួងថា យើងទាំងឡាយពាល់គ្នាកូនវែលានេះ យើញនឹងដល់ទ្បូរសេចក្តីវិនាសអន្តរាយក្រៃយអាយុដ៏វែងក្រោកដហើយ ព្រោះលីចោ៉គិតការខុស ពុំបានយកតាមគំនិតក្រោជ្ញអ្នកឯណោះសោះ លីចោ៉មិនបានគិតនឹងចេញតាំងក្បាំងនឹងបួនទ្បូរទេ ចេះតែនាំនាងងៀមស៊ី, នាងតៀរសៀន ផឹកស្រាជាអាចិន្ត្រៃព្រឹកល្ងាចប្រាប់ថានឹងឲ្យរសាយរសេចក្តីវុក្ខលំបាក ។

ឯទៅតី, អង្គកាយ ជាទីប្រឹក្សាយើញលីចោ៉មិនបានគិតការសង្គ្រាមដូច្នោះ ក៏នាំគ្នាចូលទៅរំឭកថា ដែលលោកនៅស្រុកព្រងើយកន្តើយដូច្នេះ ស្រុកហៃហ្វុងនឹងអន្តរាយអស់ការៈដោយថ្ងៃដៃបួនជាក្រោកដហើយ សព្វថ្ងៃនេះអ្ងួនសុតនៅស្រុកហួយណាំ ក៏មានសេនាគាហានជាច្រើន សូមឲ្យលោកចាត់បម្រើទៅនិយាយនឹងអ្ងួនសុតថា លោកនឹងលើកកូនក្រមុំឲ្យជាការិយាកូនអ្ងួនសុត ឲ្យអ្ងួនសុតលើកកងទ័ពមកជួយវាយរួបកងទ័ពបួនទ្បូរ ។ ក៏គង់នឹងបែកខ្ញែកចេញមិនខាន ។ លីចោ៉យល់

យើញត្រូវកំណើសុំបុត្រឲ្យទៅគឺ, អង្គការ កាន់ចេញទៅឲ្យអ្នកសុត ។ ទៅគឺជំរាបថា ខ្ញុំបាទនឹងសុំការហានចេញជូនដំណើរទៅឲ្យផុតកង់ទ័ពចូលសិន ។ លុះចោ៉ក់ចាត់ទ្រើតៀវលៀវជានាយទ័ពមុខ ទ្រើឡាន់បេង៉ជានាយទ័ពក្រោយលើកំពាហាន ១.០៦០ ចេញទៅ លុះពេលយាម ៣ យប់ ទៅគឺ, អង្គការ ក៏លាលីចោ៉ចេញពីស្រុកហៃហ្វឹ ។ តៀវលៀវនឹងឡាន់បេង៉ ទៅគឺ លើកទៅដល់ដែនហួយណាំ ។ ឡាន់បេង៉ចែងពាហាន ៩០០ ទៅជាមួយទៅគឺ អង្គការ, ឲ្យតៀវលៀវនាំពាហាន ៩០០ ត្រឡប់មកស្រុកហៃហ្វំវិញ ហើយទៅគឺ, អង្គការ, ឡាន់បុង ក៏លើកចូលទៅកន្លែងស្រុកហួយណាំ ចូលទៅជួបនឹងអ្នកសុតយកសំបុត្រលីចោ៉ជូនទៅឲ្យអ្នកសុត។ លុះមើលរួចក្តីថា "ខ្ញុំលីចោ៉សូមគំនាប់មកអ្នកសុត ជួតអ្នកឲ្យបម្រើមកសុំកូនក្រមុំខ្ញុំ នឹងនាំទៅឲ្យកូនអ្នកនោះ ខ្ញុំទៅមិនទាន់រៀបមង្គលការ ព្រោះចូលើកទ័ពមកជាច្រើនណាស់ លើសកំឡាំងខ្ញុំដែលនឹងចេញតទល់ ហេតុនេះ ខ្ញុំសុំឲ្យអ្នកលើកកង់ទ័ពមកដួយក់យទ្រប់ពីក្រោយ ដោយផ្លូវមត្រឹមប់តាន់គ្នាតទៅ" ។

អ្នកសុតមើលសំបុត្រហើយក៏ថា លីចោ៉នេះជាមនុស្សនិយាយមិនមានភាស្សត្យពិតត្រង់។ ណាសោះ កាលគ្រាមុនគោះយើងឲ្យសំបុត្រទៅសុំកូនក្រមុំ លីចោ៉ខ្លួលភាស្សថាត្រមឲ្យដល់យើង ឲ្យយើងរៀបទៅទទួលនាំយកតាមទំនៀម លីចោ៉ក៏ត្រឡប់កែប្រែថាប់ខ្នងហានសុំនបញ្ជូន

ទៅឲ្យចូលធ្លូ ហើយសម្ងាត់ខាងហានចំរើដែលយើងត្រៃទៅខឿននោះទៀត ឥឡូវចូលធ្លូលើកទំពាមកព័ទ្ធស្រុក ហេតុម្តេចមិនតឹងប្រែស័យចូលធ្លូ កំត្រឡប់ជាមុខមកតឹងយើងជាគូសត្រូវវិញ? ។

ទៅតីបានឮដូច្នោះ ក៏ឆ្លើយតបថា លីចាំ"ចៅហ្វាយខ្ញុំបានទឹងបានគិតប្រទូសរ៉ាយទឹងលោកដូច្នោះក៏ទេ កាលលោកប្រើហានអ៊ុនទៅសុំកូនក្រមុំនោះ លីចាំ"មានសេចក្តីត្រេកអរណាស់ ព្រមលើកកូនក្រមុំឲ្យចំរើលោកនាំមកជូនលោកជាពិត តែថាវេលានោះចូលធ្លូប្រែកលៗបាយផ្សេង។ ទើបការនោះប្រែត្រឡប់ខុសទៅ ឥឡូវលីចាំ"ធ្លាំមកជំរាបលោកថា ម្តងនេះព្រមជូនកូនក្រមុំមកលោកជាច្រាកដហើយ ។

អ៊ិនសុតតបថា ឥឡូវលីចាំ"ប្រែហេតុសិទ្ធិឯចូលធ្លូមិនបានហើយឬ? បានជាលើកកូនក្រមុំឲ្យយើង បើប្រសិនម្តងណោះជាការពិតមែន កំត្រូវតែលីចាំ"បញ្ជូនកូនក្រមុំមកឲ្យយើងសិន ទើបយើងនឹងលើកកងទ័ពទៅជួយដែលទឹងឲ្យយើងលើកទៅជួយជាមុននោះ យើងមិនខុកចិត្តជាច្រាកដទេ ព្រោះលីចាំ"ធ្វើឲ្យយើងរង្គៀសចិត្តម្តងទៅហើយ ។ ទៅតីបានស្តាប់តិមិនបានឆ្លើយតបថាម្តេច ទើបលាអ៊ិនសុតនាំគ្នាចេញពីស្រុកហួយណាំមកវិញ លុះមកដល់ប្រទល់ដែនយើញបន្ទាយឡៅតីតាំងស្តាត់ទឹងផ្លូវ ទៅតីទឹងតឹងកាយក៏និយាយទឹងឡាន់ចេងថា យើងជាអ្នកកាន់សំបុត្រខ្លួនអ្នកជាសេនាលីចាំ"។ ច្រើឲ្យមកជួយការពារយើងមិនឲ្យមានសេចក្តី

អន្តរាយ រៀលាយបន់នេះ យើងនឹងលបចេញទៅឲ្យផុតបន្ទាយឡៅពីចុះ អ្នកចូរនាំពលទាហានដួយការពារតើគ្រាយឲ្យមាំមួន ។ ឡាន់បេងទទួលពាក្យពេចន៍ស្រេចហើយ លុះដល់ពេលយប់ ទៅតី, នឹងអង្គាយកំលបចេញទៅផុតបន្ទាយឡៅពី ឡាន់បេងក៏នាំទាហានការពារគ្រាយ ។

តៀវហ៊ុយនៅកងបន្ទាយបានឮសូរដើងមនុស្សដើរសន្ធឹកណាស់ក៏ទឹកសង្ស័យនាំទាហានចេញទៅមើល ឃើញឡាន់បេងលើកទាហានការពារបន្ទាយធ្វងទៅ តៀវហ៊ុយក៏បំផាយសេះដេញឡាន់បេងពីគ្រាយ ឡាន់បេងក៏ទាញសេះបែរមកតនឹងតៀវហ៊ុយបាន ១ ភ្លែង តៀវហ៊ុយចាប់ខ្លួនឡាន់បេងបាន ឯទាហាន ៥០០ ក៏រត់ចែកព្រាត់ព្រាយអស់ទៅ តៀវហ៊ុយក៏នាំខ្លួនឡាន់បេងទៅផ្ទះឡៅពី ។ សួរសេចដឹងសេចក្តីសព្វគ្រប់ហើយ ក៏ឲ្យបំរើឃុំនាំខ្លួនឡាន់បេងទៅឲ្យចូចូ។ សួរឡាន់បេងថា ខ្លួនឯងទៅណាមកណា ? ។ ឡាន់បេងក៏ឆ្លើយដំរាបតាមដំណើរពិតត្រង់ឲ្យចូចូស្តាប់ ។

(មានត)

ជាលៈ ន ន ធមយន្តី

រឿងព្រេងប្រទេសឥណ្ឌៀ

អ្នកស្រីស្រ៊ុន-សារីយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីភាសាចាំងមកជាខ្មែរ

វគ្គទី ១

ព្រះបាទវីរសេន (Viraséna) គ្រងរាជសម្បត្តិនៅប្រទេស និសធៈ (Nishadhas) ទ្រង់ព្រះសុវណ្ណគតៈ មានព្រះរាជបុត្រាពីរព្រះអង្គគឺព្រះរាជវង្ស ។ ព្រះរាជបុត្រច្បងព្រះនាម នាលៈ (Nala) មានរូបឆោមលោមពណ៌ល្អក្រៃលែង ធ្វើឲ្យព្រះឥន្ទ្រាធិរាជ (Indra) ដែលជាម្ចាស់ស្ថានសួគ៌ តើតសេចក្តីប្រណែន, បើកាលណាទ្រង់យាងតាមផ្លូវក្នុងទីត្រង់នៅក្បាលក្បួនទ័ព គេឃើញទ្រង់ហាក់ដូចជាព្រះសុរិយាបញ្ចេញរស្មីគ្រប់ពណ៌ដែលគួរឲ្យចេតនា ។ ព្រះអង្គប្រកបដោយព្រះហឫទ័យក្លាហាន ទ្រង់បំពេញកិច្ចជាវីរបុរស ទ្រង់ជាក្សត្រគោរពសាសនា ទ្រង់ចេះចាំក្បួនខ្នាតនឹងវេទៈ (Véda) ហើយទ្រង់ទំនុកបំរុងពួកព្រាហ្មណ៍ណាស់ ។ ជនណាដែលមានវាសនាបានឃើញទ្រង់ហើយ មិនអាចនឹងភ្លេចទ្រង់បានឡើយ តែងតែដើរផ្សាយនូវកិត្តិស័ព្ទពេញលោកទាំងមូល ។

ព្រះអនុជនៃព្រះបាទនាលៈ ព្រះនាម បុស្ករៈ (Pushkara) មានព្រះរូបកាន់តូចហើយខ្សោយជាង ទ្រង់សព្វព្រះហឫទ័យនៅតែកាន់តែស្មោះ

ហើយពួកប្រជាទុកស្រុក កំពុំសូវបានឃើញខ្ទង់ផង ។ នៅវេលាដែលព្រះបាទនាលៈធ្វើព្រះពរជពិធី, ព្រះអគ្គមាសប៉ុស្ការៈ ជ្រើនតែមួយព្រះអង្គឯង មិនបួលម៉ាកបង្ហាញព្រះអង្គក្នុងពិប្រជុំជនឯងទេ ម្ល៉ោះហើយបានជាគេមិនអាចដឹងបានថាខ្ទង់ជាក្សត្រអង់អាច ឬជាក្សត្រដែលមានព្រះចរិយាតន់ខ្សោយឡើយ ។ ជនទាំងឡាយតែងតែគិតថាខ្ទង់សព្វព្រះពរជហ្លួងយ៉ាងតន់នៅក្នុងទីស្ងាត់តែម្នាក់ឯង មិនឲ្យអ្នកណាស្គាល់តែប៉ុណ្ណោះ ។

ចំណែកព្រះបាទនាលៈវិញ តែងខ្ទង់សព្វព្រះពរជហ្លួងយ៉ាងខ្លាំងណាស់ទីការបង្ហាត់សេះ ទោះសេះទោះសាហាវយ៉ាងណាក៏ដោយ - ក៏ខ្ទង់ពុំខ្លាចបន្តិចសោះឡើយ ខ្ទង់ឡើងគង់លើក៏ ចាញ់ហក់ទៅក្នុងនិមហ៊ោយបង្វឹកឲ្យទាល់តែទៅជាស្ងួតបូតបាន ។ នៅគេលដែលខ្ទង់ចង់ក្រសាលម្តង។ ខ្ទង់បន្ទំឲ្យពួកសារថីដែលមានថ្វីដៃ មកប្រណាំងប្រជែងប៉ុន្តែអ្នកតាំងនោះចាញ់ខ្ទង់តាំងអស់ ។

ជួនកាល ក្រោយពីការពិភាក្សាអំពីកិច្ចការក្នុងព្រះពរជអាណាចក្ររួចហើយ ខ្ទង់ក្រសាលទៅក-ឡាក់ (ដង់) ដើម្បីនឹងលំហែព្រះហ្លួងយ៉ង ។ កាលណាខ្ទង់មានជោគជ័យ ព្រះអង្គមិនខ្លុកប៉ាក់នោះទេ ខ្ទង់ប្រទានទៅពួកតាបសនឹងពួកអ្នកក្រីក្រ ។ ឯព្រះអង្គមាសប៉ុស្ការៈ ដោយឮស្ងួរគេលេងខ្ទង់ហឹង ក៏ខ្ទង់យាងចេញមកទតគេលេងដែរ ហើយចេះតែ

សំឡឹងក្រែកដែលព្រះបាទនាលៈលេងឈ្នះ ។ លុះឃើញព្រះបាទនាលៈ
ទ្រង់យកក្រែកនោះបែកជាខានអស់ទៅ ទ្រង់ក៏លួចញាក់ព្រះអង្ករះគន់ ។

វគ្គទី ២

នៅឯប្រទេស វិទភ៌ៈ (Vidarbhas) មានមហាក្សត្រមួយព្រះអង្គ
ព្រះនាម ភីមៈ (Bhimas) គ្រងរាជសម្បត្តិ ទ្រង់ប្រកបដោយតេជា-
នុភាពជាយ៉ាងក្រៃលែង ទ្រង់មានព្រះរាជបុត្រីមួយព្រះអង្គព្រះនាមទម-
យន្តី (Damayanti) ដែលប្រកបដោយរូបឆោមលោមពណ៌ល្អលើសលប់
ស្រីគាំងឡាយ ។ ព្រះភក្ត្រព្រះនាងល្អលើសរាល់ព្រះចន្ទ្រ លំអនៃព្រះ
នេត្រព្រះនាងរកអ្វីផ្ទឹមគ្មាន ហាក់ដូចជាធ្វើឲ្យកើតសេចក្តីរន្ធត់ដល់ពួក
ឥរិវដែលសរសើរអំពីវិចិត្រនៃផ្កាឈូក មានសម្បុរបរិសុទ្ធដូចជាមាស
ទឹកដប់ មានព្រះកេសាវែងសំយុងក្រាសដី មានព្រះសុជន់ដូចដើងពាន
មានដីវិត មានបបូរព្រះឧស្ឋញញឹមស្រស់ប៉ិច្រឹម ដែលបង្ហើរព្រះសូរ-
សៀងយ៉ាងស្រទន់ពីរោះ ហាក់ដូចជាគេច្រៀង ។

ព្រះបាទភីមៈ ទ្រង់សព្វព្រះរាជហឫទ័យ នឹងព្រះរាជបុត្រីណាស់
ហើយរើសយកស្រីក្រមុំយ៉ាងល្អ ។ នៅក្នុងភូមិភាគនោះមកធ្វើជាសំពៅ
នាង ប៉ុន្តែព្រះនាងនៅតែមានលំអលេចធ្លោជាងស្ត្រីគាំងឡាយទៅទៀត
បីដូចជាផ្កែបន្ទោរលេចឡើងកណ្តាលពពកសម្បុរស្រអាប់ ។ គេគ្រាន់
តែក្រឡេកឃើញនាង ក៏មានចិត្តរីករាយទៅហើយ ពួកអ្នកដំណើរដែល

ដើរកាត់តាមប្រទេសនៃគេ: ក៏នាំសេចក្តីសរសើរអំពីរូបល្អនៃព្រះនាង
ខមយន្តី ទៅផ្សាយពេញពិភពលោក ។

ពេលវេលាដែលព្រះនាងខមយន្តី នឹងត្រូវរើសព្រះកស្តាក៏កាន់តែ
ជិតមកដល់ ។ ព្រះនាងចេះតែគង់ទ្រមឹង ព្រះទ័យអណ្តែតអណ្តូង
ជាខ្លាំង ។ កាលណាពួកស្រីស្នំមកស្រែកពាក់តែង ព្រះអង្គឲ្យព្រះ
នាង។ ក៏នៅតែព្រងើយ មិនរវល់នឹងការសន្ទនានៃស្នំឡើយ ។ គេមក
ក្រាបទូលព្រះនាងជារឿយៗ ថា "ព្រះបាទនាល.ជាស្តេចមួយព្រះអង្គ
ដែលមានព្រះរូបល្អលើសលប់ក្សត្រគ្រប់អស់" ។

វគ្គទី ៣

គេបានមកក្រាបទូលព្រះបាទនាល:ជាញឹកញាយថា: "ព្រះនាង
ខមយន្តី ជាក្សត្រីល្អឆើតជាងគេ" ។ ព្រះបាទនាល:ក៏ចេះតែទ្រង់
ព្រះតម្រិះគិតមមៃទៅរកព្រះនាងខមយន្តី ។ ទ្រង់គង់នៅក្នុងព្រះពជ
ដំណាក់មិនសុខសោះ ហើយទ្រង់ចេះតែជូញគ្រាន់នឹងការពិភាក្សានៃ
ពួកនាហ្មឺនសព្វមុខមន្ត្រី ។ ទ្រង់មានព្រះបន្ទូលយ៉ាងខ្លី ជាមួយនឹង
ពជទូតស្តេចជិតខាង ហើយទ្រង់ចេះតែរកទីស្ងាត់ ។

ព្រះបាទនាល:ទ្រង់ស្តេចទៅសម្ងំពួនកន្លែងឯក្រាន តែមួយ ព្រះកន្តុងឯង
នៅក្រោមម្លប់នៃដើមឈើដែលមានផ្កាក្រអូបល្អមួយ ហើយទ្រង់ផ្ទំគ្រាល
នៅលើស្មៅដែលមានផ្កាព្រាងព្រាត ។

ខ្ញុំឆ្ងេចព្រះនេត្រតម្រឹម ។ នៅក្នុងពន្លឺព្រឹល ព្រះអង្គស្រមៃ
ឥតទៅឃើញដូចជាខ្មោចស្លុង ហើយខ្ញុំទំរែស្រកថា: "ហ្ន៎ងហើយឬ
នាងមយន្តី? ស្រីសំឡាញ់បងមកនេះ ប្អូន!" បន្តិចមកស្រមោលនោះ
វិនាសបាត់ទៅ ព្រះអង្គខ្ញុំគង់នៅតាំងមានព្រះទ័យវិតក្ក ។

ថ្ងៃមួយ ព្រះអង្គឥតយល់ក្មានវៃជាច្រើន ដែលមានសម្បុរស្អាប
ដូចមាស ហើរចុះពីលើមេឃសំដៅមកកន្លែងគុម្ពោតដែលខ្ញុំគង់ ។ បក្សី
នោះចុះមកទំក្បែរព្រះអង្គ។ ក៏ឈោងព្រះហស្តទៅកៀបយកក្មានមួយ ស្រាប់
តែក្មាននោះពោលថា: "ឧត្តមភក្សិន! សូមខ្ញុំកុំសម្លាប់ខ្ញុំលបង្គុំ។
មិនសមនឹងស្លាប់ដោយដៃគឥសនាអាក្រក់យ៉ាងនេះទេ ។ បើខ្ញុំ
ប្រែសប្រណីទុកជីវិតឲ្យខ្ញុំលព្រះបង្គុំ។ នឹងថាយវង្វា ដល់ព្រះអង្គវិញ
មិនខាន ។ ខ្ញុំលព្រះបង្គុំនឹងហើរទៅឯប្រទេសវិទេភ: ហើយខ្ញុំល
ព្រះបង្គុំនឹងខ្ញុំលព្រះនាងទមយន្តីថា ព្រះបាទនាល: ដែលជាបមកពមាន
ព្រះហឫទ័យប្រតិពន្ធចំពោះព្រះនាង នោះព្រះនាងមុខជានឹងលែងរវល់
នឹងស្តេចឯណាក្រៅពីខ្ញុំទៀតហើយ" ។

ព្រះបាទនាល: ខ្ញុំព្រះសណ្តាប់ហើយ ខ្ញុំញញឹម, គេឃើញ
ព្រះនេត្រព្រះអង្គមានទឹកដមយ៉ាងថ្លា ដែលបណ្តាលមកអំពីសេចក្តី
សប្បាយ ។ ក្មានវៃក៏ហើរសំដៅទៅឯប្រទេសវិទេភ: ។

(មានត)

រឿងចិញ្ចៀនទិព្យ

អ្នកស្រីសារិយ៉ាន់ ប្រែរៀបរៀង

(ត-ចប់)

ស្រីបំរើដែកទៅសួរគ្នាវិញ ហើយក៏បើកឲ្យទ្រង់ចូល ។ លុះទ្រង់យាងចូលទៅទ្រង់ទតឃើញយាយចាស់អង្គុយ មានស្រីបំរើទៅអង្គុយអមត្រៃបត្រា ។ យាយចាស់លុះឃើញស្តេចយាងចូលទៅសុំមកទទួល "អ្នកស្រីអញ្ជើញ!" ។ ព្រះអង្គម្ចាស់អាលីទ្រង់សួរថា: "យាយមិនស្គាល់ខ្ញុំទេឬ?" ។ រួចទ្រង់បើកសំពត់គ្របមុខទ្រង់ចេញហើយចាប់ដៃយាយមកថើប ។ យាយចាស់ស្រែកថា "ទុកូនមាសម្តាយ! ទ្រង់អាលីតើ" ហើយក៏ឱបតែព្រះអង្គម្ចាស់អាលីគាល់តែសន្ធប់ចាត់មាត់ ។ លុះក្បាលខ្ទួនឡើងកាលណា គាត់សួរស្តេចថា "កូនតែម្តាយ!, ចូរកូនប្រាប់ម្តាយផង តើមានរឿងអ្វី?" ។ ទ្រង់អាលីក៏ប្រាប់រៀបរាប់រឿងរ៉ាវរបស់ខ្លួនតាំងតែពីដើមដល់ចប់ ។ យាយចាស់ស្តាប់ហើយ បែបឆ្ងឿងឆ្ងល់ថា "កូនអើយ! ហ្នឹងហើយជាការណ៍ដែលម្តាយខ្លាចដួសកូន ល្អើយលែងវៀសទៅកូន! តើឯងមានបំណងយ៉ាងណា?" ។ ទ្រង់ទ្រឹងតបថា: "ខ្ញុំនឹងយកចិញ្ចៀននោះឲ្យបានហើយនឹងបំផ្លាញមេចង្រៃឲ្យបានដូចបំណង" ។

– មិនអ៊ីទេ ចាំម្តាយជួយឲ្យសំរេចសេចក្តីដែលឯងប្រាថ្នា ។

ពួកស្រីបំរើនាំគ្នាលេងសប្បាយទទួលម្ហូបដែលខើបនឹងហោះមកដល់ថ្មី ។ យាយថាសំបូលទៅក្នុងបន្ទប់ទឹក យកខ្លឹមនឹងខ្លាញ់ ប័រ (Beurre jondu) កំនលាយគ្នាហើយលាបខ្លួនគាត់ត្រង់កន្លែងដែលត្រូវលុតជង្គង់ គាត់ថ្វាយបង្គំហើយកន្លែងនោះទៅជាភ្លៅ បើនរណាឃើញគាត់នៅពេលនោះ ទឹងស្មានថាគាត់ជាអ្នកសមាធានសីល គាត់ស្លៀកសំពត់អាវអំបោះ ហើយទទួលក្រមាកេមចៀមកាន់ក្អមមួយមានទឹកតេញ ហើយមានថ្មក់១ពាន់ឌីណារនៅក្នុងថាតក្អមនោះ ដែលគាត់គ្របដោយសំពត់មួយ ហើយក៏ចេញដើរទៅដល់ដំណាក់ព្រះនាងវរកដិន្ន ។ លុះគាត់ចូលទៅដល់មាត់ទ្វារ គាត់ឃើញមានពាន់ទឹកមួយនៅក្នុងលែងប្រចាំការ ឃើញមនុស្សបំរើនឹងពួកស្ងួយកាន់ក្អមទៅជនឹងទឹកពីក្នុងពាន់នោះ ។ ពួកបំរើសួរគាត់ថា: "យាយមានការអ្វី? ត្រូវការទឹកឬ?" ។ ដូនដីលុះឮគេសួរដូច្នោះក៏និយាយថា: "ខុណាឬណ្យព្រះជាម្ចាស់ លោកមានបំរើដែលអាចធ្វើឲ្យទឹកនៅក្នុងក្អមខ្ញុំទៅជាមាសពាសអស់" ថាដូច្នោះហើយគាត់យកក្អមទៅចាក់ចិននឹងពួកអ្នកបំរើ (សាប់តែមាសហូរចេញមកគគុក ។ ពួកបំរើនាំគ្នាស្រែកខ្ចរដឹងអឺងកងដណ្តើមមាសគ្នា ។ ព្រះពាសន៍ជាទង់ឮសូរសំពូរំពងខ្ញៀវៗ ក៏មានព្រះបន្ទូលសួរថា: "សូរអ្វីលាន់រន្ធឺម្ល៉េះ?" ។ អ្នកបំរើទូលព្រះមង្គថា: "មានយាយម្នាក់ចូលមកដងទឹក ហើយពួកយើងក៏ឮនសួរគាត់ថា: យាយឯងមកយកអ្វី ត្រូវការទឹកឬ?

គាត់នៅតែឈរហាលថ្ងៃ ប៉ុន្តែគាត់ជ្រមុជក្អមគាត់ទៅក្នុងលូទឹកដែលគ្មានទឹកសោះ ហើយស្រាប់តែលើកឡើងមានឱណាពេញ រួចគាត់ដើរចេញបាត់ទៅហើយ គ្មានខណៈមួយដែលមិនយកឱណារបស់គាត់ទេ"។ ព្រះរាជាទ្រង់ព្រះសណ្តាប់ដូច្នេះហើយក៏មានព្រះបន្ទូលថា: "ព្រះអើយ! បើប្រសិនជាអញបានឃើញគាត់ អញនឹងសូមឲ្យគាត់ច្រាសប្រណីឲ្យពរអញ ពីព្រោះគាត់ពោលសំដីពិត" នេះហើយជាហេតុដែលបង្កើតឡើងដោយមិនដឹងខ្លួន ។ ចំណែកឯយាយចាស់ បានត្រឡប់ទៅកាន់ទីលំនៅគាត់វិញ ។ ព្រះអង្គម្ចាស់អាលីទ្រង់ទតឃើញហើយ ទ្រង់សូមកន្ទួលហើយថើបដៃគាត់។ ក៏ទូលទ្រង់ថា: "ខ្ញុំម្ចាស់បានប្រើឧបាយប្រភ័ញ្ជន៍បើប្រសិនជាឧបាយនេះប្រកបការពាំងអម្បាលម៉ាន នឹងបានសំរេចដូចសេចក្តីប្រាថ្នាពាំងអស់ សូមទ្រង់កុំព្រួយព្រះហឫទ័យ" ។ គាត់ខុកវេលាបីថ្ងៃឲ្យរំលងហួសទៅទេ ។ ដល់ថ្ងៃទីបួន គាត់យកឱណាជាក់ក្នុងក្អមគាត់ទៀត គាត់គ្រប់ដោយកន្សែងមួយ ហើយក៏ដើរកាត់មុខទ្វារព្រះរាជវាំងដូចមុន ។ ពួកអ្នកបំរើស្តេចលុះគ្រាឃើញគាត់ក៏រត់សំដៅទៅ ហើយថើបដៃគាត់។ ក៏ដើរចូលទៅជិតលូទឹក ជ្រមុជក្អមទៅក្នុងទឹកហើយពោលថា: "ចូរអ្នកយកទូរអំណោយក្នុងពិភពលោកដែលប្រកបដោយអនត្តាធម៌" ថាហើយគាត់ចាក់ឱណាគ្រាលពេញកន្ទែងខោះ ។ ពួកអ្នកបំរើស្ទុះដណ្តើមគ្នាប្រញាប់ ថែមទាំងស្រែកលាន់

ទៃហឹងផង ។ ព្រះពាជាទ្រង់ជ្រាបដោយមានគេទូលទ្រង់ៗ ត្រាស់បង្គាប់ថា: "នាំយាយនោះមកឲ្យអញ" កាលទ្រង់ទតយល់យាយចាស់មកដល់ ទ្រង់សួរទៅថើបដៃយាយចាស់នោះដោយគោរព ។ យាយចាស់ក៏ប្រដៅឲ្យទ្រង់ខ្ចាចខ្លួវអំពើបាបអំពើនរក ហើយឲ្យប្រព្រឹត្តតាមផ្លូវធម៌ផង ។ កាលណោះ ព្រះពាជាទ្រង់មានព្រះបន្ទូលថា: "ខ្ញុំមានចិត្តត្រេកអរនឹងយាយណាស់ពេក ខ្ញុំមានចិត្តចង់ឲ្យយាយទៅលេងផ្ទះកូនស្រីខ្ញុំផង ប្រសិនបើយាយជានាងចូលចិត្តទទួលពរយាយដែរមិនដឹង" ។ យាយចាស់ទូលតបថា: "តាមតែទ្រង់សព្វព្រះពាជហឫទ័យ" ។ ព្រះមហាក្សត្រក៏នាំយាយចាស់ចូលទៅក្នុងដំណាក់ព្រះនាង ។ ព្រះនាងលុះឃើញគាត់ទៅដល់ក៏ស្ទុះមកទទួលថើបដៃគាត់ដោយគោរព ហើយទ្រង់មានព្រះបន្ទូលថា: "លោកយាយ! ខ្ញុំចង់ឲ្យលោកយាយនៅសំពត្តផ្ទះខ្ញុំក្នុងយប់នេះ ដើម្បីនឹងប្រស័យគ្នាលេង ហើយនឹងឲ្យស័ព្ទសាធុការពារដល់ខ្ញុំផង" ។ យាយចាស់ឆ្លើយថា: "ខ្ញុំម្ចាស់នឹងនៅតាមព្រះពាជបំណងពុំបានទេ ព្រោះខ្ញុំម្ចាស់មានកូនស្រីមួយហើយគ្មាននរណានឹងមើលថែទាំផង" ។ ប៉ុន្តែព្រះនាងនៅតែបញ្ជេសថា: "ទុកជាយ៉ាងណាក៏ដោយ ត្រូវតែយាយនៅសំពត្តផ្ទះខ្ញុំ" ។ យាយចាស់ក៏នៅជាមួយនឹងព្រះនាងអស់រាត្រីមួយគត់ ។ ក្នុងពេលនោះ បេះដូងនៃព្រះអង្គម្ចាស់អាលីហាក់ដូចជានៅលើរណើកភ្លើង ។

លុះដល់ថ្ងៃជាគំរប់បួន ទ្រង់អាលីដែលមានព្រះទ័យចាប្រម្ណ៍នឹងចាត់យាយចាស់យូរពេក ក៏មានព្រះបន្ទូលថា: "មានតែព្រះជាម្ចាស់ទេ ដែលមានកំឡាំងព្រះហឫទ័យតូចតែ តើមានហេតុអ្វីបានជាយាយចាស់ចាត់សូន្យម្ល៉េះ?" ។

ចំណែកឯយាយចាស់គាត់ក៏ទូលព្រះនាងថា: "ព្រះនាងដ៏ប្រសើរ! ខ្ញុំម្ចាស់ចង់ត្រឡប់ទៅផ្ទះចាប់កូនឲ្យជឹងជិនកុំឲ្យក្អកខ្លឹង ហើយខ្ញុំម្ចាស់នឹងត្រឡប់មកវិញ បើត្រូវទៅ១ខែ ឬ២ខែក៏ខ្ញុំម្ចាស់លែងចាប្រម្ណ៍អ្វីទៀតឡើយ" ។ ព្រះនាងសួរបញ្ជាក់ថា: "យាយឯងចាកដជាមានកូនស្រីមែនឬ?" ។ យាយចាសទូលតបថា: "តើមនុស្សបែបខ្ញុំម្ចាស់នេះ ចេះនិយាយកុហកឬ? ខ្ញុំម្ចាស់មានកូនស្រីមួយដែលមានមុខល្អគ្មាននរណាដូច នាងរាល់តែគោរពព្រះអាទិទេពហើយមិនរាល់ដល់សត្វលោកទេ" ។ ព្រះនាងទ្រង់ព្រះសណ្តាប់ហើយមានព្រះបន្ទូលទៀតថា: "ព្រះគុណអើយ! ខ្ញុំចង់ឲ្យនាងមកផ្ទះខ្ញុំ" ។ យាយចាស់ឆ្លើយថា: "គ្មានផ្លូវទេ ព្រះនាង!" ។

- ឧអកម្ពាយអើយ! លួងលោមៈថ្ងៃយ៉ាងដូចម្តេចឲ្យតែនាងសុខចិត្តមក ។

- បើសិនជាខ្ញុំម្ចាស់និយាយបាន ខ្ញុំម្ចាស់នឹងនាំមកថ្វាយព្រះនាង ប៉ុន្តែគាល់តែព្រះនាងព្រមព្រះហឫទ័យកុំឲ្យនាងបើកមុខឲ្យសោះ ពីព្រោះតាំងតែព្រះជាម្ចាស់ប្រទានឲ្យដំរែតនាងមក នាងមិនដែលបើកមុខឲ្យនរណាឃើញទេ ។ ព្រះនាងមានព្រះបន្ទូលថា. "ខ្ញុំសុខចិត្ត" ។

យាយចាស់ក៏គ្រាកឆេះចេញពីដំណាក់ព្រះនាង ហើយដើរដង្ហក់ៗ
រកព្រះអគ្គមហាស៊ាលី។ មានព្រះហឫទ័យរីករាយគេក ដោយឃើញយាយ
ចាស់ត្រឡប់មកវិញ ហើយមានព្រះបន្ទូលសួរថា: "សូមយាយនិយាយ
រឿងរ៉ាវដែលបានទៅនៅជាមួយនឹងព្រះនាងច្បាប់ខ្លះផងយ៉ាងណាខ្លះ"។
យាយចាស់ក៏និយាយរឿងរ៉ាវទូលទ្រង់សព្វគ្រប់ ហើយក៏យកសំលៀក
បាក់ នឹងគ្រម៉ាខ្លួនធ្វើអំពីពេមចៀមមកបំភាក់ឲ្យទ្រង់ ហើយក៏នាំ
ទ្រង់ទៅកាន់ដំណាក់ព្រះនាង។ លុះអ្នកទាំងពីរដើរមកដល់ទ្វារព្រះ
បរមរាជវាំង ពួកអ្នកបំរើនឹងពួកឆ្មាំទ្វារនាំគ្នាស្រែកទទួល ព្រមទាំងនាំគ្នា
ចេញត្រេសង់មកថើបដៃគាត់ដោយគោរពផង។ បន្ទាប់មក គេបែគល់
គេហស្ថានមួយទុកឲ្យព្រះអគ្គមហាស៊ាលីសូត្រធម៌នៅពេលយប់។ យាយ
ចាស់ច្បាប់ទៅពួកអ្នកបំរើទាំងប៉ុន្មានថា: "ខ្ញុំត្រូវទៅកន្លែងការនាធម៌
ព្រោះខ្ញុំក៏ដូចជាកូនខ្ញុំដែរ ដែលមិនអាចនឹងបោះបង់ព្រះធម៌ចោលបាន"
ថាដូច្នេះហើយក៏ទៅកាន់ទីកន្លែងគាត់ទៅ។

ចំណែកព្រះអគ្គមហាស៊ាលី ទ្រង់រំលែកគ្នានធម៌តាំងតែពី
ព្រលឹមដល់ព្រលប់គ្មានសំកកសោះ នៅពេលនោះគេយកអាហារនឹងនំ
ផ្សេងៗមកថ្វាយទ្រង់ ប៉ុន្តែទ្រង់មិនព្រមទទួល។ គេក៏សួរទ្រង់ថា:
"តើអ្នកត្រូវការពីសាអ្វីវិញ?"។ - នំប៉ុងធ្វើអំពីថ្មានឹងអំបិលគ្រាប់។
ពេលនោះព្រះនាងទ្រង់បែរទៅមានព្រះបន្ទូលនឹងនាងមាដិនា ជាស្នំឯក

ថា: "នេះគឺជាអនុគ្រោះនៃព្រះជាម្ចាស់ដ៏ក្រៃលែង" ហើយព្រះនាង
ក៏មានព្រះបន្ទូលទៀតថា: "ខ្ញុំចង់ឲ្យគាត់សង្កត់ខ្លួនគាត់មកលើខ្លួនខ្ញុំ
ដើម្បីកុំឲ្យក្អេងក្អែងមកធាបនេះខ្ញុំបាន" បន្ទាប់មកព្រះនាងគ្រាស់បង្គាប់
ឲ្យគេនាំព្រះអគ្គម្ចាស់អាលីទៅព្រះដំណាក់ព្រះនាងមួយរំពេច ។ ព្រះ
អង្គម្ចាស់អាលីសោយទំពុងនឹងអម្បិលគ្រាប់ហើយក្រោកឡើងសូត្រធម៌ជា
ក្រោយបង្អស់ម្តងទៀត ។ នាងមាជិនាចើបដៃទ្រង់ ហើយក៏និយាយ
ទូលទ្រង់ថា. "អ្នកស្រី! ខ្ញុំសូមអង្វរចិត្តអ្នក ឲ្យអ្នកទៅសំពត្ត
នៅដំណាក់ព្រះនាងយប់នេះ" ។ ទ្រង់អាលីមានបន្ទូលថា "ដូច្នេះក៏
បាន" ទ្រង់ក្រោកឡើងហើយដើរចូលទៅកន្លែងបន្ទប់ព្រះនាង។ ឃើញ
ស្តេចចូលទៅក៏ស្ទុះមកចើបដៃទ្រង់ដោយគោរព ។ ទ្រង់អាលីគ្រាស់
បង្គាប់ថា: "យកខ្នើននេះទៅឲ្យឆ្ងាយពីខ្ញុំទៅ" ក្រោយនោះទ្រង់
ដោះសំលៀកបំពាក់ធ្វើអំពីពេមចៀម ទុកតែអាវទ្រនាប់ ។ ព្រះនាង
ដោះអាវក្រៅចេញហើយក៏ចូលទៅ ព្រះនាងនឹងនាងមាជិនាដេកអមព្រះ
អង្គម្ចាងម្នាក់ ។ កាលណោះនាងមាជិនាក្រោកមុន ឃើញមើលស្គាល់ជា
ស្តេចអាលីពិត ក៏និយាយទៅកាន់ទ្រង់ថា: "ឱ! ព្រះម្ចាស់ថ្លៃអើយ!
ទ្រង់មិនគិតដល់ដំរែតទ្រង់ទេឬ ឃើញជាហ៊ានយកដំរែតមកវង្វេងដល់ទីនេះ?
យាយថាសម្លាប់ដ៏យដំនះ កងការប្រឹងចាយប្រវ័ញ្ចន៍" ។ បន្ទាប់
មកនាងច្រៀសំយ៉ាងមួយនឹងទ្រង់លុះដល់ព្រឹក ។ តមកទ្រង់អាលីតើន

ឡើងហើយកាវនាធម្មិហើយអង្គុយធ្វើព្រងើយ ។ នៅពេលនោះ ព្រះមហាក្សត្រជាព្រះវរបិតានៃព្រះនាង ទ្រង់យាងចូលទៅទាញដៃទ្រង់ អាលីមកថើបដោយគោរព ។ ព្រះនាងក៏ទូលព្រះរាជាថា: "យើងខ្ញុំបានបរិភោគជាមួយគ្នាទាំងអស់ពីល្ងាចម្សិលមិញ" ។ នាងមាជិនាដឹកដៃយាយដីក្រែងក្មាយនាំទៅឯផ្ទះសំណាក់ធម្មិ នាងធ្វើតយកតុកាសស្ងាត់នោះទូលទ្រង់ថា: "ដល់ពេលសោយបើកាលណាគេយកក្រយាស្វាយមកថ្វាយទ្រង់ សូមទ្រង់កុំសោយ ហើយទ្រង់ធ្វើពុតថាទ្រង់ប្រឈួនបេះដូង, បើកាលណាគេសួរទ្រង់ថាទ្រង់ចង់សោយអ្វី សូមទ្រង់ថ្លែងគេវិញថា: ចង់ស្មោយក្រូចជូ នោះព្រះនាងមុខជានឹងប្រើបំរើឲ្យរត់រកទិញពេញទាំងក្រុងពុំខាន ហើយខ្ញុំម្ចាស់នឹងទូលតបព្រះនាងវិញថា: "ព្រះនាងរកបាន ដោយបង្គាប់ទៅពួកអាវក្សីបំរើព្រះនាងយកចិញ្ចៀនមកប្រើការទៅ" កាលណាខ្ញុំម្ចាស់ឃើញព្រះនាងយកចិញ្ចៀនពីកន្លែងណាហើយ ខ្ញុំម្ចាស់នឹងរកឧបាយលួចចិញ្ចៀនមកថ្វាយទ្រង់ឲ្យបានពុំខាន" ។ ព្រះអគ្គម្ចាស់អាលីទ្រង់ព្រះសណ្ដាប់ហើយឆ្លើយថា: "ចុះឧបាយអ្វីក៏ប្រសើរម្ល៉េះ" ។

លុះដល់ពេលក្រយាស្មោយល្ងាច យាយដីក្រែងក្មាយក៏ធ្វើតាមបណ្ដាំនាងមាជិនា ។ ព្រះនាងមានព្រះបន្ទូលសួរថា: "អ្នកត្រូវការអ្វី?" ។ យាយដីក្រែងក្មាយឆ្លើយថា: "ក្រូចជូ" ។ ព្រះនាងមានបន្ទូលថា:

"ទៅកេរិញនៅកន្លែងនេះមក" ។ ពេលនោះនាងមាដ៏នា ក៏ឆ្លើយ
តបក្នុងមាថា: "បពិត្រព្រះនាងដ៏ប្រសើរ! ព្រះនាងអាចប្រើពួកអាក្សែ
ឲ្យទៅកេរបាន ហេតុម្តេចបានជាព្រះនាងមិនប្រើឲ្យវាទៅយកក្រួចដូចនេះ
ស្រុកអៀកក់ យកមកជូនគាត់ទៅ" ។ ព្រះនាងតបថា: "ព្រះគុណ
អើយ! ឯងនិយាយនេះត្រូវមែន!" គ្រាស់ហើយព្រះនាងក្រេងក្រោក
ឈរឡើង ហើយទាញកូនសោមួយពីក្នុងអាវព្រះនាងប្រគល់ទៅឲ្យនាង
មាដ៏នា ហើយមានព្រះបន្ទូលថា: "មាដ៏នាចូរឯងទៅបើកបន្ទប់តូចនោះ
ហើយយកដណ្តើរមួយដែលមានកំពស់ ១០ ម៉ែត្រយកទៅដាក់លើគ្រែនៃ
មហាប្រាសាទ" ។ បន្ទាប់មក ព្រះនាងក្រេងចូលទៅយកថង់មួយហើយ
ទាញយកកូនសោមួយ រួចព្រះនាងយកទៅបើកទ្វារបន្ទប់តូចមួយ ។
ព្រះនាងបើកប្រអប់មាសមួយហើយយកកូនប្រអប់តូច ១ ទៀតធ្វើអំពីភ្លុក
រុំខ្នើមាស ហើយព្រះនាងយកចិញ្ចៀនពិព្រោះចេញមក ។ រួចព្រះ
នាងចុះដណ្តើរមកវិញក្រេងចូលទៅសំងំក្នុងបន្ទប់តូចមួយ ។ មួយស្របក់
ក្រោយមកនាងមាដ៏នា កាន់ចានក្រួចដូដែលមាននៅក្រែងអៀកក់ ដើរ
ចេញមក ។ នាងយកទៅដាក់នៅមុខព្រះកំភ្លឺព្រះអង្គម្ចាស់អាលីហើយ
ទូលក្រេងដោយខ្សឹបៗថា: "ខ្ញុំម្ចាស់ស្គាល់កន្ទៃដ៏ទុកចិញ្ចៀនហើយ" ។
ក្នុងខណៈ ព្រះនាងមានព្រះបន្ទូលថា: "អញ្ជើញអ្នកពីសា!" ។
ព្រះអង្គម្ចាស់អាលី ថ្វាយបង្គំព្រះជាម្ចាស់ហើយ ទើបស្តេចសោយ ។

នាងស្នំក៏ថយចេញទៅ ព្រះអង្គម្ចាស់អាលីទ្រង់រំពៃព្រះនេត្រចាំមើលព្រះនាង ។ ក៏ទ្រង់យាងឡើងលើដណ្តើរយកចិញ្ចៀនទៅខុក ហើយដោយព្រះនាងមានព្រះហឫទ័យរីករាយពេក ព្រះនាងខុកកូនសោនៅកន្ទែងដដែលហាក់ដូចជាព្រះដម្ចាស់ដែលប្រគល់ដោយធន្លុះលួមកជួយទ្រង់ ។ បន្ទាប់មក ព្រះនាងក៏ចេញមកមានព្រះបន្ទូលសួរទ្រង់អាលីថា: "ម្តេចទៅអ្នក?" ។ - ព្រះនាងដ៏ឧត្តម! ខ្ញុំម្ចាស់ស្រួលទេ ប៉ុន្តែយប់នេះខ្ញុំម្ចាស់ចង់ទៅខួលទានដំណេកឯផ្ទះខ្ញុំម្ចាស់ ដើម្បីកុំឲ្យមានន្រណាទៅវិញ" ។ ព្រះនាងក៏ចូលទៅផ្ទំក្នុងបន្ទប់ព្រះនាងទៅ ។

នាងមាជិនាមកដល់ភ្លាម នាងឃើញដណ្តើរ ឃើញកូនសោនៅនឹងទ្វារ ហើយក៏ទៅផ្តាស់ព្រះអង្គម្ចាស់អាលីថា: "សូមទ្រង់តេនឡើងការយើងបានសំរេចហើយ" ។ ព្រះអង្គម្ចាស់ទ្រង់តេនឡើងដោយមិនចង់ជឿដល់សិរីសួស្តីផង ទ្រង់ស្រែកឡើងលើដណ្តើរ បើកទ្វារនាំយកប្រអប់មាសហើយយកចិញ្ចៀនមកសឹកនៅមាមព្រះហស្តទ្រង់ ទើបទ្រង់យាងមកទីកន្លែងទ្រង់វិញ ដោយមាននាងមាជិនាដើរតាមក្រោយ ។ នាងមាជិនាទូលទ្រង់ថា: "ព្រះអង្គម្ចាស់ក្សត្រ ទ្រង់បានសន្យាថាមិនបោះបង់ចោលខ្ញុំម្ចាស់ទេ" ។ ទ្រង់អាលីឆ្លើយថា: "អញបានតាំងសន្យាថាមិនក្បត់ឯង ហើយទឹងការឯងយកធ្វើជាប្រពន្ធផង អញទឹងប្រគល់រាជសម្បត្តិឲ្យផង ដោយអញមានបំណងច្បាស់ថាតែចិញ្ចៀនប៉ុណ្ណោះ

នេះជាការណ៍ដែលអញអាចធ្វើបាន" ។ នាងស្នំសុំនៅលុតជង្គង់ថើបព្រះហស្តខ្ចង់ ។ ក៏បង្គាប់នាងថា "មាដិនា! ចូរឯងដកខ្នងចេញពីកន្លែងនេះសិនទៅ" ។ ក្រោយនោះព្រះអង្គម្ចាស់អាលីជាក់ចិញ្ចៀនទៅលើដីហើយពោលថា: "ចេញមកម៉ែមួន! ។ អាវក្សបង្ហាញខ្លួនភ្លាម ខ្ទនគំនាប់ខ្ចង់ហើយមានវាចាថា: "ព្រះអង្គម្ចាស់! ខ្ញុំលព្រះបង្គំជាខ្ញុំមានសេចក្តីលំបាកណាស់ កាលដែលព្រាត់ចេញពីខ្ចង់ទៅ, ប៉ុន្តែខ្ចង់ជាបស្រាប់ហើយឲ្យខ្ញុំលព្រះបង្គំធ្វើម្តេច បើខ្ញុំលព្រះបង្គំជាប់រើចិញ្ចៀននេះហើយត្រូវតែស្តាប់បង្គាប់អ្នកណាដែលជាម្ចាស់ចិញ្ចៀននេះ" ។ ខ្ចង់អាលីថ្វៃងសេចក្តីអរគុណចំពោះអាវក្ស ហើយខ្ចង់បង្គាប់ថា: "នៅព្រឹកស្អែកនេះ ខ្ញុំចង់ឲ្យឯងរកអស្សកោទិបាន ១ ពាន់នាក់ ដែលមានរូបភាពជាមនុស្សហើយសុទ្ធសឹងពាក់ស្រោមដៃកែវមានកាន់ធាប កាន់ស្គរនឹងកាន់ខ្ចង់ដ៏យគ្រប់គ្នាផងមកឡោមខ្ញុំក្រុងនេះ" ។ ម៉ែមួនទទួលថា: "ព្រះករុណាថ្លៃពិសេស" ។ អាវក្សក៏រលាយបាត់ទៅវិញ ។ មួយស្របក់ក្រោយមកអាវក្សបង្ហាញខ្លួនឲ្យឃើញ ហើយទូលខ្ចង់ថា: "ខ្ញុំលបង្គំបានធ្វើតាមព្រះពាលបញ្ជាស្រេចអស់ហើយ" ។ ខ្ចង់អាលីឆ្លើយថា: "សូមឲ្យព្រះដ៏មាំ បុណ្យជួយខ្ចង់ខ្ចង់ឯង" ហើយខ្ចង់មានបន្ទូលថែមទៀតថា: "ចូរឯងយកកូនសោនេះទៅជាក់កន្ថែងដ៏ព្រះនាងដោយកុំឲ្យព្រះនាងដឹងឲ្យសោះ ដើម្បីកុំឲ្យនាងមាដិនាត្រួយបារម្ភណ៍" ។

ម៉ែមួនក៏ធ្វើតាមបង្គាប់ ទ្រង់អាលីក្រោកឡើងដាក់ដណ្តើរឲ្យដូចដើមវិញ ហើយក៏បង្គាប់ទៅម៉ែមួនទៀតថា: «ម៉ែមួន! អញចង់ចាន់សេះខ្មៅមួយមានពាក់កងកមាស ហើយនឹងសំពត់អាវដូចជាសំពត់អាវស្តេច» ។ ម៉ែមួនយកមកថ្វាយទ្រង់ភ្លាម ។ ព្រះអង្គម្ចាស់អាលីឡើងគង់សេះហោះសំដៅទៅក្រៅក្រុង ហើយចុះទៅដឹតពួកពលដែលឃើញហាក់ដូចជារបងដែកសុទ្ធ គ្រាន់តែសំរែកសេះធ្វើឲ្យញាប់ញ័រគាំងប្រចំពី ធ្វើឲ្យទ្រង់អាលីមានសេចក្តីរីករាយពន់ពេក ។

ព្រឹកស្អែកឡើង ពួកពលទាំងប៉ុន្មានដើរទន្ទ្រានចូលក្រុង គេឮសូរតែសំណូរធាបត្រែហើយនឹងការចលាចលកំរើកឡើងយ៉ាងសំបើម ។ ពួកពលរដ្ឋល្មុះឮសូរសន្ធឹកដូច្នេះនាំគ្នារត់ឡើងដិះសេះពាល់រូប ។ ព្រះមហាក្សត្រក៏តើនឡើងដែរ ហើយទ្រង់យាងចូលទៅកន្លងបន្ទប់ព្រះពជបុត្រីដើម្បីនឹងប្រាប់ហេតុមហន្តរាយនោះ ។ ព្រះនាងទូលសួរព្រះវរបិតាថា: «ចុះខ័ពរបស់អ្នកណាអេះ?» ។ ព្រះមហាក្សត្រតបថា: បិតាមិនស្គាល់ទេ» ។ ព្រះនាងទូលព្រះមហាក្សត្រទៀតថា: «សូមព្រះវរបិតាកុំខ្វាច ខ្ញុំម្ចាស់នឹងចំណាយវាចេញអស់ជាន» ថាហើយ ព្រះនាងយាងឡើងទៅលើប្រាង្គប៉ែកខ្ពស់រកមើលចំញ្ជើន ប៉ុន្តែពុំឃើញសោះ ព្រះនាងត្រឡប់ចុះមកវិញដោយមានសេចក្តីតក់ស្លុតជាខ្លាំង ហើយក៏ត្រាស់សួរថា: «មាដិនាងឯងដឹងចំញ្ជើននាងណាឬទេ?» ។ នាង

ស្តេចឆ្លើយថា: "ព្រះនាង! កាលដែលខ្ញុំម្ចាស់បែកចេញពីព្រះនាងទៅ ទ្រង់បានចាត់សោកុះហើយតើ" ។ ព្រះនាងមានបន្ទូលទៀតថា: "ឯងនិយាយត្រូវហើយ ប៉ុន្តែឥឡូវនេះ អាត្មាវិលមកលួចយកទៅបាត់ទៅហើយ" ។ ព្រះនាងក៏ចូលទៅក្រាបបង្គំទូលព្រះវរបិតា ក្ងេចគតសង្ស័យដល់យាយជីក្នែងក្លាយ ។

ព្រះមហាក្សត្រឡើងគង់សេះចេញទៅក្រៅទីក្រុង ពួកទ័ពទាំងពីរទំរៀបគ្នាជាជួរ ដើរឈមមុខទៅរកគ្នា ។ ព្រះពជាក៏ហៅបំរើម្នាក់មកថា: "ឯងទៅមើលមើ! ពួកអស់នោះវាមានការអ្វី ហើយនឹងមើលឲ្យច្បាស់ តើទ័ពរបស់អ្នកណា?" ។ បំរើលុះទៅដល់ជិតទ័ពបច្ចាមិត្តស្គាល់ច្បាស់ជាព្រះអង្គម្ចាស់អាលី ហើយវត់ចាញ់ដើរត្រឡប់មកវិញ ។ ព្រះពជាឆតយល់ដូច្នោះ ត្រាស់សួរថា: "មានអ្វីដេញតាមក្រោយបានជាឯងរត់លឿនម្ល៉ះ?" ។ បំរើឆ្លើយថា: "ស្តាប់ហើយ ក្រាបទូលព្រះករុណាថ្លៃវិសេស! ព្រះអង្គម្ចាស់អាលីដែលជាស្វាមីនៃព្រះពជ-ធិតា ព្រះអង្គ ទង់លើកទ័ពមកច្រើនអនេកបញ្ជាការ ហើយប៉ងមកចាប់ព្រះពជា នឹងព្រះពជបុត្រីទ្រង់ព្រះសណ្តាប់ដូច្នេះហើយ ទ្រង់ព្រះខ្សែជាខ្លាំង ។ ព្រះនាងមានបន្ទូលទាំងខ្ជឹកខ្ជួលថា: "ឥតគិតមកសង៏សិកយើងគាលតែបាន" ។ ព្រះពជាបរពលសង្ឃឹញទៅទល់នឹងទ័ពបច្ចាមិត្ត ។ ទ័ពទាំងពីរពួក

ប្រយុទ្ធគ្នាយ៉ាងសំបើម ។ ប៉ុន្តែពួកជននៅក្រុងនោះធន់មិនបានដោយ
ត្រូវពួកអាវក្រៅកាប់ផ្តាច់ជាពីរកំមាន កាប់ខ្លួចខ្លីកំមាន កំរត់រាត់រាយ
អស់ ។ ព្រះរាជាត្រឡប់ចូលមកក្នុងព្រះបរមរាជវាំងវិញ ហើយគង់ចាំ
ជោគវាសនាជាមួយនឹងព្រះរាជបុត្រី ។

មៃមួននឹងអាវក្រៀ ១ រយនាក់ទៀតមាំគ្នាមកប្រាន់បំបាក់ទ្វារវាំងហើយ
ចាប់ព្រះរាជានឹងព្រះរាជបុត្រីយកទៅថ្វាយខ្នង់អាលី ។ មានព្រះបន្ទូល
ទៅព្រះនាងយ៉ាគូតាថា: « ស្រីចង្រៃ ! ម៉េចហ៊ានយើញព្រះរាជាម្ចាស់
លោកផ្តន្ទាហ៊ានទើតពុកហ៊ានយ៉ាងណាប្លុះ » ។ បន្ទាប់មកខ្នង់
បង្គាប់ឲ្យអាវក្រៀម្នាក់ចាប់ព្រះនេត្រយ៉ាគូតា ទៅធ្វើការុណកម្មយ៉ាងសំបើម
ហើយខ្នង់ពត ១ ដារហើយធ្វើឲ្យក្បាលហើរដាច់ចេញពីខ្លួន ឯចំណែក
ព្រះមហាក្សត្រជាបិតាក៏ជាន់ខ្លួនឯងមរណភាពយ៉ាងនេះដែរ ។

ស្រេចហើយខ្នង់ប្រើឲ្យយកបរស់យ៉ាងប្រសើរទៅដូនយាយចាស់
ដែលបានជួយគិតការខ្នង់ ហើយហៅនាងមាជិនា មកសួរថា: « មាជិនា !
ឯងចង់ឲ្យអញយកឯងធ្វើជាអ្វី ?» ។ នាងស្នំឆ្លើយថា « សូមខ្នង់ធ្វើតាម
សេចក្តីដែលខ្ញុំម្ចាស់បានទូលសុំព្រះអង្គ » ។ ខ្នង់អាលីបានព្រះស-
ណ្តាប់ហើយ ប្រើឲ្យហៅមនុស្សគ្រូជាសាកី ទើតាមឹមកសរសេរកិច្ច
សន្យាអាពាហវិវាហមង្គលខ្នង់នឹងនាងមាជិនា ។ ព្រះអង្គម្ចាស់ទើនាង
ក៏រួមសេចក្តីសុខជាមួយគ្នា ព្រមទាំងមានសេចក្តីត្រេកអរជាពន្លឹកន ។

ក្រោយមក ព្រះបាទអាលីមានព្រះតម្រាស់ហៅម៉ែមូនមកប្រាប់ថា: "អញចង់ឲ្យឯងទៅក្រាបទូលព្រះពុទ្ធអញតាមពាក្យថា: អញបានសោយរាជសម្បត្តិនៅនគរនេះ" ។ ម៉ែមូនទទួលតាមព្រះរាជបញ្ជាហើយ ហោះទៅតម្រង់នាំសេចក្តីនោះទៅទូលព្រះពុទ្ធគោតមពីព្រះអង្គ ។ ព្រះពុទ្ធតាមពីក៏មានបន្ទូលផ្តាំផ្ញើមកវិញថា: "ចូរឯងទៅគំនាប់នឹងថើបដៃទ្រង់ចំនួនយើងផង ហើយទូលទ្រង់ថា យើងសូមកុំឲ្យទ្រង់ភ្លេចយើងតាមពីរឲ្យសោះ" ។ អាស្រ័យម៉ែមូន ក៏ហោះត្រឡប់ទៅទូលព្រះបាទអាលីតាមពាក្យបណ្តាំនៃព្រះពុទ្ធតាមពីរវិញ ។

បន្ទាប់មកទៀត ព្រះបាទអាលីក៏ត្រាស់ប្រើបំរើឲ្យទៅអញ្ជើញតាថាស់ដែលបានឲ្យផ្ទុះទ្រង់សំណាក់នឹងអ្នកលក់គ្រឿងក្រអូប ហើយទ្រង់សំដែងអាការគោរពនឹងប្រាប់អានជ័ប្រសើរ ។ ព្រះបាទអាលីក៏ទៅសោយរាជសម្បត្តិជាមួយនឹងនាងមាជិនា ដោយសួស្តីជាបជរាអស់ជីវិតន្ត ។

ចប់ រឿងចិញ្ចៀនទិព្យ

លោក ផេង-ជ្រៃ សាស្ត្រាចារ្យ នៅសាលាគរុកោសល្យ ភ្នំពេញ

ប្រៃរៀបរៀង

(តបបំ តពីខ្សែលេខ ១០ មក)

កន្លែងនោះ នៅចំកណ្តាលភោះ មានព្រៃតូចដុះព្រិញ គេមើលសមុទ្រក៏មិនឃើញ កំពង់ផែល្វីក៏មិនឃើញ រីហារបុំប្លេមុះក៏មិនឃើញ អ្វីដែលនាំឲ្យអាប៉ូលរលឹកនាងវ៉ែរ៉ូនី គឺគ្មានទាំងអស់ ។

នៅទីស្ថាននោះហើយដែលខ្ញុំនាំអាប៉ូលយកទៅទុក ។ ខ្ញុំមិនហ៊ានឲ្យវានៅស្ងៀមឡើយ គឺឲ្យវាដើរជាមួយនឹងខ្ញុំ ហាលថ្ងៃ ហាលភ្លៀង ទាំងទិវាតត្រីឥតឈប់ឈរ ខ្ញុំនាំវាធ្វើដូចជាវង្វេងក្នុងព្រៃ នាទីដើម្បីបំភ្លេចនឹកនាថ្មី ក្នុងចំការទាំងឡាយ ដើម្បីបំភាន់គំនិតវា ដោយការខ្វែងហត់កាយខាងក្រៅ ទឹងប្លែគំនិតឲ្យទៅជាគំនិតគិតពិចារណារកព្រោះភ្លេចកន្លែងដែលយើងដើរនឹងចាត់ផ្លូវដែលមក ។ តែគ្រាន់ព្រលឹងនៃសង្សារ គោះទៅនៅទីណាគង់មិនភ្លេច: ស្នាមគំនូសនៃវាជាទីស្រឡាញ់ ។ យប់នឹងថ្ងៃ ការសូបស្មាត់នឹងសំឡេងអ្នកស្រុកទាំងឡាយ ទាំងពេលវេលាក៏ដោយដែលសម្រាប់បន្ទាត់បង់នូវសេចក្តីរលឹកគប់យ៉ាងសភាវៈទាំងឡាយនេះ មិនអាចបំបែកចិត្តអាប៉ូលបាន ។ សេចក្តីខាងលើនេះ ប្រៀបដូចម្ជុលដែលគេយកទៅឲ្យប៉ះនឹងមេដែក ហើយគោះ

បីគេយកទៅចុកស្បៀមក៏វានៅតែញ័រ រីលកមេដែកដែលសម្រាប់ទាញ
វាទៅ ។ កាលដែលយើងនៅកន្លែង ហើយវង្វេងផ្លូវក្នុងភូមិ រីល្ងាំ ខ្ញុំសួរ
វាថា: "ឥឡូវនេះ តើយើងនឹងវាកទៅទិសខាងណាវិញ? " ។ វាបែរទៅ
ខាងដើងហើយ ឆ្លើយខ្ញុំថា: "ខ្ទុះនក្តុំយើង ចូរយើងត្រឡប់ទៅវិញ" ។

ដល់ឃើញឯចឹង ខ្ញុំគិតថា ចុះយកលាងប៉ុន្មានដែលខ្ញុំយកមកប្រើ
ដើម្បីបន្ទំវាឥតបានការ ។ ដូច្នេះ នៅសល់តែតម្រិះមួយគឺព្រលែង
ចំត្រង់ចំណង់វាតែម្តង តែមិនដឹងជានឹងកើតការឬទេ ព្រោះគាល់
ច្រាជ្រហើយ ។

ខ្ញុំឆ្លើយទៅវិញថា: "មែនហើយ! អើ! កុំហ៊ឺនហើយដែលនាង
កញ្ញា វ៉ីស៊ីនី ធ្លាប់ទៅពីដើម រួចនេះនៃកូន! រូបដែលឯងបានឲ្យទៅ
នាង ហើយវេលានាងស្លាប់ទៅយើងឃើញពាក់ជាប់នៅនឹងខ្លួននាង" ។
ខ្ញុំបង្ហាញកូនរូបទៅវា គឺរូបហ៊ឺនហើយដែលអាប៉ូលឲ្យទៅ វ៉ីស៊ីនី នៅ
ក្បែរកំពង់ទឹក ក្រោមដើមដូង ។ ក្រឡេកឃើញរូបនេះ វាញញឹម
សួត ។ វាទទួលយកប្រញាប់ប្រញាល់ ដោយដៃទាំងពីរ ញ័រញ័រ
លើកដាក់ដល់មាត់ ។ ថ្ងូរបុកផ្អូក ទឹកភ្នែកចាប់ហូរទៅជាធ្លាក់មក ។

ខ្ញុំប្រាប់ថា "នែកូន! ចូរអ្នកស្តាប់ខ្ញុំជាមិត្តរបស់អ្នកទនឹងនាង វ៉ីស៊ីនី
ហើយជាអ្នកយកចិត្តទុកដាក់ខ្ចីបង់ជួយពន្យល់ ទាំងការពារនឹងគ្រោះថ្នាក់
ទាំងឡាយដែលបំរុងនឹងមានឡើងដល់ជីវិតអ្នក នាកណ្តាលសេចក្តី

ច្រើនជាងនេះទៅទៀត ដែលអ្នកត្រូវការស្មើរតែជាប់ជីវិតខ្លួន ។ ប៉ុន្តែអ្នកស្រណោះស្រណោកអ្វីខ្លាំងម្ល៉េះ? តើជាទុក្ខផ្កាល់ខ្លួនឬ? ជាទុក្ខអំពី រ៉ាស៊ូនី? តើជាទុក្ខផ្កាល់ខ្លួន! ច្បាស់ជាមែនហើយ ទុក្ខហ្នឹងធំមែន ព្រោះអ្នកព្រាត់ចាកស្រីជាទីបេតី ជាស្រីគួរជាងស្រីទាំងពួង ។ នាងនោះស៊ូលះបង់ប្រយោជន៍ផ្កាល់ខ្លួន ដើម្បីជាប្រយោជន៍ដល់អ្នក ហើយស៊ូលះបង់សេចក្តីសុខឲ្យតែបានច្រំនឹងរូបអ្នក គឺខ្លួនអ្នកជួបជារង្វាន់មួយគួរដល់ចិត្តធម៌របស់នាង ។ តើអ្នកឯងដឹងទេ វត្តណាដែលអ្នកត្រូវការចង់បាន សេចក្តីសុខដ៏បរិសុទ្ធិហើយត្រឡប់បណ្តាលឲ្យកើតអណ្តឹងគឺសេចក្តីទុក្ខរាប់មិនអស់វិញ, វាគ្មានសុខទេ ចៃមទាំងច្បាស់ថាសមត្តិផងហើយចាប់តាំងពីបានគ្នាជាប្តីប្រពន្ធវេលាណា អ្នកត្រូវខំធ្វើការយ៉ាងខ្លាំយហត់ជាមួយគ្នា ។ នាងនោះត្រឡប់ខ្សោយកំឡាំងដោយការបង្ហាត់បង្រៀន តែមានចិត្តក្លាហានដោយសារមានទុក្ខញាយ។ ហើយអ្នកតែងឃើញនាងនោះទ្រុឌទ្រោមទៅរាល់ថ្ងៃ មកពីខំជួយខ្លាយហត់លំបាកជាមួយគ្នា ។ កាលណាមានកូន សេចក្តីទុក្ខរបស់នាងនឹងអ្នកតែតែចំរើនច្រើនឡើង ព្រោះលំបាកវេចខ្ចប់តែគ្នាពីនាក់តាំងម្តាយផង តាំងកូនបេះតែកើតច្រើនឡើងផង ។

អ្នកឯងមុខជាឆ្ងើយថា: « ឈប់ចៅហ្ស៊ាយនឹងជួយទុក្ខបុរុង » ។

អ្នកដឹងប្អូនទេ នៅស្រុកចំណុះ អ្នកពាជការផ្ទាស់ប្តូរជាធម្មតា ដ៏អ្នកស្មានថាលោក ប្តូរដុំណែ ធ្វើការនៅទីនេះជានិច្ច? ចុះបើថ្ងៃក្រោយលោកចៅហ្វាយថ្មីត្រូវផ្ទាស់មកគ្មានចិត្តធម៌ក្នុងខ្លួន, ហើយចុះ បើចង់បានឲ្យគេជួយទុក្ខធុរៈបន្តិចបន្តួច តើត្រូវធ្វើដូចម្តេច មានតែគោរឲ្យប្រពន្ធអ្នកទៅគំនាប់គាប់គូរនឹងគេ, ចុះបើនាងនោះចិត្តទន់ពេក អ្នកឯងនឹងមិនកើតទុក្ខទៀតហើយ ឬបើនាងចិត្តស្មុតត្រង់ អ្នកមុខជាត្រូវនៅតែក្រលំបាកជាដរាប! សប្បាយមែន បើប្រពន្ធអ្នកមានរូបល្អ ចិត្តប្រកបដោយធម៌ ហើយខ្លួនអ្នក លោកចៅហ្វាយមិនធ្វើទុក្ខបុកម្នេញ គេជួយទំនុកបំរុងដោយល្អ ។

អ្នកមុខជាឆ្លើយមកទៀតថា: "នៅសល់សេចក្តីសុខម្យ៉ាង: មកពីខ្ញុំឈប់ត្រូវការចង់មានចង់បាន គ្រាន់តែទំនុកបំរុងវត្តជាមួយស្រឡាញ់ដែលជាប់ដំណាក់ជាមួយគ្នា សមគួរដល់ចំណង់ក គ្រាន់តែថ្នាក់ថ្នមលួងលោមវត្តនោះដោយការប្រឹងប្រែងញាប់ញ័រដៃដើង គ្រាន់តែធ្វើឲ្យវត្តនោះរីករាយ ដោយចិត្តខ្ញើយព្រួយទឹងបង្កើតចិត្តស្នេហា ដោយការខ្ញើយលំបាកជួយគ្នាទៅវិញទៅមក ។ មែនពិតចិត្តធម៌ទឹងចិត្តស្នេហាតើតមកពីសេចក្តីរីករាយល្អឯងណ៎ ។ ឥឡូវធ្វើម៉េច នាងបាត់បង់ទៅហើយ នៅសល់តែម្តាយនាងនឹងម្តាយអ្នក ដែលអ្នកនឹងជូនដំណើរទៅកាន់លោកខាងមុខប្រកបដោយសេចក្តីទុក្ខប្រៀបពុំបាន ។ ចូរអ្នកឯង

ទំថែរក្សាអ្នកដ៏មានគុណចាំដ៏ពីរឲ្យបានសុខដូចជាលោកធ្វើឲ្យអ្នកបានសុខ
មកយូរហើយ ។ អំពើល្អជាសុខម្ល៉ាងតើតមកពីចិត្តធម៌ ។ គ្មានសេចក្តី
សុខណាទៀងទំដ៏ធំជាងសេចក្តីសុខនោះឡើយ នៅលើផែនដី ។
គំនិតជ្រាបថាបានសេចក្តីភ័យ តើតមកពីការសម្លាក សេចក្តីភ័យ
ដ៏ក្រៃលែង សម្បត្តិសុភសុភ្ម ចុំថ្កើងដោយយុសស័ក្តិ របស់ទាំងនេះមិន
មែនតើតសម្រាប់មនុស្សសាមញ្ញជាអ្នកដំណើរដ៏ខ្សត់ខ្សោយទេ ។ ឯង
ឃើញឬទេ គ្រាន់តែឈានដំហានមួយសោះសំដៅរកធនធានប៉ុណ្ណោះ
វាច្រានយើងដជ្រុលដជ្រកវាមៀលដាំតដាំតួង ធ្លាក់ពីរណ្តៅមួយទៅ
រណ្តៅមួយ ។ អីខ្ញុំថាដូច្នេះ អ្នកឯងយល់ថាសំឬ ? រឿងនេះពិត
ណាស់ ឃើញឬទេ អ្នកណាមិនស្មានថាដំណើរនាងកញ្ញាវីស៊ូនីបាន
ដល់នៅទីបំផុត ត្រូវបានសេចក្តីសុខស្រួលចាំងរូបនាង ចាំងរូបអ្នក,
ម្ចាយមិងចាស់ចាំងមានទ្រព្យច្រើនហៅទៅ ពាក្យពន្យល់របស់លោក
ថៅហ្វាយដ៏ស្ងួតត្រង់ ពាក្យឲ្យពរសព្វសាធុការនៃអ្នកស្រុកចាំងឡាយ
ក្នុងកោះ លោកសង្ឃមួយអង្គ ជួយនិយាយបន្ថែមឆ្លើយប្រើអំណាចព្រះជា
ម្ចាស់ទៀត ឲ្យតែនាងបានទៅ ព្រោះចង់ឲ្យនាងសុខស្រួល ប៉ុនជា
បបួលគ្នាបញ្ជូននាងឲ្យដល់នូវសេចក្តីទុក្ខធំបំផុតកែមិនឡើងទៅវិញ ។
ហេតុដូច្នេះ យើងកាលរូបបានទូវសេចក្តីវិនាស ព្រោះតែភ័ន្តដោយការ
ប្រយ័ត្នខ្លាំងពេកនៃនាយថៅហ្វាយជាអ្នកត្រួតត្រាក៏មាន ។ បើឯចិត្តត្រូវ

តែកុំជឿទ្បាសោះ ទូវអ្នកទាំងនោះនឹង កុំទុកចិត្តដល់សំដី សេចក្តីសង្ឃឹម នៃលោកទាំងមូល ព្រោះច្រើនកុហក បំភ័ន្ត ។ ប៉ុន្តែបើនិយាយដោយ ជាប់ខាត មនុស្សទាំងឡាយដែលយើងឃើញនៅធ្វើការរកស៊ីសព្វថ្ងៃក្នុង គោះនេះក្តី មនុស្សទាំងឡាយដែលចេញទៅស្វែងសម្បត្តិឯប្រទេសកូរ៉ែក្តី ឬអ្នកណាមួយមិនចេញពីទីកន្លែងខ្លួន នៅទំតែធ្វើការងារក្នុងប្រទេស-នុរុបក្តី មិនមានអ្នកណាមួយចង់ទ្បាសា ឃ្លាតចាកវត្តដ៏ថ្លៃថ្លារបស់ខ្លួនឡើយ គឺបុណ្យយសសក្តិ ទ្រព្យសម្បត្តិប្រពន្ធកូននឹងមិត្តសំឡាញ់ ។ ចំណែកអ្នក ។ មិនត្រូវចិត្តឡើយ ។ ចិត្តនៅតំណោះ ឈាមការ ដូចផ្កាតំពុងរីក មានសេចក្តីស្ងួតត្រង់ល្អព្រមទាំងមានការប្រយ័ត្ន កាន់រៀបអ្នកចេះ ។ មានតែសេចក្តីយល់របស់អ្នកទេ ទើបត្រូវតាមច្បាប់ ព្រោះជាយោបល់ដ៏បរិសុទ្ធិ តាមធម្មតា រៀរចាកប្រយោជន៍ផ្ទាល់ខ្លួន ហើយចិត្តអ្នកដែលមានចំពោះនាងនារី វ៉ែរ៉ូនីន ជាចិត្តឯក គួរកោតក្រែងរកវត្ថុអ្វីយកមកថ្វាយឲ្យស្មើពុំបាន ។ វ៉ែរ៉ូនីន ដែលវិនាសទៅ មិនគឺមកពីសេចក្តីប្រហែសធ្វេសនៃអ្នកក៏ទេ មកពីសេចក្តីកំណាញ់នៃអ្នកក៏ទេ មកពីចិត្តអ្នកគិតខុសក៏ទេ នេះគឺមកពីព្រះជាម្ចាស់ទេតើ ព្រោះព្រះអង្គបណ្តាលចិត្តអ្នកដទៃ ឲ្យមានចំណង់ជូចេះ ដើម្បីដកហូតវត្តជាទីបេតីពីអ្នក ព្រះអង្គដែលអ្នកគោរពកាលថ្ងៃ ទ្រង់ជ្រាបច្បាស់ទូវបេះដែលសមគួរដល់ភាពនៃអ្នក បើជូចេះ អ្នកមិនត្រូវមានវិប្បដិសារីឡើយ អំពីរឿងនេះ ។

សេចក្តីប៉ុណ្ណោះហើយ ដែលអ្នកគួរយកទៅទូន្មានចិត្តថាន់ថាក់របស់អ្នក ខ្ញុំមិនគួរនឹងនិយាយឡើយ ។ នាង រីសុីន មានសេចក្តីទុក្ខរហូតដល់ស្លាប់ខ្លួន រហូតដល់ឥឡូវនេះទៀត អ័ឯងនៅស្រណោះស្តាយ! នាងដែលទទួលអកុសលកម្មនេះ គឺជាអំពើមានមកសម្រាប់ជាតិ សម្រាប់លំអទាំងឡាយរហូតដល់រដ្ឋទាំងមូល ។ ជីវិតរបស់សត្វព្រមទាំងសេចក្តីប្រាថ្នា តែងចំរើនខ្លះទោលើដូចជាប៉មតូចមួយដែលមានកំពូលចុងបំផុតគឺសេចក្តីស្លាប់ ។ អ្នកណាដែលកើត មានទោសត្រូវស្លាប់ទៅវិញ ។ នាងនេះចំជាមានសំណាងល្អហើយស្រួលខ្លួនផង ដែលបានស្រាយចំណងរួចចេញពីជីវិតមុនម្តាយនាង មុនម្តាយអ្នក មុនអ្នក គឺថានាងនេះមិនត្រូវស្លាប់ច្រើនដងមុនការស្លាប់ជាបរិយោសាន ។

នែកូន! មរណភាពជាសម្បត្តិរបស់សត្វទាំងឡាយក្នុងលោក ។ ជាព្រះតិដ្ឋដ៏ធំរបស់ព្រះអាទិត្យ ដែលមនុស្សលោកមានចិត្តញាប់ញ័រមិនឈប់ឈរអំពីជីវិត ។ ជម្ងឺរោគាព្យាធិ សេចក្តីទុក្ខ សេចក្តីព្រួយ សេចក្តីភ័យទាំងឡាយដែលញាំងសត្វលោកឲ្យរំភើបជានិច្ច តែងតែទៅសម្រាកក្នុងនោះនៃសេចក្តីស្លាប់ ។ ចូរឯងពិនិត្យមើល មនុស្សណាដែលដូចជាបានសុខស្រួលគ្មានថើជាងគេ អ្នកនឹងឃើញសេចក្តីសុខនោះមានដំណែរក្រៃពេក គឺការរាបស់អាននៃជនផងទាំងពួង បានមកដោយការនឿយហត់ក្សេរខាងយ៉ាងច្រើន ទ្រព្យបានមកដោយការខំ

ប្រឹងរកភាល់តែស្គមខ្លួន សេចក្តីកែកយដ៏ក្រគើដើម្បីឲ្យជាទីរពាចិត្ត ប្រពន្ធ ជាន់មកដោយការធ្វើមិនគិតខ្លួនប្រាណជានិច្ចកាលថ្ងៃ ហើយ លុះដល់ទីបំផុតនៃកិច្ចដូចជាន់ពោលខាងលើ ដែលខ្លួនចំប្រឹងដើម្បីជា ប្រយោជន៍អ្នកដទៃ មនុស្សនោះច្រើនតែចួបប្រទះតែនឹងជាបមិត្រ ទឹង ញាតិអកតញ្ញូនៅជុំវិញ ។ នាងជាន់សុខស្រួលជាមួយនឹងអ្នក ដោយ អំណាចបុណ្យព្រះជាម្ចាស់នៅឆ្ងាយពីយើង ដោយសារគុណនៃចិត្តធម៌ ហើយក្នុងពេលដែលយើងមានគ្រោះថ្នាក់យ៉ាងធំជាទីបំផុត យើងក៏តង់ ឃើញនាងនៅតែសុខស្រួលដដែល ទោះបីនាងក្រឡេកមើលអ្នកកោះ ទាំងម្ជុលដែលទុក្ខព្រួយដោយសារតែរូបនាង ឬមើលចំមកអ្នកដែលចេះ តែសុំចុះសុំឡើង ដោយចិត្តក្លាហានឥតខ្លាចស្ញប់ដើម្បីនឹងទៅជួយ សង្គ្រោះនាង នាងក៏តង់តាំងចិត្តជាកល្យាណមិត្តដ៏ថ្លៃថ្លាដល់យើងទាំង អស់គ្នាឥតរើសមុខ ។ នាងចំប្រឹងយកសេចក្តីស្លូតត្រង់ពីដើមមកគប់ គល់នឹងអនាគតកិច្ចប្រកបដោយទុក្ខ ហើយនាងជាន់ទទួលវង្វាន់ពីព្រះ-ជាម្ចាស់ដែលទុក្ខសម្រាប់ឲ្យចិត្តធម៌ គឺចិត្តក្លាហានយ៉ាងឆ្នើមនៅចំពោះមុខ នៃគ្រោះថ្នាក់ ។ នាងទទួលយកខ្លួវសេចក្តីស្ញប់ដោយមុខស្រស់ញញឹម ។

. . . . . .

សេចក្តីព្រឺព្រួចក្នុងចិត្តខ្ញុំនឹងពេក នាំឲ្យខ្ញុំឈប់ពន្យល់តែត្រឹម ប៉ុណ្ណឹង ។ ចំណែកអាប៉ូល លោសំឡឹងចំខ្ញុំ ក្អែកក្រឡែតហើយ

ស្រែកថា: "នាងវែកហានទៅហើយ! នាងបាត់បង់ទៅហើយ!" រួចដោយអំណាចអស់កំឡាំងមកយូរហើយ រកស្រែកតទៅទៀតពុំរួច ក៏បាត់មាត់ឈឹងដូចគេសន្ធប់ ។

លុះត្រឡប់ចេតក្លែកឡើងវិញ ក៏និយាយថា: "បើសេចក្តីស្លាប់ជាសម្បត្តិមួយ ហើយនង វ៉ីស៊ូនី ជាស្រីសុខស្រួល ខ្ញុំក៏ចង់ស្លាប់ដែរ ទើងទៅជួបនាងទៀត" ។ ម្នើលទៅ គ្រឿងអាងតាំងប៉ុន្មានដែលខ្ញុំនាំយកមកអធិប្បាយដើម្បីលួងលោម ឃើញថាត្រឡប់ជាធ្វើឲ្យវាំងវិតតែកើតទុក្ខឡើងទៀត ។ ខ្ញុំឧបមាដូចជាបុគ្គលម្នាក់ចង់ស្រង់សំឡាញ់ម្នាក់លង់ទឹកកណ្តាលទន្លេដែលមិនចង់ហែល ។ នេះគឺសេចក្តីទុក្ខពន្លិច ។ សេចក្តីទុក្ខតាំងឡាយនៃជនក្នុងបឋមវ័យ ជាចង្កួយឲ្យបានស្រួលទៅក្នុងវ័យតាំងឡាយខាងចុង តែអាប៉ូល មិនយល់ដូច្នោះសោះ ។

ខ្ញុំនាំគ្នាត្រឡប់មកផ្ទះវិញ ។ គេឃើញម្តាយវាន់ធីនាង ឡាតួរ ចេះតែស្រងូតស្រងាត់ហៅវៅ ។ នាង ម៉ារីតែ មើលទៅ ដូចជាធ្ងន់ជាងគេ ។ ចរិតតាំងឡាយដ៏ហ៊ាសវាងវៃ កាលមានទុក្ខចន្លិចបន្លួច មិនធ្វើជាដឹង ដល់ប៉ះលើទុក្ខព្រួយយ៉ាងធំ ទប់កម្រៃបានណាស់ ។

នាងនេះ មានវាចានិងខ្ញុំថា: "ឧ! មាអើយ! យប់មិញ ខ្ញុំយល់សប្តិឃើញនាង វ៉ីស៊ូនី ស្លៀកសពាក់ស ឈរនៅនាគណ្តាលផ្លាដ៏ល្អយ ឈ្មប់កូនស្លួនច្បារ ។ នាងមានវាចាមកកាន់ខ្ញុំថា . នាងបានសេចក្តី

សុខស្រួលគួរសមណាស់ ។ រួចនាងដើរចូលទៅជិត អាប៉ូល សើចញញឹម។ ហើយចាប់លើកកូនខ្ញុំទៅជាមួយនឹងនាងទៅ ។ ដល់ខ្ញុំចង្រៃឆ្គាញកូនខ្ញុំទុក ដូចជាខ្លួនខ្ញុំហ្នឹងក៏អណ្តែតផុតដើងពីដីដែរ ហោះទៅតាមក្រោយអាប៉ូល ខ្ញុំសប្បាយឥតឧបមា ។ រំលេចដែលខ្ញុំរៀបនឹងលាសំឡាញ់ស្រីខ្ញុំ ស្រាប់តែឃើញនាងព្រមទាំងខ្លួនឯង នឹង ម៉ារី ហោះតាមក្រោយខ្ញុំមកទៀត ។ ហើយរឿងនេះគួរអស្ចារ្យណាស់ គឺកន្លែងដែលនាង ឡាតួរ ក៏យល់សប្តិឃើញដូចខ្ញុំដែរ ,, ។

ខ្ញុំធ្វើឥតឮថា: ,, នែនាងសំឡាញ់! ខ្ញុំយល់ថារបស់អ្វីដែលមានមកក្នុងលោក សុទ្ធតែព្រះអាទិទេពបើកអំណាចឲ្យមកទាំងអស់ ។ ចួនកាលយល់សប្តិហ្នឹងទៀងដែរ" ។

នាង ឡាតួរ ក៏បាននិយាយប្រាប់ខ្ញុំនូវហេតុយល់សប្តិដែលមានទំនងដូចគ្នា នឹងនាង ម៉ារីតើរឹត ហើយក្នុងក្រឹតែមួយ ។ ខ្ញុំមិនទាន់បានសំគាល់អំពីការដឿផ្តេសផ្តាសក្នុងរូបនាងទាំងពីរផង ស្រាប់លោមកប្រទះនឹងយល់សប្តិស្រដៀងគ្នាដូច្នេះ ហើយខ្ញុំយល់ដោយឥតសង្ស័យថាប្រាកដជានឹងឃើញហេតុគេអ្វីមួយយ៉ាងទាន់ហន់នឹងក្បែរជាមិនខាន ។ មនុស្សទាំងឡាយលើផែនដីតែងដឿដូច្នេះដែរ ថាយល់សប្តិ ចួនកាលទៀងប្រាកដណាស់ ។ អ្នកប្រាជ្ញទាំងឡាយពីសម័យបូរាណ ដូចជា: អាឡិក្សង់ (Alexandre) សេសារ (César) កាតុន (Caton) នឹងព្រួយទុះ

(Brutus មានបញ្ជាមិនអន់ប៉ុន្មាន គង់ដឿថាយល់សប្តិមានខ្លែងខ្លះដែរ ។ រឿងខាងសម័យបុរាណនឹងរឿងខាងសម័យបច្ចុប្បន្ន មានថ្លែងជាឧទាហរណ៍ពន់មិនអស់ ពិយល់សប្តិដែលពិត ។ ចំណែកខ្ញុំត្រូវការតែខាងទំលាប់របស់ខ្ញុំ ខ្ញុំបានដឹងជាច្រើនលើកមកហើយដែរ ថាយល់សប្តិជាបុព្វនិមិត្ត ដូចជាប្រាជ្ញរបស់យើងដែលឈ្វេងយល់ការអ្វីមួយឯចឹងដែរ មុននឹងចាប់ធ្វើ ។

រឿងយល់សប្តិរបស់ស្ត្រីជាស់ឡាញ់ខ្ញុំចំជាត្រូវមែន ។ មិនយូរប៉ុន្មាន បានប្រមាណជាពីរខែ អាប៉ូល ចេះតែហៅកនាង វីស៊ុនី ក៏មានជម្ងឺឈឺស្ទាប់ទៅ ។ នាង ម៉ារគីរីត ស្ទាប់ត្រាយ អាប៉ូល ប្រាំបីថ្ងៃ ។ មុននឹងអន្ទិច្ចកម្ម នាងមានសេចក្តីសប្បាយរីករាយក្នុងចិត្ត ព្រោះនាងមានធម៌ក្នុងខ្លួន ហើយបានលះ បានផ្តាំនាង ឡាគ្លូរ ដោយមធុរភាពថា ថាចាំយើងនឹងទៅដួបគ្នាឯស្ថានលើឯណោះ ជាស្ថានមិនចេះព្រាត់គ្នា ។ នាងប្រាប់ទៀតថា: "មរណភាព ជាសម្បត្តិមួយធំជាងសម្បត្តិដទៃទាំងអស់ តែត្រូវចង់បានគ្រប់គ្នា ។ ដ្បិតថាការរស់នៅជាទោស ត្រូវប្រាថ្នាការស្ទាប់វិញ ព្រោះការរស់នៅជាសេចក្តីព្រួយ ជាទុក្ខ ជាសោក ជារោគ ជាភ័យ ជាគ្រោះថ្នាក់ដូច្នេះជាដើម បើឯចឹងត្រូវធ្វើវាឲ្យខ្លី" ។

ភជការដួយចិញ្ចឹម ខំទុកបំរុង ខ្ជូម៉ាំងនឹង ម៉ារីដ្បិតថាស់ពេក ធ្វើការអ្វីមិនកើត ។ មិនយូរប៉ុន្មាន ប្តីប្រពន្ធទាំងពីរក៏ចែកស្ថានទៅដែរ ។

ឆ្កែមួយឈ្មោះ ហ្វីដែល ក៏ស្ទាប់ស្រែកប្រាលគ្នានឹងម្ចាស់វាដែរ ។

ខ្ញុំនាងឯ ឡាតួរ ទៅនោជាមួយនឹងខ្ញុំ ។ ស្រីនេះចេះធ្វើខ្លួនឲ្យ
រឹងប៉ឹងនៅកណ្តាលនៃសេចក្តីវិនាសដ៏ធំ ដោយចិត្តក្លាហាន ស្ទើរតែមិន
គួរជឿ ។ នាងបានលួងលោមប្រដៃប្រដៅខ្លួនាន អាប៉ូល ទីងនាង
ម៉ារគីរីត រហូតដល់ពេលជាទីបំផុត ដូចជានាងគ្មានទុក្ខផ្ទាល់ខ្លួនសោះ
មានតែទុក្ខរបស់អ្នកដទៃ ។ លុះអាប៉ូល ទីង ម៉ារគីរីត ចាត់ចង់ទៅ
នាងនិយាយរឿងជនពាំងពីរថ្ងៃចប់ខ្ញុំពលថ្ងៃ ដូចគ្រានតែជាមនុស្សក្រៅប
អានគ្នាទៅដិតខាង មិនជាប់ចិត្តប៉ុន្មាន ។ ប៉ុន្តែបានមួយខែក្រោយមក
នាងក៏ធ្វើមរណកាលទៅដែរ ។ ចំណែកម្តាយមីងទៅឯប្រទេសចាក់ង
ដែលជាស្រីចិត្តអាក្រក់ ក៏ធ្វើទុរ្ភមរណកាលខាងក្រោយដែលបានបញ្ជូន
នាងវ៉ែស៊ុនី មក ។ មុនទីងស្លាប់ នាងនោះ លំបាកមើលណាស់ ញាក់
ញ័រ មិនដឹងយកទ្រព្យទៅផ្តឹងឲ្យជនណា ណាមួយស្តាយទ្រព្យ
ហើយមានតែបងប្អូនសាច់ញាតិដែលគាត់ស្អប់ ម្ល៉ោះហើយក៏តែងចលា-
ចលកង់ចិត្តគាត់អីម្ល៉ោះទេ រៀបស្លាប់ ។

អាប៉ូល គេយកទៅកប់ក្បែរគុម្ពឬស្សីជិតខ្ទោចនាង វ៉ែស៊ុនី ជាគូសង្សារ
របស់ក ហើយទៅពីខាងក្រៅ គេកប់ខ្ទោចម្តាយកចាំងពីរនឹងឈ្មួល
ពីរនាក់ប៉ុន្តឹមប្រពន្ធ ។ គ្មានឧរណាយកផែនឆ្ងៃទៅដាក់ពិលើផ្នូរហើយចារឹក
ដាក់ឈ្មោះទេ ។ ប៉ុន្តែអំណាចនៃអំពើជាកុសលរបស់គេ តែងមាននៅ
កង់ជួងវិញ្ញាណនៃមនុស្សគ្រប់គ្នា មិនចេះរលាយឡើយ ។ ចប់

បុណ្យឈាបនកិច្ចសពឧបាសិកាវ៉ុត

ព្រះគ្រូសង្ឃសត្តា បុណ្យ-សម្ភាជ រៀបរៀង

កាលនៅថ្ងៃសុក្រទី ១១ ធ្នូ ព. ស. ២៤៩៦ គ. ស. ១៩៥៣ ក្នុងវត្តខេតធីតារាម ក្រុងកំពង់ឆ្នាំង មានធ្វើពិធីឈាបនកិច្ចសពឧបាសិកាវ៉ុត ជាញោមរបស់ព្រះឧបាត់បឧមវង្ស ពុធ-កេត ឧបាត់គណខេត្តកំពង់ឆ្នាំង ។

ក្នុងឧកាសបុណ្យឈាបនកិច្ចនោះ សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ បាននិមន្តទៅជាអធិបតីព្រមទាំងសំដែងធម៌ទេសនា ។ កាលសម្តេចបាននិមន្តទៅដល់វត្តខេតធីតារាម នៅវេលាម៉ោងប្រាំមួយជាប់ប្រាំនាទីរសៀល, ពួកពុទ្ធបរិស័ទជាច្រើននឹងកងជីវពល, កងនារីក្លាហាន ព្រមទាំងអ្នកពាជការទាំងឡាយ មានឯកឧត្តមលីតឹម-ឃុត ចៅហ្វាយខេត្តកំពង់ឆ្នាំងជាប្រមុខ បានមកឈរចាំទទួល ដើម្បីធ្វើការគោរពចំពោះសម្តេច ។ សម្តេចព្រះមហាសុមេធាធិបតីបាននិមន្តឡើងលើវេទិកា ដែលគេរៀបចំទុកប្រគេន ហើយមានថវាយបដិសណ្ឋារកិច្ចតបចំពោះពួកពុទ្ធបរិស័ទទាំងឡាយ មានឯកឧត្តមលីតឹម-ឃុត ជាប្រធាន អស់កាលដ៏គួរ, លុះសម្តេចបានថ្លែងសេចក្តីចប់ហើយ មានឧបាសកម្នាក់ជាតំណាងបានរៀបរាប់អំពីជីវប្រវត្តិឧបាសិកាវ៉ុត ដែលទើបនឹងទទួលមរណភាពនោះ ដូចមានសេចក្តីជាសង្ខេបតទៅនេះ:

ឧបាសិកាវុត្ត កើតនៅថ្ងៃសុក្រ ៧កើតខែមិគសិរ ឆ្នាំម្សាញ់ឯកស័ក ព. ស. ២៤១៥ នៅភូមិកណ្តាល ឃុំកំពង់ឆ្នាំង ស្រុកសណ្តែក (កំពង់ឆ្នាំង) ។ល។ ឧបាសិកានេះ លុះដល់ជន្មាយុគំរប់ ៨១ ឆ្នាំ ក៏មានជរាពាធចូលមកយាយីតាមធម្មតារបស់សត្វលោក, ព្រះបាឡាត់បពុមវង្ស នាម ពុធ-កេត ទីឯបុត្តធីតាព្រមទាំងញាតិមិត្រសាច់សាលោហិតដ៏ច្រើន ប៉ាននាំគ្នាទំបីបាច់ថែរក្សាព្យាបាលពេគនោះ ដោយថ្នាំឧសថផ្សេងៗ ក៏នៅតែមិនបានស្រាកស្រាន្តសោះ, ពេគចេះតែមានកម្លាំងឡើង នាំឲ្យឧបាសិកាវុត្តមានធន់នាហារ (ជាប់អាហារ) អស់រយៈកាល ១ ខែ, លុះដល់មកថ្ងៃចន្ទ ២កើតខែមិគសិរឆ្នាំម្សាញ់បញ្ចស័ក ព. ស. ២៤៩៦ ឧបាសិកាវុត្តមិនអាចទ្រទ្រង់ជីវិតាពបាន ក៏ធ្វើកាលកិរិយាក្នុងជន្មាយុគំរប់ ៨១ ឆ្នាំ រំលងខ្លួនទៅគាន់បរលោកនាយ នៅវេលាម៉ោង ១ ជាប់នាទីយប់ ចំពោះព្រះភក្ត្រព្រះសង្ឃក្នុងវត្តទេពធីតារាមនោះ ។

ចំណែកព្រះសង្ឃព្រមទាំងបុត្តធីតាញាតិមិត្រជិតឆ្ងាយ ដែលធ្លាប់ស្គាល់រាប់អានគាត់នោះ ក៏មានសេចក្តីអាឡោះអាល័យសោកស្តាយជាទីបំផុត, តែធ្វើម្តេចមច្ចុសង្គ្រាមគឺជាសង្គ្រាមសម្រាប់ពង្រាត់មនុស្សសត្វឲ្យផ្តាច់ជីវិតសង្ខារ មិនដែលទទួលអង្វរបស់មនុស្សសត្វណាមួយឡើយ ។

លុះចប់ដំណើរបែវត្តនេះហើយ ព្រះបាឡាត់បពុមវង្ស បានថ្លែងអំណរគុណចំពោះពុទ្ធបរិស័ទមកជួយជាំជ្រាយ, ចំពោះអ្នកភូមិភាគក៏ខេត្តដែលមាន

ឯកឧត្តមលីតិម - ឃុត ជាប្រធានទីឯកឯកជីវពល, កងនាវីក្វាហ្វាន ដូច
មានសេចក្តីតទៅនេះ :

ខ្ញុំព្រះករុណាអាត្មាភាពសូមថ្លែងអំណរគុណដ៏លើសលុប ចំពោះ
ព្រះកិក្ខុសង្ឃក្នុងខេត្តនេះ ដែលមានព្រះតេជព្រះគុណព្រះធម្មវង្សាធិបតី
មេគណជាប្រធាន ទីឯអស់លោកភ្ញៀវមានតេជទាំងឡាយមានឯកឧត្តម
ជាដើម ដែលបានទទឹមទ្ទឹងមកអញ្ជើញមកធ្វើតាវកិច្ចចំពោះសម្តេចផង
ជាកិត្តិយសក្នុងឧកាសបុណ្យនេះផង, ខ្ញុំព្រះករុណាអាត្មាភាពសូមលែក
កុសលដែលកើតឡើងអំពីជម្ងឺទានទីឯអាមិសទានទាំងពីរប្រការ ចែក
ប្រគេនជូនចំពោះអស់លោកម្ចាស់ទាំងឡាយ មានឯកឧត្តមជាប្រធាន សូម
ឲ្យបានសម្រេចផលស្មើៗភាគគ្នា កុំបីប្រែក្លាយទៅជាបាការៈដទៃឡើយ ! ។

មួយចំណែកទៀត អាត្មាភាពសូមលែកកុសលនេះ ថ្វាយចំពោះ
ព្រះករុណាជាម្ចាស់ជីវិត ដែលព្រះអង្គទ្រង់កំពុងតែតុះពាល់ទុបសំគ្គ
ដើម្បីស្វែងរកឯកភាពផ្សះផ្សាបបូរបារណ៍ ឲ្យប្រជាពលស្ថិតក្នុងព្រះពាជាណាចក្រទាំង
មូលរបស់ទ្រង់ ។ ដោយអំណាចនៃបុញ្ញភាគីនេះ សូមព្រះករុណាជា
ម្ចាស់ជីវិត អាចដឹកនាំប្រទេសជាតិទាំងមូល ទៅកាន់វិថីនៃធម៌ទីង
អារ្យធម៌ ហើយសូមទ្រង់ប្រកបតែរឿងបរមសុខ កុងសិរីភាពជាសម្បត្តិកុំបី !
មានទុបសំគ្គមកប៉ះពាល់ទ្រង់បានឡើយ ! ។

ព្រះពុទ្ធសាសនា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៦ ខែកុម្ភៈ លេខ ២

ព.ស. ២៤៩៦ – គ.ស. ១៩៥២



កាសិកសន្ទនា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ.

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— អត្តកថា	ព្រះមហា សៅរ- យ៉ីយ	៨៣
— រឿងព្រះអង្គុលិមាលត្ថេរ	លោក ប៊ូ-ប៉ូ	៩២
ផ្នែកអក្សរសាស្ត្រ		
— ការប៉ុន្មះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៊ម ...	១០៣
— រឿងសាមកុក (តមក)	ឧកញ៉ា ឆ្ង-កន	១១៦
— នាលៈនឹងទមយន្តី (តមក)	អ្នកស្រី ស្រ៊ុន—សារីយ៉ាន់ ...	១២៩
— ដំណើរអស្ចារ្យនៃលោក ភ័ស្ចូច៉ីយូយេ ...	លោក ភ័យ-ប៊ុក	១៣៥
— ដំណឹងតាមខ្សាច់ក្នុងកន្ទារៈ	លោក ផេង-ទ្រីវ	១៤៧
កំណត់ទឹងប្រវត្តិការណ៍		
— ការប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ	ក្រុមដំនុំទំនៀមទម្លាប់ខ្មែរ	១៥៤

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដារ ២០០ រៀល

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE

— Attakatha . . . . . *Brah Maha SAU-YOI* 83

— Histoire de Brah Angulimalatthera . . . . . *M. BOU-PO* 92

PARTIE LITTERAIRE

— Education morale (suite) . . . *Vén. PEUNG-PAM* 103

— Histoire de SAMăOK (suite) . . *Oknha NOU-KAN* 116

— Nala et Damayanti . . (suite) *Mme SRIN-SARIS-YANN* . . . 129

— Le Voyage extraordinaire de Vasiobioyé. . . . . *M. RAY-BUC* 135

— Le Souffle du désert (suite) . *M. PHENG-CHRIV* 147

NOTES ET CHRONIQUES

— Concours des Moeurs et Coutumes. . . . . *Commission des Moeurs et Coutumes* 154

Prix d'abonnement annuel (comprenant 12 numéros): 200$00

អត្តកថា

ព្រះមហា សៅរ៉-យ៉ែយ វិត្តឧណ្ណាលោម

និស្សិតសាលាពាលីជាន់ខ្ពស់

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ត្រមាំង ព្រះធម៌ទីង ព្រះអរិយសង្ឃដោយសេចក្តីគោរព) ។

ឥឡូវនេះ អាត្មាភាពសូមសំដែងធម្មកថាតាមព្រះពុទ្ធដីកាក្នុងគម្ពីរ សំយុត្តនិកាយថា នត្ថិ *អត្តសមំ បេមំ "សេចក្តីស្រឡាញ់អ្វីស្មើនឹងខ្លួនមិនមាន" ដើម្បីជាសណ្តាប់នៃពុទ្ធសាសនិកជន ដូចមានសេចក្តីតទៅនេះ ៖*

សម្តេចព្រះមហាមុនីបរមគ្រូទ្រង់សំដែងបញ្ជាក់អំពី "អត្តា" គឺខ្លួនរបស់មនុស្សក្នុងលោកថា "មនុស្សយើងគ្មានស្រឡាញ់អ្វីឲ្យប្រហែលនឹងខ្លួន ឬជាងខ្លួនទេ" ។

ពាក្យថា "អត្តា" នេះ មានបទវិគ្រោះថា សុខទុក្ខំ *អត្តនិ: ទាទតីតិ* អត្តា *(ប្រែថា) សភាវៈដែលទំពារសុំខ្លួនឯងនូវសុខទុក្ខឈ្មោះថា "អត្តា" ។ អត្តានេះខ្មែរយើងប្រែថា ខ្លួន ហេតុដូច្នេះ ពាក្យថា*

ខ្លួន មិនគឺអ្វីដទៃឡើយ គឺចិត្តនេះឯង, ព្រោះចិត្តតែងជ្រកសំងំនៅក្នុងកាយ ហើយអាចគិតនូវអារម្មណ៍ផ្សេងៗ ដឹងថាស្រួល ឬមិនស្រួលបាន ចំណែកអវយវៈតូចធំមានដៃនឹងដើងជាដើមហៅថា កាយ ឬពងកាយ; កាយហើយនឹងចិត្តពាំងពីរនេះ លុះតែអាស្រ័យគ្នានឹងគ្នាទើបអាចប្រព្រឹត្តទៅបាន; ព្រោះហេតុនេះ គួរសន្និដ្ឋានថា "ការប្រជុំព្រមដោយកាយនឹងចិត្ត ហៅថា ខ្លួន" ។

ធម្មតាមនុស្សក្នុងលោកតែងស្រឡាញ់កាយនឹងចិត្ត ដែលលោកសន្មតហៅថាខ្លួននេះឯង ជាងអ្នកដទៃ ឬជាងវត្ថុអ្វីៗគ្រប់យ៉ាង, កុំថាឡើយចំពោះនិយាយដល់មនុស្សដែលមានពងកាយល្អមាំមួននោះឡើយ ដោយហេតុនេះ សូម្បីមនុស្សដែលមានពងកាយពិការជាទម្ងន់ មានកើតឃ្លង់ឬខ្វាក់ខ្វិនជាដើម ក៏នៅតែស្រឡាញ់ខ្លួនឯងជាងអ្នកដទៃ ទោះបីស្វាមីភរិយាឬឯងប្អូនកូនចៅ ឬទ្រព្យសម្បត្តិដែលមានដំឡៃ ដូចត្បូងពេជ្រមាសប្រាក់ជាដើម ដែលគេកាប់ថាជាទីស្រឡាញ់នោះ ក៏គង់តែមិនស្រឡាញ់ស្មើនឹងខ្លួនដែរ; អ្នកដែលស្រឡាញ់រាបស់ពាំងនោះ ហើយខំស្វែងរកដោយមិនគិតនឿយហត់ ក៏ព្រោះតែសេចក្តីស្រឡាញ់ខ្លួនទើបបានស្វែងរកមកដើម្បីជាគ្រឿងជួយទំនុកបំរុងខ្លួននោះឯង, សេចក្តីនេះគួរជ្រាប ដូចមនុស្សក្នុងលោកពាំងមូលដែលនឹងធ្វើការងារអ្វីៗគ្រប់យ៉ាង ក៏សុទ្ធតែប្រាថ្នាខ្លួនឯងជាមុន ហើយទើបបានធ្វើតាមសេចក្តីប៉ុនប៉ង

នោះ ឬតាមសេចក្តីយល់ឃើញ ថាត្រូវធ្វើយ៉ាងណាគ្រប់ៗគ្នាទាំងអស់ ដូចកូនឈ្លដែលធ្វើការឲ្យគេ ក៏ព្រោះតែចង់បានថ្លៃឈ្លួស ពេទ្យដែលរក្សាពេគឲ្យគេ ក៏ព្រោះតែចង់បានកំណាល់វង្វាន់ ឬអ្នកដែលធ្វើអ្វីមួយក៏ព្រោះតែប្រាថ្នាផលប្រយោជន៍គឺឲ្យសម្បត្តិនឹងយសបរិវារជាដើម ដើម្បីទំនុកបំរុងខ្លួនជាមុន ហើយទើបទំនុកបំរុងអ្នកដទៃដែលនៅអាស្រ័យនឹងខ្លួនជាខាងក្រោយ ។

សំដែងមកនេះ ដើម្បីបញ្ជាក់ឲ្យឃើញច្បាស់ថាធម្មតាមនុស្សក្នុងលោក តែងស្រឡាញ់ខ្លួនឯងជាងអ្នកដទៃ ។ ព្រោះហេតុនោះ ឋាន ជាព្រះសក្យមុនីជាម្ចាស់ទ្រង់ត្រាស់ទេសនាថា ឥត្តិ អត្តសមំ បេមំ "សេចក្តីស្រឡាញ់អ្វីស្មើនឹងខ្លួនមិនមានឡើយ" ។

មនុស្សទាំងពួងដែលធ្វើអ្វីៗដើម្បីផលប្រយោជន៍ណាមួយ ព្រោះតែស្រឡាញ់ខ្លួននោះក៏មែនពិតហើយ ប៉ុន្តែតាមធម្មតារបស់មនុស្សក្នុងលោកនេះ ច្រើនតែខ្វល់ខ្វាយក្នុងការដែលមានប្រយោជន៍ក្នុងបច្ចុប្បន្នភាន់តែក្នុងឃើញ មិនសូវខ្វល់ខ្វាយប្រយោជន៍ក្នុងជាតិខាងមុខឲ្យច្រើនផងទេ ។

មានជនចំពួកខ្លះ មិនស្វែងរកគុណធម៌សេចក្តីល្អ សេចក្តីត្រូវដាក់ខ្លួន គឺមិនធ្វើទាន មិនរក្សាសីលជាដើមទេ ។ មិនតែប៉ុណ្ណោះអ្នកខ្លះថែមទាំងបណ្តែតបណ្តោយឲ្យកាយ វាចា ចិត្តប្រព្រឹត្តលង់ទៅតាមអំណាចបាបអកុសលលាមកអាក្រក់ មានសេចក្តីលោភ សេចក្តីក្រោធខឹង ទន់ងសេចក្តី

វង្វេងកាន់ច្រឡំ ជាដើមទៀតផង ។ ជនបែបនេះ អ្នកប្រាជ្ញតាំងឡាយ មានព្រះពុទ្ធជាដើម ឲ្យឈ្មោះថាជាមនុស្សស្អប់ខ្លួន ធ្វើខ្លួនឲ្យដូចជាសត្រូវដល់ខ្លួនឯងវិញ ។

ព្រោះហេតុនេះឯង សាធុជនតាំងឡាយដែលជាបណ្ឌិតប្រកបដោយប្រាជ្ញា កាលបើជ្រាបច្បាស់ថា ខ្លួនជាទីស្រឡាញ់របស់ខ្លួនជាបំផុតហើយ គួរតែប្រញាប់ប្រញាល់កំចាត់បង់អកុសលធម៌ដ៏លាមកអាក្រក់ឲ្យឃ្លាតចេញឆ្ងាយចាកសន្តាន គួរកុំបណ្តោយឲ្យលង់ខ្លួនទៅតាមអំណាចកិលេសធម៌ជារៀងសៅហ្មងចិត្ត គឺ លោភៈ ទោសៈ មោហៈ ឡើយ ។

ន័យមួយទៀត អ្នកដែលស្រឡាញ់ខ្លួន គួរតែប្រញាប់ស្វែងរកទីពឹង គឺបុណ្យកុសលមកដំកល់ទុកក្នុងខ្លួនឲ្យឆាប់ៗ ឲ្យមានដីវិតនៅរស់ ព្រោះដីវិតរបស់មនុស្សនិងសត្វតាំងឡាយ មិននៅថិតថេរយឺនយូរប៉ុន្មានឡើយ មុខជានឹងដល់នូវសេចក្តីស្លាប់សាបសូន្យទៅយ៉ាងឆាប់រហ័ស បើជនណាមួយធ្វេសប្រហែស ឬយល់ខុសថា ខ្លួនមិនងាយនឹងស្លាប់ទេ ជននោះឯងក៏មុខជានឹងបណ្តែតបណ្តោយចិត្តឲ្យប្រព្រឹត្តធ្វើតែអំពើចាបអកុសល ឥតរវល់នឹងអំពើបុណ្យ មានឲ្យទាននឹងរក្សាសីលជាដើមឡើយ បើប្រសិនជាកំពុងតែធ្វេសប្រហែសដូច្នោះ ហើយបួនជាប្រទះលើពេលដែលសេចក្តីស្លាប់ត្រូវមកដល់ ក្នុងមរណសម័យនោះ

ទោះបីមានចិត្តប្រាថ្នាចង់ធ្វើការកុសលក៏មិនងាយនឹងធ្វើបាន ព្រោះចិត្ត
មិនធ្លាប់ដួបប្រទះនឹងបុណ្យកុសលដល់ម្ដងសោះ ។

ម្យ៉ាងទៀតសេចក្ដីស្លាប់នេះ ជាកំពូលនៃសេចក្ដីទុក្ខព្រួយយ៉ាងធំ
ព្រោះវេលាដែលទៀបនឹងស្លាប់នោះ តែងមានសេចក្ដីលំបាកយ៉ាងខ្លាំងជា
មុនចំផុតហើយទើបស្លាប់ បើយ៉ាងដូច្នេះ អ្នកដែលធ្លុះប្រហែសមិនខំ
សាងសន្សំបុណ្យកុសលមានទាន សីល ភាវនាជាដើម ទុកក្នុងចិត្តឲ្យបាន
ច្រើនអំពីចម្ងាយឲ្យហើយទេ ធ្វើម្ដេចនឹងអាចសាងសន្សំបុណ្យក្នុងពេល
ដែលមានសេចក្ដីព្រួយដោយមរណៈមកគ្របសង្កត់នោះបាន ។ កាល
បើមិនមានអំពើបុណ្យកុសលណាមួយមកជួយឧបត្ថម្ភគាំទ្រក្នុងពេលនោះ
ហើយ មុខជានឹងច្យុតកំណើតដែលកើតជាមនុស្សនេះ អ្នកនោះឯង
រមែងបែរមុខឆ្ពោះទៅកាន់ចតុបាយ គឺទៅកើតក្នុងនរក ឬប្រែជាដើម
កាលបើទៅកើតក្នុងអបាយនោះហើយ កម្រណាស់នឹងត្រឡប់មកកើត
ជាមនុស្សវិញបាន សមដូចព្រះពុទ្ធភាសិតថា បិត្តេ សំកិលិដ្ឋេ
ទុគ្គតិ បាដិកង្ខា "កាលបើចិត្តសៅហ្មងហើយ ទុគ្គតិក៏រមែងកើត
ប្រាកដ" បើទុកជាមិនចង់បាន មិនចង់ទៅកើត ក៏គង់តែគេចមិនផុត
ដៀសវាងពុំរួចដែរ ។ ព្រោះហេតុនេះហើយបានជាយើងទាំងឡាយ
គួរតែស្គាល់កំណើតដែលកើតមកជាមនុស្សនេះឲ្យណាស់ ដ្បិតដែល

យើងបានមកកើតជាមនុស្សនេះមិនមែនងាយទេ សឹងបានដោយកម្រៃគ្រៃពេកណាស់ ដូចពុទ្ធភាសិតក្នុងគម្ពីរខុទ្ទកនិកាយថា:

កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ
កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ

"កំរិយាដែលត្រឡប់មកកើតជាមនុស្ស ជារបស់ក្រ, ជីវិតគឺការរស់នៅរបស់សត្វទាំងឡាយ ថាធម្មជាតក្រ, ការស្តាប់ធម៌របស់សប្បុរសជាកិច្ចកម្ម, កំរិយាកើតឡើងរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ជារបស់ក្រ" ។

ឥឡូវនេះ យើងទាំងឡាយបានកើតមកជាមនុស្ស ហើយមានជីវិតរស់នៅ ត្រមទាំងបានជួបប្រទះនឹងធម៌អាថ៌ដែលជាពាក្យប្រដៅយ៉ាងពិសេសនេះថែមទៀត កំប្រហែលគ្នានឹងបានទាន់ព្រះពុទ្ធដែរ បានឈ្មោះថារួចអំពីសេចក្តីក្រទាំង ៤ យ៉ាងនោះហើយ គឺថាជាបុញ្ញលាភដ៏ប្រសើរបំផុតរបស់យើងទាំងឡាយ គួរតែខំប្រឹងធ្វើបុណ្យ មានឲ្យទាន រក្សាសីល ចំរើនភាវនា ត្រមទាំងរៀនសូត្រធម៌អាថ៌ឲ្យចេះចាំស្ទាត់ជាដើម យ៉ាងប្រញាប់គ្រាន់នឹងបានជាតិពឹងពាក់ក្នុងជាតិនេះនឹងជាតិខាងមុខតទៅ គួរកុំបណ្តែតបណ្តោយឲ្យខូចជាតិកំណើតដែលកើតមកជាមនុស្សនេះឡើយ ។ ធម្មតាបុគ្គលដែលបានទូក ឬសំពៅនឹងរនេះមកហើយ មិនគួរនឹងទុកយាននេះឲ្យពុកផុយរលួយខូចចោលទេ ។ គួរតែប្រញាប់ផ្ទុក

ខំនិញហើយចេញទៅដួញឲ្យមានកំរៃ សេចក្តីនេះមានឧបមាយ៉ាងណា មានគួរនាដូចយើងគាំងឡាយ ដែលបានមកចាប់កំណើតជាមនុស្សហើយ មិនគួរបណ្តោយឲ្យកងកាយ ចាស់ឈឺស្លាប់ខូចទៅទេ។ គួរតែប្រញាប់ធ្វើបុណ្យកុសល ដើម្បីយករបស់ចំណេញ គឺសេចក្តីសុខក្នុងជាតិនេះនឹងជាតិខាងមុខដោយឆាប់រហ័ស ។

ម្យ៉ាងទៀត សាធុជនណាដែលបានកសាងសន្សំបុណ្យកុសលមានឲ្យទានរក្សាសីល ៥ សីល ៨ ជាដើម សាធុជននោះទើបឈ្មោះថាជាមនុស្សស្រឡាញ់ខ្លួន ហើយដុសខាត់សំអាតខ្លួនឲ្យស្អាត; សេចក្តីនេះដូចព្រះពុទ្ធភាសិត ក្នុងគម្ពីរខុទ្ទកនិកាយថា:

អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ
តិណ្ណមញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ

"បើបណ្ឌិតដឹងខ្លួនថាខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឲ្យល្អ គួរថែទាំសំអាតខ្លួនកុងវ័យគាំង ៣ វ័យណាមួយឲ្យបាន" ។

ឯវិធីនឹងថែទាំរក្សាខ្លួន ឬនឹងដុសខាត់ស្អិតស្អាងខ្លួនឲ្យស្អាតនោះ ដូចសេចក្តីអធិប្បាយតទៅនេះ ។

បើជាគ្រហស្ថគួរធ្វើបុណ្យគាំងឡាយ មានឲ្យទានរក្សាសីល ៥ សីល ៨ ជាដើម តាមសមគួរនឹងកម្លាំងរបស់ខ្លួន, បើជាបព្វជិតគួរខ្ជាប់ខ្ជួយធ្វើវត្តប្រតិបត្តិតួចៗ ឬទុំយកចិត្តទុកជាក់ក្នុងការរៀនសូត្រធម៌វិន័យ

ឲ្យចេះចាំស្ងាត់ ហើយប្រព្រឹត្តឲ្យត្រឹមត្រូវ ។ ធ្វើយ៉ាងនេះទើបហៅថា ថែរក្សាខ្លួន ព្រមទាំងស្អិតស្អាងឲ្យស្អាតល្អដោយពិត ; បើប្រសិនជា គ្រហស្ថមិនអាចធ្វើការកុសលក្នុងវ័យឲ្យសព្វគ្រប់បាន ព្រោះ មានសេចក្តីខ្វល់ខ្វាយក្នុងការងារ, លុះចូលកាន់មជ្ឈិមវ័យគួរកុំប្រហែស ធ្វេសឡើយ គួរខំប្រឹងធ្វើឲ្យបាន ; បើប្រសិនជាកន្លងមជ្ឈិមវ័យរួចស្រេច ដោយកិច្ចការរបរចិញ្ចឹមជីវិតខ្លួនទើបកូនចៅ មិនអាចនឹងធ្វើការកុសលបាន ទេ លុះចូលដល់វ័យបច្ឆិមវ័យ គួរប្រឹងជំនះចិត្តធ្វើឲ្យខាងតែបានកុំឲ្យ ខាន, យ៉ាងនេះទើបហៅថាស្រឡាញ់ខ្លួនហើយបីបាច់រក្សាខ្លួនសំអាត ខ្លួន, បើមិនធ្វើការកុសលគ្រប់វ័យទាំងអស់ មិនហៅថាស្រឡាញ់ ខ្លួនឡើយ ត្រឡប់បានឈ្មោះថាស្អប់ខ្លួន ធ្វើខ្លួនឲ្យសូន្យចាក ប្រយោជន៍វិញ ។

ឯចំណែកខាងឫត្តិជិត បើក្នុងបឋមវ័យរួចនឹងរៀនសូត្រធម៌អាចិ ប្តូរធ្វើជាអាចារ្យបង្រៀនសិស្សគណ ឬក៏រួចនឹងធ្វើវត្តតូច-ធំ មានការ បំរើឧបដ្ឋាយ៍អាចារ្យជាដើម ហើយធ្វេសប្រហែសមិនបានធ្វើសមណ-ធម៌, លុះដល់ចូលក្នុងរាងមជ្ឈិមវ័យគួរកុំប្រហែសឡើយ គួរខំចំរើន សមណធម៌ឲ្យបាន, បើប្រសិនជាក្នុងរាងមជ្ឈិមវ័យរួចស្រេចនឹង អដ្ឋកថា ឬរួចនឹងវិនិច្ឆ័យកាត់សេចក្តីខុសត្រូវឲ្យគេ ឬក៏រួចនឹងដោះ សារអាចិប្រស្នា ហើយកំពុងប្រហែសទៀតនៅ លុះចូលដល់បច្ឆិមវ័យ

គួរទំធ្វើសមណធម៌កុំឲ្យខាន បើបានធ្វើទើបឈ្មោះថា ស្រឡាញ់ខ្លួន រក្សាខ្លួន សំអាតខ្លួនឲ្យស្អាតល្អ ។

អាត្មាភាពសំដែងធម៌ទេសនាមកនេះ សមគួរដល់កាលវេលានឹងបញ្ចប់តែប៉ុណ្ណេះ ។ សូមដួនពរដល់ពុទ្ធបរិស័ទ សូមឲ្យបានប្រកបដោយឥដ្ឋមនុញ្ញផលវិបុលសុខគ្រប់ប្រការ ! ។

ទុក្ខប្បត្តា ច និទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្ពេបិ បាណិនោ

សត្វទាំងឡាយទាំងពួងដែលមានសេចក្តីទុក្ខ សូមឲ្យបាត់សេចក្តីទុក្ខទៅ ! ដែលមានភ័យ សូមឲ្យបាត់ភ័យទៅ ! ដែលមានសេចក្តីសោក សូមឲ្យបាត់សេចក្តីសោកទៅ !

រតនត្តយតេជេន កម្ពោជរដ្ឋវាសិនោ
រុឡ្ហី រុទ្ធិ បប្បោន្តុ សន្តិភាវញ្ច នាញ្ញថា

ដោយតេជៈនៃព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សូមឲ្យប្រជាជនទាំងឡាយអ្នករស់នៅក្នុងកម្ពុជរដ្ឋ បានលូតលាស់ចំរើនទីនឹងសន្តិភាពកុំបីឃ្លាតឆ្ងាយទៅជាប្រការដទៃឡើយ ! ។

រឿងព្រះអង្គុលិមាលត្ថេរ

កណ្ឌសុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក:

ឃុនបណ្ណាសុរក្ស ប៊ូ-ប៊ូ

ក្រសួងពុទ្ធសាសនបណ្ឌិត្យដាក់ប្រែ (១)

សម័យនោះឯង កណ្ដែនព្រះជេតវនៈនៃនគរសាវត្ថី មានចោរម្នាក់ ឈ្មោះអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស្ថិតក្នុងការ បៀតបៀននឹងការសម្លាប់ ឥតមានសេចក្ដីអាណិតអាសូរពួកសត្វមាន ជីវិតឡើយ ។ ចោរនោះតែងធ្វើស្រុកនិគមជនបទឲ្យទៅជាមិនមែនស្រុក និគមជនបទ តែងសម្លាប់ពួកមនុស្សហើយកាត់យកម្រាមដៃមកធ្វើជា កម្រងពាក់ ។ គ្រានោះ ព្រះដ៏មានព្រះភាគស្ដេចចូលទៅទ័ដបិណ្ឌបាតក្នុងក្រុងសាវត្ថីក្នុងវេលាព្រឹក លុះថ្ងៃរសៀល ព្រះអង្គស្ដេចទៅកាន់ផ្លូវធ្លាយសំដៅទៅតែងនូវដែលអង្គុលិមាលចោរនៅ (តែមួយ ព្រះអង្គឯង) ។ ពួកអ្នកឃ្វាលគោ អ្នកឃ្វាលចស៊ុសត្វ អ្នកក្បែរពស់ ទើស អ្នកដើរផ្លូវ ឃើញព្រះដ៏មានបុណ្យកំពុងស្ដេចទៅកាន់ផ្លូវធ្លាយសំដៅ ទៅតែងនូវដែលអង្គុលិមាលចោរនៅ ក៏ក្រាបទូលថា បពិត្រព្រះសមណៈ សូមព្រះអង្គកុំនិមន្តទៅតាមផ្លូវនោះឡើយ ដ្បិតផ្លូវនុ៎ះមានចោរឈ្មោះ

---

១ មិនបានប្រែតាមប្រយោគដាលីទេ ប្រែប្លែកការតំយកសេចក្ដីខ្លឹដើម្បីឲ្យងាយស្ដាប់ ។ ដោយអាងច្បាប់ព្រះត្រៃបិដកប្រែ ភាគទី ២៤ ។

អគ្គិលិមាល ជាមនុស្សកាច តែងសម្លាប់ពួកមនុស្ស ហើយកាត់យក
ម្រាមដៃមកធ្វើជាកម្រងពាក់ ។ កាលបើពួកមនុស្សគ្រាបទូលយ៉ាងនេះ
ពីរបីដង ព្រះដ៏មានបុណ្យក៏ទ្រង់ស្ងៀម ទ្រង់ចេះតែស្តេចទៅ ។

ឯអគ្គិលិមាលចោរ ឃើញព្រះដ៏មានបុណ្យកំពុងតែស្តេចមក
អំពីចម្ងាយ ក៏គិតរិះថា យ៉ាអើ អស្ចារ្យណាស់ អើហ្ន៎ ចំឡែកណាស់
ព្រោះបុរស ១០ នាក់ក្តី ២០ នាក់ក្តី ៣០ នាក់ក្តី ៤០ នាក់ក្តី នាំគ្នាដើរ
ជាពួក ។ មកតាមផ្លូវនេះ ក៏បុរសទាំងនោះឯង ដល់នូវសេចក្តីវិនាសក្នុង
កណ្តាប់ដៃរបស់អញ (ទាំងអស់) ចុះសមណៈនេះ តែម្នាក់ឯង ឥតមាន
គ្នីគ្នាសោះ ម៉្លេចក៏ហ៊ានដើរមក ហាក់ដូចជាមិនកោតញញើតទៀយ
បើដូច្នោះ អញនឹងសម្លាប់សមណៈនេះ ឲ្យក្សយជីវិត ។ គ្រានោះ
អគ្គិលិមាលចោរកើចប៉ប់ដាវនឹងខ្លួន សៀតធនូនឹងបំពង់ព្រួញដេញព្រះ
ដ៏មានព្រះភាគជាប់តាមពីក្រោយ ។ ព្រះដ៏មានបុណ្យ ទ្រង់សំដែង
ឫទ្ធិធ្វើឲ្យអគ្គិលិមាលចោរដែលរត់ពេញទំហឹងហើយ មិនឲ្យរត់តាមទាន់
ព្រះអង្គដែលស្តេចតាមដំណើរប្រក្រតីបាន ។ អគ្គិលិមាលចោរគិតថា
យ៉ាអើ អស្ចារ្យណាស់ យ៉ាអើ ចំឡែកណាស់ ព្រោះកាលពីមុនៗមក
អញស៊ុះដេញចាប់ដំរីកំពុងបោលក៏បាន ស៊ុះដេញចាប់សេះកំពុងផាយ
ក៏បាន ស៊ុះដេញចាប់រថកំពុងលឿនក៏បាន ស៊ុះដេញម្រឹគកំពុងបោល
ក៏បាន ចំឡែកតែម្តងនេះ ហេតុអ្វី បានជាអញរត់ពេញទំហឹងហើយ

ក៏នៅតែមិនឃាន់សមណៈនេះ ដែលដើរតាមដំណើរប្រែក្រឡាដូច្នេះ ។ អង្គុលិមាលចោរឈប់ឈរស្ងៀម ស្រែកឃាត់ព្រះដ៏មានបុណ្យថា ឈប់សិនសមណៈ ឈប់សិនសមណៈ ។ ព្រះដ៏មានបុណ្យត្រាស់តបថា នែអង្គុលិមាល តថាគតឈប់ហើយ អ្នកឯងចូរឈប់ដែរទៅ ។

គ្រានោះ អង្គុលិមាលចោរគិតថា ពួកសមណៈជាសក្យបុត្រធ្លាប់និយាយតែពាក្យពិត ប្តេជ្ញាតែពាក្យពិត ចំឡែកតែសមណៈនេះ កំពុងដើរទេ ម្តេចឡើយក៏និយាយថា នែអង្គុលិមាល តថាគតឈប់ហើយ អ្នកចូរឈប់ដែរទៅ បើដូច្នោះ អញត្រូវសួរសមណៈនេះមើល ។ លំដាប់នោះ អង្គុលិមាលចោរក៏ពោលនឹងព្រះដ៏មានព្រះភាគថា :

នែសមណៈ លោកកំពុងដើរសោះទេ ត្រឡប់ជានិយាយថា តថាគតឈប់ហើយ ថែមទាំងថាឲ្យអញដែលឈប់ហើយថា អ្នកឯងទេមិនឃាន់ឈប់ ដូច្នេះវិញ នែសមណៈ អញសូមសួរដំណើរនុ៎ះនឹងលោក លោកដែលឈប់ហើយ តើដូចម្តេច អញដែលមិនឃាន់ឈប់ តើដូចម្តេច ។ ព្រះអង្គតបថា នែអង្គុលិមាល តថាគតបានឈ្មោះថាឈប់ហើយ (នោះ) ព្រោះដាក់ចុះនូវគ្រឿងប្រហារដ៏ក្លៀវក្លាចំពោះពួកសត្វ ទាំងអស់សព្វ ។ ការ ឯអ្នកឯងជាអ្នកមិនសង្រួមក្នុងពួកសត្វ ព្រោះហេតុនោះ អ្នកឯងឈ្មោះថាជាអ្នកមិនឈប់ ។ អង្គុលិមាលចោរតបថា "នែសមណៈ លោកស្វែងរកនូវគុណដ៏ធំ ជាអ្នកដែលទេវតានឹងមនុស្សតែងបូជា លោក

មកកាន់មហាវន (ដើម្បីសង្គ្រោះ) ដល់ខ្ញុំអស់កាលយូរហើយ ខ្ញុំនឹងប្រព្រឹត្តតាមនឹងលះបង់នូវបាបចោលចេញ ព្រោះបានស្តាប់នូវគាថារបស់ព្រះអង្គដែលប្រកបដោយធម៌" ថាដូច្នេះហើយ ក៏គ្រវែងដាវនឹងអាវុធចោលទៅក្នុងត្រពាំង ក្នុងជ្រោះ ក្នុងរណ្តៅ ហើយថ្វាយបង្គំព្រះបាទានៃព្រះសុគត ហើយសូមផ្នួសនឹងព្រះអង្គក្នុងទីនោះឯង ។ ចំណែកព្រះសម្ពុទ្ធ បានត្រាស់ហៅអង្គុលិមាលចោរនោះថា អ្នកចូរមកជាភិក្ខុចុះដូច្នេះ ។ ក្នុងគ្រានោះ កិក្កាវ កំកើតមានដល់អង្គុលិមាលចោរនោះ ។ ព្រះភគវន្តមុនីទ្រង់យកអង្គុលិមាលភិក្ខុជាបច្ចាសមណៈ ស្តេចធ្វើតុន្ទដំណើរសំដៅទៅក្រុងសាវត្ថី ព្រះអង្គទៅគង់នៅជេតវនារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គាប់ប្លួនសម័យនោះ ពួកមហាជនកំពុងតែប្រជុំគ្នាទៀបទ្វារ ខាងក្នុងបុរីរបស់ព្រះបាទបសេនទិកោសល ស្រែកហ៊ោគឹកកងថា បពិត្រព្រះសម្មតិទេព ក្នុងដែនរបស់ព្រះអង្គមានចោរម្នាក់ ឈ្មោះអង្គុលិមាល ជាមនុស្សកាច តែងសម្លាប់ពួកមនុស្ស ហើយកាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ សូមព្រះសម្មតិទេពកំចាត់អង្គុលិមាលចោរនោះចេញ ។ លំដាប់នោះ ព្រះបាទបសេនទិកោសលស្តេចចេញអំពីក្រុងសាវត្ថី ដោយអស្សយាន ចំនួន ៥០០ ស្តេចចូលទៅកាន់អាស្រមតាំងថ្ងៃ បរយានទៅទល់ត្រឹមទីដែលឈប់យាន ហើយក៏ស្តេចចុះអំពីយាន ស្តេចទៅតែព្រះបាទទេ ចូលសំដៅទៅរក

ព្រះដ៏មានបុណ្យ ដល់ហើយក្រាបថ្វាយបង្គំគង់ក្នុងទីដ៏សមគួរ ។ ព្រះដ៏មានបុណ្យទ្រង់ត្រាស់សួរថា បពិត្រមហាភដ ចំនង់ជាមហាបពិត្រខ្ញាល់នឹងព្រះបាទមគធសេនិយពិម្ពិសារ ឬខ្ញាល់នឹងស្តេចលិច្ឆវី អ្នកក្រុងវេសាលី ឬក៏ខ្ញាល់នឹងពួកស្តេច ដែលជាបច្ចាមិត្តឯទៀតឬអ្វី ។ ព្រះបាទបសេនទិកោសលក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនខឹងនឹងស្តេចឯណាទេ តែងដែនរបស់ខ្ញុំព្រះអង្គ មានចោរម្នាក់ឈ្មោះអង្គុលិមាល ជាមនុស្សកាចណាស់ ។ល។ ខ្ញុំព្រះអង្គនឹងកំចាត់អង្គុលិមាលចោរនោះចេញ ។ ព្រះដ៏មានបុណ្យត្រាស់ថា បពិត្រមហាភដ ចុះបើមហាបពិត្រត្រឡប់ជាឃើញ អង្គុលិមាលកោរសក់ពុកមាត់នឹងពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះទៅកាន់ផ្នួសវិញ តើមហាបពិត្រត្រូវធ្វើអង្គុលិមាលនោះដូចម្តេចទៅ ។ ព្រះបាទបសេនទិកោសលក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គគប្បីថ្វាយបង្គំ ឬក្រោកទៅទទួល និមន្តដោយអាសនៈឬទំនុកបម្រុងនូវអង្គុលិមាលនោះដោយចីវរបិណ្ឌបាតសេនាសនៈ ថ្នាំរក្សារោគ នឹងបរិក្ខារតាំងពីឃ្លាយឬនឹងចាត់ចែងនូវការរក្សាសេចក្តីការពារ នឹងការគ្រប់គ្រង ប្រកបដោយធម៌ ដល់អង្គុលិមាលនោះ ។

ឮដូច្នោះហើយ អង្គុលិមាលគិតុ កំពុងអង្គុយជិតព្រះដ៏មានបុណ្យ។ លើកព្រះហស្តខាងស្តាំចង្អុលបង្ហាញ ព្រះបាទបសេនទិកោសល

ថា បពិត្រមហាភដ ទុះហ្នឹងអង្គុលិមាល ។ លំដាប់នោះព្រះបាទបសេនទិ-
កោសលក៏មានសេចក្តីភ័យកិត តក់ស្លុត ព្រឺរោម ព្រឺស្បែកឡើងមួយ
រំពេច ។ ព្រះដ៏មាបុណ្យជ្រាបច្បាស់ថា ព្រះបាទបសេនទិកោសល
ទ្រង់ភ័យញ័រចំប្រប់ព្រឺរោមដូច្នោះហើយ ក៏ត្រាស់ថា បពិត្រមហាភដ
សូមមហាបពិត្រកុំភ័យឡើយ ភ័យអំពីសំណាក់អង្គុលិមាលនេះ មិន
មានដល់មហាបពិត្រទេ ។ លំដាប់នោះ ព្រះបាទបសេនទិកោសល
បាត់ភ័យតក់ស្លុត ក៏ចូលទៅជិតអង្គុលិមាលកិក្ខុ ហើយមានព្រះទន្ទ្រាវស្សរ
ថាបពិត្រលោកដ៏ចំរើន លោកម្ចាស់ឈ្មោះអង្គុលិមាលឬ ។ អង្គុលិមាល
កិក្ខុថា ថ្វាយព្រះពរមហាភដ ។ - ចុះបិតាមាតាលោកម្ចាស់គោត្រអ្វី ។
- បិតាអាត្មាភាពជាគគ្គគោត្រ មាតាអាត្មាភាពជាមន្តានីគោត្រ ។
- បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់គគ្គគោត្រ មន្តានីបុត្រ
អភិវាទ្យចុះ ខ្ញុំព្រះករុណានឹងនំទុកបម្រុងដោយចីវរ បិណ្ឌបាត សេនា
សន ថ្នាំរក្សាពេគ ទានបរិក្ខារគ្រប់ប្រការ ដល់លោកម្ចាស់គគ្គគោត្រ
មន្តានីបុត្រ ។ សម័យនោះ អង្គុលិមាលកិក្ខុ ប្រព្រឹត្តនៅតែកន្លងព្រៃ
ប្រព្រឹត្តតែបិណ្ឌបាត ប្រើប្រាស់តែសំពត់បំសុកូល ប្រើប្រាស់តែ
ចីវរ ៣ ។ បានដាក់ាលនោះ អង្គុលិមាលកិក្ខុថ្វាយព្រះពរថា
ពុំប៉ាច់ទេមហាភដ អាត្មាភាពមានត្រៃចីវរគ្រប់គ្រាន់ហើយ ។

លំដាប់នោះ ព្រះបាទបសេនទិកោសលក្រាបទូលព្រះដ៏មានបុណ្យថា បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យណាស់ ចំឡែកណាស់ ព្រោះថា ព្រះអង្គអាចទូន្មានបុរសដែលគេទូន្មានមិនបាន អាចរម្ងាប់បុរសដែលគេរម្ងាប់មិនបាន អាចរំលត់ពុតត្បុតនៃបុរសដែលគេរំលត់មិនបាន បពិត្រព្រះអង្គដ៏ចំរើន ដ្បិតខ្ញុំព្រះអង្គមិនអាចនឹងទូន្មានទូន្មានបុរសឯណា ដោយអាជ្ញាក្តី ដោយគ្រឿងសស្ត្រាវុធក្តី ព្រះដ៏មានព្រះភាគអាចទូន្មានបុរសនោះបានដោយមិនបាច់មានអាជ្ញា ដោយមិនបាច់មានគ្រឿងសស្ត្រាវុធកំឥឡូវនេះ ខ្ញុំព្រះអង្គសូមថ្វាយបង្គំលាទៅវិញ ព្រោះខ្ញុំព្រះអង្គមានកិច្ចការច្រើន មានការរវល់ច្រើន ។

លំដាប់នោះ អង្គុលិមាលកិក្ខុចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី នៅវេលាបុព្វណ្ហសម័យ ទៅតាមលំដាប់ច្រក ឃើញដួងទឹកស្ត្រីម្នាក់ឈឺពោះសំពលកូន លុះលោកឃើញហើយក៏គិតថា អើហ្ន៎ ពួកសត្វលំបាកណាស់ ។ ដល់ពេលរសៀល អង្គុលិមាលកិក្ខុចូលទៅគាល់ព្រះដ៏មានព្រះភាគក្រាបទូលពីដំណើរស្ត្រីឈឺពោះសំពលកូននោះគ្រប់ប្រការ ។ ព្រះសាស្តាត្រាស់ថា ម្នាលអង្គុលិមាល បើដូច្នោះ ចូរអ្នកចូលទៅរកស្ត្រីនោះហើយនិយាយថា នែនាង៎ តាំងពីអាត្មាកើតមកមិនដែលកំណត់ផ្តាច់ផ្តិលជីវិតសត្វឡើយ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់នាង៎ សូមសិរីសួស្តីកើតមានដល់គភ៌ ។ អង្គុលិមាលកិក្ខុទូលថា ខ្ញុំ

ព្រះអង្គឧទ្ទិចត្រូវសម្បជានមុសាវាទមិនខាន ព្រោះខ្ញុំព្រះអង្គបានកែងផ្តាច់ផ្តិលជីវិតសត្វជាច្រើនណាស់ ។ ព្រះអង្គត្រាស់ថា បើដូច្នោះ អ្នកចូរនិយាយនឹងស្ត្រីនោះថា នែនាង តាំងពីអាត្មាកើតហើយក្នុងអរិយជាតិ គឺបានជាអរិយបុគ្គល មិនដែលកែងផ្តាច់ផ្តិលជីវិតសត្វឡើយ ដោយពាក្យសច្ចនេះ សូមសិរីសួស្តីកើតមានដល់នាង សូមសិរីសួស្តីកើតមានដល់គត់ ។ អង្គុលិមាលកិក្ខុចូលទៅនិយាយនឹងស្ត្រីនោះ តាមព្រះពុទ្ធដីកា សិរីសួស្តីក៏បានកើតដល់ស្ត្រីនោះនឹងដល់គត់ គឺសម្រាលកូនរួចក្តាម ឥតលំបាកឡើយ ។

លំដាប់នោះ អង្គុលិមាលកិក្ខុ ជាបុគ្គលម្នាក់ឯង ដោះខ្លួនចេញចាកពួក ឥតមានសេចក្តីឆ្អែសប្រហែស មានព្យាយាមដុតន្ទូរកិលេសប្រថុយលះបង់នូវអត្តភាព មិនយូរប៉ុន្មាន លោកក៏បានសម្រេចព្រះអរហត្តផលដល់វេលាបុព្វណ្ហសម័យ លោកនិមន្តទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ។ មានមនុស្សដទៃយកដុំដីខ្លះ ដម្បងខ្លះ ក្រួសខ្លះ គ្រវែងចោលទៅលើកាយព្រះអង្គុលិមាល ។ ត្រូវបួសបែកព្រះកេសហូរឈាម បែកបាត្រ រហែកសង្ឃាដិ លោកក៏ចូលទៅគាល់ព្រះដ៏មានបុណ្យ ។ ត្រាស់ប្តូន្មានថា ម្នាលព្រាហ្មណ៍ ចូរអ្នកខំអត់ធ្មត់ទៅ អ្នកគួរទទឹងនេះក្នុងនរកជាច្រើនឆ្នាំ កាប់រយតាន់ឆ្នាំ ដោយវិបាកនៃកម្មឯណា អ្នកបានសង្វួលរងវិបាកនៃកម្មនោះក្នុងបច្ចុប្បន្ននេះ (តែប៉ុណ្ណោះទេ) ។

វេលានោះ អគ្គិលិមាលភិក្ខុ ទៅនៅកន្លែងទិវាហោស្ថានពួនសម្ងំតែម្នាក់ឯង សោយនូវសុខក្នុងឈាន ទើបបន្ទូលនូវឧទានក្នុងវេលានោះថា :

"បុគ្គលឯណាធ្វើសប្បកម្មកន្លងកាលមុន តែដល់កាលជាខាងក្រោយមកបុគ្គលនោះមិនធ្វើសប្បកម្មវិញ បុគ្គលនោះឈ្មោះថាញ៉ាំងលោក(១) នេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទផុតស្រឡះចាកពពក ចាបកម្មដែលបុគ្គលឯណាធ្វើហើយ តែបុគ្គលនោះត្រឡប់ជាបិទបាំងបាន គឺមិនសោយផលកម្មវិញ ដោយសារកុសលគឺមគ្គ បុគ្គលនោះឈ្មោះថា ញ៉ាំងលោកនេះឲ្យភ្លឺច្បាស់ដូចព្រះចន្ទផុតស្រឡះចាកពពក ភិក្ខុឯណា ជាកំឡោះនៅឡើយ ប្រកបព្យាយាមក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះឯងឈ្មោះថាញ៉ាំងលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទផុតស្រឡះចាកពពក ។

សូមពួកមនុស្សជាសត្រូវស្តាប់នូវធម្មកថារបស់ខ្ញុំ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ ប្រកបព្យាយាមក្នុងព្រះពុទ្ធសាសនា ពួកសប្បុរសឯណា តែងដឹកនាំមនុស្សឲ្យរៀនធម៌ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ សេពគប់នូវពួកសប្បុរសទាំងនោះចុះ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំស្តាប់ធម៌ជាទីផ្សាយដ៏ជាទីសរសើរនូវការមិនខឹងគឺមេត្តាតាមកាលដ៏សមគួរផង សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ ចំពេញនូវធម៌នោះផង

---

១ ពាក្យថា លោក ៗ ក្នុងទីនេះ សំដៅយកខន្ធ ធាតុ អាយតនៈរបស់ឯង ។ អដ្ឋកថា ។

មនុស្សឯណាជាសត្រូវនឹងខ្ញុំ សូមសត្រូវនោះកុំបីបៀតបៀនខ្ញុំ ទាំងកុំបៀតបៀនទូរបុគ្គលដទៃណាមួយឡើយ សូមឲ្យដល់ទូរសេចក្តីសុខគឺព្រះនិព្វាន ចូរកក្សាទូរមនុស្សដែលប្រកបដោយតណ្ហា នឹងមនុស្សដែលមិនមានតណ្ហា ។

ពួកអ្នកបង្ហូរទឹករមែងបង្ហូរទឹក (តាមប្រឡាយទឹក) ពួកអ្នកធ្វើកូនសរូរមែងពត់កូនសរ ពួកអ្នកចាំងឈើរមែងចាំងឈើ អ្នកប្រាជ្ញទាំងឡាយរមែងខ្នាន់ខ្លួន ។

ពួកមនុស្សខ្លះគេខ្នាន់ដោយដំបង ដោយកន្ត្រែ ដោយរំពាត់ ចំណែកខ្ញុំជាអ្នកមានប្រាជ្ញ ដែលព្រះដ៏មានបុណ្យជាតាទិបុគ្គលមិនបានយកដំបង ឬគ្រឿងសស្ត្រាវុធ (មកខ្នាន់ខ្ញុំទេ) កាលដើមខ្ញុំឈ្មោះថា អហឹសកកុមារ (ជាអ្នកមិនបៀតបៀនគេ) តែជាអ្នកបៀតបៀនគេដល់មកថ្ងៃនេះ ខ្ញុំមានឈ្មោះទៀងទាត់ គឺសមតាមឈ្មោះដើមរបស់ខ្ញុំ ព្រោះខ្ញុំលែងបៀតបៀនទូរអ្នកណាមួយហើយ កាលពីដើមខ្ញុំជាចោរមានឈ្មោះប្រាកដថា អង្គុលិមាល ដែលជំនន់ធំបន្សាត់ទៅ (តែឥឡូវនេះ) ខ្ញុំបានដល់ទូរព្រះពុទ្ធជាទីពឹងហើយ កាលពីដើម ខ្ញុំមានដៃប្រឡាក់ឈាម មានឈ្មោះប្រាកដថា អង្គុលិមាល (តែឥឡូវនេះ) សរណគមន៍ខ្ញុំបានដល់ហើយ តណ្ហាជាគ្រឿងនាំទៅកាន់កំព ខ្ញុំបានរំលើងចោលហើយ ខ្ញុំបានធ្វើអំពើដែលគួរទៅកាន់ទុគ្គតិជូញ្ចោះជាច្រើន

តែកម្មវិបាក គឺមគ្គផលនាំបានមកអប់រំ (កន្លងខ្ញុំហើយ) ខ្ញុំជាអ្នក
មិនមានបំណុលគឺកិលេស បរិភោគភោជន ពួកជនតាលឥតជ្រាជ្រា
តែងប្រកបនូវសេចក្តីប្រមាថ ឯអ្នកជ្រាជ្រាតែងរក្សានូវសេចក្តីមិនប្រមាថ
ទុក ដូចគ្រឿងដ៏ថ្លៃថ្លា សូមអ្នកទាំងឡាយកុំប្រកបនូវសេចក្តីប្រមាថ
ឡើយ កុំប្រកបនូវសេចក្តីត្រេកអរនឹងកាមមូលមិត្តក្នុងកាមឡើយ ព្រោះ
ថាបុគ្គលអ្នកមិនប្រមែាសខ្វេស ខំដុតបំផ្លាញ (នូវកិលេស) រមែង
បានដល់នូវសេចក្តីសុខដ៏ខ្ចាយ ខ្ញុំមកហើយ ខ្ញុំមិនគេចចេញទេ
គំនិតនេះ ខ្ញុំមិនមែនគិតខុសទេ បណ្តាធម៌ទាំងឡាយដែលព្រះអង្គបែក
រំលែកល្អហើយ ព្រះនិព្វានឯណាជាគុណជាតិដ៏ប្រសើរ ខ្ញុំបានដល់នូវ
ព្រះនិព្វាននោះហើយ ខ្ញុំមកល្អហើយ ខ្ញុំមិនគេចចេញទេ គំនិតនេះ
ខ្ញុំមិនមែនគិតខុសទេ វិជ្ជា ៣ ប្រការខ្ញុំបានសម្រេចហើយ ពុទ្ធសាសនា
ខ្ញុំបានធ្វើតាមហើយ ។

អង្គុលិមាលសូត្រចប់ប៉ុណ្ណេះ ។

ព្រះមហាឧត្តមរាជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម
អាចារ្យសាលាចាលីវង្ស វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង
ឃុនបណ្ឌាឝ្រុក្ស ប៊ូ-ប៊ូ ឝៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តមក)

២— បេះពឹងខ្លួនឯង.— ពាក្យប្រដៅរបស់ព្រះពុទ្ធម្ចាស់ថា: "ខ្លួនជាទីពឹងរបស់ខ្លួន មនុស្សដទៃណាម្តេចនឹងគប្បីជាទីពឹងបាន" នេះជាពាក្យសម្រាប់ដាស់តឿនឲ្យយើងចេះពឹងខ្លួនឯង ។ ពិតមែនយើងនឹងមានជីវិតរស់នៅបាន ដោយសារអាស្រ័យខ្លួនឯងជាមូលហេតុ. យើងខូចមាសច្បាក់ ឈ្មោះថាខូចច្រែន យើងសូន្យមិត្តសំឡាញ់ ឈ្មោះថាសូន្យច្រែនជាងខូចមាសច្បាក់ បើសូន្យការចេះពឹងខ្លួនឯង ឈ្មោះថាសូន្យទាំងអស់ សូន្យទាល់តែទៅជាមនុស្សអនាថាគ្មានទីពឹង ។ មើលចុះដើមឈើគ្មានផ្លែ បក្សីមិនចុះចោម, ព្រៃគ្មានម្ចប់ឈើ សត្វមិននៅអាស្រ័យ, ឈើគ្មានផ្កា កមរជាតិមិនត្រូវការ, ជ្រោះគ្មានក្រសែទឹក ត្រីមិននៅ, នាយចៅហ្វាយមិនសំបូណ៌សម្បត្តិ ជាវត្ថារត់ចេញ, ប្រុសគ្មានទ្រព្យ សូម្បីនៅក្មេង ក៏ស្រីជាគចេញឆ្ងាយដែរ ។ ចូរបរិភោគអាហាររបស់លោក-អ្នក ដែលជាផលកើតឡើងដោយសារ

ញើសក្អែលរបស់ខ្លួន ព្រោះលោក-អ្នកជាមនុស្សមួយ ដែលច្បាប់ធម្មជាតិបានបញ្ជូនចូលមកកាន់លោកនេះ ជាមួយនឹងដើងពីរដៃពីរ ដែលវែង ។ មាំ ។ ល្អមឈានឆ្ពោះទៅយកវត្ថុដែលគួរជ្រាថ្នាណា ។ បានសមតាមជ្រាថ្នាគ្រប់យ៉ាង ។ "ក្នុងការណីយកិច្ចគ្រប់យ៉ាង យើងត្រូវពឹងខ្លួនឯង ព្រោះជាងពឹងនរណា ។ ទាំងអស់" នេះជាពាក្យមង្គលសម្រាប់ឲ្យយើងទឹករឭកដល់ការចេះពឹងខ្លួនឯង ។ ជោគវាសនា មិនអាចជួយមនុស្សឲ្យសំរេចសេចក្តីជ្រាថ្នាបានទេ ។ បើតាមពិត ការដែលសំរេចតាមសេចក្តីជ្រាថ្នានោះ នៅត្រង់ការចេះពឹងការងាររបស់ខ្លួនឯង ។ បើមាត់របស់លោក-អ្នកស្រែកសូមជំនួយអំពីទេវតា ហើយដៃរបស់លោក-អ្នក កំពុងប្រកបធ្វើការងារ ដោយសេចក្តីប្រឹងប្រែងមែនទែន នោះទេវតានឹងជួយលោក-អ្នកពុំខាន ។ តែបើលោក-អ្នកបានត្រឹមតែមាត់ស្រែកអង្វរករសូមឲ្យទេវតាជួយតែម្យ៉ាង ឥតធ្វើការអ្វីសោះ ក៏ប្រហែលគ្មានឱកាសថ្វាយទុក្ខជ្រាប់មនុស្សត ដែលនិយាយមិនបានច្បាស់លាស់ដែរ ។

ការចេះពឹងខ្លួនឯង គឺជាកូនសោមាសដែលសំពាប់ចាក់បើកទ្វារដើរទៅកាន់ជោគជាក ។ បើលោក-អ្នកស្រឡាញ់ការពឹងខ្លួនឯង គួរស្វែងរកទំពឹងដែលល្អជាន់ខ្ពស់ក្នុងខ្លួនឯង ល្អជាងការរង់ចាំទៅរកទំពឹងក្នុងខ្លួនអ្នកដទៃ ព្រោះខ្លួនឯងជាឃ្លាំងនៃការទំពឹងពុំនាក់ដូប្រែសើរ ។

បើលោក អ្នកអាស្រ័យខ្លួនឯងជាទីពឹងពិតមែនហើយ លោក-អ្នកក៏នឹងទៅជាឥស្សរសេរីដែនតេញ៉ាទី មានចិត្តក្លឹស្វាងីរកាយ មានជីវិតដ៏ថ្លៃស្អាង ក្នុងវត្តគ្រប់ចំណែកនៃអង្គារយ: តែការ:ដែលធ្ងន់ឲ្យស្រាលជំរះពង្រាបដងផ្លូវ ដែលជាទីធ្វើដំណើរទៅនៃជីវិតឲ្យស្អាតរាបស្ល ហើយតទៅ លោក អ្នកនឹងលែងពោលតែខ្លួនដោយអាងដល់ជោគវាសនាថា "ខ្លួនជាមនុស្សមានវាសនាតិច មិនមានបុណ្យត្រែងសំណាងដូចអ្នកដទៃ មិនមាននរណាមួយឧបត្ថម្ភគាំទ្រ មិនមាននរណាជួយលើកដំកើងខ្លួនឲ្យអណ្តែត" ។ កាលជ្រាបដូច្នេះហើយ លោក-អ្នកត្រូវពឹងខ្លួនឯង តាំងចិត្តធ្វើការងារទៅតាមបំណងដែលខ្លួនប៉ុនប៉ង នឹងមិនត្រូវប្រែត្រឡប់ ឬ នៅស្ងៀមនឹងថ្កល់ឡើយ ត្រូវពឹងអាស្រ័យខ្លួនឯងធ្វើការងារដោយសេចក្តីប្រឹងប្រែងមែនទែន មិនត្រូវបណ្តោយខ្លួនឲ្យរង់ចាំតែឧកាសល្អមកដល់ នឹងមិនត្រូវគាន់យកសេចក្តីលំបាកកង្វល់ណ:ជាមួយគ្នាឲ្យច្រើនជាងអ្នកម្នាង មិនត្រូវគាន់យកបែបយ៉ាងនៃមនុស្សដែលមានទិស្សយធ្ងាប់ទីពឹងអ្នកដទៃ ដែលចូលចិត្តនាំយកសេចក្តីលំបាកចូលមកទុកក្នុងខ្លួនដល់ទៅ ៣ យ៉ាងគឺ សេចក្តីលំបាកដែលខ្លួនធ្លាប់ប្រសព្វមកហើយ, សេចក្តីលំបាកក្នុងបច្ចុប្បន្ន នឹងសេចក្តីលំបាកក្នុងកាលដែលនឹកឃើញថា នឹងជួបប្រទះក្នុងវេលាខាងមុខទៀត ។

ពិតមែន ទិស្សយទំនឹងអ្នកដទៃ វាមែនជាគ្រឿងចង នឹងបណ្តុះសេចក្តីអាក្រក់ឲ្យកើតឡើងកើតផ្លែឡើងក្នុងខ្លួនឯង តាត់បង់នូវគំនិតដែល

ជាកុសល ។ មនុស្សដែលមានទំស្ប៉ែយព៌នឹងអ្នកជម្ងៃ ឈ្មោះថាជាក់ច្រក់ខ្លួនដោយខ្លួនឯង ។ អ្នកជាក់ច្រក់ខ្លួនដោយខ្លួនឯង ឈ្មោះថានាំមេរោគចូលមកកុកកង្វ ខ្លួន ។ បើកង្វ ខ្លួនមានពួជមេរោគគឺទំស្ប៉ែយព៌នាក់អ្នកជម្ងៃហើយ រោគគឺកាពជាមនុស្សអនាថា គឺកើតឡើងជាបន្ទាប់តទៅទៀត, មនុស្សកើតរោគអនាថានោះ ត្រូវឃុំគ្រងរាងកាយដោយសំពត់រហែក ហ៊ុមហាចិត្តរបស់ខ្លួនដោយកម្មដ៏លាមក. អស់សេចក្តីគោរពកប់អានក្នុងខ្លួនឯង ច្រាសចាកសេចក្តីស្មោះត្រង់ មានកម្ទាំងខន់ខ្សោយនឹងក្តៅក្រហាយគ្រប់យ៉ាង ត្រូវដើរសូមទានគេបរិភោគខ្លះ លបលួចគេបរិភោគខ្លះ មិនចូលចិត្តធ្វើការងារឲ្យជាដុំកំភួន ជាមនុស្សខន់ខោរមិនមានធ្មឹងខ្នុងខ្នង ឆ្ងន់មិនយកស្រាល មិនស្ងួ ចូលចិត្តធ្វើការងារដូចដង្កូវដែលចោះរកអ្វីចូលទៅគ្រាន់តែដើម្បីរកអាហារបរិភោគ គឺថា បើធ្វើការអ្វីគ្រប់យ៉ាង ធ្វើដោយសារតែសេចក្តីចង់រស់បង្គាប់ឲ្យធ្វើ ដើម្បីឲ្យខ្លួនបានអាហារបរិភោគគ្រប់ថ្ងៃ ទឹងមានកន្ទែងនៅគ្រប់គ្រាន់ប៉ុណ្ណោះជាមនុស្សរស់នៅតែត្រឹមមាត់ត្រឹមថ្ងៃ មិនបានគិតនឹងបណ្តុះខ្លួនឲ្យជាទំពីងរបស់ខ្លួន មិនច្រាថ្នាទឹងឲ្យខ្លួនឈានទៅមុខ មិនទឹកដល់សេចក្តីវ៉ែនវឿងនៃជីវិត តាំងពីណាឃើញតែការងារថាជាសេចក្តីលំបាកយ៉ាងពន្លឹក គិតឃើញតែត្រង់ថាធ្វើមិនបាន ឃើញតែការអាស្រ័យព៌នាក់អ្នកជម្ងៃ បានបរិភោគបន្តិចបន្តួចលំបាករវេនាថាជារបស់ល្អ ឈ្មោះថាធ្វើខ្លួនឲ្យជា

សត្រូវរបស់ប្រជាតម មិនឲ្យសអ្វីអំពីសង្កើច - មួសដែលចោមរោមបរិភោគ
ឈាមមនុស្សសត្វខ្លះ ព្រោះគ្រែអំពីការធ្វើខ្លួនឯងឲ្យក្តៅក្រហាយហើយ
គង់នៅបង្កសេចក្តីរំខានឲ្យដល់មនុស្សដទៃទៀត ជាមនុស្សខន្ធឹងចាំតែ
ខ្លួលផលនៃការងាររបស់មនុស្សដទៃ ធ្វើខ្លួនឲ្យជាដង្កូវ ឲ្យជាមនុស្ស
ល្មោយពួក ឲ្យជាបញ្ហែក្អែកខ្មង់លោក ដោយការមិនដឹង ឬក្លែង
បំភ្លេចនាទីរបស់ខ្លួនចេញ ។ "មកនេះ! ទៅ! ចុះ! ត្រែកឡើង!
និយាយ! ស្ងៀម!)" ពាក្យអំប៉ាលនេះ ជាពាក្យរបស់អ្នកមានទ្រព្យ
បង្គាប់បញ្ជាលេងនឹងមនុស្សជាអាប់ ដែលច្បាច្បាតែពីងគេ ដើរមុខ
ចូលទៅរកគេដោយចង់បានទ្រព្យចិញ្ចឹមជីវិត ។ ប្រយ័ត្នកុំឲ្យគេបង្គាប់
លេងនឹងលោកអ្នកដូច្នេះ នាំឲ្យខូចកិត្តិយស ។

លក្ខណៈនៃការចេះពឹងខ្លួនឯងនោះ គឺគឺការចេះជួយខ្លួនឯង ។
លោក - អ្នកចូរជួយខ្លួនឯងដោយការសិក្សា, ដោយការធ្វើការងារនឹង
ដោយការប្រព្រឹត្តសម្ងាចារ ។ ព្រោះការសិក្សាជាអណ្តាំកើតនៃ
ចំណេះវិជ្ជា, ការប្រកបការងារ ជាអណ្តាំហូរមកនៃគោលចារិកដ៏ម៉ាំមួន
គឺទ្រព្យសម្បត្តិ, ការប្រព្រឹត្តសម្ងាចារ ជាគ្រឿងតែងលោកអ្នកឲ្យជា
មនុស្សល្អ ។ ចំណេះវិជ្ជា, គោលចារិកដ៏ម៉ាំមួន ទឹងសេចក្តីល្អនោះ
ចាត់ថាជាមតិកយ៉ាងសំខាន់ចំពោះរូប មិនដូចជាម៉ាតិកក្នុងចំណោមមាស
ច្បាក់ ដែលនរណា ។ ក៏អាចខ្ចួលបាននោះទេ ព្រោះយើងអាចប្រើ

ច្រើន ទិញគ្រឿងឧបភោគបរិភោគ ឬចាយវាយជួយមនុស្សដទៃឲ្យធ្វើការងារឲ្យយើងបាន តែយើងមិនអាចនឹងទិញសតិបញ្ញាចំណេះវិជ្ជា និងសេចក្តីល្អអំពីមនុស្សដទៃ យកមកធ្វើជារបស់ខ្លួនបានឡើយ យើងនឹងទិញបានក៏ដោយសារតែការចេះជួយខ្លួនឯងម្យ៉ាងប៉ុណ្ណោះ ។ ព្រោះការចេះជួយខ្លួននោះឯង បង្រៀនយើងឲ្យចេះបរិភោគទឹក បរិភោគនំផ្អែមផ្លាញ់ និងអាហារប្រណីតបញ្ចុះរបស់ខ្លួនឯង ឲ្យចេះប្រើគ្រឿងឧបភោគបរិភោគដែលជារបស់ខ្លួនឯង ឲ្យចេះសិក្សាវិជ្ជាដោយធន្លុះខ្សាច់ ឲ្យចេះធ្វើការងារ បង្កើតការរកទ្រព្យសម្បត្តិ ក្នុងដីកងទឹកដោយសេចក្តីច្រឹងច្រែងយ៉ាងមុឺងមាត់ និងឲ្យចេះប្រព្រឹត្តកងវត្តុដែលល្អដោយប្រយ័ត្នប្រយែង ។ សរុបសេចក្តីឲ្យខ្លីទៅគឺថា ការចេះជួយខ្លួនឯងនោះ តែងនាំមកនូវចំណេះវិជ្ជា នូវគោលចារិកដ៏មាំទាំ និងនូវភាពជាមនុស្សល្អប្រគល់ឲ្យជាសទ្ធិដល់យើង ។

ហេតុនេះ លោក-អ្នកទើបត្រូវតែជួយខ្លួនឯង ។ បើលោក-អ្នកមិនសម្តែងសេចក្តីអង់អាចរបស់ខ្លួន ឲ្យអ្នកដទៃឃើញច្បាស់ក្សាជាមុនទេ គ្មាននរណានឹងលូកដៃចូលមកជួយលោក-អ្នកឡើយ "សាំញ៉ាំស្មៅនៅល្អគ្រាន់បើជាងសាំញ៉ាំមនុស្ស" នេះជាពាក្យបូរាណ កាលបើលោក-អ្នកធ្វើអ្វីមិនសម ឬធ្វើការងារនាំឲ្យខ្មើសខែង ក៏មុខជាត្រូវនឹងគាសិតនេះថា ជាមនុស្សស្មុគស្មាញក្នុងលោក ហើយនឹងត្រូវគេចោស

ចោលចាកសង្គមពុំខាន តែកាលបើលោក - អ្នកពឹងខ្លួនឯងបាន ដោយការជួយខ្លួនឯងហើយ មនុស្សដទៃក៏ត្រៃកអរ ក្នុងការជួយលោក - អ្នកដោយមុខរីករាយ ដូចការសិតបាំងថា Aide - toi le ciel t' aidera "ចូរអ្នកជួយខ្លួនអ្នកទើបទេព្តាជួយអ្នក" ។

មនុស្សដែលមានឧស្សាហ៍ព្យាយាមដទៃ ចូលចិត្តប្រតិត្តខ្លួនដូចជាបញ្ជើអ្នក ប្រាថ្នាតែនៅពឹងពាក់អាស្រ័យអែបនៃបនឹងមនុស្សដទៃជានិច្ច មិនព្យាយាមធ្វើខ្លួនឲ្យជាទីពឹងរបស់ខ្លួន ដែលចាត់ថាជាបច្ច័យឲ្យមនុស្សដទៃពឹងពាក់អាស្រ័យខ្លួនផងបានទេ ។ សូម្បីក្នុងខណៈដែលនៅអាស្រ័យគេ ក៏ធ្វើខ្លួនដូចជាសង្កើចទាំស៊ីសាច់ឈាមគេតែមួយចំណែក ។ មាតាបិតាដែលមានបុត្តធីតា បៃបបញ្ជើអ្នកនឹងបៃបសង្កើចជាច្រើនគ្នាហើយ រមែងមានតែការខ្វល់ខ្វាយតាមផ្ទាក់ផៅកាន់សេចក្តីវិនាសឆើបមិនរួចឡើយ ។ កាលបើនិយាយឲ្យឆ្ងាយទូរទៅដល់ប្រទេសជាតិផង ក៏គង់ឃើញថា ប្រទេសណាដែលមានតែពលរដ្ឋខ្វិលច្រអូសទន់ខ្សោយ បណ្តោយខ្លួនឲ្យពឹងអាស្រ័យតែមនុស្សដទៃ ប្រទេសនោះនឹងត្រូវសំយុងមុខចុះទៅកាន់សេចក្តីវិនាសលិចលង់ ព្រោះពលរដ្ឋទាំងនោះជាមនុស្សគំលាយខ្លួនឯង, គំលាយគ្រួសារ, គំលាយប្រជុំជន រហូតដល់គំលាយជាតិ, ភូមិ, ស្រុក, ប្រទេស របស់ខ្លួនឯងផង ។

លោក - អ្នកជាបង្គោលមួយរបស់ជាតិ បើប្រាថ្នាចង់ឃើញប្រទេសជាតិចំរើនរុងរឿង ក៏ត្រូវកុំធ្វើខ្លួនឲ្យដូចជាបញ្ជើអ្នកឬសង្កើច ដែល

ដំរុញចិត្តឲ្យរកសេចក្តីស្រួលសប្បាយតែចំណែកខ្លួន ដោយការពឹងពាក់អ្នកដទៃតែមួយចំណែកនោះឡើយ ។ ចូរព្យាយាមជួយខ្លួនឯង ដោយការកសាងខ្លួនឲ្យជាកោះសម្រាប់ទ្រទ្រង់ខ្លួនឯង, ដោយការសិក្សាសាងខ្លួនឲ្យជាទីពំនាក់របស់ខ្លួនឯង, ដោយការងារនឹងសាងខ្លួនឲ្យជាទីពឹងរបស់ខ្លួន ដោយការប្រព្រឹត្តិសម្មាចារី ។ កាលបើលោក-អ្នកពឹងខ្លួនឯងបានហើយ សូម្បីពឹងអ្នកដទៃក៏ងាយ ប៉ុន្តែនឹងពឹងខ្លួនឯងដែរ គឺពឹងគុណសេចក្តីល្អរបស់ខ្លួនឯង ។ ព្រោះលោក អ្នកមានគុណ គឺសេចក្តីល្អ ល្មមជាទីពឹងរបស់មនុស្សដទៃ ទើបល្មមឲ្យលោក-អ្នកពឹងពាក់អាស្រ័យមនុស្សដទៃបាន ។ មួយទៀត កាលបើលោក-អ្នកជួយខ្លួនឯងបានហើយ ក៏អាចជួយគ្រួសារ, ជួយពួកញាតិ ជួយមិត្តភក្តិ ទើបជួយជាតិបានផងក្នុងវេលាដែលត្រូវការ ។

បើចង់ឲ្យមានឥស្សរភាពពិតប្រាកដមែន ចូរមានជីវិតជាតួកោះសម្រាប់យឺតយោងសណ្តោងខ្លួនឯង កុំមានជីវិតសម្រាប់តែនៅអាស្រ័យទើបកោះរបស់អ្នកដទៃឡើយ ។ ព្រោះការប្រព្រឹត្តិ ដោយមិនអាស្រ័យកោះរបស់អ្នកដទៃ រមែងឲ្យផលល្អដល់ជីវិត ។ បើពឹងអ្នកដទៃ ត្រូវមានការអាស្រ័យកោះរបស់គេ ទើបបន្តជីវិតទៅបាន ហើយកាលឥតអំពីគេទៅ ខ្លួនក៏មិនអាចនឹងរស់នៅបានស្រួល ។ មនុស្សតាំងអស់គ្មាននរណាមួយសុខចិត្តស្លាប់ទេ ដូច្នេះកាលបើឃើញអ្នកណាមួយតាំង

ខ្ញុំបានម៉ាំមួនហើយ កំនាំគ្នាចូលទៅនៅអស្ចារ្យផង ។ សូម្បីតែពួកទេវតា កំរមែងប្រសិទ្ធិពរ ដល់អ្នកដែលម៉ាំមួននោះ ឲ្យមានអាយុយឺនយូរអង្វែង ព្រោះគេពឹងខ្ញុំនឯងបាន ហើយឲ្យអ្នកដទៃពឹងបានទៀតផង ។ លោក-អ្នកចូរនឹកជានិច្ចថា: ប្រមុខរបស់ខ្ញុំនយើង ក៏គឺជាវត្ថុឯង, មនុស្សដែលអស្ចារ្យគេចំញាំមដាវែត, មនុស្សខ្លិលប្រអូស, មនុស្សស្អប់ខ្ពើមការងារ, មនុស្សមើលងាយការងារ ដើរវែលវែល, មនុស្សល្មោភខ្លាំង ចូលចិត្តតែនរោកលុយចេបរំកោត នឹងមនុស្សចូលចិត្តលេងល្បែងក្តាល់ មនុស្សទាំងនេះឯងជាពួកដែលត្រូវបានខ្ញុំលចំណោក នៃសេចក្តីទុក្ខយ៉ាងខ្លាំងក្លា មិនអាចនឹងតាំងខ្ញុំនឲ្យបានរហូតទៅអស់ ១ ជាតិទេ ។

៣- ប៉ះជើខ្ញុំនឯង.— ការជឿខ្ញុំនឯង ជាឫសគល់នៃការណើយកិច្ចត្រង់យ៉ាង ។ ព្រោះថាកម្មគឺការធ្វើ ការនិយាយ នឹងការគិតដែលនឹងអាចសម្រេចជាផលបាននោះ ត្រូវមានជំនឿចំពោះខ្ញុំនឯងជាចក្រដឹកនាំ, មានការតាំងចិត្តធ្វើពិត ។ ជាចក្រនាំឲ្យផល, មានវីរិយ: ឧស្សាហ: ជាគុណភាព, មានសាមគ្គីជាគ្រឹងប្រកបប្រាប់ប្រាមតួចក្រឲ្យជាប់តស៊ូគ្នា ធ្វើដំណើរទៅបានស្រួលមិនលំបាក ។ កាលបើលោកអ្នកចាប់ធ្វើការងារណាមួយ ដោយសេចក្តីសង្ស័យ ដោយចិត្តមិនចុះសិប់ព្រោះខ្លះដំនឿចំពោះខ្ញុំនឯងហើយ សូម្បីហានដម្រែះវិជ្ជាច្រើន ក៏ធ្វើ

ការងារនោះឲ្យសម្រេចទៅពុំបាន ឬប្រសិនបើធ្វើអ្វីបាន ក៏ដោយសារតែមានអ្នកនាំផ្លូវ ឬអ្នកបង្គាប់បញ្ជា បើមិនមានអ្នកបង្ហាញផ្លូវ ឬអ្នកបង្គាប់ទេ ក៏ធ្វើការអ្វីមិនសម្រេចដែរ ។ តែគាលបើលោកអ្នកមានដម្រែវិជ្ជាច្រើន ហើយមានជំនឿចំពោះខ្លួនឯងប្រកបផ្សំផង ព្រមទាំងចាប់ធ្វើដោយចិត្តខ្ជាប់ខ្ជួន ដោយចិត្តស្ម័គ្រស្រឡាញ់ការងារយ៉ាងពិត ។ ផង ក៏រមែងធ្វើការងារនោះ ឲ្យបានសម្រេចផលល្អជាងអ្នកដែលមានវិជ្ជាច្រើន តែមានជំនឿចំពោះខ្លួនឯងតិចទៅទៀត ។

មែនហើយ វិជ្ជានោះជារបស់ល្អបំផុត អាចឲ្យអ្នកសិក្សាក្លាយទៅជាមនុស្សមានប្រាជ្ញាប្រសើរឈ្វេងយល់ដឹងច្បាស់បាន តែបើជាវិជ្ជានោះចូលទៅប្រកបនឹងការងារហើយ អាចអំណោយលទ្ធផលតែ ១០០ ភាគបានត្រឹមតែ ១៥ ភាគ (១៥%) ឯ ៨៥ ភាគទៀត (៨៥%) នោះ នៅត្រង់លក្ខណៈដឿខ្លួនឯង ។ ដូច្នេះមនុស្សដែលមានវិជ្ជាជាន់ខ្ពស់ហើយ តែគ្មានជំនឿចំពោះខ្លួនឯង ទើបមិនចាត់ថាជាអ្នកអាចធ្វើការងារឲ្យសម្រេចបានទេ ។ មនុស្សដែលធ្វើការងារឲ្យសម្រេចបាននោះ គឺមនុស្សដែលដឿខ្លួនឯងព្រមទាំងមានវិជ្ជាផង មិនមែនជាមនុស្សសង្ស័យឬល្ងង់ខ្លៅគឺមនុស្សតាំងចិត្តធ្វើពិត ។ មិនមែនឡេះឡោះបានតែមាត់ក្រៅ, គឺមនុស្សមានវីរៈ: ខ្សាហ. ព្យាយាម មិនមែនមនុស្សខ្លិលច្រអូសបានតែខាងសូមគេ, គឺមនុស្សដែលត្រេកអរក្នុងដៃរមែងចិត្ត រួមកម្លាំងគ្នាខ្លួនខ្លុំស

ត្រូវ មិនមែនមនុស្សរកតែគេចវេះ, គឺមនុស្សដែលជួយផ្តុកការងារលើស្មា មិនមែនមនុស្សឈរ ឬអង្គុយមើលត្រងើយកន្តើយ ។

និស្ស័យដឿខ្លួនឯង ជាអាវុធសំខាន់បំផុត អាចឈ្នះឧបស័គ្គ ទីឥសេចក្តីលំបាកគោកយ៉ាកឿយហាត់ប្រាណគ្រប់បែប ធ្វើឲ្យយើងដំណើរកិច្ចការទៅបានយ៉ាងហូរហែរហូតផុតចាំង ។ លោក-អ្នកចូរបន្ថុះនិស្ស័យដឿខ្លួនឯង កំចាត់និស្ស័យរួញរា សន្ទុះសង្ស័យទីឥអល់ឯកកន្ទុះរាចេញ ធ្វើខ្លួនឲ្យពេញជាខ្លួនរបស់ខ្លួនឯង អប់រំឲ្យមានចិត្តជាសមាធិ ចេះបង្ហាត់ចិត្តឲ្យក្លាហានម៉ឺងម៉ាត់កឥការងារ បើថាទីឥធ្វើ ក៏ត្រូវចាប់ធ្វើក្លាម តែត្រូវចេះដឿខ្លួនឯងយ៉ាងសុភាព បណ្តុះនិស្ស័យដែលធ្វើឲ្យអ្នកជុំវិញស្រឡាញ់ចូលចិត្តឲ្យមានរឿងក្នុងខ្លួន កុំពាយបូកចិត្តម៉ឺតក្រអឺតក្រទមដោយសំគាល់ថាខ្លួនជាមនុស្សវិសេសឯកឡើយ ត្រូវគិតដល់បុគ្គលជុំវិញផង ។ ចូរបណ្តុះនិស្ស័យដឿខ្លួនឯងតាមគោលចំនួនេះ គឺ:

ក) បណ្តុះនិស្ស័យដឿខ្លួនឯងដោយលក្ខណៈតទៅនេះ គឺ: យឺតយោងខ្លួនឲ្យត្រង់អង់អាច, អង្គុយឲ្យត្រង់កឥកាលអង្គុយ, ឈរឲ្យត្រង់កឥកាលឈរ, ប្រយ័ត្នកឥកាលដើរ ជាក់ស្តែងឲ្យតាំងទៅនឹងធឹង នឹងដើរយ៉ាងរហ័សរហួន មិនយឺតពើក ។, បណ្តាយឲ្យរាងកាយគ្រប់ចំណែកឲ្យសព្វទៅយ៉ាងស្រួលបួល សំដែងលំនាំឲ្យគេឃើញថា លោក-អ្នកមានជំនឿចំពោះខ្លួនឯង, ព្យាយាមកែប្រែលក្ខណៈគ្រប់តែសំដីនិយាយ

ទឹងត្រូវតែតវ៉ាយកឲ្យបានដែលសំដែងចេញមកជាគ្រឿងសំគាល់ ដល់សេចក្តីពាបថោករបស់ខ្លួនឯងឲ្យអស់រលីងទៅ ទឹងធ្វើខ្លួនឯងឲ្យជាតារាស័ គួរជាទីគោតខ្លាច ទឹងគួរជាទីគោរពរាប់អាន ឬជាប់ចិត្តរបស់មនុស្សដទៃ ។

២) បណ្តុះនិស្ស័យដឿខ្លួនឯង ដោយភាពជាអ្នកឲ្យតែងត្រង់ចំពោះវេលា "ការឲ្យតាត់តាមពេលវេលានោះ ជាព្រះរាជករណីយកិច្ចយ៉ាងសំខាន់របស់ព្រះមហាក្សត្រិយ៍, ជាទំរបស់មនុស្សសុភាពទឹងជាសេចក្តីត្រូវការយ៉ាងក្រៃលែង របស់បុគ្គលអ្នកធ្វើកិច្ចការទូទៅ" ។ បើយើងស្រឡាញ់ជីវិតរបស់ខ្លួនពិត ត្រូវកុំឲ្យខ្ជះវេលាណា ។ ព្រោះពេលវេលានេះឯង ច្រកបង្វែគ្នាឡើង តើតបានជាជីវិតរបស់យើង ។ ដូច្នេះ យើងត្រូវជាមនុស្សឲ្យតែងតាត់តាមពេលវេលា កាលបើតាំងចិត្តថាទឹងធ្វើការឯណា ត្រូវធ្វើការនោះឲ្យបានតាមពេលវេលា ។ សូម្បីកាលណាតាត់សន្យាទឹងអ្នកណា ក៏ត្រូវរក្សាកំណាត់សន្យានោះកុំឲ្យឃ្លៀងឃ្លាតទឹងត្រូវកាន់ការដឹកនាំឲ្យសន្សឹម ។ កុំឲ្យតូងតាង ព្រោះវេលាមានដំឡៃជាមាសជាប្រាក់ កុំបណ្តោយឲ្យកន្លងទៅដោយឥតប្រយោជន៍ សូម្បីត្រឹមតែ ១ វិនាទីឡើយ ។ ត្រង់ពេលដែលកន្លងទៅដោយឥតប្រយោជន៍នោះ ជាឱកាសវិបីបើកឲ្យគ្រោះកាច លបចូលមកកាន់ការងារដោយមិនដឹងខ្លួន ។ ការឲ្យតែងត្រង់ចំពោះពេលវេលានេះ ជាវិធីប្រយ័ត្នឲ្យមនុស្សចេះប្រើពេលវេលាដើម្បីធ្វើការងារត្រង់យ៉ាង, ឲ្យលោក-អ្នក

អស់កង្វល់កង់ចិត្តថាធ្វើអ្វី ។ មិនសម្រេច ទុំងឲ្យលោក អ្នកទៅជាទី
គោរពកប់អានទុកចិត្តរបស់មនុស្សដែរ ។

គ) បណ្តុះនិស្ស័យដឿខ្លួនឯងដោយបង្ហាត់ខ្លួនឲ្យជាមនុស្សហ្មត់ចត់
"ដើរដៃត្រកុំមើលតែដៃត្រឡើយ ត្រូវមើលដើមឈើផង" នេះជាការសិត
សម្រាប់ជាស់តឿនខ្លួនឲ្យទៅជាមនុស្សហ្មត់ចត់ ក៏ដែរ ធ្វើកិច្ចអ្វីក៏ដោយ
ត្រូវធ្វើឲ្យយ៉ាងហ្មត់ចត់ ត្រូវកុំសំឡឹងយើញតែចំណែកធំ ត្រូវមើលឲ្យ
យើញតាំងពីចំណែកតូចតាចឡើងទៅជាលំដាប់ ដរាបដល់ចំណែកធំ ។
មួយទៀតកាលបើធ្វើការអ្វី ចូរពិចារណាការនោះឲ្យដឹងច្បាស់លាស់ពិត
ប្រាកដជាមុនសិនសឹមធ្វើ កុំឲ្យភ្លាត់ខុសប្រែប្រួលទៅបាន ។

ឃ) បណ្តុះនិស្ស័យដឿខ្លួនឯង. ដោយការប្រព្រឹត្តិសម្ថៈចារី
គឺប្រព្រឹត្តិកិរិយាជាអ្នកសុភាពរាបរយ ស្គាល់ច្បាប់ទំលាប់ ទីជាប ទីខ្ពស់
ទីខាងក្នុង ទីខាងក្រៅ មានសម្ថគារៈ: មិនរឹងរូសរឹងត្អឹង ទុំងប្រព្រឹត្តិ
ខ្លួនឲ្យល្អត្រឹមត្រូវដោយកាយ វាចា ចិត្ត មិនត្រូវប្រព្រឹត្តិអំពើអាក្រក់
ថោកទាបដូចជាមនុស្សគ្មានយោរយៅ ចិត្តយង់ឃ្នង ស្រេវឹងស្រា ដក់
កញ្ជាដក់អាកៀនលេងល្បែងក្តាល់ផ្សេង ។ ដែលជាមនុស្សប្រកាន់ទិដ្ឋិ
មាន: ចូលចិត្តរករឿងឈ្លោះវិកទ ដែលជាហេតុឲ្យខូចក្តីឈ្លោះ ទុំង
ឲ្យជាទីមើលងាយនៃមនុស្សទាំងពួងនោះឡើយ ។

(មានត)

ឧកញ៉ាវិបុលរាជសេនា ស្វ-កន ប្រែរៀបរៀង

(ត្រមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាំងវិទ្យាសបើបាន់ឮអាន
ទឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

កណ្ឌទី ១៨

តាំងពីចូឆូសម្លាប់ឡាន់បេង ហើយឡោមព័ទ្ធលីហៅទៅស្រុកហៃហ៊ូ រហូតដល់តាំងស៊ុនឆឺងឡើងគិតផ្ចាំនឹងសម្លាប់ចូឆូ ។

ចូឆូក៏បង្គាប់ឲ្យយកខ្លួនឡាន់បុង៑ទៅកាត់ក្បាលដោតទុកនៅមុខបន្ទាយ ហើយបរពលចូលឡោមព័ទ្ធស្រុកហៃហ៊ូដុំវិញ ហើយកំផ្លាប់ភាក្យទុកថា បើមនុស្សក្នុងស្រុកវត់ចេញទៅបានត្រង់គយល្បាតពួកណា យើងនឹងយកទ្រោសនាយទំពាយកង៑ ដែលត្រួតត្រាពួកគយល្បាតពួកនោះដល់អស់ជីវិត ។ ឡៅពីបានភ្លុចូឆូដាក់ពាត្យឲ្យនាយទំពាយកង៑ដូច្នោះក៏លាចូឆូរលៅទៅបន្ទាយ ហើយនិយាយដាក់ពាត្យលើគួនអ៊ូ, តៀវហ៊ុយ ស៊ុនខឿនឲ្យប្រុងប្រយ័ត្ន កុំឲ្យលីប៉ោនឹងអ្នកនុតទៅមករកគ្នាបាន ។

ខណៈកាលគៀវហុយនឹងឡានបុងកំពុងចាំងគ្នានោះ ខៅគីនឹងអងកាយក៏រត់មកដល់ក្រុងហៃហ្វឺ ហើយចូលទៅប្រាប់លីចាំថា ខ្ញុំបានបានទៅដល់ក្រុងហួយណាំ បានប្រាប់អ្នកសុតសព្វប្រការ អ្នកសុតថាឲ្យលោកបញ្ជូនកូនក្រមុំទៅឲ្យមុនវិញទើបនឹងលើកទ័ពមកជួយ ដែលនឹងលើកមកមុននោះ អ្នកសុតថាបានយើញចិត្តលោកម្ដងហើយ ។

លីចាំក៏ប្រឹក្សាថា ឥឡូវកងទ័ពចូរូឡាមព័ទ្ធស្រុកយើងដុំវិញដូច្នេះធ្វើម្ដេចយើងនឹងឲ្យនាំកូនក្រមុំចេញទៅបាន ។ ខៅគីធ្វើយថា កាលចូរូបានខ្លួនឡានបុងយកទៅ ក៏សាកសួរដឹងសេចក្ដីអស់ហើយ ដែលលោកនឹងប្រើអ្នកដទៃ ឲ្យទៅជំនួសនោះកម្រណាស់ សុំឲ្យលោកលើកតាហានដែលមានថ្វីដៃ ជូនដំណើរឲ្យនាំកូនក្រមុំទៅដល់ច្រកល់ដែនស្រុកហួយណាំទើបនឹងចេញទៅបាន ប្រសិនបើចូរូនឹងតច្បាំងប្រការម្ដេច នឹងបានជួយការពារឲ្យមាំមួន ។ លីចាំយល់យើញត្រូវទើបចាត់ប្រៃតៀវលៀវនឹងកោស៊ុនឲ្យលើកតាហាន ៣ ០០០ នឹងវរនេះតូច ១ ហើយនិយាយថា "យើងត្រូវប្រើអ្នកឲ្យឃុំនាំខ្លួនកូនក្រមុំយើងទៅឲ្យអ្នកសុត យើងនឹងជូនដំណើរអ្នកចេញទៅដល់ច្រកល់ដែនស្រុកហួយណាំ, ថាហើយឲ្យកូនក្រមុំតែងខ្លួនពាក់ក្រឹសយ៉ាងខាំមួនណាស់ ។ លុះដល់ពេលយាម ២ យប់ លីចាំក៏យកពៃតណៃ ៣ ផាប់ចងរុំខ្លួនកូនក្រមុំណែន ហើយស្ពាយពីក្រោយខ្លួនឡើងដិះសេះកាន់ខ្លួន នាំកោសុននឹងតៀវលៀវលើកតាហាន ៣,០០០ លបចេញទៅផុតពីស្រុកហៃហ្វឺ" ។

ឯតាហានចូឆ្នូវដែលឡោមព័ទ្ធស្រុកនោះ មិនបានសង្កេតត្រួតត្រាជាមាំមួន ក៏បណ្តោយឲ្យលីចោ"ឈបចេញទៅបាន ។ លុះលីចោ"ទៅដល់ព្រំដែនស្រុកហួយណាំខ្លួនគួនអ៊ូ, តៀវហ៊ុយលើកតាហានចេញទៅយោមលបតៀបខ្លួយ ឃើញលីចោ"នឹងតាហានលើកទៅដល់តៀវហ៊ុយស្រែកថាអាលីចោ"អាឯងលបរត់ទៅណា? ។ លីចោ"ឃើញគួនអ៊ូ, តៀវហ៊ុយស្គាល់ទឹងពីមុខក៏ញាក់សេះនឹងស៊ុះខំលាយ ខ្លួលឡៅពីក៏លើកតាហានតាមមកជាន់លីចោ"ពីក្រោយ លីចោ"ភ័យណាស់ខ្លាចគួនក្រមុំនឹងអន្តរាយ ក៏បរពាខំលាយកងទ័ពចូឆ្នូត្រឡប់ចូលទៅកុងស្រុកហៃហ្វីវិញបាន ។ ឡៅពី, គួនអ៊ូ, តៀវហ៊ុយក៏លើកតាហានតាមមកទៀត ឡោមព័ទ្ធស្រុកនោះពីទិសខាងលិច ។

លីចោ"គាល់គំនិតមិនដឹងគិតយ៉ាងម្តេច ក៏បេះតែធីកស្រាពិកល្ងាចមិនឈប់ឈរពេលណាសោះ ចូឆ្នូក៏ឡោមព័ទ្ធស្រុកហៃហ្វីខុតដល់ ៣ ខែ ។ លីចោ"ក៏មិនបានចេញតប្បាំងសោះ ចូឆ្នូនឹងលើកទ័ពវាយខំលាយឃើញថាលីចោ"ត្រួតត្រាការពារសែនបន្តាយមាំមួនណាស់ ។ ខ្លួលមានបំរើសេះនាំសេចក្តីចូលទៅដំរាបចូឆ្នូថា តៀវអេងចៅហ្វាយស្រុកហោឡាយដឹងថា មហាឧបរាជលើកទ័ពមកឡោមព័ទ្ធស្រុកហៃហ្វី តៀវអេងក៏លើកតាហាននឹងមកជួយលីចោ" អៀវស៊ីវានាយតាហានមិនយល់ព្រមលិបសម្ងាប់តៀវអេងស្លាប់ ហើយកាត់ក្បាលនឹងនាំមកជូន

មហាឧបាសក, លុះមកដល់ពាក់កណ្តាលផ្លូវ អ៊ុយក ជាមនុស្សស្មុគ្ធរបស់តៀវអេងតាមមកទាន់សម្ងាប់តៀវស៊ីវបាន ហើយនាំក្បាលតៀវអេងវិលទៅស្រុកវិញ ។

ប៊ូឆូបានឮដូច្នោះ ក៏ប្រើស៊ីហ៊ីនលើកទាហានទៅសម្ងាប់អ៊ុយកបានហើយ ប្រដុំនាយទ័ពនាយកងទាំងពួងមកប្រឹក្សាថា: ឥឡូវតៀវអេងស្លាប់ទៅហើយ សត្រូវរបស់យើងខាងទិសឯដើងនៅបាម្កវែងតែអ៊ីនសៀវ ចុំណែកទិសឯលិច វែងតែឡៅតៀវនឹងតៀវស៊ីវមានកំឡាំងខ្លាំងពូកែឡើង យើងនឹងទុកចិត្តមិនបាន ឥឡូវយើងមកឡោមព័ទ្ធក្រុងហៃហ៊ីទុកយូរហើយ ទាហានទាំងឡាយក៏មានតែសេចក្តីខ្ជឿយលំបាក យើងនឹងត្រឡប់ទៅស្រុកហ៊ូតៅវិញ ដើម្បីនឹងបំរុងប្រុងប្រៀបរៀបចំសន្សំសេនាទាហានឲ្យមានច្រើនឡើងទៀត ទុកបង្ការស្រុកយើងឯនាយផង តើក្នុកទាំងឡាយនឹងយល់ឃើញដូចម្តេច? ។

ស៊ុនហុកឆ្លើយថា យើងធ្វើការគ្រានេះលើបោ"ក៏ថ្មោះការនឹងយើងជាច្រើនគ្រាហើយ ជិតនឹងចាល់ច្រកយកខ្លួនមិនរួច ដែលនឹងលើកទ័ពត្រឡប់ទៅវិញនោះ ខ្ញុំបាទយល់ឃើញថា លីបោ"គង់នឹងមានកម្លាំងខ្ជឿងវិញ បើយើងនឹងវិលមកធ្វើការទៀតក៏លំបាកនឹងយកដ័យដំនះណាស់ ។ គុយកែឆ្លើយថា មហាឧបាសកកុំតែក្តព្រួយខ្ជឿយ ស្រុកហៃហ៊ីនេះជាមុខងារបស់ខ្ញុំបាទនឹងគិតកលឧបាយវាះបង្ខូចបែកបាន ។

ចូឆួសួរថា អ្នកនឹងគិតធ្វើប្រការម្តេច? ។ គុយតែឆ្លើយថា ឥឡូវនេះ
ជាទេសកាលទឹកដីនន់ជន់ឡើងលិចគ្រប់អន្ទឿ ហើយហូរចុះមកស្បែរស្រុក
ហៃហ្ន៎ ខាងទិសឯលិចសុំឲ្យលោកវិនគិតចាត់ពាហានទប់ទឹកស្ទឹងខាងត្បូង
ដែលមានដងស្ទឹងហូរខាងលិចស្រុកនោះឲ្យជាប់ កុំឲ្យទឹកហូរចុះទៅបាន
បើមានទំនប់ដូច្នេះហើយ គង់តែទឹកនឹងហូរចូលមកកន្លែងស្រុកហៃហ្ន៎លិច
ខាងអស់ លីចោ"ក៏ថ្លោះការរបស់យើងជាច្រាកដ ។

ចូឆួបានស្តាប់យើញត្រូវណាស់ ក៏ឲ្យប្រមូលពាហានចុះទៅលើក
ទំនប់ទប់ស្ទឹង ហើយឲ្យលើកទំនប់ទប់ព័ទ្ធជុំវិញស្រុករហូតឡើងមកបើក
ប្រឡាយ ១ ឲ្យហូរចូលទៅកន្លែងស្រុកហៃហ្ន៎ លុះមានភ្លៀងធំធ្លាក់មក
ទឹកនោះក៏ហូរចុះពីលើភ្នំតាមពោះស្ទឹងចុះទៅខើរលើទំនប់ ត្រឡប់ហូរ
ចូលទៅក្នុងស្រុកហៃហ្ន៎លិចអស់ផ្ទះសម្បែង ។ អ្នកស្រុកក្នុងស្រុកនោះ
ក៏ផ្អើលជ្រួលច្របល់ខ្លាំងណាស់ បណ្តាមនុស្សម្នាក៏នាំយកសេចក្តីទៅ
ជំរាបលីចោ" ។ ក៏ថា "យើងនឹងអារម្ភខ្លាចទឹកនោះធ្វើអ្វី សេះសឹកចៅ
របស់យើងមានកំឡាំងច្រើនណាស់ ចោលធ្នូទឹកដូចជាចោលលើគោក
ដូចគ្នា" ហើយលីចោ"ក៏មិនមានយកចិត្តទុកដាក់ ចេះតែផឹកស៊ីសប្បាយ
ពាល់វេលា ។ ខណៈនោះ លីចោ"ក៏ជតាកសីថយចុះ ថ្លៃមួយកវិយោ
យកកញ្ចក់មកឲ្យលីចោ"ឆ្លុះមើលមុខ ។ លីចោ"យើញទឹកមុខខ្លួនសៅហ្មង
ក៏គិតថា "ដោយហេតុធំកស្រាច្រើន ស្រានេះរមែងជាពេសច្រើន

ណាស់ ទោះអ្នកឯណារូបស្អាតល្អដូចម្តេចក៏គង់តែសៅហ្មងព្រោះស្រា ។ លីចោ"គិតឃើញដូច្នោះ ក៏ចេញទៅប្រកាសហាមសេនាពាហានតាំងពួងថា តាំងថ្ងៃនេះតទៅបើនរណាសេពសុរាទឹងយកទោសកាត់ក្បាលចេញ ។

ខណៈនោះ មនុស្សដែលថែរក្សាសេះលីចោ" គិតល្ងង់យកសេះ ១៥ ទៅឲ្យខ្លៅពី ។ ហៅសេងជានាយត្រួតដឹកនាំទាន់ ក៏តាមទៅចាប់ខ្លួនមនុស្សពាំងសេះនោះទៅសម្លាប់បង់ ។ នាយខ័ននាយកងតាំងពួងដឹងដូច្នោះ ក៏បបួលគ្នាទៅសួរហៅសេង។ គិតចង់លៀងស្រាបណ្តាពាហានតាំងពួង តែខ្លាចអាជ្ញាលីចោ" ក៏ចូលទៅដំកបលីចោ"ថា មានអាចារកំណាចលួចនាំសេះចេញទៅឲ្យខ្លៅពី ខ្ញុំបានតាមទៅទាន់សម្លាប់អស់ទៅហើយ ពីព្រោះបុណ្យរបស់លោកមិនដែលខូចរបស់ទឹងសឹកសត្រូវ ឥឡូវនាយខ័ននាយកងតាំងពួងមកសួរខ្ញុំបានជាច្រើន ខ្ញុំបានចង់សុំចាប់លោកលៀងស្រា តើលោកនឹងប្រុងសមត្តាបានឬទេ? ។

លីចោ"ឆ្លើយតបទៅវិញថា ៖ យើងបានហាមឃាត់ថា ស្រានេះជាទោសទឹងនាំឲ្យខូចផលប្រយោជន៍តាំងពួង បើនរណាផឹកស្រា យើងនឹងកាត់ក្បាលចេញ ហេតុម្តេចខ្លួនមកចរចាសុំលៀងស្រាដូច្នេះទៀតចង់ឲ្យខូចអាជ្ញារបស់យើងឬ?" ថាហើយក៏បង្គាប់ពាហានឲ្យចាប់ខ្លួនហៅសេងទឹងយកទៅសម្លាប់ ។

ស៊ីងហៀនទឹងងុយសុក ក៏ចូលទៅអង្វរសុំទោសហៅសេង ។ លីចោ"ថា "ហៅសេងធ្វើខុស ទោសត្រូវប្រហារជីវិតហើយ តែយើង

យល់ដល់អ្នក ព្រមលើកទោសឲ្យរួចជីវិតម្តងចុះ" ហើយឲ្យគាហានយក
ខ្លួនហៅសេងទៅវាយដោយរំពាត់ ៥០ ខ្សាប់ ។ គាហានទាំងពួងឃើញ
ដូច្នោះក៏តូចចិត្តពន់ពេក ។ ស៊ុងហៀនទើងទុយសុកក៏នាំគ្នាទៅសួរហៅ
សេងដល់ផ្ទះ ហៅសេងក៏ចេញទៅទទួលហើយនាំឡើងទៅអង្គុយនិយាយ
ថា "កាលពីម្សិលមិញបើកុំតែអ្នកទាំងពីរទៅជួយខ្ញុំហើយ ខ្ញុំក៏មិនបាន
រស់ឃើញមុខអ្នកឡើយ" និយាយហើយហៅសេងអង្គុយយំ ។

ស៊ុងហៀនថា សព្វថ្ងៃនេះលីចោ"ប្រែកិរិយាខុសពីដើមប្លែកណាស់
ព្រោះមិនយកចិត្តសេនាគាហាន ដឿស្តាប់តែពាក្យកិរិយា ទាល់តែបូតូ
លើកទ័ពឡោមព័ទ្ធស្រុកទុកដុំវិញ ហើយទប់ទឹកឲ្យឡើងលិចក្នុងស្រុក
ទាំងអស់ ដូច្នេះហើយ លីចោ"ក៏នៅព្រងើយកន្តើយមិនយកចិត្តយើង,
យើងទាំងឡាយដូចជាមនុស្សមានជម្ងឺឈឺធ្ងន់ មិនអាចដឹងថាថ្ងៃណាខ្លួន
ស្លាប់ ហេតុដូច្នេះយើងត្រូវតែលះបង់ចោលលីចោ" គិតរត់ចេញឲ្យតែ
រួចអាយុជីវិតចុះ ។

ង៉ុយសុកថា បើយើងនឹងរត់ចេញទៅទេដូចមិនមែនជាជាតិ
គាហាន គួរតែយើងព្រួតគ្នាចាប់ខ្លួនលីចោ"ឋាបញ្ជូនទៅឲ្យបូតូ ដើម្បីយក
គុណគាប់ប្រសើរជាជាង ។ ហៅសេងថា លីចោ"នេះមានកម្លាំងខ្លាំង
ពូកែណាស់ មានជំនិះគឺសេះសិកចៅក៏ចំណាប់ បើយើងនឹងគិតចាប់
លីចោ"គួរតែលួចយកសេះសិកចៅទៅឲ្យបូតូសិន ។ ស៊ុងហៀនទើងទុយ-

សុភក័យល់ត្រូវគ្នា លាហៅសេងត្រឡប់ទៅផ្ទះ លុះដល់ពេលយប់ហៅ
សេងក៏ចូលទៅលួចយកសេះសឹកថៅមកបាន ចេញទៅរកចូឆូតាមផ្លូវ
ព្នាវទិសឯកើត ហើយហៅសេងក៏នាំសេះនោះទៅជូនចូឆូ ដំរាបថាខ្ញុំបាន
ទឹងឆុយសុក-ស៊ីងហៀន គិតគ្នានឹងចាប់ខ្លួនលីចោ៉ាមកជូនមហាឧបរាជ ។
ចូឆូបានស្តាប់ក៏មានចិត្តត្រេកអរណាស់ ទើបសរសេរសេចក្តីចងនៅចុង
ព្រួញបាញ់ផ្ញើងទៅក្នុងស្រុកហៃហ្វឺ សេចក្តីថា "ឥឡូវលីចោ៉ាអស់
អំណាចដោយជតាពសឹកហើយ ឧបមាដូចជាខ្លានៅក្នុងអណ្តូងបើប្រសិន
អ្នកឯណាចាប់ខ្លួនលីចោ៉ានាំទៅឲ្យយើងបាន យើងនឹងឲ្យបំណាច់ផ្ងាន
តាំងជានាហ្នឹងធំ" ។ លុះពេលព្រឹកឡើងចូឆូក៏បរពលទំលាយបន្ទាយ
ចូលទៅក្នុងស្រុក តាហានដែលរក្សាទាទីសែនបន្ទាយ ក៏តតាំងច្បាំង
តាប់សម្លាប់គ្នាស្លាប់ជាច្រើន ។

លីចោ៉ាឮសំឡេងគឹកកងក៏ភ័យតក់ស្លុត ហៅតាហានឲ្យយកសេះសឹក
ថៅ តាហានដែលរក្សាសេះនោះជំរាបថា ហៅសេងលួចយកសេះនោះ
នាំទៅឲ្យចូឆូឥឡូវមិញទៅហើយ ។ លីចោ៉ាក៏ចាប់យកខ្លួនសុះឡើងទៅ
លើសែនបន្ទាយឃើញស៊ីងហៀន, ឆុយសុក ក៏សួរថា "ហេតុម្តេច
ខ្លួនឯងប្រែចិត្តទៅចូលនឹងគេហៅសេង លួចយកសេះអញទៅ បើតាល
ណាអញធ្វើការនេះសម្រេច អញនឹងកាត់ក្បាលឯងទាំង ២ នាក់ឲ្យបាន"
ថាហើយលីចោ៉ាក៏បង្ខំដេញតាហានឲ្យចេញទៅតច្បាំងនឹងកងទ័ពចូឆូ តាំង

ពីព្រឹកឆាប់ដល់ថ្ងៃត្រង់ តាហានចូលធ្វើថយក្រោយទៅវិញ លីចោ"ក៏វិលមកអង្គុយលើកៅអីនៅច្របូរស្រុកខាងក្នុង ហើយយកខ្លួនផ្អែកនឹងកំពែងក៏ធ្វេសលក់ទៅ ។ ស៊ុងហៀនទឹងឃុយសុកឃើញបានការដូច្នោះ ក៏ធ្វើជាដូចជាចូលទៅច្រឹក្សាការពារការ ហើយបណ្តេញតាហានដែលនៅរក្សាខ្លួនលីចោ"នោះឲ្យថយចេញ ឃុយសុកក៏កន្ត្រាក់យកខ្លួនទៅចោះចោលឆ្ងាយពីលីចោ" ហើយស៊ុងហៀនទឹងឃុយសុកសុះត្រមគ្នា ចូលទៅយកខ្សែចងលីចោ"។ ភ័យភ្ញាក់ឡើងស្រែកឲ្យតាហានជួយ តាហានចាំងអស់នោះក៏គ្មាននរណាម្នាក់ទឹងចូលទៅជួយសោះ លុះចងលីចោ"ជាប់ហើយ ឃុយសុកក៏បើកច្របូរស្រុកស្រែកប្រាប់ប្រកាសតាហានចូរធ្លូថាយើងចាប់ចងខ្លាប់ហើយ ឲ្យច្របាច់ចូលមកយកខ្លួនទៅចុះ ។

ហៃហ៊ូអឿនឮដូច្នោះ ក៏បំផាយសេះចូលទៅដល់ច្របូរស្រុកតែគិតសង្ស័យថា លីចោ"នឹងធ្វើកល។ ចាំយដូចម្តេចទេដឹង តែឆ្ងល់ហេតុម្តេចក៏មិនឃើញមានសេះ ។ ខ្លួលឃុយសុកយកខ្លួនរបស់លីចោ"ចោលចេញទៅជាសំគាល់ ហៃហ៊ូអឿនទឹងតាហានចាំងពួងក៏អស់សង្ស័យ សុះស្រែចូលទៅក្នុងស្រុកហៃហ៊ូបាន ។ ឯកោស៊ុនទឹងតៀវលៀវដែលរក្សាត្រតត្រាយាមល្បាតច្របូរទិសខាងលិចដឹងថា ស៊ុងហៀនទឹងឃុយសុកច្របូសវាយលីចោ" ក៏ចុះពីលើនាទីសែនបន្ទាយទៅជួយលីចោ" ។ ខ្លួលតាហានចូរធ្លូទំលាយបន្ទាយច្របូរស្រុកចូលមកបាន ក៏ចាប់ខ្លួនកោស៊ុនទឹង

តៀវលៀវបានទៀត ។ តាន់កុងយើញគាហានចូឆូហែកទំលាយចូលទៅកន្លែងស្រុកបាន ក៏ឡើងសេះបំផាយចេញតាមទ្វារស្រុកទៅទិសឯដើងជួបប្រទះនឹងស៊ីឡង ។ លើកគាហានពីខ្នងតាន់កុងបានទៀត ។ ចូឆូក៏លើកទ័ពចូលទៅតាំងនៅក្នុងស្រុកហៃហ្វឺ ហើយចាត់គាហានទៅរំលើងរំលាយទំនប់ដែលទប់ទឹកនោះចេញ ទឹកក៏ហូរស្រុកអស់ទៅ ហើយចូឆូក៏ជ្រាប់ជ្រាមអស់បណ្តាពលទ្លា ដែលទៅកន្លែងស្រុកនោះឲ្យនៅជាសុខក្សេមក្សាន្តតាមប្រក្រតី ។

ចូឆូក៏នាំទ្លៅពីឡើងទៅអគ្គិយលើសែនឈ្មោះបេកប៊ុនទ្លៅ គួនអ៊ូ, តៀវហ៊ុយក៏ឡើងទៅជាមួយ ចូឆូក៏នាំខ្លួនលីចោ៉ឡើងទៅ ។ លីចោ៉ក្រឡេកឃើញគាហានតាំងពួន ព្រួតគ្នាចូលចាប់ចងខ្លួនខ្ជាប់តែរួតស្ទើរតែនឹងស្លាប់ដូច្នោះក៏ស្រែកថា មហាឧបាជសូមអាណិតមេត្តាខ្ញុំបាទផង ។ ចូឆូថា ធម្មតាខ្លាដែលជាប់ចំណងយ៉ាងមាំមួនហើយគេមិនដែលស្រាយលែងទេ ។ លីចោ៉ឮដូច្នោះក៏ចាល់គំនិត ក្រឡេកទៅឃើញហៅសេង, នឹងស៊ីងហៀន, ង៉ុយសុក ឈរក្បែរខ្លួន លីចោ៉ក៏ស្តីថា អញបានចិញ្ចឹមក្បាជួយទំនុកបំរុងខ្លួនឯងពាល់គ្នាជាយូរមកហើយ ហេតុម្តេចខ្លួនមកគិតខ្ជិសនឹងអញដល់ពីរនេះ ។ ស៊ីងហៀនថា យើងធ្វើដូច្នេះ ព្រោះអ្នកឯងមិនដឿស្តាប់ពាក្យយើងសោះ អ្នកឯងដឿស្តាប់តែពាក្យគរុយា ហើយត្រឡប់មកកេរឿងធ្វើទោសយើងវិញ ហេតុម្តេចក៏ថាយើងគិតខ្ជិសខ្លួន ។ លីចោ៉ឮដូច្នោះក៏ពុញចាល់មិនដឹងធ្វើយថាប្រការម្តេច ។

ឯតាហានដែលចាប់ខ្លួនគោស៊ុនបាន ក៏ចងនាំទៅជូនបូតូ។ សួរថា អ្នកឯងមានការនិយាយនឹងយើងឬទេ? ។ គោស៊ុនមិនឆ្លើយ បូតូខឹងណាស់ ប្រើតាហានឲ្យនាំខ្លួនគោស៊ុនយកទៅច្រហារដើរតែ ។ ក្រោយនោះ ស៊ីឡុងក៏ឃុំនាំខ្លួនតាន់កុងទាំងចំណងឡើងទៅជូនបូតូទៀត ។ បូតូសួរថា តាំងពីអ្នកឯងឃ្លាតចាកយើងមក បានសេចក្តីសុខសប្បាយជាទេឬ? ។ តាន់កុងឮដូច្នោះក៏សំគាល់ថា បូតូនិយាយឡកឲ្យខ្លួនក៏ឱនក្បាលណាស់ឆ្លើយថាអ្នកឯងជាមនុស្សអាក្រក់ណាស់ មិនមានសេចក្តីសត្យពិតត្រង់ មានតែឆបោកមនុស្សឲ្យវង្វេងដោយកលឧបាយ បានជាយើងរត់ចោលតាំងពីនោះមក ។ បូតូឆ្លើយថា យើងជាមនុស្សអាក្រក់ហើយ បានជាអ្នកឯងរត់ចេញពីយើងទៅ ហេតុម្តេចមិនទៅនៅទីងមនុស្សល្អ ក៏បានជាមកនៅទីលីប៉ោជាមនុស្សអាក្រក់ទៀត? ។ តាន់កុងឆ្លើយថា លីប៉ោជាមនុស្សគ្មានដំរេះច្បាស់ជាមិនចេះគិតការអ្វីក៏មែន តែមិនបានជាមនុស្សកូតកុហកដូចខ្លួន បានជាយើងចូលមកនៅធ្វើការផង ។ បូតូថា លីប៉ោជាមនុស្សគ្មានដំរេះច្បាស់ ខ្លួនអ្នកឯងជាអ្នកមានដំរេះច្បាស់ ហេតុម្តេចក៏បណ្តាយឲ្យលីប៉ោធ្វើការដូច្នេះ? ។

តាន់កុងស្តាប់ហើយងាកទៅនិយាយនឹងលីប៉ោថា ព្រោះតែខ្លួនមិនចេះស្តាប់យើងរំលឹកសោះ បានជាធ្វើការយ៉ាងនេះ បើជាស្តាប់ពាក្យយើងខ្ញុំ កាលណាឡើយនឹងរាប់យសខ្លួនតាហានទាំងពួងដូច្នេះ ។

ចូរឆ្លងតាន់កុងនិយាយដូច្នោះកំថា លីចៅមិនស្តាប់ពាក្យខ្ញុំបានដាច្នោះការ
ឥឡូវខ្ញុំមានប្រាជ្ញានឹងគិតដូចម្តេច? ។ តាន់កុងឱនឯណាស់ស្រែក
គំហកថា ខ្ញុំអញគ្រានេះដល់អាយុជីវិតនឹងស្លាប់ហើយ ឯងមិនត្រូវ
មកដេញដោលសួរយកការធ្វើអ្វីទៀតទេ ។ ចូរធ្វើជាមិនឱនសួរថា
ដែលខ្ញុំនិយាយនេះត្រូវហើយ តែថាមាតានឹងកំរិយាបុត្រវេស់ខ្ញុំ ។
នឹងគិតប្រការម្តេច? ។ តាន់កុងបានស្តាប់កំគិតអាល័យដល់មាតានឹង
កំរិយាបុត្រពន់ប្រមាណ ទ្រើយតបទៅចូរវិញថា ធម្មតាជាតិសេនា
គាហានឹងប្រាថ្នាតាំងខ្ញុំជាធំ ពោះបើនឹងចាប់សឹកសត្រូវបាន គេក៏ម៉ិន
ដែលមានធ្វើអន្តរាយដល់មាតាបិតាកំរិយាបុត្រសត្រូវនោះទេ គេធ្វើ
អន្តរាយចំពោះតែរូបអ្នកដែលប្រព្រឹត្តខុសនោះ ដូចខ្ញុំយើងក៏មានទោស
ដល់អាយុជីវិតហើយ យើងមិនមានស្តាយរូបកាយនេះទេ តែមាតា
នឹងកំរិយាបុត្រវេស់យើង។ សូមផ្ទើនឹងមហាឧបរាជ។ ត្រូវមានសេចក្តី
ករុណាចិញ្ចឹមរក្សាផងចុះ ។ ចូរក៏នឹករលឹកដល់គុណបុការតាន់កុង
ដែលបានជួយសង្គ្រោះដោះខ្ញុំមកពីខាងដើម ប្រាថ្នានឹងចិញ្ចឹមរក្សា
តាន់កុងខ្លាំង មិនខានឱនឹងថាប្រការម្តេច តាន់កុងក៏ស្ទុះលោតចុះពីលើ
សែន ដើម្បីនឹងឲ្យគាហានសម្លាប់ខ្ញុំចេញ ។ ចូរឃើញដូច្នោះក៏ឲ្យ
គាហានចាប់ខ្ញុំតាន់កុងខ្លាំង តាន់កុងមិនព្រមស្តាប់ ចូរក៏មានចិត្តអាណិត
អាណាថដើរយំពីក្រោយទៅហើយក៏និយាយនឹងតាន់កុងថា បើអ្នកមិន

ចូលចិត្តនៅជាមួយនឹងយើងក៏វាហ៊ីទៅចុះ តែមានតែនឹងកវិយាបុត្រវបស់អ្នក យើងខ្លួលពិភ័ក្តិវិក្យា អ្នកកុំបីមានវិតក្កខ្លុកក្តៅផ្សារឡើយ ។ ឯតាន់កុង ដើរទៅដល់ក្រៅកំពែង ក៏សំដែងអាការឲ្យតាហានប្រហារជីវិតស្ងាប់កុងទីនោះ ។ ចូឆ្លូក៏ប្រើតាហានឲ្យរៀបចំសពតាន់កុង នាំយកទៅបញ្ចុះតាមប្រវៃណីហើយឲ្យបំរើយុំនាំយកខ្លួនមាតា នឹងកវិយាបុត្រតាន់កុងចូលទៅវក្សាខុកកុងក្រុងហ៊ូតោ ហាមក្រាមមិនឲ្យនរណាទៅបៀតបៀនឲ្យបានសេចក្តីលំបាកឡើយ ។

ឯលីចោ"នៅលើសែនបន្ទាយនិយាយទៅនឹងឡៅពីថា មហាឧបរាជកាប់អានស្រឡាញ់អ្នកជាក្រៃលែង គ្រានេះខ្លួនឱ្យគេញាជាមនុស្សទោសមានទោសដល់ស្លាប់ហើយ អ្នកចូរជួយរិះគិតយកអាយុជីវិតឱ្យផងចុះ គុណូបការៈរបស់អ្នកនឹងមានលើខ្លួនឱ្យតទៅ ។ ឡៅពីបានឮដូច្នេះក៏នៅស្ងៀមគ្មានតែញាក់មុខ ។ ខ្លួលចូឆ្លូឡើងទៅលើសែនវិញ លីចោ"ក៏និយាយថា សព្វថ្ងៃមហាឧបរាជគិតការធំ ចាំរកតែខ្លួនឱ្យបានមួយថា ជាមនុស្សចម្រើនឆបម្រះ គប្បីរាប់ខ្លួនឱ្យបានហើយ ឱ្យគេសុំអាយុជីវិតខុកធ្វើការតបស្នងសងគុណលោកតទៅ ព្រោះអំណើះទៅមុខឱ្យបានយល់ថា រាជសម្បត្តិគង់នឹងជាកម្មសិទ្ធិរបស់លោក ។ ចូឆ្លូបានស្តាប់ដូច្នេះទើបសួរឡៅពីថា ដែលលីចោ"ថាដូច្នេះ អ្នកនឹងយល់ឃើញប្រការដូចម្តេច? ។

(មានត)

រឿងព្រេងប្រទេសឥណ្ឌា

អ្នកស្រីស្រិន-សារិយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីភាសាជ្វាកំឆមកជាភាសាខ្មែរ

(តមក)

វគ្គទី ៤

ព្រះនាងទមយន្តីទ្រង់ស្តេចចេញមកក្រសាលឧទ្យាន ដោយមានស្រីស្នំហែតាមក្រោយគ្រប់គ្រង ។ នៅក្នុងឧទ្យាននោះមានស្រះមួយដែលសម្បូណ៌ទៅដោយផ្កាឈូកពេញពាស ។ ព្រះនាងចង់ចុះស្រង់លេងក្នុងគង្គា ។ នៅពេលដែលព្រះនាងកំពុងតែហែលលេងជាសុខសាន្ត ស្រាប់តែមានក្វានមួយចុះបណ្តែតខ្លួនលើផែនទឹកដែលរំជួយដោយរលក ។ ព្រះនាងទមយន្តីទ្រង់ទតមើល ហើយមានព្រះបន្ទូលថា: "មកនេះ ក្វានដ៏ថ្លៃវិសេស! ឲ្យខ្ញុំសុំស្ទាបស្ទាបទន់ល្មើយដែលជាវត្ថុមួយអស្ចារ្យផង" ។ ប៉ុន្តែក្វានហាក់ដូចជាគ្មានឮសោះ វាចេះតែហើរថយទៅ ។ ព្រះនាងទមយន្តីចង់ក្រសាលផងក៏ចេះតែតាមចាប់ផុត ។ ពួកស្រីស្នំដែលនៅលើមាត់ច្រាំង ឃើញព្រះអង្គម្ចាស់ក្សត្រីដេញតាមក្វានដូច្នោះក៏នាំគ្នាសើចសប្បាយ ។ ក្វានអន្ទងព្រះនាងឆ្ងាល់តែដល់លើវាលស្មៅមួយនៅក្បែរទឹក ហើយវាក៏ឈប់នៅទីនោះចាំព្រះនាង ។

ទ្រង់រត់ឡើងពីទឹកដោយមានសេចក្តីត្រេកអរជាពន្លឹក ហើយស្រែកបណ្តើរ
ផងថា: "ឯងទៅណាទៀត ម្តងនេះអញចាប់បានឯងហើយ, នៅកងទឹក
ឯងហែលពូតែជាងអញ ប៉ុន្តែដល់គោកហើយ ឯងមិនមែនរត់ឈ្នះអញ
ទេ" ។ ខណៈនោះស្រាប់តែក្មានពោលពាក្យយ៉ាងស្រទន់ពីពេះឡើងថា
"ខ្ញុំព្រះបង្គំជាខ្ញុំលែងរត់ទៀតហើយ ព្រះនាង! ព្រោះខ្ញុំបានអន្ទងព្រះនាងឲ្យធ្លាយអំពីពួកស្រីស្នំហើយ, អស់ពាក្យដំយុរទើបគេមកដល់ព្រះនាង ។ បើដូច្នេះ សូមព្រះនាងទ្រង់ព្រះសណ្តាប់ខ្ញុំបង្គំ, ខ្ញុំបង្គំជាខ្ញុំនេះ ជាអ្នកនាំពាសារមកក្រាបទូលព្រះនាង: នៅឯប្រទេសនិសធ: មានស្តេចមួយព្រះអង្គព្រះនាមព្រះបុណ្យនាល: សោយរាជសម្បត្តិទ្រង់ប្រកបដោយរូបឆោមលោមពណ៌ល្អ គ្មានអ្វីប្រដូចបាន កាលណាគេឃើញទ្រង់ គេតែងគិតថា ក្រែងតែគន្ធ៌ព (Kandarpa) មកកើតខ្លួនបន្ទុំ ។ ទ្រង់មានព្រះទ័យក្លាហាន ហើយនឹងមានសន្តិភាពផង ពួកសត្រូវបុខ្លាចទ្រង់ណាស់ ។ ទ្រង់បានឮគេពោលពាក្យសរសើរព្រះនាងជាញយៗ ហើយទ្រង់កួចព្រះទ័យស្នេហាព្រះនាង បើសិនជាព្រះនាងបានព្រះអង្គជាព្រះស្វាមី ម្ល៉ះសមព្រះនាងនឹងបានគប់ប្រសព្វនូវសេចក្តីសុខពិត ។ ខ្ញុំព្រះបង្គំធ្លាប់នៅឯសួគ៌និងាយ ជាមួយនឹងព្រះអាទិទេពនឹងទេពកញ្ញា ប៉ុន្តែខ្ញុំបង្គំនឹងថា ព្រះអាទិទេពណាមួយល្អដូចព្រះបុណ្យនាល: ឬនឹងថាទេពកញ្ញាណាមួយល្អដូចព្រះនាងមិនមានឡើយ ។ កន

ចំណែកមន្ត្រីតាំងអស់ ព្រះនាងទុកដូចជាវត្ថុមួយដ៏ថ្លៃថ្លា គួរតែអ្នកដែលមានសម្ផស្សភាពល្អឆើតឆៃរួបរួមរាស្សនាជាមួយនឹងអ្នកល្អឆើត; ការរួបរួមរាស្សនាបែបនេះ នឹងបានសេចក្តីសុខ សេចក្តីចំរើនជាពិត" ។ ព្រះនាងមេយន្តី ទ្រង់ព្រះសណ្តាប់ក្នាងចរចាហើយ ព្រះនាងទ្រង់ញញឹម, មើលទៅរមែព្រះនេត្តនៃព្រះនាងទ្រង់ញញឹមបីដូចជាផ្កាឈើបន្លឺរីកថ្មីៗ ដែលមានសម្បុរស្រស់ប៉ិច្រមិ, ក្នាងក៏ឈប់ក្រាបទូល, ព្រះនាងទ្រង់ព្រះដំរិះដោយគន្លឹះទៅស្ងៀម ។ បន្តិចមក ព្រះនាងទ្រង់អង្អែលក្នាង ដែលមានស្ងាបសម្បុរមោស ហើយទ្រង់មានព្រះបន្ទូលថា: "ក្នាងសម្លាញ់! ចូរឯងទៅក្រាបទូលព្រះបាទនាល: វិញថា: បើព្រះអគ្គមិនឆ្នើនឆ្នៃទេ សូមស្តេចទ្រង់យាងមកគាន់ប្រទេសព្រះបិតានៃព្រះនាង។ នឹងមានសេចក្តីត្រេអរជាពន្ធឹក" ។ ព្រះនាងលុះមានព្រះបន្ទូលហើយ ក៏បបោះអង្អែលក្នាង។ ក៏ហើរសំដៅទៅឧត្តរព្រះបាទនាល: ។

វគ្គទី ៥

ព្រះនាងទ្រង់ចេះតែនិកឃើញនូវសំដីក្នាងវិញ ពុំមានក្ងេចមួយវេលា ហើយទ្រង់ចរិតក្តក្តួលព្រះហឫទ័យថា: "អញមានគេស្រឡាញ់! អញមានស្តេចមួយព្រះអង្គ ដែលមានរូបឆោមលោមពណ៌ល្អគ្មានពីរស្រឡាញ់" ។ ប៉ុន្តែលុះព្រះនាងទ្រង់នឹកឃើញថា: "ស្តេចនោះគង់ទៅឆ្ងាយពីព្រះនាងណាស់ កាលណាទៀបព្រះអង្គនឹងស្តេចយាងមកដល់!

កាលណាឡើយ ព្រះនាងនឹងបានយល់ព្រះកត្តិព្រះអង្គ" ។ ព្រះនាង
កំដកដង្ហើមធំហើយមានព្រះកត្តិស្រែកថាខ្លួនជាទុក្ខខ្វល់ក្នុងព្រះទ័យ ។

ពួកស្រីស្នំទាំងអម្បាលមាណតុំយល់ហេតុ ដែលនាំឲ្យព្រះនាង
កើតកង្វល់យ៉ាងនេះសោះ ។ នាងមលវិកា (Malavika) ដែលជា
ស្នំជំនិតបានទូលសួរព្រះនាងថា "ហេតុអ្វីបានជាព្រះនាងសែនញញួមសប្បាយ: ព្រះនាងជ្រះសើរ! ខ្ញុំដកដង្ហើមដោយលំបាក ខ្សល់
ដែលបក់មកពីក្នុង ហាក់ដូចជាមានសភាពធ្ងន់សង្កត់លើព្រះរូបព្រះនាង
ដែលខ្ចីល្អក់ ។ កងដែលនៅទឹងកព្រះហស្ត នឹងកព្រះបាទនៃព្រះនាង
កំលែងបញ្ចេញទូវសំណូរយ៉ាងពីពេតទៅទៀត ព្រះនាងបើមានវិតក្កអំពី
រឿងអ្វី សូមព្រះនាងកុំខ្ចីលាក់រឿងហេតុនោះទឹងខ្ញុំម្ចាស់ថ្វី" ។ ប៉ុន្តែ
ព្រះនាងនៅព្រងើយ ប្រហែលជាព្រះនាងគ្រាន់តែស្តាប់ចាលទៅទេ
កំមិនដឹង ។ នាងមលវិកាចង់ដួយយកអាសាព្រះនាង កំរត់ទៅទូលព្រះ
បាទកិមៈជាព្រះវរបិតាថា: "បពិត្រព្រះករុណាថ្លៃវិសេស! សូមខ្ចីព្រះមេត្តាជ្រាស! ខ្ញុំបានប្រគល់ខ្លួនខ្ញុំម្ចាស់នេះ ឲ្យមៅបំរើព្រះកជ-
បុត្រី ដោយប្រិយភាព ។ ប៉ុន្តែឥឡូវនេះ ខ្ញុំម្ចាស់មានសេចក្តីព្រួយ
ជាខ្លាំងណាស់ ព្រោះព្រះនាងព្រួយព្រះហឫទ័យទាំងយប់ទាំងថ្ងៃ ។
ព្រះនាងមិនខ្ចីធ្វើយនឹងសំនួរខ្ញុំម្ចាស់សោះ ហើយខ្ចីចេះតែតប់ប្រ-
មល់នឹងការសព្វសារពើ ។ ព្រះនាងខ្ចីប្រឈួនហើយ សូមខ្ចីព្រះ

មេត្តាប្រោស! សូមខ្ញុំយាងទៅមានព្រះពុទ្ធតម្កាសួរព្រះនាងឲ្យខ្ញុំដឹងថា ហេតុអ្វីបានជាព្រះនាងកើតទុក្ខ សូមខ្ញុំប្រោសប្រណីមើលព្រះនាងឲ្យជាសះស្បើយផង" ។ ព្រះបាទកិម: លុះខ្ញុំព្រះសណ្ដាប់សព្វសេចក្ដីហើយ ខ្ញុំទ្ទូន្ទឹងព្រះរាជបុត្រី ខ្ញុំយាងចេញយ៉ាងលឿនទៅកាន់ដំណាក់ព្រះនាង ហើយខ្ញុំឥតយល់ព្រះនាងទមយន្តីគង់សំឡឹងទៅទីឆ្ងាយ . ជួនកាលព្រះនាងមានព្រះបន្ទូលជាច់ៗ ដូចគេហត់ ។ ព្រះនាងខ្ញុំក្រោកឈរឡើង ព្រះពុទ្ធាស្មានតែព្រះនាងឃើញខ្ញុំ ។ តែព្រះនាងបែរព្រះភក្ត្រចេញមិនថ្វាយបង្គំខ្ញុំ ព្រះនាងយាងពីរបើដំហាន ហើយខ្ញុំដាក់ព្រះអង្គគង់លើព្រះឥន្ទសំពកព្រះកាយវិញ ។ ព្រះពុទ្ធាមានព្រះតម្រាស់ថា: "ទមយន្តី កូន!..." ប៉ុន្តែខ្ញុំយល់ថាព្រះនាងគ្មានស្ដាប់ខ្ញុំទេ ទើបខ្ញុំគិតថា "តើកូនអញកើតអ្វីអេះ?" ហើយខ្ញុំនៅតែសំឡឹងព្រះនាងគ្មានដាក់ព្រះនេត្រ ។ ព្រះនាងខ្ញុំក្រោកឈរឡើងទៀត ហើយខ្ញុំគង់ទៅវិញដោយដកដង្ហើមធំ ។ មួយរំពេចនោះស្រាប់តែព្រះនាងក្រឡេកស្គាល់ជាព្រះវរបិតាក៏ស្ទុះទៅនមព្រះបាទព្រះអង្គ ហើយមានបន្ទូលដោយសំឡេងខ្សោយថា "ន: ព្រះវរបិតា!" ប៉ុន្តែព្រះនាងមានព្រះបន្ទូលពុំទាន់ចប់ផង ព្រះនាងក៏ខ្ញុំព្រះកន្សែង ។ ព្រះមហាក្សត្រខ្ញុំមានព្រះតម្រាស់យ៉ាងស្រួលទៅកាន់ព្រះនាងថា: "ម្នាលកូន! ព្រះបិតាដូចជាយល់នូវទុក្ខរបស់កូន

កន្លះណាៈដែលកូនកំពុងតែពេញវ័យ - ពន យ៉ាងនេះ មិត្តភាពរបស់បិតាតែមួយ មិនធ្លុនល្មមនឹងធ្វើឲ្យកូនសប្បាយចិត្តបានទេ ។ ថ្ងៃណាមួយកន្លងពេលឆាប់ៗ នេះ បុរសដែលជាប្តីរបស់កូននឹងមកនាំកូនចេញឆ្ងាយពីព្រះបិតាហើយ ព្រះបិតាគ្មានសិទ្ធិនឹងភ្ជួញស្អែរឡើយ ។ ចូរកូនកុំយំថ្ងូរណាទេមយន្តី ! ចាំព្រះបិតាប្រែក្លូតឲ្យទៅក្លូលស្តេចកន្លងទ្លូបង្គំទូលឲ្យមកប្រជុំនៅក្នុងសន្និបាតដែលកូនស្រីត្រូវរើសប្តី ដែលប្រកបដោយផោគជ័យដោយខ្លួនឯង" ។ ព្រះនាងទេមយន្តី ក៏ស្តុះរហ័សទៅថុបព្រះបិតាដោយមានកត្តញ្ញញឹមស្រស់ស្រាយ ។

វគ្គទី ៦

ពួកក្លូតចេញនាំសារទៅគ្រប់នគរ ហើយចូលទៅក្លូលស្តេចគ្រងរាជ្យថា: " សូមព្រះករុណាជាម្ចាស់ជីវិតលើក្បាលខ្ញុំជ្រាប ដ្បិតព្រះនាងទេមយន្តី ដែលជាពជបុត្តីព្រះចាទកិមៈ ដែលជាស្តេចសោយរាជ្យនៅប្រទេសវិទគិៈត្រូវរើសរកព្រះស្វាមី ព្រះករុណាជាម្ចាស់យើងខ្ញុំពាល់គ្នាសូមឲ្យខ្លួនយាងចូលទៅក្នុងមហាសន្និបាតនោះ" ។

ពួកស្តេចតាំងប៉ុន្មានដែលបានទទួលដំណឹងយ៉ាងដូច្នេះ ក៏រៀបព្រះអង្គឡើងគង់លើរាជរថដ៏វិសេស ព្រមទាំងមានក្បួនហែដ៏ស្កុកស្កម្មផង ។

(មានត)

ដំណើរអស្ចារ្យនៃលោកកាំសូប៊ីយូយេ

លោក យូកូតូស៊ី អ្នករៀបរឿង

លោក វ៉ាយ-ប៊ុក ក្រមការ ប្រែពីបារាំងមកជាខ្មែរ

កថាមុខ

កន្លងមក គ. ស. ១៧៧១ នៅកោះស៊ីកូកូ (Shikoku) នៃប្រទេសជប៉ុន គេមានចុះពុម្ពផ្សាយនូវរឿងនេះ, អ្នកនិពន្ធនាម "យូកូតូស៊ី" - ជាវហាសនាម ប្រែថា "អ្នកស្រុកនៅជ្រោះភ្នំ" គឺជារឿងព័ត៌ប្រកបដោយអច្ឆរិយភាព ដែលយើងបានបកប្រែមកចុះផ្សាយនៅពីនេះ ។ សៀវភៅនោះនាមថា អ៊ីកូគូគីដន់ (Ikoku - Kidan) "រឿងព្រៃងនៅស្រុកបែកុ" ។ រឿងនេះមានអ្នកនិពន្ធចំណានខាងប្រឌ្ឋមលោក នាម ចាគិន (Bakin) បានយកមកវចនាហាសិបឆ្នាំក្រោយមក ដាក់អត្ថបទថា "មុសូប៊ីយូយេ" (Musobioyé) តែកិច្ចការដែលធ្វើតាំងប៉ុន្មានមិនសូវមានសារៈសំខាន់អ្វីឡើយ ។ ដំណើរទីមួយនឹងដំណើរទីប្រាំមួយ គេបានបកប្រែចុះក្នុងទស្សនាវដ្តី "Transaétions of the asiatic Soiéty of Japan" ពី គ. ស. ១៨៧៩ ។ ការបកប្រែនេះ គឺបកប្រែតាមលោក វ. ក្រែសវ៉ុសុង (M. w. Cresvdson) ដែលបានចុះផ្សាយនៅកន្លងទស្សនាវដ្តី (Nineteenth Century) ។ យើងសូមឲ្យលោក - អ្នកដែលពេញចិត្តខាងការសិក្សារក

នូវបញ្ហាខាងក្រៅពីអ្វីទីមួយ ។ នៃសៀវភៅនេះ អានទៅអាចក្លាយជារបស់លោកក្រែស្តវ៍សុងចុះ! រឿងក៏វាក្នុងសៀវភៅនេះ ដូចគ្នានឹងដំណើរលោកប្រកបដោយអមតភាពនៃគូលីវើរ (Gulliver) ចំពោះតែដំណើរទៅប្រទេសប្លូបឌិនញ៉ាក់ (Pays de Brobdingnac) គេបានឲ្យដំណឹងថាសៀវភៅដែលលោកស្វីហ្វត៍ (Swift) និពន្ធបានផ្សាយទៅដល់ប្រទេសជប៉ុនជាសេចក្តីបកប្រែភាសាហុលឡង់; គឺសៀវភៅនេះ ដែលជាហេតុឲ្យអ្នកនិពន្ធសៀវភៅអ៊ីកូតូដង់ បានយកមកវចនាជារឿងព្រៃងនេះ ។ បើតុក្កជាយ៉ាងណាក៏ដោយ សៀវភៅនេះ សមរម្យទីងយកមកអនុវត្តន៍ខាងមជ្ឈដ្ឋានជប៉ុន ហើយយើងសង្កេតទៅប្រហែលជាសៀវភៅនេះ សម្រាប់រៃគន់ដោយស្វាត់កំចាំងនៅសម័យបច្ចុប្បន្ននេះ ។ មានសេចក្តីខ្លះដូចជាពាក្យដែលមានលំនាំគួរឲ្យសើចរបស់លោកស្វីហ្វត៍ ហើយយោបល់ដែលអ្នកនិពន្ធបានពណ៌នាកងំណើរទៅប្រទេសយក្ស ដែលលោកវលតែរ (Voltaire) បានយកទៅវចនានូវរឿងព្រៃងនោះ គឺថាសៀវភៅនេះមានតុជារសប្លែកអស្ចារ្យ ដែលជាហេតុឲ្យលោកអ្នកអានពេញចិត្តមិនខាន ។

គ. សាំង្ត - អ៊ីវ្ស (G Saint. Yves)

១.— ដំណើរទៅកាន់អមតៈប្រទេស (Pays d'Immortalité)

កន្លងកាលពីកន្លងមកសម្តេចណិដោយកោតក្តីព្យ ហើយប្រកបដោយសន្តិភាព នៅទីក្រុង នាគាសាគី (Nagasaki) ក្នុងខេត្តហ៊ីសែន (Hisen) មានមនុស្សម្នាក់នាម "ស៊ីកាយ៉ាវ៉ាសូប៊ីយូយ៉ែ" [hikaiya wasobioyé] ពូជវង្សត្រកូលរបស់លោកមានមកតាំងពីបុពណាកាល ជាសេដ្ឋីតាំងទីលំនៅនៅទីក្រុងនោះ ។ លោកជាចៅហ្វាយគួរជាទីគោរពនៃពាណិជ្ជដ្ឋានមួយ លក់ល័ក្តមកពីប្រទេសចិនធំហូរធំ ដោយមានអ្នកជំនួញបរទេសទៅមកជាញឹកញាយ, ហើយលោកជាអ្នកប៉ុនប្រសប់ខាងនិពន្ធរឿងវែងឆ្ងាយ ។ ដល់ឆ្នើជំនួញនោះបានចំរើនតាមលំដាប់ លោកបានប្រគល់ហាងនោះមកកូនប្រុសលោកនាម សូសូ (Shuz] លោកអាយុបានសែសិបប្រាំបីឆ្នាំ លោកបានចាត់ឲ្យសង់គេហដ្ឋានមួយដោយឡែក ស្ថិតនៅជិតគ្រឹហាដើមរបស់ លាក ហើយលះបង់ការងារទាំងអស់ចូលទៅនៅទីនោះ ។ លោកនៅតែមាតងឯងជាមួយនឹងភាស៊ីម្នាក់សម្រាប់ជាំជុយបរិភោគ ។ ដើម្បីនឹងសម្រាកកំឡាំង លោកបានទៅធ្វើនេសាទត្រីជាកិច្ចកំសាន្ត ព្រោះលោកចូលចិត្តតាំងពីយុនកាលមក ។ ជំបូងលោកបានស្ងប់ត្រីនៅលើមាត់សមុទ្រ តមកទៀតលោកមានទូកមួយអុំទៅកណ្តាលសមុទ្រ ។

នៅពាក់កណ្តាលខែសីហា សម័យដែលព្រះចន្ទកំពុងពេញបូណ៌មី; ក្នុងពេលនេះ មានពួកអ្នកមានចំណេះច្រើនទៅលេងកំសាន្តនៅទីនោះ ។ លោកវ៉ាសូប៊ីយូយេ ដើម្បីចៀសចេញពីការដាច់ដៃគ្នា ចំពោះពួកបណ្ឌិតទាំងនោះដែលអួតអាងអំពីចំណេះវៀនច្រើន លោកក៏ដើរទៅតែម្នាក់ឯង ។ បន្តិចព្រះចន្ទក៏រះឡើងភ្លឺចែងចាំងដោយរស្មីស្រទន់ នៅលើថ្នល់ដើមស្រល់ ។ លោកក៏បានទស្សនាទៅពួកភ្លឺគំនាងនោះ ដោយពេញចិត្តពន់ពេក, ហើយអុំបណ្តើរសូចបណ្តើរ ដល់ទៅចម្ងាយមួយយោជន៍ពីមាត់សមុទ្រ លោកបានឃើញពពកខ្មៅនៅលើនាលំយ ។ បន្តិចទៀត, ភ្លៀងយោចក់ធ្លើង ភ្លៀងក៏ធ្លាក់មក ។ លោកបានចាំទូវសុភាសិតមួយឃត្នែងថា: "មេឃក្នុងសរទៈរដូវប្រែប្រួលដូចចិត្តមនុស្សទៅទៀត" ។ លោកក៏ប្រញាប់ប្រញាល់អុំវិលត្រឡប់មកវិលគោកវិញ តែមិនបានសម្រេច! ភ្លៀងធ្លាយរៃហែកក្តោង កាប់បំបាក់ដងក្តោង ហើយទូកក៏វិលទៅកាន់កណ្តាលសមុទ្រវិញ ។ បន្តិចទៀត, មេឃកាន់តែងងឹត លោកវ៉ាសូប៊ីយូយេលែងដឹងទិសតំបន់ ភ្លេចទូកជាការឥតប្រយោជន៍, ហើយលោកអស់កម្លាំងផង ។ តែចិត្តលោកកាន់តែក្លៀវក្លាឡើង, លោកអង្គុយនៅក្នុងទូកហើយបណ្តោយទៅតាមខ្យល់ព្យុះនាំទូកទៅកាន់ទីណាក៏ដោយ ។

លុះពេលបុព្វណ្ហសម័យនៃថ្ងៃទី ៤ ក៏យោកសប់ ។ លោកក៏សួរយ៉ូយេ
មិនដឹងថាលោកស្ថិតនៅទីណាទេ ព្រមទាំងមិនស្គាល់ទិសណាដែល
លោកបំរុងនឹងចែវទៅ, លោកក៏បណ្តែតទូកលោកទៅតាមទំនើងទឹក
ហូរ ហើយលោកចំណាយនឹងរស់នៅក្នុងពេលនោះដោយការនេសាទត្រី
ដូចជាលោកសង្ឃនាម សុនក្វាន់(១) នៅលើថ្មមួយនៃកោះដែលមានព្រះ
ពាយបក់ប្រោកជាខ្លាំង ។ ក្នុងរយៈវេលាបីថ្ងៃ, ទូកនោះបានអណ្តែត
ទៅដល់កូមិភាគមួយដែលលោកសន្មតថា "សមុទ្រកក់" (Mer de Boné)
ដែលគ្មានវាយោនឹងរលកស្មោះ ។ ហើយក្នុងពេលនោះ លោកឃ្លាន
ជាយពន់ពេក ។ ដល់ថ្ងៃក្រោយតមក លោកស្ថិតនៅក្នុងទូកធ្វើចាំតែ
សេចក្តីស្លាប់មកដល់ ។ ក្នុងមួយរំពេច, លោកដូចជាមានកំឡាំងថ្មីជាយ
មានព្រះពាយបក់នាំកូនក្រអូបមកពីទីមួយ ។ លោកក៏ឆើបក្បាលឡើង,
ក្រឡេកទៅឃើញដី, ក៏ចែវទូកដើម្បីទៅឈប់នៅទីនោះ ។ លោកមាន
ចិត្តធ្ងល់ពន់ពេកថាដល់លោកអញ្ជើញជិតទៅដល់ទីនោះ លោកទៅជា
មានកំឡាំងថ្មីឡើងវិញ ; លោកក៏ចែវហួតដល់មាត់សមុទ្រ ។ ដល់
លោកឡើងទៅលើគោក, លោកស្វែងរកទឹកបរិភោគសិន, លោក
បានទៅប្រទះនឹងទឹកសន្សើមមានឧជារសែបក្រអូរ្យ លោកអស្រ័យ

(១) លោកសង្ឃនាមក្នុងសតវត្ស ១២ ដែលគេដាក់ទណ្ឌកម្មនិរទេសចេញពីស្រុកទៅ
ស្ថាប់កណ្តាលកោះសមុទ្រ ។

ទឹកនោះច្រើនគាំទ្រឲ្យលោកសប្បាយចិត្ត លែងនឹកនាដូចពុំធ្លាប់ឃើញពីកាលមុន ។ លោកបានឡើងទៅលើភ្នំកូចមួយហើយក្រឡេកមើលទៅគ្រប់ទិសដៅបន់ដឹងថាខ្លួនស្ថិតនៅក្នុងប្រទេសមួយ ដែលមានត្រឹមតែវត្តមួយ។ ក្រៅពីវត្តដែលមាននៅប្រទេសជប៉ុន ថែមទាំងធម្មជាតិនោះ មានសភាពស្អាតល្អមួយរយៈសួនទៅទៀត ។

ពួកប្រជាជនដែលមកចោមរោមដុំវិញលោកក្នុងមួយរំពេច លោកបានសាកសួរពួកនោះដោយពោលពាក្យជាភាសាចិនសុទ្ធ តែប្រជាជនទាំងនេះ នៅស្ងៀមស្ងាត់មិនអាចឆ្លើយតបអ្វីឡើយ ។ លោកនៅទីនោះ ប្រៀបដូចជាមេ្លមដែលមានហ្វូងក្អែកចោមរោម, តែលោកមានភ័ព្វសំណាងខ្លួលជួបនឹងមនុស្សម្នាក់ ប្រហែលអាយុជាងសែសិបឆ្នាំកំពុងញែកចូលមកជិតលោក ហើយក៏សួរមកលោកជាភាសាចិនថា លោកអញ្ជើញមកពីណា? ។ លោកកំពុងរំជាំជំពប់ក្នុងនោះអំពីព្រឹត្តិការណ៍សព្វគ្រប់ហើយ អ្នកនោះបានសរសើរថា "លោកមានភ័ពវាសនាល្អបានអញ្ជើញមកដល់ប្រទេសនេះ នាមថា: អមតៈប្រទេស ស្ថិតនៅជ្រុងមួយម៉ឺនយោជន៍ពីប្រទេសជប៉ុន ។ ខ្ញុំឈ្មោះសូ-ហ្វូ-គុ (Jofoku) ហើយព្រះអធិរាជប្រទេសចិនព្រះនាមស៊ីស្កូ (Shisko) ស្តេចវិលចរិតហើយជាចណ្ឌាធ ចាន់ចាត់ខ្ញុំជាគ្រូពេទ្យឲ្យមកកាន់ទីនេះ ដើម្បីនឹងស្វែងរកទឹកម្រឹត្យ (ទឹកដែលធ្វើឲ្យអាយុវែង, (élixer de Congue vie) ។ ខ្ញុំ

ជានមកកេរយើញនូវទឹកអម្រិតនេះ. តែខ្ញុំយល់ថាគួរឲ្យស្អប់ខ្ពើមនូវការធ្វើ
ឲ្យបណ្តាជនជានអមតភាព ធ្វើចិត្តខ្ញុំមិនឲ្យវិលត្រឡប់ទៅកាន់ប្រទេស
វិញ ។ លោកអាចពិស្មោធន៍ជានថានៅទីនេះគេអាចរស់នៅជានជានិរន្តរ៍
ហើយមិនដែលមានភេតាម្តងសោះឡើយ" ។

- លោកវ៉ាសូប៊ីយូះយ ធ្វើយតបទៅវិញថា: ខ្ញុំពុកជាមានកត្តា
សំណាងល្អដែលជានមកសន្ទនាការនៃធ៌បណ្ឌិត សូហ្គូ ដែលខ្ញុំជាន
អានសៀវភៅរបស់លោកជាច្រើន ។ ខ្ញុំជានឮគេពោលពីអមត:ប្រទេស
តែខ្ញុំមិនជឿអ្នកណាហានឡើយ" ។ សេចក្តីឆ្លើយនេះ ធ្វើឲ្យលោក
សូហ្គូ សប្បាយចិត្តពន់ពេកគាល់តែលោកស្រែកថា: "បើប្រទេស
ជប៉ុនជាសមន្តប្រទេសនឹងប្រទេសចិន សូមលោកចូលមកនៅកន្លែងគេហ-
ដ្ឋានខ្ញុំប្រៀបដូចជាគេហដ្ឋានរបស់លោកចុះ" ។ លោកវ៉ាសូប៊ីយូយោកធ្វើ
តាមបង្គាប់នៃលោក សូហ្គូ ។ លោកវ៉ាសូប៊ីយូយេជានស្ថិតនៅទី
នោះ រាងពីរឆ្នាំសតវត្សជាទីគោរពប់ះន ហើយមានសិទ្ធិចេញទៅ
ពិនិត្យនូវកិច្ចការនៃអភប្បកិរិយាពួកប្រជាជន ដែលនៅក្នុងអមត:ប្រទេស
(ដែលមនុស្សមានសភាពដូចបុគ្គលទើបអាយុ ៤០ ឆ្នាំ) គ្រប់គ្នា ហើយ
មិនដែលមានអាពាធសោះឡើយ ។ ក្នុង ១០០ ឆ្នាំម្តង ដួនកាលមាន
មនុស្សកើតឆ្កួស្លាប់ដោយមិនដឹងហេតុមកពីណា ហើយព្រឹត្តិការណ៍បែប
នេះធ្វើឲ្យប្រជាពស្តែជ្រែមពន់ពេក ។ អាកាសត្រជាក់ស្រួល: ភ្លៀង

ព្រះអាទិត្យផ្ទាស់វេនគ្នាដោយសមភាគ មានផលានុផលសម្បូណ៌ ។ សត្វក្រសាគេបង្ហាត់ឲ្យចេះភ្ជួរពាស់ស្រែចម្ការ ហើយអាចទ័មដឹកទំនិញតវ៉ាន់បាន ។ លោក ក៉ាសូប៉ីយូយេ ចាប់រៀនដំបូកគ្នានោះដាយានជំនិះបែបថ្មី ហើយក៏ធ្វើដំណើរទៅកាន់ប្រទេសនោះ ទស្សនាទូទឹកន្លែងដែលមាននាមល្បីល្បាញ ។ លោកបានឃើញកន្លែងមួយដាំមង្ឃុតដប៉ុន (pêcher) ជាច្រើន នៅជិតទីក្រុង ។ នៅទីនោះ មានសង់ភោជនាគារ ភេនៈស្ងាន និងរចាំផ្សេង ។ នៅជិតនោះមានភ្នំតូចមួយមានដាំវុក្ខជាតិកាមេលីយ៉ា (Camélias) ផ្កាកង់មួយពាន់ធាំមួង ។ កង់ពេលនោះ ជាទុកាសដែលប្រជាពស្តុតាំងមូលស្រែកភោអាវស្អាតមកពីគ្រប់ទិស ដំរសត្វក្រសាដែលលោក ក៉ាសូប៉ីយូយេបានប្រៀបធៀបថាដូចហ្វូងភាលៃហើរលើអាកាសកង់សរទេរដូវ ។ អ្នកតាំងអស់បានក្រៃបន្ទូរវាសជាតិនៃដីវាគ ដោយឥតមានតំយតក់ស្តុតនឹងទុក្ខនឹងសេចក្តីស្លាប់ ។

តែដោយទេសកាលមានគេយកទៅកង់កោះនោះ ន្ទូរសៀវភៅគម្ពីរព្រះពុទ្ធសាសនាដែលពណ៌នាពីសេចក្តីសប្បាយ ខាងស្ថានសួគ៌ពួកប្រជាពស្តុបានអានន្ទូរគម្ពីរតាំងនោះ ដែលអធិប្បាយអំពីសម្បត្តិទិព្វនៅស្ថានសួគ៌បានយល់ថាដីវាគនៅ ើនៃនដ៏ មានសភាពតែដដែលៗ ចិត្តទៅជាខ្ជិយណាយនឹងគ្រឿងអាមិស ក៏មានចំណង់ចង់លះបង់ដីវត ។ បុគ្គលណាដែលធ្វើមរណភាព គេទុកបុគ្គលនោះជាសន្តបុរស ហើយ

សេចក្តីមរណៈ គេទុកជាមន្តអាគមដ៏វិសេសដែលអ្នកពាំងអស់ចំណែកដោយការណ៍ពិចារណាខ្លួនឯងផង ។ អ្នកពាំងអស់នោះមិនអាចបរិភោគខ្លួនផ្លែសាំងសេង (Ginséng) ដ៏ល្អឆ្ងាញ់ពិសារ ។ ពិតមែនតែម្ហូបអាហារពាំងនោះសម្បូណ៌ហើយថោកផងប្រជាពលស្តុកពាំងប៉ុន្មានក៏មើលងាយខ្លួនអាហារនោះ ថាជាទុសចរិតលុះអាចធ្វើជីវិតឲ្យវែងនៅអស់កាលយូរ ហើយមានតែពួកពុតដែលគេប្រមូលរបស់ពាំងនោះមកសំចៃទុកក្នុងគេហដ្ឋាន ។ ពួកសេដ្ឋីតែញាប់ញ័រចិត្តខ្លាចវត្ថុអ្វីដែលធ្វើឲ្យមរណៈ ដូចជាត្រីព្រះចន្ទ (poisson de lune) ដែលមានពិស ។ នៅប្រទេសនោះ មនុស្សណាដែលបរិភោគត្រីព្រះចន្ទមានរសជាតិដូចខ្លាញ់គោ ឬកំភេមមួយប្រភេទ (cant harides) គេយកមកចងនៅតាមរបៀប មិនអាចធ្វើខ្លួនឲ្យមរណៈបាន តែនាំឲ្យមានពេគក្នុងរយៈវេលាកន្លះម៉ោង តែប៉ុណ្ណោះ បុគ្គលនោះនៅជាច្បាស់កំសប្បាយ ដោយមានគំនិតថាអញមុខជានឹងស្លាប់មិនខាន ហើយសភាពយល់ប្រភេទនេះធ្វើឲ្យមានហាសនចិត្តពន់ពេក ។ ដល់ថ្ងៃចូលឆ្នាំ, ឬពេលដែលមានធ្វើបុណ្យធំ ដើម្បីនឹងឲ្យសេចក្តីរបត់បែនមកដល់ខ្លួន, ត្រូវជាជនាំគ្នាដំឡើងវាយធាទន៍ (paravent) លើត្រើយៗលើ, កាំនន់ជាប់ញ្ជាំសហើយស្ងៀកពាក់ខោអាវគាន់ខ្លួន ។ លិខិត

សំដែងខ្លួនសេចក្តីសោកស្តាយ ជាលិខិតប្រសើរបំផុតដែលគ្រូបញ្ជូនទៅមិត្តភ័ក្តិក្នុងពេលចូលឆ្នាំ ហើយជាកិច្ចមិនសមគួរបើឡើលិខិតទៅឲ្យពាសត្ថសាធុការ ក្នុងពេលនោះចំពោះបុត្រធីតា ។ ការគួរសមគឺគេបញ្ជាក់ឲ្យដឹងថាខ្លួនមានសុខភាពមិនសូវបរិបូណ៌ ហើយថាខ្លួនជិតដល់ពេលក្សីយជីវិតដែលបិតាមាតាមានចិត្តរីករាយពន់ពេក ។

មុនដំបូងលោកវ៉ាសូប៊ីយូយេ យល់ថាជាទំនៀមនេះប្លែកអស្ចារ្យ ហើយទៅជាមានចិត្តសប្បុរយចំពោះសុខភាពដ៏ល្អ នឹងអមតភាពរបស់លោកទៅវិញ, លុះលោកនៅពីនោះប្រហែលពីរសប្តាហ៍ លោកទៅជាអផ្សុកដោយជីវភាពមានលក្ខណៈដដែលៗ ។ លោកបានយកបញ្ហាទាំងនេះទៅពិចារណា, លោកក៏យល់ច្បាស់ថាមិនដែលមានមនុស្សណាស្លាប់ ។ ការដែលគ្រូស្លាប់ជាហេតុញ៉ាំងលោកឲ្យមានបំណងចង់ស្លាប់, លោកពិសោធន៍ខ្លួនលោកមុជទឹកឲ្យលង់លិច, លោកបណ្តែតខ្លួនលោកដូចឆ្កែដប ហើយលោកគិតលោតទឹកឲ្យស្លាប់ តែដល់លោតទៅ ខ្លួនលោកធ្លាក់ដូចធ្លាក្នុងលោតពីបំពង់ទឹកខាងលើ ។ ការពិសោធន៍ទាំងប៉ុន្មានបរាជ័យធ្វើឲ្យលោកកាន់តែព្រួយបារម្ភជាខ្លាំង; តែលោកមានបំណងចង់យកអមតភាពរបស់លោកមកអនុវត្តន៍ការ ដើម្បីនឹងចេញពីអមតៈប្រទេសទៅទស្សនាប្រទេសថ្មីក ។ ហើយនឹងនិពន្ធពីទំនៀមទម្លាប់ប្រជាជនស្ត្រីដែលនៅប្រទេសទាំងនោះ ។ ដល់លោក

កំណត់ក្នុងចិត្តរួចស្រេច, លោកក៏ចាននយកទៅសោកណាគតនៃជីវិតដែលរស់នៅ, លោកក៏ចំបរិភោគអាហារឆ្អែតស្កប់ស្កល់ ដែលជាហេតុនាំឲ្យប្រជាពស្ត្រគាំងប៉ុន្មានចំអកឲ្យលោក ។ លោកក៏ចាននសរសេរសំបុត្រថ្វាយអំណរគុណចំពោះសប្បុរស ដែលលោកចាននពឹងពាក់អាស្រ័យ, លោកលួចក្រសាមួយដែលមានស្នាមាំភ្នំង ហើយក៏ដំរែកសោនោះតម្រង់ទៅទិសខាងត្បូង ។

គតិអ្នកធិពន្ធ

ក្នុងពេលចូលឆ្នាំថ្មី, ជនជាតិជប៉ុនចានតុបតែងគេហដ្ឋានទឹងអក្សរសន្ធតនាមថាអាយុវែង, ហើយមិនត្រមសរសេរពាក្យថា "បួន" ដែលមានសូរសំឡេងថា "ស្លាប់" ។ យើងត្រមតាំងសត្វតិរច្ឆានទន្លេនទូរសេចក្តីខ្លាចស្លាប់ តែមិនសមទៅតាមវិចារណញ្ញាណសោះឡើយ ។ ដល់ក្បាត់ពីនិត្រាឡើង យើងត្រូវធ្វើការលំបាកហើយនឹងតស៊ូទូរសេចក្តីទុក្ខជាច្រើនប្រការ; បើយើងនិត្រាលក់ រូបកាយយើងសម្រាកហើយ ចិត្តយើងលះបង់នូវការបលិពោធក្នុងលោក ។ ចំពោះន័យនេះសេចក្តីមរណៈជាកម្រៃហើយអ្នកដែលក្រែយជីវិតស្រួរខ្លួនឯងថា ហេតុម្តេចក៏ខ្លួនយើងមិនស្លាប់ពីកាលមុន បើសេចក្តីស្លាប់ស្រួលដាយយ៉ាងដូចនេះ ។ លំអានៃបុប្ផាស្តីព្រះចន្ទធ្វើឲ្យយើងសប្បុរយចិត្តពន់ពេក ព្រោះវត្តុតាំងនេះមិននៅស្ថិតស្ថេរបានកាល តែងតែរស់នៅរួចស្លាប់ជាធម្មតា, បើវត្តុតាំងនេះស្ថិតនៅ

ជានិរន្តរគ្មានអ្នកណាចង់មើលចង់ឃើញទេ ។ ដូចគ្មានឯងមនុស្សមិនចេះស្លាប់, មនុស្សនោះ លែងសប្បាយនឹងជីវិតដែលរស់នៅរាល់ថ្ងៃ ហើយមុខជាថ្ងរង៉ំក្រៃយដែលឆ្លើមរណកាល ដូចជាប្រជាជននៅអមតៈប្រទេស ។ មានតែអ្នកណាដែលមានជីវិតរស់នៅដោយសុខស្រួលជាមួយនឹងយើងអាចខ្ចាចសេចក្តីស្លាប់ជាធម្មតា ។ មានពួកសេដ្ឋីជាច្រើនដែលមានរូបកាយមាំមួន អាស្រ័យនុសថឲ្យគេបំរើច្រចាប់គក់ ហើយយកមកអុជសរសៃ (Moxas) លោកទាំងនោះអាចជាបបានថា ថ្នាំតែកេតគឺសម្រាប់អ្នកឈឺពិត ។ ហើយមិនត្រូវយកមកប្រើសម្រាប់អ្នកឈឺមិនពិតនោះទេ ។ បើអ្នកឯងអាពាធត្រូវអែញ្ជើញគ្រូពេទ្យមកពិនិត្យសុដ្ឋានកេត ហើយត្រូវប្រតិបត្តិតាមពាក្យដែលលោកគ្រូពេទ្យបង្គាប់, កុំឲ្យទុកកេតនោះឲ្យយូរទៅអនាគត, ដោយហេតុថាកេតនោះស្រាលនៅឡើយ, មិនត្រូវនឹងជាក់នុសថភ្លាមទេ បើអ្នកប្រព្រឹត្តយ៉ាងដូចនេះ, កេតនោះអាចមានអានុភាពខ្លាំងក្លាឡើង ហើយដល់ចង់ជាក់នុសថ។ នោះក៏ទៅជាមិនបានការគ្មានផល ។ ចូរអ្នកពិចារណាទូវត្តន៍នៃអមតៈប្រទេស ហើយចូរអ្នកតាំងចិត្តកុំឲ្យតក់ស្លុតនឹងសេចក្តីស្លាប់ អ្នកមិនត្រូវចង់បានស្ថានភាពជាពួកអមតៈបុគ្គលទេ ។ ចូរអ្នករស់នៅដោយចិត្តសន្តោសហើយរំរក្សាចិត្តនោះឲ្យស្ងប់ស្ងៀមនឹងនួនដូចកំពូលភ្នំដូចនោះ ។

(មានត)

ដំណើរតាមឡរ៉ក្នុងកម្ពុជា

លោកផើង - ជ្រើរ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាចុងមកជាភាសាខ្មែរ

អ៊ី - ស្កាអ៊ីល

ព្រះអាទិត្យចាំងរលោងខ្លាចខ្លើងក្តៅដូចគេដុត គឺពេលកណ្តាលថ្ងៃត្រង់ ។ ផ្លូវទឹកខ្វះ រីតែដំណើរក្នុងរថយន្តឡរ៉ក៏ហួរក្រៃវេចក្រៃវាក់ចេញពីពួកគុំ (ហាម៉ូត) កាត់ព្រៃគ្មោត ធ្លាក់ចុះកន្លងឈូង នាំទឹកថ្លាដូចកញ្ចក់ស្រាលយជាមួយទឹកសមុទ្រខៀវស្រងាត់ ។

ពេលនោះក្តៅណាស់ ហាក់ដូចគេយកសំណកំពុងពុះមកចាក់បង្ហូរពាសពេញសាលាលើព្រះធរណី ។ ក្រែងអាចប់តូចមួយឈ្មោះកាស៊ិ - កាព៉ូលី ហាក់ដូចជាដេកលក់ស្ងាត់ច្រៀបឮដំណើរក្រាមអណ្តាតភ្លើងតឹងដៅព្រះសុរិយា ហើយឃើញតែស ។ ភ្ញី ។ ដោយត្រូវចំណាំងថ្ងៃ ។ កន្លងសម័យដែលរឿងនេះកើតឡើង ជនជាតិអាព៉ាច់ក្រែងកាស៊ិ - កាពប៊ូលីចំណុះសាសន៍ត្បូគី ។

មេក្រុមព្រមទាំង កាអ៊ិត បានប្រឹក្សាគ្នាថា ពេលនេះត្រូវតែយើងចុះចូលនឹងពួកទ័លសិន តែយើងកុំចូលដៃជាមួយ ។ ត្រូវយើងធ្វើឲ្យស្លូត ។ នេះគឺជាឧបាយមួយយ៉ាងសំខាន់ដើម្បីវៀរចាកការប្លន់ដណ្តើម

យកទ្រព្យរបស់ដោយបទកំហែង នឹងរក្សាកុំឲ្យមានសេចក្តីស្ងាប់ដល់ជនជាតិអ្នកស្រុកអាយឥតប្រយោជន៍ ហើយត្រូវឲ្យអ្នកចាំងអស់ទទួលស្គាល់អំណាចទ្រង់តែខាងក្រៅ អត់ចាំ មិនយូរប៉ុន្មានគង់មានថ្ងៃសងសឹកនឹងមកដល់ ។

ហេតុដូច្នេះ ប្រជារាស្ត្រអាប៉ាច់គ្រប់ៗ គ្នា យកចិត្តទុកជាក់គោរពច្បាប់ទ្រង់ចាំងអស់ ។ គ្មាននរណាម្នាក់ស្ងាប់សោះ ហើយពួកមេទ័ពតួរគីក៏ព្រមទទួលរក្សាទំនៀមទម្លាប់ស្រុករបស់គាអិតទុក មិនមានចិត្តឈ្លានពីរនឹងមិនត្រូវការធ្វើទុក្ខបុកម្នេញដល់អ្នកស្រុកអាយ ឬក៏ប្រឲ្យអ្នកណាចាប់យកក្មេងចាស់មកជាយបែកឈាមនោះឥតមានឡើយ ។

គាំងពីឆ្នាំកាន់ប្រែនោះមក ថ្ងៃទី១ ខែតែកទ្វាទសៅ ទាំយកចាំងសេចក្តីសុខទុក្ខគ្រប់គ្នាទៅជាមួយផង ។ តំបន់ចាំងមូលហាក់ដូចជាសុខសាន្តគ្មាណាពិតប្រាកដ តែដែលតាមការណ៍ពិត គឺស្ងៀមស្ងាត់តែក្រៅទេ ព្រោះអាប៉ាច់យកសេចក្តីគោរពនឹងការគួរសមមកជាវិនាំងពីក្រៅ ចំណែកចិត្តខាងក្នុងនៅតែមានគំនុំជាធម្មតា ។

ក្នុងសម័យនោះ គេបានឲ្យការណ៍ជាច្រើនដងថា នៅតាំបន់ក្នុងមានការបះបោរគ្រប់កូមិ ជនជាតិអាប៉ាច់ដើរមេសនាំគ្នាដើរកេតក្បាតពេញចាំងលើទ្វង់ក្នុ សម្លាប់ពួកអ្នកយាមល្បាតតួរគីឥតត្រាប្រណី មកពីមានជាតិក្រែកនាំយកគ្រឿងអាវុធនឹងស្បៀងផ្សេង ។ មកលបលួចលក់ឲ្យ ។

សូម្បីនៅទីក្បែរៗ ក្រុងក៏ដោយ តែងមានពួកអ្នកយាមស្ទាប់ដោយជាប់ក តាមពិនិត្យទៅ ឃើញថាពួកខ្មាមយកជាវត្ថុចាំសណ្ដានដូចកណ្ដៀវមកពិឃាត ព្រោះឃើញមានក្បាលជាប់ចេញពីដងខ្លួន ។

និយាយដោយសង្ខេប គឺពួកពាណិជកាកេងស្តុកស្តម្ភីណុបមានសេចក្តីរំគើបយ៉ាងខ្លាំង ។ ដ្បិតស្រុកដែលខ្មុកចិត្តថាជាសុខសាន្តត្រាណហើយត្រឡប់ជាមានការចលាចលខាងក្នុងយ៉ាងខ្លាំង រៀលដែលខាងក្រៅមានអាការបំពាន់ដោយប្រើសន្ធិកាព ទីឯសេចក្តីអត់ធ្មត់នៅក្រោមទឹមសង្កត់ពីលើ ដូចជាក្អើង ត្រជាក់តែខាងក្រៅ ចំណែកខាងក្នុងនៅក្តៅដាំជានិច្ចដោយអាស្រ័យការត្អូតត្អាអយុត្តិធម៌របស់ខ្មែល ព្រោះអំពើល្អរបស់ខ្មែលថយៗទៅ ក្លាយទៅជាតម្រូវឲ្យធ្វើសេដ្ឋកិច្ចបានតែខាងក្នុងប្រទេស ទីឯតម្រូវឲ្យជួយធ្វើពាណិជ្ជកម្មមិនបាន មានបង្កើតការខាងប្រាក់ពន្ធកាល់ឆ្នាំ ជាកិច្ចនាំឲ្យរៀលតែនឹងពាណិជ្ជកម្ម ហើយការពេបជ្រាយចំពោះទំនៀមទម្លាប់ស្រុកក៏កាន់តែមានឡើង ប្រសិនបើមានដំណាស់អ្វីបន្តិចបន្តួចដល់ពាណិជ្ជកម្ម មានតែចាប់សាមីខ្លួនយកមកឃុំឃាំងចោល មិនសូវមានការជំនុំជំរះរកខុសត្រូវតាមផ្លូវយុត្តិធម៌ឡើយ ។

ប៉ុន្តែក្នុងគ្រាសង្គ្រាមនោះ នៅក្រុងកាស៍ - កាព៉ាប៊ូលី ការបះបោរមិនទាន់ឃើញមានសំដែងអាការឲ្យលេចចេញច្បាស់នៅឡើយ ។ មហាកាអ៊ីតក្រុងតូចនេះ នៅក្រោមអាណាព្យាបាលសាសន៍តួគីព្រមទាំង

ប្រជារាស្ត្រមានសេចក្តីគោរពដ៏អស្ចារ្យ នឹងការខំនុកនុកចិត្តទៅលើគំនិតនាយចៅហ្វាយរបស់ខ្លួនតាំងអស់ ។

តាំងពីប៉ុន្មានសតវត្សមកហើយ វង្សាគតស្តាបនានៅស្រុកនេះ បានបន្តទំនៀមទម្លាប់នឹងសេចក្តីគំនុំចំពោះសាសនាគ្រែចៀងតាំងពីអាពុកដល់កូនជាច្រើនដំណមកហើយ តាមពាក្យចាស់ទុំបរាមៀងមក ។

ជនជាតិអាក៉ាប់ កាលសម័យដើម ធ្លាប់មានថ្កើងថ្កាន បានគ្រាប់ទៅកាន់សាគរគ្រប់ទិស ហើយចេញចាកកំពង់ធំ ។ ទៅដើរវាយយកស្រុកចំណុះកាន់សាកលលោក ព្រមទាំងបានកសាងប្រាសាទស្តុកស្តម្ភនុកជាអនុស្សាវរីយ៍កាន់ទីនេះខ្លះ កាន់ទីនោះខ្លះ ដែលជាអមតៈកិច្ចកាន់អតីតកាល ហើយពួកប្រជារាស្ត្រតែងរីករាយចំពោះភក្តីដំណែល គឺជ័យជំនះនោះ ។ ប៉ុន្តែឥឡូវនេះ សម័យប្រកបដោយកិត្តិយសសោភរលាបផុតរលត់អស់ហើយ ។

ទោះបីជាបាន៉ះពាល់ច្រឡូកច្រឡំ ជាមួយវឌ្ឍនធម៌នៃបច្ចុប្បន្នប្រទេសដែលយកគ្រឿងប្រស់ព្រំដ៏ខ្ចាំង សម្រាប់បន្ទន់ចិត្តមកផ្សព្វផ្សាយនាយនឹងក្បៀរទឹកក្រអូប ក៏ពួកចាស់ព្រឹទ្ធាចារ្យ ពួកគាអុត ពួកលោកសង្ឃ ពួកប្រជារាស្ត្រដែលអាស្រ័យនៅគ្រាមជំរំ កាន់វាំង កាន់ព្រះវិហារ មិនស្ងាប់គំនិត នៅតែនឹកមិនភ្លេច ថាពេលវេលាតែងវិលដូចកង់វែនេះ គង់តែគំនិតប្រាជ្ញាទំនៀមទម្លាប់របស់បូព៌ាប្រទេសត្រូវត្រួតលោកខាងលិចវិញជាមិនខាន ។

ហោរាបានទំនាយទុកមកដែរថា ក្នុងស្រុកនឹងមានវេកាហ៍ គឺមួយសាសនាគ្រែចៀងបាំងបន្ទុំស្ដីផ្ការកាប់ ។ ប៉ុន្តែមួយនេះមិនបិតថែរនៅបានប៉ុន្មានសតវត្សទៀយ គង់មានថ្ងៃណាមួយ កូរ៉ាំ (សាសនាមហាម៉ុត) នឹងមានជ័យ ខាងចុងបំផុត គ្មាននរណាអាចផ្ដាញ់បាន ហើយពួកទ្វិលត្រូវពួកអារ៉ាប់ដេញចេញពីទឹកដីដែលខ្លួនបានដ្រើសសំរាំងទុកឲ្យនេះ ។

ក្នុងពេលនោះ ដើម្បីនឹងតាំងពួកទ្វិលឲ្យបានឈ្នះ មិនត្រឹមតែតាំងចិត្តឲ្យមានក្លាហានជានិច្ចទេ ថែមទាំងត្រូវពិនិត្យពួកទ្វិលឲ្យស្គាល់ជាក់ច្បាស់ពីកម្លាំងនឹងការខ្លាយផង ។ ការសំខាន់ គឺត្រូវសំដែងទឹកមុខស្រស់ញញឹមជាក់ នឹងមានការខ្លួចក់ចាក់រកុយ គឺថាត្រូវធ្វើជាគោរព. ជាចំណុះដោយពិត ចំណែកគំនិតនឹងចិត្តត្រូវតែកុំខ្លួចស្គាល់ទាំងអស់ ។

ហេតុនេះ លោកកាអ៊ីតព្រះនាមអៃយ៉ាដ ជាចៅហ្វាយធំក្នុងក្រុងកាស៊ី-កាប៉ូលីដែលប្រកបដោយសប្បុរសធម៌ បានបញ្ជូនកូនច្បងរបស់លោកឈ្មោះអ៊ីស្មាអ៊ីល ឲ្យទៅសំណាក់អាស្រ័យអស់អំឡុងជាច្រើនឆ្នាំក្នុងប្រទេសអ៊ីរុប ដើម្បីសង្កេតនូវដើមកំណើតទំនៀមទម្លាប់ប្រទេសនោះ។ ហើយនឹងឲ្យដឹងគិតពីការណាអំពីបទនយោបាយ ។

មនុស្សទាំងអស់ក៏មូលមតិគ្នាសុទ្ធចិត្តតាមលោកអៃយ៉ាដ ព្រោះគេចូលចិត្តថាត្រូវឲ្យស្គាល់របៀបវិឌ្ឍនធម៌ប្រទេសបច្ចឹមឲ្យសព្វគ្រប់ ឲ្យ

ច្បាស់លាស់ដើម្បីនឹងដាយកំចាត់ ។ ប៉ុន្តែមានហេតុកំចាំងមួយដែលលោកអែយ៉ាជ នឹងអ្នកជិតខាងមិនបានប្រឆងទុកជាមុន ។

វឌ្ឍនធម៌ប្រទេសបច្ចឹមា ចំទៀមទម្លាប់នឹងគំនិតរបស់សាសន៍អ៊ីរុប មានអានុភាពដ៏អស្ចារ្យអាចធ្វើកិរិយាមារយាទនៃអ្នកកំឡោះ អ៊ីស្មាអ៊ីល ឲ្យប្រព្រឹត្តតាមបាន ។

អ៊ីស្មាអ៊ីល ប៉ានសំណាក់អាស្រ័យក្នុងទីក្រុងធំៗជាច្រើន ហើយមិនអាចអត់ព្រំនឹងសេចក្តីតម្រេកដ៏សុខុម ដែលធ្វើឲ្យរំភើបចិត្តក្នុងក្រុងទាំងនោះ ។

ក្រុងប៉ារីស៍ គឺជាស្ថានដ៏ស័ក្តិសម ព្រមទាំងមានស្ត្រីទាំងឡាយប្រកបដោយរូបឆោមលោមពណ៌យ៉ាងឆើត ជាដំបន់ដែលពួកអ្នកមេគំនិតអ្នកច្នៃប្រឌខាងទស្សនវិជ្ជា ពួកជាងរចនាការ នឹងក្រុមអ្នកនិពន្ធតែងមករកអាហារសម្រាប់ខួរក្បាល រកមហាជនដើម្បីសង្កេត រកមិត្តសំឡាញ់ដើម្បីជ្រើសរើសយក ។

នៅក្រុងវីយ៉ែន អ៊ីស្មាអ៊ីលកើតមានសេចក្តីស្រងូតស្រងាត់ រលឹកដល់ស្រុកកំណើត ព្រោះក្រុងនេះមានសណ្ឋានស្រះឆ៍ះស្រងោចពេកដោយមានផ្ទះកំពូលស្រួចនឹងខ្នងវែចវៀន ចំណែកនៅក្រុងឡុងឌ៍ននឹងក្រុងប៉ែរឡាំង អ៊ីស្មាអ៊ីលបានស្គាល់នូវអាការកាពនៃពួកក្រុមហ៊ុនជាតិអ៊ីរុបផ្សេវាណិជ្ជកម្ម សិប្បិយការ ឬក្រុមការជាធិបតេយ្យ តាំងនៅជាគណៈ។ កងចិបចំងាំងយ៉ាងមាំ ។ គឺពីនោះហើយដែលពួកមនុស្សមានត្រកូល

មុខក្រហមដូចឥដ្ឋ ឬពួកដុកទ័រ (បណ្ឌិត) មុខក្រហមដូចមំសំខើបនឹងកាប់ថ្មី។ យកស្រាប៊ីយែរ សុភ នឹងល្បែងបៀរជាប្រមាណ នាំគ្នាជំនុំអំពីកិច្ចការពាជការ អំពីប្រស្នាប្រាក់កាស នយោបាយ ផ្លូវសេដ្ឋកិច្ច នឹងបញ្ហាយ៉ាងសំខាន់ៗ ចាំងពួងតាមរបៀបវិធានការពាល់ថ្ងៃ ។

លុះមកដល់ស្រុកឡាតាំង មុនដំបូង អ៊ីស្មាអ៊ីលងឿងឆ្ងល់នឹងរបៀបដ៏សុខុមនឹងសេចក្តីគួរសមរបស់អ្នកស្រុកចំពោះពួកស្រី។ តែដល់ទៅប្រទះឃើញប្រទេសអ៊ីតាលី នឹងអេស្បាញ ក៏ធ្វើដូចគ្នាដែរ រឿងនេះបណ្តាលឲ្យអ្នកកំណែ្ចតគិតពិចារណាហើយយល់ថា ការណ៍ភាពអានឥតិភាពដូចជាប្រទេសអាហ្ស៊ី ដែលបានទុកស្រីដូចជាវត្តុជាគ្រឿងលំអមកជាយូរឆ្នាំហើយ នោះមិនមែនគាស់ទេ សាសន៍ណាដែលធ្វើបែបនេះគេទុកសាសន៍នោះជាមានអារ្យធម៌យ៉ាងពិតប្រាកដ ។

កាលវិលមកស្រុកកំណើតវិញ អ៊ីស្មាអ៊ីលនៅតាន់តាមទំនៀមទម្លាប់នៃប្រទេសអឺរុបខ្លះដែលជាទំនាស់នឹងជាទំនៀមប្រទេសអាហ្ស៊ីប ។ អ៊ីស្មាអ៊ីលលះបង់សំលៀកបំពាក់សំពាប់ជាតិអាហ្ស៊ីបអស់ ដូចយ៉ាងខោខូលាយស៊ូដ្រូ មួកក្រឡមជាំត្បូងស្កុកស្កុះ សំពត់រយ៉ែរយ៉ៃសម្រាប់រុំនឹងឆ្តជួតសំពោងពីលើដូចជាបម ។ ក្តៅឡប់ជាស្លៀកពាក់របៀបល្បែងកីឡា (ស្ពរ) សំពត់សាឡាតអង់គ្លេសខ្លីនឹងសមរម្យ គឺខោខ្លីពាក់ស្រោមជើងស្បែកយ៉ាងខ្លីពីក្រៅ ថែមអាវខ្លីនាប់សំពត់សាច់ម៉ដ្ឋ ហើយស្តើងស្រាលដែលនាំឲ្យត្រជាក់កាយស្រួល ។ (មានត)

ការប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ត្រូវការជ្រើសរើសយកឯកសារទំនៀមទម្លាប់ខ្មែរ ដោយបើកការប្រឡងប្រជែង ២ រឿង គឺ

រឿងទី ១ អំពីរាហូ

រឿងទី ២ អំពីការស្ថាបនាក្រឹះស្ថាន

ឯកសារសម្រាប់ប្រឡងនេះ សម្រេចយកនៅឆមាសទី ១ គឺតាំងពីខែមករា ដល់ដាច់ខែមិថុនា ឆ្នាំ ១៩៥៤ ។

ដូច្នេះ អស់លោកចាំធ្លាយ ទោះជាស្ត្រី បុរស គ្រហស្ថ ឬបព្វជិត ដែលស្ម័គ្រចិត្តជាបេក្ខជនប្រឡង សូមតែងរឿងដូចខាងលើ ជូនទៅក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ឲ្យទាន់មុនថ្ងៃដាច់ខែមិថុនាឆ្នាំ ១៩៥៤ ។

បេក្ខជននឹងយករឿងប្រឡងទៅដូនផ្ទាល់ខ្លួនក៏បាន, ផ្ញើតាមប៉ុស្ត៍ទៅក៏បាន, យកទៅដូនសាលាឃុំ ឬសាលាស្រុកឲ្យផ្ញើឲ្យក៏បាន ដោយកាន់សំបុត្រថា:

ជូនដល់ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសន-បណ្ឌិត្យ ភ្នំពេញ

រឿងដែលបានជាប់លេខ ទឹងបានរង្វាន់ជា ៤ ថ្នាក់ គឺ

រង្វាន់លេខ ១ ..... ៤០០រ. ០០

រង្វាន់លេខ ២ ..... ៣០០, ០០

រង្វាន់លេខ ៣ ..... ២០០, ០០

រង្វាន់លេខ ៤ ..... ១០០, ០០

បេក្ខជនមួយរូប។ អាចតែងតាំង ២ រឿងបាន, តែសូមសរសេរ រឿងមួយធ្វើជាឯកសារមួយជាប់ដោយឡែកពីគ្នា ដោយដាក់ឈ្មោះ ឯកសារ ឈ្មោះបេក្ខជនត្រមតាំងទីលំនៅឲ្យច្បាស់ដលើឯកសារ នីមួយ។ ។

មួយរូប។ បើតែងលួតាំង ២ រឿងទឹងបានជាប់លេខ បានរង្វាន់ តាំង ២ រឿង ។

ឯសំនួរខាងមុខនេះ ចួនកាលបេក្ខជនធ្វើយពុំបានសព្វគ្រប់ទេ ប៉ុន្តែបើបេក្ខជនយើញការឯទៀតក្រៅពីនេះ ហើយអាចសរសេរឲ្យការ ទៅបាន នោះក្រុមជំនុំអរគុណណាស់ ពីព្រោះសំនួរតាំងប៉ុន្មាននេះ គ្រាន់តែជាលំនាំគ្រាយផ្លូវអ្នកតែងទេ, ឯការចំបំផុត គឺ ក្រុមជំនុំត្រូវ ការតែឯកសាររបស់បេក្ខជនណា ដែលឲ្យការច្បាស់ហើយមានគោល ចាកសព្វគ្រប់ ។

គោលនៃការតែងរឿងប្រឡង

រឿងទី ១ អំពីរូបភាព

ក្នុងបច្ចុប្បន្នកាលនេះ យើងតែងឃើញមានរូបភាពច្រើនជាអនេក នៅលើជញ្ជាំងក្រុងសាខបុរាណ នឹងនៅទីវត្តនានារបស់ខ្មែរយើងក្នុងកម្ពុជរដ្ឋ ។ ការនេះបង្ហាញឲ្យឃើញថា ប្រជាជនខ្មែរយើងធ្លាប់ដឿងធ្លាប់គោរពរូបភាពអំពីអតីតកាល ។

ហេតុនេះ ចានជាក្រុមជំនុំទំនៀមទម្លាប់ខ្មែរដែលជាអ្នកស្រាវជ្រាវរកទំនៀមខ្មែរត្រូវការប្រមូលឯកសារផ្សេង។ ដែលពាក់ព័ន្ធដោយរូបភាពដូចមានសំនួរតទៅនេះ :

ក) រូបភាពដែលគេត្រូវការគូរ ឬធ្លាក់នៅក្រុងសាខ ឬនៅវត្ត តើគេតែងគូរជាក់ត្រង់ណា ខ្លះ? ប្រយោជន៍អ្វីបានជាគេគូរជាក់ត្រង់នោះ?

ខ) គេមានគូរឬធ្លាក់រូបភាពនៅទីណា ខ្លះទៀតក្រៅពីក្រុងសាខ ឬវត្តដែរឬទេ ?

គ) នៅស្ពានជ័យ ឬក្តារម្ជួស តើគេមានគូរ ឬ ធ្លាក់រូបភាពឬទេ? បើមានធ្វើនៅវត្តនោះ តើប្រយោជន៍អ្វីបានជាគេធ្វើ? ដោយមានទំនៀមដូចម្តេច?

ឃ) ប្រយោជន៍អ្វីបានជាគេគូរឬធ្លាក់រូបភាពជាក់ក្នុងផ្ទះ នឹងក្នុងព្រះពុទ្ធរូបជាដើម?

ឆ) កាលគេនឹងតូរប្តូនឹងធ្វាក់រូបភាហូ តើមានក្បួនខ្នាតនិយាយយ៉ាងណាខ្លះដែរឬទេ? ហើយគេតូរឲ្យធ្វាក់ធ្វើទម្រង់មុខ, ធ្វើសក់, ធ្វើធ្មេញ ។ល។ គេឲ្យព័ណ៌បៃបណា? ។ល។

ជ) កាលគេនឹងចាប់ផ្តើមតូរប្តូធ្វាក់ប្តូនឹងបង្ហើយកិច្ចនេះ តើមានទំនៀមធ្វើពិធី (សំណែន បូជា ត្រណម) ។ល។ ដែរឬទេ?

ឈ) មានឈ្មោះផ្សេង។ សម្រាប់ហៅជំនួសឈ្មោះភាហូឬទេ?

ញ) ហេតុដូចម្តេចបានជាគេធ្វើរូបភាហូតែ ១ កំណាត់ខ្លួន?

ដ) មានរឿងព្រៃឆ្កាក់ទង់ដោយភាហូដែរឬ?

ឋ) ក្បួនហោរ ភាហូមានតំណែងជាអ្វីខ្លះ?

ឌ) បើមានជំនឿឬពិធីអ្វីភាក់ទង់ដោយភាហូ សូមបរិយាយ ។

រឿងទី ២ អំពីការស្តាបនាក្រុងស្វាយ

ការសង់ផ្ទះ:

ក) សណ្ឋានទ្រង់ទ្រាយផ្ទះខ្មែរយើង មានឈ្មោះប៉ុន្មានយ៉ាង? ផ្ទះពេងដោល, ពេងឌឿង, បុត, កន្តាំង, ។ល។ មានទ្រង់ទ្រាយខ្លួកតីគ្នាដូចម្តេចខ្លះ? (បើអាចគួរបូកាពផ្ទះគំរាងនោះបាន សូមគួរដោយទឹកភ្លៀឲ្យមានសរសៃច្បាស់។ ដោយជាក់ខ្នាតទទឹងបណ្តោយជាដើមផង) ។

ខ) រដ្ឋការណាគេធ្វើផ្ទះបែបណា ?

គ) ផ្ទះនីមួយៗ មានលែ្វងប៉ុន្មាន? ថ្នាក់ប៉ុន្មាន? ហើយលែ្វងណាសម្រាប់ជាក់អ្វី? ថ្នាក់ណាសម្រាប់ធ្វើអ្វី?

ឃ) ផ្ទះមានឈ្មោះជាមួយគ្នា តើគេរចនាបែ្លកគ្នាទៅតាមជនបទដែរឬ?

ង) ក្នុងកូមិកាគនីមួយ ៗ តាមទំនៀមគេសង់ផ្ទះធំ, ផ្ទះបាយ, ជង្រុកស្រូវតែង់ការគណា ? អណ្តូងទឹកតែង់ការគណា ? ។ល។

ច) ផ្ទះគ្រឿងឈើក្តី - ឥដ្ឋក្តី - ស៊ីម៉ងត៍ក្តី វេលាផ្តើមប្រូង ដូចលើកសសរឬរៀបឥដ្ឋដំបូង តើគេចាត់របៀបនឹពិធី (សំណែនបូជា គ្រណម) ។ល។ ដូចម្តេចខ្លះ?

ឆ) នៅពេលសង់ផ្ទះ ប្រយោជន៍អ្វីបានជាគេជាក់សំពត់ជាតិ ១ ផ្ទាំងនៅមេដំបូល ? ជាតិនោះគេធ្វើយ៉ាងណា ?

ជ) នៅពេលឡើងផ្ទះ តើគេធ្វើពិធីដូចម្តេចខ្លះ?

ការសាងវិត្តៈ

ក) ខ្នាតវត្តនីមួយៗដែលសាងថ្មី តើត្រូវធ្វើទឹងបណ្តាយប៉ុណ្ណា? ហើយទឹងបណ្តាយបែរទៅខាងណា ?

ខ) សណ្ឋានទ្រង់ទ្រាយវិហារ សាលាកុដិ ។ល។ ដូចម្តេចខ្លះ? មានឈ្មោះប៉ុន្មានយ៉ាង? (បើអាចគួរបូរូបភាពអចលនវត្តុទាំងនេះបាន សូម

គួរដោយទឹកឡើងឲ្យមានសភាសៃច្បាស់ៗ ដោយជាក់ខ្លាតទទឹងបណ្តោយ ជាដើមផង) ។

គ) សណ្ឋានទ្រង់ទ្រាយវិហារ សាលា កុដិ មានប្លែកគ្នាដោយរដ្ឋកាលដែរឬទេ ?

ឃ) គ្រឿងរចនាដូចម្តេចខ្លះដែលគេតែងធ្វើជាក់វត្ត ? ហើយគ្រឿងណាគេធ្វើតំណាងអ្វី ?

ង) ក្នុងភាគផែនទីវត្តនីមួយ ។ តើគេត្រូវធ្វើវិហារត្រង់ណា ? សាលាបុណ្យត្រង់ណា ? កុដិចៅអធិការត្រង់ណា ? ។ល។ (បើមានក្បួនណានិយាយពីការបែងភាគនេះសូមកត់ទៅផង) ។

ច) ការសាងទីវត្តចាំងមូលក្តី ការសង់វិហារក្តី សាលាបុណ្យក្តី កុដិក្តី ។ល។ មានពិធីប៉ុន្មានថ្នាក់ ? ដូចថ្នាក់ប្រឹងដំបូង, ថ្នាក់លើកសសរ, ថ្នាក់លើកជហ្វា, ថ្នាក់ធ្នង, ថ្នាក់ឡើងកុដិ, តើមានរបៀបទំនងពិធី (សំណែន ឬជា គ្រោម) ដូចម្តេចខ្លះ ?

ឆ) ហេតុអ្វីបានជាគេធ្វើខ្នុមអកតាជាក់ពីមុខវត្តពស់តែវត្ត ? តើគេធ្វើតាមជំនឿអ្វី ? មានប្រយោជន៍អ្វីបានជាគេធ្វើ ? ក្នុងកិច្ចសាងវត្តតើខាងធ្វើខ្នុមនេះបានឬពុំបាន ?

បណ្តាឯកសារសម្រាប់ប្រឡងទាំង ២ មុខ ដូចរៀបរាប់ក្នុងសំនួរខាងលើនេះ បើបេក្ខជនត្រូវការតែងឯកសារមុខណា សូមកុំភ្លេចប្រាប់ដើមកំណើតអត្ថបទក្នុងឯកសារមុខនោះ ថាធ្វើតាមគម្ពីរឬក្បួនណា, តាមពាក្យនរណា, ឬបានឃើញគេធ្វើនៅទីណា ។ល។

ក្រុមដំនុំទៀមទម្លាប់ខ្មែរ

ភគ្គវចសទ្ទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៦ ខែមីនា លេខ ៣

ព.ស. ២៤៩៦ – គ.ស. ១៩៥៤



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— សុទ្ធកថា	ព្រះមហា សុខ-វិន់	១៦៣
— វិម្ជិកប្បញ្ហា	ព្រះមហា ច័ន្ទ-ហុង	១៧២
ផ្នែកអក្សរសាស្ត្រ		
— រឿងព្រេងបួនឥរិយាបថ	ឃុនបណ្ណាន៉ុរក្ស ប៊ូ-ប៊ូ	១៨២
— ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៊ម ...	១៨៩
— រឿងសាមកុក (តមក)	ឧកញ៉ា ន្ហូ- កន	១៩៨
— ទាល:ទំងទមយន្តី (តមក)	អ្នកស្រី ស្រ៊ីន-សារីយ៉ាន់	២១០
— ដំណើរអស្ចារ្យនៃលោកភីសូប៊ីយូយេ (តមក)	លោកភ័យ -ប៊ុក	២១៩
— ដំណឹងតាមខ្សែក្នុងកន្ត្រាះ (តមក)	លោកផេង-ជ្រីវ	២២៥
កំណត់ទឹងប្រវត្តិការណ៍		
— សុន្ទរកថាថ្លែងក្នុងពិធីអនុស្សាវរីយ៍ជ្រះមហាសន្និ-ប៉ាតនៃមន្ត្រីសង្ឃលើកទី ១០	ឯកឧត្តម សម -ញាណ.....	២៣៥

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដាវ ២០០រ.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE BELIGIEUSE:

— Sukhakatha . . . . . *Brah Maha SOK-VON* 163

— Vammikappanha . . . . . *Brah Maha CHANN-HONG* . . . 172

PARTIE LITTERAIRE:

— Les quatre légendes . . . . . M. BOU-PO 182

— Education morale (suite) . . . *Brah Maha PEUNG-PAM* 189

— Histoire de SAMKOK (suite) . *Oknha NOU-KAN* 198

— Nala et Damayanti (suite) . . *Mme SRIN-SARIS-YANN* 210

— Le voyage extraordinaire de Vasiobioyé (suite) . . . . . M. RAY-BUC 219

— Le souffle du désert (suite) . M. PHENG CHRIV 225

NOTES ET CHRONIQUES:

— Allocution de S. E. le Ministre des Cultes à la 10 ème Assemblée Religieuse . . . . . S. E. SAM-NHEAN 235

Prix d'abonnement annuel (comprenant 12 numéros) 200$00

ព្រះមហា សុខ - វ៉ែន ៖ និស្សិតសាលាបាលីជាន់ខ្ពស់

រៀបរៀង

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការព្រះកតវន្តមុនីអរហំសម្មាសម្ពុទ្ធ (ត្រមាំងព្រះធម៌ នឹងព្រះអរិយសង្ឃដោយសេចក្តីគោរព) ។

លំដាប់នេះ អាត្មាភាពនឹងសំដែងអំពីកំណើតនៃសេចក្តីសុខ ជាសង្ខេបតាមសមគួរដល់កាលវេលា ដូចមានសេចក្តីតទៅនេះ ។

សុខោ ពុទ្ធានមុប្បាទោ "ការកើតឡើង នៃព្រះពុទ្ធទាំងឡាយ ជាហេតុទាំឲ្យកើតសេចក្តីសុខ" ។

អធិប្បាយថា: កន្លងកាលដែលមានព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹងឡើង, សត្វមានចំនួនច្រើនឥតនឹងរាប់មិនអស់ តែងបានជួបប្រទះនូវប្រយោជន៍នឹងសេចក្តីសុខស្ងប់ជាំក្រៃលែង ។ ព្រោះព្រះសព្វញ្ញុពុទ្ធទ្រង់ទ្រព្រឹងឡើង ទ្រង់ប្រកបដោយសិរីសម្បត្តិដ៏ខ្ពង់ខ្ពស់គួរស្ញើច ជាទីបូជារបស់ពួកជនហើយបរិបូណ៌ដោយចំណេះវិជ្ជាគ្រប់យ៉ាង ត្រមាំងមានព្រះទ័យពោញប្រៀបដោយសេចក្តីករុណា អាណិតអាសូរពួកសត្វខ្លួនទៅកន្លងនូវគ្រួគព

ឥតរើសមុខ ។ ដោយពិត, ព្រះបរមគ្រូដែលទ្រង់បានជួបប្រទះនឹងសេចក្តីសុខក្សេមក្ខេមដ៏ខ្ពស់ផុតចំណោមមនុស្ស ដោយគោត្រតែកូលពាជសម្បត្តិជាដើម ក៏ព្រោះកម្រៃបុណ្យ សេចក្តីល្អដែលទ្រង់បានកសាងសន្សំទុកជាលំដាប់ជាតិៗមក ។

ព្រះលោកនាថប្រកបដោយព្រះមហាករុណាគុណ ទោះបីព្រះអង្គបានសេចក្តីសុខស្រួលដូចម្តេច ក៏មិនទម្រន់ឲ្យលក់ដក់ងប់ជាប់ព្រះទ័យឲ្យតាល់តែលង់ចាំងគំនិតដល់ភ្លេចនឹកមិនឃើញ នូវការសុខទុក្ខរបស់ពពួកសត្វដែលលិចលង់ក្នុងលោកសន្និវាសនេះទេ, ព្រះអង្គមិនត្រមទទួលសោយសេចក្តីសុខថ្កុំថ្កើងជាផលសំណាងដែលបានមកតាំងនៅស៊ប់ក្នុងកណ្តាប់ព្រះហស្តរបស់ព្រះអង្គតែមួយព្រះអង្គប៉ុណ្ណោះទេ ទ្រង់ស៊ូលះបង់ប្រយោជន៍ចាំងនោះចោលស្រឡះមិនទឹកនា ។ ទ្រង់បំពេញព្យាយាមតាល់តែបានសម្រេចជ្រាជ្រៅពេញញាណលើរតនបល្ល័ង្ក ព្រះអង្គបានដឹងជាសត្តនាយក:អ្នកដឹកនាំស្រោចស្រង់សត្វឲ្យឆៅកង់លោក ឲ្យផុតពីសេចក្តីទុក្ខលំបាកមានកើត, ចាស់, ឈឺ, ស្លាប់ជាដើម (ដូចជាសំពៅធំ) ។

ចាប់ដើមតាំងពីត្រឹមឆ្នាំដែលទ្រង់បានត្រាស់ដឹងមក ព្រះអរហំសម្មាសម្ពុទ្ធ ស្តេចយាងទៅប្រកាសសាសនាប្រទានឧបាទេក្យរប្រៀនប្រដៅណែនាំពពួកសត្វមានមនុស្សនឹងទេវតាជាដើម. ។ ទ្រង់ព្យាយាមសំដែងធម៌បំភ្លឺពន្យល់ប្រាប់គុណ, ទោស, ឧស, ត្រូវ ឲ្យសត្វយល់ឃើញ

ពិតៗឥតរួញរាន់ដ៏សេចក្តីខ្ជឿយព្រួយព្រះកាយពលក្នុងការប្រកាសប្រាប់ប្រយោជន៍របស់សត្វទាំងនោះឡើយ ។

ព្រះអង្គទ្រង់ប្រឹងបំពេញពុទ្ធកិច្ចគ្រប់គ្រាន់មិនមានចន្លោះសមស័ក្តិព្រះអង្គជា សត្ថានាយក: អ្នកដឹកនាំស្រោចស្រង់ជាទីពឹងពាក់ព័ន្ធក់អាស្រ័យនៃសត្វក្នុងត្រៃលោកមែន ។ ទាំងមានព្រះឥរិយាបថស្រគត់ស្រគមសមរម្យ មានព្រះអធ្យាស្រ័យដ៏ទន់ភ្លន់ស្មោះស្មើ ស្លូតត្រង់ទៅរកសត្វទួទៅ, គួរឲ្យមនុស្សទេវតានឹងសត្វគ្រប់ថ្នាក់ មានសេចក្តីសង្ឃឹមកក់ក្តៅចូលទៅជិតកោនក្រោមម្លប់ពោធិស្តារ ជានសម្រេចសន្តិសុខតាមប្រាថ្នា; ព្រះអង្គមានទំនងគួរឲ្យសត្វក្នុងសកលលោកគោរពក្រាបសំពះយកតម្រាប់តាម ដោយសេចក្តីពេញចិត្តមិនចាប់ចង្អុំ ។

ព្រះពុទ្ធគុណដែលរៀបរាប់មកខាងលើនេះ បើពោលបំព្រួញឲ្យខ្លីរាយចំណាំជាងនោះមកទៀត ថា ព្រះអរហំសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ទ្រង់មានព្រះជ័យស្អាត មិនច្រឡាក់ដោយបាបសេចក្តីអាក្រក់ណាមួយដូច្នេះហៅថា វិសុទ្ធិគុណ ។ ទ្រង់ទំប្រឹងបំពេញប្រយោជន៍ឲ្យសត្វបានទទួលសេចក្តីសុខតាមគតិលោកគតិធម៌ពាល់គ្នា សមគួរដល់ភ័ព្វសំណាងសត្វ មិនណាក់បំខ្ចប្រយោជន៍ទុកសម្រាំរសោយសេចក្តីសុខស្រួលតែមួយព្រះអង្គឡើយ ដូច្នេះហៅថា ករុណាគុណ ។ ទ្រង់មាន

ចាយដ៏ប្រពៃក្នុងការឲ្យទានសត្វ ធ្វើសេចក្តីជ្រះថ្លាឲ្យរាក់ កំចាំងឲ្យងាយយល់ ងាយគិតជាដើម ដូច្នេះហៅថា បញ្ញាគុណ ។

ដោយហេតុនេះទើបប្រកាសដថា ព្រះពុទ្ធគ្រប់ព្រះអង្គបានត្រាស់ដឹងឡើងក្នុងលោក ជាហេតុនាំឲ្យបានសេចក្តីសុខ (ដល់ពួកសត្វក្នុងត្រៃភព) ។ សេចក្តីដែលសំដែងមកនេះជាគុណដែលមានក្នុងព្រះអង្គ ។

ស្វាក្ខាតោ ភគវតា ធម្មោ ធម្មដែលព្រះសម្ពុទ្ធសំដែងដោយប្រពៃ មានគុណអាចស្រោចស្រង់សត្វលោកដែលពេញចិត្តកាន់តាមឲ្យផុតអំពីទុក្ខទោស បានសេចក្តីសុខស្រួលយើញជាក់ច្បាស់ចំពោះមុខភ្លាម។ តាមថ្នាក់តាមជាន់ឥតបង្អន់ចំាកាលវេលា ។ ធម្មោ សុបិណ្ណោ សុខមាវហាតិ ធម្មដែលសត្វបានរក្សាទុកត្រឹមត្រូវ នឹងផ្តល់សេចក្តីសុខមកឲ្យវិញពុំខាន ។

អធិប្បាយថា : អំពើល្អហៅថាធម៌, អ្នកប្រព្រឹត្តត្រឹមត្រូវតាមធម៌ ឈ្មោះថាបានរក្សាធម៌ទុកដោយប្រពៃ នឹងត្រូវបានផលជាសុខ; អ្នកមិនកាន់តាមធម៌នឹងត្រូវបានផលជាទុក្ខ ។ រួមព្រះធម៌ចាំង ៨៤០០០ ធម្មក្ខន្ធ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងហៅថាពុទ្ធសាសនា ។

សាធុជន ដែលពេញចិត្តគាប់អធ្យាស្រ័យក៏ចង់បានប្រយោជន៍សេចក្តីសុខសេចក្តីចំរើនត្រឹមតែក្នុងលោកនេះក៏គួរតែបង្អោនចិត្ត ចូលមក

កាន់ព្រះពុទ្ធសាសនាកុំខាន ព្រោះព្រះពុទ្ធសាសនានេះ អ្នកប្រាជ្ញជាន់ខ្ពស់កន្លងមក បានពិនិត្យឃើញពិតថា ជាសាសនាមានអានុភាពអាចធ្វើលោកឲ្យស្ងប់, ទាំងញាំងមនុស្សសត្វដែលទន់ទាបថោកថយឲ្យខ្ពង់ខ្ពស់ថ្កុំថ្កើង, បើថ្ងៃថ្ងៃស្រាប់ ឲ្យរឹងរឹតតែវិសេសវិសាលឡើងទៀត ។ សេចក្តីដែលពណ៌នាមកនេះ ត្រង់តាមគោលដើមនៃពុទ្ធបំណងពិត, ព្រោះព្រះអង្គដែលទ្រង់ព្រះប្រឹងព្យាយាមសំដែងប្រាប់ប្រាប់ពន្យល់មនុស្សទាំងនេះយូរអង្វែងម្ល៉េះ ដោយទ្រង់មានព្រះទ័យករុណាចង់ដោះស្រាយពួកសត្វដែលជាប់ចំណងនៃសេចក្តីទុក្ខលំបាកមានជាតិ, ជរា, ព្យាធិ, មរណៈជាដើម ឲ្យរួចចាកទុក្ខបានសេចក្តីសុខស្កប់ស្កល់ប៉ុណ្ណោះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ថា ពួកមនុស្សសត្វកើតមកពេញទាំងសកលលោក សុទ្ធសឹងតែប្រាថ្នាសេចក្តីខ្ពង់ខ្ពស់ថ្កុំថ្កើងគ្រប់ៗរូប, ដែលបែរជាបានសេចក្តីអាប់ឧនទន់ទាប មិនសមដូចបំណងស្មើគ្នាទៅវិញនោះ បណ្តាលមកពីហេតុច្រើនយ៉ាងណាស់, ខ្លះកើតឡើងដោយសេចក្តីទន់ទាបគ្រឹក្រលំដ៏ខ្លាំងស្រាប់មកអំពីកំណើតកំមាន ព្រោះផលបុព្វតិច, ខ្លះកើតមកបានជួបប្រទះនឹងសេចក្តីថ្កុំថ្កើងសម្បូណ៌សម្បត្តិគ្រប់គ្រាន់ស្រាប់ពីកំណើត តែឆ្មៃសក្ខេចគិតបណ្តោយចិត្តឲ្យទៅប្រព្រឹត្តអាក្រក់ថាស់ទំនង ពានទៅលើអំពើមិនមែនជាធម៌ បានសេចក្តីថ្លង់

ឲ្យយល់ក្នុងជាអ្នកទន់ខាបអាប់ឧនខ្លួចទៅវិញក៏មាន, ខ្លះចប់ខ្លួនឲ្យនៅ
តែមតែស្មើ។ មិនខាបមិនខ្ពស់ក៏មាន, តាមសមគួរដល់អំពើដែលសត្វបាន
ធ្វើរៀង។ ខ្លួន; ដូចព្រះគាសិតថា សព្វេ កម្មំ រិភជ្ជេពិ កម្មគឺអំពើ
ដែលសត្វធ្វើពុកមកអំពីជាតិមុន ឬជាតិនេះជាមេចំណែកចែកឲ្យសត្វបាន
សុខបានទុក្ខផ្សេង។ គ្នា មិនមែនអ្វីផ្សេងក្រៅពីអំពើរបស់ខ្លួននោះចែក
ឲ្យឡើយ ។

ឯអំពើអាក្រក់ នាំមនុស្សឲ្យវិនាសបានសេចក្តីទុក្ខលំបាកខាងលោក
នេះនឹងលោកខាងមុខនោះ គឺ:

អបាយមុខ (ហេតុដែលនាំឲ្យវិនាសសេចក្តីចំរើន) ៤ យ៉ាងគឺ:

១—ឥត្ថីធុត្តៈ: អ្នកជោកចិត្តជក់នឹងមាតុគ្រាម មិនមានចិត្តសន្តោស
តែមតែកបិយា - ស្វាមីរបស់ផងខ្លួន

២— សុរាធុត្តៈ: អ្នកសេពគ្រឿងស្រវឹង

៣— អក្ខធុត្តៈ: អ្នកលេងល្បែងភ្នាល់

៤— បាបមិត្តៈ: អ្នកគប់រកមនុស្សអន្ធពាល អាក្រក់ជាមិត្ត ។

ហេតុទាំង ៤ នេះសុទ្ធសឹងតែជាអំពើអាក្រក់ អាចនាំឲ្យប្រទេសជាតិ
មាតុភូមិ កោតសម្បីទន្ទឹងចំបាស្រុកស្រុតចុះថោកទាបនាំឲ្យវិនាសដូស
ឲ្យខូចបង់ប្រយោជន៍សេចក្តីសុខចំរើន របស់មនុស្សក្នុងសកលលោក

ជាកំស្តែងក្លាមៗ មិនចាប់ពោលថ្លើមៅលោកខាងមុខនោះឡើយ ។ មែនពិត, អំពើទាំងនេះ បើសត្វទំប្រើងប្រព្រឹត្តជាប់មិនលែង លោកពោលថាទុកដូចជាគប់ក្តីធំយ៉ាងធំ មកដុតពោលកំឡោចបំផ្លាញគោគសម្បត្តិ ចំណេះវិជ្ជា, ចរិយា, មារយាទ, ជាតិកំណើត, ទឹងសន្តិសុខ ដ៏រុងរឿងរបស់ខ្លួនឲ្យខ្ទេចក្រិនខូច លែងលូតលាស់ដុះចំរើនឡើងទៀត រួចចេះតែរេចរៃៅជានិច្ច ឈ្មោះថាមនុស្សជ្រូញទុក្ខ ។

បុគ្គលគួរកុំប្រព្រឹត្តអំពើទាំងនេះឲ្យសោះ កាលបើយើងវៀរចាកអំពើទាំងនេះរួចស្រឡះហើយ ឈ្មោះថាបានប្រព្រឹត្តធម៌ រក្សាធម៌ទុកដោយប្រពៃ ទឹងបានផលជាសុខច្រើនប្រការ; បើពោលដោយសង្ខេបវិញ គឺ:

១ - សុខព្រោះមានចិត្តស្រេះស្រួលស្មោះស្មើៅកេស្មាមីកវិយោដោយមិនជាប់ចិត្តនឹងបុរេ-ស្ត្រីឯទៀត;

២ - សុខព្រោះមានសំដីពិរោជាប្រក្រតី មិននិយាយឡេះឡោះកកែកកវែកវើងឈ្មោះ មិនខូចបង់ប្រាក់កាស់ ដោយហេតុមិនសេពសុភ;

៣ - សុខព្រោះបានធ្វើការងារចំរើន រៀនវិជ្ជាចេះចាំមិនភ័យនឹងអ្នកពាក្យចោទប្រកាន់ ឃុំឃាំងលក់ដៃ ដោយហេតុមិនលេងល្បែងល្បាន់ក្តាល់;

៤ - សុខព្រោះចិត្តស្លូតត្រង់ មិនចេះធ្វើអំពើអាក្រក់ ដោយហេតុមិនសេពគប់រកជនពាល ។

ឯការតប់រកជនអន្ធពាល នាំឲ្យចេះចំណេះអាក្រក់ ព្រោះមនុស្សពាលមិនដែលមានសមត្ថភាព ខាងឯនាំឲ្យប្រព្រឹត្តល្អទេ មិនស្គាល់ហេតុនាំឲ្យបានសុខ ស្តាប់ពាក្យត្រូវមិនសូវបាន, បើអ្នកដែលទៅសេពតប់មិនចេះលេងស្រី នាំឲ្យចេះលេងស្រី, មិនចេះសេពសុរា នាំឲ្យចេះសេពសុរា, មិនចេះលេងល្បែងភ្នាល់ នាំឲ្យចេះល្បែងភ្នាល់, រហូតដល់ទៅនាំឲ្យចេះដើរលេងយប់, ចោកប្រាស់បំបាត់ប្រវ័ញ្ចគេ ធ្លាក់ដល់ចេះលួចប្លន់កាប់សម្លាប់គេក៏សឹងមាន; ត្រូវនឹងព្រះពុទ្ធភាសិតថា អសេវនា จ พาลานំ ការមិនគប់រកពួកជនពាល ចាត់ជាមង្គលដ៏ប្រសើរ ។

អ្នកដែលរៀបចាកអំពើអាក្រក់ ដូចបានពោលមកហើយនេះ ពុកដូចជាអ្នកបានបណ្តុះប្រយោជន៍ដ៏ធំទូលាយចំពោះខ្លួនផង ពុកសម្រាប់ប្រទេសជាតិមាតុភូមិ ឲ្យដើរលឿនទៅកាន់វឌ្ឍនធម៌ខាងអនាគតផង ។ សេចក្តីសុខទុក្ខទាំងនេះកើតមកអំពីកម្មផ្ទាល់ខ្លួនពិត ។ ការលះបង់អច្ចយមុខមានប្រយោជន៍ដ៏ធំទូលាយក្រៃពេក ។ ដែលសំដែងមកនេះជាសេចក្តីសង្ខេប ។

មិនត្រឹមតែប៉ុណ្ណោះដែលហៅថាសាសនាបរិសុទ្ធនោះ គឺជាសាសនាអាចជ្រាបលោកឲ្យលឿនទៅកាន់សេចក្តីចំរើន ពប់សត្វមិនឲ្យធ្លាក់ទៅកាន់ទីថោកទាបមាននរកជាដើម ឲ្យលោកបានសេចក្តីសុខសូប ទាំង

ធ្វើឲ្យអ្នកដឿស្តាប់តាន់តាម ជាន ច្រៃ ន ប្រយោជន៍សេចក្តីចំរើនដោយ
គោតសម្ប័ទបញ្ញាសម្ប័ទ កើត្តឈ្មោះយសសក្តិតាមសមគួរ មិនមែន
សំដែងច្រាប់ឲ្យមនុស្សសត្វ ដេកទម្រន់ចាំសំណាងពីព្រៃនាយតែម្យ៉ាង
ទេ ដូចពុទ្ធភាសិតថា សុស្សូសំ លភតេ បញ្ញំ អ្នកមានច្រាជ្ញចេះ
ចំណេះវិជ្ជាគ្រប់យ៉ាងជាន មកពីច្រឹងរៀនស្តាប់ទន្ទេញ មិនធ្វេសច្រហែស
ក្នុងការរៀនសូត្រ ឧដ្ឋាតា វិន្ទតេ ធនំ អ្នកមានទ្រព្យគ្រប់គ្រាន់
មកពីរវៀសរវៃច្រឹងកច្រឹងធ្វើមិនខ្ជិល ។ សេចក្តីដែលសំដែងមកប៉ុណ្ណេះ
តាមលំអានព្រះពុទ្ធសាសនា ជាសាសនាច្រាប់ផ្លូវច្រតិបត្តិយ៉ាងកណ្តាល
មិនឲ្យសត្វកាន់ងាកធ្លាក់ទៅលើផ្លូវច្រតិបត្តិធ្វេនដែលហៅថា អត្តា បដិ
បទា សេចក្តីច្រតិបត្តិដ៏លាមក ឬអមខាងនោះឡើយ មានទំនងឲ្យពួក
ពុទ្ធបរិសទ្យ នាំគ្នាកាន់តាមសេចក្តីពេញចិត្តឥតបង្ខិតបង្ខំ ។

ព្រោះហេតុនោះ ទើបអធិប្បាយថាជាសាសនា ស្អាងលោកឲ្យ
រុងរឿង ចប់សត្វមិនឲ្យធ្លាក់ទៅកាន់ទីទាប ។

អាត្មាភាពសំដែងមកអំពីដើមកំណើតនៃសេចក្តីសុខ សូមសន្មតថា
ចប់ដោយសង្ខេបតែប៉ុណ្ណេះ ឯវំ ។

ព្រះមហា ប៊ន្ធ-ហុង

វត្តបល័ង្គ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

រៀបរៀង

ពាក្យថា "វម្មិកៈ" នេះ ប្រែថា "ដំបូក" គឺសូត្រសំដែងអំពីរូបកាយ ដោយយកដំបូកមកប្រៀបធៀប ។ ព្រះសូត្រនេះ ព្រះបរមសាស្តាទ្រង់សំដែងក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ចំពោះកុមារកស្សបព្រាហ្មណ៍ ដូចខ្លះថា ៖

១ – អ្វីហ្នា+ហៅថាដំបូក ?

២ – អ្វីហុយផ្សែងក្នុងពេលយប់ ?

៣ – អ្វីឆេះក្នុងពេលថ្ងៃ ?

៤ – អ្នកណាជាព្រាហ្មណ៍ ?

៥ – អ្នកណាជាសុរមេធ ?

៦ – អ្វីជាសស្ត្រា ?

៧ – អ្វីជាការដឹក ?

៨ – អ្វីជាសន្ទុះទ្វារកន់ ?

៩ – អ្វីជាសត្វហ៊ឹង ?

๑๐ - អ្វីជាផ្លូវបែកជាពីរ?

๑๑ - អ្វីជាសំពត់ដណ្តប់ក្បាល?

๑๒ - អ្វីជាអណ្តើក?

๑๓ - អ្វីជាកាំបិតនឹងដុតញ?

๑๔ - អ្វីជាដុំសាច់?

๑๕ - អ្វីជានាគ?

ប្រស្នាទាំង ๑๕ នេះនឹងសូមលើកយកមួយម្តងៗ មកអធិប្បាយតទៅ ។

អ្វីឬហៅថា ដំបូក?

កាយដែលប្រកបដោយមហាភូតរូប ๔ គឺ ដី, ទឹក, ភ្លើង, ខ្យល់ បានឈ្មោះថា ដំបូក ។

អធិប្បាយ: សភាវៈធម៌ដែលប្រកបដោយ "សង្ខតធម៌" គឺធម៌មានបច្ច័យប្រជុំតាក់តែងឲ្យកើតបានទៅជារូប មានសណ្ឋានទ្រង់ទ្រាយមានពណ៌សម្បុរដោយអំណាចជាតុ ๔ ទ្រង់ គឺ:

๑ - ជាតុដី

๒ - ជាតុទឹក

๓ - ជាតុភ្លើង

๔ - ជាតុខ្យល់ ។

ជាតុណាដែលមានលក្ខណៈរឹងប៉ឹងមាំមួនជាដើម ជាតុនោះឈ្មោះ ឋាបឋវីធាតុ ។ នោះដែលជាខាងក្នុង ១៩ គឺ: សក់, រោម, ក្រចក, ធ្មេញ, ស្បែក, សាច់, សរសៃ, ឆ្អឹង, ខួរក្នុងឆ្អឹង, តម្រងជស្សាវៈ(๑), បេះដូង, ថ្លើម, ក្រលៀន, ក្រពះ, ស្លឹត, ពោះវៀនធំ, ពោះវៀនតូច, អាហារថ្មី, អាហារចាស់ ។

ជាតុណាមានលក្ខណៈរាវរង្គើតទ្រាប ជាតុនោះឈ្មោះថា អាបោ-ធាតុ ។ នោះដែលជាខាងក្នុង ១២ គឺ: ប្រមាត់, ស្លេស្ម, ខ្ទុះ, ឈាម, ញើស, ខ្លាញ់ខាប់, ទឹកភ្នែក, ខ្លាញ់ក្រអូ, ទឹកមាត់, ទឹកសំបោរ, ទឹក រំអិល, ទឹកមូត្រ(๒) ។

ជាតុណាដែលមានលក្ខណៈក្តៅ ជាតុនោះឈ្មោះថា តេជោធាតុ ។ នោះដែលជាខាងក្នុង ៤ គឺ:

๑ – ភ្លើងដែលញ៉ាំងកាយឲ្យក្តៅ

๒ – ភ្លើងដែលញ៉ាំងកាយឲ្យទ្រុឌទ្រោម

๓ – ភ្លើងដែលញ៉ាំងកាយឲ្យក្រហល់ក្រហាយ

๔ – ភ្លើងដែលដុតអាហារឲ្យរលួយ ។

---

๑ តម្រងជស្សាវៈនេះ បាលីថា វក្កំ ដែលធ្លាប់ប្រែមកថា ទាប, តែបើតាមសេចក្តីពិត តំតម្រងជស្សាវៈទេ, ទាបនុ៎ះដាំឈ្មោះរបស់ពោតទេតើ ។ ๒ ក្នុងសូត្រដដែរ ។ អាការៈនោះ មានត្រឹមតែ ๓๑ ប៉ុណ្ណោះ, តែអដ្ឋកថាឃើញមានបន្ថែម មត្ថកេ មត្ថលុង្គំ (ខួរក្នុងក្បាល) ផ្លួចទើបគ្រប់ជា អាការៈ ๓๒ ។

ជាតុណាដែលមានលក្ខណៈបក់ទៅមក ។ ជាតុនោះឈ្មោះថា វាយោជាតុ ។ នោះដែលជាខាងក្នុង ៦ គឺ :

๑ – ខ្យល់បក់ឡើងលើ

๒ – ខ្យល់បក់ចុះក្រោម

๓ – ខ្យល់បក់ក្នុងពោះ

๔ – ខ្យល់បក់ក្នុងពោះវៀន

๕ – ខ្យល់បក់តាមខាងកាយ

๖ – ខ្យល់ដកដង្ហើមចេញចូល ។

បណ្ឌិតគប្បីកំណត់ពិចារណាកាយនេះឲ្យឃើញថា គ្រាន់តែជាជាតុ ๔ ប្រជុំគ្នាប៉ុណ្ណោះ មិនមែនជាយើងជាគេឡើយ យ៉ាងនេះហៅថា ជាតុកម្មដ្ឋាន ។

ម្យ៉ាងទៀត គប្បីពិចារណាថា កាយនេះជារូបធម៌តែងវិបត្តិ គ្រប់វិយោបថទាំង ๔ គឺ ដេក, ដើរ, ឈរ, អង្គុយ, កាលក្នុងសាសនានេះ កាលបើដេកក្តី, ដើរក្តី, ឈរក្តី, អង្គុយក្តី, កំគប្បីឲ្យដឹងច្បាស់ថា អាត្មាអញ ដេក, ដើរ, ឈរ, អង្គុយ, យ៉ាងនេះហៅថា ការពិចារណាក្នុងឥរិយាបថ ។

ឬកំពីចារណាថា កាយនេះជាសាកអសុក ៩ យ៉ាង គឺ :

๑ – ។ សាកអសុកដែលគេយកទៅចោលក្នុងព្រៃស្មសានទៅថ្ម ។

ចំនួន ១ ថ្ងៃ ឬ ២ ថ្ងៃដ៏មានសម្បុរទៀវហើមទៀន ប្រកបដោយខ្ទុះហូរ ចេញមកខាងក្រៅ ។

២ – សាកអសុកដែលមានសត្វរុយ ក្អែក គ្នាត ចោមចឹកស៊ីជារដើម

៣ – សាកអសុកនៅតែពងឆ្អឹង មានសរសៃទឹងសាច់ឈាម

៤ – សាកអសុក មានតែសរសៃទឹងឆ្អឹងមានឈាមប្រឡាក់

៥ – សាកអសុក មានត្រឹមតែសរសៃទឹងឆ្អឹងឥតឈាមប្រឡាក់

៦ – សាកអសុកមានតែឆ្អឹងជាប់ពាក់ពាយខ្ចាត់ខ្ចាយពីគ្នា

៧ – សាកអសុកពងឆ្អឹងមានសម្បុរស

៨ – សាកអសុកមានតែឆ្អឹងសល់នៅគរ ចំនួន ១ ឆ្នាំ

៩ – សាកអសុកនៅតែកំទេចឆ្អឹងល្អិត ។ ។

បណ្ឌិតគប្បីពិចារណាខ្ទូរអសុកកម្មដ្ឋានទាំង ៩ យ៉ាងនេះ ដោយការប្រៀបធៀបឲ្យឃើញច្បាស់នូវកាយរបស់យើងថា ជារបស់ពុកផុយ រលួយម៉ត់គ្មានខ្លឹមសារ ព្រោះមានសភាវៈមិនទៀងពាត់ប៉ិតថេរថិរកាល, ហេតុនោះបានជាព្រះអគ្គសំដែងថា "ត្រូវតែលះបង់នូវនិច្ចសញ្ញា (១) សុខសញ្ញា (២) អត្តសញ្ញា (៣) ចេញ, ហើយគប្បីចំរើននូវអនិច្ចសញ្ញា ទុក្ខសញ្ញា អនត្តសញ្ញា" ដោយសេចក្តីសំគាល់ថា "កាយជារបស់មិនទៀង ប្រកបដោយទុក្ខ (៤) មិនមែនជារបស់យើងទេតែងឈឺចាប់

---

១ - ២ - ៣ - សេចក្តីសំគាល់ថាទៀង, ថាសុខ, ថាខ្លួន ។ ៤ បានដល់ទុក្ខទាំង ១២ កងមានជាតិទុក្ខជាដើម មានយម្បិញ្ចំ ៨ លោតិ តម្បិទុក្ខ ជាអរិសាន ។

ខ្ញុះតែមនុះឯង មានសេចក្តីស្លាប់ជាទីបំផុត សមទ្ធិឯសុភាសិតថា

ឯវំ ជរា ច មច្ចុ ច អធិវត្តន្តិ បាណិនោ
ខត្តិយេ ព្រាហ្មណេ វេស្សេ សុទ្ទេ ចណ្ឌាលបុក្កុសេ

ប្រែថា សេចក្តីចាស់ជរា (ឈឺចាប់) នឹងសេចក្តីស្លាប់ តែងគ្របសង្កត់សង្កិន (ញាំញី) ខ្លួនពួកសត្វទាំងឡាយ (ក្នុងលោក) (ឥតមានរើសមុខឬយល់មុខ) ថា ក្សត្រ, ព្រាហ្មណ៍, អ្នកជំនួញ, ពួកគូលី, ចណ្ឌាល, អ្នកចាក់សំពាមយ៉ាងនេះ (ទេ) ។

ម្យ៉ាងទៀត បើត្រូវនឹងស្លាប់ហើយ ទោះបីរត់ពួនសម្ងំនៅក្នុងកន្លែងណាក៏ដោយ ក៏នៅតែមិនរួចអំពីសេចក្តីស្លាប់បានឡើយ ។ ដូចពុទ្ធភាសិតដែលព្រះអង្គទ្រង់សំដែងប្រារព្ធនឹងសក្កៈឈ្មោះសុប្បពុទ្ធថា

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្ពតានំ វិវរំ បវិស្ស
ន វិជ្ជតេ សោ ជគតិប្បទេសោ
យត្ថដ្ឋិតំ នប្បសហេយ្យ មច្ចុ

ប្រែថា (បើ) បុគ្គលចូលទៅក្នុងពពកក្តី, ចូលទៅកណ្តាលមហាសមុទ្រមានជម្រៅ ៥៤ ០០០ យោជន៍ក្តី, ចូលទៅកាន់ចន្លោះប្រហោងនៃភ្នំក្តី ក៏មិនគប្បីរួចអំពីសេចក្តីស្លាប់បានឡើយ ព្រោះអកប្រទេសលើផែនដីដែលសេចក្តីស្លាប់មិនគប្បីបៀតបៀន ខ្លួនបុគ្គលបាននោះគ្មានទេ ។

អ្វីហៅយប់ផ្សែងក្នុងពេលយប់?

បុគ្គលធ្វើការងារក្នុងវេលាថ្ងៃ ហើយត្រឹះក្នុងវេលាយប់ ឲ្យនេះឈ្មោះថា បង្គុយផ្សែងក្នុងភត្តិ ។ ពាក្យថា ហុយផ្សែងក្នុងភត្តិនេះ ជាឈ្មោះរបស់បំណាង ដែលឲ្យនេះខុសជាមូលហេតុ ព្រោះថាការងារដែលត្រូវធ្វើដោយកាយក្តី វាចាក្តី គាស្រ័យនឹងសេចក្តីត្រិះរិះគិតគូរខុសជាមុន ត្រូវនឹងបុព្វណាសិកថា "មុខនឹងគួរត្រូវគិត មុននឹងប្រព្រឹត្តត្រូវពិចារណា" ។ កិច្ចការទាំងពួង ដែលធ្វើទៅលឿនមិនប៉ះទង្គិចនឹងបស័ក្ខណាមួយ ក៏ព្រោះតែសេចក្តីត្រិះរិះជាដើម ។ គំនិតចិត្តហ្នឹងឯងដែលជាម្ចាស់កាយវាចា តែងចាត់ចែងការគ្រប់ជំពូក ។

អ្វីឆេះក្នុងពេលថ្ងៃ?

បុគ្គលត្រិះរិះក្នុងពេលយប់ ហើយប្រកបការងារក្នុងវេលាថ្ងៃ ឲ្យនេះឈ្មោះថាឆេះក្នុងពេលថ្ងៃ ។

បុគ្គលត្រិះរិះដើម្បីសការងារដែលត្រឹមត្រូវតាមផ្លូវពុទ្ធសាសនា រមែងទទួលផលប្រយោជន៍ ៣ យ៉ាង គឺ:

๑ - ប្រយោជន៍ក្នុងបច្ចុប្បន្ន

๒ - ប្រយោជន៍ក្នុងបរលោក

๓ - ប្រយោជន៍ដ៏ឧត្តមគឺព្រះនិព្វាន ។

ប្រយោជន៍ក្នុងបច្ចុប្បន្ន មាន ៤ យ៉ាង

๑ — ឧដ្ឋានសម្បទា បរិបូណ៌ដោយការលេះបង់នូវសេចក្តីខ្ជិលច្រអូស ហើយត្រេកអែនស្រឡាញ់ចាប់ការងារឥតធុញច្រាន់ គឺការស្វែងរកនូវគោតសម្ព័ទ ដែលមិនប្រែបដោយទោស[1] មានកសិកម្ម ទីឯពាណិជ្ជកម្ម ទៅតាមយថាពលំបេះខ្លួន ដើម្បីឲ្យកើតសេចក្តីសុខ-ចំរើន មិនកំណត់កាលវេលាឬជាក់ធុរៈក្នុងកិច្ចការងារដែលត្រូវធ្វើ ។

—๒ អារក្ខសម្បទា បរិបូណ៌ដោយការរក្សាថែទាំរឿបចំទុកជាក់ឲ្យសម្បត្តិ ដែលខ្លួនរកបានមកហើយកុំឲ្យវិនាសខ្ចាត់ខ្ចាយអន្តរាយព្រោះល្បែងផ្សេងៗ មានល្បែងស្រីស្រាកញ្ឆាអារឿន ទីឯល្បែងក្តាល់ជាដើម ល្បែងទាំងនេះជាផ្លូវនៃសេចក្តីខ្ជាត់ក្លាត់វិនាសបង់ ប្រាសចាកសុខភាព អនាម័យ ។

๓ — កល្យាណមិត្តតា ភាវៈជាអ្នកគប់រកកល្យាណមិត្តដែលមានកល្យាណកម្មប្រចាំក្នុងឱទ្ធសន្តាន ទើបបានសេចក្តីចំរើនដោយលាភនិងយសសក្តិមានឋានៈដ៏ខ្ពង់ខ្ពស់ ព្រោះភាវៈសេពគប់នឹងកល្យាណ-មិត្រនេះ អាចធ្វើមនុស្សឲ្យក្រាយពីហិនភាពទៅកាន់ឧត្តមភាព, ឲ្យឡើងពីមូឡ្ហភាពទៅកាន់បណ្ឌិតភាព, ឲ្យឡើងពីទុគ្គតៈភាពទៅកាន់សុខភាព,

---

๑ រឿងចាកបញ្ចវិកៈ ។

ឲ្យឡើងពីអន្លបុថុជ្ជនទៅកាន់កល្យាណបុថុជ្ជន, ឲ្យឡើងពីកល្យាណ-បុថុជ្ជនទៅកាន់អរិយជន, មានគុណសម្បត្តិសមគួរតាមដំរិថ្លាថ្លាពរបរិបូណ៌ដោយមហិទ្ធិរិទ្ធិជាតិយ្យោតាតទៅ ។

៤— សមជីវិតា ប្រកបការអាជីពចិញ្ចឹមជីវិតល្មមសមគួរដល់កម្លាំងទ្រព្យធនធានដែលខ្លួនមាន គឺថាកុំគប្បីចាយវាយគោគសម្បត្តិឲ្យហួសហេតុខុសទំនង ។

អ្នកមានក្លាយទៅជាអ្នកក្រដោយហេតុ ៤ យ៉ាង (១)

១ — មិនទំប្រឹងរកវបស់ដែលបាត់

២ — មិនជួសជុលវបស់ចាស់

៣ ស៊ីផឹកចាយវាយទ្រព្យសម្បត្តិឥតកំណត់

៤ — លើកមនុស្សទ្រុស្តសីលឲ្យជាធំ ។

ឯប្រយោជន៍ក្នុងបច្ចុប្បន្នតាំង ៤ យ៉ាងដែលបុរសស្ត្រីកេបានមកប្រកបដោយធម៌ មិនឈ្មោះថា "តណ្ហា" ទេ, បានជាថាដូច្នោះព្រោះពាក្យថា "តណ្ហា" នេះសំដៅយកមេរ្ចៅចិត្តដែលអោបស្ងួតន្ទរទ្រព្យសម្បត្តិមិនចែកចាយចំណាយធ្វើបុណ្យកុសល មានមិនដឹកអណ្តាំ, មិនលើកស្រះ, មិនដាំដើមឈើ, មិនសង់ស្ពាន, មិនសាងផ្លូវថ្នល់ជាដើម ។ សេចក្តីស្ងួតស្វាញប៉ែបនេះ ទើបឈ្មោះថា "តណ្ហា" ។

---

១ មានសៅក្នុងគម្ពីរអង្គុត្តរនិកាយ ចតុក្កនិបាត ។

បុរសស្ត្រីណាដែលមានសេចក្តីកំណាញ់ការញ់សម្បត្តិទុក ដូចរៀបរាប់មកនេះ ឈ្មោះថាជាបុគ្គលមានសេចក្តីសុខតិចដោយហេតុតែមិនបែងចែកសេចក្តីសុខឲ្យដល់អ្នកដទៃព្រោះតែសេចក្តីកំណាញ់ ដូច្នេះ សាធុជនគួរប្រតិបត្តិធ្វើតាមពុទ្ធភាសិតក្នុងគម្ពីរធម្មបទ ខុទ្ទកនិកាយ ត្រង់បកិណ្ណកវគ្គ ថា:

មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ
បជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ

ប្រែថា បើបុគ្គលឃើញនូវសេចក្តីសុខដ៏ធំទូលាយហើយ គប្បីលះបង់នូវសេចក្តីសុខមានប្រមាណតិចចេញ អ្នកប្រាជ្ញកាលឃើញនូវសេចក្តីសុខដ៏ធំទូលាយ តែងលះបង់សេចក្តីសុខតូចតាចចោល ។

ការដែលលះបង់សេចក្តីសុខដែលមានប្រមាណតិច ដើម្បីប្តូរយកវិបុលសុខ គួរតែអនុវត្តន៍ធ្វើនូវប្រយោជន៍ក្នុងលោកខាងមុខតទៅទៀត ។

(មានត)

រឿងត្រីងប្លែនិងខាន

ឃុនបណ្ណាសុរិយ្ស ប៊ូ-ប៊ូ រៀបរៀង

តាមសេចក្តីដំណាលរបស់លោកហាន់-គីមសេង

១.— រឿងអ្នកជួយសង្គ្រោះគេ

មានតាចាស់ម្នាក់ជាជាតិយីពុន សង់ផ្ទះនៅក្បែរមាត់សមុទ្រ គាត់ជាអ្នកដឹងពេលទឹកសមុទ្រជោរ ។ ថ្ងៃមួយជិតទំនងដល់ពេលទឹកសមុទ្រជោរ មានមនុស្សជាច្រើនរយនាក់នាំគ្នាចុះទៅរកចាប់ក្តាមនៅមាត់សមុទ្រ ចានទៅជួបនឹងតាចាស់នោះ។ ឃាត់ថា "អ្នកពាល់គ្នាកុំចុះទៅ ដ្បិតទឹកសមុទ្រជិតជោរដន់ហើយ បើចេះតែចចេសទៅ មុខជាលង់ទឹកស្លាប់ទាំងអស់គ្នាមិនខាន" ។ អ្នកចាប់ក្តាមទាំងនោះមិនព្រមស្តាប់ ចេះតែនាំគ្នាចុះទៅចាប់ក្តាម ។ ពេលនោះតាចាស់យកភ្លើងដុតផ្ទះរបស់ខ្លួនឲ្យឆេះហុយផ្សែងខ្ចរលោមហើយស្រែកហៅឲ្យគេជួយលត់ភ្លើង ។ អ្នកចាប់ក្តាមទាំងអស់ចានឮដូច្នោះ ក៏ក្រឡេកមើលមកក្រោយ ឃើញភ្លើងឆេះផ្ទះតាចាស់ ក៏នាំគ្នារត់មកជួយលត់ភ្លើង ។ ក្នុងវេលាដែលគេកំពុងតែរត់មកនោះ ស្រាប់តែទឹកសមុទ្រជោរមកដល់ប្រផុត ។ អ្នកទាំងនោះ ។ រត់ស្ទើរតែមិនទាន់ ។ អ្នកចាប់ក្តាមកាលជួយលត់ភ្លើងរលត់ហើយ ក៏សួរតាចាស់ថា "នែតា! ហេតុអ្វីបានជាភ្លើងឆេះផ្ទះតា?" ។ តាចាស់ច្រាបថា "អត ហេតុអ្វីទេ ខ្ញុំដុតផ្ទះរបស់ខ្ញុំដើម្បីឲ្យពួកអ្នករត់ត្រឡប់មកវិញ កុំឲ្យលង់

ទឹកដន់ខ្លាំង" ។ អ្នកចាប់ក្តាមចាំងអស់បានដឹងថាខ្លួនរួចរស់ជីវិត ដោយសារតាចាស់កំសត់អណាស់ ទើករលឹកគុណតាចាស់មិនភ្លេច ដោយឃើញថា តានេះជាមនុស្សមានចិត្តសប្បុរសល្អ ព្រោះតែគាត់ចង់ជួយសង្គ្រោះពួកយើង ទើបសុខចិត្តដុតផ្ទះរបស់ខ្លួនចោលមិនស្តាយ ។

រឿងនេះ បានតតិថាអ្នកដែលជួយសង្គ្រោះដោះទុក្ខធុរៈគេ ត្រូវតែជាអ្នកព្រមគិតឲ្យយ៉ាងល្អិតល្អៀលជ្រៅ ហើយចុំនប្រសប់ខាងការជួយគេឲ្យបានរួចពីទុក្ខភ័យផង កុំឲ្យខ្លួនមានទុក្ខទោសផង ។

២.— រឿងអ្នកសុខចិត្តលះបង់ប្រយោជន៍ពិប ដ្បិរយកប្រយោជន៍ប្រើន

មានស្ត្រីជាតំយីពុនម្នាក់ ជាអ្នកមានធនធានសុភសុខ ។ នាងនេះមានចានយ៉ាងល្អ ១២ ជាទីស្រឡាញ់បំផុតចិត្ត ។ ថ្ងៃមួយមានខ្ញុំស្រីម្នាក់ធ្វើឲ្យបែកចាននោះមួយ ។ នាងម្ចាស់បានខឹងណាស់ អត់មិនបានកំយកកាំភ្លើងបាញ់ខ្ញុំស្រីនោះស្លាប់ភ្លាមៗ ។ ពេលនោះ តាហានម្នាក់បានដឹងរឿងនេះ ក៏ស៊ូប្រថុយកាត់ចិត្តចូលទៅនិយាយទប់ស្ត្រីម្ចាស់បាននោះថា "សូមជំពុបអ្នកស្រី ! ខ្ញុំចេះផ្សាចានដែលបែកនោះឲ្យជាប់គ្នាស្ទុះដូចដើមវិញបាន ប៉ុន្តែឲ្យខ្ញុំសុំមើលចានដែលនៅសល់ចាំង ១១ នោះសិនដើម្បីនឹងផ្សាចានបែកនោះឲ្យត្រូវជុនគ្នាកុំឲ្យខុសពីគ្នា" ។ ស្ត្រីម្ចាស់បានឮដូច្នោះត្រេកអរណាស់ ចូលទៅលើកយកចានចាំង ១១ មកហុចឲ្យ

ទាហាន។ ខ្ចួលយកមកហើយក៏លើកចានទាំង ១១ នោះចោលទៅ
លើក្តារ នៅចំពោះមុខនាងនោះ ។ ឯចានក៏បែកខ្ចេចទាំងអស់គ្នាសល់
១ឡើយ ចោកវួចច្រាបថា "សូមអ្នកស្រីយកកាំភ្លើងមកបាញ់សម្លាប់ខ្ញុំ
ឥឡូវនេះចុះ ព្រោះដំរៀបចាន ១ នេះអ្នកស្រីសម្លាប់ដីវិតមនុស្សម្នាក់ដែរ
ឥឡូវនៅសល់ចាន ១១ ទៀតនេះ មុខជាអ្នកស្រីសម្លាប់ដីវិតមនុស្សអស់
១១ អ្នកទៀត ដោយហេតុនេះបានជាខ្ញុំដាច់ចិត្តយកដីវិតខ្លួនខ្ញុំមួយមកប្តូរ
ស្លាប់ជំនួសដីវិតមនុស្សទាំង ១១ នាក់ ។

ស្ត្រីម្ចាស់ចានឃើញចានបែកខ្ចេចទាំងអស់ ហើយឮសំដីទាហាន
និយាយច្រាបដូច្នោះ ក៏ភ្ញាក់ខ្លួនត្រឹត ត្រឹត្រូចស្តុតចិត្តជាយ៉ាងខ្លាំង
ទាល់តែដួលសន្លប់នៅកន្លែងនោះ លុះនាងមានស្មារតីឡើងវិញហើយ
ក៏គ្មានចិត្តខឹងទឹងទាហានសោះ លែងនឹកស្តាយចានទាំងរបស់ទ្រព្យទាំង
ពួងខុសគំនង់ដូចមុនទៀត មិនចាប់ទោសទាហាននោះឡើយ ។

រឿងនេះ ប្រាជ្ញគតិថា អ្នកមានគំនិតច្បាស់ប្រាជ្ញបានពិចារណាឃើញ
ប្រយោជន៍យ៉ាងធំទូលាយទៅខាងមុខហើយ សុខចិត្តលះបង់ប្រយោជន៍
តិចផ្ទាល់ខ្លួនចេញ សូម្បីដីវិតខ្លួនស្លាប់ក៏មិនស្តាយ គិតតែចំធ្វើឲ្យបាន
កើតផលប្រយោជន៍យ៉ាងធំទូលាយដល់សាធារណៈដល់មនុស្សទូទៅ ។

៣.— រឿងអ្នកបិត្តូធ្ងន់

នៅប្រទេសអល្លឺម៉ង់មានមេទ័ពជាតិអល្លឺម៉ង់ម្នាក់ឈ្មោះប៊ីស្មាក ជា
មនុស្សក្លាចរោះយៅណាស់ ។ ថ្ងៃមួយ លោកប៊ីស្មាកមានជម្លឺឈឺ

ប្រើបំរើឲ្យទៅហៅគ្រូពេទ្យម្នាក់មក ព្យាបាលពេគលោក ។ គ្រូពេទ្យមក ដល់សួរលោកមេទ័ពថា "លោកឈឺត្រង់ណាខ្លះ?" ។ លោកបិស្នាកមិន ឆ្លើយ ប្រាប់ថាឈឺអ្វីសោះ សូម្បីគ្រូពេទ្យសួរប៉ុន្មានដង លោកក៏ចេះតែ សំងំស្ងៀមឈឹង ។ ទើបគ្រូពេទ្យជំពប់លោកមេទ័ពថា "ជម្ងឺរបស់លោក នេះ មានតែគ្រូពេទ្យសត្វទើបចេះមើល ឯគ្រូពេទ្យមនុស្សដូចជាយើងខ្ញុំនេះ មើលជម្ងឺលោកមិនបានទេ" ថាយ៉ាងនេះហើយក៏លាលោកមេទ័ពចេញ ទៅដល់របងមុខផ្ទះ ។ លោកមេទ័ពឲ្យបំរើទៅតាមហៅគ្រូពេទ្យនោះមក វិញហើយសួរថា "អម្បាញ់មិញអ្នកនិយាយដូចម្តេច?" ។ គ្រូពេទ្យក៏ ជំពប់តាមសំដីដើម ។ លោកមេទ័ពឮដូច្នោះហើយ ក៏ពេញចិត្តនឹងចំឡើយ របស់គ្រូពេទ្យនោះយ៉ាងក្រៃលែង ឥតប្រកាន់ទោសទិដ្ឋនឹងគ្រូពេទ្យ នោះវិញសោះ ។

រឿងនេះ បានគតិថា អ្នកដែលមានបុណ្យស័ក្តិជាធំ ជាអ្នកត្រួត គ្រាលើគេ ត្រូវតែមានចិត្តនឹងធឹងទូន្មង់ មិនត្រូវធ្លាប់ប្រកាន់ទិដ្ឋនឹងអ្នក តូចតាចជាដើមឡើយដោយឥតពិចារណាទេ ។

៤.— រឿងអ្នកភិតភ័យដោយគំនិតស្មានខុស

មានអ្នកដំណើរពីរនាក់ ជាជាតិអ្វី នៅស្រុកទេសណា មិនដឹង ច្បាស់ ជាធ្វើដំណើរទៅប្រទេសដទៃ លុះដើរទៅដល់ភូមិមួយ ក៏ ចូលទៅសូមផ្ទះបុរសប្តីប្រពន្ធដេក ១ យប់ ទំរាំតែភ្លឺនឹងចេញដំណើរទៅ

មុខទៀត ។ អ្នកម្ចាស់ផ្ទះក៏ទទួលដោយពាក្យគាត់ហៅអ្នកដំណើរទាំងពីរ
នាក់នោះឲ្យចូលទៅក្នុងផ្ទះហើយឲ្យអង្គុយនៅក្នុងបន្ទប់មួយ ។ អ្នកដំណើរ
បានគយគន់មើលឃើញមានគ្រឿងបាត, ប៉ូវថ្កា, ដាវ, ធ្នូ, ស្នា, និង
គ្រឿងវែងខ្លីដែលគេព្យួរដាក់រៀបគ្នានៅជញ្ជាំងក្នុងបន្ទប់នោះ ។ អ្នកដំណើរ
ទាំងពីរនាក់នឹកព្រួយចារម្ភថា ផ្ទះនេះប្រហែលជាគន្លងស្នាប់របស់យក្ស
ខេដឹង? គិតព្រួយចិត្តគិតភ័យណាស់ ទាល់តែសាបមាត់បរិភោគថ្វាយ
មិនឆ្ងាញ់ ។ លុះរួចថ្វាយហើយ ម្ចាស់ផ្ទះសួរអ្នកដំណើរថា ពេល
ព្រឹកស្អែកនេះ អ្នកនឹងអញ្ជើញទៅស្រុកណាទៀត?

អ្នកដំណើរតបថា "ខ្ញុំនឹងទៅភូមិគេខាងមុខឯណោះ" ។

ម្ចាស់ផ្ទះថា "បើដូច្នោះ សូមអ្នកកុំប្រញាប់ប្រញាល់ទៅពីព្រលឹម
ពេក សូមបង្អង់ចាំខ្ញុំធ្វើអាហារឲ្យដាក់ទៅតាមផ្លូវដ្បិតភូមិនោះនៅឆ្ងាយ
ក្រែងអត់ថ្វាយកណ្តាលផ្លូវ" ធ្វើចាប់រួចហើយក៏ឲ្យអ្នកដំណើរទាំងពីរនាក់
ឡើងទៅដេកលើស្អាតតូចមួយក្នុងផ្ទះ ។

ឯអ្នកដំណើរម្នាក់នៅក្នុងសេចក្តី ឥតគិតខ្វាចអ្វីសោះ ចេះតែដេក
លក់ស្រួមកកខុរគាល់ភ្លឺទៅ ។ ចំណែកអ្នកដំណើរម្នាក់ទៀតជាមនុស្ស
ចាស់សេចក្តី មានគំនិតល្អិតល្អ ចេះតែគិតរំពឹងដល់គ្រោះថ្នាក់ក្រែងកើត
មានមកដល់ខ្លួន ពេលដេកគាត់មិនហ៊ានខ្ទុកហឺបស្បែកឲ្យឆ្ងាយពីខ្លួន
គាត់ទេ គាត់យកហឺបនោះក្រើយដំនួសខ្នើយ ហើយគាត់ព្រួយចារម្ភ

ណាស់ ដេកមិនលក់តាំងពីព្រលប់រហូតដល់ពេលមានរស្មីថ្ងៃតូចក្តី ស្រាប់តែគាត់ឮសូរស្រែបៗ នៅខាងក្រៅមុំណេកខ្លួន គាត់គិតភ័យខ្លាំងណាស់ ចំសម្លឹងបមើលទៅតាមបំពង់ក្តីដើងគ្រាន ឃើញប្រពន្ធកាន់កាំបិតធំ ១ ប្តីកាន់ប៊ូវថៅ ១ ហើយឮសូរប្តីខ្សឹបខ្សៀវៗ សួរប្រពន្ធថា "យើងសម្លាប់ក្មាំងពីរតន្សារនេះទៅឬអី ឬក៏សម្លាប់តែ ១ ទុក ១ សិន?" ។ ឯអ្នកដំណើរគ្រាន់តែបានឮពាក្យប៉ុណ្ណោះហើយ ក៏ស្ទុតចិត្តជាតិញាណត្រជាក់ខ្លួនដូចសម្រែងគិតថា "ខ្ញុ! ជីវិតអញនៅកន្លងកណ្តាប់ដៃអ្នកទាំងពីរនេះហើយ មិនដឹងគិតធ្វើម្តេចនឹងឲ្យបានរួចជីវិតទេ អញនឹងជាស់សំឡាញ់ម្នាក់នេះឲ្យក្បាក់ខ្សែង ទាបក្រែងវាមាត់ឡូឡាស្រែកទ្រហោយំឲ្យផ្តេលគេឯង បើអញនឹងលោតចុះទៅតាមបង្អួច។ នេះខ្ញុំសង្ឃឹមពីដណាស់ មួយទៀត នៅឯដីមានឆ្កែធំៗ សុទ្ធតែកាចសាហាវនៅជុំវិញផ្ទះផង អញនឹងរត់ទៅណាក៏មិនរួចពីមាត់ឆ្កែទាំងនោះដែរ ណ្លើយចុះ បើដូច្នោះគួរតែអញសម្ងំឲ្យស្ងៀមចាំសង្កេតមើលហេតុគេសិន" ។ អ្នកដំណើរកំពុងតែជញ្ជឹងគិតយ៉ាងនេះ ស្រាប់តែឮសូរជើងឡើងជណ្តើរថ្មមៗ ត្រឹប។ មក ពេលនោះព្រលឹងរបស់អ្នកដំណើរត្រង់ចេញបាត់ពីខ្លួនអស់រលីង ។ បន្តិចមកទៀតគាត់ឮសូរសន្ធឹកគ្នារគឹតៗ ដែលគេចានសន្ធឹម។ គាត់តែតែតក់ស្លុតខ្លាំងណាស់ គិតរកផ្លូវដោះកុនខ្លួនមិនឃើញសោះ ក៏នឹកថា "ខ្ញុ! ជីវិតអញមុខជាស្លាប់ពេលនេះពិតប្រាកដហើយ" ។ គាត់គិតស្មានយ៉ាងនេះរួច

ខំសម្លឹងដេកដើរខ្លួនស្លុកលែងហ៊ានគំរើត គ្រាន់តែមើលក្អែកព្រឹមៗ ចាំលបមើល ស្រាប់តែគាត់ឃើញបុរសម្ចាស់ផ្ទះលូកដៃទៅចាប់មាន់ក្រៀមមួយគូដែលវាដេកលើធ្នើរក្បែរស្លាកនោះបានហើយយកចុះចាត់ទៅ ។ អ្នកដំណើរឃើញច្បាស់ដូច្នោះហើយ ក៏គ្រែតអរព្រួចនឹកអស់សំណើចតែក្នុងចិត្តម្នាក់ឯងថា "តុ! ពុទ្ធោ! អញគិតភ័យដោយគិតស្មានខុសស្រឡះទេតើ" ។

លុះដល់ព្រឹកឡើង អ្នកដំណើរទាំងពីរនាក់ចូលទៅលាម្ចាស់ផ្ទះនឹងចេញដើរទៅទៀត ។ អ្នកម្ចាស់ផ្ទះយកមាន់ឆ្អិនស្រេចទាំងពីរនោះមកប្រគល់ឲ្យអ្នកដំណើរហើយច្បាប់ថា "មាន់ ១ នេះបួរអ្នកថវិកោតផង្ហួរនេះទៅ ឯមាន់ ១ ទៀតបួរអ្នកជាក់យកទៅខុកបរិកោតតាមផ្លូវ ក្រែងអ្នកទៅយឺតយូរ ក្រទៅដល់ស្រុកគេឯនាយ" ។ អ្នកដំណើរក៏ពាយសប្បាយចិត្តណាស់ ទទួលយកមាន់ទាំង ២ រួចសំពះលាម្ចាស់ផ្ទះចេញដំណើរទៅទៀត ។

រឿងនេះបានគតិថា បើកាលណាយើងមិនទាន់បានដឹងហេតុការណ៍ច្បាស់លាស់ទេ យើងមិនត្រូវគិតភ័យតក់ស្លុតដោយគំនិតគិតស្មានខុសជាមុនឡើយ យើងត្រូវតែចាំសង្កេតមើលហេតុកេរនោះ។ ឲ្យដឹងជាក់លាក់សិន បើយើងចេះតែភ័យខ្លាចឥតគំនិតទៅ នឹងនាំឲ្យមានទុក្ខទោសដល់ខ្លួនជាមិនខាន ។

ព្រះមហាឧត្តមវិជ្ជា ជិលញ្ញាណោ ប៊ុង-ប៉ម
អាចារ្យសាលាឡាលីវង់ វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង
ឃុនបណ្ឌាគុរុក្ឍ ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តមក)

ន) បណ្តុះនិស្ស័យដើម្បីឲ្យនឯងដោយការសន្ទនាប្រស័យ គ្នាក្នុងការសន្ទនាគ្នា ចូរមានចិត្តគំនិតដែលបរិសុទ្ធច្បាស់លាស់ទឹងធឹង នឹងស្មោះត្រង់ ។ កាលបើគិតនឹងនិយាយពាក្យយ៉ាងណាដែលគួរនិយាយ ចូរនិយាយពាក្យយ៉ាងនោះនិយាយតាមសេចក្តីពិត, និយាយដោយអាងហេតុផលជានិច្ច, ដៀសវាងការក្រោធទឹងត្រង់ទោរទន់រកគ្នា, ចរចាដោយរីករាយបរិសុទ្ធជាមួយនឹងគូសន្ទនា, ស្តាប់អ្នកដទៃនិយាយដោយយកចិត្តទុកដាក់, មិននិយាយកាត់រឿងគេក្នុងកាលដែលគេកំពុងនិយាយ, ត្រូវស្តាប់ឲ្យចូលចិត្តច្បាស់លាស់ក្នុងពាក្យសំដីរបស់អ្នកដទៃ, មិនយើញតែសេចក្តីអាក្រក់របស់អ្នកដទៃ, មិនសរសើរតែតែក្នុងទីចំពោះមុខ, មិនទន្ទានតែតែក្នុងទីកំចាំងមុខ ទឹងចូរប្រើសំដីសុភាព កុំប្រើពាក្យគ្រោតគ្រាតបែបមនុស្សថោកទាប. កុំនិយាយត្រឡប់ត្រឡិនរកតែគេដើម្បីមិនបាន, កុំជាមនុស្សមាត់ស្រែចដើរចាក់រុកញុះញង់គេឬយករឿងពីឯណោះទៅរុកឯណោះ យករឿងពីឯណោះមកឲ្យឯណោះ, កុំជាមនុស្សមាត់ដាច

លាក់រឿងកំចាំងខុកមិនដឹង ទឹងកុំជាមនុស្សនិយាយឡេះឡោះត្រឡប់ត្រឡិនខាល់តែគ្រាន់ត្រចៀកស្តាប់មិនបាន ទាំងមិនមានសារប្រយោជន៍អ្វីមួយនោះឡើយ ។

ច) បណ្តុះនិស្ស័យដឿនឯង ដោយការដឿកម្មជាច្បាប់ធម្មតាដែលខឿងខាត់, ជាគ្រាដូ នៃសម្ពន្ធកម្មរវាងពួកសត្វក្នុងកំណើតផ្សេងៗ, ជារបស់ខឿងខាត់ជានិច្ច គឺអ្នកណាមួយធ្លាប់អំពើណាហើយមិនដែលប្រែប្រួលទៅចាកផ្លូវនៃអំពើនោះឡើយ ។ ប៉ោងដ៏កុំឲ្យមានគំនិតអាក្រក់ទឹងគំនិតថោកទាប ត្រូវកុំភ្លេចច្បាប់នេះឲ្យសោះ សូម្បីលោក - អ្នកសង្ស័យថា ដួងផ្កាយអាចក្លាយទៅជាក្ងើងបាន ព្រះអាទិត្យអាចប្រែប្រួលទៅជាអ្វីបាន, សេចក្តីពិតអាចក្លាយទៅជាសេចក្តីមិនពិតវិញបានក៏ដោយ ក៏កុំសង្ស័យក្នុងកម្មរបស់ខ្លួនឯង ដែលខ្លួនបានធ្វើមកហើយថាទឹងអាចក្លាយទៅជាយ៉ាងដទៃនោះឡើយ ចូរដឿឲ្យជាក់ថាយើងមានកម្មជារបស់ខ្លួន, មានកម្មជារបស់អំណោយផល, មានកម្មជាកំណើត, មានកម្មជារបស់ផាប់ទៅតាម, មានកម្មជាទីពឹងពាក់អាស្រ័យ, បើធ្វើកម្មល្អ ត្រូវបានទទួលផលល្អ, បើធ្វើកម្មអាក្រក់ទទួលអាក្រក់ត្រូវតាមសងមកវិញ ។ ព្រោះតួនសារតឹងលរបស់កម្មគ្មានឡើយ ទាំងសាបសូន្យទៅណាឡើយ ត្រូវអណ្តែតឡើងត្រលប់ទៅរកដែលហើរទៅលើមេឃ ត្រូវចុះតាមមកត្រូវតួកសត្វដែលនៅលើផែនដី, ត្រូវតស៊ូលុះទៅ

ត្រូវជំនួសដែលនៅក្នុងដី· ទើបត្រូវផ្លែកទឹកចុះទៅត្រូវហូរគ្រឹះ ក្នុងផ្លែមហាសមុទ្រ (នេះជាពាក្យប្រៀបធៀបឲ្យឃើញកម្លាំងរបស់ផលនៃកម្ម) ។

ដោយសារតែមានទិស្សយៈដ្បិតខ្លួនឯងនេះជាហេតុហើយ បានជាលោក - អ្នកអាចយកឈ្នះការងារបានគ្រប់យ៉ាង ទោះបីការងារនោះលំបាកយ៉ាងណាក៏ដោយ គាំងធ្វើឲ្យអ្នកនៅក្រៅមគ្គាប់បញ្ជាដ្បិតខ្ជិលចិត្តច្រកដល់ឆ្ងាយផង ឬសូម្បីលោក អ្នកនៅក្រៅមគ្គាប់បញ្ជារបស់អ្នកជំនៃ ក៏អាចនៅបានយ៉ាងស្រួល ព្រោះលោកជាប្រធានមិនចាប់លំបាកចិត្តអ្វីឡើយ មិនចាប់អង្សរកណោនាំញយៗពេក គាំងមិនចាប់ចាំឈរមើលឲ្យឃើញថា លោក - អ្នកធ្វើការសម្រេច ឬមិនសម្រេចឡើយ ។ សូម្បីអ្នកជំនៃ ក៏គង់ដ្បិតច្រកដ ចំពោះខ្លួនលោក - អ្នកបានថា ទោះបីលោក - អ្នកមិនមានទ្រព្យសម្បត្តិ មិនមានអំណាចបុណ្យសក្តិ អាចនឹងលើកដំកើងឋានៈរបស់គេឲ្យអណ្តែតបាន ក៏គង់អាចធ្វើការងារឲ្យដល់មិត្តភក្តិរួមជាតិបានល្អ ជាងមនុស្សដែលកើតមកប្រកបព្រមដោយទ្រព្យសម្បត្តិ តែនឹងអំណាចជាតិតែកូល តែខ្វះការដ្បិតខ្លួនឯងទោះទៅទៀត ។

៤— បើពិចារណាខ្លួនឯង គោលសំខាន់ពិតច្រកជំនៃការពាក់ព័ន្ធខ្លួនរបស់យើង នៅត្រង់ការបើពិចារណាខ្លួនឯង ត្រូវតាមទ

សេចក្តីដែលដកចេញមកអំពីពុទ្ធភាសិតមួយបទថា "លោក-អ្នក ប្បរ
ពិចារណាខ្លួនដោយខ្លួនឯង" ។ គោលនេះចាត់ថាជាមូលហេតុ
នៃសេចក្តីសម្រេចកិច្ចគ្រប់ឥរិយាយ ទើបជាគ្រឿងនាំជីវិតរបស់យើងឲ្យ
ឈានទៅមុខយ៉ាងរីករាយផុតភ័យ ឃ្លានសេចក្តីក្សេមក្សាន្តសុខសប្បាយ
រហូតដល់ត្រើយ ។ បុរាណគោលថា "ពួកមាត់ធ្មាជាមគុទ្ទេសក៍
របស់ធ្មា, ការពិចារណាខ្លួនឯង ក៏ជាផ្លូវដ៏ណើរដ៏បំពើនរបស់ខ្លួន
ដែរ" ។ ពិតមែនមនុស្សដែលពាក់អានខ្លួនឯង បើធ្វើការអ្វី ក៏ត្រូវតាម
គោលដែលគួរធ្វើសមគួរដល់អំពើរបស់មនុស្ស ទើបជានៈរបស់ខ្លួន មិន
ធ្វើការអ្វីដែលខុសចាកគោលដ៏គួរ ដែលជាអំពើថោកទាប ជាអំពើ
របស់មនុស្ស ទើបជានៈរបស់ខ្លួនឡើយ ធ្វើតែការងារដែលត្រូវតាម
គន្ធៈសីលធម៌ ឬត្រូវតាមគន្ធៈច្បាប់ ដែលបីកឲ្យធ្វើហើយមិនជាការ
ក្តៅក្រហាយដល់មនុស្សដទៃផង ព្រមទាំងជាអំពើត្រូវតាមគន្ធៈនិតិធម៌
របស់ប្រជាជនគ្រប់ៗគ្នា ហើយមុននឹងធ្វើ តែងមានការព្យាយាមត្រួត
ត្រាពិនិត្យខ្លួនឯងដោយប្រយ័ត្នប្រយែងជានិច្ច ។

ការរៀនឲ្យស្គាល់ខ្លួនឯង ជាលក្ខណៈនៃការបេះត្រួតត្រាពិនិត្យ
ខ្លួនឯង ។ យើងបញ្ជាក់ឡាំងសម្រាប់កាយ, យើងពិចារណាត្រួត
ត្រាខ្លួនឯងសម្រាប់ចិត្ត ដើម្បីឲ្យក្លែតអនាម័យល្អ ។ ការបញ្ជាក់ឡាំង
ជាអនាម័យរបស់កាយ ធ្វើឲ្យយើងមានកំឡាំងរឹងប៉ឹង ។ ការ

ពិចារណាត្រួតត្រាខ្លួនឯង ជាអនាម័យរបស់ចិត្ត ធ្វើឲ្យយើងមានជីវិតជាខ្ពឹមសារ ។ ប៉ុណ្ណោចនឹងសុភាសិតខ្មែរថា "អ្នកដែលស្គាល់ជម្រៅរបស់ទន្លេ គឺទន្លេ. អ្នកដែលស្គាល់ទំហំរបស់អាកាស គឺអាកាស, .ឯអ្នកដែលស្គាល់ល្អស្គាល់អាក្រក់ក្នុងខ្លួនបាន ក៏គឺខ្លួនរបស់យើងហ្នឹងឯង" ។ ដូច្នេះ មនុស្សដទៃ សូម្បីតាំងផែនដី បើខ្មែរជាយើងមិនដឹង ក៏មិនជាអ្វីដែរ តែត្រង់ការដឹងស្គាល់ខ្លួនឯងនេះ ចូរកុំភ្លេចឲ្យសោះ ។ ព្រោះការរៀនឲ្យស្គាល់ខ្លួនឯងនេះ លំបាកវែកលែងជាងការរៀនឲ្យស្គាល់មនុស្សដទៃទៀត តែសូម្បីយ៉ាងនោះក៏ជារឿងដែលត្រូវរៀនឲ្យស្គាល់ខ្លួនឯងមុនជាងស្គាល់អ្វីៗ តាំងអស់ ។ ព្រោះថា អ្នកដែលមានស្មារតីតែងមិនខ្វល់, អ្នកប្រយ័ត្នខ្លួនតែងមិនខ្ជូចចិត្ត, អ្នកប្រឹងប្រែងព្យាយាមតែងមិនអត់ឃ្លាន, អ្នកឃើញកំហុសរបស់ខ្លួន ដោយការពិចារណាត្រួតត្រាខ្លួនឯង រមែងខ្វាចរអាចំពោះការមិនពិចារណា, អ្នកដែលចេះឈឺចិត្តព្រោះឃើញកំហុសរបស់ខ្លួន តែងប្រែក្លាយទៅជាមនុស្សល្អវិញបាន ដោយការប្រយ័ត្នខឹងការដឹងខ្លួនតាន់នោះ, អ្នកព្យាយាមយកខ្លួនរបស់ខ្លួនមកពិចារណាត្រួតត្រាខ្លួនាខ្លួនឯងថា អំពើណាគួរធ្វើ សំដីណាគួរនិយាយឬគួរនិយាយក្នុងកាលណា គួរស្ងៀមមាត់ក្នុងកាលណា ទឹងអារម្មណ៍ណាគួរទឹកភ្នែកនោះ កាលបើចួបប្រទះនូវហេតុទាំងអម្បាលនេះហើយ អាចផុតចាកសេចក្តីតក់ឥតមានឆ្ងល់ពុំខ្លួ

ខាងពួងបាន ខាងមិនតើតជម្ងោះវិវាទបែកបាក់គ្នា ឬត្រូវទោសទុក្ខវិនាសិចលង់ទៅខាងមុខផង ។

អំពើ, សំដីទង់គំនិត ជារបស់សំខាន់ដោយមុខ ។ តែដែលជារបស់សំខាន់បំផុត គឺការពិចារណាត្រួតត្រាខ្លួនឯង ខាងក្នុងវេលាកំពុងគិត កំពុងធ្វើឬកំពុងនិយាយ, ចំណុចនៃការពិចារណាត្រួតត្រាខ្លួនឯងនៅត្រង់ការធ្វើ, ការនិយាយ នឹងការគិតរបស់ខ្លួន ខាងក្នុងផ្នែកការងារ ផ្នែកការសិក្សា ផ្នែកការប្រព្រឹត្តិ រហូតដល់ផ្នែកនៃការស្វាត់ដំនាញនឹងសមត្ថភាព ។ កាលយើងពិចារណាត្រួតត្រាខ្លួនឯង ដោយន័យនេះហើយ យើងអាចស្គាល់ខុសស្គាល់ត្រូវ អាចប្រព្រឹត្តខ្លួនឲ្យសមគួរល្មមមើល មិនខ្ពស់ពេកមិនទាបពេកបាន អាចសង្កេតឃើញបាន នូវសេចក្តីខ្វះខ្វាយ ឬសេចក្តីពេញលេញល្អ, រឿងពិរុទ្ធនឹងរឿងបរិសុទ្ធរបស់ខ្លួនកងផ្នែកនោះ ។ ព្រោះការដឹងខុសនឹងត្រូវនេះ ជាបច្ច័យឲ្យស្គាល់ខ្លួនឯងស្គាល់ហានៈរបស់ខ្លួន នឹងចេះពិចក្ខិរក្សាអ្នកមានហានៈខ្ពស់មិនឲ្យធ្លាក់មកទាប លើកស្ទួយអ្នកមានហានៈទាបឲ្យខ្ពស់ឡើងទៅតាមលំដាប់នាំទៅកាន់ការភ្ជឹស្វាងរុងរឿង នឹងការយល់វិញ្ញាណការជាស្ពានកងវេលាខាងមុខ នាំឲ្យផុតចាកសេចក្តីលង់ខ្លៅដែលជាចំរូងយ៉ាងមុតស្រែវលង់ចំពោះអ្នកនាំយកទៅទុក្ខកង់ខ្លួន ។

ឧបសគ្គដែលនាំកំឝ័ពបំណងកងផ្លូវនោះ គឺសេចក្តីលង់ខ្លៅ ។ លោកអ្នកមិនត្រូវមើលមនុស្សដទៃឲ្យច្រើនជាងមើលខ្លួនឯងឡើយ បើ

មិនដូច្នោះទេធំត្រូវដំទៀលថាខ្លួនល្ងង់ ។ គប្បីនឹកឆងថា មនុស្សល្ងង់បំផុតក្នុងចំណោមមនុស្សទាំងអស់នោះ គឺមនុស្សដែលចូលចិត្តស្វែងរកសេចក្តីល្ងង់នៃមនុស្សដទៃ មកផ្សំបំពេញនឹងសេចក្តីល្ងង់របស់ខ្លួនឯងដែលមានស្រាប់ហើយ ។ មនុស្សល្ងង់នោះ កុងវេលាត្រូវដំទៀលឬបានទទួលពាក្យសរសើរ រមែងជាមនុស្សមិនស្គាល់ខុស - ត្រូវច្រើនដងគ្នឹងប្រកាន់ខឹងចំពោះពាក្យដំទៀលកុងកាលដែលខ្លួនត្រូវដំទៀល នឹងរីករាយចិត្តកុងពាក្យសរសើរ ដែលគេសរសើរខ្លួន ទោមនស្សតូចចិត្តកុងពាក្យដំទៀល ក្តើតក្តើនកុងពាក្យសរសើរ កាលបើក្តើតក្តើនខ្លាំងក៏រវើរវាយ កាលបើរវើរវាយក៏ល្មើស បើល្មើសហើយ ក៏ខូចមនុស្សធម៌ ។

មនុស្សល្ងង់ច្រើនតែមានក្អែកខ្មាក់ កុងភ្នែកខ្លួនរបស់ខ្លួន ហើយមានក្អែកភ្នឹកកុងកំហុសរបស់មនុស្សដទៃ ចូលចិត្តមើលមនុស្សដទៃពេញផ្នែកក្អែក មើលខ្លួនឯងដោយកន្ទុយក្អែក កំហុសរបស់អ្នកដទៃ សូម្បីតូចប៉ុនគ្រាប់ស្ពៃក៏ឃើញបានដាយ កំហុសរបស់ខ្លួនវិញ សូម្បីប៉ុនដូងទាំងសំបក ក៏មើលមិនដាយឃើញ ព្រោះចូលចិត្តចង់ដឹង ចង់ឃើញតែទោសរបស់អ្នកដទៃ ឯទោសខ្លួនវិញ ចូលចិត្តធ្វើព្រងើយកន្តើយមិនអើពើឡើយ ទំតែចិទ្ទុក សូម្បីចិទ្ទុកហើយមិនដឹត ក៏សម្គាល់ថាកំហុសខ្លួនមិនធ្ងន់ប្រហែលនឹងកំហុសអ្នកដទៃ ត្រឡប់ជាដំតើនខ្លួនថាគ្មានបើជាធំមនុស្សដទៃទៅវិញថែមទៀត ចូលចិត្តបាចសាចទោសគេ

ដូចជាបាចសាចអង្កាម សូម្បីមិនមានគេស្តីក៏ដោយ, តែឯគុណគឺ
សេចក្តីល្អរបស់គេវិញ សូម្បីមានគេស្តី ក៏មិនពណិនាឲ្យដល់ ឯទោស
របស់ខ្លួន ខ្លួនបិទទុកឲ្យជិត ដូចជាអណ្តើកលាក់ក្បាលនឹងដើងទុកក្នុង
សុក សូម្បីត្រូវគេស្តី ក៏និយាយបញ្ចៀសវាងឯបន្ទែបន្ទប់ឲ្យបាត់
ទៅ គុណរបស់ខ្លួនវិញ សូម្បីមិនមាននរណាស្តី ក៏និយាយកោរកាវ
ព្រោកប្រាជ្ញទៅ នេះឯងជាទោសនៃការមិនចេះពិចារណាត្រួតត្រា
ខ្លួនឯង ។

ដូច្នេះ យើងទើបគួរចេះពិចារណាត្រួតត្រាខ្លួនឯងឲ្យណាស់ បើ
យើងមិនមានទោសកំហុសកងខ្លួនឯងទេ ទឹងតិះដៀលមនុស្សដទៃដើម្បី
ជាស់តឿនខ្លះក៏គួរ តែបើយើងមានទោសកំហុសពេញពាំងខ្លួនត្រាប់
ទៅតិះដៀលគេវិញ ក៏ជាហេតុចាក់រុកឲ្យគេសើច - ចំអកមកវិញបាន ។
យើងមុនទឹងតិះដៀលគេនោះ គប្បីពិនិត្យមើលទោសខ្លួនឯងឲ្យសព្វ
គ្រប់សិន ទឹងគប្បីត្រួតមើលខ្លួនឯងឲ្យច្បាស់ ដោយប្រៀបធៀបទឹង
អ្នកដទៃ ព្រោះបើគេធ្វើខុស ប្រាប់ឲ្យយើងដឹងថាគេធ្វើខុស តែពេល
ដែលយើងធ្វើខុសវិញ គ្រៃពីខ្លួនឯងហើយ មិនមាននរណាប្រាប់ថា
យើងធ្វើខុសទេ ទើបយើញថា មិនមានដំណឹងឯណាកងលោកដែល
មានដំណែម្ប៉ុន្មាន ទឹងការចេះត្រួតពិនិត្យខ្លួនឯង ដោយការតិះដៀល
ខ្លួនឯងសង្កត់សង្កិនខ្លួនឯងនេះឡើយ ។ បើយើងចង់ជួយខ្លួនឯងឲ្យផុត

ចាកពាក្យពោលផ្តាសាអំពីអ្នកដទៃផង ក៏ធើតែតែត្រូវបង្ហាត់ហ្វឹកហ្វឺនការត្រួតពិនិត្យខ្លួនឯង ឲ្យស្ទាត់ជំនាញថែមទៀត ដូចជាកន្លងវេលាត្រូវដំទៀលឬបានទទួលពាក្យសរសើរ បើយើងធ្លាប់ត្រួតពិនិត្យខ្លួនឯងជានិច្ចមកហើយ កាលឮគេដៀល ក៏មិនត្រេញធ្លក់ក្រញាំងប្រកាន់ខឹងចំពោះអ្នកដៀល កាលបើឮគេសរសើរ ក៏មិនក្តើតក្តើនកន្លងពាក្យសរសើរនោះ ។

តាមពិត មនុស្សដទៃ មានគេសប៉ុន្មាននោះ មិនជារឿងអ្វីដែលយើងត្រូវស្វែងរកទេ ។ គោលយ៉ាងសំខាន់ត្រកែលែងនោះ នៅត្រង់យើងព្យាយាមត្រួតត្រាពិចារណាខ្លួនឯង ។ បើយើងត្រួតត្រាពិចារណាខ្លួនឯងច្រើនឡើងត្រឹមណា នឹងឃើញច្បាស់នូវសេចក្តីល្ងង់ខ្លៅរបស់ខ្លួនឯងច្រើនឡើងត្រឹមនោះ ។ បើយើងរំតែតែឃើញច្បាស់ នូវសេចក្តីល្ងង់ខ្លៅរបស់ខ្លួនឯងច្រើនឡើងត្រឹមណា ក៏ធើរំតែតែស្គាល់ការខ្ជិលច្រអូស នឹងការពុំទុកដែលមាននៅក្នុងខ្លួន, ហើយតែងការខ្ជិលច្រអូស នឹងការពុំទុកដែលរបស់ខ្លួនរំតែតែបានច្រើនឡើងត្រឹមនោះ ។ "មិនគួរយកបិត្តទុកជាកំនឹងពាក្យប្រាក់ដោតអាក្រក់ នឹងកិច្ចដែលធ្វើហើយ នឹងមិនទាន់ធ្វើរបស់ជនដទៃទេ គួរពិចារណាមើលតែកិច្ចដែលធ្វើហើយ នឹងមិនទាន់ធ្វើរបស់ខ្លួនប៉ុណ្ណោះជាការប្រសើរជាង" នេះជាពុទ្ធោវាទសម្រាប់ខ្លួនយើង ។

(មានត)

កណ្ឌទី ១៨

ឧកញ៉ាវិបុលរាជសេនា ន្ង-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាឃ្លុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
ធឹងបេះឧបាយកូលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ខ្ញុំពីតបថា កាលគ្រាតេងន្ធនធឹងតាំងតុះស្ងាប់នោះ លោកក៏គង់ជាបស្រាប់ហើយ ហេតុម្តេចត្រឡប់មកស្នូរចង់ដឹងចិត្តខ្ញុំធ្វើអ្វីទៀត ។ លីចុ"ឮខ្ញុំតបដូច្នោះក៏ងឿងឆាស់សំឡក់សំឡឹងខ្ញុំពីដោយនឹកក្នាញ់ថា ខ្ញុំពីនេះជាមនុស្សមិនដឹងគុណអញសោះ ។ ចូរឆ្លក់បង្គាប់ឲាហានឲ្យនាំខ្លួនលីចុ"ចេញទៅសម្លាប់ ។ ខណៈកាលឲាហានចូលទៅចាញ់យកខ្លួនខោះ លីចុ"ស្រែកដេរថា អាខ្ញុំពីត្រចៀកយារ! អាឯងមិនគិតដល់គុណអញសោះ កាលគ្រាគ្មានឡើងធ្វើអន្តរាយវា កុំតែអញគិតកលឧបាយចាញ់ឆ្ងល់ត្រូវបុងខ្លួន វាក៏មិនមែនរួចជីវិតទេ ឥឡូវវាត្រឡប់រំលឹកគុណអញវិញ ។ ខ្លួលឲាហានចូរឆ្លាប់ខ្លួនត្រៀវលៀវចង់នាំ

មកខ្មែត ។ តៀវលៀវឮលីចោ"ថាដូច្នោះ ក៏និយាយនឹងលីចោ"ថា កើត
មកជាជាតិគាហានហើយមិនត្រូវស្លាយដីវិតទេ បើត្រូវស្វាប់ក៏ស្វាប់ទៅ
ចុះ ត្រូវចុះតែឈ្មោះឲ្យជាប់ក្នុងឥតិ្ថវតារ ។ លីចោ"បានស្តាប់
តៀវលៀវថាដូច្នោះក៏រះស្ងៀម គាហានទាំងពួងក៏នាំខ្លួនលីចោ"ចេញទៅ
ច្រហារជីវិត ហើយកាត់ក្បាលជោតទៅមុខគ្រូវស្រុក ។

គាហានក៏នាំខ្លួនតៀវលៀវឡើងលើសែនដួចនឹងចូលួៗក៏ថា តៀវ-
លៀវ! អ្នកឯងនេះមានរូបរាងមាំមួនសមជាសេនាគាហាន មួយទៀតយើង
ក៏នៅចាំថាអ្នកឯងនេះហើយដែលចាំងនឹងយើងម្តង ។ តៀវលៀវធ្វើយថា
កាលចាំងនៅស្រុកចា"ក់អៀងនោះលោកក្មេចទៅហើយឬ ខ្ញុំនៅគិតស្តាយ
ពេកណាស់ ។ ចូលួសួរថា អ្នកឯងស្តាយអ្វី? ។ តៀវលៀវតបថា
ខ្ញុំស្តាយ កាលដុតស្រុកចា"ក់អៀងនោះក្តៅនេះតិចពេក បើក្តៅនេះខ្ញុំង
ច្រហៃលស្វាប់អាសត្រូវរាជសម្បត្តិឯងចាត់ទៅហើយ ។ ចូលួបានឮដូច្នោះ
ក៏បានសេចក្តីអាប់យសណាស់ ស្រែកថា "ខ្លួនអាឯងជាឈ្លើយ ទឹង
ស្វាប់ជីវិតឥឡូវហើយ ហេតុម្តេចក៏ហ៊ាននិយាយទៀតទៅឲ្យអញដូច្នេះ"
ថាហើយក៏ហូតគ្រឿងតែងតទឹងកាប់តៀវលៀវ ។ ក្នុងខណៈនោះតៀវលៀវ
ក៏ឥតញញើតនុនកទៅឲ្យចូលួកាប់ ។ ខ្លួលគួនអ៊ិចូលទៅហាមឃាត់
ចូលួហើយតំនាប់ថា ដែលលោកទឹងសម្លាប់តៀវលៀវនោះសុំឲ្យបង្អង់សិន
ព្រោះតៀវលៀវជាមនុស្សសុចរិតពិតត្រង់ គួរចិញ្ចឹមរក្សាទុកឲ្យនៅធ្វើ

ភជការជាមួយនឹងលោក បើទៅមុខហើយតៀវលៀវត្រឡប់វៀចគិត
ច្រឡូសរ៉ាយនឹងលោកវិញ សុំឲ្យលោកកាត់ក្បាលខ្ញុំចុះ ។

ចូឆូបានស្តាប់ដូច្នោះ ក៏មានសេចក្តីត្រេកអរឡើយថា "យើងដឹងហើយ
គឺចិត្តតៀវលៀវនេះជាមនុស្សខ្វែងត្រង់ល្អណាស់ ដែលយើងធ្វើដូច្នេះ
ច្បាថ្នានឹងពិសោធចិត្តតៀវលៀវលេីល បើជាតាហានមែននឹងមិនខ្លាច
ស្លាប់ទេ ឥឡូវយើងឃេីញចិត្តតៀវលៀវជាមនុស្សម៉ាំមួន គួរចិញ្ចឹម
រក្សាទុកតទៅបាន" និយាយហើយក៏គ្រាតទៅស្រាយចំណងតៀវលៀវ
ចេញទាំងអស់ ហើយយកអាវយ៉ាងល្អឲ្យតៀវលៀវពាក់ហើយដឹកដៃ
ទៅអង្គុយលើទីសមគួរ ។ តៀវលៀវមានចិត្តត្រេកអរក៏នុនគំនាប់ហើយ
និយាយថា ដែលមហាឧបភជមានសេចក្តីករុណាទុកអាយុជីវតខ្ញុំបាទ
ឲ្យរស់នៅដូច្នេះ ព្រះគេជព្រះគុណធ្ងន់មិនមានទីបំផុត ខ្ញុំបាទនឹងសុំនៅ
ជួយធ្វើភជការនឹងលោកត្រាតែអស់ជីវិត ។ ចូឆូក៏តាំងតៀវលៀវជាបុង-
ឡងដៀង គឺនាយតាហានទេ ហើយក៏ចាត់ប្រើតៀវលៀវឲ្យទៅបញ្ជុះ
បញ្ចូលបុងចា"ជាសេនាលីចា" ។ ឯបុងចា"កាលបានដឹងដំណឹងថាលីចា"
ស្លាប់ហើយ ឥឡូវតៀវលៀវបួលទៅនៅនឹងចូឆូដូច្នោះ បុងចា"ក៏បបួល
ស៊ុនគួន ១, ង៉ីតុន ១, ស៊ុនទេ្ស ១ ចោរទាំង ៣ នាក់នេះ នឹងតា
តាហានទាំងពួងចូលទៅរកចូឆូឯស្រុកវែហ៊ូ នៅតែសៀងហ៊ីរត់ទៅព័ទី
នោះបាត់ ។ ចូឆូឃេីញបុងចា"នឹងតាហាននោះមកក៏ទួលរាក់ទាក់

រួសពាយណាស់ តាំងចុងចាំជានាយភាហានធំ ឯនាយចោរតាំង ៣ តាំង
ជានាយភាហានរង ហើយឲ្យលើកពលៈទៅគយល្បាតលាតកងក្រវែល
ជុំនៃគ្រតាមមាត់សមុទ្រដើម្បីការពារសេត្រូវ ។

ក្នុងសម័យនោះចូងធូឲ្យរង្វាន់បំណាច់នាយកងនាយទ័ព នឹងពល
ភាហានធំតួចតាមសមគួរ ហើយឲ្យលើកនាំយកគ្រប់គ្រួលចូលទៅ
ក្រុងហ្វ័តោ ។ ឯចូងធូក៏លើកទ័ពត្រឡប់ទៅស្រុកឈីដាវ អាណា
ប្រជានុករស្តេតាំងពួងដឹងដូច្នោះ ក៏តែងតុះតាំងគ្រឿងសក្ការៈបូជាអុជធៀន
ធូបគំនាប់ជាកិត្តិស័ព្ទកិត្តិយសចូងធូទូទាំងបរិវេណ ។ បណ្ដារស្តេតាំងនោះ
ដំរាបចូងធូថា សុំឲ្យលោកតាំងទៀតពីទុកជាចៅហ្វាយស្រុកឈីដាវចុះ ។
ចូងធូតបថា គ្រានេះទៀតពីមានបំណាច់នឹងរាជការផែនដីច្រើនណាស់
យើងនឹងនាំខ្លួនចូលទៅគ្រាបបង្គំគាល់ព្រះចៅហៀនតេសិន បើទ្រង់
ប្រោសព្រះរាជទានគុណបំណាច់ស្រេចហើយ ទើបនឹងវិលត្រឡប់មក
ឈរជើងត្រតទៅ ។ ចូងធូក៏ចាត់ភាហានឲ្យនៅព្យាបាលតរិយាបុត្រទៀតពី
នៅក្នុងស្រុកឈីដាវនោះ ។

រួចចូងធូក៏នាំទៀតីលើកកងទ័ពត្រឡប់ចូលទៅក្រុងហ្វ័តោ កាលទៅ
ដល់ហើយ ក៏ចូលទៅគ្រាបបង្គំគាល់ព្រះចៅហៀនតេ ហើយគ្រាប
ទូលថា គ្រានេះទៀតីធ្វើរាជការមានសេចក្តីគាប់ប្រសើរជាច្រើនណាស់ ។
ព្រះចៅហៀនតេ ទ្រង់ព្រះសណ្ដាប់ក៏មានព្រះទ័យសោមនស្សត្រេកអរ

គ្រាស់ឲ្យហៅទៀតពីចូលទៅគាល់ហើយគ្រាស់សួរថា អ្នកឯងជាបុត្រអ្នកឯណា ? ។ ទៀតត់ក្រាបទូលថា ទូលព្រះបង្គំជាខ្ញុំជាបុត្រទៀហេង បិតាទូលព្រះបង្គំជាខ្ញុំជាពូជព្រះពជវង្សព្រះចៅហៅកេងតេ ។ ព្រះចៅហៀនតេទ្រង់សណ្តាប់ ក៏គ្រាស់បង្គាប់អាលំក្សឲ្យយកពង្សាវតារមកទតពាប់តាមលំដាប់ក្សត្រតៗមកក៏ឃើញថា ទៀតីជាមាបស់ព្រះអង្គ ហើយទ្រង់តាំងទៀតីជាទីឃីតេងហៅ គឺសេនាបតីធំខាងក្រុមកាំង ។ អំណើះតមកព្រះចៅហៀនតេទ្រង់ពាប់អានទៀតីហៅម៉ា ។ ចូឆូទឹងទៀតីក៏ថ្វាយបង្គំលាថយទៅទីលំនោរវៀងខ្លួន ។

ស៊ុនហុកចូលទៅដុំកបចូឆូថា តឡូវនេះព្រះចៅហៀនតេទ្រង់ពាប់អានទៀតីថាជាពូជព្រះពជវង្ស អំណើះតទៅគង់តែទៀតីទឹងគិតប្រទូសកាយដល់លោកជាប្រាកដ ។ ចូឆូតបថា ដែលព្រះចៅហៀនតេពាប់អានទៀតីថាជាពូជព្រះពជវង្សនោះមិនជាអ្វីទេ ព្រោះកិច្ចការពជការតាំងពួងជាកម្មសិទ្ធិនៅលើយើងតាំងអស់ ឧបមាដូចពងមាន់នៅក្នុងកណ្តាប់ដៃយើង ទោះបីទៀតីទឹងប្រទូសកាយដល់យើង។ ក៏មិនត្រូវញាញើតសោះ សព្វថ្ងៃនេះយើងនៅជាម្ចាស់ក្រុងតែអៀវពីវ ដែលជាប្អូនទឹងអ៊ួនសៀវ, អ៊ួនស៊ុតប៉ុណ្ណោះ ត្រែងឲមកធ្វើកលសឹកកងទីក្រុងព្រោះអ៊ួនសៀវនេះទឹងអ៊ួនស៊ុតនៅមានកម្លាំងច្រើន ។ ស៊ុនហុកស្តាប់យល់ត្រូវ ។

ចូឆូទើបប្រឹក្សាជាយកល ឲ្យប័ក្សពួកបស់ខ្លួនទៅលបស៊ើបស្តាប់ថាអៀវពីវផ្ញើសំបុត្រសំងាត់ទៅដល់អ៊ួនស៊ុតថា ឲ្យអ៊ួនស៊ុតលើកទ័ពមកវាយ

ស្រុកហ្នឹងតោ អៀវពីវនឹងខ្លួលធ្វើកលស៊ឹកខាងកន្ត ។ ចូរឆ្លូស៊ើបដឹងការ ប្រាកដក៏បង្គាប់ឲ្យចាប់ខ្លួនអៀវពីវដាក់គុកខុក ហើយឲ្យមានចំនួនសម្រេច សេចក្តីធ្វើទោស ។ ឯយុងដឹងការណ៍ក៏ចូលទៅដួបនឹងចូរឆ្លូហើយដំរាបថា អៀវពីវធ្វើពជការជានាម៉ឺនត ។ ពិជីតានឹងបិតាជរាបមកដល់ខ្លួនអៀវពីវនេះ។ មិនដែលធ្វើសេចក្តីប្រទូសព៌យដល់អ្នកឯណាសោះ ដែលលោកជឿស្តាប់ពាក្យមនុស្សព្រុះញាន់ មិនពិចារណាឲ្យយើញរឿងនឹងត្រង់សិនោះមិនគួរសោះ ហេតុនេះខ្ញុំបាទសុំឲ្យលោកពិចារណាតាមយុត្តិធម៌សិន ។ ចូរឆ្លូតបថា ការណ៍នេះជាព្រះពជតម្ចាស់ព្រះចៅហ្នឹងតេ មិនមែនយើងធ្វើតាមអំពើចិត្តទេ ។

ឯយ៉ងថា មហាឧបរាជជាអធិបតីសំរេចរាជការក្នុងព្រះនគរ ទោះបីព្រះពជតម្ចាស់ព្រះចៅហ្នឹងតេគ្រាស់ឲ្យធ្វើយ៉ាងណា ក៏ត្រូវតែលោកពិចារណាឲ្យយើញឧសត្រូវសិន ។ ចូរឆ្លូបានឮដូច្នោះក៏មានសេចក្តីខ្លាស់ណាស់ ទើបឲ្យដោះលែងអៀវពីវចេញពីកន្លែងគុក តែឲ្យហួតងារពីតំណែងមន្ត្រីរាជការ ។ អៀវងាន់ជានាម៉ឺនរាជការព្រះចៅហ្នឹងតេដឹងសេចក្តីដូច្នោះ ក៏ធ្វើរឿងរ៉ាវគ្រាបបង្គំទូលព្រះចៅហ្នឹងតេឲ្យទ្រង់ជ្រាបថា ចូរឆ្លូធ្វើការអែបបន្ទំព្រះតម្ចាស់យកខ្លួនអៀវពីវទៅដាក់គុកហើយហួតងារចេញពីពជការ ។ ព្រះចៅហ្នឹងតេជ្រាបហើយក៏មិនគ្រាស់ថាប្រការម្តេច ។ ចូរឆ្លូដឹងដូច្នោះ ក៏ប្រែគាហានទៅចាប់ខ្លួនអៀវងាន់

យកទៅប្រហារជីវិតចង់ ។ តាំងពីនោះរៀងមក នាហ្មឹនជំតូចនៅកង់ក្រុងហ៊ូតៅ ក៏កោតខ្លាចបួងជាខ្លាំងណាស់ ។

ឆៀយ៉ុកឥប្រឹក្សាបួលទៅនិយាយនឹងបួងថា ឥឡូវនេះបណ្តានាហ្មឹនតូចធំនិយមកោតខ្លាចអំណាចមហាឧបរាជទាំងអស់ហើយ ហេតុម្តេចមហាឧបរាជមិនគិតយកពាជសម្បត្តិតែម្តង់ទៅ នឹងបង្អង់ទុកនៅចាំដល់ណាទៅទៀត ។ បួងតបថា ‘ វេលានេះនៅមាននាហ្មឹនមុខមន្ត្រីដែលព្រះចៅហៀនតេ ទុកព្រះទ័យច្រើនណាស់ យើងនឹងធ្វើការរឹតត្បិតមិនបានសម្រេចដូចចិត្តនៅឡើយ បើដូច្នេះត្រូវយើងរិះគិតអញ្ជើញស្តេចព្រះចៅហៀនតេទៅប្រពាតព្រៃមើលកលល់ការសិន ” និយាយហើយក៏ចាត់ចែងគ្រឿងប្រដាប់សម្រាប់ប្រពាតព្រៃទុកតែម្តងស្រេច ក៏ចូលទៅក្រាបទូលអញ្ជើញស្តេចចេញទៅប្រពាតព្រៃជាកំសាន្ត ។

ព្រះចៅហៀនតេគ្រាស់ថា នឹងទៅលេងព្រៃនោះមិនត្រូវព្រួយការនឹងសេនាទាហានទេ ព្រោះគ្មានផលប្រយោជន៍អ្វីសោះឡើយ ។ បួងក្រាបទូលថា ប្រសិនណីនៃព្រះមហាក្សត្រតាំងបូរាណ ស្តេចចេញទៅប្រពាតព្រៃសំសាន្តក្នុង ១ ឆ្នាំ ៤ ដង ត្រូវលៀងថ្វាយដែរសេនាទាហានផង ឥឡូវក្នុងព្រះពាជអាណាខែត្តក៏មិនទាន់ពាបពាជាប្រក្រតី សូមអញ្ជើញស្តេចចេញទៅប្រពាតព្រៃ នឹងបានខត្ថុំពាជការទាំងពួងលៀងថ្វាយជ្រះ ។ ព្រះចៅហៀនតេខ្ជិលព្រះសណ្តាប់ក៏មិនអាចនឹងខ្ជិលទាស់បួងបាន បួង

ក៏ចាន ប្រមូលពលទាហាន ១០ ម៉ឺន ព្រមដោយគ្រឿងសស្ត្រាវុធ ព្រះចៅហៀនតេក៏យាងគង់លើទីនាំងអស្សតរ បណ្តានាហ៊ីនមុខមន្ត្រីទីឆ្វេងស្តាំ, គួនអ៊ូ, តៀវហ៊ុយ ក៏ជិះសេះហែហមអមស្តេចចេញទៅ ។ ឯចូឆ្ងក៏ធ្វើឫកពាដូចជាស្តេច ជិះសេះអែបព្រះទីនាំងមិនចាន់កោតក្រែងព្រះចេស្តា លុះស្តេចយាងទៅដល់ជាយព្រៃព្រឹក្សាមានវល្លិ៍ចោះមួយអន្ទើក៏ឲ្យឈប់កងទ័ព ។ នាហ៊ីនទីឆ្វេងសេនាតាំងពួន ក៏លើកគ្នាដេញហ្វូងសត្វកៀរប្រមូលចូលទៅតែងំចែកក្នុងមុខព្រះភ័ក្ត្រ ។ ព្រះចៅហៀនតេក៏ទ្រង់ត្រាស់ទីឆ្វេងថា យើងចង់ឃើញថ្លើដែមាចាញ់សត្វនោះលួងមើល ។ ទ្បៅតីទទួលព្រះពាជនុង្ការហើយក៏ឡើងសេះចាញ់ធ្វើតែវរមាំង ១ ដួលចុះនៅទីនោះ ។

ព្រះចៅហៀនតេក៏ទ្រង់ធ្វើចាញ់ប្រើសមិនត្រូវ ទើបត្រាស់ទីឆ្វេងចូឆ្ងថា អ្នកចូរចាញ់ប្រើសនោះឲ្យចាន ។ ចូឆ្ងទូលថា បើព្រះអង្គទីឆ្វេងចង់ទតថ្លើដែទូលព្រះចង្កឹងាឡុំ សុំព្រះកុណាព្រះពាជទានឆ្វេងព្រះសែងមកចុះទូលព្រះបង្កឹងាឡុំទីឆ្វេងចាញ់ថ្វាយទត ។ ព្រះចៅហៀនតេក៏ហុចព្រះសែងកៅខ័ណ្ឌទ្រង់ឲ្យទៅចូឆ្ង ។ ទទួលហើយក៏លើកឡើងចាញ់ទៅ ត្រូវប្រើសនោះដួលចុះមួយរំពេច ។ នាហ៊ីនទាំងពួងដែលនៅពីចម្ងាយឃើញព្រះសែងកៅខ័ណ្ឌចំព័ន្ធរូបម្ភរ ត្រូវប្រើសដួលដូច្នោះ ក៏ស្មានថា "ព្រះចៅហៀនតេទ្រង់ថ្វែងព្រះអង្គឯង" ទាំងអស់គ្នាក៏ចូលមកក្រាប

ថ្វាយបង្គំចំពោះព្រះភ័ក្ត្រ ។ ចូរឆ្លើយញុះញង់ដូច្នោះកំរើតសោនមស្សថ្រិតាបវ
សេះកាត់មុខព្រះភ័ក្ត្រាចេញទៅហើយស្រែកថា ខ្ញុំនយើងបាញ់ត្រូវ
ប្រើសនេះ ។ នាហ្នឹនឹងសេនាគាហានតាំងពួង ឃើញចូរឆ្លើកវិយា
មើលងាយព្រះចេស្តាដូច្នោះ កំភាក់ស្មារតីស្ងាំងកាំងតាំងអស់គ្នា ។

គួនអ្វីឃើញចូរឆ្លើអាកប្បកិរិយាដូច្នោះកំនឹកខឹងណាស់ បរសេះ
ចូលទៅលើកដាវឡើងនឹងកាប់ចូរ ហើយត្រឡេកមកមើលមុខឡៅពី។
កំញាក់ក្តែកបញ្ឈប់ហើយត្រិះក្បាល ។ គួនអ្វីក៏ឈប់ថយចេញ ។ ឡៅពី
និយាយថា ថ្លៃដៃមហាឧបរាជបាញ់ធ្នូនេះនឹងរកអ្នកឯណាស្មើមិនបានទេ ។
ចូរឆ្លៃក្លៃងតបថា "ថ្លៃដៃយើងជាប្រមាណយ៉ាងសមគួរប៉ុណ្ណោះ" ហើយ
ត្រឡប់មុខមកគំនាប់ព្រះចៅហៀនតេរួចក្រាបទូលថា ដែលទូលព្រះបង្គំ
បាញ់ទៅត្រូវប្រើសនោះ ព្រោះព្រះសែងគៅម៉ាងនឹងព្រះចារមើរបស់
ព្រះអង្គជួយខ្លែងដ៏ ។ ព្រះចៅហៀនតេខ្លែងមិនជ្រាបឧបាយកល
ចូរក៏នាំនាហ្នឹនមុខមន្ត្រីក្រសាលដេញសត្វកំសាន្តព្រះទ័យ លុះពេល
វាសៀលហើយក៏ស្តេចត្រឡប់ចូលក្នុងព្រះបរមរាជវាំងវិញ ។ ចូរក៏យក
ព្រះសែងគៅម៉ាងគុតជាកម្មសិទ្ធិមិនបានថ្វាយទៅវិញ ។ ឯនាហ្នឹនមុខ
មន្ត្រីក៏ត្រឡប់ទៅទីលំនៅរៀងខ្លួន ។

គួនអ្វីនិយាយនឹងឡៅពីថា ចូរឆ្លើកិរិយាមើលងាយព្រះចេស្តា
ខ្ញុំប៉ងនឹងសម្លាប់ចេញ ហេតុម្តេចបានជាបង្ខាត់ខ្ញុំ? ។ ឡៅពី

តបថា ព្រះចៅហៀនតេនឹងខ្ជួនបង់វេលានោះទៅកង់ចំណោមទាហានចូរឆ្លៀ
បើម្ជុនសម្ងាប់ចូរឆ្លៀហើយ ទាហានគេកំសម្ងាប់បង់វិញ ហើយនឹងធ្វើ
អន្តរាយដល់ព្រះចៅហៀនតេដង ព្រោះហេតុនេះបានជាបង់ហាមយាត់ ។

ខណៈនោះ ព្រះចៅហៀនតេយាងចូលទៅរកព្រះនាងហុកហៅជា
អគ្គមហេសី ហើយគ្រាស់ប្រាប្តពីរឿងបេញទៅប្រពាតវិត្រ ចូរឆ្លៀ
កិរិយាមើលងាយកណ្តាលទីប្រជុំ ឲ្យព្រះអគ្គមហេសីស្តាប់គ្រប់ប្រការ
ទ្រង់គ្រាស់ថាខ្ជួនយើងបានសោយរាជសម្បត្តិនេះ មានតែសេចក្តីព្រួយ
រំខានក្នុងចិត្តឥតស្រាកស្រាន្ត កាលគ្រាតាំងគុះកំពង់ធ្វើអាក្រក់នឹងយើង
ច្រើន កាលគ្រាលើឈុយគុយតីកំពង់ធ្វើអន្តរាយដល់យើងផ្សេង ។ ឥឡូវ
យើងគិតថា ចូរឆ្លៀនឹងជួយទំនុកបំរុងផែនដី កំត្រឡប់មកធ្វើអប្រិយអាក្រក់
ដល់យើងទៀត ជីវិតរបស់យើងនឹងនាងនេះ មិនដឹងជាមានសេចក្តី
ស្លាប់មកដល់ថ្ងៃណាទេ" ។ ព្រះចៅហៀនតេទ្រង់ពណិនាវូចហើយកំ
ទ្រង់ព្រះកន្សែងពិលាប ។ ព្រះអគ្គមហេសីបានទ្រង់ជ្រាបតាមក្រសែ
ព្រះរាជឆន្ទារព្រះស្វាមី កំទ្រង់ព្រះកន្សែងថ្វៃងថា នាហ្មឺនមុខមន្ត្រីធំតូច
តាំងប៉ុន្មានសុទ្ធតែបានស៊ីបៀវត្សរ៍គ្រប់គ្នា ម្តេចក៏ចេះតែមើលបំណាំមិន
ជួយទំនុបំរុងផែនដី លះបង់មេត្រីទុកឲ្យព្រះអង្គសោយទុក្ខលំបាកដូច្នេះ
កំជាកេណ្ឌាកម្ចាស់ម្ងាប់ព្រះអង្គនឹងខ្ញុំម្ចាស់ ។

ពេលនោះ ទន្ទួលហុកអ៊ិនជាបិតាព្រះនាងហុកហៅចូលទៅគាល់
ខាងក្នុង ឃើញព្រះចៅហៀនតេទ្រង់ព្រះកន្សែងក៏ទូលសួរថា ព្រះ

អគ្គទ្រង់ទាស់ព្រះហឫទ័យពីការអ្វី ឬទ្រង់នរណា? ។ ព្រះចៅហៀនតេក៏អធិប្បាយក៏យរឿង ដែលចូរធ្វើល្មើសមើលងាយប្រមាថឲ្យហុកអ៊ួនស្តាប់គ្រប់ប្រការ ។ ហុកអ៊ួនក៏ទូលថា កាលស្តេចចេញទៅប្រពាតព្រៃវែងនោះទូលព្រះបង្គំជាខ្ញុំក៏បានឃើញជាក់ច្បាស់ទាំងអស់ហើយ តែមិនដឹងធ្វើប្រការម្តេច សូមឲ្យនាហ៊ីនមុខមន្ត្រីទាំងពួងក៏មិនមានឈឺចិត្តក្តៅដួសព្រះអង្គ ទូលព្រះបង្គំឃើញតែតាំងស៊ុនជាព្រះពជវង្សទ្រង់ជួយគិតអានគិតកំចាត់ចូរចូរចេញបាន ។

ព្រះចៅហៀនតេត្រាស់ថា ការទាំងនេះគួរទ្រង់រកតាំងស៊ុនចូលមកគាល់ទ្រង់បានពិគ្រោះប្រឹក្សា ឬទ្រង់គិតប្រការម្តេច? ។ ហុកអ៊ួនទូលថា សព្វថ្ងៃនេះចូរទ្រង់បានទុកចិត្តដល់ព្រះអង្គក៏ទេ វាមានប្រើមនុស្សស្រីជាទំនុកទុកចិត្តឲ្យចូលមកចាំស្តាប់ការល្អអាក្រក់ ក្នុងព្រះបរមរាជវាំងជានិច្ច ដែលទ្រង់ទ្រង់ឲ្យហៅតាំងស៊ុនចូលមកក្រាបបង្គំគាល់នោះ ខ្លាចដឹងទៅដល់ចូរ ការដែលគិតទុកក៏ទ្រង់ខូចអស់រលៀតទៅ សូមឲ្យព្រះអង្គទ្រង់ព្រះអក្សរលាក់ទុកក្នុងស្រទំពាក់ឲ្យកំចុំង រួចទ្រង់ឲ្យហៅតាំងស៊ុនចូលមកគាល់រួចយកអាវនោះព្រះរាជទានឲ្យតាំងស៊ុន ហើយទ្រង់ប្រាប់តាំងស៊ុនថា បើបានទៅដល់ផ្ទះហើយឲ្យយកព្រះអក្សរចេញមកមើល ឃើញថាចូរចូរទ្រង់មិនបានដឹងសេចក្តីកំចុំងនោះឡើយ ។ ព្រះចៅហៀនតេក៏ទ្រង់យល់ឃើញត្រូវ ហុកអ៊ួនក៏លាចេញទៅ ។

ព្រះហៀនតេយកព្រះសែងចាក់ម្រាមព្រះហស្តឲ្យព្រះលោហិតហូរចេញមក ហើយយកពិតជ្រលក់សរសេរលើផែនព្រៃសតាមព្រះពរជំរិះហើយបង្គាប់ព្រះអគ្គមហេសីលាក់ស៊ីកទុកក្នុងស្រទាប់ជាយអាវ ហើយទ្រង់ឲ្យហៅខ្លួនតាំងស៊ុនចូលទៅគាល់ មានព្រះពរជន្លឹរត្រាស់ថា "កាលពីយប់ម៉ិញ យើងនឹងព្រះអគ្គមហេសីនឹងដល់អ្នក កាលគ្រានាំយើងរត់ពីលីឈុយគុយគីទៅនោះ សេចក្តីគាប់ប្រសើរបស់អ្នកក៏មានលើយើងច្រើនណាស់ ហេតុនេះយើងឲ្យអាវនេះដល់អ្នកជាបំណាច់យ៉ាងតិចតួច" ហើយទ្រង់ទន្ទឹងបញ្ជាថា បើទៅដល់ផ្ទះវិញឲ្យយកសំបុត្រក្នុងស្រទាប់អាវមើល បើបានឃើញអាការៈទុក្ខក្តៅរបស់យើងយ៉ាងណា ចូរបញ្ជាប់គិតការនោះឲ្យសម្រេច សុំកុំឲ្យអ្នកឯណាដឹងដល់យល់សេចក្តី ។ តាំងស៊ុនក៏ទទួលយកអាវដែលទ្រង់ព្រះពរទាន ហើយក៏លើកពាក់ចំពោះព្រះភ័ក្ត្រ រួចក៏គាបថ្វាយបង្គំលាចេញចាកទ្វារព្រះបរមរាជវាំងក្នុងនឹងតម្រង់ទៅផ្ទះ ។

(មានត)

ជាលៈ ន៏ន ទមយន្ដ៏

រឿងព្រេងប្រទេសឥណ្ឌៀ

អ្នកស្រីស្រ៊ុង-សារីយ៉ាង់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីភាសាចាំង់មកជាភាសាខ្មែរ

(តមក)

ពេលប្រជុំមហាសន្និបាតក៏កាន់តែខិតចូលមកជិតណាស់ហើយ, នៅខណៈនោះ ឫសីកង់ទេវពិភពឈ្មោះនារទៈ (Narada) នឹងបរវតៈ (Parvata) ទាំងពីរអង្គឡើងទៅគាល់សម្តេចព្រះឥន្ទ្រាធិរាជ, ដល់ហើយព្រះឥន្ទ្រនឹងឥសីក៏ធ្វើការកិច្ចចំពោះគ្នាទៅវិញទៅមក ។ បន្ទាប់មកព្រះឥន្ទ្រាធិរាជក៏មានព្រះបន្ទូលសួរឥសីថា: "ម្នាលឥសីបណ្ឌិត! តើអ្នកអាចប្រាប់យើងបានទេ ថាហេតុអ្វីបានជាយើងលែងឮព្រះសំណូរនៃស្តេចទាំងឡាយនៅលើផែនដី សូត្រធម៌មិនមសារយើង?" ឫសីនារទៈស្តែដូច្នោះញញឹមធ្វើព្រងើយ ហើយធ្វើយតបថា "ទ្រង់ព្រះដ៏មានបុណ្យប្រសើរអើយ! ទូលបង្គំដឹងហេតុដែលព្រះដ៏ជាធំលែងឮធម៌មិនមសារនៃស្តេចទាំងឡាយនោះ ។ ស្តេចគ្រងរាជ្យនៅប្រទេសវិទេហៈ: មានព្រះរាជបុត្រីមួយព្រះអង្គទ្រង់នាមទមយន្តី ព្រះនាងល្អឆើតលើសក្សត្រីផងក្នុងលោក ។ ព្រះនាងនឹងវ៉ាសវកស្វាមីដោយព្រះអង្គឯង ហើយស្តេចទាំងប៉ុន្មាននាំគ្នាទៅប្រជុំក្នុងរាជសន្និបាត ដោយមានព្រះទ័យស្ទើរតែរលាករលួយ មិនដឹងគិតធ្វើម្តេចនឹងបាន

បំពេញព្រះហឫទ័យព្រះនាង" ។ ព្រះឥន្ទនិងព្រះអគ្គី (Agni) ព្រមទាំងទេវតាឯទៀតស្តាប់ហើយ ។ លុះឫសីថ្ងៃសេចក្តីចប់កាលណា ពួកទេវតាមើលមុខគ្នាទៅវិញទៅមក ។ ព្រះអគ្គីឆ្លើមមានបន្ទូលថា: "នារទអ្នកឯងថាព្រះនាងមយន្តីល្អផុតស្រីទាំងពួងឬ?" ។ ឥសីនារទ;ឆ្លើយថា: "មនុស្សទាំងអស់ក៏ថាដូច្នេះដែរ" ។ ព្រះឥន្ទ្រាធិពជក៏ដាក់មក មានបន្ទូលនឹងទេវតាឯទៀតថា: "តើយើងនឹងទៅដណ្តឹមយកកូនស្រីដែលល្អឯកអំពីពួកស្តេចពិភពលោកដែរឬទេ?" ។ ព្រះអគ្គីដែលមានសន្ធានចិត្តពុះពារដោយចំណង់ខ្លាំងក៏ឆ្លើយតបភ្លាមថា: "ទៅ! ទៅ! យើងនាំគ្នាចុះទៅកាន់ប្រទេសព្រះបាទកិម: ឲ្យព្រះនាងមយន្តី រើសយកស្វាមីជាព្រះអាទិទេពវិញ" ។ គ្រានោះព្រះឥន្ទ្រាធិពជ ព្រះអគ្គីនិងទេវតាឯទៀតជារើន ហោះចុះមកកាន់ប្រទេសព្រះបាទកិម: ព្រមទាំងកូនហែហមអមព្រះអង្គជារើនឥតគណនា ។

វគ្គទី ៧

ព្រះបាទនាល: ក៏បានទទួលដំណឹងជាទីគាប់ព្រះហឫទ័យនោះពីពជទូតដែរ ពិតមែនតែទ្រង់ពុំដែលឃើញព្រះកន្តព្រះនាងមយន្តី, ប៉ុន្តែទ្រង់មានព្រះហឫទ័យប្រតិព័ទ្ធចំពោះព្រះនាង លើសលែងអ្វីទៅក្នុងលោកទាំងអស់ ។ ព្រះអង្គទ្រង់យាត្រាដំរង់ទៅប្រទេសវិទេភ: ដោយមានព្រះហឫទ័យស្រាលស្រឡះ ។

ពួកទេវតាព្រមទាំងព្រះអគ្គី ក្រឡេកទៅឃើញស្គាល់ច្បាស់ជាព្រះបាទនាលៈ ហើយក៏ប្រាប់គ្នាថា: "ហ្ន៎ហើយព្រះបាទនាលៈ ដែលទៅកាន់ប្រទេសព្រះបាទតិមៈដែរ ក្នុងចំណោមបុរសដែលទៅក្នុងលោកគ្មានអ្នកណាមួយល្អដូចព្រះបាទនាលៈទេ ចុះអ្នកណាអាចដឹងថាព្រះនាងទមយន្តី ពេញព្រះទ័យនឹងក្សត្រនេះដាច់ពួកអាទិទេពទាំងអស់ឬ? ប៉ុន្តែព្រះបាទនាលៈជាស្តេចគោរពសាសនា ត្រូវយើងកុំលាក់បំណងរបស់យើងឡើយ យើងត្រូវប្រើគេដាច់អ្នកបំរើយើងវិញ" ។ ព្រះឥន្ទ្រាធិរាជតបថា: "ធ្វើតាមតែអ្នកឯងគិតយើញចុះ" ។ ក្នុងខណៈនោះ ពួកព្រះអាទិទេពនាំគ្នាបញ្ជាប់នូវរាជរថនៃព្រះបាទនាលៈ ហើយព្រះអគ្គីពោលថា: "ម្នាលនាលៈ ឯងជាកំពូលនៃមនុស្សលោក ហើយឯងតែងតែធ្វើកត្តិការចំពោះអាទិទេពជានិច្ចរាល់ ។ ចូរឯងដឹងថា អ្នកដែលនិយាយទៅកាន់ឯងនេះ ជាព្រះអគ្គី នៅក្បែរខាងខ្ញុំនេះជាព្រះឥន្ទ្រាធិរាជ យើងទាំងអស់គ្នាជាអាទិទេព" ។ ព្រះបាទនាលៈ កំលើកកបង្គំហើយពោលថា: "ខ្ញុំសូមនមស្សការគោរពព្រះអាទិទេពទាំងអស់" ។ ព្រះអគ្គីញញឹមហើយតបថា: "ល្អហើយ ប៉ុន្តែឯងត្រូវបំពេញកិច្ចមួយឲ្យយើង ឯងធ្វើជាអ្នកនាំសារឲ្យយើង" ។

- "ទោះជាខ្ញុំបក្ខជនមានកិច្ចប្រញាប់ចំពោះការធ្វើដំណើរនេះ ឲ្យដល់ទ្វារគុំណងយ៉ាងណា ក៏ខ្ញុំបង្គំនៅតែស្តាប់បង្គាប់អាទិទេពដែរ តើខ្ញុំព្រះបង្គំត្រូវនាំសារអ្វី? ហើយនឹងត្រូវទៅឯប្រទេសណា?" ។

- ព្រះឥន្ទ្រាធិរាជមានបន្ទូលថា: "យើងមានចិត្តសោមនស្សទទឹងឯងណាស់ អមតក:បុរសមានសេចក្តីស្នេហាចំពោះមតក:នារី ។ យើងបានឮកិត្តិសព្ទនៃព្រះនាងទមយន្តីល្បីល្បាញក្នុងពិភពលោក គេនឹងបើកសន្ទិបាតប្រដុំនៅកន្លែងដែលនាងត្រូវរើសស្វាមីដោយខ្លួនឯង ហើយស្វាមីនៃនាងត្រូវតែជាអាទិទេព" ។ ព្រះបាទនាល:មានព្រះតម្កល់ស្នាំងមួយរំពេច ។ ព្រះឥន្ទ្រាធិរាជមានព្រះបន្ទូលតទៅទៀតថា "ចូរឯងទៅរកក្សត្រីទមយន្តី ហើយទូលព្រះនាងថា: យើងប្រឹងនឹងដំកើងកិត្តិយសនៃព្រះនាងឲ្យស្មើនឹងអាទិទេព ព្រះនាងមិនបាច់ចាំរើសយកមហាពលណាមួយទេ ។ ចូរឯងនិយាយដូចម្តេចឲ្យខាងតែព្រះនាងស្គាល់ច្បាស់នូវកណ្តាលកិច្ចរបស់ព្រះនាង" ។

ព្រះបាទនាល:ស្តេចតែនឹងស្តុតបាត់ស្មារតី ហើយមានព្រះបន្ទូលទាំងភ័យថា: "ឧត្តមអាទិទេព! ខ្ញុំចង់ធ្វើឲ្យទូលបង្គំកើតសេចក្តីលំបាកឬ? ។ ព្រះគុណមិនមែនមិនជ្រាបថា ទូលបង្គំនឹងទៅកន្លែងនោះទេ ព្រះគុណមិនមែនមិនជ្រាបថា ទូលបង្គំស្រឡាញ់ព្រះនាងទមយន្តីទេ បើដូច្នេះតើទូលបង្គំនឹងធ្វើជាអ្នកនាំសារម្តេចបាន?" ថាហើយព្រះអង្គក៏លើកតបង្គំហើយពោលតទៅទៀតថា: "ឧត្តមអាទិទេពដ៏ប្រសើរអើយ! ទូលបង្គំសូមអង្វរកុំឲ្យខ្ញុំប្រើទូលបង្គំទៅកន្លែងនោះ, តើទូល

បង្គំនឹងអាចទៅច្រាប់ស្រីដែលខ្ញុំស្រឡាញ់ថា ឲ្យទៅធ្វើប្រពន្ធអ្នកដទៃទៀតម្តេចបាន?" ។

ព្រះឥន្ទ្រាធិរាជឆ្លើយថា:

- "នែនាល:! ឯងបានទទួលសន្យានឹងយើងហើយ" ។

- ឧព្រះអាទិទេព! ខ្ញុំលបង្គំកើតទុក្ខពន់ពេកណាស់ សូមទ្រង់ប្រោសប្រណី ។

- នាល:ឯង បានទទួលកិច្ចសន្យានឹងយើងហើយ ឯងបានព្រមទទួលស្តាប់បង្គាប់យើង បើដូច្នេះ ឯងត្រូវធ្វើតាមយើង ។

ព្រះបាទនាល: ទ្រង់សំឡឹងព្រះឥន្ទ្រាធិរាជនឹងព្រះអគ្គី ដោយមានទឹកព្រះនេត្រដោរដល់រហាម ហើយក៏ពោលតទៅទៀតថា: "ប្រទេសព្រះបាទកឹម: មានមនុស្សយាមមាំតាំណាស់ តើខ្ញុំលបង្គំនឹងចូលទៅដូចម្តេចបាន?" ។

ព្រះឥន្ទ្រាធិរាជតបថា "ចូរឯងកុំបារម្ភ ទ្វារតាំងប៉ុន្មាននឹងបើកឲ្យឯងស្រាប់។ ស្តាប់តែបង្គាប់យើងចុះ" ។

ព្រះបាទនាល: ដែលទោរទន់ទៅដោយសេចក្តីទុក្ខ ក៏ឆ្លើយដោយសំឡេងខ្សោយៗទៅវិញថា: "ខ្ញុំលបង្គំព្រមស្តាប់បង្គាប់" ។

វគ្គទី ៨

ព្រះបាទនាល: ក៏ធ្វើដំណើរទៅទៀត ប៉ុន្តែទ្រង់ដាក់ព្រះនេត្រចុះដោយមានព្រះហឫទ័យព្រួយខ្លាំងពេក ទោះជាទ្រង់មានចិត្តក្លាហាន

យ៉ាងណាក៏ខ្ញុំមិនអាចនឹងទប់ទឹកព្រះនេត្រយូរបាន ។ ចួនកាលខ្ញុំភ្ញាក់ព្រះអង្គដល់ទៅខ្ញុំព្រះករុណាយ៉ាងខ្លាំងផង ។ ក្រោយមកខ្ញុំក៏បានដល់ទៅប្រទេសព្រះបាទកិមៈ ខ្ញុំក៏យាងចូលទៅ ពួកឆ្មាំទ្វារគ្មានឃាត់ខ្ញុំសោះ ហើយហាក់ដូចជាគ្មានទាំងឃើញខ្ញុំផង ទ្វារទាំងប៉ុន្មានក៏បើកថ្វាយខ្ញុំឯង មានបន្ទប់ខ្លះទំនេរស្អាត មានបន្ទប់ខ្លះទៀត មានពួកចៅចមនឹងអ្នកបំរើអង្គុយត្រៀបត្រា ព្រះបាទនាលៈខ្ញុំយាងកាត់បន្ទប់ទាំងនោះដោយគ្មានអ្នកណានិយាយរកខ្ញុំ ១ ម៉ាត់សោះ ខ្ញុំក៏នឹកថាព្រះអាទិទេពបានបំបាំងខ្លួនអញកុំឲ្យមើលឃើញ ។ ព្រះកិជាចេញផុតពីទ្វារមួយក្រោយបង្អស់ ហើយខ្ញុំយាងចូលទៅក្នុងព្រះភជនវិមាន ។ ព្រះអង្គខ្ញុំយាងត្រសាល បន្តិចស្រាប់តែខ្ញុំក្រឡេកឃើញនៅទីគុម្ពជាមួយ ស្រីៗលេងសើចរបល់ ។ ខ្ញុំក៏គ្រាប់សំដៅទៅហ្វូងស្រី។ ដែលខ្ញុំឥតស្គាល់ជាព្រះនាងទមយន្តីនៅជាកណ្តាល ។ ព្រះអង្គខ្ញុំព្រះករុណាដោយមានសេចក្តីស្នេហា នឹងសេចក្តីត្រេកអរផង ដោយទឹកឃើញកិច្ចសន្យាជាមួយនឹងព្រះឥន្ទផង ហើយនឹងនឹកព្រួយជាខ្លាំងផង ។ ព្រះនាងទមយន្តីក្រឡេកឃើញស្គាល់ជាព្រះបាទនាលៈ ពីព្រោះព្រះអាទិទេពលែងបំបាំងទៀតហើយ ។ ព្រះនាងភ្ញាក់សំរែកដោយសេចក្តីអរពេក ប៉ុន្តែព្រះនាងមិនរត់ទេ ខ្ញុំឈានពីរបីជំហានទៅជិតព្រះអង្គ ហើយខ្ញុំថយមកវិញ ព្រោះព្រះនាងខ្ញុំញញើត ខ្ញុំមិន

ហ៊ានមានព្រះបន្ទូលទៅកាន់ព្រះអង្គមុនទេ ប៉ុន្តែទឹមព្រះនេត្រព្រះនាងហើយ ឡើងឯងយ៉ាងច្បាស់ស្រស់ ។ ព្រះចុតនាល:លែងទ្រង់ព្រះកន្សែងសោះ ព្រោះទ្រង់ទំបង្ហាញសេចក្តីទុក្ខរបស់ព្រះអង្គ ហើយទំដំរង់គោរពកិច្ចសន្យា ។ បន្ទាប់មកព្រះនាងទមយន្តីទំដំឡើងសេចក្តីក្លាហាន ហើយមានព្រះបន្ទូលសួរទៅព្រះពជាថា " ព្រះអង្គដែលមានរូបឆោមលោមពណ៌គួរឲ្យចេតនា តើព្រះអង្គជាអ្វី? ស្តេចយាងមកពីប្រទេសណា? ព្រះនាមអ្វី?" ។ ព្រះចុតនាល:ត្រាស់តបថា: ទ្រព្រះនាងដ៏ល្អវិសេស! ខ្ញុំឈ្មោះនាល: ។

ព្រះនាងមានបន្ទូលដោយរីករាយថា "ខ្ញុំម្ចាស់ស្គាល់ហើយ ខ្ញុំម្ចាស់នៅចាំតែព្រះអង្គទេតើ" ថាហើយព្រះនាងទះព្រះហស្តទ្រង់ព្រះសំរួលយ៉ាងវែង ដែលមានព្រះសូរសៀងដូចជាគេច្រៀង ។

ព្រះចុតនាល:មានបន្ទូលតទៅទៀតដោយមានសំឡេងមាំថា: "ខ្ញុំជាអ្នកនាំសារនៃអាទិទេពទេ ។ ព្រះឥន្ទ្រាធិរាជ ព្រះអគ្គីនឹងព្រះវរុណ (Varuna) ទាំងបីអង្គនេះបានព្រះនាងធ្វើជាឯកអគ្គមហេសី ។ ព្រះនាងត្រូវរើសយកអាទិទេពណាមួយជាស្វាមីក្នុងអាទិទេពទាំងអស់នេះ សូមព្រះនាងបំពេញព្រះទ័យនៃអាទិទេពកុំខាន ទ! ព្រះនាងដែលមានរូបឆោមធ្វើឲ្យខ្ញុំពិលភ្នែក! ឥឡូវនេះ ខ្ញុំបានបំពេញកិច្ចខ្ញុំរួចហើយ" ។ ព្រះពជាក៏ទ្រង់យាងចេញត្រឡប់មកវិញ ព្រោះព្រះអង្គខ្លាចត្រែងនៅ

យូរទៅក្នុងគំនិត ។ ប៉ុន្តែព្រះនាងឃាត់ព្រះអង្គថា: "ទេ! ទេ! កុំស្តេចត្រឡប់ទៅវិញ" ព្រះនាងទ្រង់ញញឹម ហើយមានបន្ទូលតទៅទៀតថា: "ខ្ញុំម្ចាស់សុខចិត្តទទួលព្រះអង្គជាអ្នកនាំសារនៃសេចក្តីស្នេហា ប៉ុន្តែព្រះអង្គត្រូវតែងជាអ្នកនាំសាររបស់ព្រះអង្គឯងទៅវិញ ។ ខ្ញុំម្ចាស់មិនក្លេចនូវសេចក្តីពណ៌នារបស់ក្មួនថ្លៃទេ ព្រះពជ្រសន្ទិបាតនេះកើតឡើងសម្រាប់តែព្រះអង្គប៉ុណ្ណោះ ។ សូមព្រះអង្គកាន់តក្តីភាពចំពោះខ្ញុំម្ចាស់ ដូចជាខ្ញុំម្ចាស់ប្រតិត្តចំពោះទ្រង់ ។ សូមព្រះអង្គស្រឡាញ់ខ្ញុំម្ចាស់ ដូចជាខ្ញុំម្ចាស់ស្រឡាញ់ចំពោះទ្រង់" ។

ព្រះបាទនាល: ឆ្លើយដោយរំជួលព្រះទ័យខ្លាំងថា: "តើនៅក្នុងចំណោមអាទិទេព ព្រះនាងនឹងអាចរើសយកមនុស្សជាស្វាមី បានដែរឬ?" ។

– បើព្រះអង្គបោះបង់ខ្ញុំម្ចាស់។ នឹងស្លាប់ដោយថ្នាំពុល ដោយក្តៅខ្លួ ឬដោយទឹក . . . ។ ខ្ញុំម្ចាស់មិនដឹងជាស្លាប់នឹងភ្លើទេ ប៉ុន្តែខ្ញុំម្ចាស់នឹងស្លាប់ពុំខាន ។

– សូមព្រះនាងកុំធ្វើឲ្យនាយកនៃពិភពលោកអាក់អន់ស្រពន់ព្រះទ័យ កុំឲ្យលោកតាមផ្តន្ទាដោយព្រះក្រោធ ។ សូមព្រះនាងនឹកដល់សេចក្តីស្រួល សេចក្តីសប្បាយដែលព្រះនាងស្នប់ខ្ចីមសិន ។ ព្រះកេសានៃព្រះនាងនឹងក្លាយជាខ្មៅ ប្រសិនបើព្រះនាងនឹងទ្រង់

សុទ្ធតែព្រះពស្ត្រដ៏មានវស្ត្រកំរីតែចេះ ។ ព្រះនាងទមយន្តី! សូមព្រះនាងទ្រង់ព្រះសណ្តាប់ខ្ញុំ : កុំព្រះនាងរត់ទៅរកនូវសេចក្តីវិនាសឡើយ ។

- ព្រះអគ្គនាល: ខ្ញុំម្ចាស់នឹងនៅគាបគោរពចំពោះព្រះកត្តិព្រះអាទិទេព ហើយខ្ញុំម្ចាស់នឹងរើសយកព្រះអង្គជាស្វាមី ។

ព្រះបាទនាល: ទ្រង់ព្រះសណ្តាប់នូវបន្ទូលព្រះនាងហើយ កំមានព្រះអង្គញ័រចំប្រប់ដោយសេចក្តីស្នេហាដុតពោលព្រះអង្គ, ព្រះអង្គមានសេចក្តីសង្ឃឹមឡើងវិញ តើព្រះអង្គនឹងប្រមាថអាទិទេពឬ? ហើយទ្រង់បញ្ចេញសេចក្តីត្រែកអរថា: "តែប៉ុណ្ណោះបានការណ៍ហើយ អាទិទេពនឹងមិនចោទប្រកាន់ដល់អញឡើយ ព្រោះអញគ្មានប្រព្រឹត្តកំរត់ចំពោះលោកទេ អញខំអត់ធ្មត់បាន ហើយចេះខំការពារលោកដោយគ្មានបណ្តាយចិត្តឲ្យទន់សោះ ។ អញបានធ្វើផ្ទុយនឹងចិត្តអញ ណ្តើយព្រះនាងកុំមានបន្ទូលអ្វីទៀត, ឱព្រះនាងទមយន្តីជាឆ្នើមចិត្តតែមួយរបស់ខ្ញុំ! ចូរនាងធ្វើតាមតែព្រះទ័យនាងចុះ" ។

ប៉ុន្តែ ព្រះនាងនៅតែឃាត់ស្តេចទៀតថា: "យើងខំធំពីរនាក់នឹងសប្បាយចិត្តដូចគ្នា ។ សូមទ្រង់យាងទៅឯព្រះពជសន្ទិប្បាតកុំខាន ទោះអាទិទេពយាងមកចាំងអស់ក្តី ហើយខ្ញុំម្ចាស់នឹងរើសយកអ្នកណា ដែលខ្ញុំម្ចាស់ត្រូវចិត្ត ទោះជាទេវតានៅស្ថានសួគ៌ក្តី ជាមនុស្សលោកក្តីក៏ពុំហានមកបន្ទោសខ្ញុំម្ចាស់ឡើយ" ។

(មានត)

ដំណើរអស្ចារ្យនៃលោកក៉ាស្ទ័យយេ

លោកយូកូតូស៊ី រៀបរៀង

លោករ៉ាយ-ប៊ុក ក្រមការ

ប្រែពីភាសាចាំងមកជាភាសាខ្មែរ

(តមក)

២.— ជំណើរទៅកាន់សម្បូណ៌ប្រទេស

(Pays d'Abondance)

លោកក៉ាស្ទ័យយេ បានបណ្តាយឲ្យសត្វក្រសារនោះហោះទៅលើអាកាសតាមទំនើងចិត្ត ចម្ងាយប្រហែលម្ភៃឬសាមសិបពាន់យោជន៍ ។ ដល់អវសាន, លោកបានអញ្ជើញទៅដល់ក្រៃទេសមួយទៀត, លោកក៏ចាញ្រក្រសារឲ្យចុះទៅទីនោះ ។ លោកបានឃើញមនុស្សជាច្រើនស្ទើរតែពាក់ស្អាតបាត ហើយមានទ្រង់ទ្រាយសមរម្យជាងអមតបុរី ។ គេមិនបានឃើញពួកទុគ្គិតអត់ឃ្លានឡើយ ។

នៅក្នុងព្រះរាជធានីនៃប្រទេសនោះ លោកបានឃើញស្ពានមួយមានបង្អាន់ដៃលាបច្រែងភ្លៅស្រាបច្រាក់ ។ គេហដ្ឋានតាំងអស់មានសុទ្ធតែ ។ ខ្លាននាងផ្លូវភ្នាត់ខ្វែង ក្រាលសុទ្ធតែច្រាក់នឹងមាសមានជណ្តើរចុះឡើងធ្វើពីអង្កាំ : គេហដ្ឋានតាំងអស់មានសសរចនាដោយត្បូងមានពណ៌ក្រូចាំងវែង (agathe) ផ្ទាំងធ្វើនឹងត្បូងខៀវដូចមេឃស្រស់ (lapis lazuli)

ហើយមានក្រដាសំណាញ់ធ្វើពីផ្កាថ្ម, មានគ្រាវលាបថ្នែងក្រហម, មានរបងច្បាក់ ។ ពាណិជ្ជស្ថាន មានកាំងនក្រហមឆ្អៅ មានឆ្កាងជាអក្សរមាសនូវនាមត្រមាំងពាក្យថា "តម្លៃលែងប្រែប្រួល" ឬ "លក់ឲ្យច្រើនដល់ដៃ" ប៉ាក់ជារង្វង់ខ្វែងមូល ។ លោកវ៉ាស្កូប៉ីយូយេ ស្មានថាលោកទៅដល់ស្ថានសួគ៌ហើយ បានសួរនាយពាណិជ្ជម្នាក់អំពីនាមនៃប្រទេសនេះ ។ ក្នុងពេលនោះ មានមនុស្សតីរឫបីនាក់ ស្លៀកពាក់ដោយសម្បុរណិកាព ហើយមានទ្រង់ទ្រាយសមរម្យសួរលោកថា "អញ្ជើញមកពីប្រទេសណា?" ។ ដល់លោកមានប្រសាសន៍ថា លោកមកពីប្រទេសជប៉ុន ។ អ្នកម្ចាស់ផ្ទះទុកចិត្តឥតសង្ស័យ ទើបស្រែកសួរថា: "អ្នកអញ្ជើញមកពីប្រទេសនោះ ដែលមានសុទ្ធតែមនុស្សសុចរិតដូចជាមនុស្សនៅក្នុងប្រទេសចិនដែរឬ? ខ្ញុំមានចិត្តសង្ឃឹមថាលោកមុខជាអញ្ជើញទៅនៅគេហដ្ឋានរបស់ខ្ញុំ ក្នុងពេលដែលលោកនៅក្នុងសម្បុណិប្រទេសនេះ ហើយលោកមុខជាមានប្រសាសន៍ពីដំណើរបស់លោកដែលមកកាន់ទីនេះច្បាប់យើងផងមិនខាន" ។

លោកវ៉ាស្កូប៉ីយូយេ បានស្ថិតនៅក្នុងប្រទេសនេះ រាងសាមសិបឆ្នាំព្យាយាមស្រាវជ្រាវនូវទំនៀមទម្លាប់ប្រពៃណីនៃប្រទេសនេះ ដែលគ្មានអ្នកណារកស៊ីធ្វើការអ្វីសោះឡើយ ។ ស្រូវសាលី, សណ្តែកដុះពាសពេញច្រើនជាអនេក គ្មានអ្នកណាដាំ, ថៃតាំរក្សាទេ ។ អ្នកតាំង

អស់អាចយកមកប្រើប្រាស់បានតាមចិត្ត គេអាចយកទឹកពីទុកយន្ត (មូរនៃទឹក) មកបរិភោគបាន ។ មានស្មៅច្រៃហូរចុះពីលើឯដីភ្នំ, ច្រនេះបង្កើតស្រោបថ្មដូចជាស្រែ (lichens), ចំណែកខាងខ្លែន ដុះដូចដើមត្រែងពាសពេញចំងាំ, ត្រពាំងដែលច្រមូលហូរចូលទៅនឹងខ្ទេស្រែ ទំពាំងបាយដូរ មានដើងពានអណ្តែតជាច្រើន ។ មានគុម្ពោតបន្លែដុះទៅក្នុងចម្ការស្តុកដុំ, ត្រពាំងស្រោងធ្វើពីផ្ទៃឈើខ្ពុំ ត្រពាំងស្រោសក្តេ (saké) ច្រកពុមេ៉យ ។ មាសច្រាក់មានពាសពេញទៅតាមឯព្រាប់ស្មឹង ព្រមទាំងត្បូងខ្លែវផ្ទៃមេយ ត្បូងគ្រប់ពណ៌ ផ្កាថ្មដែលលំបាកតែរើសប៉ុណ្ណោះ ។ គេបានឃើញមានគុម្ពោតឈើ មានសុទ្ធតែនំហើយនឹងរុក្ខជាតិតូចៗ ល្អ មានផ្លែពាល់ឆ្ងាំ សុទ្ធតែដំណាប់វែង ។ គេស្តាប់ឮសត្វសូរពីពេះអស្ចារ្យ ក្នុងទិវាយ:រដូវ, របងទាំងប៉ុន្មានទៅជាមានផ្កាសុទ្ធតែកំណាត់សំពត់ទឹកខ្មែរពោះគោ ។ ចំណែកខាងគីរីវិញ មានដើមឈើសូត្រដុះពាសពេញ ហើយមានស្មឹករចនាច្រមូលជាអាវវែងប៉ាក់ ច្រៃសភាតទៅតាមរដូវ ហើយច្រជាកស្តុកចូលមករើសយកទៅពាក់តាមត្រកោរ ។ ច្រជាកស្តុកទៅច្រទេសនេះ សម្បូណិដោយគោគ្រឿងគ្រប់បែបគ្រប់យ៉ាង, មិនមានច្រាថ្មាបង់បានអ្វីទៀត, តែសូមកុំឲ្យព្យុះសង្ឃរាមកបំផ្លាញប្តូរទៅក្នុងទន្សាន, ហើយគ្មានព្រួយបារម្ភអ្វីគ្មានតែព្រួយនឹងពពកចាំងលំអងៃព្រះចន្ទប៉ុណ្ណោះ ។

នៅក្នុងប្រទេសនេះសុខស្រួលគ្មានសេចក្តីក្រខ្សត់ ទាំងគ្មានលំបាកនឹងធ្វើកិច្ចការទាំងពួងទេ, លោកវ៉ាស្ប៊ុយយ៉ូយ បានដើរលេងកំសាន្តសប្បាយរាល់ថ្ងៃជាមួយនឹងមិត្តរបស់លោកបួនប្រាំនាក់ ហើយបរិភោគម្ហូបអាហារទៅតាមរាល់ស្រែ ហើយមានតែវត្តធ្វើឲ្យរីករាយនៅដុំវិញខ្លួន ។

ប៉ុន្តែពីរបីឆ្នាំមុន មានពួកវិញ្ញាជនមកពីប្រទេសឥណ្ឌា ហើយបានបង្ហាត់បង្រៀនប្រជាពលរដ្ឋក្នុងប្រទេសនេះ អំពីលទ្ធិខាងពួកសន្តបុគ្គលថា: "សេចក្តីសប្បាយរបស់មនុស្សមកពីមានទុក្ខ, ដីវភាពរបស់មនុស្សដែលសុខស្រួលទៅបាន មកពីអ្នកត្រូវប្រាថ្នាចង់មាន និងមកពីពួកសាមញ្ញជន ចង់ឡើងទៅកាន់ឋានៈខ្ពស់ក្នុងសង្គម; ការសប្បាយបំផុតនៅត្រង់កិច្ចព្យាយាមទៅរកវត្ថុមួយ ដែលមិនងាយអ្នកណាបានទៅដល់ព្រោះសុភមង្គលពិតស្ថិតនៅតែក្នុងប្រទេសណា ដែលមានស្ថានភាពស្ថិតនៅជាកណ្តាល រវាងសេចក្តីក្រនឹងសេចក្តីមាន; សេចក្តីក្រដែលរាំងកមនុស្សមិនឲ្យប្រព្រឹត្តជ្រុលមកហើយកិច្ចដែលចង់សប្បាយ ដោយចង់បរិភោគអាហារឆ្ងាញ់ ឬចង់ស្លៀកពាក់ខោអាវថ្មី ត្រូវគិតដល់ការលំបាកក្នុងកិច្ចស្វែងរកទ្រព្យសម្បត្តិ" ។ លទ្ធិទាំងនេះ នាំឲ្យប្រជាពលរដ្ឋនៅសម្បូណ៌ប្រទេស រំតើបញ្ចាប់ញ័រជាខ្លាំង ហើយពួកនេះទៅជាស្រក់ទឹកភ្នែកដោយចិត្តគិតថា ខ្លួនមិនដែលជួបប្រទះនឹងសេចក្តីលំបាកសោះ ។ ព្រោះហេតុដូចនេះ បានជាប្រជាពលរដ្ឋនៅប្រទេសនេះ

ចានមាំគ្នាស្អាតព្រះវិហារមួយជំនួសយទៅក្នុងភូមិក្រៅ នៃព្រះពុទ្ធសាន៍ ហើយគេគោរពព្រះអាទិទេពនៃទុគ្គតភាព (le Dieu de la pauvreté) ។ ក្នុងថ្ងៃចូលឆ្នាំជាបឋមនឹងក្នុងថ្ងៃបុណ្យធំៗ គេតែងសូត្រធម៌សូមឲ្យព្រះអាទិទេពនេះ នាំសេចក្តីក្រឡត់មកឲ្យ, ហើយដល់ថ្ងៃអាសាឍចូលឆ្នាំ គេព្យាយាមដេញចេញពីគេហដ្ឋាន នូវព្រះអាទិទេពចាំងនឹងជាំពីរអង្គនៃសុភមង្គលនឹងជោគជ័យសិនាល្អ, តែកិច្ចចាំងនេះមិនបានផល; ប្រជារាស្ត្រក្នុងប្រទេសនេះនៅតែមានភោគទ្រព្យដដែល ។ ពួកជនចាំងនេះគ្មានចិត្តសប្បាយរីករាយនឹងការសម្បូណ៌សប្បាយសោះ ។ លោកប៉ាសូប៉ីយូយេអង្គុកខ្ចាំងហើយកំលោអ្នកម្ចាស់ផ្ទះជិះក្រសារហោះតម្រង់ទៅទិសបស្ចឹម ។

គតិអ្នកធិពន្ធ

ពួកនេសាទដែលរកទទួលទានចិញ្ចឹមជីវិតកណ្តាលសមុទ្រ មិនមែនជាអ្នកលំបាកទេ, ហើយមនុស្សនៅតាមលើត្រែដែលមានតម្រាលសំពត់សូត្រប៉ាក់ដោយមាសប្រាក់ មិនមែនសុទ្ធតែជាអ្នកសុខស្រួលសប្បាយឡើយ ។ សុខហើយនឹងទុក្ខមិនមែនមកពីមានភោគទ្រព្យនឹងក្រសម្បត្តិទេ ។ អ្នកណាដែលប្រព្រឹត្តធ្វើបុណ្យកុសល អ្នកនោះឯងសុខសប្បាយ ។ អ្នកក្រ (ពួកទុគ្គតបុរស) អាចស្វែងរកនូវសុភមង្គលបាន បើអ្នកនោះព្យាយាមធ្វើការឲ្យពេញកំឡាំង ហើយអាចសម្រេចកិច្ចនោះទៅតាមវត្ថុបំណងក្នុងជីវភាពទៅតាមលក្ខខ័ណ្ឌរបស់ខ្លួន; តែអ្នកណាដែល

គ្មានបំពេញការណ៍យកិច្ចរបស់ខ្លួនហើយរស់នៅក្នុងដីវិភាព ប្រកបដោយ
កាមារម្មណ៍នឹងតណ្ហាច្រើនថ្មាមិនចេះឆ្អែតស្កប់ស្កល់ ទាំងមានទុក្ខសោកស័
ចោមរោមជាបរិវារ អ្នកនោះមិនគាន់ឈ្មោះថាសុខសប្បាយទេ ។
សប្បាយមកពីលំបាកហើយលំបាកមកពីសប្បាយ ។ ទឹកស្ងឹងដែលហូរ
មានសភាពបរិសុទ្ធស្អាត, ទឹកដែលនឹងមិនហូរ ច្រើនល្អក់ខ្វក់ខ្វល់ ។
បក្សា, មច្ឆជាតិ, ខ្ទុកសត្វ (Insectes) ព្យាយាមរកចំណីអាហារមក
ទុក ព្រោះគ្មានវត្ថុអ្វីនឹងបរិភោគ, ពួកសត្វទាំងអស់នោះធ្វើការគ្មានឈប់
ឈរអ្វីឡើយ, ព្រោះហេតុដូចនេះបានជាសត្វទាំងអស់នោះរស់នៅជាសុខ
សប្បាយ ។ តែពួកបសុសត្វ; សេះ, ឆ្កែ, ឆ្មា, មាន់, ទា ដែល
គេចិញ្ចឹម ទៅជាមានជម្ងឺច្រើន ព្រោះសត្វទាំងនោះរស់នៅឥតបានធ្វើ
ការអ្វីឡើយ ។ ដោយមនុស្សចេះស្វែងរកអាហារនឹងសំពត់ខោអាវបំរុង
ទុកបរិភោគនឹងស្ងៀតពាក់ បានជាមនុស្សបង្ហាញខ្លួនវិសភាពថ្លៃថ្លាជាង
សត្វតិរច្ឆាន ។ អ្នកមានច្រើនស្ងៀតពាក់ខោអាវនឹងបរិភោគអាហារមិន
ដឹងប្រមាណ, ព្រោះហេតុដូចនេះ ទើបជាអ្នកមានច្រើនមានជម្ងឺ ។ ប្រាជ្ញា
បើមិនព្យាយាមទេទៅជាមានសភាពអន់ថយ; រូបកាយមិនហាត់ទៅជា
ខ្សោយ មានអាពាធ ។ បើខ្ទុកជាមានកោតខ្លាចយ៉ាងណាក៏ត្រូវតែធ្វើការ
ដូចជាអ្នកក្រខ្សត់ដែរ ទើបហើយដែលជាឧសថសម្រាប់ធ្វើកាយឲ្យមាន
សុខភាពដ៏បរិបូណ៌ត្រមាំចិត្តប្រកបដោយហាសនៈរីករាយតាមត្រូវការ ។

(មានត)

ដំណឹងតាមខ្សែក្នុងស្រុក:

លោក ផេង-ជ្រឿ សាស្ត្រាចារ្យនៅសាលាភ្នំពេញ

ប្រែពីភាសាចាំងមកជាភាសាខ្មែរ

(តមក)

លោកអៃយ៉ាដជាបិតា ក្រែឡេកឃើញកូនលោកមានការផ្លាស់ប្តូរកិរិយាដូច្នោះ ក៏ភ្ញាក់ខ្លួនឡើង ប្រហែលលោកតូចចិត្តខ្លាំងណាស់ដោយគិតថា កូនលោកគ្រាន់តែឃ្លាតពីស្រុកប៉ុន្មានឆ្នាំ ស្រាប់តែលះបង់ចំនៀមទុកម្តាយចោលអស់ ។

លោកអៃយ៉ាដមានដន្ទាយុជិតចិតសិបឆ្នាំហើយ លោកជឹងថា ខ្លួនលោកបានរស់នៅជាយូរអង្វែងហើយ ប្រហែលមិននៅរស់បានប៉ុន្មានទៀតឡើយ ។ តើពាក្យថ្នឹងឆ្ងាញ់ប្លែកទេ? តើលោកនឹងបានឃើញសម័យថ្មីនេះ មុនពេលដែលទៅកាន់ទីសម្រាកឥតវិលត្រឡប់ឬទេ? ។

លោកមិនហ៊ានថ្លែងមុនសេចក្តីយល់ ចាំងមិនហ៊ានធ្វើយ ក្រាប់ការណ៍ពិតការណ៍មែន ប៉ុន្តែបើតាមហេតុកេទស្រុក ហាក់ដូចជាបំរុងនឹងត្រូវតាមសេចក្តីយល់ដំណឹងអតីតកិច្ចហើយ ។ លោកអៃយ៉ាដជាអ្នកតេក ខ្ចាចក្រែងការសង្ឃឹមរបស់លោកតើតអុកឡុកនូវបណ្តាគំនិតអាក្រក់នៃពួកអ៊ីរុប កងវៀលមុនលោកអនិច្ចកម្ម ។

ដោយអំណាចសប្បុរសធម៌នឹងការពិសោធន៍ក្នុងដីវភាពដែលលោកបានសន្សំ នឹងបានប្រទេតាំងពីសក់ខ្មៅដល់សក់ស លោកមិនបានសំដែងអាការមិនពេញចិត្តចំពោះការផ្លាស់ប្តូរទំនៀមទម្លាប់នឹងសេចក្តីស្នេហាជាស្ងាត់ ។ ចំពោះប្រទេសបច្ចុប្បន្ន របស់កូនប្តីនិងលោក ឲ្យយើញជាក់ច្បាស់ឡើយ ។ លោកមានសាសនាមហាម៉ូតជាពិតនឹង ជាសាសនាមួយខាងបូពាប្រទេស ដែលគេសន្មតទុកថាប្រកពនៃសប្បុរសធម៌នឹងជាទំបាយដ៏ពិតខ្លឹងត្រង់សម្រាប់ខ្លួនទៅកាន់ស្ថានសុគតិបាន ។ លោកយល់ច្បាស់ថា ដីវភាពតែងដឹកនាំមនុស្សខាំងឲ្យ ហើយគ្មានអ្នកណាអាចទប់ទល់នឹងហេតុគេបានឡើយ បើចង់សុខ គ្រាន់តែកុំព្រួយរវល់នឹងការណ៍នោះតេកក៏បានហើយ ។

លោកតែងមានប្រសាសន៍ជាញឹកញយថា អ្វីដែលត្រូវមាន គង់នឹងមានមកដល់, សូមឲ្យបំណងនៃព្រះអាឡស់បានសម្រេច ហើយយើងគ្រប់គ្នាត្រូវថ្វាយពរចំពោះព្រះអង្គ ដែលបានសំដែងនូវហេតុគេឲ្យយើងយើញ ។

មានមនុស្សជាច្រើនដែលមានសេចក្តីខ្ពស់ខ្ពែនាជាងយើង គឺអ្នកគ្រដើរសូមអង្គុយសូមបាយនំ តាមផ្លូវដើម្បីបង្ខំនូវការស្រេកឃ្លាន ។

ពួកមិត្តភក្តិ ពុកមាត់ស្រមូមដែលអង្គុយរាល់ថ្ងៃជិតក្បាលគ្រែមគ្មានខ្លួលតាមយោបល់លោកនៃយ៉ាង ។ ជនទាំងនោះជានិច្ចចាស់ស្រុក

ជាបរិស័ទចិត្តស្មោះត្រង់ចំពោះព្រះអាឡស់ ជាមនុស្សសុចរិតហើយមានច្បាប់ប្រកាន់លទ្ធិថា ក្នុងដីវិកាពមិនត្រូវឲ្យខុសទៅលើឈ្មោះណា ។ ពួកពស្តីប្រជា តាំងពីអ្នកមានសម្បត្តិទ្រព្យ រហូតដល់អ្នកក្រខ្សត់តែងពប់អានជនចាស់ស្រុកតាំងនោះ ហើយនាំគ្នាលើកតំកើងលទ្ធិនោះថាជាលទ្ធិឧត្តុង្គឧត្តម ។

ពួកចាស់ព្រឹទ្ធាចារ្យក្នុងស្រុកតាំងប៉ុន្មានទាក់ តែងមកប្រជុំគ្នានៅវេហៃថ្ងៃរសៀលទៅកន្លែងទទួលភ្ញៀវ ក្នុងផ្ទះលោកអែយ៉ាជ កាលណាវស្ទីព្រះអាទិត្យចាំងមកយ៉ាងក្តៅលើដី ធ្វើឲ្យសូរសំឡេងតាំងពួងស្ងៀមស្ងាត់ឈឹង ដូចសម្ងុនវេលាស្ងប់ឃ្លាំ ។ កន្លែងនោះគឺជាបន្ទប់មួយដ៏ធំទូលាយ ដែលបង្អួចសំណាញ់បើកចំទៅលើសួនមួយសុទ្ធតែដើមគ្រោតនឹងផ្កាកូឡាបដើម ។ ជញ្ជាំងជុំងដោយព្រំដ៏មានតម្លៃដែលតូញជាព្រៃឈើនឹងសរសៃសូត្រពណ៌លឿងខ្ចី លាយចំរុះនឹងសំពត់កាំម៉ីពណ៌ក្រហម មានបក្សីបក្សាពណ៌យ៉ាងឆើតហើរឆ្លៀលឆ្លាត់ប្រចឹកគ្នាខាងក្នុង ។ ព្រំនេះគេទិញមកពីប្រទេសស្ពឺណ៏ ។ ឯពិតានមានចង្កៀងគោមស្តាន់ធំៗ ភ្លឺចាំងអុជសុទ្ធតែប្រេងក្រអូបព្យួរសំគោកមក ។

នៅឯក្រោម លើឥដ្ឋ គ្រាលសុទ្ធតែព្រំនឹងកន្ទេលក្រហមពាសពេញដោយខ្នើយ: ខ្នើយកែប ខ្នើយកូន ខ្នើយច្បាក់ថាវ ទំនឹងពួកខ្នាប់តូចធំ ហើយមានមនុស្សបំរើម្នាក់ចាស់ឈ្មោះតាឡប ចិត្តស្មោះត្រង់ចំពោះ

នាយចៅហ្វាយ នៅទីឯផ្ទះលោកអៃយ៉ាដតាំងពីកើតដល់ធំមិនដែលឃ្លាតចេញទៅណា ជាអ្នកបំរើខាងទឹកតែ ឬនៈ ធ្លើផ្ទៃដុំក្រក ផ្ទៃក្រូចពោធិ៍សាត់ជាក់ក្នុងតែវពែងចរណៃទឹងនំផ្សែង ។ ជាក់ក្នុងចានទៀបសង្ឃាំងយកមកតម្រៀបលើតុៈមួយចាប ក្រហមក្រមៅរិចិត្រដោយក្បាច់រចនាទឹងក្ងុក ។

ក្នុងវេលាដែលពួកមិត្តសំឡាញ់កំពុងនាំគ្នាបរិភោគនឹងផឹកឬនៈ ស្តៅឬត្រជាក់ទឹងនំមានឧជារស លោកអៃយ៉ាដតង្គុយជាក់ខ្សៀវទឹកក្រអូបបង្ហុយផ្សែងកុយ ។ ផ្សែងនោះមិនយូរប៉ុន្មានក៏ហុយទៅជួបហើយលាយឡំជាមួយផ្សែងខ្ទឹមចន្ទន៍ក្រស្នា ដែលបំពាក់ក្នុងហិនឡូវស្ងាន់ជានិច្ចកាលតាំងពីព្រលឹមដល់ថ្ងៃលិច ។

លុះផឹកស៊ីរួចហើយ ក្មេវតាំងនោះនាំគ្នាដំណាលរឿងផ្សេង ។ ច្រើនយករឿងជាតិគាប់ចិត្តនៃខ្លួនមកពិ៉ាយរ៉ាប់ គឺចូលចិត្តលើកយករឿងចាស់ៗពីឆ្នាំមុន ។ រឿងពីកាលខ្លួននៅក្មេង ។ មកប្រៀបធៀបទឹងរឿងសម័យបច្ចុប្បន្ន ហើយឃើញថាសម័យពីបុរាណបានសុខសប្បាយជាង ។ ជនតាំងនេះដែលពោលរឿងអស់នេះ ច្រើនប្រើសំដីសុភាពស្ទើម។ ស្ទើរដូចរូបអ្នកគា មិនសំដែងគាកាកៃម្រើកដៃដើងឡើយ ប្រហែលគ្នាទឹងអ្នកស្ទឹងស្ទាដ៏ហើយបានសម្រេចមគ្គផល ទឹងបានស្ថានបរមសុខទុតចាកកង្វល់កងលោក ។

*
* *

ថ្ងៃនោះ រស្មីមេដាកូនប្រុសរបស់សំឡាញ់លោកអៃយ៉ាដទើបនឹងចូលមកកន្លែងជ្រកដុំ, ខាងក្រោយដែលបានធ្វើគារវកិច្ចចំពោះចាស់ព្រឹទ្ធាចារ្យរួចហើយ រស្មីមេក៏ទៅអង្គុយក្បែរមុត្តាជាសំឡាញ់ ។ អ៊ីស្មាអ៊ីលក៏ចូលមកកន្លែងបន្ទប់នោះដែរ ។

អ៊ីស្មាអ៊ីលស្វែកញាក់ឯកសណ្ឋានតាហានេះ ក្រឡាចត្រង្គខ្មៅយ៉ាងសង្ហាស័ក្តិសម ដៃភាក់ស្រោមកាន់កាតិបមួយលំអដោយសែសយ ច្បាក់ ទឹងកាន់រំពាត់វែងតែមួយផង ។ គេទុនគំនាប់ជារបៀបអាប៉ាប់ដល់ខ្ទុកគេជាមុន គឺយកដៃជាក់ត្រង់ថ្ងាស ហើយជាក់ត្រង់បបូរមាត់ រួចស្អាបត្រង់បេះដូងជាទីបំផុត ។ រួចពីគារវកិច្ចចំពោះខ្ទុក គេចាប់គំនាប់ក្បែរជាបន្ទាប់ បែរវិលដុំវិញ ១ខនហើយសុះភ្លែតទៅអង្គុយច្រកក្បែរលើកូនកៅអីឫស្សីមួយដែលជាក់នៅក្បែរជញ្ជាំង ។

ខណៈនោះ បរិយាកាសពេញដោយរហស្សភាព ហាក់ដូចជាដំណើរដែលអ៊ីស្មាអ៊ីលចូលមក បណ្តាលឲ្យសុះការចរចារវាងពួកក្បែរតាំងអស់មិនឲ្យនិយាយរួច ។

ពួកក្បែរតាំងអស់ ឈប់ខ្វល់ស្គាល់អ៊ីស្មាអ៊ីលដែលស្វែកញាក់ជាបែបបាហានេះយ៉ាងស័ក្តិសម ពង់ស្តើង ថាជាមនុស្សមានសញ្ជាតិជាមួយ, តែដែលតាមការពិត មនុស្សក្នុងទីជ្រដុំនោះសុទ្ធតែមានសញ្ជាតិតែមួយ គឺសុទ្ធជាអ្នកផឹកទឹកតែក្រអូប តាំងស្មែកសំពត់ដោយរុំដូចៗគ្នា ។

អ៊ីស្មាអ៊ីល មាត់ប៉មមានសាច់ហើយឡើងក្រហម ច្រមុះត្រង់ស្អួច បបូរមាត់ចង្អាន់ចង្អាល់គោរយ៉ាងរលើង មានជាក់មេរ៉ាស្តើងព្រាល ។ ដើម្បីចំបាត់ស្រមោលខៀវ ។ នៃស្បែក ។

ហេតុបច្ចុប្បន្នអស់នេះមិនល្មមទំនងយកជាការណ៍ថានឡើយ ប៉ុន្តែពួកមិត្តភ័ក្តិលោកអៃយ៉ាដនៅតែមិនពេញចិត្តសោះ ។

អើ! ច្បាកដមែន! អ៊ីស្មាអ៊ីលផ្ទាស់ប្តូរអស់ហើយ ដែលទើបទំនងមកពីប្រទេសអឺរុប ហើយជាការដែលនាំឲ្យលេចផ្សែងខ្លាំង, ដូច្នេះក្នុងចំណោមនោះ មនុស្សសុទ្ធតែចាស់ ។ ក្នុងស្រុក ជាអ្នកកាន់ចំខៀមទម្លាប់យ៉ាងមុងមាត់ចំពោះសាសនាឥស្លាមផង ។

រស្មីមេបេនអាប់ជាឡស់ ក្នុងអំឡុងប្រហែលដប់ឆ្នាំមុន ជាគូកនជាមួយនឹងអ៊ីស្មាអ៊ីល ធ្លាប់លេងល្បែងជាមួយគ្នា តែងនាំគ្នាទៅកន្លែងព្រៃយកសំបុកចាប តាប់ឃ្មុំ ឬកំនាំគ្នាទៅលបលាក់ខ្លួនពួនខាងក្រោយដុំថ្មយ៉ាងស្ងាត់ ចាំលួចមើលនារីអាក៉ាប់ដែលនាំគ្នាស្រាត ហើយជុះលោតងូតទឹកជ្រះស្រែកហ៊ោកញ្ជ្រៀវ ហើយឡើងមកវិញ ដូចខ្លួនច្បាណស្អាតច្បាតនាំគ្នាដើរដង្ហែមុខក្រោយជាដួរ . ទួលក្អមទឹកមួយម្នាក់ត្រាច់ចរតាមផ្លូវដើងដីចង្អៀត ស្រែកច្រឹងភ្ញាក់ខ្នុកបែបបង្ហូស ។ គួរឲ្យស្រងេះស្រងោចពេក នាវេលាថ្ងៃខៀបហៀបចូលរន្ធ ។

ខ្ញុំ! គួរស្រណោះសេចក្តីរីករាយដ៏សុខុមកន្លងវង្វេងកុមារភាព! គួរស្តាយមិត្តភាពកន្លងវង្វេងដប់ច្រើនឆ្នាំ ខ្ញុំគួរស្តាយពេក! ដីវភាពដែល

ប្រព្រឹត្តទៅតែងចំបែកស្មើរតែជាធម្មតា នូវមិត្តសំឡាញ់ក្នុងកាលជាតរុណភាព ។

ហេតុកេះតែងមានកម្លាំងខ្លាំងជាងមនុស្សជានិច្ច ចំណែកកាំរស្មីសុភាព កម្រែនឹងតាំងនៅស្មើភាគគ្នាទៅវិញទៅមកបានណាស់ ។

កាន់តែធំចំរើន កាន់តែបានស្គាល់សេចក្តីពិសោធន៍យ៉ាងច្រើនអំពីសត្វនឹងសង្វារកាលតែឆ្នាំ យើងត្រូវប តែងត្រូវប់ផ្សង់ចាកគំនិតដើមដែលបានគ្រោងទុកក្រមានណាស់ មនុស្សដែលអាចរក្សាពាក្យក្នុងកាលជាកុមារភាពទុកបានមិនឃ្លៀងឃ្លាត ។

រឿងដែលនិយាយមកនេះ តើឲ្យផលខាងល្អ ឬខាងអាក្រក់? ការណ៍នេះត្រូវស្ទុះទុក កុំសំរេចសេចក្តី, ស្រេចលើព្រៃងកសនារបស់យើងជាអ្នកតាក់តែងមកឲ្យសុខឲ្យទុក្ខ ។ ស្រេចលើព្រះអាឡស់ដែលជាតួសេចក្តីល្អគ្មានទីបំផុត ជាអ្នកមេចំណែកស្រាប់ ។

*
* *

អ៊ីស្មាអ៊ីលបានចេញចាកក្រុងតូច ឈ្មោះកាស៊ី · ភាពប៉ិលី តាំងពីអាយុដប់ប្រាំបីឆ្នាំ ដើម្បីទៅរៀនសូត្រចំណេះវិជ្ជាឯប្រទេសអឺរុប ហើយដើម្បីធ្វើឲ្យបានស្គាត់កន្លងផ្លូវភាសានៃជនបរទេសកន្លះពាក់បីឆ្នាំ គេបានទំសិក្សាបែបខាងវិជ្ជាពាណិជ្ជកម្មទឹងសិប្បិយការ ដែលជាវិជ្ជាបានបង្ហើបគំនិតប្រាជ្ញាអ៊ីស្មាអ៊ីលទៅលើសាកលលោក ដែលនៅកំពុងមកយូរ

ហើយ នឹងជាវិជ្ជាដែលធ្វើឲ្យគេមានប្រាជ្ញាដ៏ធំទូលាយដល់សាសន៍នៅខ្លី តែខ្ចាំងបំផុតប្រសប់ក្នុងផ្លូវចាត់ការផ្សេងៗ ។

ឯរស្មីមេបនអាប់ជាឡើយ មិនដូច្នោះឡើយ នៅតែនឹងនីត្រួតកំណើតនៃគាត្តាតែរៀងរហូតក ហើយលុះផុតអនិច្ចកម្មទៅ ខ្លួនក៏ឡើងបានជានាយកក្នុងត្រកូមញាតិជំនួសផុតក ម្ល៉ោះហើយទើបកើតមានអស្ចារ្យនានាតែច្រើន ហើយថែមទាំងខំចិញ្ចឹមសេចក្តីគោរពចំពោះទំនៀមទម្ងាប់ពីបុរាណឲ្យកាន់តែជាប់ធំផង ។

រស្មីមបណ្តាយឲ្យពុកចង្កាដុះតាមបុរាណសម័យនិយម ហើយពេមភ្លៅៗដែលដុះព័ទ្ធជុំវិញមុខ រឹតតែសំដែងទឹកមុខថាជាមនុស្សមានសេចក្តីមុឺងម៉ាត់ ព្រមទាំងយឺនយ៉ឺង, បបូរមាត់ស្តើងនឹងចិញ្ចើមក្រាស់បង្ហាញឲ្យស្គាល់ចរិតធាប់ខឹងនឹងមុខរឹង ហើយបើច្រៀងឡើត គ្មាននរណាអាចបន្ទន់បាន, ចំណែកទស្សនាការ បើគ្រែឡើកទៅខាងណាអាចនិយាយថ្កាប់ថាជាអ្នកល្មោភលោភលន់ នឹងច្រណែនឈ្នានិះយ៉ាងធំ ព្រោះមានសេចក្តីស្តាយដែលខ្លួនមិនបានធ្វើជានាយកបណ្តាប់នៃជនជាតិអាប៉ាច់នាក្រុងកាសិ-កាកប៊ូលី ។

ហេតុដូច្នេះ បានជារស្មីមេបំការពារហានន្តរៈដែលត្រូវបានមកលើខ្លួនទុក ហើយសព្វថ្ងៃនៅឯផ្ទះ គេគ្មានធ្វើការអ្វីក្រៅពីបង្វឹករៀនប្រឹងអំណាច លុះប្រឹងយូរៗទៅរហូតដល់គ្មានសប្បុរសធម៌ក្នុងខ្លួន ។

រស្មីមកបំភ្លឺចិត្តឲ្យតែអ្នកដទៃធ្វើតាមនឹងត្រូវតែស្តាប់បង្គាប់ គេបង្កើតទំនៀមមួយថាជនណាក៏ដោយ មិនត្រូវមានសិទ្ធិរើសទុំដាស់នឹងសំដីរបស់គេទេ ហើយការណ៍ដែលគេទំសំដែងកិតមុខស្រកយកត់ចាត់ចំពោះសាស្ត្រគ្នា ដ្បិតគេនឹកថាពួកគ្នានឹងមិនលែងតិតថាគេជាមនុស្សមួយហើយទៅថ្ងៃមុខនឹងឲ្យរង្វាន់ជាយសសក្តិអ្វីមិនខាន ។

ម្ល៉ោះហើយការឆ្នើងឆ្នៃនឹងអតិជ្ឈាធមិបណ្តេញសេចក្តីស្នេហាចំពោះស្រុកទេសចេញពីក្នុងខ្លួនអស់ ម្យ៉ាងទៀត ប្រហែលនៅក្នុងខ្លួនគេមានធម៌កំសាកមួយពីកំណើត ដែលតែងធ្វើគេឲ្យត្រូវតែទន់លំទោនទៅចំពោះមុខជនមានកំឡាំងជាង ។

សេចក្តីខ្មោរទៅនៃចរិតបែបនេះផង ការចាត់មុខនៃអ៊ីស្មាអ៊ីលដែលធ្វើដំណើរទៅកាន់ប្រទេសអ៊ីរុបជាយូរឆ្នាំផង ធ្វើប្រឡាយដ៏ជ្រៅហើយធំយ៉ាងអ្នកកំណែរទាំងពីរ ។

ចំណែកអ៊ីស្មាអ៊ីលវិញ តែងចំញឹមនូវសេចក្តីស្នេហាយ៉ាងម៉ាចំពោះស្រុកទេស នឹងចំពោះអ្នកណាដែលបានធ្វើសេចក្តីថ្លៃថ្នូរគុណរឿងដល់ជាតិ ទុកនៅក្នុងចិត្តជាមិច្ច ។ គេមិនបណ្តោយតាមតែគំនិតនាំឲ្យថយក្រោយ ដែលបណ្តាលឲ្យកើតជារឿងដំនាស់ដល់សម័យនិយមដឹកចុះដឹកឡើងដូចមនុស្សខ្វាក់ទេ ក្នុងណាដែលអារ្យធម៌នៃប្រជាជនត្រូវស្ទុះចំរើនឡើង ។

អ៊ីស្នាអ៊ីលបានរៀនអាជីវកិច្ចផ្សេង ។ នៃមនុស្សពីបរទេស ហើយ
ព្រមទាំងបានយកទៅការដំរេកចំពោះសេវ៉ាភាព វិជ្ជាយុត្តិធម៌ បំណែះ
អត់ទុន សាមគ្គីធម៌ពីកន្លែងនៃដំណើរនោះផង ។ រឿងប៉ុណ្ណេះជា
គ្រឿងដំទាស់ដល់ជនជាតិកន្លែងនោះ ដែលធ្លាប់ប្រកាន់តែដំរេកតាមច្បាប់
អ្នកមានកំឡាំងខ្លាំង តែមិនតាមច្បាប់អ្នកមានយុត្តិធម៌ឡើយ ។

ហេតុដូច្នេះ ការណ៍ដែលរស្មីមេធ្លីមដំលុះរហាសភាពដោយ
សំឡេងយ៉ាងមុត ពួកមិត្តភក្តីនៃលោកអែយ៉ាដ តាមដោយស្មាន
ច្រហែលពេញចិត្តណាស់ ។

រស្មីមេគ្រោកឡើង ចែរមុខឆ្ពោះទៅរកសំឡាញ់ចាស់ ហើយ
និយាយដោយពាក្យចំអកថា: "អ៊ីស្នាអ៊ីល! ចូរឯងរៀបរាប់រឿងរ៉ាវ
ច្បាប់យើងបន្តិចទៀតមើល! ។ រឿងបរទេស អញចូលចិត្តស្តាប់
ពន់ពេក! ធ្វើឲ្យអញសប្បាយអស្ចារ្យ! ។

អ៊ីស្នាអ៊ីលសំឡឹងរស្មីមេយូរបន្តិច ក៏ស្គាល់ទឹកមុខសំឡាញ់ចាស់ថា
ជាអ្នកមានចិត្តព្យាបាទលោភគិតទាន់ភ្លាមថាត្រូវតែប្រើឧបាយទប់ទល់វិញ
ទើបធ្វើយ៉ាងខ្លីថា: "បពិត្រអស់លោកជាញាតិមិត្តទាំងឡាយ! រឿង
ច្រទេសអ៊ីរុបរបស់ខ្ញុំមិនសូវមានច្រយោជន៍ដល់អស់លោកពាល់គ្នាទេ" ។

(មានត)

ឯកឧត្តម សម-ញ្ញាណ រដ្ឋមន្ត្រីក្រសួងធម្មការ

ថ្លែងក្នុងពិធីអនុស្សាវរីយ៍មហាសន្និបាតនៃមន្ត្រីសង្ឃទី ១០ នៅថ្ងៃទី ១៩ ខែមករា ២៤៩៦ ពុទ្ធសករាជ

អនុស្សាវរីយ៍មហាសន្និបាតនៃមន្ត្រីសង្ឃនេះ ជាគំរប់ ១០ ឆ្នាំហើយ ក្នុងឆ្នាំនេះ ព្រះមហាវីរក្សត្រចំណាយព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ៨០០០ រៀល ឲ្យក្រសួងធម្មការចាត់ធ្វើកត្តប្រគេនមន្ត្រីសង្ឃក្នុងក្រុងភ្នំពេញនិងមន្ត្រីសង្ឃដែលនិមន្តមកពីខែត្រនានា ។ មហាសន្និបាតនេះទុកជាព្រះរាជពិធីរបស់ព្រះករុណាដោយពិត ។

ឯកឧត្តមសម-ញ្ញាណ បានពិតទូលព្រះថេរានុត្ថេរៈទាំងឡាយអំពីកិច្ចការខាងពុទ្ធចក្រនិងខាងអាណាចក្រ ដែលក្រសួងធម្មការបានបំពេញក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើតំរូវ ដែលយើងជាក្រស់ដោយសេចក្តីបំប្លែញ សំដៅយកតែត្រង់គោលសំខាន់ៗដូចតទៅនេះ ៖

អំពីពុទ្ធបក្រ

សព្វថ្ងៃនេះ មានសាលាសម្រាប់សិក្សាធម៌វិន័យគឺ: សាលាបាលីជាន់ខ្ពស់នៅក្រុងភ្នំពេញ ១, សាលាបាលីវង់ នៅខែត្រក្រៅ ៣៣៩វត្ត, សាលាបាលីវង់ នៅដែនកូសាំងស៊ីន ១៩វត្ត ។ សាលាទាំងនេះមានសិស្សានុសិស្សទាំងអស់ ៩.៣៩៤អង្គ ។

សាលាធម្មវិន័យថ្នាក់ឯកទឹងថ្នាក់ទោ មានតែនៅវត្តទុណ្ណាលោម ក្រុងកំពង់ញ ឯវត្តខែត្រក្រៅមិនទាន់មាននៅឡើយ ។

សាលាធម្មវិន័យថ្នាក់ត្រី មាននៅវត្តចាំង១ឡាយក្នុងព្រះរាជធានីទឹង ខែត្រក្រៅ រួមចាំងអស់ចំនួន ១០៧វត្ត មានសិស្សរៀនចាំងអស់ចំនួន ១២.០-០អង្គ ។

ឥឡូវនេះទឹងមានសាលាមួយយ៉ាងប្រសើរ ចានរៀបចំកសាងហើយ នៅត្រង់កន្លែងដីផ្សារស្លួនចាស់ ជាខាងជើងសាលាចាលីជាន់ខ្ពស់ ។ សាលានេះប្រហែលជាដល់ខែពុទ្ធសករាជ ២៤៨៧ ទឹងធ្វើរួចស្រេច ។

អំពីបុព្វហេតុដែលកើតសាលាដ៏ប្រសើរនេះ គឺនៅពេលដែលព្រះពោធិវង្ស ហួត-តាត ចានហ្វាងសាលាចាលីជាន់ខ្ពស់ ទិមន្តត្រឡប់មកពីប្រទេសថៃវិញ ចានធ្វើសេចក្តីពយការណ៍ថ្វាយព្រះពរព្រះគុណថានៅប្រទេសថៃមានមហាវិទ្យាល័យពុទ្ធសាសនា ២កន្លែង មានសឿនយ៉ាងសឿនក្នុងការសិក្សាពុទ្ធសាសនាចាន់សម័យ ដូច្នេះគួរតែបង្កើតមហាវិទ្យាល័យពុទ្ធសាសនាមួយក្នុងប្រទេសកម្ពុជាក្នុងសម័យនេះ ដើម្បីកុំឲ្យចាញ់ប្រៀបពុទ្ធសាសនានៅប្រទេសថៃ ។

ព្រះគុណាខ្ញុំសូមព្រះរាជហឫទ័យធន ខ្ញុំឲ្យគ្រប់ធម្មការចាត់ការនេះឲ្យចានសម្រេចតាមព្រះពោធិវង្ស ព្រមចាំងប្រាសព្រះ

ពជគានដ៏ត្រង់កន្លែងផ្សារសួនចាស់នោះ ឲ្យសង់មហាវិទ្យាល័យព្រះពុទ្ធសាសនា ។

ជាសិទ្ធិជោគនៃព្រះពុទ្ធសាសនា បណ្តាលឲ្យគហបតី បេ- យាន អ្នកដំបូញនៅក្រុងកំពេញ មានសទ្ធាយ៉ាងមុះមុតបរិច្ចាគធនធានផ្តល់ថ្លៃនកសាងមហាវិទ្យាល័យនេះជាបឋមក់ ដោយគ្រឿងស៊ីម៉ង់ត៍ដែកបូជាចំពោះព្រះពុទ្ធសាសនា ។

ក្រសួងធម្មការ បានចាត់តាំងគណៈកម្មការមួយក្រុម នឹងគណៈកម្មការឯងមួយក្រុមទៀត សម្រាប់រៀបចំកម្មវិធីនៃការសិក្សាជា ២ ផ្នែក:

๑ - រៀបចំកែប្រែកម្មវិធីនៃការសិក្សា នៅសាលាចាស់ជាន់ខ្ពស់ ដោយបន្ថែយវិជ្ជាមុខណាមួយចេញ ហើយបញ្ចូលវិជ្ជាថ្មីថែម ឲ្យសមនៅតាមកម្មវិធីសម័យនិយម ។

๒ - រៀបចំកម្មវិធីនៃការសិក្សា នៅមហាវិទ្យាល័យពុទ្ធសាសនា ដោយប្រែបំណែងវិជ្ជាខាងព្រះពុទ្ធសាសនា ឲ្យស្មើនឹងវិជ្ជាខាងផ្លូវលោកត្រឹមថ្នាក់ដុកទ័រ កំណត់ពេលរៀន ๒๐ ឆ្នាំយ៉ាងតិច ។

អំពីគោលបំណងនៃការបង្កើតមហាវិទ្យាល័យ ខាងព្រះពុទ្ធសាសនានេះ ដោយមានថ្លែងឲ្យពួកបព្វជិតជាសិស្សមហាវិទ្យាល័យនេះ បេះដើងចំណេះវិជ្ជាខាងផ្លូវលោកនឹងផ្លូវធម៌យ៉ាងចំណាន គឺថានឹងបណ្តុះបណ្តាលពួកសិស្សានុសិស្ស នៃមហាវិទ្យាល័យពុទ្ធសាសនានេះឲ្យបេះ

ដឹងចំណេះវិជ្ជាខាងផ្លូវលោក រួមជាមួយនឹងផ្លូវព្រះពុទ្ធសាសនា ល្មម ប្រើការបានគ្រប់គ្រាន់អាចធ្វើជាធម្មទូតជាតិ នៅក្នុងប្រទេសនឹងក្រៅប្រទេសបាន នាំឲ្យប្រទេសយើងបែរមុខឆ្ពោះទៅកាន់សេចក្តីចំរើនជាន់សម័យ ។

មួយវិញទៀត ឯកឧត្តមសូមធ្វើបញ្ហាមួយចំពោះព្រះសង្ឃថា ព្រះពុទ្ធសាសនាមានធុរៈ ២ យ៉ាងគឺ:

គន្ថធុរៈ ១

វិបស្សនាធុរៈ ១

ឯគន្ថធុរៈប្រទេសយើង បានបំពេញជាលំដាប់មកហើយ នៅតែវិបស្សនាធុរៈពុំទាន់មានសាលាសម្រាប់រៀនដូចប្រទេសភូមានៅឡើយ ។

អំពីអាណាបក្រ

ឯកឧត្តម បានទូលព្រះសង្ឃគ្រប់ព្រះអង្គថា ស្ថានការណ៍នៃប្រទេសយើង មានអាសន្នគ្រោះថ្នាក់ផ្សេងៗ រវាង ៧ - ៨ ឆ្នាំមកហើយ នាំឲ្យប្រជាជនបែកសាមគ្គីគ្នា មិនសូវប្រតិបត្តិតាមច្បាប់សម្រាប់ប្រទេស, អសន្តិសុខកើតមានឡើងជាដរាបមក ។

កាលបើអំពើអកុសលគ្រប់បែបគ្រប់យ៉ាង ធ្លាក់មកលើប្រជាជនរួមជាតិដូច្នេះ ព្រះគុណាជាអម្ចាស់ដ៏វិតលើត្បូង ស្តេចយាងចេញពីព្រះរាជអាណាចក្រ ដើម្បីបំពេញបេសកកម្មនាឋរាទេស តាមការយក

ឯកពាជ្យ លុះព្រះមង្គស្តេចត្រឡប់មកកាន់ព្រះពាជធានីវិញ ទ្រង់ដឹកនាំប្រជាពស្តូព្រះអង្គ ដោយព្រះពាជមធ្យោបាយដ៏សុខុមឲ្យកើតសាមគ្គីធម៌លះបង់អស្មិមានៈ ស្រេចគំនិតគ្នាស្វាមីភក្តិព្រះមហាវីរក្សត្រ ព្រមព្រៀងស្ម័គ្រចិត្តហាត់ធ្វើជាកងដីវាល កងនាវាក្បែហាន តាមផែនការព្រះសីហនុនាំឲ្យបាក់ឆ័អត់ទាំពុំបាន ក៏ព្រមថ្វាយកេតនកណ្ឌនៃឯកពាជ្យ ខាងតុលាការ, ក្រុមព្រះនគរបាល (ប៉ូលិស) ទីឆ័ខាងកងទ័ព, ក្រៅពីនេះព្រះអង្គទ្រង់ព្យាយាមខាមខាវកេតនកណ្ឌនៃឯកពាជ្យដែលនៅសេសសល់ទាំងប៉ុន្មាន ឲ្យបានបរិបូណ៌ក្នុងពេលយ៉ាងខ្លីដោយសន្តិវិធី ។

ទោះបីព្រះនរបតីទ្រង់ទំយ៉ាងនេះ ក៏នៅតែមានមនុស្សអកុសលពោលកូតកុហកទៀបាន ដូចមានក្នុងព្រះពាជសាសន៍ចុះថ្ងៃទី ២៥ ទី ២៦ ទឹងទី ២៧ ខែវិច្ឆិកា គ.ស ១៩៥៣ ហើយនឹងព្រះសង្ឃប្រកាសនៃសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ បានបដិសេធពាក្យយោសនាអកុសលនេះសព្វគ្រប់ហើយ ដូច្នេះ សូមព្រះសង្ឃពិនិត្យតាមព្រះពាជសាសន៍នឹងព្រះសង្ឃប្រកាសទាំងនេះ ហើយសូមជាស់តឿនរំលឹកកិក្ខុ-សាមណេរឲ្យប្រព្រឹត្តតាមធម៌វិន័យ កុំឲ្យមានអធិករណ៍ តាំងនៅក្នុងសាមគ្គីធម៌ ហើយសូមនរមានពុទ្ធបរិស័ទចំណុះវត្តឲ្យនាំគ្នារក្សាសាមគ្គីធម៌ ដើម្បីការពារខ្លួនក្នុងសរណដ្ឋានគឺជាតិ-សាសនា មហាក្សត្រ ឲ្យបានថ្កុំថ្កើងរុងរឿងទៅ

នៅទីបំផុតនេះ ឯកឧត្តមបានលើកយកនូវផលអាគន្តុកម្មនេះ ថ្វាយចំពោះព្រះករុណា ហើយទទឹងសូមបួងសួងដល់ទេវតាចាំឆ្មាយឲ្យ ជួយការពារថែរក្សាព្រះមហាក្សត្រ ឲ្យស្ថិតនៅជាបរមសុខក្នុងសិរីរាជ សម្បត្តិដរាបដល់រយៈព្រះវស្សា ។

ម្ួយទៀត សូមផលានិសង្សនេះបង្ហូរនូវសេចក្តីសុខចំរើនគ្រប់ប្រការដល់ជនរួមជាតិក្នុងព្រះរាជអាណាចក្រ ហើយសូមឲ្យប្រទេសកម្ពុជាបានឯករាជ្យបរិបូណ៌ ក្នុងពេលយ៉ាងខ្លីកុំបីឃ្លៀងឃ្លាតឡើយ ។

ចប់

សូមកុំភ្លេច !

ទស្សនាវដ្តីកម្ពុជសុរិយានេះ ជាសម្បត្តិរបស់លោក-អ្នក ហើយ, ដូច្នេះ សូមលោក-អ្នកកុំភ្លេចជួយផ្សាយដល់ជនរួមជាតិដែលនៅឆ្ងាយ ឲ្យបានជាវទស្សនាវដ្តីនេះអានផង ព្រោះទស្សនាវដ្តីដែលនឹងមានអាយុវែង ហើយបំរើនធំជាត់ទៅបាន ដោយសារតែមានអ្នកជាវប្រើនឡើងៗ ។

សូមអគុណ !

ព. ស. ๒๔๗๑

ភាវនាសាសនា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៦ ខែមេសា លេខ ៤

ព.ស. ២៤៩៧ – គ.ស. ១៩៥៤

សេចក្តីថ្លែងអំណរគុណ

កាលពីថ្ងៃ អង្គារ ១៣ កើត ខែផល្គុន (១៦ មីនា) គ.ស. ១៩៧៤ នេះ អ្នកស្រី ម៉ិញ ក្រែង គ្រួបង្ហាត់ល្ខោនព្រះពរជន្យ ព្រមទាំងអ្នកស្រី ក្តាំង ង៉ារ ជាប្អូន ទីលំនៅនៅភូមិបឹងកេងកង សង្កាត់លេខ ១ ខ័ ក្រុងភ្នំពេញ មានចិត្តសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា យល់ច្បាស់នូវអានិសង្សនៃសាធារណប្រយោជន៍ ឲ្យានធ្វើអំណោយគម្ពីរ ស្មុតិ្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកបាលី ចាលីសុទ្ធដាគម្ពីរស្លឹករឹត ចំបាមសយ៉ាងល្អ ១ គម្ពីរ ចំនួន ១៥ ខ្សែ ដល់ពុទ្ធសាសនបណ្ឌិត្យ ដើម្បីដំកល់ទុកនៅមន្ទីរនេះ សម្រាប់ជាប្រយោជន៍សាធារណៈ ដល់ពួកសិក្ខាកាមកុលបុត្រក្នុងព្រះពុទ្ធសាសនាទូទៅ ។

ពុទ្ធសាសនបណ្ឌិត្យ ឲ្យានទទួលគម្ពីរនេះចុះបញ្ជីទុកជាសម្បត្តិរបស់ត្រកូលតទៅ ៖ ហើយសូមសរសើរនូវកាយវិការដ៏ថ្លៃថ្លារបស់អ្នកស្រីម៉ិញ ក្រែង នឹងអ្នកស្រីក្តាំង ង៉ារ ព្រមទាំងសូមថ្លែងអំណរគុណយ៉ាងក្រៃ ....



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— ពហុបការធម៌	ព្រះមហា ជា - ឆាយ	២៤៣
— វិធីកឋិញ្ញា (តចប់)	ព្រះមហា ច័ន្ទ - ហុង	២៥៤
— បញ្ញាសជាតក ភាគទី ២	បណ្ឌិតមហា ឈឹម - ស៊ុម	២៦២
ផ្នែកអក្សរសាស្ត្រ		
— ការបណ្តុះនិស្ស័យ (តចប់)	ព្រះមហាឧត្តមវិជ្ជា ប៊ឹង - ប៊ម ...	២៨២
— រឿងសាមកុក (តមក)	ឧកញ៉ា ន្ហូ - កន	២៩១
— ទាលៈនឹងទមយន្តី (តមក)	អ្នកស្រី ស្រ៊ីន - សារីយ៉ាន់	២៩៨
— ដំណើរអស្ចារ្យនៃលោកភីសូប៊ីយូយេ (តមក)	លោកវ៉ាយ -ប៊ុក	៣០៤
— ដំណឹងតាមខ្សល់ក្នុងការ: (តមក)	លោកផេង - ជ្រីវ	៣០៩
កំណាត់ទឹនប្រវត្តិការណ៍		
— សកម្មភាពនៃក្រុមដំនុំទំនៀមទម្លាប់ខ្មែរ បរិយាយពីវិធានៃក្រុមដំនុំ	លោក ជាប - ពិន	៣១៤
— សមណសក្តិនៃព្រះសង្ឃ ១៣ រូប	ពុទ្ធសាសនបណ្ឌិត្យ	៣១៨

មួយឆ្នាំមាន ៤២ លេខ — ដំឡៃដារ ២០០រ.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE:

— Bahupakaradharma	*Brah Maha CHEA-CHHAY* . . .	243
— Vammikappanha (suite et fin) .	*Brah Maha CHANN-HONG* . .	254
— Pannasaja'aka-vol.II	*M. CHHIM-SOUM*	262

PARTIE LITTERAIRE:

— Education morale (suite et fin)	*Brah Maha PEUNG-PAM*	282
— Histoire de SAMKOK (suite) .	*Oknha NOU-KAN*	291
— Nala et Damayanti (suite) . .	*Mme SRIN-SARIS-YANN*	298
— Le voyage extraordinaire de Vasiobioyé (suite)	*M. RAY-BUC*	304
— Le souffle du désert (suite) .	*M. PHENG CHRIV*	309

NOTES ET CHRONIQUES:

— Activité de la Commission des Moeurs et Coutumes.	*M. CHAP-PIN*	314
— Avancement en grade de 13 dignitaires religieux	*Institut - Bouddhique*	318

Prix d'abonnement annuel (comprenant 12 numéros) 200$00

ព្រះមហា ជា-ធាយ វិត្តិញ្ញាណោម

រៀបរៀង

ឥមោ តស្សូ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្សូ

សូមនមស្ការចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌នឹងព្រះអរិយសង្ឃ) ។

ពេលនេះជាធម្មស្សវនកាល ត្រូវតាមសណ្តាប់ប្រពៃណីពីបុរាណ-សម័យ នៃពុទ្ធសាសនិកជនរៀងរាបមក ។ អាត្មាភាពបានទទួលការៈមកសំដែងធម៌ទេសនា តាមសមគួរដល់កាលវេលា, ទុកាសនេះសូមសំដែងអំពីឥហុបការធម៌ តាមន័យព្រះពុទ្ធភាសិត ក្នុងសុត្តន្តបិដកទសុត្តរសូត្រ គម្ពីរទីឃនិកាយ ដូចមានបទព្រះបាលីថា

ឯកោ ធម្មោ ពហុបការោ អប្បមាទោ កុសលេសុ ធម្មេសុ, អយំ ឯកោ ធម្មោ ពហុបការោ វុច្ចតិ "ធម្មមួយមានឧបការៈច្រើន គឺ អប្បមាទ (ការមិនធ្វេសប្រហែស) ក្នុងធម្មទាំង-ឡាយជាកុសល, នេះហៅថា ធម្មមួយ មានឧបការៈច្រើន" ។

អាត្មាភាពសូមអធិប្បាយតាមន័យព្រះពុទ្ធដីកាខាងលើ ដូចសេចក្តីតទៅនេះ :

អប្បមាទ ប្រែថា សេចក្តីមិនធ្វេសប្រហែស, ការមិនធ្វេសស្មារតី ឬការប្រុងប្រយ័ត្នមិនឲ្យភ្លាំងភ្លាត់ ។ សេចក្តីមិនប្រហែសធ្វេសនេះជាធម៌ចំបង់ជាងកុសលធម៌ទាំងពួង ឬថាកុសលធម៌ទាំងពួងមានអប្បមាទជាឫស សមដូចព្រះពុទ្ធដីកាថា យេ កេចិ កុសលា ធម្មា សព្វេ តេ អប្បមាទមូលកា អប្បមាទសមោសរណា អប្បមាទោ តេសំ អគ្គមក្ខាយតិ ប្រែថា "ធម៌ទាំងឡាយណានីមួយដែលជាកុសល, ធម៌ទាំងអស់នោះ មានសេចក្តីមិនប្រមាទជាឫស គឺជាឫសគល់ប្រជុំចុះក្នុងសេចក្តីមិនប្រមាទទាំងអស់; អ្នកប្រាជ្ញទាំងឡាយតែងពោលសរសើរសេចក្តីមិនប្រមាទថា ជាធម៌ចំបង់ជាងកុសលធម៌ទាំងនោះ" ។

សេចក្តីមិនប្រមាទនេះ អ្នកប្រាជ្ញពោលថាជាចំបង់ ឬជាកំពូលនៃកុសលធម៌នោះ ព្រោះកុសលធម៌ទាំងអស់ដែលនឹងកើតឡើងបានក៏ព្រោះតែសេចក្តីមិនប្រមាទកើតឡើងជាមុន ឬថាលុះណាតែអប្បមាទធម៌កើតឡើងមុន ទើបកុសលធម៌ឯទៀតៗកើតឡើងបាន ដូចមេដំបូលផ្ទះ ជាទីប្រជុំចុះនៃឧត្តរង្គារៈ មានផ្ទៅដ៏ផ្ទាន់ជាដើម ។ ព្រោះហេតុនោះ ព្រះបរមគ្រូទ្រង់ត្រាស់ដែនថា ឥមាហំ ភិក្ខវេ អញ្ញំ ឯកធម្មំ សមនុបស្សាមិ "ម្នាលភិក្ខុទាំងឡាយ! តថាគតឥតឃើញនូវធម៌ដទៃណា ដែលជាធម៌មានអានុភាពអាចញុំាងកុសល

ដែលមិនទាន់កើតឡើងឲ្យកើតឡើង, ដែលកើតឡើងហើយឲ្យរឹងរឹតតែចំរើនឡើង. ដូចជាសេចក្តីមិនច្រមាទនេះឡើយ" ។ ម្យ៉ាងទៀត សេចក្តីមិនច្រមាទនេះ ប៉ុន្តែឆ្ពោះតាមបរិយាយ គឺសតិប្បដ្ឋានឯង. សតិនឹងអប្បមាទ មានសេចក្តីជាមួយគ្នា សមដូចព្រះពុទ្ធដីកាថា បត្តិសុ ភិក្ខវេ ហត្ថេសុ អគ្គរូបេន អប្បមាទោ សតិ បេតសោ អារក្ខោ ករណីយោ ច្រៃថា "ម្នាលភិក្ខុទាំងឡាយ! :សេចក្តីមិនច្រមាទ គឺសតិជាធម៌រក្សានូវចិត្ត ជាធម៌ដែលអ្នកពាល់គ្នាត្រូវធ្វើក្នុងស្ថាន ៤ យ៉ាង តាមសមគួរដល់ខ្លួន ។ ឯសេចក្តីមិនច្រមាទដែលអ្នកទាំងឡាយត្រូវធ្វើក្នុងស្ថាន ៤ យ៉ាងនោះ គឺត្រូវតាំងចិត្តថា:

๑ ចិត្តរបស់អាត្មាអញ កុំត្រេកត្រអាលក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្តីត្រេកត្រអាល;

๒ ចិត្តរបស់អាត្មាអញ កុំប្រទូសក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្តីប្រទូស្ត;

๓ ចិត្តរបស់អាត្មាអញ កុំវង្វេងក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្តីវង្វេង;

๔ ចិត្តរបស់អាត្មាអញ កុំស្រវឹងក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្តីស្រវឹងឡើយ ។

ន័យមួយទៀត សេចក្តីមិនប្រមាទនេះ បើពោលដោយការប្រតិបត្តិ ដែលជាការទំនុកបំរុងផ្នែកចិត្តសាស្ត្រ គឺការយកចិត្តទុកដាក់ក្នុងខយវយធម៌ គឺរំពឹងដល់សេចក្តីអស់ទៅនឹងសូន្យទៅ ។ មែនពិត, បុគ្គលទឹករំពឹងដល់សេចក្តីអស់ទៅនឹងសូន្យទៅនៃសង្ខារ ដោយអំណាចនៃការចាស់ ឈ ស្លាប់ក្តី នឹករំពឹងជញ្ជឹងថា នុសេចក្តីចាស់ ឈឺ ស្លាប់ជាត់ ជាកំយុធំរបស់សត្តនិការចេះតែរុកពន្លូនចូលមកកាន់តែជិត ។ ណាស់ហើយ ដូច្នេះក្តី, ត្រង់នេះពាណានូវអត្ថិណ្ហាប្បច្ចវេក្ខណធម៌ មានដើមថា ការចាស់គ្រាំគ្រាជាធម្មតានឹងកន្ទុងការចាស់គ្រាំគ្រាទៅមិនបានឡើយដូច្នេះក្តី កាលបើពិចារណាក្នុងអត្ថិណ្ហាប្បច្ចវេក្ខណៈយ៉ាងនេះជាដើមហើយ តពីនោះទៅទើបមិនប្រមាទ ហើយទំនឹងឃាតបំពេញការណីយកិច្ចរបស់ខ្លួន ឲ្យចំរើនកើតមានឡើង ។ ការពិចារណានេះជាឧបាយដើម្បីបំបាត់នូវសេចក្តីប្រមាទសេចក្តីស្រវឹងថា អាត្មាអញនៅកម្លោះក្រមុំ ថាមិនមានភេត មិនខាន់ស្លាប់ ទាំងជាឧបាយដើម្បីរំកិលខ្លួនឲ្យផុតចាកបាប បែរមុខឆ្ពោះទៅរកបុណ្យកុសលតែម្យ៉ាង ។ ឯឧបាយសម្រាប់រំពឹងពិចារណាឲ្យឃើញសេចក្តីអស់ទៅនឹងសូន្យទៅ ដែលជាហេតុនាំឲ្យកើតអប្បមាទធម៌នោះមានច្រើនប្រការណាស់, អ្នកប្រាជ្ញបាននាំយកធម៌ទាំងឡាយ ដែលជាហេតុឲ្យកើតអប្បមាទធម៌ ហៅថាវិបស្សនា មកឲ្យពិចារណាថា "រូបទាំងអតីត អនាគត បច្ចុប្បន្ន ដែល

អាស្រ័យបច្ច័យតាក់តែងហើយកើតឡើង ជារបស់មិនទៀង មានកិរិយាអស់ទៅសូន្យទៅ ប្រែប្រួលទៅ រលត់ទៅជាធម្មតា; ទាំងវេទនា សញ្ញា សង្ខារ វិញ្ញាណ ក៏ដូចគ្នាដែរ ។ សេចក្តីទៀង សេចក្តីសុខសប្បាយ តែងយកត្រែតត្រអាលអរសោរនឹងមានមកពីណា ? ព្រោះថារបស់ណាដែលកើតឡើងហើយ សុទ្ធតែត្រូវវិនាសបែកធ្លាយទៅវិញទាំងអស់; ទ្រព្យសម្បត្តិរបស់អាត្មាអញក្តី ជីវិតរបស់អាត្មាអញក្តី នឹងវិនាសព្រាត់ច្បាស់ទៅមិនខាន; ទោះសត្វសត្វក្នុងត្រៃភព ក៏ត្រូវវិនាសព្រាត់ច្បាស់ដូចគ្នាទាំងអស់ដែរ ព្រោះការព្រាត់ច្បាស់ចាកសត្វនឹងសង្ខារនេះជាធម៌សម្រាប់ជនទូទៅ ។ ខ: ថ្ងៃនឹងយប់ចេះតែកន្លងទៅហើយ អាយុរបស់អាត្មាអញក៏អស់ទៅ តាមថ្ងៃនឹងយប់ដែលកន្លងទៅនោះដែរ បច្ច័យនៃសេចក្តីស្លាប់របស់អាត្មាអញមានច្រើនក្រៃពេក . មានទាំងខាងក្នុងទាំងខាងក្រៅ អាត្មាអញមុខជានឹងធ្វើកាលកិរិយាដោយហេតុនោះៗ ដោយអន្តរាយនោះ ។ មិនខានឡើយ" ។ កាលបើបានពិចារណាតាមន័យនេះហើយ ក៏ជាទុក្ខាយឲ្យកើតអប្បមាទធម៌ទាំងអស់ ។ កាលបើអប្បមាទធម៌កើតឡើងហើយ, បណ្ឌិតគួរសន្ធឹងត្រង់រក្សាថែទាំអប្បមាទធម៌នោះ ដូចជាបុគ្គលស់ឡឹងឃើញនូវប្រយោជន៍នៃទ្រព្យ ហើយទំថែរក្សាទ្រព្យមិនឲ្យអន្តរាយដូច្នោះ ព្រោះអប្បមាទធម៌នេះ ព្រះសម្មុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា មានឧបការៈច្រើនណាស់ ជាកំពូលនៃធម៌ជា

កុសលឯទៀត ។ ព្រោះហេតុតែអប្បមាទធម៌ ជាធម៌មានឧបការច្រើន ជាធម៌ចំបងជាងធម៌ជាកុសលទាំងពួង ឬថាជាមាតាបិតានៃសេចក្តីសុខចំរើនដូចពិតប្រាកដមែនហើយ បានជាព្រះបរមគ្រូ សូម្បីតែទ្រង់ហៀបនឹងរំលត់ខន្ធចូលកាន់បរមនិព្វានហើយ ទ្រង់បែរព្រះភ័ក្ត្រឈមទៅរកកិក្ខុបរិស័ទ ដែលអង្គុយគាល់ព័ទ្ធជុំវិញព្រះអង្គ ទ្រង់មានព្រះពុទ្ធដីកាផ្តាំថា ហន្ទទានិ ភិក្ខវេ អាមន្តយាមិ ពោ, វិយធម្មា សង្ខារា អប្បមាទេន សម្បាទេថ "ម្នាលភិក្ខុទាំងឡាយ ! ឥឡូវនេះតថាគតផ្តាំនូវអ្នកទាល់គ្នា សង្ខារទាំងឡាយមានការសូន្យទៅជាធម្មតា. អ្នកទាល់គ្នាចូរញុំាងប្រយោជន៍ឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ" ។ ឥទំ បច្ឆិមពុទ្ធវិបតំ នេះជាព្រះពុទ្ធដីកាប្រៀនប្រដៅពៅចុងបំផុតនៃព្រះពុទ្ធជាម្ចាស់ ។

សេចក្តីមិនប្រមាទនេះ មានមំនងគួរនឹងអ ប្បាយបានច្រើនជាអនេក ដូចជាសេចក្តីមិនប្រមាទក្នុងការថែទាំរក្សាខ្លួន ក្នុងវ័យទាំងបីវ័យណាមួយ, មិនប្រមាទក្នុងការរៀនសូត្រចំណេះវិជ្ជាផ្សេង ។, មិនប្រមាទក្នុងការសំដែង, មិនប្រមាទក្នុងការស្វែងរកទ្រព្យសម្បត្តិ, មិនប្រមាទក្នុងការសន្សំកុសលជាដើម ទាំងនេះក៏គួរយើញថាសេចក្តីមិនប្រមាទនេះ ជាប្រធានលើកិច្ចការគ្រប់ដំពូក ។

សេចក្តីមិនប្រមាទ ពិតមែនតែមានន័យច្រើនយ៉ាង តែបើរួមឲ្យខ្លីទៅមានតែត្រឹមពីរយ៉ាង គឺ:

១ - មិនប្រមាទក្នុងការលះ

២ - មិនប្រមាទក្នុងការចំរើន

លំដាប់ពីនេះ អាត្មាភាពសូមអធិប្បាយនូវសេចក្តីមិនប្រមាទទាំងពីរយ៉ាងនេះ ដូចតទៅនេះ ៖

មិនប្រមាទក្នុងការលះ

បាបកម្ម គឺអំពើដ៏លាមក អំពើដែលជាហេតុញុំាងសត្វឲ្យទៅកើតក្នុងចតុរបាយ អំពើដែលញុំាងសត្វឲ្យក្តៅក្រហាយស្តាយក្រោយ ព្រោះតែការវង្វេងខ្លួនលំបាកក្នុងទុគ្គតិ បុគ្គលគួរលះបង់ គួរវៀរតមកុំធ្វើ ព្រោះជាអំពើនាំឲ្យវិនាសខ្លួន ។ អកុសលមូលគឺឫសគល់នៃអកុសលធម៌ទាំង ៣ ប្រការគឺលោភៈ ទោសៈ មោហៈ បុគ្គលគួរតែលះបង់ ព្រោះអកុសលមូលទាំង ៣ នេះ ជាតួបាបផង ជាមូលហេតុគឺជាដើមចមនាំឲ្យធ្វើអំពើបាបផង ។ បញ្ចវេរគឺអំពើ ៥ យ៉ាងដែលបុគ្គលៈធ្វើហើយនាំឲ្យមានពៀរវេរគឺការសម្លាប់សត្វដែលមានជីវិតមិនកំណត់ថាប្រុសស្រីចាស់ក្មេង ទោះបីសត្វតូចល្អិត។ ឬសត្វទៅក្នុងគភ៌; ការលួចទ្រព្យដែលគេមិនបានឲ្យ ទោះបីថោកថ្លៃ តិចច្រើនក៏ដោយ ឬទ្រព្យដែលគេទុទ្ធិសបូជាចំពោះសង្ឃ ឬក៏ចំពោះសាសនា; ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺកិរិយា

ស្រឡាញ់ក្លួចកាន់ ឬច្រឡាំក្តីផ្លូវច្រៃវេណី ដែលមិនត្រូវច្រឡាំ មិនត្រូវ
ច្រឡែតជាហេតុឲ្យសៅហ្មង មានគំនុំគុំគួនឥតគ្មានវេរ តែកូលឲ្យ; ការ
កុហក គឺការនិយាយបំភ័ន្តអ្នកស្តាប់ឲ្យច្រឡំចិត្តខុស ឲ្យយល់ខុស ឲ្យ
យល់ឃ្លាតចាកគន្លងធម៌; ការផឹកសុរានឹងមេរ័យ គឺទឹកដែលកើតមកអំពី
គ្រឿងត្រាំផ្លែឈើ ឬធញ្ញជាតិផ្សេង។ គេត្រាំចុកយូរពាល់តែជូរផ្អូមខ្លាំង
ក្លាយរសជាតិទៅជាស្រវឹងក្តី គេយកធញ្ញជាតិស្ងោរមូស់បិទចំហុយ
យកតំណក់ញើសនោះក្តី ធ្វើដោយបែបផ្សេង។ ទៀតក្តី ទឹកតម្រាំ ដែល
គេជាក់មេជាតិស្រវឹងត្រាំចុកឲ្យចេញរសជាតិ ដូចទឹកគ្មោតជូរជាដើមក្តី
ទោះបីខ្លាំងក្តី ខ្សោយក្តីជាទឹកស្រវឹងជាតិតាំងនៃសេចក្តីប្រមាទ។ ទាំង
៥នេះហៅថាបញ្ចវេរ បុគ្គលគួរលះបង់ គួរវៀរតមកុំធ្វើ ព្រោះសុទ្ធតែ
ជាអំពើនាំឲ្យមានទោសទុក្ខច្រើនប្រការក្នុងលោកនេះ ទន្ទឹមបរលោក ដូច
ជាជាប់គុកច្រវាក់ រាយដំបៃនាស់ស្ទើរតែក្សុយច្រាណ ឬក៏កើតជាជម្ងឺ
ទាស់ខែងខ្វែងគំនុំតគ្នា នាំឲ្យមានទោសទុក្ខច្រើនប្រការទៀតជាដើម
ឯបព្វជិតគឺអ្នកបួសវិញ ក៏ត្រូវលះអំពើដែលទំនាស់ទាស់ខុសនឹងវិន័យ
សិក្ខាដូចជាអនេសនៈ ចាបជម្ម ភេរ្ជកម្ម ទូតកម្ម កុលទូសកកម្ម ទន្ទឹម
អនាចារផ្សេង។ ជាដើមចោលចេញដែរ។ មែនពិត, កេទបព្វជិតនេះ ជា
កេទុត្តមវិសេសវិបុលជាងកេទគ្រហស្ថ ត្រូវតែឲ្យមានអប្បមាទធម៌ជានិច្ច
ដើម្បីបំពេញកិច្ចវត្តផ្សេង។ ឲ្យបានបរិបូណ៌, មិនត្រូវបណ្តែតបណ្តោយ

ធ្វេសប្រហែសក្នុងខ្លួនឡើយ ត្រូវតែជាអ្នកភ្ញាំងនៅកងសីល ជាគ្រឿងរក្សាកាយវាចាឲ្យមានសណ្ដាប់ធ្នាប់ ឲ្យមានតម្លៃស្រគត់ស្រគំសមរម្យ ត្រូវតែអរកងកឋិនកាលីយកិច្ចរបស់ខ្លួន ជាអ្នកឃញ្ចក់យកកងឧទ្ទេសសូម្បីបន្តិចបន្តួច ប្រតិបត្តិមានទំនងឆ្ងាយរវើរវាយឲ្យរួចចាកទុក្ខ គួរឲ្យជាទីជ្រះថ្លា, មិនត្រូវប្រហែសចំណាតបណ្ដោយ ធ្វេយតំនិតឲ្យបាបធម៌ញាំញីសង្កត់សង្កិនចិត្ត ហើយប្រព្រឹត្តប្រទូស្តបៀតបៀនអ្នកដទៃឡើយ ។ បព្វជិតណា ដែលមិនអើពើនឹងវិន័យសិក្ខា មានអាការកិរិយាប្រព្រឹត្តច្រឡើសបើសឃ្លើសឃ្លងច្រឡាំងខាម ខុសឆ្គាតវិន័យ បព្វជិតនោះមិនសមស័ក្តិជាភិក្ខុ ឬជាសមណសក្យបុត្រឡើយ លុះតែបព្វជិតណាដែលសង្រួមកាយ វាចា ដោយល្អតាមវិន័យ សេក្ខិយវត្ត ដែលព្រះសុគតប្រញ៉ាប្តីឲ្យតមក មានចិត្តស្ងប់រម្ងាប់ចាកបាបអកុសល បព្វជិតនោះ ទើបគួរដល់ឋានៈជាភិក្ខុជាសមណសក្យបុត្រពិតប្រាកដមែន ។ ម្យ៉ាងទៀតកិច្ចការណា ។ ដែលប្រព្រឹត្តទៅដើម្បីខូចប្រយោជន៍ខ្លួននឹងអ្នកដទៃនោះ ។ ជាអំពើគួរលះឲ្យស្រឡះចេញ ទោះបីបន្តិចបន្តួចស្តួចស្តើងយ៉ាងកិច្ចការណា ក៏មិនគួរប្រថុយធ្វើដែរ ។ ដែលអធិប្បាយមកនេះកងសេចក្តីមិនប្រមាទកងការលះ ។

មិនប្រមាទក្នុងការបម្រើ

កុសលកម្ម គឺអំពើដែលកំចាត់បង់នូវសេចក្តីអាក្រក់ខ្លួនៗ ជាកម្មអាចញុំាងសត្វឲ្យដល់នូវសុគតិ ជាអំពើគួរធ្វើគួរបម្រើនឲ្យកើតមាន ។

និច្ចសីល គឺជាសីលដែលគួរប្រព្រឹត្តកាន់រក្សាឲ្យទៀងទាត់អស់កាលជានិច្ចមិនកំណត់កាលវេលា ។ ឧបោសថសីល ជាសីលគួរសមាទានរក្សាតាមកាលកំណត់ ។ ធម្មចរិយា គឺការប្រព្រឹត្តិល្អដោយកាយវាចាចិត្ត សម្រាប់បណ្តុះសេចក្តីចំរើន ទប់ទល់នឹងសេចក្តីវិនាសទាំងអស់ គ្រហស្ថគួរចំរើនឲ្យកើតមានឡើង ។ ចតុប្បារិសុទ្ធិសីល នឹងកិច្ចវត្តឯទៀត ។ ដូចយ៉ាងអភិសមាចារិកវត្ត សេក្ខិយវត្ត, ឧបជ្ឈាយវត្ត ជាដើម បព្វជិតត្រូវប្រព្រឹត្ត ដើម្បីឲ្យមានសណ្តាប់ធ្នាប់សមរម្យជាគុណសាមណេរក្នុងពុទ្ធសាសនានេះ ។

ម្យ៉ាងទៀត អំពើណា ។ ដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ដើម្បីសេចក្តីសុខ ចំរើន ដល់ខ្លួនទើងអ្នកដទៃ អំពើនោះ។ ជាអំពើគួរចំរើនទោះបីតិចតួចក៏មិនគួរប្រមាទដែរ គួរតែចំរើនឲ្យកើតច្រើនឡើងដោយលំដាប់កុំខាន ។ នេះជាសេចក្តីមិនប្រមាទក្នុងការចំរើន ។

រួបរួមសេចក្តីដែលបានអធិប្បាយមកនេះ ឈ្មោះថាអប្បមាទធម៌ជាធម៌មានឧបការៈច្រើនជាងកុសលធម៌ទាំងអស់ ។ ធម៌នេះសប្បុរសទាំងឡាយគួរសិក្សាគន់រក្សាទុក ជាធម៌តែមួយទេ តែមានឧបការៈច្រើនសមដូចព្រះពុទ្ធភាសិតដែលពោលមកក្នុងខាងដើម ។

អាត្មាភាព សំដែងធម៌មកនេះសមគួរដល់កាលវេលាតែប៉ុណ្ណេះឯង ។

យំ យម្បិ បដ្ឋិតំ តុយ្ហំ តំ តំ សព្វំ សមិជ្ឈតុ
តវមិតា ធម្មទានេន សុខិតា ហោថ សាធវោ

សេចក្តីប្រាថ្នាណា ៗ ដែលតុន្ទបរិស័ទប្រាថ្នាហើយ សេចក្តីប្រាថ្នានោះ ៗ ចាំងអស់ សូមឲ្យបានសម្រេចកុំបីខាន! ដោយអំណាចនៃធម្មទាននេះ សូមឲ្យតុន្ទបរិស័ទចាំងឡាយបានសេចក្តីសុខគ្រប់ប្រការកុំបីឃ្លាត!

រតនត្តយតេជេន ភវោជរដ្ឋវាសិនោ
ហ្វឹ្ស ហ្វឹ្ស បប្បោន្តុ សព្ពិភារវញ្ច ឆាញ្ញបា

ដោយតេជៈនៃព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ទឹងព្រះសង្ឃ សូមឲ្យប្រជាជនចាំងឡាយ អ្នកនៅកងឆកមុជរដ្ឋ ចាំទទួលសេចក្តីចម្រើនលូតលាស់ទឹងសន្តិភាព កុំបីឃ្លាតក្បាយទៅជាប្រការដទៃឡើយ! ។

ព្រះមហា ប័ន្ធ-ហុង

វត្តបល្ល័ង្ក ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

រៀបរៀង

(ត - ចប់)

ប្រយោជន៍ក្នុងបរលោកមាន ៤ យ៉ាង

១.— សទ្ធាសម្បទា បរិបូណ៌ដោយសទ្ធាគឺការជឿជាក់ចំពោះគុណព្រះរតនត្រ័យ ដែលជាតែវជិរសេសវិសាលត្រកាលជាងសញ្ញាណករតន:នឹងអញ្ញាណករតន: ។ ក្នុងភពទាំងបី(១) ឥតមានវត្ថុអ្វីសម្រាប់បំភ្លឺបានទេ, លោកទាំងមូលដែលអាចនឹងភ្លឺស្វាងរុងរឿងកំចាត់អវិជ្ជាទៅបាន ក៏ព្រោះតែគុណព្រះរតនត្រ័យ ដ៏មានសិរីតេជានុភាព ។

សទ្ធាតោះមាន ៤ យ៉ាង គឺ

ក) កម្មសទ្ធា ជឿកម្ម

ខ) វិបាកសទ្ធា ជឿផលរបស់កម្ម

គ) កម្មស្សកតាសទ្ធា ជឿថាសត្វមានកម្មជារបស់ខ្លួន

---

១ ធំកាមភព, រូបភព, អរូបភព ។

ឃ) តថាគតពោធិសទ្ធា ដើម្បីបញ្ជាក់ដឹងរបស់ព្រះតថាគត ។

បើធ្វើល្អ ផលដែលហុចឲ្យមកវិញក៏ល្អ, ធ្វើអាក្រក់ ផលដែលហុចឲ្យមកវិញក៏អាក្រក់. បើធ្វើខ្លួរកម្មល្អឆ្ងាអាក្រក់ផង ផលដែលហុចឲ្យមកវិញក៏ចានតាំងអាក្រក់តាំងល្អ ។ សមដូចសុភាសិតថា

យាទិសំ លភតេ ពីជំ តាទិសំ លភតេ ផលំ
កល្យាណការី កល្យាណំ បាបការី ច បាបកំ

ប្រែថា "បុគ្គលសាបពណ្តុះព្រោះពូជបែបណា រមែងចានផលបែបនោះ បុគ្គលធ្វើខ្លួរកម្មល្អតែងចានផលល្អ បុគ្គលធ្វើខ្លួរអំពើអាក្រក់តែងចានផលអាក្រក់" ។

លក្ខណៈរបស់សទ្ធាមាន ៤ យ៉ាងគឺ

ក) សទ្ធាមានសេចក្តីជឿជាលក្ខណៈ

ខ) សទ្ធាមានសេចក្តីជ្រះថ្លាជាលក្ខណៈ

គ) សទ្ធាមានកិរិយាលឿនទៅ ឬសុះសូរទៅជាលក្ខណៈ

ឃ) សទ្ធាមានកិរិយាតាំងមាំ កន្ទរត្តដែលគួរជឿជាលក្ខណៈ ។

លក្ខណៈតាំង ៤ យ៉ាងនេះ ជាគ្រឿងសំគាល់របស់សទ្ធា ឲ្យដឹងថា ជឿប្លែមិនជឿ, ជ្រះថ្លាប្លែមិនជ្រះថ្លា, មានកំឡាំងអាចសុះសូរលឿនទៅ

ដែរឬគ្មាន, មានកិរិយាតាំងមាំសឹងបំបែកសួនក្នុងវត្តដែរឬគ្មាន យ៉ាងនេះ ហៅថា ប្រជាប់សម្រាប់សង្កេតឲ្យចំណាំចាំជាក់នូវសទ្ធា ។

ម្យ៉ាងទៀត សទ្ធានេះអាចធ្វើឲ្នូវអន្ទង់ឆ្លងបានដោយពិត ដូចសុភាសិតថា សទ្ធាយ តរតិ ឱឃំ គេឆ្លងនូវអន្ទង់ ដោយសទ្ធា ។

អន្ទង់ ៤ យ៉ាង គឺ

ក) អន្ទង់គឺកាមគុណ ៥ ប្រាំ

ខ) អន្ទង់គឺភព

គ) អន្ទង់គឺទិដ្ឋិ

ឃ) អន្ទង់គឺអវិជ្ជា ។

๒.— សីលសម្បទា បរិបូណ៌ដោយការរក្សាសីល ។ សីលនោះ សម្រាប់គ្រហស្ថបានដល់នូវសីល គឺសីលដែលបុរសស្ត្រីរក្សាជានិច្ចមិនកំណត់កាលវេលា នឹងកុសលកម្មបថ ๑๐ ប្រការ ។

๓.— បាគសម្បទា បរិបូណ៌ដោយការបរិច្ចាគទ្រព្យសម្បត្តិចាត់ចែងធ្វើបុញ្ញកម្ម មានកសាងកុដិ, សាលា, វិហារ, ជីកអណ្តូង, លើកស្រះ, សង់ស្ពាន, សាងផ្លូវថ្នល់, សង់មន្ទីរពេទ្យសម្រាប់ព្យាបាលរោគជាដើម ។

๔.— បញ្ញាសម្បទា បរិបូណ៌ដោយប្រាជ្ញាការត្រាស់ដឹងនៃកុសលធម៌ដ៏ឥតខ្ចូល, ប្រកបចាក់ធ្លុះចំពោះខន្ធបរមត្ថសច្ចៈ ។

អ្នកណាជាព្រាហ្មណ៍?

ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ដែលប្រកបដោយមហាបុរិសលក្ខណៈទាំង ៣២ ប្រការ(๑) ហៅថាព្រាហ្មណ៍ ។

អ្នកណាជាសុមេធៈ?

គឺកូនសេដ្ឋីបុគ្គលអ្នកប្រកបកន្លងការរៀនមាន ៧ ដំបូក មានសោតាបត្តិមគ្គជាដើម មានអរហត្តមគ្គជាបរិយោសាន ហៅថាសុមេធ ។

អ្វីជាសស្ត្រា?

ប្រាជ្ញាដ៏ប្រសើរ ហៅថា សស្ត្រា ។ បញ្ញានេះមានច្រើនប្រភេទណាស់, តែក្នុងទីនេះសូមដកស្រង់យកបញ្ញា ៤ យ៉ាង គឺ

๑.— ទុក្ខេ ញាណំ ប្រាជ្ញាដឹងទុក្ខទាំង ๑๔ កង មានជាតិទុក្ខជាដើម មានយមកប្បិ ន លកតិ តម្បិទុក្ខ ជាទីបំផុត ។

---

๑ ចូរមើលលក្ខណសូត្រ ទីឃនិកាយ ៣ ជាដីកវគ្គ, និងព្រហ្មាយុសូត្រ មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកឯណោះ ។

កំប៉ុន្តែទុក្ខទាំងអស់នេះបើប្រមូលឲ្យខ្ជិះមកមានត្រឹមតែ ៥ យ៉ាងប៉ុណ្ណោះគឺ រូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។

ព្រះសយម្ភូញាណ ទ្រង់សំដែងថា "បើនៅមានខន្ធដកបណា ដកបានោះឈ្មោះថាប្រកបដោយទុក្ខ" បើមិនមានខន្ធទេ សេចក្តីយំសោកបោកប្រាណទុក្ខគ្រាមនស្សក៏មិនមានដែរ, យ៉ាងនេះហៅថាបញ្ញាដឹងកងកងទុក្ខ ។

២.— ទុក្ខសមុទយេ ញាណំ ប្រាជ្ញាដឹងកងហេតុដែលនាំបណ្តាលឲ្យកើតទុក្ខ មកពីតណ្ហាទាំង ៣ ប្រ ១០៩ ។

៣.— ទុក្ខនិរោធេ ញាណំ បញ្ញាដឹងនូវកន្លែងរំលត់ទុក្ខ គឺព្រះនិព្វាន ។

៤.— ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ ប្រាជ្ញាដឹងនូវផ្លូវប្រតិបត្តិទៅកាន់សេចក្តីរំលត់ទុក្ខទាំង ១២ កង ។

អ្វីជាការដឹក?

សេចក្តីព្យាយាមឈ្មោះថាជាការដឹក ពាក្យថា ព្យាយាមនេះគឺព្យាយាមញ៉ាំងសាធារណៈប្រយោជន៍ ទាំងបច្ចុប្បន្នទាំងបរលោកឲ្យកើតមានដល់ខ្លួននឹងអ្នកដទៃ ។

អ្វីជាសន្ធះទ្វារកង់ ?

សេចក្តីធ្ងន់តន ធន ល់ ឈ្ងល់ ឈ្ងប់ ពុំ ដឹង ច្បាស់ នូវ សច្ចធម៌ ទាំង ៤ ហៅ ថា គន្ធិះ ដែក ឬ សន្ធះ ទ្វារ កង់ ។

កង់ ដែល វិល លឿន ទៅ មិន បាន ទេ តែ តឹង តាំង នោះ ព្រោះ តែ គន្ធិះ ដែក ឬ ទុក ដែក ចូល ទៅ កាន់ ចិត្ត ផ្លូវ កង់ មិន ឲ្យ វិល យ៉ាង ណា, ពពួក សត្វ កន្លង លោក ដែល ប្រកប ដោយ អវិជ្ជា ក៏ យ៉ាង នោះ ដែរ ។

អ្វីជាសត្វហឹង ?

សេចក្តី ក្រោធ ខឹង ចោ៎ង ឡើង ឈ្មោះ ថា សត្វ ហឹង ។ សេចក្តី ក្រោធ ខឹង នេះ ជា ឈ្មោះ របស់ ទោសធម៌ ឬ ធម៌ ឈ្លួន ធម៌ ម្យ៉ាង, ហេតុ នោះ ហើយ បាន ជា ព្រះ អង្គ ទ្រង់ សំដែង អំពី ទន្លីធម៌ ជា តប.ធម៌ មួយ សម្រាប់ ដុត កំ ដៅ បំ បាត់ បង់ នូវ សេចក្តី ក្រោធ ពិ ភេង; ម៉ៃ យើង ចង់ ឈ្នះ សេចក្តី ក្រោធ ត្រូវ តែ កុំ ក្រោធ ខឹង តប ។

អ្វីជាផ្លូវ បែក ជា ពីរ ?

សេចក្តី សង្ស័យ ដែល បែក ក ខ្លែក ចិត្ត ជា ពីរ ផ្នែក ឈ្មោះ ថា ផ្លូវ បែក ជា ពីរ ។ ការ ដែល សង្ស័យ មិន ដាច់ ស្រេច ទឹង សម្រេច ទៅ មិន បាន យ៉ាង នេះ

មិនអាចនឹងរកសេចក្តីសុខចំរើនបានទេ ព្រោះវល់តែនឹងសេចក្តីសង្ស័យ រកទីបំផុតមិនមាន ។

អ្វីជាសំពត់តម្រងក្បួង?

នីវរណធម៌ ៥ ជាគ្រឿងផង់ល្អិតម៉ត់ បាននឹងឈ្មោះថាតម្រងក្បួន ។

អ្វីជាអណ្តើក?

សេចក្តីប្រកាន់ក្នុងខ្លួនបានក្នុងខ័ន្ធ ៥ ហៅថា សត្វអណ្តើក ។

អ្វីជាកាំបិតនឹងជ្រញ?

កាមគុណ ៥ ដែលអាស្រ័យគ្នាទៅវិញទៅមកគឺរូប អាស្រ័យនឹងភ្នែកជាដើម ហៅថា កាំបិតនឹងជ្រញ ។

អ្វីជាដុំសាប់?

សេចក្តីតម្រេកត្រេកត្រអាលស្រើបស្រាលចំពោះកាមគុណ ឈ្មោះថា ដុំសាប់ ។

អ្វីជានាគ?

ព្រះខីណាស្រពដែលលោកលះបង់នូវអាសវៈអស់ពីខ្លួនស្ងាត់ជាប់ដំណាក់ ហៅថា នាគ ។

ហេតុនេះគ្រហស្ថគាំងឡាយក្តី បព្វជិតក្តី ដែលបានមើលឬបាន
រៀនខ្ទរមិកប្បញ្ហានេះ សូមឲ្យសម្រេចតាមបំណងកុំបីឃ្លាតឡើយ ។
រីមិកប្បញ្ហា ប្រស្នាគាំង ១៩ ដែលបានសំដែងមកប៉ុណ្ណេះ សន្មត
ថាចប់ដោយសង្ខេប ។

សាសនារុង្សរឿងដោយបរិស័ទ
សច្ចធម៌ នៅបវរ បិតគត់មត់
មិនរលត់ មិនរលុប ចាត់បង់ទៅ
ដោយបរិសេទ្យ គាំង ៤ ទិស ឲ្យតាំងនៅ
កាន់ត្រឹមត្រូវ មិនខុសផ្លូវ ពីទុក្ខ ។
ដែលវិនាស ឬភ្លាត់ភ្លាយ អន្តរាយបង់
នេះកំលង់ កុងិបរិសេទ្យ កាន់មិនស្អាត
គាំងចំរើន ឬវិនាស ពាក្យទុក្ខ
ពុទ្ធាទុក្ខ កំបរិសេទ្យ គាំង ៤ ដែរ ។

ជឌ្ឍ-ហុង

បញ្ញាសជាតក

ភាគទី ២

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាភេទបព្វជិតតី ព.ស. ២៤៨៦, គ.ស. ១៩៤៣

អារម្ភកថា

គម្ពីរបញ្ញាសជាតក ច្បាប់ដើមជាភាសាបាលី ពុទ្ធសាសនបណ្ឌិត្យ ជាន[ស្រាវជ្រាវ]តាំងពី គ ស. ១៩៤៩ ជាន[សុំ]សម្តេចព្រះធម្មលិខិត ល្វី-ឯម, ព្រះឧត្តមមុនី អ៊ុម-ស៊ូរ នឹងព្រះញាណវីរិយៈ ឲ្យ[ប្រែ]ជាសេចក្តីសម្រាយជាន**ភាគទី ១** មានចំនួន ៥ រឿង ហើយបោះពុម្ពបញ្ចូលក្នុងទស្សនាវដ្តី កម្ពុជសុរិយា ជាលើកដំបូងមកម្តងហើយ លុះមកដល់ គ. ស. ១៩៤៤ ជាន[រៀបចំ]បោះពុម្ពជាសៀវភៅមួយដោយឡែកម្តងទៀត ដែលហៅថា បញ្ញាសជាតក ភាគទី ១ (ទាំងចាលីទាំងសម្រាយ) ។ សៀវភៅនេះមានជាវិសេសថ្លៃនៅពុទ្ធសាសនបណ្ឌិត្យ ។

ចំណែកខាងជាភាសាបាលី ច្បាប់ដើម ជាគម្ពីរសឹកវិត មានអត្ថន័យប្រយោគវិបត្តិច្រើនអន្ទើ ។ កាលពី គ. ស. ១៩៤៣ បណ្ឌិតមហា ឈឹម-ស៊ុម កាលនៅជាភេទបព្វជិតជាន[ចម្លង]ចែកជាភាគ១ជាន ៤ ភាគ ក្នុងមួយភាគ១ មាន[ប្រាំ]រឿង គឺតាំងពីជាតកទី ១ ដល់ទី ២០, ហើយ

ចានផ្សឹងកែចាលីទីនរបៀបប្រយោគឲ្យត្រឹមត្រូវ ព្រមទាំងបានចាត់ការឲ្យប្រែ ហើយយកមកពិនិត្យកែសម្រួលខាងសម្រាយតាំងពីភាគទី ២ ដល់ភាគទី ៤ ផង ។

ឯគម្ពីរបញ្ញាសជាតក តាំងពីភាគទី ២ តទៅ ពុំទាន់បានបោះពុម្ពផ្សាយនៅឡើយ ។ ហេតុដូច្នេះ យើងយកផ្នែកខាងសម្រាយដែលបណ្ឌិតមហា ឈឹម - សុំម ចាត់ការធ្វើនោះ មកបោះពុម្ពបញ្ចូលក្នុងទស្សនាវដ្តី កម្ពុជសុរិយា តាំងពីឆ្នាំ ១៩៥៤ នេះតទៅ ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទ. ព្រោះគម្ពីរបញ្ញាសជាតកនេះ មានរឿងទាក់ទងដោយគតិធម៌សុទ្ធ ។

វិបុលភ ជាតកទី ៦

(និយាយអំពីពាហិរកទាននឹងអដ្ឋង្គិកទាន)

លោកអាចារ្យ ឈឹម - ណាក ក្រុមដំនុំព្រះត្រៃបិដក

ប្រែពីចាលី

បាវិតសរីរោតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ អត្តនោ ទាន៍បារមឹ អារព្ភ កថេសិ ។

សត្ថា រីអង្គ្គសម្តេចព្រះបរមសាស្តាចរិយាវង្សកាលទ្រង់គង់សម្រាន្តព្រះឥរិយាបថក្នុងវត្តព្រះជេតពន ក្រុងសាវត្ថី ព្រះជិនស្រីទ្រង់ប្រារព្ធ

នូវការបរិច្ចាគទានរបស់ព្រះអង្គ ទ្រង់គ្រាស់សំដែងព្រះធម៌ដ៏វិសេស មានបទថាហារិតសរីរកេ ដូច្នេះជាដើមបទកំណត់ព្រះគាថា ។

សេចក្តីដំណាលថា សម័យថ្ងៃមួយ មានកិកុជាច្រើនរូបអង្គុយប្រជុំគ្នាក្នុងភេងធម្មសភា ថ្វែងសរសើរគុណព្រះបរមគ្រូពិតមានថា "ម្នាលលោកដ៏មានអាយុទាំងឡាយ, ព្រះតថាគតព្រះអង្គមានបុណ្យច្រើន មានប្រាជ្ញាច្រើន បានបំពេញបារមីមកជាអនេកប្រការ គួរឲ្យអស្ចារ្យក្រៃពេក" ។

គ្រានោះ សម្តេចព្រះបរមសាស្តាទ្រង់ព្រះសវនាការឮពាក្យនោះដោយទិព្វស្រោត ទើបទ្រង់ស្តេចចេញចាកគន្ធកុដី មកទ្រង់ប្រថាប់នៅលើអាសន ដ៏ប្រសើរ. ហើយទ្រង់មានព្រះពុទ្ធដីកាសួរកិកុទាំងឡាយនោះថា "ម្នាលកិកុទាំងឡាយ, អ្នកទាំងឡាយអង្គុយជជែកគ្នាពីរឿងអ្វី?" ។ កិកុទាំងឡាយនោះក្រាបបង្គំទូលថា "បពិត្រព្រះអង្គដ៏ចំរើន, ខ្ញុំព្រះអង្គទាំងឡាយអង្គុយជជែកគ្នាពីការបរិច្ចាគទាន របស់ព្រះអង្គ" ។ ទើបព្រះដ៏មានបុណ្យទ្រង់គ្រាស់ថា 'ម្នាលកិកុទាំងឡាយ, តថាគតបានបំពេញទានក្នុងកាលឥឡូវនេះ មិនជាទីអស្ចារ្យប៉ុន្មានទេ, កាលពីដើមវដ្ត តថាគតបានបរិច្ចាគបុត្តកិយារបស់ខ្លួន ឲ្យទៅជាខ្ញុំបម្រើអ្នកដទៃ នោះទើបមានសេចក្តីអស្ចារ្យជាពន្លឹក" ទ្រង់មានព្រះពុទ្ធដីកាតែប៉ុណ្ណេះហើយក៏ទ្រង់គង់នៅស្ងៀម ។ គ្រានោះ កិកុទាំងឡាយអាចធានាទំមន្តព្រះអង្គ

ឲ្យទាំអតីតនិទានខោះមកសំដែងប្រាប់ ។ ព្រះសាស្តាចារ្យទ្រង់សំដែងអតីតនិទានតាមពាក្យអាពាធនាបេសកភិក្ខុទាំង ឡាយថា ៖

ម្នាលភិក្ខុទាំង ឡាយ, កុងកាលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមព្រះបាទ វិបុល សោយរាជសម្បត្តិកងនគរសុចិវត្តី, ព្រះអង្គមានអគ្គមហេសីទ្រង់ព្រះនាម សុន្ទរីទេវី, ព្រះរាជបុត្រីទ្រង់ព្រះនាមនាង សុចី ។ ព្រះរាជាអង្គីនោះមិនមានព្រះទ័យលំអៀងដោយអគតិ-ធម៌ណាមួយឡើយ, ទ្រង់សោយរាជ្យប្រកបដោយធម៌, ចុះខ្ចីណាយព្រះរាជទ្រព្យ ឲ្យជាងសង់សាលាសម្រាប់ឲ្យទាន ៥ ខ្នង ហើយទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់សូមយាចក អស់ចំនួន ៥ សែនកហាបណៈ រាល់ៗថ្ងៃ ។

កាលនោះ អ្នកជម្ងឺទូទាំងអស់ ឈប់ធ្វើវេជ្ជកម្ម ពាណិជ្ជកម្ម ចាំតែទទួលព្រះរាជទានអំពីព្រះរាជាប៉ុណ្ណោះ, ជនទាំងនោះបានជាអ្នកបរិបូណ៌ដោយទ្រព្យសម្បត្តិ ចាត់ចែងបង្កើតចម្រើនរបាំរបៀងកំសាន្តជាទីសប្បាយក្រៃពេក ។ ព្រះមហាសត្វទ្រង់ប្រព្រឹត្តសុចរិតធម៌ ទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ដោយព្រះទ័យសោមនស្សយ៉ាងក្រៃលែងប៉ុណ្ណឹងហើយក៏នៅតែមិនទាន់ស្កប់ស្កល់ក្នុងព្រះរាជហ្ឫទ័យនៅឡើយ ។

ថ្ងៃមួយ ព្រះអង្គទ្រង់ប្រថាប់នៅលើប្រាសាទដ៏ប្រសើរ ទ្រង់បើកព្រះសីហបញ្ជរ ទតឥស្សរិយភាពរបស់ព្រះអង្គ ទើបទ្រង់មានព្រះ

តម្រិះថា "អញបានបំពេញតែពាហិរកទាន (ទានខាងក្រៅ) ប៉ុណ្ណោះ ឯអជ្ឈត្តិកទាន (ទានខាងក្នុង) អញមិនទាន់បានបំពេញសោះ", ទើបទ្រង់មានចំណង់ចង់ធ្វើអជ្ឈត្តិកទានទៀត; ទ្រង់រំពឹងថា 'បើអ្នកណាសូមក្បាលអញ, អញនឹងកាត់ក្បាលឲ្យអ្នកនោះ; បើអ្នកណាសូមភ្នែកអញ, អញនឹងឆ្កៀលភ្នែកឲ្យអ្នកនោះ; បើអ្នកណាសូមបេះដូងអញ, អញនឹងពុះទ្រូងអោសាច់សម្រក់ឈាម យកសាច់បេះដូងឲ្យអ្នកនោះ; បើអ្នកណាសូមសាច់អញ, អញនឹងពន្លះសាច់ក្នុងសរីរៈទាំងមូលឲ្យអ្នកនោះ; ពុំនោះសោត បើមានអ្នកណាមួយមកនិយាយនឹងអញថា បពិត្រមហាពាជ, សូមព្រះអង្គទៅធ្វើជាខ្ញុំបំរើខ្ញុំ ដូច្នេះក៏អញស៊ូតែទៅធ្វើជាខ្ញុំបំរើអ្នកនោះ" ។ កាលដែលព្រះពាជាកំពុងតែទ្រង់ព្រះចិន្តនាការយ៉ាងនេះ ក៏ស្រាប់តែមហាប្រឹថពីដែលមានគម្រាស់ ២សែន ៤ ម៉ឺនយោជន៍ កម្រើកញាប់ញ័រឮសូរខ្ទរខ្ទារឡើង ដូចជាដំរីចុះប្រែងបញ្ចេញសំឡេងពេទ្ធរខ្ទារគួរឲ្យខ្លាច, ភ្នំសិនេរុពាជក៏នុនលំនោនតោរទន់មក, ទាំងមហាសមុទ្រក៏តើតជារលកចោកបែកផ្លាត្រែង, មហាមេឃ ក៏បញ្ចេញសំឡេងគម្រាមដោយរន្ទះ ហើយបង្អុរមកនូវភ្លៀងរលឹមជាខ្លាំង, ទាំងផ្កែបខ្លោរពុំដួរ កាលក៏ភ្លឺផ្កែបច្រាត, ពួកទេវតាក្នុងកាមាវចរសួគ៌ ក៏ឲ្យសព្ទសាធុការពរដ៏យ, សេចក្តីជ្រួលជ្រើមក៏តើតមានរហូតដល់ព្រហ្មលោក ។ សេចក្តីអស្ចារ្យ ជាអនេកវិត្រៃពេក ទើតគណនាត្រាវាប់ពុំបានឡើយ ។

ព្រោះហេតុនោះហើយ ឥឡូវនេះ ព្រះបរមសាស្តាចារ្យជាម្ចាស់ ទ្រង់ត្រាស់ថា:

តទា អារុយ្ហ បាសាទេ ទិលោកេគ្គ មហាសិរឹ
សុទ្ធបិតុំ ឧប្បាទេត្វា ទានំ ទាតុំ វិចិន្តយិ
សិសំ សបេបិ ចក្ខុញ្ច បាទយញ្ចបិ មំសកំ
ទទេយ្យំ កាយំ សារេត្វា យទិ កោបិ យាចេយ្យ មំ
សភារំ បិន្តយន្តស្ស អកម្បិតមសណ្ឋិតំ
អកម្បិ តត្ត បបរឹ សិនេរុវនវដំសកាតិ

ក្នុងកាលដែលតថាគតឡើងទៅលើប្រាសាទ រមិលមើលនូវសិរីដ៏ធំ ញុំាងចិត្តដ៏ស្អាតឲ្យកើតឡើង ដើម្បីនឹងឲ្យទានហើយ មានសេចក្តីត្រិះរិះថា "បើអ្នកណា ប្រាថ្នាចង់បានក្បាលក្នុងបេះដូង ឬសាច់របស់អញ អញអាចកាត់ឆ្អឹលពន្លះឲ្យទៅអ្នកនោះ ដោយឥតញាប់ញ័រឡើយ"; តថាគតកំពុងតែត្រិះរិះដូច្នោះ ស្រាប់តែមហាប្រឹថពីកំរើកញាប់ញ័រស្ទើរតែចប់ទល់ទ្រនៅពុំបាន, ទាំងក្នុងសន្ទុះកំអោនលំអោនទៅទន់ល្អាសល្អន់មករកតថាគត ។

កាលនោះទីសុយនាគ្រឡាបន្ទូលនៃសក្កទេវរាជ ក៏ក្តៅគ្រហាយដោយតេជានុភាពនៃទានចារមី ។ សម្តេចសហស្សនេត្រទ្រង់ប្រមើលមើលឃើញហេតុនោះហើយក៏លាន់ព្រះឧស្សាថា ឧហ្ម៎ ! ព្រះចុតិបុលភជាតាពុទ្ធង្កុរបណ្តាលពុទ្ធវង្ស ទ្រង់ឋិតនៅក្នុងមនុស្សលោកឯណោះ មានព្រះរាជសន្ទេចានចំណាយព្រះរាជទ្រព្យ ឲ្យទៅជាទានដល់សមយាចកអ្នកកំសត់ទុគ៌ត ដោយឥតការខ្នះអាល័យសោះ ដល់ម្ល៉ោះទ្រង់ក៏មិនទាន់ស្កប់ព្រះរាជហឫទ័យក្នុងការហិរកទាន ឥឡូវទ្រង់គិតថា នឹងបំពេញអជ្ឈត្តិកទានទៀត ។ ។ សក្កទេវរាជទ្រង់អាវជ្ជនាការពិចារណាឃើញហេតុដូច្នេះហើយ ក៏ក្លែងកេរជាព្រាហ្មណ៍ក្មេងមកអង្គុយក្នុងសាលាទាន ។

គ្រានោះ ព្រះរាជាទ្រង់ស្រង់ព្រះខេតជាពត់ព្រលឹម ហើយទ្រង់សោយព្រះស្ងោយមានតុជារសផ្សេង ។ ស្រេចស្តេចទ្រង់ប្រថាប់គ្រឿងអលង្ការ ក្សត្រាទ្រង់ឡើងគង់លើព្រះទីនាំងគជេន្ទ្រ មានពួកអាមាត្យហែហមជាបរិវារ ទ្រង់យាត្រាឆ្ពោះទៅកាន់ទានសាលា, លុះដល់កាលណាក៏ទ្រង់ចុះចាកព្រះរាជទីនាំង ចូលទៅក្នុងសាលា ទ្រង់បែងចែកព្រះរាជទ្រព្យព្រះរាជទានក្នុងពេលនោះតាមធម្មតា ។ គ្រានោះ ឥន្ទ្រព្រាហ្មណ៍លើកតំបង់អញ្ជលីជាក់លើស្មាសាត្រាថ្វាយបង្គំទូលថា "បពិត្រព្រះសម្មតិទេវរាជ្យ ទ្រង់នូវព្រះរាជសម្ភារ, សូមព្រះអង្គមានជ័យជំនះឈ្នះអស់សត្រូវសព្វគ្រប់ប្រការ" ថាដូច្នេះ ហើយក៏ឋិតនៅក្នុងទីដ៏សមគួរ ។

លំដាប់នោះ ព្រះពជាទ្រង់ព្រះសវនាការពាក្យនោះហើយ ទ្រង់ត្រិះរិះថា "ព្រាហ្មណ៍នេះចង់បានអ្វីអែះ? បើដូច្នេះ អញនឹងសួរវាមើល" កាលមានព្រះបន្ទូលសួរនូវហេតុនោះទើបត្រាស់នូវបឋមគាថាថា:

ហរិតសរីរោ តរុញ្ច ទស្សនីយោ សុរូបិយោ
បគ្គយ្ហ អញ្ជលិញ្ចរិ កិំ មំ យាចសិ ព្រាហ្មណាតិ

ម្នាលព្រាហ្មណ៍, អ្នកឯងមានសរីរៈហាក់ដូចជាលាបស្រឡាបដោយខ្ទឹមបន្ទុំក្រហម គួរឲ្យអ្នកផងក្រឡេកមើល, រូបអ្នកសោតក៏ស្រស់បំព្រង គួរឲ្យអ្នកផងគយគន់, អ្នកមកអង្គុយប្រណម្យអញ្ជលីនៅទីនេះ តើអ្នកចង់បានអ្វី? ។

ព្រាហ្មណ៍បានស្តាប់ហើយ ក៏មានចិត្តរីករាយត្រេកអរគ្រាបបង្គំទូលសុំព្រះពជទៅ ទើបគ្រាបទូលនូវព្រះគាថាទីពីរថា:

យថា វារិវហោ បូរោ សព្វកាលំ ន ទិយ្យតិ
ឯវំ ត្វំ យាចិតាគញ្ច នេវ មេ ទេហិ យាចិតោតិ

បពិត្រព្រះនរបតី, ទឹកក្នុងបឹងស្ទឹងវៃព្រឹក តែងហូរទៅគាន់សមុទ្រសព្វកាល មិនចេះអស់យ៉ាងណា ព្រះរាជទ្រព្យរបស់ព្រះករុណា ក៏តែងតែជះថ្វាក្នុងការព្រះរាជទានពុំមានអស់យ៉ាងនោះដែរ; ទូលព្រះបង្គំជាខ្ញុំមកសូមព្រះនាងទេវី សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទានកុំខាន ។

ព្រះរាជាទ្រង់បានព្រះសវនាការពាក្យព្រាហ្មណ៍ ក្រាបបង្គំទូលសូមព្រះនាងទេវីដូច្នោះហើយ, ទ្រង់ក៏មានព្រះបីតិសោមនស្សអស់ពីព្រះរាជហឫទ័យ ហាក់ដូចជាបុរសកំសត់បានមាស ๑ ពាន់ដំឡឹងអំពីសំណាក់ព្រះមហាក្សត្រ ទើបទ្រង់មានព្រះរាជឧង្ការត្រាស់នូវគាថាគំរប់ ๓ ថា:

ទទាមិ ន វិកម្បាមិ យំ មំ យាចសិ ព្រាហ្មណ
សន្តំ ន បដិគុយ្ហាមិ ទានេ រមតិ មនោ មិ

ម្នាលព្រាហ្មណ៍, អ្នកសូមរបស់អ្វី យើងឲ្យរបស់នោះឥត ខើសឆាល់ទេ យើងមិនលាក់ទុករបស់ដែលមានទេ, ចិត្តយើងត្រេកអរបំពេរការឲ្យទានតែម្យ៉ាង ។

ទើបទ្រង់ត្រាស់ហៅព្រះនាងទេវីមកថ្កាប់ថា: "ម្នាលប្អូនស្រីជាទីស្រឡាញ់ពេញចិត្ត, ដ្បិតព្រាហ្មណ៍នេះមកសូមនាង យើងថ្វាយសត្វញ្ញតញ្ញូណ ចូរនាងបំពេញទានជាមិដល់យើងឲ្យបានសម្រេចដូចសេចក្តីថ្វាយចុះ ។ ឯអគ្គមហេសីជាស្ត្រីគ្រប់លក្ខណ៍ លុះបានស្តាប់ដាក់ក៏មានព្រះរាជហឫទ័យត្រេកអរសោមនស្សអស់ពីព្រះចិត្តា ហើយមានព្រះរាជសវនីយទូលព្រះរាជឧង្ការថា:

ទាសី តុយ្ហំ អហំ ទេវ សាធិកា មម តិស្សរោ
យស្សាប្ប តស្ស មំ ទជ្ជា វិក្កីឡេយ្យ ហរេយ្យ វាតិ

បពិត្រព្រះរាជសម្ភារ, សូមទ្រង់ព្រះករុណាមេត្តាត្រាស,

ខ្ញុំម្ចាស់ជាទាសីរបស់ព្រះអង្គស្រាប់ ព្រះអង្គជាម្ចាស់លើខ្ញុំ ព្រះអង្គ, បើព្រះអង្គត្រូវការព្រះពជ្ឈាន៍ដល់នរណា, សូមទ្រង់ព្រះពជ្ឈានតាមសព្វព្រះពជ្ឈហប្ញទ័យ; ទុកណាជាព្រះអង្គត្រូវការលក់ដូរយ៉ាងណាក្តី សម្ងាប់បង់ក្តី កំសែងធនធ័ន ព្រះពជ្ឈប្ញទ័យព្រះអង្គស្រាប់ ។

ព្រះពជ្ឈាទ្រង់ព្រះសវនាការព្រះពជ្ឈសវនីយ នៃព្រះអគ្គមហេសី ដែលទទួលត្រមដូច្នោះហើយ ក៏ពាក្យយកក្អមមាសហើយចាប់ព្រះហស្ត ព្រះអគ្គមហេសី បួងសួងយកផែនដីជាបន្ទាល់, ទ្រង់ផ្ចង់ស្មោទកហើយ ត្រាស់យ៉ាងនេះថា "ម្នាលព្រាហ្មណ៍, កុរិយាបស់យើងជាទីស្រឡាញ់ពេញចិត្តក្រៃពេក, ប៉ុន្តែយើងបង់បានសព្វញ្ញុតញ្ញាណលើសលុបជាងនេះ មិនអាចពាក់ថា ១ រយគុណ ១ ពាន់គុណ ១ សែនគុណបានឡើយ, បានជាយើងស្ប៊ូលះបង់នាងទៅជាទីស្រឡាញ់ពេញចិត្ត ឲ្យដល់អ្នកឯង យើងមិនប្រាថ្នាសម្បត្តិមនុស្ស សម្បត្តិសួគ៌ សម្បត្តិព្រះឥន្ទ្រ សម្បត្តិព្រហ្ម សម្បត្តិសាវ័ក សម្បត្តិបច្ចេកពុទ្ធឡើយ ប្រាថ្នាចំពោះសព្វញ្ញុតញ្ញាណនៃម្យ៉ាង" លុះទ្រង់ត្រាស់ដូច្នេះហើយ ទ្រង់ព្រះពជ្ឈានព្រះអគ្គមហេសីដល់ព្រាហ្មណ៍ក្នុងកាលនោះឯង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ សម្តេចព្រះបរមសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះទ្រង់ត្រាស់ថា:

ទេវី ហត្ថេ គហេត្វាន ឧទកមណ្ឌលំ គណ្ហិ
បសន្នមនសង្កប្បោ តស្សុ ទេវី អទាសិ សោ
ទេវិយា ទទមានាយ បិយបិត្តេន បមោទិតោ
តស្មា បឋវី កម្បត្ថ សិនេរុនវដិសកាតិ

ព្រះពាជាអង្គនោះបានចាប់ព្រះហស្តព្រះនាងទេវី ហើយកាន់យកភ្លុមទឹកមានព្រះទ័យដ៏ជ្រះថ្លា បានប្រទានព្រះនាងទេវី ដល់ព្រាហ្មណ៍នោះ កាលបើទ្រង់ព្រះពាជទានព្រះនាងទេវីរួច ហើយក៏មានព្រះទ័យត្រេកអរជ្រះថ្លា យ៉ាងក្រៃលែង, ព្រោះហេតុនោះ បានជាមហាប្រឋពីញ្ជាប់ញ័រ ទាំងភ្នំសិនេរុក៏អោនលំទោនទោរទន់ ។

ឯព្រាហ្មណ៍នោះបាននាងទេវីហើយ ក៏នាំយកបាត់ពីទីនោះទៅភ្លាម ។ ក្នុងណានោះ ឥន្ទព្រាហ្មណ៍ជាតួអង្គសក្កទេវរាជ និម្មិតជាព្រាហ្មណ៍ថ្មែក មកថ្វាយសព្វសាធុការ ហើយពោលថា

យថា វាវិរោហេយ្យ សព្វកាលំ ឆ ឱយតិ
ឯវិទ្ធំ យាបិតាគញ្ឆិ បុត្តិ មេ ទេហិ យាបិតោតិ

បពិត្រព្រះពាជសម្ភារ, ធម្មតាទឹកស្ទឹងចំណែកតែងហូរទៅកាន់សមុទ្រសព្វ ។ កាល មិនចេះអស់យ៉ាងណា ព្រះទ័យ

ព្រះករុណា កំតែងជ្រះថ្លាក្នុងការព្រះពុទ្ធទានមិនចេះអស់យ៉ាងនោះដែរ; បពិត្រព្រះនរបតី, ទូលព្រះបង្គំជាខ្ញុំមកសូមព្រះពុទ្ធបុត្តិ សូមទ្រង់ព្រះមេត្តាប្រោសព្រះពុទ្ធទាន ។

ព្រះពុទ្ធទ្រង់ព្រះសវនាការពាក្យនោះហើយ ក៏មានព្រះពុទ្ធហ្ឫទ័យសោមនស្សជ្រះថ្លា ទើបមានព្រះពុទ្ធឫក្តាវថា:

ទទាមិ ន វិកម្បាមិ តីសុ្សវោ ឆយ ព្រាហ្មណ
សន្ទំ ន បតិគុយ្ហាមិ ទានេ មេ រមតី មនោតិ

ម្នាលព្រាហ្មណ៍, យើងជាឥស្សរៈ យើងឥតធុញទ្រាន់នឹងការឲ្យទេ អ្នកឯងចាំតែនាំយករបស់ដែលយើងឲ្យចុះ, យើងមិនលាក់លៀមរបស់ដែលមានទេ, ចិត្តយើងត្រេកអរតែក្នុងការបរិច្ចាគទានតែម្យ៉ាង ។

លុះព្រះអគ្គទ្រង់ត្រាស់ដូច្នោះហើយក៏បញ្ជូនព្រះពុទ្ធបុត្តិឲ្យទៅស្រង់ស្ថិតស្ថានព្រះកាយដោយគ្រឿងអលង្ការគ្រប់យ៉ាង ហើយហៅមកឲ្យគង់លើអាសនៈ. ទ្រង់ដប់ព្រះសិរសួងលោមផ្តែផ្តាំសព្វគ្រប់សេចក្តីព្រះចក្ខីកាលនឹងទ្រង់ប្រកាសដល់អស់ទេវតាចាំឆ្ងាយ យកជាបន្ទាល់សាក្សី ទើបទ្រង់ត្រាស់ខ្ញុំព្រះគាថាថា:

ហាហា ភោន្តោទេវសង្ឃា សព្វេ ទេវា សមាគតា
ទានំ មេ អនុមោទន្តុ បុញ្ញំ គណ្ហន្តុ ឆឌ្ឌិតំ

តស្ស បុត្តិញ្ច ទស្សាមិ បិយំ បិត្តេន ទេមិហំ
បុត្តិមហំ សុភជាតិំ ភោគិយា យេវ ការណាតិ

បពិត្រទេពតាទាំងឡាយអើយ! សូមពពួកទេវតាអញ្ជើញ
មកជួបជុំជាបន្ទាល់សាក្សីពេជ្ឈញ្ញាណ សូមជួយអនុមោទនា
ទានរបស់ខ្ញុំ ហើយសូមទទួលយកចំណែកបុណ្យនេះ ដ្បិតខ្ញុំ
បានឲ្យបុត្រីជាទីស្រឡាញ់ពេញចិត្តប្រកបដោយរូបឆោមប្រពៃ
ដើម្បីនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដក្នុងអនាគត ។
លុះទ្រង់ត្រាស់ដូច្នេះហើយ ក៏ព្រះរាជទានព្រះរាជបុត្រីដល់
ព្រាហ្មណ៍ក្នុងកាលនោះឯង ។

ត្រានោះកើតមានសេចក្តីអស្ចារ្យជាអនេកប្រការ ដោយតេជៈនៃ
ការបរិច្ចាគទាន ដែលពុំមាននរណាធ្វើដូចបាន ។ ព្រោះហេតុនោះ
បានជាអង្គសម្តេចព្រះទ្រង់ញាណទ្រង់មានព្រះពុទ្ធដីកាថា:

តទាសិ យំ ភីសនកំ តទាសិ លោមហំសនំ
រាជបុត្តិម្ហិ បទិន្នម្ហិ មេទនី សមកម្បថ ។
អប្ផរិយំ ច អាសិ សោ យោសោ ច រិបុលោ មហោ
បុត្តីភរិយេ បទិន្នម្ហិ សកលេ សគ្គំ កម្បិថាតិ

កន្លងកាលដែលតថាគតបានឲ្យបុត្រីទៅជាទាន តថាគតមាន
សេចក្តីត្រេកត្រអរសព្វសព៌ាង្គកាយ ទាំងផែនដីបាត់ជាទី

ទ្រង់ទ្រង់សត្វចាំងឡាយ កំកង្រែកវែតកញាប់ញ័រ ចាំងហាន
សួគ៌ជាទីនៅអាស្រ័យ នៃពួកទេពនិករ កំញាប់ញ័រអស្ចារ្យ
ជាពន្លឹក ។

គ្រាដែលព្រះមហាសត្វទ្រង់ព្រះពរជាន់រួចហើយ ទ្រង់កំពុងមាន
ព្រះពរជ័យតែកយសោមនស្សស្រស់ស្រាយ ស្រាប់តែសក្កទេវរាជ
ដែលនាំយកព្រះពរជបុត្រីពីមុនោះទៅ ក៏ក្លែងកេរជាព្រាហ្មណ៍ចាស់ប្លែក
ដៃកាន់ឈើច្រត់ មានសក់ស្កូវ មានពុកមាត់ពុកចង្កាវែង ។ មកអង្គុយ
ទៀបទ្វារព្រះពរជដំណាក់ ។ ព្រះពរជាទ្រង់ទស្សនាការកេតឃើញ
ព្រាហ្មណ៍នោះហើយ ក៏ត្រាស់សួរថា:

អបិ តុំ កេន វណ្ណេន កេន វា បន ហោគុនា
អន្ធប្បត្តោសិ ឥតរំ តំ មេ អក្ខាហិ បុច្ឆិតោតិ

នែអ្នកដែលមានរូបអន្ធការ, អ្នកមកពីណា ? មានការអ្វី ?
ចូរអ្នកប្រាប់យើងឲ្យដឹងសេចក្តី កុំបីគោតញ្ញើត ។

គ្រានោះ សក្កទេវរាជបានស្តាប់ព្រះពរជន្ទ្រាវរួចហើយ ក៏ក្រាបបង្គំ
ទូលថា:

ជិណ្ណោហមស្មិ អាគតោ ទីឃមទ្ធានមាគតោ
សុត្វាន សុភរិតញ្ច រាជ អាគតោស្មិ តវ
សន្តិកេ អនុជានាហិ ឥតរំ ទេហិ តុំ មមាតិ

បពិត្រព្រះពជសម្ភារជាបរមក្សត្រដ៏ប្រសើរ ទូលព្រះបង្គំជាខ្ញុំ
ជាមនុស្សចាស់ដពមកពីស្រុកឆ្ងាយជាច់សន្ទែន ឮដំណឹងថា
ព្រះអង្គទ្រង់ប្រកបដោយសេចក្តីសុចរិត ព្រមទាំងមានព្រះ
រាជសទ្ធា បានជាទូលព្រះបង្គំជាខ្ញុំមកដើម្បីសូមព្រះនគរ, សូម
ទ្រង់ព្រះរាជទុញ្ញាតព្រះរាជទាននគរដល់ទូលព្រះបង្គំជាខ្ញុំ ។
ព្រះមហាសត្វទ្រង់ព្រះសវនាការហើយ ក៏មានព្រះបិតិសោមនស្ស
អស់ពីព្រះទ័យ ទើបទ្រង់លះបង់ព្រះសិរីរាជសម្បត្តិ ព្រះរាជទានដល់
ព្រាហ្មណ៍, ទ្រង់មានព្រះរាជឧទ្ឋារថា:

គណ្ហាហិ តវំ ឥច្ចម្ហិ ឥសូរោ ឆយ ព្រាហ្មណ
មនោរបិ បូរេស្សាមិ ទាឆេ មេ រមតី មនោតិ

ម្នាលព្រាហ្មណ៍, ចូរអ្នកជាធំលើនគរ តាមសេចក្តីប្រាថ្នា
របស់អ្នកចុះ, យើងនឹងបំពេញសេចក្តីប្រាថ្នារបស់អ្នកឲ្យ
បានពេញលេញដូចបំណង ព្រោះចិត្តយើងតែងត្រេកអរ
តែក្នុងការបរិច្ចាគទាន ។

ទើបព្រះរាជាចាប់យកកន្ទីរមាស មកដួចស្នោទក ហើយទ្រង់
ព្រះរាជទាននគរនោះ ដោយព្រះរាជឧទ្ឋារវួសពាយថា:

ឥទំ ហិ នគរំ មយ្ហំ សព្វលោកសមិទ្ធំ
ទត្វាន នគរំ ឥទ្ធំ ខេត្តបិណ្ឌំ វ ឆឌ្ឌិតំ

សំសារតរណត្ថាយ កាមរាគមហណ្ណវេ
សព្វេ សត្តា បរិត្តាវ៎ បាបុណាសិ្សមិ ធិឪតិត្តិ

នគរបស់យើងនេះ ស្តុកស្តម្ភជាងស្រុកដែលមាននៅក្នុងលោកទាំងអស់ យើងបានឲ្យនគរនោះ ផុតស្រឡះពីដួងចិត្ត ឥតមានសេចក្តីស្តាយស្រណោះ ដូចជាបុគ្គលស្តោះចោលទូវដុំនៃទឹកមាត់ដូច្នោះ; សព្វសត្វទាំងឡាយដែលវិលកើតស្លាប់នៅក្នុងមហាសមុទ្រគឺកាមភពនោះច្រើនណាស់; យើងប្រាកដជានឹងបានជួយសត្វទាំងនោះ ឲ្យឆ្លងចាកសង្សារវដ្ត ទៅកាន់ព្រះនិព្វានបានពុំខាន ។

សម្តេចព្រះសក្កទេវិន្ទ្រពិនិ្ទអមក បានឃើញទឹកព្រះទ័យគួរជាទីអស្ចារ្យក៏លាន់ព្រះឧស្នឋថា "ឧហ្ម! ព្រះពជានេះប្រាកដជាពុទ្ធង្កុរបណ្តុលពុទ្ធវង្សជាអគ្គសព្វញ្ញុពុទ្ធ ជាទីពឹងពាក់សំណាក់អាស្រ័យនៃមនុស្សនិងទេវតាទាំងឡាយទៀងអនាគតពុំខានឡើយ", ហើយក៏បង្គំទូលព្រះពជាថា "បពិត្រមហាពជ, ខ្ញុំជាព្រះឥន្ទ្រទេតើ មិនមែនព្រាហ្មណ៍ទេ, ខ្ញុំបានឃើញព្រះអង្គប្រតិ្តត្តសុបរិតធម៌ បានជាមកជួយបំពេញសព្វញ្ញុតញ្ញាណ; បពិត្រមហាពជ, សូមព្រះអង្គទទួលយកបុត្រីនឹងអគ្គមហេសីនឹងនគរ ព្រះអង្គវិញចុះ" ។ សក្កទេវពជ ក៏ប្រគល់ព្រះពជបុត្រីនឹងអគ្គមហេសីថ្វាយ

ព្រះបាទវិបុលរាជហើយនូនព្រះសិរីគំនាប់ដោយសមគួរ ទើបក្លែងកេងជា
ព្រះឥន្ទ្រមានព្រះកាយដ៏រុងរឿងល្អក្រៃពេក ហោះផ្លោះផ្លេកឡើងទៅ
កាន់អាកាស ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ដំណើរសេចក្តីតាមរឿងនេះ
ដែលតុំពាន់ច្រាកដ លុះសម្តេចព្រះសុគតបរមសាស្តា ចាន់ត្រាស់ឡើង
កាលណា ទើបទ្រង់ប្រកាសសេចក្តីនោះឲ្យច្រាកដឡើងថា:

តស្ស សង្កប្បមញ្ញាយ មឃវា ទេវកុញ្ជរោ
អាកាសគគណេ បត្វា ឥទំ វចនមព្រវិ
និដ្ឋាទិតា តេ បហិ សទ្ធោ តេ តិទិវង្គតោ
សមគ្គា វិដ្ឋិតា អាគ្ម គីរីនំ វ បតិស្សុតា
តស្ស តេ អនុមោទន្តិ ឧភោ នារទបព្វតា
តិន្នោ ព្រហ្មា បជាបតិ សោមោ យមោ វេសុវណោ
សព្វេ ទេវា អនុមោទន្តិ ទុក្ករំ ហិ ករោតិ សោ
ទុទ្ទមំ ទមមានានំ ទុក្ករំ កម្មកុព្វតំ
អសន្តោ នានុកុព្វន្តិ សតំ ធម្មោ ទុរន្វយោ
តស្មា សតញ្ច អសតំ នានា ហោតិ តិតោ គតិ
អសន្តោ និរយំ នេតិ សន្តោ សគ្គបរាយនោតិ

មឃវៈជាទេវកុញ្ជរ ឃាននៃជាបន្ទរពាក្យចិត្តព្រះមហាសត្វនោះ
ហើយក៏ហោះផ្លោះឡើងទៅកាន់អាកាស ប្រកាសសរសើរ
គានធម៌ថា ផែនដីរបស់ព្រះអង្គញាប់ញ័រហើយ កិត្តិស័ព្ទ
របស់ព្រះអង្គ ផ្សាយទៅហើយរហូតដល់ពិភពត្រៃត្រឹង្ស
ទាំងផ្ទេកបន្ទោរកំដាលធ្វៀលឆ្វាត់ច្រវាត់ជុំវិញ សត្វទិស-
នានា សេចក្តីអស្ចារ្យមានច្រើនដរហូតដល់សត្វតិរច្ឆានត
សម្តែងសាគរហាក់ដូចជាមានអំណរជួយត្រេកអរ ចំពោះ
គានធម៌នៃព្រះអង្គ ទាំងពួកអមរវង្សអគ្គឥន្ទ្រាហ្មជាបតី
ទាំងព្រះអាទិត្យព្រះចន្ទ្រ ព្រះយមកាជព្រះវេស្សវ័ណក្តីសឹង
មានសេចក្តីត្រេកអរគ្រប់ៗ គ្នា ទទួលអនុមោទនាសរសើរ
ព្រះអង្គថា ឧ! ព្រះបាទវិបុលកាជអើយ! ព្រះអង្គទ្រង់បរិច្ចាគ
គានឥតមាននរណាធ្វើដូចព្រះអង្គបានឡើយ, បុគ្គលជា
សប្បុរសតែងឲ្យរបស់ដែលគេឲ្យបានដោយកម្រ តែងធ្វើ
នូវអំពើដែលអ្នកទាំងពួងធ្វើបានដោយកម្រ, ឯអសប្បុរស
ធ្វើតាមយ៉ាងនេះផងពុំបានទេ, ធម៌របស់ពួកសប្បុរសទាំង
ឡាយ គឺពួកអសប្បុរសកម្រទំងប្រព្រឹត្តតាមកើតណាស់
ព្រោះហេតុនោះ បានជាសប្បុរសទំងអសប្បុរសតែងមានគតិ

ដំណើរអង្វៀលទៅកាន់តពផ្សែងគ្នា គឺអសប្បុរសតែងទៅ
កាន់ទុគ្គតិភព សប្បុរសរមែងទៅកាន់ស្ថានសួគ៌ ។

សក្កទេវរាជនោះលុះពោលសរសើរព្រះបាទវិបុលរាជរួចហើយ ក៏
ហោះត្រឡប់ទៅកាន់ឋានអាត្មាវិញហោង ។

តមត្ថំ បកាសេត្វោ សក្កោ អាហ ព្រះសាស្តាចរិយាវង្ស
កាលទ្រង់ប្រកាសសេចក្តីនោះទ្រង់ត្រាស់ថា:

តទាទិ វត្វា ឧ. មយារិ ទេវរាជា សុជម្បតិ
ពោធិសត្តំ ឋិតំ កត្វា សគ្គកាយំ អបក្កមាតិ

ទេវរាជឈ្មោះមយវ៉ា ជាស្វាមីនៃនាងសុជាតា ពោល
សរសើរព្រះពោធិសត្វដូច្នេះហើយ ក៏ភៀសខ្លួនចៀសចេញ
ទៅកាន់ទេវលោកទៅ ។

ព្រះបាទវិបុលរាជទៅក្នុងសុចិវត្តីសីមហានគរ ទ្រង់ប្រកបដោយ
ទសពិធរាជធម៌តមានល្អក់កករ ក្នុងព្រះរាជហ្ឫទ័យឡើយ ហើយទ្រង់
សន្សំបុណ្យទាំងឡាយមានទានជាដើម រៀងរាបដរាបដល់អស់ព្រះ
ជន្មាយុ ស្តេចបានទៅសោយសេចក្តីសុខក្នុងទេវលោក ។

សម្តេចព្រះបរមសាស្តាចារ្យ ទ្រង់នាំធម៌ទេសនាមកសំដែងប្រាប់
ភិក្ខុទាំងឡាយថា "ម្នាលភិក្ខុទាំងឡាយ តថាគតបានឱ្យទានដ៏ធំនេះ
មិនមែនតែក្នុងកាលឥឡូវនេះទេ, កាលពីមុនដែលតថាគតកើតជាស្តេច

វិបុលភាជ កំតថាគតបានឲ្យទានមានសេចក្តីអស្ចារ្យជាអនេកប្រការយ៉ាងនេះដែរ ។ លុះត្រាស់ដូច្នោះហើយ ព្រះអង្គប្រកាសនូវសច្ចធម៌តាំងឡាយ ទើបទ្រង់ប្រជុំជាតកកំណត់បំផុតនៃសច្ចកថាថា "ស្តេចទេវតាបានចេរឋិលរឹងមកកើតជាកិកឈោះអន្ទរទ្វ, នាងសុន្ទរីទេវីជាអគ្គមហេសីព្រះបាទវិបុលភាជ បានចេរឋិលរឹងមកកើតជានាងយសោធរាពិម្ពា ជាមាតាពហុល, នាងសុចីជាភជបុត្តីនៃព្រះរាជានោះ បានមកកើតជានាងកណ្ហកត្តេរី, ពួកជនអ្នកប្រទេសសុចិវត្តីកំណើតកាលណោះ គឺជាពុទ្ធបរិស័ទរបស់តថាគតកំណើតឥឡូវនេះ, ព្រះបាទវិបុលភាជ គឺជាអង្គតថាគតដែលជាទីពឹងរបស់សត្វលោកហ្នឹងឯង ។

សូមអ្នកទាំងឡាយជាពុទ្ធបរិស័ទ ចងចាំចំណាំជាតកនេះ ដោយបការយ៉ាងនេះឯង ។

ចប់ វិបុលភាជជាតកទី ៦ តែប៉ុណ្ណេះ

ព្រះមហាឧត្តមវិជ្ជា ធីលញ្ញាណោ ប៊ុង-ប៉ែម
អាចារ្យសាលាជាលីវង់ រត្តបឧមវតី ក្រុងភ្នំពេញ រៀបរៀង
ឃុនបណ្ឌាឧរុក្ខ ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តចប់)

៥— បេះដូងញ៉ូនឯង.— *ការផ្តាញ់ខ្លួនឯង គឺផ្តាញ់ចិត្តខ្លួនឯង ដោយការតស៊ូច្បាំងការពោរពាំងខា នូវអំណាចខាងទាបគឺសេចក្តីអាក្រក់ ដោយអំណាចខាងខ្ពស់គឺសេចក្តីល្អ ។ យើងដែលនឹងផ្តាញ់ខ្លួនឯងនោះ ត្រូវតែជាអ្នកតស៊ូដ៏រឹងប៉ឹង នឹងដឹង អង់អាច មាំមួននឹងខែងរែង រឹងដូចជាកំពែងថ្ម តាំងវិនិយបង្គាប់ចិត្តខ្លួនឯងឲ្យនៅក្នុងអំណាចខាងខ្ពស់ ដូចជាសតិសម្បជញ្ញៈ, ប្រឹងប្រែង, ព្យាយាម, អង់អាច, ភ្ញាហាន, អត់ធ្មត់, មេត្តា, ករុណា, មុទិតា, ហិរិ, ឧត្តប្បៈ, ស្មោះត្រង់, សុចរិត, កតញ្ញូ, សម្មាគារៈ, យុត្តិធម៌ នឹងសុភាពរៀបរយជាដើម ។ សូម្បីបេះដូង (ចិត្ត) យើងតូចតាចចង្អៀតក៏ដោយ ក៏គួរជាក់បញ្ចុះខាំងនេះខ្លុក ព្រោះសេចក្តីល្អខ្លុកដូចជាសាច់មាសបរិសុទ្ធពិតៗ ។ ខ្លួនយើងនឹងមានសណ្ឋានតូចប្តឹងនោះ លើកខ្លុកចុះ តែគួរធ្វើឲ្យកម្ពស់ចិត្តធំជាងសណ្ឋានត្រង់ច្រើយរូបកាយ ឬយ៉ាងហោចណាស់ ក៏កុំឲ្យតូចជាងពងក្រួ*

ដែរ សូម្បីអំណាចខាងតាបដូចយ៉ាង លង់ទៅមិនស្គាល់ខុសត្រូវ, ខ្ជិលច្រអូស, មាក់ងាយ, មឹតពត់, រួញារ, ច្រេងច្រកាង, យោរយៅ, ឫស្យា, ឈ្នានីស, រៀចវៃ លុបគុណ, ក្អេងក្អាង, អំនួតនឹងកិរិយា រាចារអាក្រក់គ្រោតគ្រាតជាដើម ជន្លួសយ៉ាងខ្លាំងខ្លាប់ចូលមកភ្ជាប់ញឹកដោយ កំយើងត្រូវខំតស៊ូឲ្យរាត់ថយវិនាសទៅវិញតាមគ្នា បើយើងធ្វើបានយ៉ាងនេះ ផ្សាន់គឺការឈ្នះខ្លួនឯង កំបានជារបស់យើងជាប់ខាត ។

ការផ្ដាច់មនុស្សទាំងពួង ដោយហេតុដទៃ ដូចយ៉ាងគេក្រោធឹងយើងកំក្រោធឹងតប យ៉ាងហោចណាស់ កំប្រើវាចាពោលស៊ីកសៀតចាក់ដោតឲ្យគេវិញ ឬប្រើរាងកាយឲ្យវាយទះតប់គ្នា បើឈ្លោះគ្នាយ៉ាងខ្លាំងកំប្រើមុខសស្ដាវុធចាក់កាប់ចាញ់សម្លាប់គ្នា តាំងអំពីតគួរហួតដល់កជាពួកជាកងចូលច្របួកគ្នានោះ សូម្បីយើងឈ្នះគេបានដោយសេចក្ដីក្សាហានអង់អាច មិនមាននរណាហ៊ានតបតមកវិញក៏ដោយ កំការឈ្នះដែលបង្កសេចក្ដីក្រវល់ក្រវាយ នឹងការញ៉ាំញីច្របូសាយដែលជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ ឲ្យកើតឡើងដល់ខ្លួនយើងដែរ ចូលក្នុងទំនងថា "ចាចទឹកជាក់គ្នា" ឬ "លាងដម្រែរបស់ស្មោកគ្រោកដោយទឹកក្រខ្វក់, លត់ភ្លើងដោយបង្គួរទុស" ហេតុនេះ ទើបយើងមិនគួរពេកយចំពោះការបរាជ័យរបស់មនុស្សដទៃ នឹងមិនគួរពេកយចំពោះជ័យជំនះរបស់ខ្លួនដោយ

ហេតុយ៉ាងនេះទេ ។ ព្រោះការឈ្នះបែបនេះ ជាជំនះមិនពិត អាច
ត្រឡប់ចាញ់វិញបាន . មិនមែនជាវិធីរម្ងាប់ពៀរទេ ត្រឡប់ជាវិធីជាប់
ជំពាក់ដោយពៀរកន្ទុយទៅវិញ ។ ក្នុងបច្ចុប្បន្នយើងឈ្នះគេយ៉ាងណា ក្នុង
អនាគតគេនឹងត្រឡប់ឈ្នះយើងវិញយ៉ាងនោះ ។ យើងឈ្នះគេប៉ុណ្ណា
នឹងត្រូវត្រឡប់ចាញ់គេវិញប៉ុណ្ណោះ ផ្ទុំមនឹងការឈ្នះខ្លួនឯងពុំបាន
ឡើយ ។ ព្រោះការឈ្នះខ្លួនឯងនេះជាជំនះដ៏ប្រសើរ, ជាជំនះដ៏លើស
លុប ជាជំនះដាច់ស្រេចមិនដែលត្រឡប់ចាញ់វិញ, ជាវិធីមិនជាប់ជំពាក់
ដោយវេរកន្ទុយ, ជាទីតាំងនៃសេចក្តីក្សេមក្សាន្តផុតពៀរកន្ទុយគ្រប់ផ្នែក;
អ្នកឈ្នះខ្លួនឯងឈ្មោះថាជាចមពលនៃចមពល ខ្ពស់ជាងចមពលដែល
ឈ្នះមនុស្សព្រមទាំងជាច្រើនលានដងក្នុងសង្គ្រាមទៅទៀត ។

ក្នុងកាសិតជយសូត្រ ពោលដល់ការសង្គ្រាមរវាងទេវតាដែលមាន
ព្រះឥន្ទ្រជាមេទ័ពតទល់នឹងពួកអសុរ ដែលមានព្រះចាតវេបចិត្តិសូរជា
នាយកដឹកនាំ ដែលមានមកជាច្រើនលើសច្រើនគ្រា; គ្រាមួយ ព្រះចាត
វេបចិត្តិសូរដឹកនាំព្រះឥន្ទ្រឲ្យច្បាំងគ្នាដោយសុភាសិត គឺបើនរណា
និយាយជាធម៌ អ្នកនោះនឹងឈ្នះ; កាលយល់ព្រមគ្នាហើយក៏តាំង
គណកម្មការជាន់ខ្ពស់មួយទុកកាត់សេចក្តី ។ ព្រះចាតអសុរិន្ទបាន
ពោលឡើងថា ៖

"ពួកមនុស្សពាល បើគ្មានគេបង្ហិបង់ទេក៏មុខជាបះបោរចលាចលតែរាមិនខាន ដូច្នេះ អ្នកមានបញ្ញាទើបគួរបង្ហិបមនុស្សពាលឲ្យហើយដោយអាជ្ញាយ៉ាងខ្លាំង" ។

ព្រះឥន្ទទត្តបថា ៖

"ខ្ញុំយល់ឃើញថា វិធីការបស់អ្នកប្រាជ្ញយ៉ាងនេះទៅវិញ គឺបើពាលខ្លាំងខ្លាក់ចលាចលឡើង យើងត្រូវមានសតិស្មារតីរម្ងាប់ចិត្តទុកនេះជាគ្រឿងបង្ហិបមនុស្សពាល" ។

អ - "លោកវាសវៈ! ខ្ញុំយល់ឃើញទោសនៃការអត់ធន់ដូច្នេះថា: កាលណាជនពាលសំគាល់ថែការអត់សង្កត់ចិត្តថា ជាការអត់សង្កត់ ព្រោះខ្លាចវាហើយ វាក៏ធឹងបានចិត្តឡើងជិះជាន់កាលនោះ ចូលក្នុងចំនងថា "គោចេះតែរត់គេតែតែដេញ" ។

ឥ - "ទោះមនុស្សពាលចូលចិត្តថា ការអត់សង្កត់ចិត្តនោះព្រោះខ្លាចវា ឬបែបណាក៏ដោយ ក៏អ្នកជំនាញការឥតអើពើ ។ ព្រោះថាក្សួនប្រយោជន៍ហើយជាកំពូលនៃប្រយោជន៍ខ្លួននោះ គ្មានគុណធម៌ណាក្រៃលែងជាងខន្តីទេ ។ អ្នកដែលមានកំឡាំងខ្លាំងរឹងរែង អត់ទ្រនឲ្យអ្នកខ្សោយ អ្នកប្រាជ្ញលោកហៅការអត់ធន់នោះថាជាកំពូលនៃខន្តី ព្រោះមនុស្សគ្មានកំឡាំង មុខជានឹងចាញ់ទៅឯង ។ មិនចាំបាច់ធ្វើអ្វីទេ ។ អ្នកណាមានកំឡាំង ហើយប្រើកំឡាំងដូចមនុស្សពាល អ្នក

ច្រើនជាមិនហៅកម្លាំងនៃអ្នកនោះថាចំបាប់ជាកម្លាំងឡើយ លុះតែមានកំហឹងហើយ មានធម៌ឃុំគ្រងការពារខ្លួនផង ទើបគ្មាននរណានឹងចោទបាន ។ មនុស្សគ្រោធតបចំពោះអ្នកដែលគ្រោធនឹងខ្លួន តែឲ្យបានឈ្មោះថាជាមនុស្សថោកទាបជាងអ្នកដែលគ្រោធចំពោះខ្លួនទៅវិញ ។ មនុស្សមិនគ្រោធតបចំពោះអ្នកដែលគ្រោធ ចាត់ថាឈ្នះសង្គ្រាមដែលគេឈ្នះបានដោយកម្រ ។ អ្នកដែលដឹងថាពាលបះបោរចលាចលរឹតវែងឡើងហើយ មានស្មារតីអត់សង្កត់ចិត្តទុកបាន ឈ្មោះថាធ្វើប្រយោជន៍ដល់ខ្លួននឹងអ្នកដទៃបានច្រើនពីរបីណែក ។ កាលបើចំណែកយើងនឹងចំណែកគេទាំងពីរជាប់ទាក់ទងគ្នាហើយ ក៏ជាការអស់សង្ឃឹម) សូម្បីមនុស្សដែលមិនឈ្វាសក្នុងគន្លងធម៌ ទឹងមើយកតែម្ខាងថា "ខន់ខ្លាយ" ក៏ដោយ ក៏ឥតជាខសំខាន់អ្វីឡើយ" ។

បរិយោសាននៃការដែកគ្នាដោយមាត់ គណកម្មការពិចារណាឃើញថា ភាសិតរបស់ព្រះចុងអស់នេះ នាំឲ្យប្រើអាជ្ញា នាំឲ្យចាប់សស្ត្រាវុធ, ញុះញង់ឲ្យគេទាស់គ្នា, ចាក់រុកឲ្យគេឈ្លោះគ្នា. ណែនាំឲ្យគេប្រកួតប្រកាន់ប្រធាំងនឹងគ្នា ។ ឯភាសិតរបស់ព្រះតន្ទមិនដឹកនាំឲ្យប្រើអាជ្ញា មិននាំឲ្យចាប់សស្ត្រាវុធ, មិនញុះញង់ឲ្យគេទាស់គ្នា, មិនចាក់រុកឲ្យគេឈ្លោះគ្នា. មិនណែនាំឲ្យគេប្រកួតប្រកាន់ប្រធាំងនឹងគ្នា ទើប

កាត់សេចក្តីឲ្យត្រឹមតែឯណេះ ។ នេះក៏ព្រោះតែយកឈ្នះខ្លួនបានជាមុន នោះឯង ។

ដូច្នេះ លោក-អ្នក គួរចេះយកឈ្នះខ្លួនឯង ផ្តើមយកឈ្នះសេចក្តីអាក្រក់ដែលជាសត្រូវខាងក្នុង របស់ខ្លួនឯង ដោយសេចក្តីល្អៗ ដូចយ៉ាងយាត់យាំង ទោសៈ, បណ្តុះសតិ, ប្រើបញ្ញា, វក្សាធម៌. បង្ក្រាប់ចិត្តខ្លួនឯង, ធ្វើឲ្យខ្លួនមានអំណាចនៅពីលើចិត្ត, ជាធំចំពោះចិត្តខ្លួនរបស់ឯង, មិនបណ្តោយតាមគាប់ចិត្តរបស់ខ្លួនឯងក្នុងផ្លូវដែលខុស ទើងតាំងចិត្តរៀនឲ្យស្គាល់រឿងធម្មចរិយាគាំងពួង, រៀនឲ្យស្គាល់នាទីចំពោះធម្មជាតិ, គ្រួសារ, មាតាបិតា, ខ្លួនឯង, អ្នកដទៃ, ទើងជាតិសាសនា ហើយចំប្រតិបត្តិតាមនាទីនោះ។ ដោយធ្វើវហ័សជាដើម, ប្លូជាសេចក្តីពិត ដូចជានិយាយពិត, ធ្វើពិត, ប្រយ័ត្នខ្លួនឲ្យប្រព្រឹត្តទៅតាមសេចក្តីពិត, មិនបណ្តោយខ្លួនឲ្យជាសម្រាមអណ្តែតទៅតាមខ្សល់, តាមទឹក, ស្មោះត្រង់ចំពោះខ្លួនឯង, មិនកុហកលួងខ្លួនឯង, ប្តូរឆន្ទៈតែតាមចិត្តខ្លួនឯង, ដឹងថាអ្វីខុស ក៏មិនរកឧបាយមកនិយាយអធិប្បាយពន្យល់កុហកខ្លួនឲ្យឃើញថាត្រូវ, សូម្បីទើងថាអ្វីអាក្រក់ ក៏មិនជំនះធ្វើទៅតាំងចំពាន, ដើម្បីសមត្ថភាពរបស់ខ្លួន ទើងទុកចិត្តខ្លួនឯង, ចាប់របស់ណាធ្លើរបស់នោះឲ្យសម្រេច, ដើម្បីមនុស្សដទៃផងដែរ តែដោយមិនមើលងាយគេ, ជាមនុស្សយុត្តិធម៌, ជាក់ខ្លួនចុះដូចសំពត់ក្រូកអុំមាស, មិន

យល់ឃើញថាត្រូវ តែគេវាទន់ចិត្តកន្ត ។ ដោយសេចក្តីអង្វរឡើយ, ផ្ទឹមគំនិតខ្លួនទឹងគំនិតអ្នកដទៃ, មិនយល់ឃើញថាខ្លួនសុទ្ធតែប្រសើរគ្រាន់បើគ្រប់យ៉ាង, អប់រំសតិសម្បជញ្ញៈឲ្យបរិបូណ៌, ជម្រង់ជីវិតខ្លួនឲ្យត្រង់ដោយគុណធម៌ដែលមាននៅក្នុងខ្លួនចាំងអស់ ទើបបង្អោនខ្លួនឲ្យទៅត្រូវតាមសេចក្តីល្អចាំងពួង មិនបានបំភ្លាត់បំផ្លាញរបស់ណាដែលល្អប្រពៃ នេះជាកុសលោបាយ ដែលប្រើសម្រាប់ផ្តាញ់ខ្លួនឯង ទើងជាវិធីផ្តាញ់អធម្មដោយធម៌ដែលជាការឈ្នះដ៏ប្រសើរវិសេស ។

លោក-អ្នក ចូរយកឈ្នះខ្លួនឯង ដោយវិធីបណ្តុះសំលៀងខ្លួនឲ្យស្រួចមុតដូចមុខសិលា ដែលមានលក្ខណៈមាំទាំខ្លាំងវែងក្នុងខ្លួនឯង ទើងមានសមត្ថភាពការពារលុកដែលចោកបក់សាចចូលមកជានិច្ចចុះ ។ មើលចុះ យើងប្រមៀលថ្នមឡើងលើកុំ ត្រូវខ្ជួលការនឿយហត់ច្រើនណាស់ តែកាលពន្លែងដុំថ្មចុះមកវិញ ក៏មកដល់ដីភ្លាមដោយមិនបាច់ហត់, កម្លាំងចិត្ត បើរឹងប៉ឹងក៏យកឈ្នះខ្លួនឯងបាន បើទន់ខ្សោយក៏ត្រូវចាញ់ខ្លួនឯង ត្រូវមៀលខ្លួនចុះមកកាន់ទីចោកភាប ដោយមិនបាច់ខ្ជល់ខ្ជាយដួយប្រមៀលឡើយ "បណ្តាយភាមួយរយដងប្រសើរជាងការវិភាមួយដង" នេះជាវិធីការរបស់អ្នកចេះផ្តាញ់ខ្លួនឯង "សូម្បីតែហេតុអ្វីក៏វិភាគ្នាដែរ" នេះជាវិធីការរបស់អ្នកចាញ់ខ្លួនឯង ។ កុំខ្លាចត្រង់ឡើយ ! បើយើងបានឈ្នះខ្លួនឯងស្រេចហើយ យើងមុខជាបាន

ខ្លួលសេចក្តីល្អប្រពៃនៃនិស្ស័យរបស់យើងតុំខាន សូមទំញាយាមធ្វើ
ទៅចុះ បើមិនដូច្នោះ ទឹងទៅជាមនុស្សបាញ់ខ្លួនឯង ។ មនុស្ស
បាញ់ខ្លួនឯងនោះ ចូលចិត្តយឺតយោងមនុស្សដទៃក្នុងផ្លូវអាក្រក់ មិនមាន
នរណាដទៃក្រៅពីខ្លួនមកដឹកនាំទេ កាលខ្លួនដឹកនាំហើយ ខ្លួនក៏ត្រូវ
ធ្វើដែរ តាលការដឹកនាំសម្រេចដោយការធ្វើតាមហើយ ក៏ឈ្មោះថាជា
មនុស្សបាញ់ខ្លួន រមែងធ្វើអំពើអាក្រក់ទៅផ្សេងៗ ។ ហេតុនេះ ត្រូវកុំ
បណ្តោយឲ្យបាញ់ខ្លួន គួរយកឈ្នះខ្លួនឯងឲ្យបាន ។ ព្រោះមនុស្សអ្នក
រក្សាចិត្តខ្លួនឯងបាន ប្រសើរជាងអ្នកដែលរាយយកស្រុកនគររបស់គេ
បានទៅទៀត សូម្បីព្រះពុទ្ធជាម្ចាស់ ក៏ទ្រង់ប្រដៅដែរថា មនុស្សឈ្នះ
ខ្លួនឯងម្នាក់ ប្រសើរជាងអ្នកដែលឈ្នះពលទាំងលានក្នុងសង្គ្រាម. គប្បី
ឈ្នះសេចក្តីក្រោធដោយសេចក្តីមិនក្រោធ គប្បីឈ្នះមនុស្សមិនល្អ ដោយ
សេចក្តីល្អ គប្បីផ្តាញ់មនុស្សស្វិតស្វាញ ដោយអធ្យាស្រ័យដ៏ធូលាយ
(មិនកំណាញ់), គប្បីផ្តាញ់មនុស្សនិយាយឡេះឡោះដោយភាក្យពិត ។

និស្ស័យកប់អានខ្លួនឯងនេះ ជាគុណសម្បត្តិដែលមានដំណែរខ្ពង់ខ្ពស់
ជាស់ចំណែកល្អក្នុងធម្មជាតិរបស់ខ្លួនឲ្យភ្លាក់ឡើង តុបតែងចិត្តឲ្យក្លាហាន
មានគំនិតជាន់ខ្ពស់, ដឹកអនុងការប្រព្រឹត្តិ ឲ្យដំណើរទៅតាមច្បាប់
ធម្មតាខាងល្អ, បំបិទទុកមិនឲ្យគិតទៅតាមច្បាប់ធម្មតាខាងអាក្រក់ ដែល
ចាត់ថាជាឫសគល់នៃសេចក្តីល្អទាំងឡាយ នឹងជាទីកើតនៃសេចក្តីគោរព

ភាប់អានឧទ្ទិសកាសតបស្នងដ៏មានដម្លៃអំពីមនុស្សដទៃ ។ ព្រោះកាលបើចំណែកម្នាក់គោរពភាប់អានហើយ ចំណែកម្នាក់ទៀត ក៏ត្រូវគោរពភាប់អានជាការតបស្នងមកវិញ ។

ដូច្នេះ ទើបគួរអញ្ជើញមកចុះ! អញ្ជើញមកបណ្តុះនិស្ស័យភាប់អានខ្លួនឯង ដោយវិធីចេះគ្រប់គ្រងខ្លួនឯង, ចេះពឹងខ្លួនឯង, ចេះជឿខ្លួនឯង, ចេះត្រួតត្រាពិនិត្យពិចារណាខ្លួនឯង នឹងចេះយកជ័យជំនះខ្លួនឯង ដូចបរិយាយមកនេះ ។

រឿងការបណ្តុះនិស្ស័យនេះ មិនទាន់ចប់ទេ ប៉ុន្តែសង្ខេបប៉ុណ្ណេះសិន ។
រឿងនេះនឹងមានបោះពុម្ពតទៅទៀត ក្នុងឆ្នាំខាងមុខ ។

កណ្ឌទី ១៥

ឧកញ៉ាវិបុលរាជសេនា ន្ធូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាឃ្លុំសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ទឹងចេះឧបាយកលបំណាន
ទាំងមានសង្ឃឹងស្នេហាជាតិ ។

ខណៈនោះ ស្រីដែលស៊ើបការកំរត់ទៅដំកបចូឆ្លូថា ឥឡូវព្រៃហៅ
ហៀនតេត្រាស់ឲ្យហៅតាំងស៊ុនចូលទៅគាល់ · ហើយព្រះពជ្ឈានអាវ
ឲ្យជាវង្វាន់ ខ្ញុំឃើញចំឡែកណាស់ ។ ចូឆ្លូឮដូច្នោះក៏ស្រែកចូលទៅ
កន់ព្រះបរមពជ្ឈំង ទទួលដួបនឹងតាំងស៊ុនចេញមកដល់ទ្វារ ក៏សាក
សួរថា អ្នកមកពីណា? ។ តាំងស៊ុនឆ្លើយថា មានព្រះពជ្ឈរង្គារហៅ
ខ្ញុំបាទឲ្យចូលទៅគាល់ ហើយទ្រង់ប្រោសព្រះពជ្ឈានអាវនេះឲ្យខ្ញុំ
បាទ ។ ចូឆ្លូសួរថា ដែលទ្រង់ប្រោសព្រះពជ្ឈានអាវនេះ អ្នកមាន
បំណាច់អ្វី? ។ តាំងស៊ុនឆ្លើយថា ទ្រង់ព្រះដំរិះលើកឃើញកាល
ត្រាខ្ញុំបាទនាំស្តេចរត់ចេញ ពីចំណោមលីឈុយគុយតី ។ ចូឆ្លូបាន

ឮដូច្នោះក៏ពិតាល់កង់ចិត្ត ទើបធ្វើជានិយាយថា អ្នកមានគុណចំណាច់មែន បានច្រៀសព្រះពរជាន់អាវនេះ បើដូច្នេះចូរដោះមកឲ្យយើងពាក់លេងមើលបន្តិច ។ តាំងស៊ីនបានឮដូច្នោះក៏ភ័យស្ទុតចិត្ត សម្លឹងស្ទៀមមិនព្រមដោះអាវនោះ ។ ចូឆូឃើញតាំងស៊ីនធ្វើព្រងើយដូច្នោះ ក៏មានសេចក្តីសង្ស័យ ទើបច្រៀឲ្យគាហានចង្អុំដោះអាវមកពិនិត្យមើល ក៏មិនបានឃើញជាប្លែក ក៏យកអាវនោះទៅពាក់ហើយធ្វើជាសើចថា អាវនេះសមគួរតែខ្លួនយើង អ្នកឲ្យយើងទៅឬអ្វី? ។ តាំងស៊ីនតបថា អាវនេះជាវបស់ព្រះពរជាន ដែលខ្ញុំបានទទឹងដូនទៅលោកនោះមិនគួរ បើលោកត្រូវការច្រើថ្លាហើយនឹងយកទុក ក៏តាមចិត្តលោកចុះ ។ ចូឆូតបថា "យើងនឹងច្រើថ្លាយកមកធ្វើអ្វី អាវយ៉ាងនេះ" ហើយក៏ដោះចោះឲ្យទៅតាំងស៊ីនវិញ តាំងស៊ីនក៏លាចូឆូទៅផ្ទះ ។

លុះវេលាយប់តាំងស៊ីនចូលទៅក្នុងទីដំណេកម្នាក់ឯង យកអាវនោះមកពិនិត្យមើលសព្វគ្រប់ ក៏ឃើញព្រៃសនៅក្នុងជាយស្រទំបហែកចេញមកមើលឃើញជាឡាយព្រះហស្តលេខា នៃព្រះចៅហៀនតេទ្រង់លិខិតដោយលោហិតជាសេចក្តីថា "តាំងពីចូឆូចូលមកនៅក្នុងស្រុកក្រុងបាន ៤ ឆ្នាំហើយ ធ្វើការអត្រក់ផ្សេង ។ បំពារលើព្រះពរជាន់ ទទឹងតាំងចិញ្ចឹមនាម៉ឺនឡើរជការ ឬចុះទោសអ្នកឯណាក៏តាមអំពើចិត្ត មិនមានសេចក្តីគិតកោតក្រែងព្រះចេស្តាបារមី មិនយកសេចក្តីក្រាបទូលស្តីឲ្យ

ទ្រង់ជ្រាប លុះតែយើងអត់ទាំពុំបាន ទើបចាក់យកព្រះលោហិតក្នុងព្រមព្រះហស្ត លិខិតជាសេចក្តីអាថ៌កំបាំងទ្រង់ព្រះពរជាន់មក បើតាំងស៊ុនយល់ឃើញមន្ត្រីទ្វុំពរការឯណា មានសតិបញ្ញាទៀងត្រង់នឹងផែនដី កំបបួលមន្ត្រីនោះមកជាគ្នារៃគិតកំចាត់បង្ខូជាសត្រូវពរជសម្បត្តិឲ្យខ្ចាត់ខ្ចាយចេញ ទើបយើងនឹងអាណាប្រជានុពស្ត្រាំងពួងនឹងបានអស់ទុក្ខគោម្ចាស់ញៅជាសុខក្សេមក្សាន្តតទៅ ។

តាំងស៊ុនឃើញឡាយព្រះហស្តដូច្នោះ ក៏មានសេចក្តីអាណិតអាណាថកងចិត្តពន់ពេកណាស់ អង្គុយយំទ្រឹកទ្រួលតែម្នាក់ឯងចម្ងៃងចិត្តគិតមិនសុខសាប់ តាំងពីព្រលប់យប់យូរស្ងាត់លុះដល់ព្រឹក ដេកមិនលក់សោះ លុះព្រឹកឡើងក៏កាន់ឡាយព្រះហស្តនោះចូលទៅក្នុងបន្ទប់សរសេរ ប៉ះខ្លួនផ្អែកចុះលើកៅអី មើលសេចក្តីចុតហ្វាយនោះទៀតក៏ខំត្រិះរិះធ្វើតនឹងរកឧបាយសម្ងាប់ចូឆ្ងូឲ្យបាន លុះគិតទៅគិតមកក៏មិនឃើញមានផ្លូវត្រង់ណា ទើបយកឡាយព្រះហស្តនោះមកសិកទុកក្នុងដៃអាវ ដោយកំឡាំងដៃលេខ្សោយហត់អត់ឆ្មុយណាស់ ក៏ផ្ងួសលក់លើកៅអីនោះ ។

ខណៈនោះដូហុកជាមន្ត្រីទ្វុំពរការ ជាមិត្តភាក់ងឹតាំងស៊ុនជ្រាប់ទៅមករកគ្នាជានិច្ចនោះ ក៏ចូលទៅឃើញព្រះសុកអក្សរនៅដៃអាវតាំងស៊ុនដែលកំពុងដេកលក់នោះ ចាន់គន់មើលមុខមាត់ក៏ឃើញសៅហ្មងគងដៃលើ

ដើមទ្រូង ដូហុកក៏ហូតយកលិខិតនោះមកលាមើល ឃើញជាឡាយព្រះ
ហស្តព្រះចៅហៀនតេទ្រង់សរសេរដោយព្រះលោហិត ដាក់សេចក្តីស្លុត
ក្នុងសំបុត្រនោះ គឺឲ្យតាំងស៊ុនគិតសម្លាប់ប្អូនចេញ ដូហុកក៏យកឡាយ
ព្រះហស្តនោះមិញលាក់សិកខុកក្នុងដៃអាវរបស់ខ្លួន ហើយកំរៃជាស់តាំង
ស៊ុនឲ្យក្រាក់ឡើងនិយាយថា ហេតុម្តេចក៏មកមានសេចក្តីសប្បាយដែក
លក់ដូច្នេះ ។ តាំងស៊ុនភ្ញាក់ឡើងពរអកឡាយព្រះហស្តមិនឃើញក្នុងដៃ
អាវក៏ភ័យស្ញាំងតាំង ។ ដូហុកឃើញដូច្នោះក៏ភ្លែងនិយាយថា អ្នកនឹង
គិតប្រទូសរ៉ាយប្អូនឬ? យើងនឹងទៅប្តឹងប្អូនឲ្យដឹង ។ តាំងស៊ុនបាន
ស្តាប់ដូហុកនិយាយដូច្នោះ ក៏រឹតតែភ័យពន់ប្រមាណ ស្មានមើលទៅដូច
ទឹងរលត់ជីវិតសូន្យសោះ ហើយថា បើអ្នកនឹងទៅប្តឹងប្អូនោះមិនមែន
ស្លាប់តែខ្លួនយើងមួយទេ បើដូចជាអ្នកធ្វើឲ្យក្សត្រិយ៍ព្រះដន្ធព្រះចៅហៀន
តេផង ។ ដូហុកឆ្លើយថាអ្នកកុំរឹតភ័យខ្លាចឡើយ ខ្ញុំចង់ដឹងហើយ
ទើបពិសោធចិត្តអ្នកមើល ខ្លួនខ្ញុំក៏ជាខ្ញុំក្រោមព្រះបាទព្រះចៅហៀនតេ
សព្វថ្ងៃខ្ញុំក៏គាំងចិត្តស្មុចរិត ទឹងធ្វើពុតការថ្ងាយស្នងព្រះតេជព្រះគុណជា
ដរាប តែថោតតាបសំណាងទឹងរកនរណាដួយគិតជាចារឹតបង្គោល
គ្មាន ត្រូវបើកនៅមានគំនិតគិតទឹងរំលងសត្រូវពុំសម្លាត្តិ ដូចគំនិត
ខ្ញុំដែរ យើងទាំង ៦ ត្រូវទំយកអាសាដែនដីរួមសេចក្តីគិតជាមួយគ្នាត
ទៅ ។ តាំងស៊ុនបានស្តាប់ក៏ភ័តត្រឡប់ចិត្តរីករាយសប្បាយណាស់

ទើបថា បើអ្នកតាំងចិត្តសុចរិតត្រង់នឹងផែនដីមែន ខ្ញុំយល់ឃើញថា ព្រះចៅហៀនតេគង់នៅមានព្រះជាម្ចាស់តេជៈឈ្នះបច្ចាមិត្រជាប្រាកដ ។ ដូហុកថា ខ្ញុំនឹងអ្នកបើនឹងចាប់គិតខំនុកបំរុងផែនដីហើយ ត្រូវតែធ្វើសំបុត្រចុះសញ្ញាគ្នាជាសំគាល់ ទើបនឹងបានតាំងចិត្តគិតការតទៅ ។ ខណៈគាលកំពុងនិយាយគ្នានោះ មានមនុស្សចូលទៅប្រាប់តាំងស៊ុនថា តាន់អ៊ុបនឹងអ៊ាំហួនមានការមកសុំជួប ។ តាំងស៊ុនបានឮដូច្នោះមានចិត្តត្រេកអរនិយាយនឹងដូហុកថា តាន់អ៊ុបនឹងអ៊ាំហួននេះជាគ្រឿនសំឡាញ់ខ្ញុំដែរ បើដូច្នេះចូរអ្នកចូលទៅអែបនឹងកំឆនពីក្នុងសិនចុះ ខ្ញុំនឹងឲ្យហៅគេចូលមក ។ តាំងស៊ុនក៏ឲ្យគេទៅអញ្ជើញចូលមក អ្នកទាំង ២ នាក់ចូលមកហើយ ក៏គំនាប់គ្នាតាមទម្លាប់ហើយតាន់អ៊ុបនិយាយថា កាលព្រះចៅហៀនតេស្តេចទៅប្រពាតដៃ ចូរធ្វើល្មើសនឹងព្រះចេស្តាជាការអាក្រក់ខ្លាំងណាស់ អ្នកមានចិត្តក្តៅខ្លះដែរឬទេ? ។ តាំងស៊ុនថា ខ្ញុំក៏ឃើញច្បាស់នឹងក្នុងហើយ តែមិនដឹងនឹងធ្វើដូចម្តេច? ។

អ៊ាំហួនថា ធម្មជាតដែលកើតមកជាប្រុសហើយ ។ បានមកនៅជាខ្ញុំរាជការ គោះបីអាយុសង្ខារនឹងស្លាប់ក៏ពុំត្រូវសោកស្តាយ ត្រូវខ្វល់ខ្វាយជួយយកអាសាផែនដីឲ្យបានសេចក្តីសុខសប្បាយ ដើម្បីទុកនាមឈ្មោះទៅមុខ ។ ដូហុកដែលអែបនៅកងកំឆនន ឮដូច្នោះក៏ស្ទុះចេញមកនិយាយនឹងតាំងស៊ុនថា អ្នកសូមធ្វើជាបន្ទាល់យើងផងចុះ ព្រោះ

វេលានេះតាន់អ៊ុបនឹងដោ"ហួនគិតគ្នានឹងប្រទូសរ"ាយប្លន់ ខ្ញុំនឹងនាំយក
សេបក្តីនេះទៅជំរាបបច្ចុប្បន្នឲ្យដឹង ។ តាន់អ៊ុបបានស្តាប់ក៏នឹកខឹងឆ្លើយថា
កើតមកជាខ្ញុំផែនដីត្រូវតែមានសេចក្តីកតញ្ញូនឹងព្រះមហាក្សត្រ មិនត្រូវ
គោតខ្លាចវៃក្រែងជីវិតនឹងអន្តរាយទេ ។ តាំងស៊ុនក៏ហាមឃាត់តាន់អ៊ុបថា
"អ្នកកុំអាលខឹងច្រឡោតឡើយ ការណ៍ទាំងអស់នេះខ្ញុំបានគិតហើយនឹង
ជូហុកព្រមចិត្តគ្នាមុនអ្នកទាំង ២ ទៅទៀត ឃានជាខ្ញុំមកធ្វើតប្រឹក្សានឹង
អ្នកជាក្រោយ ឯជូហុកនិយាយនេះ ដើម្បីពិសោធចិត្តអ្នកល្បងមើល
ទេ" ហើយតាំងស៊ុនក៏យកឡាយព្រះហស្តលេខាហុចឲ្យតាន់អ៊ុបនឹង
ដោ"ហួនមើល ។ តាន់អ៊ុបនឹងដោ"ហួនឃើញច្បាស់ជាឡាយព្រះហស្តក៏
ស្រក់ទឹកភ្នែកយំយែក ទឹកអាណិតព្រះចៅហៀនតេពន់ពេកណាស់ ។

ជូហុកនិយាយថា អ្នកទាំង ២ ទៅជាមួយនឹងតាំងស៊ុនចុះ ខ្ញុំសុំទៅ
ហៅជូឡាន់មកជួបទៀត ជូហុកក៏ចេញទៅហៅជូឡាន់ចូលមក ហើយ
យកឡាយព្រះហស្តបង្ហាញឲ្យមើល ទើបគិតព្រមព្រៀងគ្នាចុះឈ្មោះ
ទុកកងសេចក្តីសញ្ញាទាំង ៥ នាក់ ។ តាំងស៊ុនក៏ឲ្យរៀបតុលាងសុភ
ហើយសច្ចាប្រណិធានចំពោះមុខគ្នាទៅវិញទៅមក គឺថាមិនបានយក
សេចក្តីនោះទៅបរិហារឲ្យលេចធ្លុតទៅ ។

មា"ចេងចៅហ្វាយស្រុកសៃលៀងដែលចូលមកកងស្រុកក្រឹង កាល
ព្រះចៅហៀនតេស្តេចទៅប្រពាធព្រៃនោះ ក៏ឃានហៅស្តេចទៅដែរ

ម៉ាថេង៖ឃើញចូធូធ្វើកិរិយាប្រមាថមើលងាយព្រះចេស្តា ក៏មានសេចក្តីឈឺចិត្តគិតខ្មេចមនស្សខ្លាំងណាស់ ។ មានថ្ងៃមួយម៉ាថេង៖ទៅគេតាំងស៊ុនឯផ្ទះ ។ អ្នកចាំទ្វារបួលទៅដំណឹងតាំងស៊ុនថា ម៉ាថេង៖មានការមកគេ ។ តាំងស៊ុនកំពុងអង្គុយផឹកស្រាជាមួយនឹងមន្ត្រី ៤ នាក់ លុះបានឮដូច្នោះក៏ភ័យណាស់ បង្គាប់ឲ្យលើកយកតុះលៀងចេញ ហើយឲ្យមន្ត្រី ៤ នាក់អែបលាក់ខ្លួនកន្លែងក្រោយ រួចក៏គ្រាកចេញទៅទទួល ។ ម៉ាថេង៖ក៏គំនាប់តាមសមគួរ ក្រែឡេកឃើញទឹកមុខតាំងស៊ុននៅមានឈាមស្រស់ថ្លាក៏សំគាល់ថាតាំងស៊ុនមិនមានឈឺចិត្តនឹងដែនដីក៏តូចចិត្ត ទើបថា "ខ្ញុំនអ្នកជាមន្ត្រីព្រះចៅហៀនតេទ្រង់កាប់អានថាជាព្រះពាជវង្ស ហេតុម្តេចអ្នកមិនមានឈឺចិត្តនឹងការដែនដីសោះ" ថាហើយក៏គំនាប់ប្រដែនឹងលាត្រឡប់ទៅវិញ ។ តាំងស៊ុនពីកាល់ក្នុងចិត្តក៏ចាប់ផាយអាវឲ្យឈប់ហើយថា ហេតុម្តេចបានជាអ្នកថាយើងមិនឈឺចិត្តនឹងការដែនដី? ។ ម៉ាថេង៖តបថា កាលព្រះចៅហៀនតេស្តេចយាងទៅប្រពាតដៃ ចូធូធ្វើកិរិយាប្រមាថមើលងាយព្រះចេស្តា យើងជាខ្ញុំពាជការខែត្រក្រែក៏គង់មានចិត្តឈឺចាប់ ចុះអ្នកជាពូជព្រះពាជវង្សព្រះចៅហៀនតេស្រាប់ ហេតុម្តេចមកនៅសប្បាយដូច្នេះ មិនគិតកំចាត់សត្រូវពាជសម្បត្តិចេញទេឬ? ។

(មានត)

ជាលៈនឹង ឧមយន្តី

រឿងព្រេងប្រទេសឥណ្ឌៀ

អ្នកស្រីស្រិន-សារិយ៉ាន់ ក្រមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីភាសាចាក់ឆ័ងមកជាភាសាខ្មែរ

(តមក)

វគ្គទី ៩

ព្រះចាខនាលៈទ្រង់ស្តេចត្រឡប់ទៅទូលអាទិទេពវិញតាមដំណើរបស់ខ្លួនដោយគ្មានលាក់បំណងរបស់ព្រះនាងឧមយន្តីឡង ។ អាទិទេពញញឹមហើយក៏ព្រមព្រៀងទៅឯប្រទេសវិទគិៈជាមួយនឹងព្រះចាខនាលៈ ។

គេបានឱ្យអាទិទេព នឹងព្រះមហាក្សត្រតាំងឆ្ងាយចូលទៅក្នុងបន្ទប់មួយខ្ពស់ដែលមានជញ្ជាំង សសរ នឹងពិតានរំលេចដោយមាសនឹងត្បូងពេជ្រដ៏ភ្លឺរុងរឿងព្រោងព្រាត ។ ព្រះចាខតមៈទ្រង់គង់នៅចាំទទួលព្រះមហាក្សត្រ ដែលមានព្រះពជចំណង់ចង់បានព្រះពជបុត្តីទ្រង់ធ្វើជាឯកអគ្គមហេសី ។ ចំពោះព្រះមហាក្សត្រមួយអង្គ ។ មហាពជទ្រង់ទទួលដោយព្រះទ័យរាក់ទាក់ ដើម្បីនឹងលើកទឹកព្រះទ័យនៃក្សត្រតាំងនោះ ។ ព្រះពជាមានព្រះហឫទ័យរីករាយពន់ពេកណាស់ ពីព្រោះទ្រង់យល់ថាបណ្តាស្តេចដែលមានក្តីល្បីនៅលើដីតាំងនោះ មុខតែព្រះពជបុត្តីទ្រង់ជ្រើសយកណាមួយជាស្វាមី ដែលសមសក្តិនឹងព្រះនាងមិនខាន ។

ព្រះពុទ្ធជាម្ចាស់ធ្វើតាមវត្តប្បដិបត្តិយ៉ាងប្រសើរចំពោះអាទិទេព ព្រះអង្គមានព្រះទ័យធូរស្រាលពន់ពេកដោយឃើញអាទិទេពមកដែរ ។ លុះស្តេចទាំងអស់ឃើញព្រះបាទាលៈ ក៏ទៅយាងមកជុំ ក៏កើតសេចក្តីអស់សង្ឃឹមក្នុងការបានព្រះនាងទេមយន្តីជាកពិយា ។

មហាក្សត្រទាំងអស់គង់លើព្រះទីនាំងខ្ពស់ៗ ហើយព្រះបាទកិមៈខ្ញុំប្រើបំរើឲ្យទៅទូលព្រះនាងទេមយន្តី ។ ព្រះនាងយាងចេញមកដោយមានកាន់កំរងផ្កាឈូក ១ ផង ដើម្បីនឹងពាក់ឲ្យក្សត្រណាដែលព្រះនាងសព្វព្រះហឫទ័យនឹងយកជាស្វាមី ។ ក្សត្រទាំងប៉ុន្មានតាំងគ្រប់មូលក្នែកទៅលើព្រះនាងទាំងអស់ ស្ទើរតែពុំហានដកដង្ហើម ក្នុងបន្ទប់នោះស្ងាត់ជ្រៀប ។ ព្រះនាងខ្ញុំស្តេចយាងសន្សឹមៗ ហើយនឹកថា អញចំណាំព្រះកត្តព្រះបាទាលៈបានហើយ ។ ប៉ុន្តែបន្តិចមកស្រាប់តែព្រះនាងសង្ស័យជាខ្លាំងហើយបើកព្រះនេត្រធំៗ សំឡឹងទៅតែជុងម្ខាងដែលព្រះនាងទតឃើញស្តេចជារោចនរូបមានព្រះកត្តដូចជាព្រះបាទាលៈ ។ លុះមួយស្របក់ព្រះនាងនឹកឃើញថា "នុនេះជាកលល្បិចរបស់ព្រះអាទិទេពដែលដំណែងធ្វើឲ្យដូចជាព្រះបាទាលៈទេតើ, ទោះជាយ៉ាងណាក៏ដោយ ក៏អញមានភ្នែកតែលើរូបព្រះបាទាលៈប៉ុណ្ណោះ" ។ កាលនោះ ព្រះនាងក៏បួងសួងថា: "នុអាទិទេព! ខ្ញុំម្ចាស់បានឮសំដីក្មេងខ្ញុំម្ចាស់មានភ្នែកតែលើរូបព្រះបាទាលៈ ១ ទេ, ខ្ញុំម្ចាស់ស្រឡាញ់

ទ្រង់ ហើយមានចិត្តត្រង់នឹងទ្រង់ផង; ឧត្តមព្រះគុណថ្លៃឧត្តមអើយ! សូមឲ្យខ្ញុំម្ចាស់ស្គាល់ថា ណាមួយ ស្តេចនាល:, ទុកជាយ៉ាងណាក៏ដោយ ខ្ញុំម្ចាស់មិនលះបង់ទ្រង់នាល:ឡើយ សូមទ្រង់មេត្តាបង្ហាញខ្ញុំម្ចាស់ឃើញឲ្យច្បាស់, សូមអាទិទេពចាំងប៉ុន្មានត្រឡប់យករូបរបស់ទ្រង់វិញ ដោយសេចក្តីអំពាវនាវរបស់ខ្ញុំម្ចាស់ . សូមទ្រង់មេត្តាបង្ហាញព្រះបាទនាល: ឲ្យខ្ញុំម្ចាស់ឃើញឲ្យច្បាស់ ខ្ញុំម្ចាស់ស្រឡាញ់ទ្រង់ហើយមានចិត្តត្រង់ចំពោះតែរូបទ្រង់មួយទេ" ។

លុះបានឮសំដីបួងសួងរបស់ព្រះនាងដូច្នេះហើយ អាទិទេពក៏យល់ថា គ្មានអ្វីនឹងអាចបំបែរបំណងព្រះនាងបានឡើយ ទ្រង់យល់ឮវិសេចក្តីស្នេហានៃព្រះនាងដែលខ្ជាប់ខ្ជួនក្រៃលែង ហើយជួយសំរេចសេចក្តីប្រាថ្នារបស់នាង ។ អាទិទេពក៏និមិត្តខ្លួនឲ្យអណ្តែតផុតពីដី ហើយមានកែកនឹងថ្កល់, ចំណែកព្រះបាទនាល:មានព្រះបាទជាប់នឹងដី ហើយពពែព្រះនេត្រ នៅគង់កណ្តាលអាទិទេព ។ ព្រះនាងទមយន្តី កើតសេចក្តីរីករាយឡើង ហើយទ្រង់យាងដោយញាញើតផង យកផ្កាកំរងទៅពាក់ថ្វាយព្រះបាទនាល: ។

* * *

វគ្គទី ១០

គង់ខណៈនោះ · មានតែអាទិទេពទេដែលសំដែងសេចក្តីរីករាយមុនគេ ។ ពួកស្តេចក្រៅពីនោះ ជាក់ព្រះកត្តិចុះបែបអៀនខ្មាស ប៉ុន្តែ

ស្តេចទាំងនោះសឹងជ្រាបថា នៅចំណោមស្តេចទាំងអស់ គ្មានស្តេចណាមួយល្អស្មើព្រះជាទនាលៈទេ ។ ព្រះជាទកិមៈទ្រង់សោមនស្សនឹងព្រះពរជសុណិសាដែរ ។ ព្រះជាទនាលៈទ្រង់មានព្រះបន្ទូលដោយព្រះវាចាស្រទន់ទៅកាន់ព្រះនាងមយន្តីថា "នែព្រះនាងដ៏ប្រសើរ! ចុះបើនៅក្នុងចំណោមអមតកៈបុរស (Immortel) ព្រះនាងរើសយកមតកៈបុរស (mortel) ជាស្វាមីហើយ ខ្ញុំក៏នឹងធ្វើតាមបង្គាប់ព្រះនាងដោយសេចក្តីរីករាយ, នែមយន្តី ក្សត្រីដ៏មានព្រះភក្ត្រញញឹមស្រស់អើយ! ព្រះនាងគង់ព្រះជន្មនៅដរាបណា ខ្ញុំមានចិត្តស្មោះត្រង់តែលើរូបព្រះនាងមួយដរាបនោះ" ។ ព្រះនាងមយន្តីធ្វើគារវកិច្ចចំពោះព្រះអគ្គ ហើយមានព្រះបន្ទូលតបថា: "ខ្ញុំម្ចាស់មានចិត្តស្នេហាព្រះអង្គជាអង្វែងណាស់មកហើយ ត្រូវតែខ្ញុំម្ចាស់គោរពព្រះអង្គវិញទេ ដោយការប្រព្រឹត្តតាមប្រពៃណីជាឯកអគ្គមហេសីចិត្តស្មោះ, ខ្ញុំម្ចាស់ទឹងមានសេចក្តីស្នេហាតែលើព្រះអង្គជានិរន្តរ៍ ហើយខ្ញុំម្ចាស់ទឹងទៅតាមព្រះអង្គជានិច្ច ទោះជាទៅទីកន្លែងណាក៏ដោយ" ។ ក្សត្រទាំងពីរនាំគ្នាបែរព្រះភក្ត្រឆ្ពោះទៅរកព្រះឥន្ទ្រ ព្រះអគ្នី ទឹងអាទិទេពឯទៀត ហើយព្រះនេត្រក្សត្រទាំងពីរអង្គនេះហាក់ដូចជាអង្វរសូមឲ្យអាទិទេពទាំងនេះជួយទ្រទ្រង់ព្រះអង្គ ។ ព្រះឥន្ទ្រក៏មានព្រះបន្ទូលឡើងថា "យើងមិនបោះបង់ឯងរាល់គ្នាទេ! ចូរឯងរក្សាសេចក្តីក្លាហានទឹងសន្តិភាពជានិច្ចចុះ, ចូរព្រះនាងមយន្តី

រក្សានូវសេចក្តីសុភត្រង់នឹងសុទ្ធចិត្ត, សូមក្សត្រទាំងពីរទ្រង់គង់នៅជាសុខក្នុងទីឋានស្មើ ដែលសម្បូរដោយផ្កាយ៉ាងបរិសុទ្ធ" ។ ព្រះអាទិទេពទ្រង់ឲ្យពរស័ក្តិសាធុការស្រេចកាលណា ក៏ហោះឡើងនៅគាន់ស្ថានសួគ៌ទេវលោកវិញតាមលំដាប់ ។ ឯស្តេចទាំងឡាយពោះមិនបានសម្រេចបំណងរបស់ខ្លួនក្តី ក៏ឲ្យពរស័ក្តិសាធុការយ៉ាងវែង ។ ចំពោះព្រះបាទនាលៈនឹងព្រះនាងទមយន្តីដែរ ។ ព្រះបាទកិមៈទ្រង់ចង់ឲ្យរៀបអភិសេកព្រះពជបុត្តី នឹងព្រះបាទនាលៈយ៉ាងឆាប់ មិនបង្អង់ឲ្យយូរការ ។

*
* *

វគ្គទី ១១

ព្រះបាទនាលៈនឹងព្រះនាងទមយន្តី គង់នៅជាសុខសាន្តក្នុងប្រទេសព្រះបាទកិមៈ ។ ទ្រង់មានសេចក្តីស្នេហារកគ្នាមិនចេះអស់មិនចេះហើយ ។

ប៉ុន្តែបន្ទាប់ពីថ្ងៃប្រជុំសន្និបាតមក ឆ្មាំទ្វារម្នាក់បានមកក្រាបបង្គំទូលព្រះបាទកិមៈថា មានបុរសម្នាក់មានមុខមាត់គ្រក់ ដើរបួលមកដល់មាត់ទ្វារព្រះបរមរាជវាំង ។ ឆ្មាំទ្វារថាគេបានឃាត់ហើយសួរថា: "ឯងនៅណាមកណា?" ។ ថាពួកឆ្មាំនាំគ្នាសើចចំអកថា: "ឯងនៅទីសន្និបាតឬ?" ។ ថាវាឆ្លើយថា "ខ្ញុំបាទនៅឯទីសន្និបាត" ។

- ហួសពេលទៅហើយសំឡាញ់! គេលើកលែងច្រើនដុំតាំងតែពីថ្ងៃម្សិលម្ង៉ៃ ម្យ៉ាងទៀតបើទុកជាទោច្រើនក៏គេមិនឲ្យឯងចូលទេ"

- ម្តេចក៏គេមិនឲ្យខ្ញុំចូល បើខ្ញុំជាអាទិទេព? ។

- អ្នកឯងជាអាទិទេពឬ? ។

- ហ្នឹងហើយខ្ញុំជាអាទិទេព, ជាអាទិទេពដែលគេត្រូវតែខ្លាចផង, យើងអាចធ្វើឲ្យកើតសម្បត្តិធនធានឬសេចក្តីលំបាកតោកយាកបានតាមចំនើងចិត្ត ។

- ពួកឆ្មាំទ្វារបានឮដូច្នេះ រឹតតែសើចខ្លាំងឡើងទៀត ហើយនិយាយបញ្ឆោះថា: "នែសំឡាញ់! តើម្សិលមិញអាទិទេពមកចាំងអស់ប៉ុន្តែគាន់អគ្គីណាមួយមានរូបដូចអ្នកឯងទេ" ។

- តើព្រះមហាក្សត្រី រើសយកអាទិទេពណាមួយជាស្វាមី? ព្រះឥន្ទ្រាធិរាជ, ព្រះអគ្នី ឬព្រះវរុណ? ។

- ព្រះនាងរើសយកព្រះចាខនាលៈជាស្វាមី ។

- ព្រះនាងធ្វើបញ្ឆោះឲ្យអាទិទេព, មិនអីទេយើងចេះជាក់ណូតម្ដងដល់ព្រះនាងនឹងព្រះចាខនាលៈ, យើងនឹងសងសឹកជំនួសអាទិទេព ។ បុរសអាក្រក់នោះ ក្រោយពីបានពោលពាក្យបំភ័យដូច្នេះហើយ ក៏ទៅបាត់ទៅ ។

(មានត)

ដំណើរអស្ចារ្យនៃលោកកាស៊ូប៊ីយូយេ

លោកយូកូតូស៊ី រៀបរៀង

លោកប៉ាយ-ប៊ុក ក្រមការ

ប្រែពីភាសាចាវ៉ាមកជាភាសាខ្មែរ

(ត្រួត)

៣— ជំណើរទៅកាន់ឧត្តរមនុស្សធម្មប្រទេស

(Pays de Parade)

លោកកាស៊ូប៊ីយូយេ បានសិក្សាខ្ជាប់ខ្ជួនគោលការណ៍នៃជីវិតនឹងសេចក្តីស្លាប់ក្នុងអមតប្រទេស ហើយនឹងនិដ្ឋាពាផ្សេងៗនៃទុគ្គតភាព នឹងសេដ្ឋភាព នៅសម្បូណ៌ប្រទេស ។ លោកទៅជាមានចិត្តទុបេក្ខាចំពោះសេចក្តីស្លាប់ ហើយការមានទ្រព្យសម្បត្តិ លោកគ្មានបំណងចង់បានអ្វីសោះឡើយ ។ ក្នុងថ្ងៃមួយលោកដើរត្រសាវហោះចេញពីសម្បូណ៌ប្រទេសចម្ងាយប្រហែល ២០ ពាន់យោជន៍ ស្រាប់តែលោកក្រឡេកទៅឃើញទីក្រុងមួយដែលរលោកស្មានថាជាព្រះពាជធានីនៃប្រទេសមួយធំ ។ មានវិថីមួយល្អក្បួលទៅកាន់គេហដ្ឋានមួយ ដែលលោកបានឃើញមនុស្សប្រុសស្រីជាច្រើន មានមុខលាបម្សៅផាត់ពណ៌ សួរលោកថា: "អញ្ជើញមកពីណា" ។ លោកបានឆ្លើយតបទៅវិញថា: "ខ្ញុំមកពីប្រទេសដប៉ុន" ។ អ្នកម្ចាស់ផ្ទះបានឮពាក្យដូច្នោះ ធ្វើឫកក្រអឺត

ក្រទមហើយពោលតបមកវិញថា: "ខ្ញុំបានឃើញប្រទេសតូចៗដូចជាប្រទេសជប៉ុន, ប្រទេសចិនហើយនឹងប្រទេសឥណ្ឌា; តែប្រទេសដែលលោកអញ្ជើញមកដល់នេះគេហៅថា "ទត្តរមន្ទុស្សធម្មប្រទេស" ជាប្រទេសទត្តមក្នុងពិភពលោក, ប្រជាពស្ត្រនៅក្នុងប្រទេសនេះ ជាបុគ្គលប្រកបដោយសុក្រិតភាព ចេះដឹងខាងអក្សរសាស្ត្រហើយនឹងឫកសង្ហា តើអ្នកអាចអញ្ជើញទៅលេងឯគេហដ្ឋានរបស់ខ្ញុំបានឬទេ?" ។

ដល់លោកចូលទៅក្នុងបាហុនស្ថាន លោកបានឃើញភាព្យនិតានផ្សេងៗហើយនឹងគំរូនៃអក្សរស្នាតល្អព្យួរលើជញ្ជាំង, ចំណែកខាងទ្វារគេបានឃើញនូវក្មេងជាតិ មានទ្រង់ទ្រាយល្អសមរម្យ នឹងចង្កៀងគោមធ្វើពីថ្ម ។ ហើយវត្តុតាំងអស់នោះ ធ្វើឲ្យលោកសប្បាយចិត្តពន់ពេក ។ ដល់បន្ទប់ទៀត មានអ្នកស្រីម្ចាស់ផ្ទះ មានអាយុជាង៣សាមសិបឆ្នាំ អញ្ជើញមកដល់ ។ អ្នកស្រីនេះពាក់អាវវែងធ្វើពីសំពត់សូត្រប៉ាក់ដ៏ឆ្មាមាស, ហើយក៏ដើងជាក់រំយោលសំយុងចុះ កំរើកដៃក្រអូបឈ្ងុយឈ្ងប់ហើយញាក់ស្មា, ពោលពាក្យស្រទន់ផ្អែមថា:

"អ្នកជាជនបរទេសដ៏ខ្ពង់! សូមលោកទទួលនូវកិត្តិយសស្ថិតនៅក្នុងគេហដ្ឋានខ្ញុំអស់កាលយូរ, ដើម្បីកុំឲ្យលោកអផ្សុក ខ្ញុំនឹងតាំងខ្លួនខ្ញុំជាអ្នកណែនាំក្នុងពិធីបុណ្យ ទទួលតែថ្លែងនូវបសំសកថា ក្នុងពេលសូត្រតវិនិពន្ធនឹងលេងក្តឹងមហោស្រព, ខ្ញុំបានឮថា នៅប្រទេសនេះ

មានវិញ្ញាជនក្នុងអតីតកាលធ្លាប់ទៅប្រទេសជប៉ុន ហើយខ្ញុំពេញចិត្តដ៏ពន្លឹកចំពោះអក្សរសាស្ត្រ; ខ្ញុំចូលចិត្តខាងតាញនិងានធំប្រលោមលោកទិពន្ធ (Momens)" ។ អ្នកស្រីពោលពាក្យយ៉ាងនេះផង, ក្រឡេកមើលទៅពពកអណ្តែតលើនគាល័យ ហើយឈប់ញញឹមទៅវិញ ។ លោកអ៊ីសូប៊ីយូយយល់ថាស្ត្រីនេះជាស្ត្រីគួរឲ្យគោតខ្លាច ក៏ភ័យតក់ស្លុតពន់ពេក ហើយខ្លួនលោកមិនបានស្ថិតនៅនឹងខ្លួន ដូចជាខាងតាសីមកថ្ងៃរឿងច្បាប់នាយចៅហ្វាយ ។ លោកពោលទៅកាន់អ្នកស្រីថា "អ្នកស្រី! ខ្ញុំបាទជាអ្នកល្ងង់ខ្លៅហើយខ្ញុំគ្មានចំណេះអ្វីជាសុក្រិតទេ ។ ក្នុងពេលនោះ លោកបានឃើញអាវវែងអ្នកស្រីធ្វើពីសូត្រនោះជាសូត្រវចនាដោយក្រូងក្រាយ។

ដល់អ្នកស្រីចេញពីទីនោះ ទៅសម្រាកកំឡាំង លោកបានឃើញស្រីនេះនៅនឹងផ្ទះបាយ (អគ្យាគារ), តែពាក់អាវវែងកញ្ចាស់អង្គុយនៅកៀនជញ្ជាំង បរិភោគនូវដំឡូង ។

ពួកមនុស្សនៅប្រទេសនេះ ពេញចិត្តឲ្យគេបញ្ឆោរ, អួតអាងហួសមាឌ, ហើយពិតមែនតែមើលទង់ទ្រាយក្រៅជាមនុស្សថ្លាដ, តែមិនមានគំនិតយល់ឃើញអ្វីឡើយ ។ ចរិយាសុទ្ធតែមានសភាពបន្ទំ ហើយបើមិនមានការគំរាមអ្នកជាទៃទេ ច្រើនស្ទើតពាក់ខោអាវចាស់រហែក ។ ជួនកាលមានខ្លះមកសួរលោកអ៊ីសូប៊ីយូយ, អ្នកគ្រែហាមរួចពោលថា: "ពីមុនលែមិញ ខ្ញុំបានទៅសន្ទិបាតពួកគាត់, ដល់ខ្ញុំត្រឡប់មកគេហដ្ឋានវិញ

គឺពេលយប់ហ្នឹង ហើយខ្ញុំមានចិត្តសប្បាយពន់ពេកដោយឃើញព្រះច័ន្ទ
ពេញបូណ៌មិត្រចះត្រចង់លើនភាល័យ" ។

មានខ្លះទៀតមកដល់ពោលថា: "ខ្ញុំបានចេញពីយប់មិញហើយ
ខ្ញុំរីករាយសប្បាយចិត្តជាពន្លឹក ដោយបានទស្សនាខ្លួនព្រះចន្ទនឹងបុប្ផាតាំង-
ម្បាយ" ។ ការដែលសន្ធូនានៃមនុស្សក្នុងប្រទេសនេះ សុទ្ធតែប្រកប
ដោយទត្តរិភាព ។

ពេលព្រឹក, មានព្រិលធ្លាក់ពាស ពេញដីគ្រាស់ហើយ អាកាស
ត្រជាក់រងាខ្លាំង ។ លោកប៉ាស្ចឺយូយេ បានឮអ្នកម្ចាស់ផ្ទះគ្នាញែ្ញរអំពី
ពេលអាត្រក់នេះ ហើយព្រួយចិត្តដោយគ្មានស្បៀងអាហារគ្រប់គ្រាន់ទំាង
ក្មេង, ព្រមទាំងប្រាក់សម្រាប់ទៅយកភោគអាវរងាពីអ្នកចង្កាប្រាក់ ។
ពួកនេះញ៉ាំខ្លួនចំប្រប់ ព្រោះខ្លាចត្រែងស្លាប់ដោយរងាឬខ្វះពិតកំយ ប៉ើ
សិនណាជារងានេះ ស្ថិតនៅអស់រយៈពេលបីថ្ងៃតទៅមុខទៀត ។
ពួកទាំងនេះ កំពុងតែគិតព្រួយពីជោគវាសនារបស់ខ្លួន, ស្រាប់តែមាន
អ្នកជិតខាងម្នាក់ហៅទៅមើលព្រិលធ្លាក់, ពិតមែនតែទៅកងហាយតែ
អ្នកទាំងអស់នោះដូចជារូបនិម្មិត តែកងចិត្តខ្លួន ក៏ពេញទៅដោយការ
ឃ្លាងពីពេះមិនអាចនឹងខ្លួលខ្លុំលំបាក ដោយស្ថិតនៅកងគេហដ្ឋាន
ដោយមិនមកជួយលែកន្លះសេចក្តីសប្បាយរបស់មិត្តកងរឿងនេះ ។ ការ
ពោលពាក្យកុហកជាទំនៀមអ្នកទៅប្រទេសនេះឥតមានសេចក្តីខ្មាសអៀន

អ្វីសោះឡើយ ។ អ្នកដែលវង់ទុក្ខលំបាកវង្វេងដោយអាកាសត្រជាក់ញ័រអស់ទាំងអាយវ:សព្វសាង្គកាយ ។ អ្នកម្ចាស់ផ្ទះខំភាកអាវវែងចាស់រត់ទៅខាងទ្វារហើយស្រែកថា: "ល្អហើយអ្នក" ។ ខ្ញុំបានត្រាកពីព្រលឹមដើម្បីនឹងទៅទស្សនានៅព្រឹលដែលធ្លាក់ល្អអស្ចារ្យ ។ ដូចជាអ្នកកវីបិនពោលថា: "រុក្ខជាតិនឹងតិណជាតិសើចញញឹមស្រស់នឹងព្រឹល មុននិទាយ:រដូវ" ឬដូចកវីដប៉ុនពោលថា "ព្រះចន្ទក្តីចាំងចែងឥឡូវនេះនៅលើព្រឹលដែលធ្លាក់ចុះបន្តិចម្តងៗ ស្ងាត់ស្ងៀមដូចសន្ទឹកបុប្ផា" ។ ខ្ញុំខ្លាចក្រែងព្រឹលនោះ ត្រឡប់ទៅជាភ្លៀងវិញ តែខ្ញុំសង្ឃឹមថាទស្សនិយភាពដ៏ល្អជាពន្ធឹកនេះ មុខជានឹងមានមកច្រើនថ្ងៃ ក្នុងកាលជាអនាគត" ។ ពួកទាំងនោះបបូរមាតស្ងាយដោយរដូវរងាចំប្រែប់អស់អង្គ, តែមានចិត្តគិតរក្សាទុកនូវការល្បីល្បាញខាងមនុស្សទៅតាមចរិតសព្វ ។ ខ្លួន ។ ក្នុងពេលនោះទាសីនៃអ្នកជិតខាងមកឲ្យដំណឹងអ្នកម្ចាស់ផ្ទះថា មានជាងមាសអញ្ជើញលោកទៅកាន់ពិធីថ្ងៃឯ អត្តកថ្នាកថា (Cérémonies d'encens) ហើយគេបានផ្ញើនូវគជខ្លាងនឹងផ្តាំមកជូនលោកពិនិត្យ ។

(មានត)

ដំណើរតាមឡស់ក្នុងកន្លោះ

លោក ផេង-ជ្រឿ សាស្ត្រាចារ្យនៅសាលាគរុជ្ជាភ្នំពេញ

ប្រែពីភាសាចាំងមកជាភាសាខ្មែរ

(តមក)

— រស្មីមសួរតបភ្លាមថា: តើព្រោះហេតុអ្វី? ឯងច្រឡាតជាន៏តស្មានថាយើងពាល់គ្នាភ្លើងដូចជាពស់សំឡាប់កង្កែប ដែលដេកនៅកណ្តាលថ្ងៃឬ? ។

— អ៊ីស្មាអ៊ីលញញឹមចំអកឲ្យហើយឆ្លើយថា: មិនមែនដូច្នោះទេសំឡាញ់! ចុះក្រែងឯងឬ ដែលបានន៏យាយអម្បាញ់មិញ តវ៉ាថារឿងអស់នេះកូវង់ហាមផ្តាច់មិនឲ្យនិយាយ? មិនតែប៉ុណ្ណោះ ថែមទាំងមានទោសដល់អ្នកនិយាយន៏ដល់អ្នកស្តាប់ទៀត ។

— រស្មីមដើរសំដៅអ៊ីស្មាអ៊ីល យកដៃទះស្មាដោយសេចក្តីស្និទ្ធស្នាលហើយនិយាយថា: ល្អហើយ! ល្អហើយ! រក្សាការណ៍សម្ងាត់ឯងទុកចុះ ។

— មួយស្របក់ រស្មីមលោដើរថយក្រោយក្រាកៗ ហើយស្រែកសើចចំអកថា: ហា! ហា! ធុំក្លិនទឹកអប់ណាស់! អីនៅអ៊ីបប ឯងរៀនអប់ខ្លួនឲ្យក្រអូបដូចជាស្រីឬ? ។

បើចង់ឲ្យយល់ថាពាក្យទាំងប៉ុន្មាន ដែលរាស្ត្រមេចេតីមនសេចក្តីប្រមាថដល់អ៊ីស្មាអ៊ីល ត្រូវឲ្យដឹងប្រវត្តិជាតិអាក៉ាប់ ទាំងត្រូវស្គាល់ឲ្យច្បាស់ថាក្នុងប្រទេសអាក៉ាប់គេទុកស្រែថាជាកេរគន់ថយដូចម្តេចសិន ។

ដោយមានសេចក្តីគោរពដល់ឪពុកដែលជាមិត្តចិត្តស្មោះត្រង់នឹងឪពុករាស្ត្រ ម្យ៉ាងទៀត ដោយមានការរក្សាទុកវប្បាប់ថាហុណាយ៉ាវត្តើបអ៊ីស្មាអ៊ីលមិនតបតជាសេចក្តីមើលងាយទៅវិញ គ្រាន់តែនិយាយដោយសំដីមធ្យ័តថា:

– នៅប្រទេសអ៊ីរុប ខ្ញុំបានស្គាល់មនុស្សខ្លាំងពូកែជាច្រើនដែលចេះស្ទាត់កន្ទឹងចេះត្រួតសង្កត់លើមហាសាគរបាន ។

ហើយពេលនោះ អ៊ីស្មាអ៊ីល តាំងរៀបរាប់អំពីរបស់ដែលគេបានឃើញ គឺឡានឹងពេងចំក្រសូរដែលក្នុងភក្ត្រនៃគំហ្មរដូចាំងពន្លឺក្រហមច្រាលទៅលើមេឃដ៏វាលាតគួរស្បថស្បែងនៅក្រោមប្រថពី តាមរូងដ៏ងងឹតឈឹងរបស់អ្នកយកឆ្អឹងថ្ម ចំការស្រែរាស៊ីនឹងចំការតំពាំងបាយជូរយ៉ាងធំឆ្ងាយទូលាយ ដែលរដូវចម្រូតមានមនុស្សខ្លាំងៗពាន់ខ្នែវមួយម្នាក់នៅដៃនាំគ្នាច្រូតកាត់គ្រឹកគគ្រែង មិនតែប៉ុណ្ណោះ អ៊ីស្មាអ៊ីលអធិប្បាយអំពីរថក្តឹងដែលទាញទូរច្រើនអនេកបរតាមផ្លូវដែកគួរឲ្យកោតគំនិតប្រាជ្ញានៃជនអ្នកសាង ព្រោះថាបើលោតែស្ពឹណាមួយវិលមិនត្រង់គ្នានឹងអាចឲ្យសេចក្តីស្លាប់ដល់មនុស្សរាប់រយ រាប់ពាន់ជាប្រាកដ ។ គេប្រាប់អំពី

ចិត្តភ្លាហាននៃតៃកុងយន្តហោះ ដែលប្រថុយជីវិតទាំងមុខស្រស់ញញឹម គេថ្វែងអំពីរបស់ដែលបានឃើញក្នុងដំណើរទាំងអស់ តាំងពីវាលស្មៅ ក់លចំការហូតដល់ពេងច័ត្រក្រហមខ្មោលដែលគេចង្អុរដែក ដំដែកប្រែត្រឡប់ហើយបង្កើតបានជានាវយ៉ាងសម្បើមអស្ចារ្យ ដែលជាកិត្តិយសដ៏ឧត្តុង្គឧត្តមរបស់ជាតិ ។

ម្យ៉ាងទៀត ប្រវត្តិប្រទេសមិនទៅកើលគ្នាតែត្រឹមវិជ្ជាហត្ថកម្មដ៏ខ្ពាំងតូចតែប៉ុណ្ណោះទេ អ៊ីស្មាអ៊ីល ពោលបាប់ថែមទៀតអំពីការប្រឹងប្រែងនៃអ្នកប្រាជ្ញទាំងឡាយ ទាំងអ្នកប្រាជ្ញខាងទស្សនវិជ្ជា អំពីកិច្ចការនៃតវិបណ្ឌិត អំពីផលប្រយោជន៍នៃជាងខាងរចនាការ គឺអ្នកទាំងអស់នេះហើយដែលជាកិត្តិយស ដែលជាសេចក្តីរុងរឿងរបស់ប្រទេស ។ រួចអ៊ីស្មាអ៊ីលគ្រាកឡើង និយាយសេចក្តីដោយពាក្យយ៉ាងខ្លី ហើយជាប់ត្រឹមថា៖

- ហ្នឹងហើយរបស់ដែលខ្ញុំបានឃើញ! ខ្ញុំមានសេចក្តីស្តាយណាស់ដោយជនជាតិប្រទេសខ្ញុំគិតតែនាំគ្នាបីតខ្សៀរទើកក្រអូប មិនគិតរំកិលមាតុភូមិទុកជាប្រយោជន៍ទៅអនាគត ។ មនុស្សម្នាក់ៗ តាំងពីក្មេងដល់ចាស់គិតតែប្រមូលស្រីៗ មកធ្វើជាអស់អ្នកអស់នាង ហើយជីវភាពម្នាក់អស់ហើយតែត្រឹមដេកខ្ជិល ពេញចិត្តតែនឹងត្រណាប់ផ្លែឈើតាំងពីព្រលឹមទល់ព្រលប់ ហើយនឹងផឹកទឹកបាន:ត្រជាក់ស្ងឹម ។ អ៊ីស្មាអ៊ីលនិយាយតែប៉ុណ្ណោះហើយក៏ឈប់ស្ងៀម ។

វស្សីមបេនអាប់ជាឡស់បែរមុខទៅរកលោកអៃយ៉ាដ ។

លោកអៃយ៉ាដអត់មិនថា ដក់តែខ្សឹកក្រអូបធ្លើមិនដឹង ក្អែកវលើវ ។ ពិតមែនតែលោកមិនបញ្ចេញអាការឲ្យស្គាល់ តែខាងក្នុងលោកកំណត់ទុកក្នុងដួងចិត្ត ដោយដាប់ស្រែចថាកូនច្បងរបស់លោកបែកគំនិតបន្តិចម្តងៗ រាល់ថ្ងៃ ឃ្លាតពាក់គំនិតរបស់លោកពេលជាគំនិតត្រឹមត្រូវបញ្ជូនបន្តគាត់ទុកជាក្បើតីឥតពាក់ផល់កូន ។

ចំណែកពួកក្មៀវលោកអៃយ៉ាដបែបក្បាក់ខ្លួនត្រឹតរាល់គ្នា ដ្បិតខើបតែម្តងនេះជាដំបូងបំផុតដែលអ៊ីស្មាអ៊ីល លោធ្លាយច្បាប់គំនិតដែលគេយល់ដោយការជាច់ខាត ។

ក្នុងឧកាសនេះ វស្សីមដឹងជាក់ថា ពួកក្មៀវមិនយល់តាមគំនិតអ៊ីស្មាអ៊ីលទាំងអស់ ហើយដោយសេចក្តីប្រកាន់ពួក ខើបនិយាយម្តងទៀតដោយសំដីលាយឡំនឹងសេចក្តីប្រមាថផងត្រមទាំងការចំអកផងថា:

– អ៊ីស្មាអ៊ីល! ឥឡូវអញស្តាប់បានថាឯងមិនបានធ្វើពេលវេលាឲ្យខូចខាតសោះ កង់សម័យដែលឯងបានទៅអាស្រ័យនៅប្រទេសអ៊ីបគឺថាឯងបានជាអ្នកចេះមួយត្រមទាំងចិត្តថ្លើមក៏សប្បុរសផង ។ បើដូច្នេះឯងត្រូវអានក្បាន់ថ្មីរបស់ឯងពីរបីគាថាឲ្យយើងស្តាប់ផងមើល! ។

អ៊ីស្មាអ៊ីលឆ្លើយតបដោយសំដីដ៏ធ្ងន់ថា:

– កុំនិយាយលេង រស្ប៊ីម! មនុស្សក្នុងប្រទេសអ៊ីរុបមានចិត្ត សប្បុរសនឹងប្រតិបដោយច្បាប់ជាជាងជន ដែលជាទីគោរពរបស់យើងទៅ ទៀត ។ នៅប្រទេសអ៊ីរុបមនុស្សទាំងអស់សុទ្ធតែមានសេរីភាព ចំណែក ស័ក្តិយសគេតម្រូវទៅតាមអំពើនឹងមារយាទល្អនៃជនម្នាក់ៗ គឺមិនមែន និយមគោត្រតែកូលនឹងធនធានឡើយ ។ គេមិនមែនចិញ្ចឹមអ្នកក្រខ្សត់ ដើម្បីបន្ទាបបន្ទោកនឹងធ្វើទុក្ខបុកម្នេញដូចជាសត្វបំរើទេ ។ អ្នកមានស័ក្តិ ខ្ពស់មិនត្រូវការតម្រូវចិត្តខ្លួនដោយការណ៍ឋានប់ឋរ៉ូ ដើម្បីសំដែងឲ្យ គេដឹងថាខ្លួនមានអំណាចទេ ចំណែកត្រង់អំពើនឹងចិត្តវិញ គេមិនចង់ ធ្វើអ្នកជិតខាងឲ្យដល់ទុរ្ភិក្សវិនាសឡើយ ។ នៅប្រទេសអ៊ីរុបមនុស្ស ទាំងអស់ទុកគ្នាជាបងប្អូន ហើយពាក្យថាសាមគ្គីធម៌មិនមែនជាសំដីឥត ការណ៍ឡើយ ។ នែរស្ប៊ីម! ចូរឯងដឿអញ មនុស្សក្នុងអ៊ីរុបច្រើន មានសេចក្តីក្លាហានជាងយើង ហើយគេក៏ត្រូវការនឹងក្តើរឈ្មោះដូច យើងដែរ ។

– រស្ប៊ីមស្រែកឡើងតាំងកំហឹងថា: យើ! អីនៅមុខយើង ឯង ហ៊ានសរសើរជនជាតិអ៊ីរុប? ។

– អ៊ីស្មាអ៊ីលគ្រាកឡើងហើយនិយាយថា: ជនជាតិអ៊ីរុបប្រាកដ ជាមានដំឡៃជាងយើង ។

(មានត)

សកម្មភាពនៃក្រុមជំនុំនៀមទម្ងាប់ខ្មែរ

បរិយាយពីវិធានការនៃក្រុមជំនុំ

ក្នុងធម្មាសនទី ២ ឆ្នាំ ១៩៥៣

លោក ចាប - ពិន រៀបរៀង

ខ្ញុំសូមបរិយាយអំពីវិធានការនៃក្រុមជំនុំនៀមទម្ងាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ កំពេញ ចំពោះធម្មាសនទី ២ ឆ្នាំ ១៩៥៣ ប្រកាសនាមសមាជិកឡើយឆ្ងាយ នឹងបេក្ខជន ដែលបានសរសេរឯកសារនៀមទម្ងាប់ខ្មែរ មកឲ្យការ នឹង មកប្រឡង ដូចតទៅនេះ ៖

១.- អំពីលទ្ធផលនៃការប្រឡង

ក្នុងធម្មាសនទី ២ នៃឆ្នាំ ១៩៥៣ ក្រុមជំនុំបានបើកឧកាសប្រឡងប្រជែងនៀមទម្ងាប់ខ្មែរ ២ រឿង គឺរឿងហោរាសាស្ត្រ និងរឿងទឹក ។ ក្រុមជំនុំបានទទួលឯកសារសម្រាប់ប្រឡងនេះ ២០ រឿង អំពីបេក្ខជន ១២ រូប ដែលស្នើសុំប្រឡង, បានជួបជុំពិនិត្យឯកសារទាំងនោះដោយហ្មត់ចត់ យើញបានលទ្ធផលដូចរៀបរាប់ខាងមុខនេះ ៖

ក) រឿងហោរាសាស្ត្របានជាប់ ២ រូប គឺ

- វង្វាន់លេខ ៣ រឿងហោរាសាស្ត្រ ត្រូវបាន ២០០រ,០០ ដល់លោក រ័ត្ន - ផូរ នៅផ្សារស្វាយរៀង ស្រុករំដួល (ស្វាយរៀង);

- រង្វាន់លេខ ៤ រឿងហោកសាស្ត្រ ត្រូវបាន ១០០រ,០០ ដល់លោក ខ្លឹង ភ្នៅ នៅភូមិពោធិ៍បុស (សៀមរាប) ។

១) រឿងទឹក បានជាប់ ៤ រូប គឺ

- រង្វាន់លេខ ២ រឿងទឹក ត្រូវបាន ៣០០រ,០០ ដល់ព្រះមហាឈឹម-ផន និស្សិតឆ្នាំទី ៣ (ខ) នៃសាលាបាលីជាន់ខ្ពស់ ភ្នំពេញ;

- រង្វាន់លេខ ៣ រឿងទឹក ត្រូវបាន ២០០រ,០០ ដល់លោកគ្រូមៀន-សុវណ្ណជោតិ វត្តសំពេង (បាត់ដំបង);

- រង្វាន់លេខ ៤ រឿងទឹក ត្រូវបាន ១០០រ ០០ ដល់លោកចាក់-ខាត់ នៅឃុំពង្រ ស្រុកឆ្លូង (ក្រចេះ);

- រង្វាន់លេខ ៤ រឿងទឹក ត្រូវបាន ១០០រ,០០ ដល់លោកគ្រូសុខ-លាក វត្តខ្សុំ ស្រុកពាមឬ (ព្រៃវែង) ។

២.- អំពីឈ្មោះសមាជិក និងឯកសារ

ឈ្មោះសមាជិកធ្វើយឆ្លង ទទឹងឯកសារដែលក្រុមជំនុំបានទទួលក្នុងខែមាសទី ២ ឆ្នាំ ១៩៥៣ ដូចរៀបរាប់តទៅនេះ គឺ

- លោក ឡឿ-ហ៊ាន់ ឃុំកំកុង ស្រុកបន្ទាយមាស (កំពត) បានឲ្យការ ៧ រឿង គឺរឿងចំណីអាហារ, រឿងប្រវត្តិភូមិខ្មែរ, សារគារខ្មែរ, ប្រវត្តិក្រែង, រឿងឆ្លងទន្លេ, រឿងហោកសាស្ត្រ ទទឹងរឿងទឹក;

- លោក ទេព-វស់ ឃុំលំចង់ ស្រុកសំពេង (តាកែវ) បានឲ្យការ ៣ រឿង គឺរឿងហោកសាស្ត្រ, រឿងទឹក ទទឹងរឿងព្រែង;

- លោក ប៊ុន-ប៉ូរ ប៉ូលិសស្រុកជាំក្សាន្ត (កំពង់ធំ) ចាន់ឲ្យការ ២ រឿង គឺរឿងហោរាសាស្ត្រ និងរឿងទឹក;

- លោក ហោ-ដឹម ឃុំកំពង់ពពិល ស្រុកតាំងគោ (ត្បែវែង), ចាន់ឲ្យការ ២ រឿង គឺរឿងផ្ការយកូនមាន់ និងរឿងទឹក;

- លោក ឌួង-អ៊ូច មេឃុំអង្គាញ់ ស្រុកត្រែកបា្លស (តាកែវ) ចាន់ឲ្យការ ១ រឿង គឺរឿងហោរាសាស្ត្រ;

- លោក កែវ-ហង្ស ចាន់ហ្គាងរ៉ុតែត ឃុំស្វង ស្រុកគ្សួងឃ្មុំ (កំពង់ចាម) ចាន់ឲ្យការ ២ រឿង គឺរឿងហោរាសាស្ត្រ និងរឿងទឹក;

- លោក ជូរ-អ៊ុក ឫទ្ធិតុងសាលាខេត្ត (តាកែវ) ចាន់ឲ្យការ ២ រឿង គឺរឿងហោរាសាស្ត្រ និងរឿងទឹក;

- លោក គង់-ចន្ធនៈ ឃុំត្រែវៀន ស្រុកត្រែឈរ (កំពង់ចាម) ចាន់ឲ្យការ ៤ រឿង គឺរឿងហោរាសាស្ត្រ, រឿងទឹក, រឿងភ្ជាប់ពាក្យស៊ីស្ងោនិងរឿងត្រែង ។

* *

នៅប្រទេសកម្ពុជាយើង ណ្តាជនដែលចេះចាំទំនៀមទម្លាប់ខ្មែរមានច្រើនជាអនេក មិនមែនតិចទេ, ប៉ុន្តែដែលនឹងសរសេរតែងឯកសាររឿងទំនៀមទម្លាប់ខ្មែរផ្សេងៗ ឲ្យការមកគ្រប់ដំនុំទំនៀមទម្លាប់ខ្មែរចាន់នោះ លុះតែចេះចាំទំនៀមទម្លាប់ផ្សេងៗ ផង, យល់ច្បាស់ថា ឯកសារ

ទំនៀមទម្លាប់ខ្មែរជាគោលចារិកដ៏សំខាន់សម្រាប់ប្រទេសជាតិផង, ចង់ឲ្យអារ្យធម៌ខ្មែរបិតថេរគង់វង្សទៅកន្លងអនាគតផង ទើបអាចកាត់សេចក្តីរលៃឆ្ងៃតនុកាសសរសេរតែងឯកសារផ្សេងៗ នោះៗ មកឲ្យការដល់ក្រុមជំនុំទំនៀមទម្លាប់បាន, បើមិនយកចិត្តទុកជាក់មិនអាចធ្វើបានទេ; ព្រោះហេតុនេះបានជា ក្រុមជំនុំទំនៀមទម្លាប់ខ្មែរដែលបានទទួលឯកសារឿងទំនៀមផ្សេងៗ អំពីអស់លោកជាសមាជិកធ្វើយឆ្ងល់ ឧទ្ទិសជាបេក្ខជនដែលបានយកចិត្តទុកជាក់សរសេរតែងឲ្យការមក ឧទ្ទិសមកប្រឡងនោះហើយមានអំណរក្រៃពេក, សូមប្រកាសសេចក្តីសរសើរជាទឡ្ហីករ ដ៏ស្មគ្រីស្មោះចំពោះអស់លោកទាំងនោះ ដែលបានឆ្ងៃតនុកាសសរសេរតែងឯកសារទំនៀមទម្លាប់មានប្រការផ្សេងៗ មកឲ្យការដល់ក្រុមជំនុំឧទ្ទិសមកប្រឡងចំពោះធម្មាសនៈ ២ ឆ្នាំ ១ ៩ ៥ ៣ ដូចរាយនាម ឧទ្ទិសតាមលើនេះ។

សូមអស់លោកសមាជិកធ្វើយឆ្ងល់ ឧទ្ទិសបេក្ខជនទាំងឡាយ ដែលជ្ឈាប់ឲ្យការមកឬជ្ឈាប់ប្រឡងក៏ដោយក្តី អស់លោកវិញ្ញូជនរួមជាតិទាំងឡាយដែលមិនទាន់ជ្ឈាប់ក្តី ចំឆ្ងៃតសរសេរតែងឯកសារផ្សេងៗ ដែលទាក់ទងដោយទំនៀមទម្លាប់ខ្មែរ ជាការជួយឧបត្ថម្ភកិច្ចការរបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរឲ្យចម្រើនជាកិយ្យាកាព ដើម្បីឲ្យអារ្យធម៌ខ្មែរគង់នៅជាមត៌ករបស់ជាតិតទៅ។

ក្រុមជំនុំសូមទទួលអំណរគុណយ៉ាងខ្លាំងទុកជាមុន។

សមណាស័ក្តិនៃព្រះសង្ឃ ១៣ រូប

ពុទ្ធសាសនបណ្ឌិត្យ

តាមបញ្ញត្តិកង្ត ព្រះរាជក្រមលេខ ១២ ន ស. ចុះថ្ងៃទី ៩ កុម្ភៈ ១៩៤៣ ដោយសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយថ្វាយព្រះពរសូម, ដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ កំបានយល់ព្រមផង ហើយបានក្រាបបង្គំទូលថ្វាយ, ព្រះករុណាជាម្ចាស់ជីវិតលើតួន ព្រះបិយមហាក្សត្រិយ៍ ជាអគ្គពុទ្ធសាសនូបត្ថម្ភក: ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានតាំងព្រះថេរៈ ចាំងឡាយ ១៣ អង្គ ឲ្យឡើងសមណៈស័ក្តិទីព្រះរាជគណៈ តាមលំដាប់ថ្នាក់ ឯក - ទោ - ត្រី - ចត្វា ដោយព្រះរាជក្រឹត្យលេខ ៥ ប.រ. ចុះថ្ងៃទី ២១ មករា ១៩៥៤ ដូចមានរាយនាមនឹងសមណស័ក្តិតទៅនេះ គឺ:

១ - ព្រះមុនីកោសល អ៊ឹ រ៉ី - ខ្លឹត មេគណខែត្តបាត់ដំបង រាជគណៈថ្នាក់ទោ ឡើងជា ព្រះវនរ័ត ថ្នាក់ឯក ជាដំនួសព្រះវនរ័ត ពេជ - មឿង វត្តខ្ណាលោម ដែលទទួលអនិច្ចធម្ម ។

២ - ព្រះពុទ្ធវង្ស សោម - ឈុង មេគណខែត្តកណ្តាល រាជគណៈថ្នាក់ត្រី ឡើងជា ព្រះមុនីកោសល ថ្នាក់ទោ ។

៣ - ព្រះញាណវង្ស ពៅ - ផេត្រ វត្តខ្ណាលោម រាជគណៈថ្នាក់ត្រី ឡើងជា ព្រះមហាវិមលធម្ម ថ្នាក់ទោ (ដែលនៅទំនេរតាំង

ពីព្រះមហាវិមលធម្ម ហួត-តាត ឡើងជាព្រះពោធិវង្ស ពាជាគណៈថ្នាក់ឯក) ។

៨- ព្រះឧបាលិវង្ស ម៉ឺង-សៃស ពាជាគណៈថ្នាក់ត្រី ចៅអធិការវត្តមហាមន្ទីក្រែងក្នុងភ្នំពេញ ឡើងជា ព្រះយោសធម្ម ថ្នាក់ទោ ជាជំនួសព្រះយោសធម្ម ហ៊ីន-មៃ វត្តឧណ្ណាលោមដែលទទួលអនិច្ចធម្ម ។

៩- ព្រះវិកន្ធញ្ញាណ ក្បៅ-ស៊ុំម វត្តលង្កា ពាជាគណៈថ្នាក់ចត្វា ឡើងជា ព្រះពុទ្ធវង្ស ថ្នាក់ត្រី ។

១០- ព្រះសមាធិធម្ម អ៊ូ-ស្សរ វត្តសាកវ័ន ពាជាគណៈថ្នាក់ចត្វា ឡើងជា ព្រះញាណវង្ស ថ្នាក់ត្រី ។

១១- ព្រះទេពសត្ថា ស្សរ-ប៉ាយ វត្តឧណ្ណាលោម ពាជាគណៈថ្នាក់ចត្វា ឡើងជា ព្រះឧបាលិវង្ស ថ្នាក់ត្រី ។

១២- ព្រះគ្រូញាណគេសរ ស្វាយ-អ៊ឹម ទីឋានានុក្រម ចៅអធិការវត្តសំពៅមាស ឡើងជា ព្រះសមាធិធម្ម ពាជាគណៈថ្នាក់ចត្វា ។

១៣- ព្រះគ្រូបញ្ញាវិទូ ផ្ទៀង-ប៊ាង ទីឋានាក្រម ចៅអធិការវត្តកែវព្រះភ្លើង ក្រែងក្នុងភ្នំពេញឡើងជា ព្រះវិកន្ធញ្ញាណ ពាជាគណៈថ្នាក់ចត្វា ។

១៤- ព្រះគ្រូសិរីសោភ័ណ កឹម-ភ្ជូរ ទីឋានានុក្រម វត្តឧណ្ណាលោម ឡើងជា ព្រះទេពសត្ថា ពាជាគណៈថ្នាក់ចត្វា ។

១១- ព្រះគ្រូសាសនមុនី អ៊ង-ឡាប ទីហានានុក្រម ចៅអធិការវត្តកោះ ឡើងជា ព្រះសិរិសង្ឃាមរុនី រាជាគណៈ ថ្នាក់ចត្វា ជាជំនួសព្រះសង្ឃាមមុនី ជុប-រស់ ដែលទទួលអនិច្ចធម្ម ។

១២- ព្រះគ្រូវិសុទ្ធិមុនី ប្រ៊ាជ-ប៉ុល ទីហានានុក្រម វត្តទុណ្ណាលោម ឡើងជា ព្រះទេពមុនី រាជាគណៈថ្នាក់ចត្វា ជាជំនួសព្រះទេពមុនី យូរ-ប៉ុណ្ណ វត្តទុណ្ណាលោម ដែលទទួលអនិច្ចធម្ម ។

១៣- ព្រះធម្មានុសិទ្ធិសាទរ ញ៉ឹក-ជា ទីហានានុក្រម ចៅអធិការវត្តសោមនស្ស ខែត្តបាត់ដំបង ឡើងជា ព្រះញាណសំវរ រាជាគណៈ ថ្នាក់ចត្វា ជាជំនួសព្រះញាណសំវរ ខុម-ឯក អនុគណស្រុកបាត់ដំបង ដែលទទួលអនិច្ចធម្ម ហើយបានឡើងជាអនុគណ ស្រុកបាត់ដំបងតាមដំណែលមុន ។

យើងសូមប្រគេនសាធុការពរចំពោះព្រះថេរ គាំង ១៣ អង្គ ដែលទើបបានឡើងសមណសក្តិថ្មី ។ នេះ សូមបានប្រកបដោយពរគឺ អាយុ: វណ្ណ: សុខ: ពល: ឥន្ទ្រិយកាពក្នុងព្រះពុទ្ធសាសនាតរៀងទៅ ។

ពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញសុទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៦ ខែឧសភា លេខ ៥

ព.ស. ២៤៩៧ – គ.ស. ១៩៥៤



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— វិភាទូបសមកថា	ព្រះភិក្ខុ ហេន- ធឿង	៣២៣
— បញ្ញាសជាតក ភាគទី ២ (តមក)	បណ្ឌិតមហា ឈឹម - ស៊ុម	៣៣៣
ផ្នែកអក្សរសាស្ត្រ		
— ព្រឿងសៅរ៍សោយ	ព្រះមហាឧត្តមវិជ្ជា ប៊ឹង - ប៊ម ...	៣៥១
— ព្រឿងសាមកុក (តមក)	ឧកញ៉ា ន្ហូ- កន	៣៥៨
— ទាល:និងទមយន្តី (តមក)	អ្នកស្រី ស្រ៊ុន - សារីយ៉ាន់	៣៦៣
— ដំណើរអស្ចារ្យនៃលោកភ៌ាសូបឺយ្យូយេ (តមក)	លោក រ៉ាយ -ប៊ុក	៣៧០
— ដំណឹងតាមខ្សល់ក្នុងកន្ទារៈ (តមក)	លោក-ផេង - ជ្រឿរ	៣៧៩
— កាសន្ធនាពីសិល្បៈខ្មែរលើកទី ១—២ ...	លោក ជាម - ពិន	៣៨៧
កំណាត់នឹងប្រវត្តិការណ៍		
— ការប្រឡងបេក្ខបញ្ជិត ដែនកូសាំងស៊ីន	ព្រះញាណកោសល ញាណ-ឈឿន	៣៩៨

មួយឆ្នាំមាន ៤២ សៀវភៅ — ដំឡៃដាវ ២០០រ.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

		Page
— Vivadopasamakatha	*Brah Bhikkhu HEN-THOEUNG.*	323
— Pannasajataka -vol-II (suite) .	*M. CHHIM-SOUM*	333

PARTIE LITTERAIRE:

— Le « SAU-SOY » ou l'influence saturnienne	*Brah Maha PEUNG-PAM* . . .	351
— Histoire de Samkok (suite) . .	*Oknha NOU-KAN*	358
— Nala et Damayanti (suite) . .	*Mme SRIN-SARIS-YANN* . . .	363
— Le voyage extraordinaire de VASIOBIOYÉ (suite)	*M. RAY-BUC*	370
— Le souffle du désert (suite) .	*M. PHENG-CHRIV*	379
— Sur les Beaux-Arts khmèrs . .	*M. CHAP-PIN*	387

NOTES ET CHRONIQUES:

— Examan des éléves religieux en Cochinchine	*Vén. NHEAN-CHHOEUN* . . .	398

Prix d'abonnement annuel (comprenant 12 numéro) 200$

វិភង្គបសមកថា

ព្រះភិក្ខុ ហេង-ធឿង វត្តមហាមន្ត្រី

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះកតវន្តមុនី អរហំសម្មាសម្ពុទ្ធព្រះអង្គ នោះ (ព្រមទាំងព្រះធម៌ទាំងព្រះអរិយសង្ឃ) ។

ក្នុងទុកាសនេះ អាត្មាភាពសូមសំដែងអំពី "វិភង្គបសមកថា" ពណ៌នាអំពីដំណើរនៃការរៀបរៀងវិភង្គ នឹងធម្មជាបដិបទានៃការកំចាត់បង់នូវសេចក្តីឈ្លោះវិភង្គនោះ ដើម្បីជាគោលបដិបត្តិហាត់ពត់កាយ-វាចា-ចិត្តរបស់សាធុជនពុទ្ធបរិស័ទទាំងឡាយ អ្នកត្រូវការនឹងចេញចាកទុក្ខ ហើយនឹងដើរទៅកាន់ផ្លូវនៃវឌ្ឍនធម៌នឹងសន្តិវរសុខ ដូចព្រះពុទ្ធភាសិតដែលមានក្នុងបទគាថាយ៉ាងនេះថា:

សកញ្ហិ ធម្មំ បរិបុណ្ណមាហុ
អញ្ញស្ស ធម្មំ បន ហីនមាហុ
ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ
សកំ សកំ សម្មតិមាហុ សច្ចន្តិ

ថ្លែងថា "សមណព្រាហ្មណ៍ពួកខ្លះ ពោលសរសើរធម៌របស់ខ្លួនថា ពេញបរិបូណ៌ ពោលបង្អាប់ធម៌របស់ជនដទៃថាខ្វះថោក, ពោលសន្ទិដ្ឋិរបស់ខ្លួន ។ ថាជាគុណជាតិពិតត្រូវ, សមណព្រាហ្មណ៍ពួកនោះ រមែងឈ្លោះប្រកែកគ្នាដោយហេតុយ៉ាងនេះឯង" ។

អធិប្បាយថា ប្រជុំជនដែលរួមគ្នានៅក្នុងផ្ទៃលោកនេះ ពោះគ្រហស្ថ ក្តី បព្វជិតក្តី ទើនៅជាសុខព្រមព្រៀងគ្នាបាន មិនខាស់ឆេងឈ្លោះ វិវាទ ប្រកាសាមគ្គីគ្នា ក៏ដោយសារមានគុណធម៌អាស្រ័យប្រចាំនៅជាប់ក្នុងសន្តាន គឺអ្នកធំតាំងនៅក្នុងសេចក្តីអាណិតមេត្តាគ្រាប្រណីឧបអាសោយរីករាយក្នុងចំណែកដែលអ្នកគួរឲ្យលួចបាន មិនសំដែងអាការខ្ពស់ទាបមិនលំអៀង ព្រោះឆន្ទាគតិជាដើម, ដល់គ្រាដែលអ្នកគួរធ្វើខុស ក៏ពិចារណារកទោសហើយផ្តន្ទាអប់រំឲ្យរឹងប៉ឹងនឹករកសេចក្តីខុស, ដល់គ្រាអ្នកគួរធ្វើត្រូវក៏បណ្តុះសេចក្តីទុកចិត្តលួមឲ្យកើតឆន្ទៈ តែកុំឲ្យមានអតិមានៈក្នុងករណីនោះ ។ ចំណែកអ្នកគួរត្រូវតាំងនៅក្នុងដេរជ្ឈាបថាយនធម៌ បដិបត្តិកោតក្រែង ខ្មាសលំទោនចំពោះលោកអ្នកធំ ជាប្រមុខរបស់ត្រកូល ប្រមុខរបស់គណៈ, ប្រមុខរបស់ប្រជាកសិ្ត - ប្រទេសជាតិ ដោយជឿស្តាប់ពាក្យតុវត ជាស់តឿនក្រែនរំលឹកក្នុងវិធីបដិបត្តិល្អ មិនលើកខ្លួនវាយឫកស្មើនឹងលោក មិនរើគ្នីគ្នង់ចេះតាស់ បង្កិបង្កើតអធិករណ៍ផ្សេង ។ បដិបត្តិអនុវត្តតាមចំណែកនៃករណីយកិច្ចដែលមិនមានទោស ព្យាយាមធ្វើខ្លួនឲ្យជាមនុស្សគួរគេអាណិត ជាមនុស្សចេះធ្វើខ្លួន

ឲ្យគេស្រឡាញ់ ។ បើមនុស្សដែលនៅរួមពួក - គណៈ បែរត្រឡប់ជា
មានចិត្តយល់ឃ្លាតគ្នាទាស់លើសបែបណា គឺអ្នកធំមិនមានការទុកចិត្តក្នុ
ក្រមអ្នកតូច ។ ក៏មិនគោរពដឿស្តាប់អ្នកធំ, កាលថើយ៉ាងនេះ គណៈ
ក្រមសង្ឃនោះ ។ ក៏នឹងនៅកាន់ហាយនធម្ម សេចក្តីសាបសូន្យយ៉ាង
ធាប់ ព្រោះមានការយល់ឃ្លាតគ្នាក្នុងករណីសព្វយ៉ាង ដោយអំណាច
ការបែកាន់ខ្លួនថាមានជាតិ ត្រកូល យសសក្តិ បរិវារ ភោគសម្បត្តិ
សិល្បវិជ្ជា ខ្ពង់ខ្ពស់ជាងគ្នា ត្រមតាំងការគិត ការយល់ឃើញក៏មិនមួល
មិត្តរៀបរយជាមួយគ្នា, ហេតុប៉ុណ្ណេះជាដើម ជាគោលជាទីតាំងនៃ
សេចក្តីឈ្លោះវាក់ទាស់ទែង ជាផម្ងោះឲ្យមានការបែកសាមគ្គីធម៌ ហូរ
ចូលមកជាលំដាប់ សមដូចព្រះពុទ្ធភាសិតដែលលើកមកទុកជានិក្ខេបបទក្នុង
ខាងដើមថា: "សកញ្ចិ ធម្មំ បរិបុណ្ណមាហុ សមណៈព្រាហ្មណ៍
ពួកខ្លះពោលសរសើរគុណធម៌របស់ខ្លួនថាជាគុណជាតបរិបូណ៌" ។ ពាក្យ
ថា "សមណៈព្រាហ្មណ៍" នោះ ត្រង់សមណៈ មតិផ្លូវព្រះពុទ្ធសាសនា
ពោលសំដៅ លោកអ្នកសង្កប់រម្ងាប់កាយ - វាចា - ចិត្ត ចាកអកុសលធម៌
ដោយប្រពឹត្តតាមធម៌វិន័យចរិយាបដិបត្តិចាត់ទុកជាពុទ្ធប្បញ្ញត្តិ ពុទ្ធ-
នុញ្ញាតដែលជាច្បាប់ប៉ែកខាងផ្លូវព្រះពុទ្ធសាសនា ឈ្មោះថា សមណៈ ។
ត្រង់ "ព្រាហ្មណ៍" នោះកាលបើពោលដោយបរិយាយ បានដល់បុគ្គល
មួយពួក ដែលមានបដិបត្តិមានការចេះដឹង ការយល់ ឧត្តការសិក្សាសិល្ប
វិជ្ជាខំនាស់គ្នាឧត្តឆ្លៀវព្រះពុទ្ធសាសនា ដោយការពាក់អាន ឬជាព្រះឥសូរ

ជាដើម, សេចក្តីបដិបត្តិរបស់គេដែលប្រតិត្តទៅដើម្បីអង្វរព្រះឥសូរ ដោយការយល់ឃើញថាសុខសម្បត្តិ - សុវត្ថិភាព ដែលមនុស្សត្រូវបានត្រូវសោយ សុទ្ធតែព្រះឥសូរលោកឲ្យកើតឲ្យមានទាំងអស់, តាលបើពួកព្រាហ្មណ៍មានការយល់ថា ព្រះឥសូរជាម្ចាស់ប្រោសប្រាណប្រគល់សុខ-សម្បត្តិដល់ខ្លួន ដោយយញ្ញវិធីបែបណា ពួកគេក៏រៀបចំយញ្ញវិធីបែបនោះ, ការធ្វើវិធីវត្តប៉ុណ្ណោះ ក៏សុទ្ធតែប្រាថ្នាយកសេចក្តីសុខ - ចំរើន ទាំងអស់ ។ មួយទៀត, តាមន័យខ្លះ លោកកំណត់យកបុគ្គលមានប្រភេទតែមួយបែប គឺសំដៅយកអ្នកប្រតិត្តបរិយាវត្តតែមួយដូចគ្នា ជាអ្នកមានវត្តប្បដិបត្តិ ប្រតិត្តទៅដើម្បីសេចក្តីស្ងប់ស្ងាត់ មិនបៀតបៀនសត្វឲ្យបានទទួលសេចក្តីក្តៅក្រហាយ ហៅថា សមណព្រាហ្មណ៍ទាំងអស់ ។ ឯសមណព្រាហ្មណ៍ពួកនេះ ប្រសិនបើមានការសិក្សាសិល្បវិជ្ជា, អក្សរសាស្ត្រ, សាសនសាស្ត្រ, បវត្តិសាស្ត្រ, តក្កសាស្ត្រ, ធម្មសាស្ត្រ ជាមួយគ្នា តែមានការយល់ឃើញឃ្លាងអំពីគ្នា គង់ក្លាយទៅជាស្រមោលជាប់តាមខ្លួន, បើប្រតិត្តទៅដោយសេចក្តីក្លាហាន មិនមានបញ្ហាជាគ្រឿងលុបលាងចោលទេ មុខជានឹងបណ្តាលឲ្យមានបែកសាមគ្គីធម៌តែមានដល់គ្រួសារ ពួក គណៈបាន តាលបើយ៉ាងនេះ អនត្ថកម្ម (អំពើមិនចំរើន) អាចលូតលាស់ឡើងយ៉ាងធំ ។

តាមគតិលោក ដូចគ្នាគ្រួសារ។ បើតែវិវាទាស់ខែងគ្នាដោយការយល់ឃើញខុសគ្នា ប្រកាន់ថា ខ្លួនមានអំណាចច្រើនជាង មានសេចក្តី

ចេះដឹង អត់អាច ក្លាហានជាង ស្វាមីប្រកាន់ថា ល្អជាងកំយ៉ោ។ មិន
ត្រមទទួលគោរពដល់ស្វាមី ដោយការប្រកាន់ថា ខ្លួនមានត្រកូលខ្ពស់
ជាង, មានកោតសម្ផ័ទ្រេចជាង មានគុណសម្បត្តិសមត្ថភាពពូកែជាង,
ស្វាមីយ៉ាងនេះ កំយាយ៉ាងនោះ សេចក្តីសុខសូម្បីត្រឹមតែថ្ងៃមួយក៏ពិបាក
ទីងមាន មានតែការប្រដាំងប្រជែងគ្នាជាប់ជានិច្ច ទីបំផុតខាល់តែបែក
ចាកភាពជាស្វាមី-កំយោវៅក៏មាន ព្រោះតែមានទិដ្ឋិមានៈប្រកាន់ខុសគ្នា
មិនមានត្រាប្រណីអត់អោនវាគ្នា, នេះជាផ្លូវវិនាសចំពោះគ្រួសារដែលជា
ចំណែកយ៉ាងតូចតាច ។ បើសំដៅយកប្រជុំជនដែលជាចំណែកធំ ចាន
ដល់ប្រទេសជាតិ ហាយនភមិក៏ងឹតតែលូតលាស់ឡើងដោយចំណែក
យ៉ាងធំ ។ បុគ្គលមានមានៈប្រកាន់ខ្លួន សូម្បីតែញាតិរបស់ខ្លួនក៏គង់
ប្រមាថមើលងាយដែរ បុគ្គលបែបនេះឈ្មោះថាជុតបំផ្លាញកម្ចាំងរបស់
ជាតិត្រកូលទីងខ្លួនឯង បើកចន្លោះឲ្យសេចក្តីវិនាសហូរចូលបាន, សម
ដោយពុទ្ធភាសិតដែលមានក្នុងបាកវាសូត្រថា:

ជាតិត្តន្ធោ ធនត្តន្ធោ គោតត្តន្ធោ ប យោ នរោ
សញ្ញាតិមតិមញ្ញតិ តំ បរាភវតោ មុខំ

ប្រែថា «នរជនដែលទីងរូសព្រោះជាតិ, ទីងរូសព្រោះទ្រព្យ,
ទីងរូសព្រោះគោត្រ តែងមើលងាយញាតិរបស់ខ្លួន, នេះជាច្រកាន
នៃសេចក្តីវិនាស» ។

តាមគតិធម៌ សមណព្រាហ្មណ៍ដែលមានការរស់នៅជាប់ដោយជនដទៃ ចេញចាកគេហដ្ឋាន ប្រព្រឹត្តអនាគារិនិយ្យ នឹងជាទីគោរពកាន់ដុះថ្លារបស់ប្រជាជន ព្រោះមានសំវរៈក្នុងធម៌បរិបូណ៌ត្រឹមត្រូវ មានបដិបទាដើរទៅរកសន្តិសុខ មិនបានចំណាយសាមគ្គីធម៌របស់ពួកគណៈ សមាទានមាំក្នុងសីលាចារវត្ត ជាបដិបទារបស់សមណៈដែលរួមបញ្ចូលក្នុងគុណសម្បត្តិ ២ ប្រការគឺ: ទិដ្ឋិសាមញ្ញតា ភាពជាអ្នកស្មើគ្នាដោយការយល់ឃើញ ១ សីលសាមញ្ញតា ភាពជាអ្នកស្មើគ្នាដោយសីល ១ ។ គុណសម្បត្តិ ២ ប្រការនេះជាហេតុចងផ្សារភ្ជាប់នឹងសេចក្តីសុខស្ងាលមិត្តមូល ក្រែកភ្ជាប់នឹងអធ្យាស្រ័យរបស់ពួកគណៈខុកបាន មិនបានឈ្លោះវិវាទ ។ រីឯសេចក្តីឈ្លោះវិវាទគ្នា សូម្បីត្រឹមតែបន្តិចបន្តួច ក៏រមែងមិនជាទីសរសើរនៃវិសេសជនចាំឡាយមានព្រះពុទ្ធជាដើមឡើយ តួយ៉ាង ដូចភិក្ខុអកនៅក្នុងក្រុងកោសម្ពីជំនាន់ពុទ្ធកាលព្រះវិនយធរឆ្លៀសនឹងព្រះធម្មកថិក ដោយហេតុត្រឹមតែសល់ទឹកដុះអាចមន៍ខុកក្នុងវច្ចកុដិ ហើយតិះដៀលថា ខុកណាជាត្រូវអាបត្តិហើយនៅតែមិនស្គាល់អាបត្តិ ហើយបានជ្រាប់សេចក្តីផ្ទេសប្រហែសរបស់ធម្មកថិក ដល់ពួកនិស្សិតរបស់ខ្លួន ។ ចំណែកខាងពួកនិស្សិតរបស់ព្រះធម្មកថិកដ៏ចាស់រឿងនោះ ក៏តូចចិត្ត, ភិក្ខុទាំងពីរប្រភេទតែមានសិស្សគណច្រើន ទើបសំដែងសេចក្តីតូចចិត្តដល់គ្នានឹងគ្នា សេចក្តីឈ្លោះវិវាទនោះ

បានរៀបរាល់ផ្តុះចេញទៅដល់ពួកទាយក ទាយិកា ទេវតា-មារ-ព្រហ្ម បែកគ្នាទៅជាពីរចំណែក សូម្បីសម្តេចព្រះទេវ៧លញាណក៏ទ្រង់រំលាងព្រះទ័យ ទើបស្តេចចេញទៅព្រៃកុតវ័ន ដើម្បីស្វែងរកសន្តិវរសុខ, រឿងនេះល្មមជាផ្លូវសន្និដ្ឋានថា អ្នកមានមាន:ទិដ្ឋិប្រកាន់ខ្លួនថា មានការចេះដឹងអង់អាចប្រសើរជាងបុគ្គលដទៃ ទាល់តែហួសប្រមាណ រមែងកសេចក្តីក្តៅក្រហាយឲ្យចំរើនឡើងដល់ពួកគណ: ដោយប្រការយ៉ាងនេះ, ព្រោះហេតុនោះ សម្តេចព្រះមហាមុនីទ្រង់ប្រកាសសន្តិវរបទអមតធម៌ ទើបបានត្រាស់ប្រដៅពួកពុទ្ធបរិស័ទ ពាំងគ្រហស្ថពាំងបព្វជិតឲ្យមានការគិតឃើញត្រូវគ្នា ដោយគន្ថធម៌ជាគោលនៃការបដិបត្តិ ដើម្បីកំចាត់មាន:ទិដ្ឋិចាកសន្តាន ព្រោះថាសេចក្តីស្ងប់នេះ ចាត់ទុកជាគុណសម្បត្តិដ៏សំខាន់ក្នុងតតិលោកតតិធម៌ អាចឡើងទៅកាន់កាពនៃវិឝ្ឍនធម៌បាន ។

សេចក្តីស្ងប់នឹងកើតមានដល់ពួក-គណ: ក៏ត្រូវអាស្រ័យបុគ្គលមានការហាត់ពត់កាយ-វាចា-ចិត្តក្នុងទីគុណ មិនជាមនុស្សធ្វេធាវធាប់ក្រោធឆាប់មិនញាប់ញ័រចំពោះកិរិយាក្តាយ ទុកជាក់ខ្លួនជាកណ្តាលឲ្យសមដល់ឋាន: មានសតិមិនលើកដំកើងខ្លួន មិនប្រកាន់វត្ថុណាមួយក្នុងលោកនេះថាជារបស់ខ្លួន បើទុកជាត្រូវគេប្រទូសចាកវត្ថុនោះ ក៏មិនសូវមានសេចក្តីសោកស្តាយប៉ុន្មាន ព្រោះសព្វសង្ខារតែងតែសូន្យទៅ

ទឹងមិនធ្លាក់ទៅក្នុងអតត្តមិតាំងឡាយ ដូច្នេះ ទើបតាំងនៅក្នុងសន្តិភាព មិនវិវាទាស់ខែងគ្នាបាន ព្រោះមានបដិបទាដើរទៅតាន់ធម្មប្បដិបត្តិ ។

ចំណែកខាងបុគ្គលអ្នកធ្លាក់ចុះទៅក្នុងអំណាចទិដ្ឋិមានៈ កាលបើមានវិជ្ជាការចេះដឹង ក៏ច្រែនតែមានសេចក្តីយល់ឃើញថា ខ្លួនមានគុណសម្បត្តិ សមត្ថភាពជាងបុគ្គលដទៃ លើកដំកើងតែខ្លួនឯងមើលងាយគេ, បុគ្គលបែបនេះឈ្មោះថាផ្សាំបណ្តុះពូជនៃការមិនគាប់ចិត្តបុគ្គលឯទៀត, បើទុកជាដំណើរខុស ដែលជនដទៃស្តីប្រដៅស្រាវជ្រាវកែការត្រូវ, ក៏គង់តែប្រឆងជជែកតស៊ូយកជ័យជំនះទឹងការពារខ្លួន; ព្រោះហេតុនោះ ការឃើញខុសជាហេតុឲ្យជជែកតវ៉ាគ្នា ទើបចាត់ជាមូលហេតុនៃវិវាទ ។ មួយវិញទៀត បុគ្គលអ្នកឃើញវិបរិតមានចិត្តប្រកួតប្រកាន់ដោយមានៈ វមែងសំគាល់វត្តុមិនមែនជាសារៈថាមានសារៈ សូម្បីវត្តុតែមតែកើតឡើងដោយសន្ទុះ ក៏គង់ថាវត្តុពិតប្រាកដទៀងទាត់ តាំងច្រែនសំដែងលទ្ធិនោះ ឲ្យបុគ្គលដទៃដឹស្តាប់បដិបត្តិតាមដូចប្រដៅថាលោកនេះ ជារបស់ទៀងជាដើម ដោយប្រាសចាកហេតុផលជាគ្រឿងអាង ព្រោះតាមការដែលពិត ពាក្យថាលោក ។ នេះ ដោយសន្ទុះកំណត់យកបញ្ចក្ខន្ធ ដែលធ្លាក់ចុះលុះក្នុងអំណាចជរា - ព្យាធិ - មរណៈ មានការកើតជាដើមចម មានការផ្លាស់ប្តូរប្រែប្រួលទៅជាកណ្តាល មានការបែកធ្លាយប្រែធាតុទៅជាទីបំផុត, ដែលលោកហៅថាសត្វឬបុគ្គល ក៏

ព្រោះសន្ទតិតាមលោកពោលហាយ៉ាងនេះឯង, បើពោលដោយខ្លីថាបញ្ចក្ខន្ធ គឺធាតុ ៤: ដី, ទឹក, ភ្លើង, ខ្យល់ ផ្សំផ្គុំចូលគ្នាជារូប-វេទនា-សញ្ញា-សង្ខារ-វិញ្ញាណ អាស្រ័យនឹងគ្នា; កាលបើបច្ច័យគឺធាតុ ៤ អស់កម្លាំងផ្សំផ្គុំគ្នាហើយ លោកគឺបញ្ចក្ខន្ធក៏នឹងតាំងនៅមិនបាន ត្រូវបែកធ្លាយទៅតាមបច្ច័យនោះដែរ, សមតាមទំនួតព្រះពុទ្ធភាសិថា យទា បច្ចយា បរិត្តជ្ជិ "របស់សព្វយ៉ាងដែលបច្ច័យប្រជុំផ្តុំឡើង រមែងប្រែប្រួលទៅតាមបច្ច័យ"។ ដូច្នេះ អ្នកដែលថាបញ្ចក្ខន្ធជារបស់ខ្លួនឯងនោះ ឈ្មោះថាងាយពាំងពាត់ការយើញត្រូវរបស់ជនដទៃ ដោយគ្មានហេតុផល ព្រោះអំណាចទិដ្ឋិមាន: ចូលលុកលុយគ្របសង្កត់សន្ធានដោយរឹងប៉ឹងមិនត្រមកហេតុផលក្នុងការយល់យើញរបស់អ្នកដទៃ ប្រកាន់មាំ ឈ្លក់ស៊ប់ក្នុងការយល់យើញរបស់ខ្លួន លើកជម្លើងធម៌គឺការចេះដឹងរបស់ខ្លួនថាជារបស់ពិត ឯការយល់យើញរបស់បុគ្គលដទៃថាមិនពិត ដោយមិនមានអាងហេតុផលព្រោះហេតុនោះឯង ការយល់យើញរបស់បុគ្គលបែបនេះ ទើបមិនប្រែប្រួលទៅដើម្បីសន្តិភាព សមសុខ, ទាំងមិនអាចធ្វើខ្លួនឱ្យបានដទៃឲ្យដើរទៅកាន់កូមិនៃវឌ្ឍនធម៌ នឹងការធម៌បានទេ, មានតែប្រែប្រួលដើម្បីបំផ្លាញសាមគ្គីធម៌ ឲ្យបែកបាក់ឃ្លាតឃ្លាចាកគ្នា ទៅជាច្រើនពួកក្រុម នឹងជាហេតុសេចក្តីឈ្លោះវិវាទ ទាស់ទែងគ្នាឲ្យចំរើនឡើងជាលំដាប់ ជាហេតុច្រានខ្លួនឯងនឹងបុគ្គលដទៃទាំងពួកគណៈឲ្យឆ្ងាត់ទៅកាន់

សេចក្តីទុក្ខក្តៅក្រហាយជានិរន្តរ៍ដោយពិត, សមដូចពុទ្ធភាសិតដែលបានលើកទុកជានិក្ខេបបទក្នុងខាងដើមថា:

សកញ្ចិ ធម្មំ បរិបុណ្ណមាហុ
អញ្ញស្ស ធម្មំ បន ហីនមាហុ
ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ
សកំ សកំ សម្មតិមាហុ សច្ចន្តិ ។

សម្មណព្រាហ្មណ៍ពួកខ្លះ ពោលសរសើរធម៌របស់ខ្លួនថា ពេញបរិបូណ៌. ពោលបង្អាប់ធម៌របស់ជនដទៃថាទាបថោក, ពោលសន្មតិលទ្ធិរបស់ខ្លួនៗ ថាជាគុណជាតិពិតប្រាកដ, សមណព្រាហ្មណ៍ពួកនោះរមែងឈ្លោះប្រកែកគ្នាដោយហេតុយ៉ាងនេះឯង ។

កាលបើពួកពុទ្ធសាសនិកបរិស័ទ ជាន់ជាបកត្តនៃភាសិតនេះហើយ សមគួរនឹងបដិបត្តិឲ្យសមដល់ឋានៈ នឹងជាទីគោរពសក្ការៈពប់អានរបស់ប្រជុំជន នឹងបានទទួលសេចក្តីសុខ - ចំរើន ទៅតាមផ្លូវវឌ្ឍនៈធម៌នឹងអារ្យធម៌ សមគួរដល់ការបដិបត្តិ សមសេចក្តីប្រាថ្នាកងវត្តដែលមិនលើសវិស័យសព្វយ៉ាង ដូចជាន់ពណ៌នាមកក្នុងវិភង្គបសមកថាតាមពុទ្ធបរិហារ ល្មមសមគួរដោយប្រការយ៉ាងនេះ

ឯវំ សមគួរតាមកាលវេលាត្រឹមប៉ុណ្ណេះឯង ។

បញ្ញាសជាតក

ភាគទី ២

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាបព្វជិត ពី ព. ស. ២៤៨៦, ត. ស. ១៩៤៣

(តមក)

សិរីចុឌាមណិជាតកទី ៧

(និយាយអំពីពាហិរកថាន និងអដ្ឋុត្តិកថាន)

លោកអាចារ្យ ឈឹម-ណាក ក្រមដំនុំព្រះត្រៃបិដក

ប្រែពីបាលី

ទទាមិ ឆ វិកម្បាមីតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ អត្តនោ ទាឋបារមឹ អារព្ភ កថេសិ ។ *សត្ថា រីអង្គសម្តេចព្រះសពេ្វជ្ញបរមសាស្តាចារ្យ កាលទ្រង់ប្រថាប់នៅវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធទូវាទនបារមីរបស់ព្រះអង្គ ហើយទ្រង់សំដែងព្រះធម្មទេសនា មានបទព្រះបាលីថា: "ទទាមិ ឆ វិកម្បាមិ ដូច្នេះជាដើម ។*

សេចក្តីដំណាលថា: ថ្ងៃ ១ កិក្ខូទាំងឡាយ កំពុងតែអង្គុយប្រជុំចរចាទៅមកវាគ្នាថា "ម្នាលអ្នកដ៏មានអាយុទាំងឡាយ, ព្រះបរមគ្រូនៃយើងទាំងឡាយ ព្រះអង្គឥតស្តប់ស្កល់កដ៏ការបរិច្ចាគទានសោះហ្ន៎ !. កាលព្រះអង្គនៅជាព្រះពោធិសត្វនៅឡើយ ទ្រង់បានបរិច្ចាគ

ទានជាច្រើនណាស់ទៅហើយ, បានចាំដរិតរបស់ព្រះអង្គឲ្យ
ទៅជាទានដល់សមយាចកផង, ព្រះអង្គបានបរិច្ចាគទានដ៏ឧត្តមថ្លៃថ្លា
កម្រមានណាធ្វើដូចបាន សូម្បីព្រះអង្គបានត្រាស់ប្រាកដជាព្រះពុទ្ធក្នុង
លោកហើយ ក៏បានប្រទានអរិយមគ្គដល់ពួកអរិយសាវ័កទៀត, ប៉ុណ្ណឹង
ហើយក៏នៅតែមិនទាន់ពេញចំណង់ក្នុងព្រះទ័យនៅឡើយ" ។

គ្រានោះ សម្តេចព្រះជិនស្រី ទ្រង់នមន្តមកកាន់ទីប្រជុំកុមារាំង
ឡាយនោះហើយត្រាស់សួរថា: "ម្នាលកុមារាំងឡាយ, អ្នកចាំងឡាយ
អង្គុយជំនុំគ្នាពីរឿងអ្វី?" ។ កុមារាំងនោះក្រាបបង្គំទូលថា: "បពិត្រព្រះ
អង្គដ៏ចំរើន យើងខ្ញុំព្រះអង្គប្រជុំនិយាយសរសើរអំពីព្រះទ័យរបស់ព្រះ
អង្គដែលនៅមិនទាន់ស្កប់ស្កល់ក្នុងការបរិច្ចាគទាន" ។ សម្តេចព្រះដ៏ទ្រង់
ញាណ ទើបទ្រង់ត្រាស់ថា: "ម្នាលកុមារាំងឡាយ, តថាគតមិនមែន
ទើបតែនឹងឲ្យទានក្នុងកាលឥឡូវនេះទេ, កាលពីដើម ដែលតថាគតនៅ
ជាពោធិសត្វនៅឡើយ តថាគតបានចាំងឲ្យសរីរៈពាក់កណ្តាលដល់សម
យាចកផង" ទ្រង់ត្រាស់តែប៉ុណ្ណោះហើយ ក៏គង់នៅស្ងៀម ។ កុមារ
ាំងឡាយ នាំគ្នាអាចធនាសូមឲ្យព្រះអង្គនាំអតីតនិទានមកសំដែងប្រាប,
ព្រះអង្គទើបនាំអតីតនិទានមកសំដែងដូចមានតទៅថា:

ម្នាលកុមារាំងឡាយ, កុងកាលដែលកន្លងទៅហើយ មានព្រះ
រាជាមួយព្រះអង្គទ្រង់ព្រះនាមសិរិឫទ្ធាមណី សោយរាជសម្បត្តិកុងក្រុង

ពាពណាសី ។ អគ្គមហេសីរបស់ព្រះអង្គ ទ្រង់ព្រះនាមបទុមវតី ជាស្រីបរិបូណ៌ដោយសីលនឹងអាចារៈ, មានបុណ្យបានធ្លាក់ចុះមកពីព្រហ្មលោក, មានព្រះកាយដ៏សមរម្យក្រៃលែង ជាទីស្រឡាញ់នៃជនទាំងឡាយ ។ ព្រះពោធិសត្វនោះ មានព្រះជន្មបានតែមួយជាតិទៀតប៉ុណ្ណោះ ទ្រង់ព្រះនាមចន្ទកុមារ ។ ឯព្រះរាជាទ្រង់សោយរាជ្យប្រកបដោយធម៌, បានចំណាយព្រះរាជទ្រព្យឲ្យជាទានសាលាសម្រាប់ឲ្យទាន ៦ ខ្នង គឺបួនខ្នងនៅទ្វារព្រះនគរ, ពីរខ្នងទៀតនៅកណ្តាលនគរក្បែរព្រះរាជដំណាក់, ហើយតែងទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ៦ សែនកហាបណៈ ពាល់ៗថ្ងៃ ដូចជាមហាមេឃបង្អុរចុះនូវភ្លៀងដ៏ជោកជាំជានិច្ច ក្នុងវេលាដែលព្រះរាជាអង្គនោះ មានកិត្តិស័ព្ទល្បីខ្ចរខ្ចាយទៅថាជាអ្នកដែរថ្លាក្នុងការបរិច្ចាគទាន ។

លំដាប់នោះ, ព្រះរាជាកំពុងតែទ្រង់ប្រទានទ្រព្យដល់ជនទាំងឡាយ មានអាមាត្យជាប្រមុខក្នុងវេលាបុព្វណ្ហសម័យថា "ចូរអ្នកពាល់គ្នាឲ្យទានរក្សាសីល តាមសេចក្តីសប្បាយ, ចូរទ្រទ្រង់នូវឧបោសថសីល" ហើយទ្រង់ស្រង់ព្រះទេវកធាភ ដែលអប់ដោយគ្រឿងគន្ធពិសោរមានក្លិនក្រអូបសាយ គួរឲ្យជនផងទាំងឡាយត្រេកអរក្រៃពេក ហើយស្តេចទ្រង់ព្រះឫស្តប្រដាប់ដោយគ្រឿងអលង្ការគ្រប់បែប មានអាមាត្យជាច្រើនរោមរោមជាបរិវារ ស្តេចឡើងគង់លើព្រះទីនាំងគជេន្ទ្រដ៏មានឫទ្ធិលេចឮបុណ្យរីកៈ ចេញសំដៅទៅទានសាលា ដល់ហើយទ្រង់ព្រះរាជទានព្រះ

ក៏ដឹងព្យាដល់សូមអ្នកចាំទទួលទាន ដោយព្រះហស្តរបស់ព្រះអង្គ ។ តមកទ្រង់ត្រាស់ព្រះពាជបញ្ជាប្រាប់ពួកអាមាត្យទាំងឡាយថា "ចូរអ្នកទាំងឡាយឲ្យទានតាមទំនងនេះចុះ" ទ្រង់ប្រគល់ការឲ្យទាននោះដល់អាមាត្យទាំងឡាយហើយស្តេចឡើងគង់លើព្រះពាជទីនាំង យាងត្រឡប់ទៅកុងព្រះបរមពាជវាំងវិញ ។ លោបច្ចូសសម័យថ្ងៃមួយ ព្រះពាជាទ្រង់តើនចាកសយនាគ្រឡាព្រះបន្ទំ ទ្រង់គង់នៅតែមួយព្រះអង្គទ្រង់មានព្រះដម្រិះថា "អញចង់ឲ្យអដ្ឋត្តិកទាន តែសមយាចកទាំងឡាយ ហ្ន៎ សូមតែពាហិរកទានដូច្នេះ, បើសិនជាមានអ្នកណាមកសូមអដ្ឋត្តិកទាន គឺកែកក្តី ក្បាលក្តី បេះដូងក្តី ឈាមក្តី ឬក៏សរីរៈទាំងមូលក្តី អញនឹងធ្វើសរីរាវយវៈទាំងនោះឲ្យជាបច្ច័យនៃសព្វញ្ញុតញ្ញាណ ហើយឲ្យដល់អ្នកនោះពុំខាន" ។ កាលដែលព្រះពាជាកំពុងតែរិះក្នុងព្រះចិត្តាដូច្នេះក៏ស្រាប់តែផែនដី កម្រាស ៦ សែន ៤ ម៉ឺនយោជន៍ កម្រើកញាប់ញ័រគ្រាមដូចជាដំរីចុះប្រែង, ទាំងៈស្តេចកុំឈ្មោះសិនេរុ ក៏ទន្ទនលំពោនដូចជាចុងផ្តៅដែលបុគ្គលកោលក្តើងពត់ មានមុខបែរទៅរកទន្តរពាណសី; ទាំងមហាសមុទ្រក៏បង្កើតជារលកចោកបែកផ្លាវត្រែង ទាំងមហាមេឃក៏បង្អុរមកនូវភ្លៀងចោកូរព័ណ៌បញ្ចេញផ្គរខ្ទរ ផ្លេកបន្ទោរពុំដូចាលភ្លឺព្រោងព្រាយ; សម្តេចព្រះសក្កទេវិន្ទពិនូអមាត ក៏ទ្រង់ទះព្រះហស្តឲ្យស័ព្ទសាធុការ, ទេវតាទាំងឡាយកង់តាមាវចរសួគ៌ាក៏ថ្វាយស័ព្ទហ

ធុតាវោរ, មហាព្រហ្មក៏ដួយឲ្យពរជ័យ មានសេចក្តីជ្រួលជ្រើមភ្ញាក់ភ្ញឹក ជាគំលាហល តាំងភពនៃផែនដីរហូតដល់ព្រហ្មលោក ។

ព្រោះហេតុនោះ ចានជាសម្តេចព្រះសាស្តាចារ្យទ្រង់ត្រាស់ថា

សិរីបុឌ្ឍមណី នាម សោហំ រជ្ជមការយឹ
តទាហំ និសជ្ជ បាសាទេ ទានំ ទាតុំ វិចិន្តយិ
ហទយំ ទទេយ្យំ បក្ខំ មំសំបិ រុធិរំ បិប
ទទេយ្យំ កាយំ សាវជ្ជា យទិ កោបិ យាចេយ្យ មំ
សភារំ បិន្តយន្តស្ស អកម្បិ តមសណ្ឋិតំ
អកម្បិ តត្ត បឋវី សិនេរុវនជំសកាតិ

កាលតថាគតកើតជាស្តេចឈ្មោះ សិរីបុឌ្ឍមណី សោយពាជ្ឈកង្គ្រែងពាណ៌ស័. កាលនោះតថាគតអង្គុយលើប្រាសាទ ចានត្រិះរិះថានឹងឲ្យអជ្ឈត្តិកទាន គឺថានឹងឲ្យបេះដូង ក្អែកសាច ឈាម ឬថាបើមានអ្នកណាមួយមកសូមខ្លួនតថាគតយកទៅធ្វើជាខ្ញុបម្រើ ក៏តថាគតសូតែទៅធ្វើជាខ្ញុបម្រើអ្នកនោះដែរ; តថាគតកំពុងតែត្រិះរិះដូច្នេះ ក៏ស្រាប់តែប្រឋពីកម្រើកញាប់ញ័រ ទាំងក្អូសិនេរុពាជក៏បង្អោនទោរទន់មកកាតថាគត ។

កាលនោះ អាសនៈនៃសក្កទេវរាជក៏សំដែងនូវឈ្មោះការក្តៅកាយឡើង, ទើបសម្តេចព្រះសហស្សនេត្រទ្រង់អាវជ្ជនាការពិចារណាថា: អ្នកណាអេះជាទេវតាឬក៏ជាមនុស្ស ជាអ្នកបូជាគោរពប្រតិបត្តិមាតាបិតា ឬជាអ្នកបានបរិច្ចាគវត្ថុដ៏ថ្លៃថ្លាឲ្យទៅជាទាន ឬមួយជាអ្នកចេះព្រឹត្តព្រហ្មចរិយធម៌បានជាធ្វើអញឲ្យកន្ត្រេមកចាកអាសនៈដល់ម្ល៉េះ ។

កាលទ្រង់រំពឹងដូច្នេះ ក៏ជ្រាបនូវហេតុនោះ មានព្រះទ័យត្រេកអរសោមនស្សដោយក្រៃលែងថា "អើហ្ន៎! ព្រះចន្ទសិរីចុះមណី ជាពុទ្ធិរបណ្តាលពុទ្ធវង្សអគ្គសពើដ្ឋទ្រង់ឲ្យបានដំណឹងអស្ចារ្យកាន ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គក្នុងកាលជាអនាគតតុំាងនេះឡើយ" ។ សម្តេចព្រះអម្ចាស្រ្តាធិរាជ ទើបទ្រង់ចុះចាកហាងសួគ៌ លះបង់នូវភេទជាព្រះឥន្ទ្រនិម្មិតអត្តភាពជាព្រាហ្មណ៍ មានរូបរៃមួយចំហៀងដើរចូលមកកាន់ទីគារាកណសិ, ចូលទៅអង្គុយក្នុងទីព្រះលានខាងក្រៅជា លើកដៃក្រាបថ្វាយបង្គំពោលថា "បពិត្រមហារាជ, សូមព្រះអង្គទ្រង់មានជ័យជម្នះឈ្នះអស់សត្រូវ! សូមព្រះអង្គទ្រង់មានជ័យជម្នះឈ្នះអស់សត្រូវ!" ។

លំដាប់នោះ ព្រះពាគ្រទ្រង់ព្រះសារនាការភ្ញាក់ផ្អើលយ៉ាងធំ, ទ្រង់ក្រោកចាកអាសនៈក៏ឆ្ពៀងព្រះនេត្រទតទៅខាងមុខឃើញព្រាហ្មណ៍មានរូបអន្ធការ ក៏ទ្រង់ស្តេចចុះចាកប្រាសាទមកកាន់សំណាក់

ព្រាហ្មណ៍ ទ្រង់ទតឃើញព្រាហ្មណ៍មានសរីរៈញាប់ញ័រដូច្នោះ ក៏មានព្រះពុទ្ធប្រកបដោយសេចក្តីមេត្តាយ៉ាងខ្លាំង មិនអាចនឹងទប់ទល់ដំណើរព្រះអង្គបាន មានព្រះជន្មនៃតាហៀរហូរសស្រាក់ ដោយទ្រង់ព្រះសង្វេគក្នុងព្រះពុទ្ធប្រយ័ថា "នែបុរេអញ្ញអើយ! តថាគតមានថ្ងៃណាមួយនឹងភៅជាយ៉ាងនោះដែរកុំបីដឹង!" ទើបទ្រង់ក៏ពិចារណាថា "អាត្មាអញមិនត្រូវសួរព្រាហ្មណ៍នោះអំពីរឿងហេតុអ្វីដទៃទេ, ត្រូវតែសួរអំពីហេតុដែលព្រាហ្មណ៍មកកន្លងទីនេះប៉ុណ្ណោះចុះ" ទើបទ្រង់ត្រាស់ជាគាថាដូច្នេះថា:

អបិ នុ ភោ ព្រាហ្មណ កេន វណ្ណេន បដិបន្នោ
អនុប្បត្តោសិ មេ វដ្ដំ(1) តំ មេ អក្ខាហិ បុច្ឆិតោ

អើព្រាហ្មណ៍ អ្នកឯងមានកេរដំណែងអ្វី? មានហេតុដូចម្តេច ទើបជាមកកាន់ដែនរបស់យើងនេះ? ចូរអ្នកឯងប្រាប់ហេតុនោះដល់យើងកុំលាក់ ។

លុះជាប់នោះ ព្រាហ្មណ៍ដែលកន្លងមានសរីរៈញាប់ញ័រដោយអំណាចវេទនាដ៏ខ្លាំងមានខ្លួនស្គមស្គាំងក្តៅក្រហល់ក្រហាយលើកដៃឡើងក្រាបបង្គំទូលយ៉ាងនេះថា "បពិត្រព្រះពុទ្ធសម្ភារ, ទូលព្រះបង្គំជាខ្ញុំជាមនុស្សថោកទាបជាង មកកន្លងទីនេះ ដើម្បីសូមសរីរៈព្រះអង្គពាក់កណ្តាល, សូមទ្រង់ព្រះពុទ្ធទានកុំខាន ខ្ញុំព្រះអង្គនឹងយកមកបង្កប់ធ្វើសរីរៈពាក់

---

1 អនុប្បត្តោសិ មំ វដ្ដិនិំ ជាហៅ ។

កណ្ដាលនៃទូលព្រះបង្គំជាខ្ញុំ, សូមព្រះអង្គប្រទានដំរីតដល់ទូលព្រះបង្គំជាខ្ញុំកុងគ្រាឥឡូវនេះ, ហើយក៏ពោលជាបទព្រះគាថាថា:

យថា វារិរុហោ បុរោ សព្វកាលំ ន ទីយតិ
ឯវំ្ហ យាបិតាគញ្ជិ អគ្ឃសរំ មេ ទេហិ យាបិតោ

បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ, ធម្មតាស្ទឹងទន្លេមេដលជារដ៏ពេញប្រៀបដោយទឹកវារី ជាទីតឹងប្រស័យនៃមនុស្សម្នាមហាជននឹងសត្វផងនានា ទោះបីសត្វផងជងឆ្លងជងផឹកឥតឈប់ឈរយ៉ាងណា ក៏ពុំដែលស្រកស្រុតរីងសូន្យអស់ទៅឡើយ ដូចម្ដេចមិញ, ឯព្រះពជ្ឈាទ័យរបស់ព្រះអង្គវិញក៏សឹងតែដូច្នោះ ទោះបីមនុស្សកំសត់ទុគតទីទំលែកមកសូមរបស់អ្វី ក៏ព្រះចក្ដីពុំដែលខ្វះខាតឬទីសាល់ឡើយ, ឥឡូវនេះ ទូលព្រះបង្គំជាខ្ញុំមកសូមសរីរៈពាក់កណ្ដាល សូមព្រះកូបាលទ្រង់ព្រះមេត្តាប្រោសព្រះពជ្ឈាន ដល់ទូលព្រះបង្គំជាខ្ញុំកុំខាន ។

ព្រះមហាសត្វទ្រង់ព្រះសវនាការពុំពាក្យនោះហើយក៏មានព្រះទ័យប្រកបដោយចីតិ មានសេចក្ដីសំគាល់ថា ហាក់ដូចជានឹងបានត្រាស់ជាព្រះពុទ្ធប្រាកដកងលោកកងថ្ងៃស្អែក ទើបទ្រង់ត្រាស់ថា "ម្នាលមហាព្រាហ្មណ៍អើយ ប្រពៃហើយ ស្រួលហើយ, យើងនឹងបំពេញសេចក្ដី

ច្រើនថាកន្ធចិត្តរបស់អ្នកឲ្យបានសព្វគ្រប់ ហើយទ្រង់មានព្រះពាជហ្ឫទ័យមិនជាប់ដំពាក់ មិនរើរក់ឃ តែកាយដូចជាបុរសកំសត់ដែលកំពុងឈរដៃស្រាប់ ហើយគេយកថង់ដែលពេញដោយពានខ្នែកហាថណៈមកដាក់លើដៃនោះ ទើបទ្រង់ត្រាស់ថា:

ទទាមិ ឥ វិកម្បាមិ យំ មំ យាចសិ ព្រាហ្មណ
សព្ពំ ឥ បដិគណ្ហាមិ ទាឌេ មេ រមតី មនោ
បញ្ចំ សីសញ្ច ហាទយំ ជីវិតំ មេ សលោហិតំ
ទទាមិ ឥ វិកម្បាមិ ពោធិយា យេវ ការណាតិ

ម្នាលព្រាហ្មណ៍អ្នកសុំរបស់ណា យើងឲ្យរបស់នោះ ឥតមានរួញរាឡើយ យើងមិនលាក់ទុករបស់ដែលមានទេ ចិត្តយើងត្រេកអរតែក្នុងការឲ្យទាន យើងនឹងឲ្យក្នែក ឲ្យក្បាល ឲ្យបេះដូង ឲ្យដើរឹត ឲ្យសាច់ ឲ្យឈាម ឥតមានរួញរាឡើយ ព្រោះហេតុចង់បានត្រាស់ពោធិញ្ញាណតែម្យ៉ាង ។

តពីនោះមកទ្រង់ត្រាស់ថា "ម្នាលព្រាហ្មណ៍! ចូរអ្នករង់ចាំកន្ធនេះសិនចុះ" ហើយទ្រង់ឡើងទៅលើប្រាសាទ ទ្រង់ប្រជុំពួកអ្នកនគរមានអាមាត្យជាដើម ទ្រង់មានព្រះពាជឫទ្ធានុភាពត្រាស់ឲ្យហៅនាងបទុមវតីទេវី ឲ្យហៅចន្ទកុមារ ជាបុត្ររបស់ព្រះអគ្គមហេសី ហើយទ្រង់ទូន្មតប្រដៅ

អង្អែលប្រាប់ថា "ម្នាលកូន ជាទីស្រឡាញ់ពេញចិត្តមាសអាពុកអើយ, តាំងពីថ្ងៃនេះទៅហើយ ចូរអ្នកកុំប្រហែស ចូរអ្នកឲ្យទាន រក្សាសីល ចំរើនភាវនាកុំខាន; បានជាបិតាប្រាប់ដូច្នេះ ព្រោះបិតានឹងឲ្យអដ្ឋត្តិកទាន ក្នុងថ្ងៃនេះឯង" ហើយទ្រង់ឲ្យព្រះរាជបុត្រគង់លើរតនបល្ល័ង្កទ្រង់ស្រោច អភិសេកទឹកធារា ដោយកុន្ទីរមាស ប្រគល់រាជ្យដល់ព្រះរាជបុត្រនោះ ។ លំដាប់ពីនោះមក ព្រះរាជាទ្រង់ស្តេចទៅកាន់សំណាក់ព្រាហ្មណ៍ដែលមកសូមទាន ទ្រង់មានព្រះរាជឫដ្ឋារថា "ម្នាលមហាព្រាហ្មណ៍អើយ! អ្នកកុំគិតឡើយ យើងនឹងបំពេញចំណង់ក្នុងចិត្តរបស់អ្នក ឲ្យពេញបរិបូណ៌តទើសទាល់" ។ ព្រាហ្មណ៍នោះក្រាបបង្គំទូលថា "បពិត្រមហារាជក្សត្រថ្លៃប្រសើរអើយ, សូមព្រះអង្គទ្រង់ព្រះរាជទានសរីរៈរាក់កណ្តាលដល់ទូលព្រះបង្គំជាទ្បិនាប់។" ។ ព្រះរាជាមានព្រះរាជឫដ្ឋារថា "ម្នាលមហាព្រាហ្មណ៍ ប្រពៃហើយ ល្អហើយ" រួចមានព្រះប្រាថ្នាទឹងប្រកាសដល់ពួកទេវតា ទើបទ្រង់គង់ទៅឯអាកាសទ្រង់គ្រាស់យ៉ាងនេះថា:

សុណន្តុ ភោន្តោ វចនំ ទេវសង្ឃា សមាគតា
ជហាមិ ជីវិតំ មយ្ហំ ពោធិយា យេវ ការណាតិ

បពិត្រទេវតាចាំងឡាយដ៏ចំរើនអើយ, សូមអ្នកចាំងឡាយអញ្ជើញមកជួបជុំចាំស្តាប់ពាក្យខ្ញុំ ដ្បិតខ្ញុំលះបង់ជីវិតរបស់ខ្ញុំ ដើម្បីឲ្យបានត្រាស់ជាព្រះពុទ្ធប្រាកដក្នុងលោក ក្នុងកាលជាអនាគត ។

លំដាប់ពីនោះមក ទ្រង់ក៏ធ្វើដង្ហានថា "កោន្ដោ បតិត្រទេវតាទាំង
ឡាយដ៏ចំរើនអើយ! សូមអ្នកទាំងឡាយចាំស្ដាប់ពាក្យខ្ញុំ: ព្រះពោធិសត្ត
ទាំងឡាយអំពីបុរាណ ដែលបានដល់នូវសព្វញ្ញុតញ្ញាណ ពិតជាបាន
ដោយការបរិច្ចាគ ៥ យ៉ាង; ដោយពាក្យសច្ចនេះ សូមឲ្យរាល់ទារុក
ចុះមកឆាប់ៗកុំខាន" ។

ព្រះស្ដេច សម័យនោះមានយក្សពីរ មានឆ្នេញ្រ្ដហម
មានក្អែកត្រហម មានកេមត្រហម មានចិញ្ចើម ពុកមាត់ ពុកចង្កាទន
សក់ត្រហម មានចង្កឹមដូចជាត្រចកជ្រូកយ៉ាងធំ មានរូបគួរស្បើមខ្លែពេក
មានដៃកាន់រាណារ ទម្លាយដែកមហាប្រឹបពីមក ដោយកម្លាំងនៃ
សេចក្ដីអធិដ្ឋានរបស់ព្រះពោធិសត្ត ។ មនុស្សទាំងឡាយឃើញយក្ស
ទាំងនោះហើយ ក៏តក់ស្លុតរត់ទៅ ។ គ្រានោះ ព្រះពារាណសី
ព្រះនេត្រឃើញយក្សទាំងពីរហើយ ទ្រង់មានព្រះពាក្យថា "ម្នាល
មហាយក្ស! ប្រពៃហើយ! ស្រួលហើយ! ចូរអ្នកអនុមោទនាអដ្ឋត្ត-
កថានរបស់យើង ដោយសេចក្ដីអនុគ្រោះចំពោះយើង, ព្រោះយើងចង់
ឲ្យសំរេចកាត់កណ្ដាលដល់ព្រាហ្មណ៍ ចូរអ្នកអាសន្នខ្លួនយើងតាំងពី
ក្បាលរហូតដល់ចុងជើង យើងនឹងឲ្យខ្លួនមួយចំហៀងដល់ព្រាហ្មណ៍,
មួយចំហៀងទៀតចូរអ្នកបរិភោគចុះ" ។

គ្រានោះ យក្សចាំងពីរក៏ទទួលព្រមថា "សាធុ មហារាជ, បពិត្រមហារាជ! ប្រពៃហើយ! ល្អហើយៗ" រួចក៏ដើរចូលទៅកាន់សំណាក់ព្រះពោធិសត្វ ឋិតនៅក្នុងទីដ៏សមគួរ។ លំដាប់នោះ ព្រះពោធិសត្វចាប់យកវាណារហើយបបោសអង្អែលវាណារនោះដោយព្រះហស្ត ចង់ញ៉ាំងពួកទេវតាឲ្យជ្រាប; ទើបទ្រង់ឆើឆមើលអាកាសហើយត្រាស់យ៉ាងនេះថា "បពិត្រពពួកទេវតាចាំងឡាយដ៏ចំរើនអើយ! ដោយការបរិច្ចាគនូវខ្លួនរបស់ខ្ញុំនេះ ខ្ញុំមិនប្រាថ្នាសម្បត្តិមនុស្ស សម្បត្តិព្រះឥន្ទ្រ សម្បត្តិព្រះព្រហ្ម សម្បត្តិស្តេចចក្រពត្តិ សម្បត្តិព្រះបច្ចេកពុទ្ធ សម្បត្តិសាវ័កឡើយ; សូមឲ្យបានជាបច្ច័យនៃការត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ! កាលបើខ្ញុំបានសម្រេចនូវសព្វញ្ញុតញ្ញាណហើយ នឹងបានដោះនូវសត្វលោកព្រមទាំងទេវតាឲ្យរួចចាកសំសារវដ្ត" ។ គ្រានោះ ពួកទេវតាក៏ភ្ញាក់ផ្អើលគឹកកងឡើងទាំងពួកមហាជនមានអាមាត្យជាប្រធាន ក៏មានអាការញាប់ញ័រពេញទាំងផែនដី គក់ទ្រនំរសាយសក់ខ្មៅហោយំ ពួរសូរទ្រហឹងអឺងកងរំពងទាំងព្រះពាជរាំង ។ លំដាប់នោះ យក្សចាំងពីរក៏អារពន្ធនព្រះសិរព្រះពោធិសត្វ ។ ដំណឹងនោះ ក៏ជ្រាបដល់ព្រះនាងបទុមវតីទេវី ព្រះនាងទ្រង់ចុះចាកប្រាសាទ រត់មករសាយសក់ ដំព្រះឧរ នេត្រាក៏ជោកជាំដោយជលនេត្រា មកក្រាបទៀបព្រះបាទព្រះពោធិសត្វ ឧបវត់ហើយទ្រង់ព្រះកន្សែងថ្លៃធំពិលាបអាណិតអាសូរក្រៃពេក ។ ចាំងចន្ទកុមារ

កំស្តេចមកនុបរិតព្រះបាទព្រះកន្ទែងសោកជាមួយព្រះវរាជមាតា ។ កាលបើយក្សអារព្រះពោធិសត្វដល់ព្រះនលាតៈហើយ ឈោមកំហូរចេញមក ។ សម័យនោះឯង ទេវតាទាំងឡាយប្រជុំគ្នាលើកទ្បៀងទូវ ទង់ជាយទង់ជ្រងសំពោងព្រោងព្រាត ទូងគេវិទ្យាវាសតូរស្មាធុការ ។ ភ្លៀងជាវិការនៃផ្កាគ្រប់យ៉ាង ក៏បង្អុរចុះមក ។ មហាមេឃពុំដូចកាលកំបណ្តាលឲ្យមានផ្លេកបន្ទោរនូរពោសពេញទាំងអាកាស ។ អាកាសទេវតាទាំងឡាយ ក៏ប្លុងដោយទៀនធូបប្រទីបក្តីផ្កាផ្សែង ។ ហើយឲ្យសតូរស្មាធុការពារ ដល់ព្រះពោធិសត្វ ។ កាលបើយក្សអារពីត្រឹមព្រះនលាតៈ មកដល់ព្រះទុស្ស ព្រះមហាសត្វទ្រង់ត្រាស់ព្រះពាដនុង្ការៈចំពោះមហាជនទាំងឡាយយ៉ាងនេះថា "អ្នកទាំងឡាយចូរកុំសោកខ្សឹកខ្សួលឡើយ" ។ ស្រីស្នំទាំងឡាយ មាននាងបទុមវតីជាប្រមុខ នាំគ្នាមកគ្រាបទៀបព្រះបាទព្រះពាជាហើយសោកថ្ងូរកាយពាល់ៗគ្នា ។ គ្រានោះ ព្រះពោធិសត្វ ដែលយក្សអារដល់ព្រះសុវណ៌ហើយទ្រង់ក៏រងទុក្ខវេទនាដ៏ក្លាខ្លាំង កាន់តាំងព្រះស្មារតី ទើបព្រះចក្ខុមានព្រះពាដនុង្ការៈថា ព្រះបាទសិរីចុឌាមណី ជាសម្ចាសម្ពុទ្ធបានឃើញនូវពួកសត្វដល់ហើយនូវសេចក្តីទុក្ខ ក៏ខំប្រឹងព្យាយាមធ្វើអំពើដែលអ្នកដទៃធ្វើបានដោយកម្រ ព្រោះតែសេចក្តីអាណិតអាសូរប៉ុណ្ណោះ ។ លំដាប់នោះ យក្សទាំងពីរអារបំបែកសរីរៈរបស់ព្រះអង្គ ដោយរណារមាស រហូតដល់បេះដូង;

ទុក្ខវេទនា ក៏ដល់នឹងតែចំរើនច្រើនឡើង ទើបទ្រង់ហៅនព្រះពាជតុង្ការច្រាប់យក្សថា "ម្នាលយក្ស! ចូរអ្នកគាបំបែកសរីរៈយើងឲ្យស្រួល" ។ គ្រានោះឈាមក៏ហូរចេញស្រោចពេញសរីរៈរបស់ព្រះអង្គទាំងអស់ ស្រក់ដេរដាសពាសពេញទាំងមហាប្រឹថពី ។ យក្សក៏អារពន្ធនសរីរៈពីត្រឹមពោះរហូតដល់ចំណែកខាងក្រោម ។ គ្រានោះដំណឹង ពួកស្រីស្នំមានព្រះនាងបទុមវតីទេវីជាប្រធាន ព្រមទាំងចន្ទកុមារជាព្រះពាជបុត្រ ទាំងបុរោហិត នឹងពួកសេវាមាត្យព្រមទាំងពួកមហាជន ក៏ដេកដួលសន្ធប់ច្បាត់ស្មារតីលើមហាប្រឹថពី ។ ឯព្រះពាជាទ្រង់ទតព្រះនេត្រទៅឃើញសរីរៈតែមួយចំហៀងដូច្នោះហើយ ក៏ទ្រង់ព្រះពាជទានសរីរៈមួយចំហៀងនោះដល់ព្រាហ្មណ៍ ហើយត្រាស់ថា "ម្នាលព្រាហ្មណ៍! ទានរបស់យើងនេះសូមឲ្យបានជាបច្ច័យនៃសព្វញ្ញុតញ្ញាណ" ។ ព្រាហ្មណ៍ក៏កាន់យកសរីរៈមួយចំហៀងនោះទៅចងផ្តោចន្ទ័សរីរៈរបស់ខ្លួន ។ ពួកទេវតាទាំងឡាយមានព្រះព្រហ្មជាដើម ក៏ថ្វាយសព្វសាធុការៈចំពោះព្រះពោធិសត្វកំរិតពេញ ។ ទេវតាទាំងឡាយ ក៏ចូលទៅឱ្យពរសព្វសាធុការ ។ ភ្លៀងក៏ធ្លាក់ត្រជាក់ជាប់ជប ក៏បង្អុរចុះមកថ្លាយ ។ ពួកមហាជនទាំងឡាយក៏ភ្ញាក់ភ្ញាក់គឹកគឹកឡើង ។ សក្កទេវរាជ ក៏ធ្វើសរីរៈរបស់ព្រះពោធិសត្វឲ្យត្រេកត្រអែកឡើងដូចប្រក្រតីវិញ ល្អដូចជារូបមាសគាន់ ។ ព្រះពោធិសត្វ កាលបើមានសរីរៈពេញលេញល្អដូចជារូបមាសហើយ ទ្រង់

ត្រាកឡើងគង់នៅក្នុងទីនោះឯង ។ ត្រានោះ សក្កទេវរាជ ចាន់ជ្រាប
អធ្យាស្រ័យដ៏ប្រសើរ របស់ព្រះពោធិសត្វនោះហើយ ក៏តោលសរសើរ
ព្រះពោធិសត្វជាអានេកប្រការ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ កាលសម្តេចព្រះបរម-
សពិជ្ញសាស្តា ចាន់ត្រាស់ឡើងហើយ ទ្រង់ប្រកាសសេចក្តីនោះថា:

តស្សូ សង្កប្បមញ្ញាយ ទេវិន្ទោ ឯតទព្រវិ
សព្វេ ជិតា តេ ឧជ្ជុហា យេ ទិព្ភា យេ ច មានុសា
ឥន្ទ្រាទិតា តេ បហីនា សព្វេ តេ តិទិវូបគោ
សមន្តា វិជិតា អាគ្ឆុ កិរីដំ វ បតិស្សុតោ
តស្សូ តេ អនុមោទន្តិ ទិវោ នារទបព្វតា
តិន្ទ្រោ ព្រហ្មា បជាបតី សោមោ យមោ វរុណោ
សព្វេ ទេវា អនុមោទន្តិ ទុក្ករំ ហិ ករោតិ សោ
ទុទ្ទុទំ ទទមានានំ ទុក្ករំ កម្មកុព្វតំ
អសន្តោ នានុកុព្វន្តិ សតំ ធម្មោ ទុរន្វយោ
តស្មា សតញ្ច អសតំ នានា ហោតិ ឥតោ គតិ
អសន្តោ និរយំ នេន្តិ សន្តោ សគ្គបរាយនោតិ

សក្កទេវរាជ ជាធំជាងទេវតា បានជ្រាបច្បាស់នូវសេចក្តី
គិតរិះរបស់ព្រះរាជានោះហើយ ទើបពោលពាក្យដូច្នេះថា:
ដែនតាំងមូលព្រះអង្គលះបង់ហើយ, វត្ថុតាំងឡាយឯណា
ជារបស់ទិព្វក្តី ជារបស់មនុស្សក្តី ក៏ព្រះអង្គលះបង់ហើយដែរ,
ដែនប្រឹបពីជាទំនៃទ្រង់នូវសត្វ ព្រះអង្គធ្វើឲ្យកន្ត្រើតរំពើក
ហើយ, សំឡេងសរសើរចំពោះព្រះអង្គ ផ្សាយទៅហើយ
ដល់ពិភពតាវត្តឹង្ស. ឆ្កែបន្ទោរ កំលេងឡើងឆ្អែលត្រាត់
ជាលប្រវាត់ព័ទ្ធជុំវិញ, ភ្នំតាំងឡាយ ក៏លាន់ឮសូរស័ព្ទ
កងរំពងឡើង, ភ្នំនារទៈទាំងពីរ ក៏អនុមោទនាចំពោះព្រះអង្គ,
ពួកទេវតាទាំងពួង គឺព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះបជាបតី
ព្រះចន្ទ្រ ព្រះយម ព្រះវេស្សវ័ណ សុទ្ធសឹងតែអនុមោទនាថា
ព្រះរាជាអង្គនោះ ទ្រង់ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ
ណាស់; ព្រះរាជាអង្គនោះ ទ្រង់ព្រះរាជទានទ្រព្យទានដែល
បុគ្គលឯទៀត ឲ្យបានដោយកម្រ ធ្វើនូវអំពើដែលបុគ្គល
ឯទៀតធ្វើបានដោយកម្រយ៉ាងនេះ, អសប្បុរសទាំងឡាយ
មិនងាយនឹងធ្វើតាមបានឡើយ ធម៌របស់សប្បុរសគឺអសប្បុរស
ដ៏ងបានដោយកម្រ ព្រោះហេតុនោះ បានជាសប្បុរសនឹង

អសប្បុរស តែងមានដំណើរផ្សេងៗពីគ្នា គឺអសប្បុរសទាំងឡាយ តែងទៅកាន់នរក ពួកសប្បុរសតែងទៅកាន់ស្ថានសួគ៌ ។

សក្កទេវរាជ ទ្រង់ត្រាស់តទៅទៀតថា "បពិត្រមហារាជ ! ព្រះអង្គបានព្រះរាជទានយ៉ាងនេះហើយ ទ្រង់កុំអាលភ្លែតនឹកការព្រះរាជទានតែមតែប៉ុណ្ណោះឡើយ" ។ គ្រានោះ ព្រះពោធិសត្វកាលបើបានរស់ព្រះជន្មឡើងវិញហើយ ក៏ទ្រង់ត្រេកអរជាទីនោះ, ទើបសម្តេចសក្កទេវរាជថ្វាយសព្វសាធុការពរ ចំពោះព្រះពោធិសត្វ រួចហើយក៏លាទៅកាន់ទេវលោកវិញ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ កាលសម្តេចព្រះបរមសាស្តាចារ្យទ្រង់ប្រកាសសេចក្តីនោះ ទ្រង់ត្រាស់ដូច្នេះថា:

ទេវរាជជាកស្តានៃនាគរាជសុជាតា មានតាមថាមយ៉ាង: ពោលនូវពាក្យដូច្នេះរួចហើយ ក៏ធ្វើនូវសេចក្តីសរសើរចំពោះព្រះពោធិសត្វហើយចៀសចេញទៅកាន់ទេវនិកាយវិញទៅ ។

លំដាប់នោះ ពួកមន្ត្រីចាំឡាយ មានអាមាត្យជាដើម នឹងស្តេចសាមន្តរាជ ព្រមចាំបណ្តាជនចាំឡាយ មានគហបតីជាដើម ក៏បានដកដង្ហើមធូរស្រួល ហើយអង្គុយប្រជុំគ្នាឲ្យសព្វសាធុការពរចំពោះព្រះអង្គ ។ ឯព្រះពោធិសត្វ តែងទ្រង់ព្រះរាជទានជាប់ជានិច្ច

ដកបដល់ទ្រង់ព្រះដុក ទ្រង់ក៏ប្រគល់ភដសម្បត្តិឲ្យព្រះពដបុត្រ. រួចទ្រង់ស្តេចចេញចាកនគរ ចូលទៅគាន់ព្រៃ ទ្រង់ព្រះផ្នួសជាឥសី ញុំាងឈានឲ្យតើតឡើង លុះដល់អស់ព្រះជន្មាយុ ក៏ចាន់ទៅសោយព្រះជាតិកង់ព្រហ្មលោក ។

អង្គសម្តេចព្រះបរមសាស្តា ទ្រង់នាំព្រះធម៌ទេសនាមកសំដែងដូច្នេះហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! តថាគតឲ្យទាននេះមិនមែនតែក្នុងកាលឥឡូវនេះទេ កាលពីដើម ក៏ធ្លាប់តែឲ្យដូច្នេះដែរ" ។ ទើបទ្រង់ប្រជុំជាតកថា "នាងបទុមវតីទេវី កុងកាលនោះគឺនាងយសោធរាជាមាតាភហុលកុងកាលឥឡូវនេះ; បទុមកុមារកុងកាលនោះ គឺភហុលកុងកាលឥឡូវនេះ, ពួកជនដ៏សេស គឺជាពុទ្ធបរិសទ្យ, ព្រះចាន់សិរីបុទ្ធាមណី គឺអង្គតថាគតហ្នឹងឯង" ។

អ្នកទាំងឡាយជាពុទ្ធបរិសទ្ធ ចូរចងចាំនូវជាតកដូចរឿងដែលថ្លែងមកយ៉ាងនេះឯង ។

ចប់សិរីបុទ្ធាមណិជាតកទី ៨ នៃប៉ុណ្ណោះ

ដោយ

ព្រះមហាឧត្តមវិជ្ជា ធិលក្ខណៈ ប៊ុង-ប៉ម

អាចារ្យសាលាលើងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមគម្រោងសាស្ត្រាស្ងឹកវិត

អហំវិទ្ធំ លើកគ្រាមក្រពុំ បង្គំត្រកត្រង់
ឆ្ពោះទៅព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃ តាំង ៣ នេះទ្រង់
ជាម្ចាស់សិរសោ ។ ខ្ញុំថ្វាយបង្គំ វន្ទាប្រណម្យ
ដោយចិត្តសទ្ធា សរសើរសម្តែប សពិជ្ញគគ៌
ព្រះអគ្គជាតិជា គ្រូគ្រប់កពវិត្រ ។ ព្រះអង្គទេសនា
ទូន្មានទេវតា មនុស្សសត្វទាំង៤ ទោះសត្វលិចលង់
ការផុងទៅឮ នរកប្រេតិស័យ ព្រះអង្គតែងប្រោស ។
ព្រះមានមេត្តា ព្រះមានករុណា មិនដែលយកទោស
មានតែផ្តត់ផ្តង់ ស្រោចស្រង់សន្តោស ទេសនាប្រុះប្រោស
សព្វសត្វទាំងឡាយ ។ បង្គំព្រះធម៌ មានអត្ថបវរ
ផ្តៀងឆ្ងាយទូលាយ តែងនាំចម្ងង់ សត្វផងគ្រប់កាយ
ទៅដាក់តៃយនាយ ទោលគឺនិព្វាន ។ បង្គំព្រះសង្ឃ
ប្រៃសើរសឹងទ្រង់ សីលសុទ្ធជាយាន តាំងជាស្រែបុណ្យ

ព្រះគុណមែនមាន អាចឲ្យសត្វបាន រំលងបាបបង់ ។
ហេតុនោះខ្ញុំថ្វាយ អស់អង្គកាយ ចំពោះទៅត្រង់
ព្រះរតនត្រ័យ ទាំង ៣ ព្រះអង្គ គោរពផ្គត់ផ្គង់
ដោយចិត្តសទ្ធា ។ ខ្ញុំបង្គំសព្វ ទូទាំងពិភព
សោឡសសួគ៌ា សូមសុខសួស្តី ឫទ្ធិបេស្កា
ចំរើនទីយា- យុយឺនកន្ទង ។ ខ្ញុំនឹងតែងកាព្យ
ទៅតាមសកាព ដោយន្យូវគន្ធង៌ សូមអស់ទេវតា
ឲ្យសាធុផង៌ កុំឲ្យមានហ្មង់ ជិតដល់អង្គកាយ ។
សូមបុណ្យចារមី រតន:ទាំង ៣ ផ្តល់សុខសព្វសាយ
សូមតេជតបះ ពីព្រះកច្ចាយន៍ សូមសុខពណ្ណរាយ
ពីព្រះបច្ចេក ។ សូមបុណ្យចារមី ពីព្រះដ៏ន្រស៊ី
ច្រើនកៃអនេក ដែលនិញ្វានទៅ ស្ថិតនៅវិវេក
គង់កងហ៊ានឯក ពោលគឺនិញ្វាន ។ បង្គំទៀតទៅ
ដល់ព្រះដែលនៅ តុំទាន់ទ្រង់ញាណ ទើបសាងចារមី
នៅខ្ចីសល់ខាន គ្រាស់ក្រៃយប៉ុន្មាន បង្គំទាំងអស់ ។
ទូទាំងឥន្ទ្រព្រហ្ម ស្ថិតស្ថានឧត្តម សុខសួគ៌សោឡស
សព្វកៃព្រឹក្សា បព្វតាតបព្ទស់ ស្ងឹងបឹងទាំងអស់
សព្វដែរះធារ ។ សូមជាប្រធាន សាក្សីពេជ្ញាណ

នៃអញខ្ញុំណា ខ្ញុំតាំងក្នុងចិត្ត ហើយចេញវាចា
សូមសាងប្រាថ្នា ប្រាថ្នាទៅមុខ ។ កើតជាតិណា ។
ត្រង់ព្យាធិពេគា អំពល់ដាច់ទុក្ខ នោះកុំឲ្យមាន .
ឲ្យបានតែសុខ សព្វជាតិទៅមុខ ទុក្ខកុំឲ្យស្គាល់ ។
សូមឲ្យបានចេះ រហែនចំណេះ នៃត្រៃបិដកធម៌
ចេះចាំប្រាកដ រត់មាត់ឥតសល់ កុំឲ្យខ្វេសខាល់
ដល់តិចឡើយណា ។ ជាតិនេះអញខ្ញុំ អក័ព្វពេកពុំ
ខាន់ព្រះសាស្តា កើតខាន់ប្រចេះ តែព្រះសាសនា
កើតជាតិបវ (១) ឲ្យបានខាន់ព្រះ ។ ខ្ញុំសូមប្រាថ្នា
ព្រះត្រៃសក់លណា ឲ្យបានប្រចេះ ឲ្យបានថ្វាយថ្វាត់
ប្រតិបត្តិគុណព្រះ ឲ្យខ្ញុំបានឈ្នះ អំពើអកុសល ។
ឲ្យអស់ទៅតា ឥន្ទ្រិយហ្មត្តីណា ដួយជាកំណល់
កសិណសាក្សី កុំបីមានឆ្ងល់ ប្រាថ្នាបានដល់
អគ្គសាវ័កស្តាំ ។ តាំងនាងគង្គីន- ធរណីនោះឯង
ចូរដួយចងចាំ ភាក្យប្រណិធាន ដែលបានតាំងមាំ
ទុកជាចំណាំ កុំភ្លេចឡើយណា ។ ឥឡូវនេះខ្ញុំ
សូមលើកសេចក្តី ពីព្រះសាស្តា កើតតាមចំនង

---

១ ជាតិមុខ ។

ល្បែចល្បងច្រែចជ្រា ជាបទគាថ្យា ពាក្យពេចន៍បរិយាយ ។
ខោះបើលើសលោះ ខុសខកខ្វះខ្ជោះ បទច្បាប់ចាំងឡាយ
ចាំងពាក្យសំដី សេចក្តីសម្ងាយ សូមលោកចាំងឡាយ
សន្តោសខោសា ។ ខ្ញុំទទឹងអធិប្បាយ ពាក្យពេចន៍បរិយាយ
ពីព្រះសាស្តា កាលសោយព្រះជាតិ ជាស្តេចនាមា
សិសៅវ៍រាជា រង់ទុក្ខពេកក្រៃ ។ បើអ្នកឯណា
មែនមានច្រែចជ្រា សូមជួយតម្រែវ តម្រង់ឲ្យខាន
ឲ្យបានត្រឹមត្រូវ ដ្បិតខ្ញុំនេះក្រៃ ពុំសូវច្រែចជ្រែចឡើយ ។
អហំវីខ្ញុំ លើកដៃឡើងផ្តុំ ប្រណម្យថ្វាត់ថ្វាយ
នឹងលើកជាកាព្យ កំណាព្យចាំងឡាយ ពាក្យពេចន៍បរិយាយ
រឿងព្រះភគវ ។ ព្រះអង្គបានត្រាស់ ជាព្រះពុទ្ធច្បាស់
ផ្តាញ់ក្រែងមាក ចាក់បបូរបូរខ្ចាច អំណាចចេស្តា
ព្រះតែងទេសនា ពួន្នានសត្វសត្វ ។ ខ្លះបានសោតា
ខ្លះបានសកិទា ខ្លះបានអរហត្ត ព្រះអង្គតែងច្រែចស
សន្តោសសត្វសត្វ ពួន្នានកំចាត់ ពីសង្សារ ។
ព្រះជន្មស្តេចបាន បរិបូណ៌មែនមាន ប៉ែតសិបវស្សា
កាលណោះព្រះអង្គ ទ្រង់គង់នៅនា ជេតពនមហា
ទៀបសាវត្ថី ។ ព្រះអង្គទេសនា អំពីកម្ម

នៃព្រះអគ្គិទ្ធី ដែលអ្នកប្រាជ្ញឆ ប្រាន្តចង់សេចក្តី
ខុកកង់ប្រាលី តាមរឿងនិទាន ។ សេចក្តីនោះថា
កាលព្រះសាស្តា ជិតចូលនិព្វាន ពេលនោះឯង់ហោង
កិកុឆង់សព្វថាន ជ្រួលជ្រើមគ្រប់ប្រាណ ដំនុំគ្នាថា ។
អាវុសោតាំងឡាយ ! ចូរលោកមៀងហ្មាយ មើលផលកម្ម
អម្បាលសម្តេច សពៀជកតវ ជាម្ចាស់សិរីសោ
នៃយើងតាំងឡាយ ។ ព្រះអគ្គិឧដ្ឋស់ ប្រសើរលើសអស់
មនុស្សសត្វសម្ងួយ តង់តែផលកម្ម ប្រចាំត្រៃឆនាយ
ដិតជាមតាមកាយ ឲ្យខុកូសែនខ្លី ។ តីកាលព្រះអគ្គ
ទ្រង់មានចំណង់ ចង់សោយភ័រ ទឹកថ្លាកង់ស្ងួង
កុកជនទី ទឹកនោះប្រែពី ថ្លាស្អាតដូចថ្លា ។
ទៅជាទឹកល្អក់ ជាទឹកក្រខ្វក់ គួរអ្វីច្នេះណា
ប្រាប់ពោលទៅថ្លី ដល់សត្វសត្តា អម្បាលសាស្តា
តង់សោយផលកម្ម ។ ទើបព្រះកតវ សំដែងទេសនា
តាមដោយចំណាំ ប្រាប់សង្ឃគ្រប់គ្នា ខុកជាបណ្តាំ
កិកុអើយកែម្ន អគ្គអញនេះណា ។ មិនតែឥឡូវ
កម្មនោះឯងកូវ កាលអញតថា- តតយកកំណើត
កើតជាកូត្រា ធ្វើឲ្យអាត្ម ព្រាត់ប្រាសស្ទើរក្បួយ ។

អត់ចាយឥតបើ ចានតែផ្លែឈើ គ្រាន់នឹងអស្រ័យ
រំផ្ងើមម្ខាក់ឯង កណ្តែងកន្ធរព្រៃ លំចាកពេកព្រៃ
ឥតឯគណនា ។ បន្លែម្ហ៎ះហ៊ាយ គង់ស្ងៀមកន្តើយ
ពុំមានពុទ្ធដីកា ខើបអស់កិក្ខុផង ផ្តុំផ្តងវិន្ធា
អាពាធនា ព្រះធម៌ព្រះអង្គ ។ ខើបព្រះនរនាថ
ទទួលអាព- ធនាអស់សង្ឃ ស្រែចហើយថ្ងាថ្ងែង
សំដែងគ្រាស់ទ្រង់ ច្រាប់កិក្ខុសង្ឃ ពីកម្មដ៏ថ្លៃក ។
ថាកិក្ខុទាំងឡាយ ! ចូរលោកខ្វល់ខ្វាយ ស្តាប់អង្គអញព្រៀក
ថាកាលពីព្រៃផង អង្រែងលង្រែក យូរជាអនេក
កន្ធង់ឆ្ងាយទៅ ។ កិក្ខុអើយកាលនោះ មានក្សត្រ ១ ឈ្មោះ
ព្រះបាទសិសៅរ៍ សោយរាជ្យទសពិធ ថេរបិតនិត្យទៅ
នគរឈ្មោះហៅ អនន្តនគរ ។ រ័អគ្គមហេសី
ល្អស្អុះប្រមប្រិយ ប្រុសស្រីសាទរ នាមអនន្តា
ទើបវ៉ា ជាឆ្នើមនគរ លើសលែងស្រីផង ។
ស្តេចមានស្រីស្នំ ល្អៗសក្តិសម ៦ ហ្មឺនហោង
ចាយ ៦ ពាន់ ណាស់ណាន់កន្ធង ប៉ំរើច្បាស់ច្បង
នោះជាប្រក្រតី ។ ខាងខ្លះបក់ផាត់ ចោមដុំមហាក្សត្រ
ខ្លះថ្វាយព្រះស្រី ខ្លះកាន់ព្រះពស្ត្រ ថ្មីស្រស់ឥតបី

នាងខ្លះឃ្នាតខ្នី គក់ច្រចាប់ផង ។ បំរើសព្វថៃ្ង
ផ្កាប់ព្រះហ្ឫទ័យ មិនឲ្យមានហ្មង ស្តែងស្តេចជាធំ
ថ្កើងថ្កុំកន្ធង អស់កស្តេចសផង សាន្តសុខសប្បាយ ។
កបកើតសម្បត្តិ សម្បូរច្រើនក្តាត់ ខ្សាវតែឆ្ងាយ
មានមុខមន្ត្រី សេនីយតាំងឡាយ ព្រាហ្មណ៍ព្រឹទ្ធច្រាផ្ងច្រាយ
ហ្មបហ្មាយជិតជុំ ។ អស់តាំងពួកឈ្មួញ ដែលធ្លើដំនួញ
មូលមកកុះកុំ ចេញផ្ងួញទៅមក ដោយពួកដោយក្រុម
កុញកកកុះកុំ ច្រើនកៃគ្រៃបគ្រា ។ មានតាំងចតុវង្គ
ច្រងាប់គ្រប់អង្គ លំពែងឆ្នូស្នា ឥតមានក្លាំងក្លឹក
ទឹងសឹកឯណា សឹងតែហានក្លា ទីកៃគ្រប់ប្រាណ ។
មានឃ្លាំងមាសច្រាក់ អនេកអនន្តា ច្រើនពន់ប្រមាណ
សព្វស្តេចនានា ឧបមាពុំបាន ឦស្សីថ្កើងថ្កាន
ទ្វទិសនានា ។ ថ្កើងកេរ្តិ៍ថ្កើងយស ថ្កើងវង្សឱឡឹងឮស
ប្រៀបផ្ទឹមឧបមា ស្មើនឹងមហាចក្រ ឫទ្ធិសក្តិថ្លៃថ្លា
អស់ស្តេចនៅនាំ ជម្ពូទ្វីបនោះ ។ សឹងតែកោតខ្លាច
ដោយនូវអំណាច នាំគ្នាមកឆ្ពោះ ថ្វាត់ថ្វាយសួយវៃ
សព្វថៃ្ងគ្មានលោះ ផ្ទេរ ៗ ដោយឈ្មោះ តែវគង់មាសច្រាក់ ។

(មានត)

ភណ្ឌ ទី ១៨

ឧកញ៉ាវិបុលរាជសេនា ឆួ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជវិទ្ធាសបើបានអាន
ធំជំបេះឧបាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ ។

តាំងសុំនៅមិនទាន់ខុកចិត្តជាប្រាកដ កំធ្វើជាតក់ស្លុតហើយ
និយាយទៅនឹងម៉ាថេងថា ហេតុអ្វីបានជាអ្នកយកសេចក្តីនេះមកចរចា សព្វ
ថ្ងៃនេះចូរឆ្លងជាទីមហាឧបាសម្រេចបានការដែនដី ដែលអ្នកមកចរចាដូច្នេះ
បើមានគេដឹងនឹងនាំសេចក្តីទៅដំណាចចូរ យើងនឹងមិននាំគ្នាស្លាប់អស់ឯ
ទេឬ? ។ ម៉ាថេងថា អ្នកនៅពាប់គានចូរឆ្លងថាជាមនុស្សល្អ តែអ្នកជា
មនុស្សប្រចុបប្រចែងស្រឡាញ់ដីវិត មិនមែនមានចិត្តនឹងចង់ធ្វើឲ្យបានដែនដីឲ្យបានសេចក្តីសុខ ចូរអ្នកនៅឲ្យសម្បាយចុះ ខ្ញុំលាទៅហើយ ។
តាំងសុំនឃើញថា ម៉ាថេងសំដែងខ្លួនទៀតត្រង់ប្រាកដនឹងព្រះចៅ-

ហៀនតេជូច្នោះក៏និយាយថា "អ្នកកុំអាលខឹងសំបា សុំឲ្យឈប់ស្តាប់ខ្ញុំ
ទឹងនិយាយឲ្យស្តាប់សិន" ហើយក៏យកឡាយព្រះហស្តមកឲ្យម៉ាថេង
មើល ។ ម៉ាថេងស្គាល់ច្បាស់ជាឡាយព្រះហស្តជូច្នោះក៏ខឹងណាស់
ខ្នើបបាទាំធ្វេញគាល់តែលោហិតហូរចេញពីមាត់ ហើយនិយាយទឹង
តាំងសុំនថា អ្នកចូរនិគិតការនេះឲ្យធាប់ចុះខ្ញុំទឹងត្រឡប់វិលទៅស្រុកសៃ-
លៀងវិញ ដើម្បីទឹងលើកទាហានមកជួយកំចាត់សត្រូវពេជសម្បត្តិចេញ
ឲ្យបាន ។ តាំងសុំនក៏ហៅមន្ត្រីតាំង ៤ នាក់ឲ្យចេញមកជួបនឹងម៉ាថេង
ហើយធ្វើសត្យាបដិញ្ញាសច្ចាន់ចុះឈ្មោះជាមួយគ្នាតាំង ៦ នាក់ ។
តាំងសុំននិយាយនឹងម៉ាថេងថា ការដែលនឹងទំនុកបំរុងផែនដីក្នុងសម័យ
នេះ បើនឹងសម្រេចជូបច្រាថ្នាក់ដោយសារដំរេះរបស់អ្នក ។

ជូហុក, ជូឡាន់, តាន់អុប, ង៉ោហួននិយាយគ្នាថា យើងនឹងគិត
ច្រកការម្តេច ទើបនឹងបានមនុស្សទៀតត្រង់នឹងផែនដីមកជួយរិះគិត
ទៀត? ។ តាំងសុំនធ្វើយថា ការគ្រានេះជាទីកំបាំង បើយើងនឹង
និយាយឲ្យច្រែកការក៏នឹងឲ្យខូចខ្លួនអសារ ។ ម៉ាថេងបានឮមន្ត្រី ៤ នាក់
ទឹងតាំងសុំននិយាយគ្នាជូច្នោះ ក៏នឹកគិតឡើងឃើញឡៅពី ១ ទៀត
ហើយទះដៃអស់សំណើចថា យើងបានម្នាក់ទៀតហើយ ។ តាំងសុីន
សួរថា អ្នកឯណា? ។ ម៉ាថេងថា ឡៅពីជាពូជព្រះពជវង្សព្រះ
ចៅហៀនតេ ហេតុម្តេចអ្នកមិនយកមករួមគិតការនេះជាមួយផង ។ តាំង

ស៊ីនថាខ្ញុំពិជាពួជព្រះពាជវង្សក៏មែន តែថានៅក្នុងអំណាចចូរួ យើង
នឹងទុកចិត្តជាប្រាកដមិនបានទេ ។ ម៉ាថេងថាកាលព្រះចៅហៀនតេ
ស្តេចទៅប្រពាតព្រៃ នាហ្នឹងពាំងពួងចូលទៅថ្វាយបង្គំ ចូរួញាក់សេះ
បរទៅជាំងពីមុខព្រះតែក្តែធ្វើអាការបីដូចនឹងគំនាប់មន្ត្រីពាំងពួង គួនអ្ញិងឹង
ណាស់លើកដាវឡើងនឹងកាប់ចូរួ ខ្ញុំពិមិចក្អែកក្រវីក្បាលយាត់គួនអ្ញិ
យើងឃើញកិរិយាខ្ញុំពិប្រែងនឹងប្រទូសរ៉ាយចូរួដែរ តែនៅក្រែងខ្លាថា
ពាហានដែលមានចិត្តស្រឡាញ់កោតខ្លាចចូរួនោះច្រើន ហើយខ្ញុំពិ
ខ្លាចថ្មោះការបានជាឃាត់ហាមគួនអ្ញិ ហេតុនេះចូរអ្នកវិនិតនិយាយការ
នេះនឹងខ្ញុំពិផងចុះ ។ តាំងស៊ីនយល់ឃើញត្រូវ ម៉ាថេងនឹងមន្ត្រី
ពាំង ៤ នាក់ក៏គំនាប់លាតាំងស៊ីនចេញទៅ ។

លុះវេលាយប់ តាំងស៊ីនក៏យកឡាយព្រះហស្តចេញទៅរកខ្ញុំពិ។
ឃើញតាំងស៊ីនមករកក៏ត្រែកអរណាស់ អញ្ជើញឲ្យបរិភោគអាហារ ។
តាំងស៊ីនដំរកបសួរខ្ញុំពីថា កាលព្រះចៅហៀនតេស្តេចទៅប្រពាតព្រៃ
គួនអ្ញិលើកដៃឡើងនឹងកាប់ចូរួ ហេតុម្តេចបានជាលោកហាមឃាត់ ។
ខ្ញុំពីភ័យស្ងុតចិត្តធ្វើយថា ហេតុម្តេចបានជាអ្នកដឹងការនេះ ។ តាំង-
ស៊ីនថា អ្នកឯទៀតមិនបានសង្កេតក៏មិនអាចដឹង តែខ្ញុំម្ចាស់ឯងបានដឹង
ប្រាកដ ។

ខ្ញុំពីបានស្តាប់តាំងស៊ីននិយាយថាឃើញការនោះប្រាកដ ក៏គិត
នឹងធ្វើយថាដំរេច តែថាស់ចូលក្នុងសេចក្តីវៀច ទើបធ្វើយតបថា គួនអ្ញិ


យើញមហាឧបាជធ្វើល្មើសទុដ្ឋសត្តិ នៅមុខព្រះកន្ត្រក ជានជាប្អូនខ្ញុំ
ទឹកចិដ្ឋបន្តិចទៅហើយ ។ តាំដសុំនភ្ញៀតីថាដូច្នោះ កំតិតដល់ព្រះ
ចៅហៀនតេជាម្ចាស់ផែនដីមានសេចក្តីឈឺចិត្តណាស់ ស្រក់ទឹកភ្នែកយំ
សោកថា ប្រសិនបើមន្ត្រីខ្ញុំពាជការតាំដឡាយ ជួយឈឺឆ្អាលស្រឡាញ់
ម្ចាស់ផែនដីដូចគួនអ្វីហើយ កាលណាឡើយព្រះចៅហៀនតេនឹដ្រួយ
លំបាកក្នុដព្រះទ័យដល់ម្ល៉េះ ។ ឡៅតីបានភ្ញៀដូច្នោះ កំនៅមិនទាន់
អស់សេចក្តីសង្ស័យ គិតថា ប្រហែលចូធ្លូក្លែដកលឧបាយឲ្យតាំដសុំន
មកល្បួដនិយាយទេដឹដ? ទើបក្លែដតោលថា សព្វថ្ងៃនេះចូធ្លូជាមហា-
ឧបាជ មានអំណាចសម្រែចពាជការជួយយកអាសាផែនដីណាស់ ហេតុ
ម្តេចបានជាអ្នកថាសព្វថ្ងៃព្រះចៅហៀនតេទ្រង់ព្រួយព្រះពាជហឫទ័យ ខ្ញុំ
មិនយើញដដែរសោះ ។ តាំដសុំនឮដណាស់គ្រាកឡើដវែស្រែកថា ខ្ញុន
អ្នកជាធំព្រះចៅហៀនតេទ្រង់ត្រាស់បាប់អានថាជាពូជព្រះពាជវង្ស ហេតុ
ម្តេចក៏អ្នកត្រឡប់ទៅលើកតំពស់អាមនុស្សទ្រុស្តក្បត់ផែនដីទៅវិញ ឬ
អ្នកនិយាយជាឧបាយបញ្ឆោតចិត្តយើដទេ ។

ឡៅតីយើញថា តាំដសុំនសំដែដសេចក្តីសត្យត្រង់នឹដព្រះចៅហៀន
តេច្បាកដ ទើបតបថា កាលដំបូដយើដនៅសង្ស័យ ក្រែដអ្នកដើរកេដ
កលឧបាយមកបញ្ឆោតយើដ ជានជាយើដបរាជូច្នោះ ។ តាំដសុំន
តំហូតយកឡាយព្រះហស្តហុចឲ្យឡៅតីមើល ។ ឡៅតីយើញជាក់ជា

ឡាយព្រះហស្តហើយ ក៏គិតខ្វាចចិត្តអាណិតព្រះថៅហៀនតេជាអនេក យំយែកស្រក់ទឹកភ្នែក ។ ក្នុងខណៈនោះ តាំងសុនក៏ហុចសំបុត្រសញ្ញាដែលគិតធ្វើការជាមួយនឹងឈ្មោះតាំង ៦ នាក់នោះ ឲ្យឡៅពីមើលខ្លឹត ។ ឡៅពីតបថា ដែលអ្នកវិះគិតកំចាត់ចូឆូនោះ យើងនឹងសុំចូលធ្វើការផង ។ តាំងសុនថា ប្រសិនបើជាអ្នកចូលគិតចំនុកបំរុងផែនដីជាមួយនឹងយើង ក៏ឲ្យចុះនាមលេខាសញ្ញាខ្លួនជាសំគាល់នឹងបានជួយគ្នាធ្វើការតទៅ ។ ឡៅពីក៏ចុះនាមលេខាក្នុងសញ្ញានោះទៀតរួមជា ៧ នាក់ប្រគល់ឲ្យទៅតាំងសុនហើយកំជាប់ថា ដែលនឹងធ្វើការគ្រានេះឲ្យអ្នកគិតត្រិះរិះឲ្យល្អ តែបែកខ្ចាត់ខ្ចាយទៅកាលណា ការក៏មិនសម្រេច ខ្លួនយើងទាំងអស់គ្នាក៏ប្លាន់ខ្លួនត្រូវយាងខ្លាំង ។ តាំងសុនទទួលពាក្យឡៅពីហើយក៏លាទៅផ្ទះ ។

(មានត)

មើលសៀវភៅប្រសើរជាងមើលរបាំ



មើលសៀវភៅ នាំឲ្យទៅ ជាអ្នកចេះ
ខ្ជូវចំណេះ តាំងផ្លូវលោក តាំងផ្លូវធម៌
នាំឲ្យចិត្ត ទំរេវត្តិ កម្មបវរ
មើលរបាំ នាំឲ្យក្រ វិនាសធន ។

យ. អ.

រឿងព្រេងប្រទេសឥណ្ឌៀ

អ្នកស្រី ស្រីធ-សារិយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យភ្នំពេញ

ប្រែពីភាសាបាលីមកជាភាសាខ្មែរ

(តមក)

ពួកឆ្មាំទ្វារគិតស្មានជាមនុស្សឆ្កួត ប៉ុន្តែនាំគ្នាជំនុំថា "បើនឹងនាំការណ៍នេះទៅទូលព្រះបាទកិមៈ ព្រះបាទនាលៈនឹងព្រះនាងទមយន្តីឲ្យជ្រាបផង ទើបជាការល្អ" រួចក៏នាំគ្នាទៅក្រាបទូលព្រះបាទកិមៈសព្វគ្រប់ប្រការ ។ ព្រះបាទកិមៈលុះបានជ្រាបដំណឹងអាក្រក់នោះទ្រង់ញញឹមបែបខ្ពើមចំអកមិនជឿថាជាអាទិទេពមែនវិទេនទេ ព្រោះទ្រង់យល់ដូចពួកឆ្មាំទ្វារដែរ ។ ឯព្រះបាទនាលៈនឹងព្រះនាងទមយន្តីគ្មានបានជ្រាបការណ៍នេះសោះ ។

លុះដល់ពេលស្តេចនឹងយាងត្រឡប់មកកាន់ប្រទេសនិវត្តវិញ ក៏យកទ្វារតនវត្តុគ្រប់បែបមកបង្ហាញព្រះអង្គ ព្រមទាំងថ្វាយទ្វារសាធុការពរជ័យមង្គលដល់ទ្រង់ ។ ទ្រង់យាងដោយក្បួនហែជាយ៉ាងធំឡាវិក ។

គេឃើញមនុស្សម្នាក់មុខមាត់អាក្រក់ដើរតាមក្រោយក្បួនហែ បុរសនោះសើចសូតបណ្តើរ ។

* * *

ព្រះបាទនាលៈទើបព្រះនាងទមយន្តី ទ្រង់យាងមកដល់ប្រទេសនិសធៈ ។ តាមផ្លូវដែលស្តេចយាងមក មានលំអដោយផ្កាម្រងបុប្ផាព្រះអង្គទ្រង់យាងលើផ្លូវកម្រងផ្កានោះ ។ នៅក្នុងព្រះរាជដំណាក់ពួកនាម៉ឺនសព្វមុខមន្ត្រីធំតូចចាំទទួលព្រះអង្គ, ពួករដ្ឋមន្ត្រីថ្វៃងសុន្ទរកថាមួយទទួលព្រះអង្គ ។ ទ្រង់បានធ្វើយតបទៅវិញដោយរីករាយ, ព្រះនាងទមយន្តីក៏ទ្រង់ញាញីមអរគុណទៅវិញដែរ ។ ពួកប្រជានុកស្តេរត់មកទទួលទ្រង់ឈប់ឆេ ។

ព្រះអង្គម្ចាស់ប៉ុស្ការៈ ទ្រង់ជ្រាបអំពីសេចក្តីសុខសប្បាយនៃព្រះរាមដែរ ប៉ុន្តែទ្រង់រីករាយទៅពុំកើត ពីព្រោះទ្រង់ចេះតែមានទុក្ខព្រះកន្ត្រួយជាធម្មតា ។ ទ្រង់ចេះតែគិតក្នុងព្រះទ័យជាយូរហើយថា: "ដល់ពេលដែលព្រះរាមអញត្រឡប់មកវិញ តួរអញទៅទទួលទ្រង់ឬតួរអញទៅពួនឲ្យបាត់?" ។ ក្រោយបង្អស់ទ្រង់ផ្តាច់គំនិតថាទើបត្រូវទៅទទួលព្រះអង្គដោយការគោរពតាមករណីយកិច្ចជាប្អូនគេ ប៉ុន្តែជាការចង់ជ្រាបនូវភាពភូតកិច្ចសព្វគ្រប់ទេ ដែលពាក្យទ្រង់ឲ្យទៅវិញនោះមិនមែនជាសេចក្តីស្នេហាសម្លាប់បងប្អូនឡើយ ។

ព្រះអង្គម្ចាស់ប៉ុស្ការៈ មិនបានដំអក់នៅក្នុងពិធីនោះយូរទេ ទ្រង់ក្រឡេកមើលព្រះនាងទមយន្តីដោយគ្នាន់ក្នាញ់ ហើយមានបន្ទូលសរសើរ

ព្រះបាទនាលៈនឹងព្រះនាងទមយន្តីដោយព្រះនេត្រាកំបុតៗ រួចខ្លែងត្រឡប់មកព្រៃជង្ហឹងវិញភ្លាម ។

នៅពេលដែលខ្លែងចាន់ភ្លាវព្រៃជង្ហឹងនឹងចូល ស្រាប់តែមានដៃមួយជាក់មកលើស្មាខ្លែងៗ ភ្ញាក់ត្រឡាច ហើយបែរព្រះកន្តែតនៅខាងក្រោយទាំងភ័យ ព្រះអង្គខ្លែងឃើញបុរសម្នាក់មានមុខអាក្រក់នៅពីខាងក្រោយខ្លែង ។ ខ្លែងមានបន្ទូលសួរថា: "អ្នកណាហ្នឹង? មានការណ៍អ្វី?" ។

បុរសនោះឆ្លើយថា: "ចូលទៅខាងក្នុងសិន" ។ ព្រះអង្គម្ចាស់ប៉ុស្ការៈតំយាងចូលទៅជាមួយនឹងបុរសចំឡែកនោះ លុះបន្តិចក្រាលណា បុរសនោះក៏ទូលខ្លែងថា: យើងចង់ឲ្យខ្លែងបានសេចក្តីសុខទេ ក៏បានជាយើងតាមខ្លែងមក, យើងស្គាល់ខ្លួនគំនិតរបស់ខ្លែង ខ្លែងនឹងអត់ទាំមិនទទួលខ្លួនជាគ្នាដ៏ប្រសើរបស់ខ្លួនម្តេចបាន, បើដូច្នេះបួរខ្លែងស្តាប់ដំបូន្មានយើង, មិនយូរប៉ុន្មានទេ បងខ្លែងនឹងធ្លាក់ទៅជាលំបាកគេកយ៉ាកជាខ្លាំងបំផុត ហើយខ្លែងនឹងបានទួរភាពសម្បត្តិដ៏ថ្លៃថ្លានេះ" ។

- ចុះឯងដែលមកពោលពាក្យសន្យាដ៏ប្រសើរយ៉ាងនេះតើឯងជាអ្វី? ។

- យើងជាអាទិទេព ។

- ជាអាទិទេពមែនឬ? ។

- ហ្នឹងហើយ ជាអាទិទេពដែលគេតែងតែស្អប់ខ្ពើម ប៉ុន្តែថាដូចម្តេចក៏ថាទៅចុះ! យើងមិនមែនអន់ថយអាត្មាភាពព្រោះតែពាក្យគេហោ-

និន្នាប៉ុណ្ណោះទេ, គេយកឈ្មោះយើងទៅសំអុយក្នុងការចុចរំតនៅពេលលេងល្បែងឡុកឡាក់ ។

- បើដូច្នេះ មានតែឯងឈ្មោះកាលី? ។

- ហ្នឹងហើយ យើងឈ្មោះកាលី, អ្នកលេងណាដែលយើងមានចិត្តគំនុំគុំគួន, អ្នកលេងនោះទឹងកើតអន្តរាយ ទឹងចេះតែអភ័ព្វ ហើយទឹងបង់អស់ទ្រព្យសម្បត្តិ ។

- ឯងគំនុំទឹងព្រះបាទនាលៈឬ? ។

- យើងបង់បានព្រះនាងទមយន្តីជាភរិយា ប៉ុន្តែនាលៈមកកាត់មុខយើងជាអាទិទេព; ឯព្រះឥន្ទ្រាធិរាជ ព្រះអគ្គី លោកលើកលោះឲ្យចំណែកយើង។ មិនមែនមានចិត្តសប្បុរសដូចលោកទេ យើងមិនចោះបង់ការសងសឹកចោលឡើយ ។

ព្រះអគ្គមាស់ប៉ុស្ការៈទ្រង់ព្រះសណ្តាប់នូវវាចៈរបស់អាទិទេពកាលីដោយប្រុងប្រយ័ត្ន ហើយមានបន្ទូលសួរថា: "តើឯងឲ្យយើងធ្វើដូចម្តេច?" ។

- ចូរទ្រង់បបួលព្រះបាទនាលៈឲ្យមកលេងល្បែងក្តាល់នឹងទ្រង់យើងនឹងនៅពីក្រោយព្រះបាទនាលៈ ហើយមានតែទ្រង់មួយទេដែលមើលយើងឃើញ, នៅពេលលេងគ្មានក្តាណាមួយដែលទ្រង់មិនឈ្នះទេ ។

ព្រះអគ្គមហាសប្បុរសក្សត្រ: ធ្វើយ៉ាងថា: "ឯងនាំឲ្យយើងចង់លេងមែន ចួនកាលព្រះពមយើងខ្លះមានព្រះទ័យចង់ក្រសាលដែរ" ។

អាទិទេពកាលីបង្គាប់ថា: "ចូរខ្លះទៅចាំស្ពាត់ផ្លូវស្តេច កាលណាខ្លះធុញទាន់ទឹងការពិភាក្សាអំពីរឿងផ្សេង ។ កុងព្រះពជអាណាព័ត៌ខ្លះទៅនិយាយយ៉ាងដូចម្តេច ឲ្យតែខ្លះសព្វព្រះទ័យនឹងលេងជាមួយខ្លះ ខ្លះនឹងបានសប្បាយជាមិនខាន" ។

ព្រះអគ្គមហាសប្បុរសក្សត្រ: ដាក់ព្រះនេត្រចុះសញ្ជឹងគិត ហើយក៏សួរទៅកាលីថា: "ចុះបើសិនជាខ្លះមិនព្រមលេង?" ។

ប៉ុន្តែកាលីកៀសខ្លួនចេញបាត់ទៅ ។

* * *

វគ្គទី ១៣

ព្រះបាទនាល: ខ្លះបំពេញព្រះពជកិច្ចក្នុងប្រទេស ខ្លះបើកការប្រជុំពលថ្មៃ ជាមួយនឹងទីប្រឹក្សា, លុះបានសំរេចការដែលមានសន្និភាពហើយ ខ្លះទៅរកព្រះនាងទមយន្តីភ្លាម ពេលដែលខ្លះគង់នៅជិតព្រះនាងជាពេលដ៏ប្រសើរបស់ខ្លះ ។

ទោះព្រះអគ្គចង់ក្រសាលក៏ខ្លះមិនដែលនឹកឃើញល្បែងឡុកឡាក់ដែរ ។ ព្រះអគ្គមហាសប្បុរសក្សត្រ: នៅតែគិតមមៃដល់ពាក្យអាទិទេពកាលីដែលថានឹងបានជាស្តេចសោយរាជ្យ ទើបខ្លះព្រះបន្ទូលថា "បើ

អញនឹងបានជាស្តេចសោយរាជ្យ ដោយឆ្នាំនឿយព្រួយ ព្រោះតែឈ្នះល្បែងឡុកឡាក់ប៉ុណ្ណោះ! ចុះហេតុអ្វីក៏អញចេះតែមិនជាប់ស្រេចទៀត", គិតដូច្នោះហើយទ្រង់ក៏គិតឧបាយនាំព្រះរាមឲ្យចុះក្នុងល្បែង ។

ព្រះបាទនាលៈទ្រង់យាងចេញពីទីប្រជុំ ។ ព្រះអង្គម្ចាស់ប៉ុស្ការៈក៏ទ្រង់យាងពីវេជ្ជដំហានទៅជិតស្តេច ទ្រង់ធ្វើជាញញឹមរកព្រះរាមហើយមានបន្ទូលថា: "ព្រះរាមមានរឹកមាំចំណាស់ ឥឡូវនេះ ព្រះអង្គលែងសព្វព្រះហឫទ័យនឹងល្បែងទៀតហើយឬ?" ។

ព្រះបាទនាលៈមានបន្ទូលតបដោយទឹកព្រួលវិញថា: "ល្បែង!" ហើយមានបន្ទូលតទៅទៀតដោយរីករាយថា "មែនហើយ កាលពីមុនមានពេលខ្លះ បងចូលចិត្តលេងល្បែង ហើយប៉ុស្ការៈឯងមិនចូលចិត្តលេងផងទេ បើសិនជាឯងចូលចិត្តលេង។ ទៅ ប៉ុន្តែចូរឯងរកអ្នកណាឯទៀតក្រៅពីបង, ចុះឲ្យបងឈប់ទៅលេងម្តេចបាន បើបងមើលឃើញព្រះនាងទមយន្តីចាំបងនៅក្នុងខ្យានឯនោះ" ថាហើយស្តេចយាងហួសទៅ ។

ព្រះអង្គម្ចាស់ប៉ុស្ការៈត្រឡប់ចូលដំណាក់វិញដោយអៀនអន់ ។ ក្នុងពេលនោះ ទ្រង់ឃើញកាលីនៅក្នុងមហាប្រាសាទ ទ្រង់មានបន្ទូលថា: "ឯងមកទៀតហើយ! ប្រហែលជាឯងដឹងថាព្រះបាទនាលៈមិនព្រមលេងនឹងយើងឬ?" ។

- កុំអាលព្រួយ, ចូរខ្ញុំលុះក្នុងគំនិតខ្ញុំឲ្យមែនទែន បើព្រះបាទនាលមិនព្រមនៅពេលនេះ ពេលស្អែកខ្ញុំនឹងព្រមតាម, ចាំពីរបីថ្ងៃទៀត ខ្ញុំនឹងទៅចូលព្រះបាទនាល: ហើយបបួលឲ្យលេងទៀត ចូរខ្ញុំកុំភ្លេចថាខ្ញុំមានបង្អែកយ៉ាងចំណាន" ។

ប៉ុន្តែ ព្រះអង្គម្ចាស់ប៊ុស្ការ: ទំនូចទំនែយ៉ាងណា ព្រះបាទនាល: ក៏នៅតែប្រកែកថា: "កុំបញ្ឈប់បង់ធ្វើអ្វី បង់នឹងទៅកន្លែងណាដែលបង់ឃើញនាងមុនយូរ, ចុះឲ្យបង់លេងធ្វើអ្វី តែបង់លេង បង់ខ្ជាតពេលនឹងបានឃើញព្រះនាងញាញឹម" ។

* *

វគ្គ ទី ១៤

លុះអំឡុងយូរទៅ ព្រះបាទនាល:នឹងព្រះនាងមុនយូរមានព្រះពជ-បុត្រាមួយព្រះអង្គនឹងព្រះពជបុត្រីមួយព្រះអង្គ ។ នៅពេលសម្រាក ព្រះបាទនាល: មិនត្រឹមតែមុនយូរព្រះឯកអគ្គមហេសីជាទីស្នេហាប៉ុណ្ណោះទេ, ថែមទាំងខ្ញុំមុនព្រះពជបុត្រទាំងពីរព្រះអង្គ ដែលខ្ញុំតែងតែទាំលេងល្បែងនានាតាមរបៀបក្មេងចូលចិត្តផង ។ ខ្ញុំបង្កើតល្បែងផ្សេងៗជាច្រើន ដែលមិនដូចនឹងល្បែងឡុកឡាក់បន្តិចសោះ ។

ព្រះអង្គម្ចាស់ប៊ុស្ការ: មុនដំបូងខ្ញុំមានសង្ឃឹមថានឹងសម្រេចបំណងតែឥឡូវនេះខ្ញុំបែរទៅជាអស់សង្ឃឹមវិញ ។ កាលីទំតែលើកទឹកព្រះទ័យព្រះអង្គម្ចាស់ប៊ុស្ការ: តែមិនបានសម្រេចដូចបំណង ។ (មានត)

ដំណើរអស្ចារ្យនៃលោកភ័ស្តុវ៉ាយ្យូយេ

លោកហ្គូតូស៊ី រៀបរៀង

លោក រ៉ាយ-ប៊ិក ក្រែមការ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តទៅ)

ទាស៊ីនោះដាំស្រែកូតកវាកុហកសោះ ព្រោះអ្នកជិតខាងខ្លាចរងាត្រជាក់, បានប្រើឲ្យគាស៊ីនេះទៅកុហកដូចនេះ; គឺនាងមកបង្គំឲ្យអ្នកម្ចាស់ផ្ទះរំលែតឲ្យប៉ូលទៅកន្លែងគេហដ្ឋានវិញ ហើយអ្នកនេះបានពោលថា ជាដោតវាសនាអាត្រែក ចាន់ជាមានគេមកបង្គំមិនឲ្យមើលទស្សនីយភាពដ៏ប្រសើរដូចនេះ ។ តែអ្នកស្រីជាម្ចាស់ផ្ទះដែលបានឮវចីយានៃអ្នកជិតខាងអញ្ជើញមកដល់ទីនោះដាំលំដាប់ ហើយពោលថា: "គេទើបនឹងយកឮវិស៊ីវ៉ែតគឺនំបង្អប់សាច់ត្រសារ ហើយមានតែលញ់មេរ៉ាធ្វើនំផ្សេង ។, សូមអ្នកអញ្ជើញពីសាតែជាមួយនឹងយើង" ។ ហើយអ្នកជិតខាង (សមន្តជន) បានសូមអភ័យទោសអ្នកស្រីហើយថ្លែងដំណឹងអ្នកស្រីថា: "ខ្ញុំបានឮលានឮវសំឡ (ស៊ីប) សាច់ក្វែកហើយមិនសូវមានឧជារសផង អ្នកស្រីបានឆ្លើយតបហើយថា មាន

គេឲ្យខ្ញុំទៅ ដ្បិតមានការប្រញាប់ ខ្ញុំសូមថ្លែងនូវសេចក្តីស្តាយពន់ពេក ចំពោះអ្នកស្រី, សូមទោសអ្នកស្រី" ។

នេះគឺចំនៀមទម្ងាប់ប្រពៃណីនៃប្រទេសនេះ ចំពោះបងប្រុសនឹងកល្យាណមិត្ត ក៏ត្រូវតែអួតអាងដោយវាចាគ្រប់ៗគ្នា ។ ពួកនេះ សុទ្ធតែពួកឧត្តរិជន (hypocrètes) តាលតែពាក្យកុហក ។ លោកវ៉ាសូប៊ី-យូយេ កំពុញគ្រាន់នូវកិច្ចការគាំងប៉ុន្មានដែលលោកបានឃើញ - ឮនៅប្រទេសនេះ ហើយក៏ដិះត្រសារហោះចេញតម្រង់ទៅកាន់ប្រទេសមួយផ្សេងទៀត ។

គតិអ្នកឆ្លាត

កន្លងពេលដែលយើងរស់នៅដោយសន្តិភាព តែងដែលយើងរលាត់ជួបជាដង្វែកសម្រាប់រែកចំនិញ ក្មេងឆ្លាត់បន្តិចជាអន្តរកាសមួយ ធ្វើឲ្យយើងស្ងៀតនៅក្នុងគ្រឹហ, ហើយក៏ប្រើពេលវេលានោះសម្រាប់លេងកំសាន្តខាងល្បែងផ្សេងៗ ទឹងក្មេងមហោស្រពតូរ្យដន្ត្រី ។ មនុស្សពាំងអស់ធ្វើខ្លួនឲ្យវិនាសដោយការសេពនូវសុក- បរិភោគអាហារច្រើនហើយនឹងកាត់ខោអាវដ៏មានដំឡៃ ហើយមានការខ្វះខាតជានិរន្តរ៍តែងកិច្ចចំណាយនូវថវិកាខាងគ្រួសារ ។ អ្នកពាំងអស់នោះ មិនត្រមយល់ថាការចំណាយមិនគ្រប់គ្រាន់មកពីខ្លួនប្រព្រឹត្តអកុសលកិច្ច: ទៅជាបន្ទោសពេលា, ជាក់កំហុសទៅដល់ជនដទៃ ហើយចោទប្រកាន់ពិភពលោកថាបង្កើត

ឧបសគ្គរាំងវាមិនឲ្យសម្រេចនូវប្រយោជន៍បាន ។ រត្តុបំណងដ៏សំខាន់
គឺការសប្បាយចិត្តនឹងសេចក្តីថ្នាចង់ធំចង់ខ្ពស់ប្រសើរ ដែលនាំឲ្យ
ខ្លួនព្យាយាមបំពេញវប្បកម្មខាងការបុនប្រសប់កុងសង្គម ពុកជាអាសាន
នៃបំណងកុងដីវិភាព ។ អ្នកចាំងនោះក្លេចនូវលក្ខណសម្បត្តិចំពោះ
ខ្លួនហើយទៅប្រព្រឹត្តដំកើងខ្លួនជាអកជន ឬជាសេដ្ឋី ។ អ្នកចាំង
អស់ធ្លើដូចនេះ បើតាមចរិយាគ្រាថាធ្លើដោយមិត្តភាព, ទម្រង់នៃ
ពាធីបុណ្យ ឬការណីយកិច្ច; តែបើតាមពិត គឺមានបំណងចង់ឲ្យអាប់ភ្លឺ
ឈ្មោះនៃមិត្តចាំងឡាយ ហើយនឹងតាំងខ្លួនជាអ្នកមានទ្រព្យសម្បត្តិ ឬជា
អ្នកចេះជាងគេចាំងអស់ ។ ពួកចាំងនោះ ដូចជាមនុស្សខ្វាយច្រាថ្នា
ចង់លើកថ្ងាវអង្គុរ; មុខគួរឲ្យស្តាយពន់ពេកថាយើងធ្លើខ្លួនយើងឲ្យមាន
ទុក្ខលំបាកមកពីមាន:, ពិតមែនតែយើងមិនបានធ្លើវត្តុអ្វីជាច្រើន តែយើង
គង់ជាកូនបំណុលចំពោះអ្នកចាំងអស់ ។ មានមនុស្សជាច្រើន មានគុណ-
សម្បត្តិល្អកងខ្លួន តែធ្លើគុណសម្បត្តិនោះឲ្យខូចវិនាសៈវិញ ។ អ្នកគ្រ
មិនត្រូវខ្មាសអៀនទេ បើអ្នកគ្រនោះមានអង្គុរគ្រប់គ្រាន់ចរិភាគ, មាន
សំលៀកបំពាក់ល្អមសមរម្យ, ត្រូវតែអ្នកគ្រនោះសប្បាយចិត្តវិញ ។
មនុស្សពិតនោះ តែងបង្ហាញកងហទយត្រូវរបស់ខ្លួនឲ្យពិភពលោកយើញ
ហើយគ្មានខ្លាចអ្វីឡើយ ។

*
* *

៤ — ធ្វើដំណើរទៅកាន់បុរាណនិយមប្រទេស

(Pays duculte de l'Autiquité)

មនុស្សដែលភ្ជាប់តែស្ថិតនៅក្នុងភូមិស្រុក ច្រើនអាណិតអាសូរដល់អ្នកដំណើរដែលទៅមកអស់កម្លាំងដោយផ្លូវឆ្ងាយ, តែលោក ប៉ាសូប៉ីយូយេ កាលដែលលោកបានអញ្ជើញទៅកាន់អមតប្រទេស ទៅជាមានកម្លាំងពេញលេញ ដូចពួកយ៉ូវនយល់ថាពិតពលោកទាំងមូលជាគេហដ្ឋានរបស់លោក ហើយសត្វក្រសារនោះក៏មានមនោសញ្ចេតនាដូចលោកដែរ, ឋានជាអ្នកទាំងពីរហោះទៅលើនភាល័យ, កប់ពពក, ត្រែបវេជាតិនៃមេឃស្រអាប ហើយស្មានថាដុំពពកកជាគ្រាប់អង្ករ ។

លោក ប៉ាសូប៉ីយូយេ បានឃើញប្រទេសមួយដែលលោកស្មានថាជាទីសប្បាយ លោកក៏ចុះនៅទីនោះ ។ ចំណែកខាងក្រសារកំពុងរលាស់ស្លាប ហើយលោក ប៉ាសូប៉ីយូយេ កំពុងពត់អវយវៈ, ស្រាប់តែមានបុគ្គលជាច្រើនចូលមកចោមរោមលោក ដូចជាសៀវភៅដែលគេបើកសន្ធឹកមួយ។ មានរូបគំនូរមនុស្សជាច្រើនចេញមកព័ទ្ធពេញដូចកោះ។ ពួកជនទាំងអស់នោះក៏ផ្ញើរឹងសោតបសាទស្តាប់ ដោយយកចិត្តទុកដាក់ពេញលេញអំពីសេចក្តីពណ៌នានូវដំណើរទៅប្រទេសផ្សេង ។ នៃវីរបុរសនេះ, បានចាត់ឱ្យរកគេហដ្ឋានមួយស្អាតល្អសមរម្យសម្រាប់ឱ្យលោកពឹងពាក់អាស្រ័យ ហើយដំពហលោកថាប្រទេសនេះនាមថា: "បុរាណនិយមប្រទេស" ។

លោក ក៉ាសូប៊ីយូយេ លោកបានពិនិត្យឃើញដោយពេញចិត្តថា ពួកទាំងនេះពោលអ្វីទៅតាមធម្មតា មិនមានអួតអាងអ្វីឡើយ, ពួកក្បែតែរធ្វើស្រែចម្ការ, ពួកជាងឈើធ្វើគ្រឿងហ, ពួកពាណិជ្ជលក់ដូរទំនិញដូចពីបុរាណកាល, ហើយគេហង្ហានទឹងគ្រឿងស្លៀកពាក់សុទ្ធតែជារបស់ចាស់ ។ ហើយដែលមានមកជាយូរកាល, ខ្លះពេញចិត្តចំពោះការប្រព្រឹត្តបែបនេះ, ខ្លះមិនចូលចិត្ត ។ មនុស្សល្អត្រូវប្រព្រឹត្តកិរិយារបស់ខ្លួន ដោយយកកិរិយាចិនពីបុរាណកាលជាទិដ្ឋានុគតិ ។ ពួកទាំងនេះស្រឡាញ់តុចាស់ ហើយពួកមនុស្សជំទង់នឹងប្រជុំគ្នាចំពោះតែការបុច្ឆាវិសជ្ជនាខាងទស្សនវិជ្ជាបុរាណ ។ ពួកអ្នកនិយមតាម (សាវ័ក) លោក កុង ហ្វូ-សឺ នឹងលោក មេង-សឺ មានខ្លះដែរ តែសាលារៀនមានច្រើនជាអនេកប្បការ ដល់គេកប់ចំនួនទាំងអស់មិនបាន, ហើយការថែទាំរុក្ខជាតិដូចជាគ្រិសង់ថែម (Chrysanthèm) ឬរបៀបដាំឫស្សីតែងយកក្បួនបុរាណជាទីតាំង ។

ពីរបីថ្ងៃក្រោយមកលោក ក៉ាសូប៊ីយូយេមកដល់, អ្នកបុរាណនិយមដែលនៅជិតលោក បានអញ្ជើញលោកទៅសន្ទិដ្ឋាត ។ ដល់លោកអញ្ជើញទៅដល់បានចូលមកក្នុងជ្រុងហ៊ុនដ្ឋាន, លោកបានពិនិត្យមើលកន្លែងនោះសុទ្ធតែរចនាក្បាច់សិល្បៈដែលមានតំនូរពណ៌ (ពាក្យជប៉ុនហៅថា កាកឹមូណូ (Kakemono) ដែលគេព្យួរនឹងជញ្ជាំង, នៅជើងជញ្ជាំង

នោះមានផ្ការីកបួកជុះនៅក្នុងដើង ។ បន្ទប់តពីនោះមក មានកូតូ (Koto) មួយនឹងស្គរ (Sho) មួយដែលវាយចាំអ្នកភ្ញៀវលេង ។ អ្នកម្ចាស់ផ្ទះទទួលភ្ញៀវពាក់អាវវែងគីមូណូ (Kimono) ពីបុរាណ ។ ភ្ញៀវដែលចូលមកដំបូងនៅក្នុងទីនោះជាសាវ័កលោក កុងហ្វូស៊ី, បន្ទាប់ទៀតមានពួកសាវ័កខាងមេង · សិប្ចូនប្ចុះនាក់ ហើយពួកចាស់អស់នោះ បានសំដែងនូវគារវភាពចំពោះអ្នកម្ចាស់ផ្ទះ ហើយក៏នាំគ្នាឈ្ងោះអំពីរឿងថាស្រាជាបុព្វហេតុនៃសេចក្តីអាក្រក់ក្នុងលោក, រួចអ្នកចាស់អស់គ្នាក៏បរិភោគស្រានោះទៅ ។

ដល់អ្នកចាស់អស់សន្ធូនាការទៅវិញ-មក ដោយបណ្ឌិតពត្រមចាស់សេចក្តីគួរសម ស្រាប់តែមានពួកគណៈខាងសាលាសូស្ហី (១) មកដល់ ។ អ្នកនោះចូលទៅអង្គុយ, ច្រៀងបទពីកេះ, ទឹងថ្ងៃនូវរឿងព័ដែលគួរឲ្យស្តាប់ តែងធ្វើឲ្យអ្នកស្តាប់អាក់អន់ស្រពន់ចិត្ត ។ អ្នកម្ចាស់គេហដ្ឋាន, ដើម្បីកុំឲ្យឆ្គែមកបៀតបៀន បានគិតឲ្យគេលេងភ្លេង, លោកបានប្រកាសជាសាវ័កតូបូសកុ (២) (Tobosaku ហើយបានជូនស្រាមួយពែងគ្រប់ៗគ្នា ទាល់តែភ្ញៀវចាស់អស់ក្រែកឡើងច្រៀងរាំ ដើងមិនសូវនឹង, រៀវលែងតែពួកសាវ័កលោក កុងហ្វូ-ស៊ី នឹងមិង-ស៊ី ។ ពួកទស្សនវិទូជាបណ្ឌិត (lettrés) ធ្វើចិត្តនឹងនួនហើយពោលថា: "លោកគ្រូយើងមាន

---

១ Ecteteur de l Ecole de sashi ពួកគណៈខាងលទ្ធិលោកសូស្ហីគឺសន្តបុគ្គលពេញចិត្តខាងភ្លេង ។ ២ តូបូសកុ ទីប្រឹក្សានៃព្រះអធិរាជចិនក្នុងសតវត្សរ៍ហ៊ាន ។

វិចារណញ្ញាណត្រូវត្រង់ការពោលថា កេរ្តិ៍សាម័ញ្ញនឹងត្រឿង ពួកបណ្ឌិតត្រូវលះបង់ឲ្យផុះស្រឡះពីសន្ដានចេញ" ។ អ្នកម្ចាស់ផ្ទះឆ្លើយតបវិញថា: "តើបានប្រយោជន៍អ្វីត្រង់ការតាំងខ្លួនជាបណ្ឌិត ជីវភាពរបស់មនុស្សមិនដែលមានផ្កាម្ពដ៏ទៀតឡើយ" ហើយអ្នកម្ចាស់ផ្ទះនោះក៏ច្រៀងតទៅទៀត ហើយថែមទាំងបរិកោគនូវសុភ ។ ពួកបណ្ឌិតទៅជាមានចិត្តមិនធឹងខ្លួនដូចប្រក្រតី. តែឲ្យចំទៅជាក្ងេចតុង់ទនៃលោក កុងហ្វូ-ស៊ីនឹងមិន-ស៊ី ហើយមានសារក៏ម្នាក់ស្រែកឡើងថា: "គេបាននិពន្ធមកថាត្រូវតែពិសោធន៍នូវរឿង៣វិសព្ទគ្រប់ចំពូកក្នុងពិភពលោក ហើយជ្រើសរើសនូវអ្វីដែលវិសេសជាងគេ" ។ ពួកសហជីវិននៃសារក៏នោះក៏បានឲ្យពរសព្ទសាធុការ ហើយប្រុងរៀបនឹងធ្វើតស៊ូច្រៀង, រាំ តាមបំណង, ហើយពោលពាក្យដូចនេះថា: "ត្រូវតែមនុស្សណាជាបណ្ឌិតធ្វើតស៊ូតំពាំងបាយជូរ ដើម្បីរចនាខ្លួនឲ្យទៅជាបណ្ឌិតកាន់តែប្រសើរឡើង" ហើយពួកនោះក៏នាំគ្នាសប្បាយអស់យូរកាល រួចត្រឡប់ទៅគេហដ្ឋានវិញជិតភ្លឺ ។

សារក៏នៃពួកមហាបណ្ឌិតប្រទេសចិនតែងមានឈ្មោះល្បីល្បាញនាពិភពលោក ។ តែមិនយូរប៉ុន្មាន, ពួកនេះទៅជាមានចំនួនតិច, ចំណែកខាងពួក យេន-សេន-ដូ Yen-g-n do) ជាទស្សនវិទូលេងល្បែងត្រូវបានហើយនឹងពួកខាង ចូសាន-ស៊ី (Chosan-Sei) ជាទស្សនវិទូសេតសុភនឹងមើរយកាន់តែច្រើនចំនួនជាលំដាប់ពាល់ពិភពត្រី ។ អ្នកបុរាណនិយមកាន់តែ

មានចិត្តសប្បាយពន់ពេក ដោយការជាគដ៏ធំរបស់លោកទៅលើពួកបណ្ឌិត (lettrés) ទាំងនោះ ហើយលោកក៏ខំព្យាយាមសូត្រវៀនទ្រឹស្តីវិជ្ជានៃគណៈសាសនាឯទៀត, ដូចជាគណៈ រិហកុ (Rihaku) អ្នកកវីស្រែរឹងស្រា ។ លោកប្រឹងព្យាយាមចំណាយច្រើនក្នុងរឿងនេះពាល់តែធ្ងាក់ក្រ, កោតទ្រព្យទាំងប៉ុន្មានរសាត់បាត់ដូចមេឃបុះអ័ព្ទ ហើយគេលែងឃើញផ្សែងចេញពីគេហដ្ឋានរបស់លោក ។ លោកក៏ជួលខ្លួនគេមួយនៅហើយបរិភោគតែនំបុ័ងដែលធ្វើពីចុងអង្ករ, តែលោកបរិភោគស្រាទំពាំងបាយជូរ ហើយច្រៀងសរសើរពីខ្លួនលោក ។ ពោលថា: "ពួកសេដ្ឋីគ្មានបណ្ឌិត ។ បើអ្នកឯងមិនស្គាល់ក្រ, អ្នកឯងមិនយល់ទ្រឹស្តាភរបស់បណ្ឌិតឡើយ ។ ហានៈទឹងដោគវាសនារបស់មនុស្សមិនស្មើតស្មេរប្រៀបដូចពីពេកដូចនោះ ។ ក្នុងពេលនេះខ្ញុំកំពុងរស់នៅពិតជ្រាកដ" ។ ហើយលោករៀនសូត្រដោយរស្មីសតូអំពិលអំពែក, បរិភោគស្រាទំពាំងបាយជូរនៅកន្លែកម្ម, ហើយបើកាលណាលោកអផ្សុកលោកពាក់មួកមួយទឹងអាវវែងធ្វើពីចំបើងហើយកាន់ចបដំរះមួយ, លោកព្យាយាមជកទំពាំងឫស្សីពីដី ដែលមានទឹកកកនៅពាសពេញ, ប្តូរយំបែកទឹកកកនៅកន្លែងដើម្បីនឹងចាប់ត្រី, ធ្វើយ៉ាងដូចនេះ គឺដើម្បីឲ្យមាតារបស់លោកពិសាបាយមួយចំណីឲ្យឆ្ងាញ់(១) ។ តែលោកមិនបានប្រយោជន៍អ្វី បែរឃើញតែកើតពេគផ្តាសាយទៅវិញ ។ កិរិយារបស់

---

១ ។ ការណ៍ប្រៀបធៀបទៅខាងកតញ្ញូចំពោះមាតាបិតា, ជាប្រពៃណីមួយប្លែក ។

លោកដែលយល់ថាស្វាមីធ្លើអំពើបែបនេះជាសភាពធ្លុត បានយំទួញជាស់តឿនលោកកុំឲ្យប្រព្រឹត្តយ៉ាងនេះតទៅទៀត ហើយឲ្យវិលមកវាសុកនិច្ច័យតាមធម្មតាទៅវិញ, តែលោកតបទៅកវិយាវិញថា:

"ធម្មតាមនុស្សជាបណ្ឌិត មិនត្រូវស្តាប់ដំបូន្មាននៃកវិយាឡើយបើគ្មានចិត្តខន្តីនឹងថាមកាត គេមិនអាចសម្រេចនូវគតិបណ្ឌិតបានឡើយ" ។

បើមាតាលោកស្តីបន្ទោសអ្វីលោកតបទៅវិញថា "មាតានេះ មានគំនិតថោកទាប ហើយមិនអាចប្រព្រឹត្តតាមបាន ដូចជាមាតានៃបុត្រជាបណ្ឌិត" ។ ព្រោះហេតុដូចនេះ បានជាមាតានឹងបុត្រតែងឈ្លោះទាស់ទែងគ្នាជាលំតែមាតានោះដកហូតយកកេរ្តិ៍មត៌កជាអវសាន ។ (មានត)

រៀនបែះខ្វិលល្ងង់

ជាតិកូនប្រុស ត្រូវឲ្យលុះ ផ្លូវសិក្សា
រៀនលុះត្រា ចាស់ជរា ជីវិតមរណ៍
រៀននេះចេះ ត្រូវកុំធ្វេស រៀននោះត
កាលបើមរណ៍ កេរ្តិ៍តង់មាន មិនបាត់បង់ ។
ជាតិកូនស្រី កុងលោកិយ ក៏ដូចគ្នា
មិនត្រូវភ ផ្លូវវិជ្ជា ដោយថ្នមអង្គ
វិជ្ជាអ្វី ខោះបីស្រី ក៏ត្រូវផ្តង់
រៀនចុះគង់ កើតសួស្តី មិនអាក់ខាន ។

យ. អ.

ដំណឹងតាមទូរស័ព្ទក្នុងកន្លែង:

លោក ផេង-ជ្រើរ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាចាវ៉ាំងមកជាភាសាខ្មែរ

(តមក)

អ៊ីស្មាអ៊ីលឱងមុខឡើងស្លេក ប៉ុន្តែគេចេះទប់ចិត្តបាន គេមិនចង់ឈ្លោះតទឹងស្មើម ព្រោះការដំលោះទៀងតែធ្វើឲ្យនុពុកគេដែលចាស់ជរានឹងមានសេចក្តីព្រួយ ម្ល៉ោះហើយគេទំអត់សង្កត់កំហឹងដែលលុកលុយក្នុងខ្លួនសន្ធាន គេគំនាប់ពួកក្មេង រួចទុនគំនាប់នុពុក ហើយងាកទៅនុបប្អូនឈ្លោះមុត្តា ទើបដើរចេញទៅ ។

ប្រហែលមួយស្របក់មក គេឮសូរជើងសេះដើរលើឥដ្ឋក្រាលក្នុងទីធ្លា ហើយបន្តិចមកទៀត ស្រាប់តែឮសូរសេះជាយចេញបាត់ទៅ ... ។

ខណៈនោះ លោកតាចេគ្រី-ដែរណា ក៏ដូចលោកអៃយ៉ាដដែរ គឺជាចាស់ព្រឹទ្ធាចារ្យ ជាទីគោរពជាងគេក្នុងស្រុក ចាប់ផ្តើមក្រោកបន្តិចៗឡើង ហើយអ្នកឯទៀតក៏ធ្វើតាមចាំងអស់ ។

លោកដើរតម្រង់អាសនៈពួកដែលលោកអៃយ៉ាដអង្គុយ ហើយចាប់នុបកាអីតដោយដៃចាំងពីរ ប្រដល់ថ្ពាល់គ្នាអស់រាងពីរបីនាទី ជាសញ្ញានៃមេត្រីចិត្តនឹងសេចក្តីទុក្ខព្រួយ ។ លោកមានប្រសាសន៍ថា:

- អៃយ៉ាជ! កូនប្អូនឯង អស់សង្ឃឹមនឹងនៅជាមួយយើងហើយ! ត្រូវប្រយ័ត្នខ្លាចត្រែងព្រះអង្គស្រមិនពេញចិត្ត! គំនិតថ្មីនឹងតាមពាគនៃប្រទេសអ៊ីរ៉ុបរំលួយអ៊ីស្មាអ៊ីលហើយ ។ កន្លងមកយើងតំពង់តាំងនៅត្រកាមអំណាចនៃទុអាវ្យធមិនេះ ចំណែកគេទៅជាហ៊ានអះអាងជួយការពារថាជាអាវ្យធមិល្អវិញ ដែលជាធម្មិធ្វើឲ្យយើងពាល់គ្នាស្ទើរនឹងរលួយប្រមាត់ថ្លើម តុមោយបុរស! ។

លោកអៃយ៉ាជ អីក៏មិនថា គ្រាន់តែថ្ងូរ ។

សំដីរបស់មិត្តចាស់ប៉ុណ្ណោះ ហាក់ដូចគេយកឈើស្រួចមកវាតមុខរបួសរបស់លោកអៃយ៉ាជឲ្យរីនឹងតែរីកធំឡើង ។ លោកធ្វើសញ្ញាចំពោះកូនបន្ទាប់របស់លោកដែលមានទឹកមុខប្រកបដោយបញ្ញា ហើយទៅជួតឈូត ឲ្យចូលមកជិត ដ្បិតមុខគាត់មានចិត្តស្មោះត្រង់មិនលះបង់សំលៀកចំពាក់ដែលជាកេរ្តិ៍ដំណែលពីជូនតាមក នឹងគំនិតរបស់ជាតិ ។

លោកតាចេគ្រី-ដែរណា សំឡឹងចំពោះប្អូន នៃអ៊ីស្មាអ៊ីល ដោយទឹកមុខមានសេចក្តីស្នេហា ហើយនិយាយថា:

- អៃយ៉ាជ កុំព្រួយអី! មុខាជាកូនដ៏ចរិស្ទុរបស់ឯងហើយ ។ គេមុខជាមិនធ្វើឲ្យឯងព្រួយទេ ។

លោកអៃយ៉ាជតបកូនបន្ទាប់នៅដើមទ្រូង ព្រោះឥឡូវលោកសង្ឃឹមតែលើរូបគេមួយ ។

ពួកក្មេងនុនគំនាប់ម្ចាស់ផ្ទះម្នាក់ម្តង ។ ហើយនាំគ្នាចុះចេញទៅដោយការស្ងៀមស្ងាត់ ។ មិនយូរប៉ុន្មានលោកអៃយ៉ាជនឆ័ត្តាទៅស្ងាត់តែពីរនាក់ក្នុងបន្ទប់ ។

វេលានោះ អ្នកកំណែ្ចះនុនថើបដៃលោកឪពុកដោយគារវភាពយ៉ាងខ្ជាំង លុះងើបឡើង គេឃើញទឹកភ្នែកហៀរហូរពេញតែភ្នែកលោកឪពុកជាទីស្នេហា ។

* * *

នៅឯក្រៅ ពួកក្មេងនាំគ្នាថយទៅទីលំនៅរៀងខ្លួនតាមពួកដោយស្ងៀមស្ងាត់គ្រប់គ្នា គឺសេចក្តីទុក្ខឥតឧបមាគ្របសង្កត់ បណ្តាលមកពីអធិករណ៍ដែលទើបនឹងកើតមានឡើង ព្រោះអ្នកទាំងអស់ពេញចិត្តចំពោះបញ្ញាកំឡាំងកាយនឹងធម៌សប្បុរសរបស់អ៊ីស្មាអ៊ីល ហើយឥឡូវអ៊ីស្មាអ៊ីល មិនបានរាប់បញ្ចូលក្នុងចំណោមអារ៉ាប់ឡើយ គឺជាសេចក្តីវិនាសមួយយ៉ាងធំ ។ អ្នកទាំងនេះព្រួយខ្ជាំងដោយមានសេចក្តីស្នេហាចំពោះអ៊ីស្មាអ៊ីលគ្រប់រូប . . . បណ្តាជនទាំងប៉ុន្មាន មានតែរស្រីមម្នាក់ឯងទេដែលថយទៅផ្ទះវិញ គ្រប់ដោយសេចក្តីក្រេវក្រាយ ។

ជាឯទ្បីទ្បា

ព្រះភាយដែលបក់មកវិញ ៗ បែបត្រជាក់លើទីវាលឲ្យដំណឹងថាពេលព្រលប់នឹងយប់ជិតមកដល់ហើយ ។ ស្ងឹកស្ងាត់ស្ងឹកស្ងាត់ថ្ងៃចាំង

ត្រូវខ្យល់ ធ្វើឲ្យឃើញព័ណ៌ក្រហមដូចស្ពាន់ លេចក្តែតចុះក្តែតឡើង ចំណែកស្មឹកចេកត្រូវចំណាំងថ្ងៃភ្លឺផ្លេកៗ ដូចកញ្ចក់ ។

នៅលើចង្កេះភ្នំដែលជាទីសំណាក់អាស្រ័យ នៃគណៈលោកតាម៉ាត្រកអែលគាឌី ដើមអាកាស្យាផ្អាចផ្អោមៗ ព័ណ៌លឿងផ្សាយគន្ធពិដោរគាំងព័ត្រលឹមមក ។ ចំណែកផ្កាម៉ម៉ូស្ហាស់ លាតត្រដាងទទួលខ្យល់មកពីទិសទក្សិណ ។ កន្លងទឹកជ្រោះទឹកត្រជាំង ផ្កាព្រលឹតផ្កាឈូកត្រដាងសរីកក្រចាឆ្ងៗ ចាំទទួលតន្ទឹព្រះអាទិត្យនាវេលាល្ងាច ។ យូរៗគេឮអនដ្ឋិកសត្វយំ សត្វត្រកួតថ្ងូរ ទន្ឋឹងស្មៅស្រែក ។

សត្វអូដ្ឋដេកទំពាអៀង ធ្វើក្អែកវលីវ ៗ នៅជាចន្លោះដុំរុំប្រក់សំពត់ឡើងព័ណ៌ប្រផេះដោយផ្ទៃថ្ងៃចាំង ឡើងពក្អាត់ដោយទឹកភ្លៀងហូរជាក់ព្រោះច្រើមកជាយូរឆ្នាំទន្ឋឹងច្រើនកន្លែងហើយ ។ បួនកាល គេឃើញស្ត្រីខ្លះស្លៀកសំពត់ ណាំឆើត ខ្លះក្រមាបិទមុខ ចេញក្តែតពីកន្លងដុំរុំ ហើយប្រញាប់ទៅដំតល់ឆ្នាំងលើដើងគ្រានដែកចំដើម ជាក់លើថ្មមួយដុំសំបែត ។ គេចាប់ស្មៅសាច់ប្តូស ។ គឺជាដុំសាច់ចៀម ក្លៀកក្លូនពពែ ឬ មាន់ទាផ្សេងៗ យកមកស្មៅ ហើយយកស្មឹកដំរម្រះត្រៃផ្ទៃដ៏ប្លែនឆ្ងាញ់មកជាគ្រឿងឆ្ងាញ់ ។ កន្លងពេលថ្ងៃរះស្រាលមានតែចាស់ៗ ទេនៅចាំដំរ ។ ពួកចាស់ៗ នាំគ្នាអង្គុយលេងនៅមុខផ្ទះសំពត់ លើទីលានថ្មាសយ៉ាងស្អាត ព្រោះខ្យាដំរីច្រើនណាស់ ហើយទំពាស្មឹកមួ

ស៊ីធ្វើព្រៃឆើយ ។ ពួកកូនក្មេងស្លៀកតែខោមកលេងក្បែរៗ ចាស់ហើយមិនយូរប៉ុន្មានស្រាប់តែទាំគ្នាអង្គុយព័ទ្ធជុំវិញចាំស្តាប់រឿងកន្ធារៈ (Désart) គឺគេនិយាយអំពីសត្វសាហាវធំៗ ក្អែព្រៃ ៣ស់ ហើយគ្រប់តែរៀបរាប់អំពីភ្នែចចកនឹងអាក្បែអ្នកតាដែលមានអានុភាពខ្លាំង ។

ពួកប្រុសៗដែលជាល្អ ចេញទៅតាំងពីព្រលឹម នាំគ្នាយកចំនិញទឹងសម្ភារៈផ្សេងៗទៅលក់ឯទីក្រុងដិតខាង ។ ពួកអាប៉ាប់ដើរទេសមិនមែនជាពួកចោរប្លន់ទេ គេសុទ្ធតែជាអ្នកធ្វើដំនួញ គឺយកវេស់ដែលខ្លួនធ្វើនឹងចំនិញដែលទិញមកពីក្រុងធំ ទៅដើរលក់ពីភូមិមួយទៅភូមិមួយដរាបតាល់តែអស់របស់ទើបត្រឡប់មកវិញ ។

អាប៉ាប់ដើរទេសគណៈលោកតាម៉ាព្រក សុទ្ធតែមនុស្សសុចរិតរកស៊ីធ្វើបរដំនួញ ។ ដ៏រាល់តាម៉ាព្រកតែងប្រព្រឹត្តទៅជារបៀបអ្នកដើរទេសតាំងពីក្មេងមកក្នុងវាលកន្ធារៈ ។ អាពួកគាត់ស្លាប់ទៅ គាត់ឡើងកាន់ហានៈជាមេគណៈដំនួសតាំងពីកាលគាត់អាយុម្ភៃធ្ងាំ ។ គាត់រកទួលទានបែបនេះរវាងសែសិបឆ្នាំមកហើយ តែងដើរទៅដើរមកក្នុងកន្ធារៈនាំកំឡុងក្រុងទីប៉ូលីតែន ។ ដំនួញដែលគាត់ធ្វើ គឺឡើវអាវកប សំពត់សំបកឈើ ស្វាបសត្វអូទ្រុះ ស្បែកពពែសំឡាប់ហើយ កបា្រស ក្នុក កូនកន្ទែងដៃ សំពត់អង់គ្លេស មេ្មស ផ្លែដីប៊ូ ម្រេច ស៊ុកតែ សំពត់សាក្លាតប្រទេសអូទ្រិះព័ណ៌ក្រហម ខ្សែ បៃតង លឿង ដើម្បីយកមកធ្វើសំលៀកបំពាក់អាប៉ាប់ ទឹងវត្ថុដទៃទៀតជាច្រើនដែលអ្នកស្រុកអាយត្រូវការ ។

ពួកឈ្មួញកាន់តែធំបន្តិចម្តងៗ មកពីពួកអ្នកដើរទេសផ្សេងៗ បាន ប្រទះគ្នាកន្លែងកន្លែង ហើយនាំគ្នាផ្ទុំធ្វើជាគណៈមួយយ៉ាងធំដើម្បីជួយរក្សា ទឹងការពារសេចក្តីសុខចំពោះគ្នានឹងគ្នា ។ ក្នុងចំណោមមនុស្សទាំង នោះ មានជនជាតិចិនដែរដែលមានកាំភ្លើងនឹងគ្រាប់រំសេវសំពះដាក់ការពារ ខ្លួន គេមិនខ្លាចតែត្រឹមចោរប្លន់ឡើយ គេត្រូវបារម្ភដល់ពួកឥសាន នៃពួកការក្នុងស្តង់ណុបទៀត ។

កាលណោះ សាយណាសម័យកាន់តែទន់ខាបបន្តិចម្តងៗនារីពីរនាក់ កៀងសន្សឹមៗនូវពៃមួយហ្វូងតូច សំដៅទីស្នាក់ ។ គឺជាយុវតីពីរនាក់ មួយអាយុដប់ប្រាំបីឆ្នាំ មួយម្ភៃឆ្នាំ ។ នាងដែលនៅក្មេងជាងឈ្មោះឡ្វីឡា, នាងបងឈ្មោះអាឥសាតា ។ នាងបង ពិតមែនតែអាយុច្រើន ប៉ុន្តែត្រូវ បណ្តោយឲ្យប្អូនដឹកដៃដូចជាកូនក្មេងតូច ដ្បិតនាងមានក្តែងធឹង ។ អាឥសាតាក្តែងខ្លាក់ទាំងសងខាង ។

សេចក្តីខ្លះនេះហើយដែលបណ្តាលឲ្យលោកតាម៉ាត្រុក មានសេចក្តី អាសូរខ្លាំងក្នុងខណៈដែលម្តាយនាងឈ្មោះ ចាដ្យា មកអង្វរសុំឲ្យលោក មេគ្តាទទួលគ្នាបីនាក់ឲ្យនៅក្នុងពួកលោកផង ខាងក្រោយមរណភាព របស់ប្តីនាង ។ នាងតែងនាំហ្វូងពៃតាមផងជានិច្ចគ្រាន់តែបានកើតជោះ ឬកូនពៃអ្នកស្រុយ ។ ចំណែកនាងចាដ្យាជាម្តាយទទួលខ្លួនជាអ្នកសូ ដណ្តាំសម្រាប់ប្រុស ។ ឯនាងឡ្វីឡាឆ្នាតខាងដេរប៉ាក់សំពត់យ៉ាងឆើត

ទឹងសែសយមាស ប្តូរដែរខ្លួយពួកដោយស្បែកដែលគេតែងយកទៅលក់ ដូនតាម៉ែទាស់ស្រែកក្នុងទីក្រែង ។ ការរស់នៅយូរទឹងការមានសេចក្តីពិសោធន៍ច្រែន ធ្វើឲ្យលោកតាម"ព្រែកមានចិត្តសប្បុរស ហើយព្រមទទួលស្រីបីនាក់នេះក្រាម មិនបានពិនិត្យយូរ ។ ហើយស្រីទាំងបីនាក់គឺម្នាយទឹងធីតាមិនជាយូរប៉ុន្មាន បានជាទីពេញចិត្តនៃមនុស្សទាំងអស់ ។ នាងអាឥស្សាតា ពិតមែនតែមានសេចក្តីទុក្ខព្រួយជាប់នៅក្នុងចិត្តជានិច្ច តែចេះសំដែងអាការស្លូតបូតទឹងសេចក្តីរីករាយ ដែលអាចញ៉ាំងសេចក្តីមេត្រីនៃលោកតាម"ព្រែកឲ្យកម្រើកបាន ។ ចំណែកនាងឡីឡាវិញនោះ ឧបមាដូចផ្កាកំពុងរីកកណ្តាលព្រៃស្បូ ។

គឺនារីនេះហើយដែលជាសេចក្តីរីករាយរបស់មនុស្សទាំងអស់ ហើយកាលណាត្រឡប់មកដល់ មានដុតចង្កៀងភ្លឺត្រហមព្រោងព្រាតលើវាលខ្ពប់, ពួកអ្នកដើរទេសទាំងប៉ុន្មានអង្វរសុំឲ្យនាងរើសខ្នុកច្រៀងអាក៏ប់ណាមួយដ៏ពីរោះស្រទន់ស្រទោចមកច្រៀងឲ្យស្តាប់ ។ ក្នុងអាកាសយប់ស្ងាត់ សូរចម្រៀងលាន់ឮក្រលួចឡើងសំដៅផ្ទាយទាំងឡាយ, ចំណែកមនុស្សទាំងឡាយនាំគ្នាស្តាប់កាំងក្តេចសេចក្តីលំបាក សេចក្តីខ្សឹយហត់ទឹងសេចក្តីទុក្ខ ដើម្បីផ្ទៅបដូងវិញ្ញាណជាមួយទឹងសូរសៀងរបស់នាងក្រមុំឡីឡា ។

នាងឡីឡាប្រកបដោយរូបសម្បត្តិ ទឹងសម្ផស្សសម្បត្តិ ។ ក្រៃពីនេះឡើយដ៏មានកេមវែង ។ ប្រកបពីលើ ជាទីធ្វើមុខមូលទ្រវែងពាសពេញ

ទៅដោយពេមស្តើង ។ ទន់ល្មើយ ឲ្យស្រស់ឡើងអស្ចារ្យ ។ ឡឺឡា មិនធំ មិនតូចយ៉ាងសម ចង្អេះមូលក្តុំ ស៊ុនឹងដងខ្លួន តែងញាំងបុរសឲ្យរំភើបចិត្តជានិច្ច, រៀលដែលនាងដើរទៅមកកាត់ជុំ ដំណើរបង់ធ្លោយសមនឹងភាព ត្រូវគ្នានឹងក្រមាទ្រូងសាច់ទន់ នាងតែងញាំងតម្រេកឲ្យកើតឡើងតាមជាន ជាតម្រេកដែលនាងគ្មានបំណង ព្រោះនាងមិនមានចេះគុបតែងខ្លួនទៅឡើយ ។

នាងឡឺឡា បើនាងលោជានឹកឡើង តែងឹកខុសពីអ្នកផងទាំងពួង គឺនាងនឹកដល់រឿងដ៏ធំស្មើរហួសវិស័យកងប្រវត្តិរបស់នាង ។

តាំងពីក្មេងមក នាងតែងជាប់ចិត្តចំពោះរឿងព្រេងដែលជីដូននាងទ្រាហ៍និយាយប្រាប់ គឺអំពីសុល្លាន អំពីកាអ៊ុត អំពីព្រះអង្គម្ចាស់ អំពីមេចំបាងផ្សេង ។ ហើយនាងតែងរក្សាបម្មជរំនុកកងដួងហទយៈយ៉ាងមាំ ខុសអំពីស្រី ។ ជាគូកនកងស្មុគស្មាញជាមួយ ។ ការតម្រេកខ្លួនមិនដែលកើតមានដល់នាងម្តងទេ ហើយបើលោជានឹក នាងនឹកឲ្យបានដូចកងរឿង គឺជាស្តេច ព្រះអង្គម្ចាស់ ឬមេចំបាង ណាមួយរូបយ៉ាងឆើត ដិះសេះមកនិយាយសំដីទន់ផ្អែម ហើយលើកនាងឲ្យអង្គុយនៅលើសេះជាមួយ រួចបន្ទាំសំដៅវាំងប្រាសាទ បរិបូណ៌ដោយទឹកថ្នាក់ជាក់ ដោយគ្រឿងក្រអូបឈ្ងុយឈ្ងប់ ដោយគ្រឿងសំលៀកបំពាក់សុទ្ធតែត្រៃ ដោយកែវកងមាសប្រាក់ ពេជ្រ មិនមានខ្វះ ។

(មានត)

លើកទី ១

របស់លោក ចាប-ពិន

កាលពីថ្ងៃទី ៧ ខែធ្នូ ព.ស. ២៤៨៦ គ.ស. ១៩៤៣

ឯ. ខ. សម-ញាណ រដ្ឋមន្ត្រីក្រសួងធម្មការ សិល្បការ និងការសិក្សាជាមិនយូរប៉ុន្មានទេ បានអញ្ជើញទៅជួបសន្ទនាជាមួយនឹង ឯ. ខ. ច្បាក់-សារិន អនុរដ្ឋលេខាធិការទទួលបន្ទុកខាងយោសនាការ ស្នើយោបល់ថា "ឯ. ខ. មានមធ្យោបាយយ៉ាងណាខ្លះដែលជាទីនាំឲ្យចំរើនសិល្បៈខ្មែរយើងតទៅ?" ។

ឯ. ខ. ច្បាក់-សារិន តបថា: រូបខ្ញុំដែលមកទទួលបន្ទុកយោសនាការថ្មីៗនេះ យល់ឃើញថា សិល្បៈខ្មែរយើង បើពោលឲ្យខ្លី មានក្នុងន័យចម្រៀងជាដើមនេះ ជាមធ្យោបាយយ៉ាងប្រពៃ តួនាទីយោសនាអាចណែនាំប្រជាជនរួមជាតិ ឲ្យងាកទៅរកសាមគ្គីធម៌ឲ្យចេះស្រឡាញ់ជាតិ សាសនា មហាក្សត្រ ព្រមទាំងឲ្យចំរើនភាសាអក្សរសាស្ត្រឲ្យប្រទេសជាតិបែរមុខទៅកាន់វឌ្ឍនភាពបានប្រសិនបើចេះសម្រួល ប៉ុន្តែបើបោះបង់មិនសម្រួលឲ្យសមតាមកាលៈទេសៈទេ នឹងអាចនាំឲ្យបែរទៅកាន់ផ្លូវផ្ទុយពីនេះទៅវិញដោយពិត ។ ព្រោះហេតុដូច្នេះហើយ បានជាខ្ញុំកំពុងគិតកែសម្រួលនូវក្នុងន័យចម្រៀងឲ្យបានស្រួល ដើម្បីនឹងឲ្យ

ផ្សាយតាមវិទ្យុកម្ពុជា ជាសំឡេងណែនាំប្រជាជនរួមជាតិយើងឲ្យបែរមុខទៅរកវឌ្ឍនភាព ។

ឯ. ខ. សម-ញ្ញា តបថា: យោបល់ ឯ. ខ. យល់ឃើញយ៉ាងនេះល្អប្រសើរណាស់ ព្រោះសំឡេងដែលផ្សាយតាមវិទ្យុយោសនសំឡេងនេះឮទូទំរង់ទៅគេញប្រទេសយើង ប្រជាជនរួមជាតិរមែងស្តាប់ច្រើនគ្នា កាលបើឮក្មេងឮសំឡេងច្រៀង តែងចំខុតណាមួយមានប្រយោជន៍ដល់ប្រទេសជាតិ ក៏មុខជាចាំបានយកទុកជាគតិ ដោយរីករាយពុំខាន ប៉ុន្តែមិនអាចធ្វើកន្លែងខ្លីបានទេ លុះត្រាតែព្យាយាមធ្វើយូរអង្វែងទៅអនាគត ឲ្យជ្រួតជ្រាបដល់ដួងចិត្តប្រជាជនរួមជាតិនោះទើបបាន ។ រីឯខំទុកដែលមានសារប្រយោជន៍ គួរយកមកផ្សាយតទៅនោះប្រសិនបើ ឯ. ខ. លើកយកអត្ថបទកន្លែងសៀវភៅចម្រៀងជាតិនិយម. ទំព័រ ១ .មកឲ្យអ្នកចម្រៀងច្រៀងផ្សាយទៅនោះ មុខជាប្រជាជនរួមជាតិយើងចូលចិត្តស្តាប់ ហើយចងចាំខុកជាគតិតទៅ ។ ដោយហេតុថាចម្រៀងជាតិនិយមនោះ ជាកិច្ចការរបស់ក្រុមដំនុំទំនៀមទម្លាប់ខ្មែរ ដោយគណៈធម្មការគីតនិពន្ធ របស់ក្រសួងពុទ្ធសាសនបណ្ឌិត្យ បានប្រជុំអស់លោកអ្នកដែលចេះដឹងស្គាល់ប្រយោជន៍ខាងផ្លូវលោកនិងផ្លូវធម៌ រៀបរៀងឡើងដោយពិនិត្យពិចៃ បានចោះពុម្ពពី ព. ស. ២៤៩៤ គ. ស. ១៩៥១ ចំនួន ២០០០ ក្បាល ផ្សាយនៅក្នុងប្រទេសយើង ពាំងបាន

ចេញទៅប្រទេសក្រៅអស់ជាច្រើនក្បាល ហើយមាននៅសល់ខ្លះ ទុកជាវដ្ដនប្រជាជនតទៅ, ខ្ញុំយកសៀវភៅចម្រៀងជាតិនិយមខ្សែទី ១ មួយក្បាលនេះមកជូន ឯ. ឧ. ប្រើការក្នុងវិស័យសំឡេងប្រទេសកម្ពុជា ជាប្រយោជន៍ដល់ប្រជាជនខ្មែរជាតិ ។

ឯ. ឧ. ប្រាក់ សារិទ្ធ ទទួលដោយរីករាយហើយមានប្រសាសន៍ថា: សៀវភៅនេះ ខ្ញុំបានទទួលពីពុទ្ធសាសនបណ្ឌិត្យ ។ ក្បាលដែរ ឃើញចំនុកណែនាំប្រជាជនឲ្យចេះដឹងនូវគុណវិបត្តិរបស់ពលរដ្ឋ សុទ្ធតែចម្រៀងមានសារប្រយោជន៍ល្អៗមែន ខ្ញុំនឹងចាត់ឲ្យយកទៅច្រៀងជាភ្លេងខ្មែរកម្ពុជាជាបន្ត ។ ត្រាតែចប់ ដោយលៃលកចែកពេលឲ្យលេងក្នុងចម្រៀងតាមសម័យថ្មីខ្លះ តាមបែបបទការប្រគំដែលប្រទេសយើងដើរទុកជាចំនៀមទម្លាប់ដកបមកខ្លះ ។ ឯសាច់ក្នុងនឹងឲ្យប្រែចាប៉ីខ្លះ សាយដៀវខ្លះ, ចំណែកបទនឹងប្រែបទសាកំមេ ជាត់ជាយ ឬជាត់ជាយក្បាយជាដើម ។ មិនត្រាន់តែឲ្យច្រៀងហើយចោះបង់ចោលទេ ខ្ញុំនឹងពិនិត្យមើល កាលបើឃើញថាចម្រៀងណាមួយមានចំនុកល្អហើយពីរោះផងនោះ ខ្ញុំនឹងចាត់ឲ្យថតសំឡេងចម្រៀងនោះ ទុកផ្សាយក្នុងប្រទេសយើង ព្រមទាំងឲ្យផ្សាយចេញទៅប្រទេសដទៃៗផងទៀត ។

ឯ. ឧ. សម ញ៉ាណ តបថា: ប្រពៃណាស់ អំពើដែល ឯ. ឧ. ប្រឹងរៀបចំនេះ ប៉ុន្តែសិល្បការខ្មែរ មានក្នុងនឹងចម្រៀងជាដើមនេះ

នឹងមានរសជាតិល្អទៀបានមកពីអ្នកច្រៀង ចេះច្រៀពាក្យពេចន៍ឲ្យ
ស្របតាមគោលវេយ្យាករណ៍ ពោលឲ្យច្បាស់ឲ្យស្តាប់បានស្គាល់ថាជា
សំឡេងខ្មែរសំដីខ្មែរ ព្រមទាំងពោលឲ្យត្រូវតាមពាក្យដែលច្រៀជាផ្លូវការ
កុំឲ្យស្អៀង ដូចតែងបានឮញយ ៗ មកហើយ គឺ

— អាណិត ទៅជា រណិត

— អាល័យ — រវៃ

— រលឹក — អាលឹក

— ចាលី — ច្រឡី ជាដើម ។

ហេតុនេះត្រូវឲ្យលោកអ្នកច្រៀងពិនិត្យមើលពាក្យតាមសៀវភៅនោះ
ច្រៀងកុំឲ្យស្អៀង, ប្រសិនបើលោកអ្នកច្រៀងណាមួយ មិនយល់
ពាក្យត្រង់ណាមួយ ឬសង្ស័យពីអ្វីមួយក្នុងចំណោមចម្រៀងខ្មែរនេះ
សូម ឯ. ខ. ចាត់ឲ្យអ្នកច្រៀងនោះទៅជួបនឹងលោក ចាប-ពិន នាយ
ការិយាល័យទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ លោកនេះនឹង
ពន្យល់ជូនដោយមេត្តាភាពដ៏ស្និទ្ធ ពាល់តែពេលធ្វើការ ដើម្បី
ឲ្យសម្រេចតាមគោលបំណងដ៏ប្រសើរបស់ ឯ. ខ. គ្រប់ ។

ឯ. ខ. ច្បាក់ - សារិន តបថា: សាធុប្រពៃណាស់ បើដូច្នេះសង្ឃឹម
ថាបំណងរបស់ខ្ញុំមុខជាបានស្រួលហើយសម្រេចគ្រប់ៗទៅពុំខាន ។

ការសន្ទនាពីសិល្បៈខ្មែរ របស់ ឯ. ខ. ទាំងពីរបូចចប់ដោយត្រមៃ
ត្រៀងស្របយោបល់គ្នាត្រឹមប៉ុណ្ណេះ ។

*
* *

សូមនុកាសបន្ថែសេចក្តី :

ឃុនឧត្តមប្រីជា ចាប ពិន ខ្ញុំជានាយការិយាល័យទំនៀមទម្លាប់
ខ្មែរនៅពុទ្ធសាសនបណ្ឌិត្យ កាលបើបានឮកិច្ចសន្ទនារបស់ ឯ ខ. ទាំង
ពីរបូត្រមទាំងដឹងនូវការត្រមត្រៀងនេះហើយ កំពេញចៅដោយ
សោមនស្សរំភើបចិត្តយ៉ាងក្រៃលែង ។ មិនត្រឹមតែរូបខ្ញុំម្នាក់ឯងទេ
អស់លោកអ្នករៀបរៀងចម្រៀងជាតិនិយមគ្រប់គ្នា ដូចមាននាមចុះក្នុង
អារម្ភកថាសៀវភៅចម្រៀងជាតិនិយមលេខទី ១ ក៏មានចិត្តត្រេកអរហើយ
តើតចិត្តឧស្សាហ៍មានបំណងថា: កាលបើ ឯ. ខ ចៅក្រសួងឃោសនា-
ការចាត់ឲ្យត្រៀងតាមរឿងនិពន្ធក្នុងសៀវភៅចម្រៀងជាតិនិយម ជិតអស់
កងសៀវភៅទី ១ នោះ ពេលណា នឹងរួបរួមគ្នារៀបរៀងទំនុកត្រៀង
តទៅជាសៀវភៅលេខទី ២ ទី ៣ ក្នុងពេលនោះតទៅទៀត ដើម្បីផ្សាយ
នូវចម្រៀងជាអគ្គការសិល្បៈខ្មែរ ឲ្យសមតាមឋានៈប្រទេសកម្ពុជាដែល
បានឯកភាជ្យ ដោយថ្វីព្រះហស្តនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង
មិនឲ្យអូនថយជាងប្រទេសដទៃឡើយ ។

ฯ ហ្ន៎ ! សេចក្តីសាមគ្គីព្រមព្រៀងបែរទៅគាន់គោលនៃការចំរើន មានដំឡៃអ្វីម្ល៉ែះហើយ ! គ្រាន់តែការដែល ឯ. ๑. ចៅក្រសួងទាំងពីរបូព្រមព្រៀងគ្នាប៉ុណ្ណោះនេះ នាំឲ្យយើងរំភើបចិត្តព្រមទាំងមានទុស្សាហ៍មានចិត្តខ្នះខ្នែងចូលជួយកងការកសាងប្រទេសជាតិខ្មែរឡើង ពុកជាការតបស្នងនូវព្រះមហាករុណាគុណនៃព្រះបិយមហាវីរក្សត្រតរៀងទៅ ។

កាលបើចិត្តយើងបានស្ងប់ឡើងយ៉ាងនេះ ក៏មានសេចក្តីសង្ឃឹមថាក្រែងមិនសម្រេចដូច្នេះទេដឹង ។

អារម្មណ៍នេះស្រួបចូលកងដួងចិត្តយើង ឲ្យយើងត្រៀមចាំមើល, ស្រាប់តែមានបង្គាប់ពី ឯ. ๑ រដ្ឋមន្ត្រីក្រសួងធម្មការថា: ឯ. ๑ ចៅក្រសួងឃោសនាការតម្រូវឲ្យច្រៀងតាមទំនុកនៃចម្រៀងជាតិនិយម នៅថ្ងៃទី ๓๑ ខែតុលា ព. ស. ๒๔๙๖ គ. ស. ๑๙๕๔ នេះ ជាលើកដំបូងបំផុត ទើបចាត់រូបខ្ញុំជានាយការិយាល័យនៃក្រុមដំនុំទំនៀមទម្លាប់ខ្មែរ ឲ្យចូលមកថ្វែងព្រឹត្តិការសន្ទនាពីសិល្បៈខ្មែរនេះ ដូចបានពណ៌នាមកពីខាងលើរួចហើយ ។

បន្ទាប់ពីការសន្ទនាមក ឯ. ๑ ចៅក្រសួងធម្មការ សិល្បការ និង ឯ. ๑. ចៅក្រសួងឃោសនាការបានចាត់ហ្លួងវេហារ វែសម នឹងនាងសម្បត្តិ ឲ្យច្រៀងចាប៉ី ចោទដើយគ្នាតាមទំនុកច្រៀងក្នុងសៀវភៅចម្រៀងជាតិនិយមរបស់ពុទ្ធសាសនបណ្ឌិត្យ ជាកំរឿសម្លេងប្រទេស

កម្ពុជានៅថ្ងៃទី ៣១ មករា ១៩៩៤ ជាសណ្តាប់អស់បងប្អូនរួមជាតិ ដើម្បី រក្សាទុកនូវតម្លៃសិល្បៈខ្មែរ ឲ្យគង់វង្សនិងតម្កើងឲ្យរីកសាយឲ្យចម្រើនជា កិយ្យាការតទៅ ។

បរិយាយតីសិល្បៈខ្មែរ

លើកទី ២

របស់លោក ចាប - ពិន

កាលពីថ្ងៃទី ៣១ មករា ១៩៩៤ នេះ ខ្ញុំបានបរិយាយតីការសន្ទនា រវាងឯកឧត្តមចាំងពីរបៃ គឺឯកឧត្តម សម - ញ្ញាណ ទៅក្រសួងធម្មការ-សិល្បការ និងឯកឧត្តម ប្រាក់ សារិន ទៅក្រសួងយោសនាការ អំពី សិល្បៈខ្មែរ ជូនជាសណ្តាប់ធងប្អូនរួមជាតិជាទីស្រឡាញ់ម្តងហើយ, ឥឡូវនេះ ខ្ញុំបានកត់ត្តិយសបរិយាយតីសិល្បៈខ្មែរមួយបៃបុផ្សេងពីនោះជា លើកទី ២ ជូនបាប់ទៀត មានសេចក្តីដូចតទៅនេះ :

ការពំ ការប្រៀង នឹងក្ងេង បើហៅដោយផ្នែក។ ការពំ ជានាដ សិល្បៈ, ការប្រៀង ជាតីតសិល្បៈ, ក្ងេង ជាតូរ្យង្គសិល្បៈ, បើហៅដោយរួមចាំង ៣ ផ្នែកថា "នាដសិល្បៈ" តែម្យ៉ាង ។ សិល្បៈ ចាំង ៣ ផ្នែកនេះ ជាសិល្បៈតែងមានប្រចាំជាតិ ប្រចាំប្រទេសរៀងពលំ ជាតិ ពលំប្រទេស ទួទៅចាំងសាកលលោក ហើយជាសិល្បៈដែល មានជាប់ជាពូជជារៀង។ តាំងពីព្រៃងនាយមក ។ សិល្បៈចាំងនេះកាល

កើតឡើងដំបូងនៅទន់ខ្សោយនៅឡើយទេ តមកទើបគេសន្សឹមៗកែលៃ
ផ្លាស់ប្តូរបែបផែនឡើងបន្តិចម្តងៗជាលំដាប់ ដោយគេលើកដំកើងពប់
អានតៗគ្នា ជាច្រើនដំណាអាយុមនុស្សរៀងរាល់ប្រទេស តាល់តែ
បានសម្រែចរូបជាសិល្បៈត្រឹមត្រូវល្អបរិបូណ៌តេញលក្ខណៈ សម្រាប់
ប្រទេសនីមួយៗ ដែលនឹងផ្លាស់ប្តូរកែលៃពុំបាន ក្រៅពីការចាត់បង់
រូបដើម ហើយនឹងកើតថ្មីជាបែបមួយផ្សេងទៀត - ។

ធម្មតាសិល្បៈ មិនថាជាតិណាទេ កាលបើគេរៀបចំកែលៃតៗ
គ្នាជាប់ជាប់បានសម្រែចរូបត្រឹមត្រូវល្អ បរិបូណ៌ធុតថ្នាក់ ដែលតាម
ភាសាចាំង គេហៅថា សិល្បៈក្លាស៊ីកឡើងហើយ សំគាល់ថាជាសិល្បៈ
ដែលចម្រែនដល់ថ្នាក់បុង្គំពូលបំផុត ។ សិល្បៈរបស់ជាតិណាក៏ដោយ
កាលបើបានចម្រែនដល់ថ្នាក់ក្លាស៊ីកហើយក៏តែងតែសន្សឹមៗ សាបសូន្យ
ទៅវិញ ព្រោះកែលៃឲ្យល្អដាយ៉ាងម្តេចទៅទៀតពុំបាន; ហេតុនេះបាន
ជាជាតិដែលចម្រែន គេតែងតែហួងហែងនឹងព្យាយាមថែរក្សានូវសិល្បៈ
ក្លាស៊ីករបស់គេទុកមិនឲ្យសាបសូន្យទៅរហ័ស ព្រោះសិល្បៈក្លាស៊ីក
របស់ជាតិជាគ្រឿងសំគាល់នឹងជាកែ្នតចម្បងរបស់ជាតិ ដូចគ្នានឹងកញ្ចក់
ឆ្នុះសម្រាប់ឆ្លុះបញ្ចាំងនិស្ស័យចិត្តនឹងព្រឹត្តិការរួមគ្នារបស់ប្រជាជន ឲ្យ
សាកលលោកបានឃើញឆ្អឹងនឹងច្បាស់ថាមិនមែនជាជាតិកៃពៃផ្សេ ពាំង
មិនមែនជាតិទើបកើតថ្មីដែលគ្មានអ្វីល្អជាសម្បត្តិសម្រាប់ជាតិ របស់ខ្លួន

គឺឲ្យដឹងថាជាតិមានសម្បត្តិជាមត៌កតៗគ្នាមកអំពីអតីតកាល ។ សេចក្តីសង្ឃឹមរបស់ជាតិ មិនមែននៅត្រង់បច្ចុប្បន្នចំពោះមុខទេ គឺនៅក្នុងអនាគត ហើយនឹងនៅត្រង់ប្រជាជនចេះចែករក្សាកេរ្តិ៍ដំណែលដ៏ល្អៗរបស់ជាតិក្នុងអតីតកាលខុសយ៉ាងខ្លាច់ខ្លួន តាំងចេះផ្ទាស់ប្តូរកែទៀរបស់ចាស់ឲ្យឈមមុខសមរម្យទៅតាមកាលសម័យ ។

គ្រឿងសំគាល់ដែលសំដែងឲ្យឃើញសេចក្តីចាប្តស់របស់ជាតិនៅត្រង់វឌ្ឍនធម៌, នាដសិល្បៈ គឺតសិល្បៈ ទំងតុរ្យង្គសិល្បៈ ក៏ជាចំណែកមួយៗរបស់វឌ្ឍនធម៌, យើងនឹងសូន៌មើលជាតិណាថាមានសេចក្តីចម្រើននៅក្នុងថ្នាក់ជាន់ចាប ឬជាន់ខ្ពស់ត្រឹមណា ក៏អាចសូន៌មើលបានដោយការពិការព្រៀងនឹងភ្លេងតូរ្យតន្ត្រី ដែលប្រជាជនចាប់អានខ្លួនទៅតាំងមហាសង្គមក្នុងប្រទេស, បើយើងធ្វើដំណើរទៅបរទេស យើងបានឃើញល្បាំរបស់ជាតិណា ដែលគេចាប់អានថាជាសេរីជាតិរបស់គេ យើងអាចវាស់សេចក្តីចម្រើនរបស់ជាតិនោះបានភ្លាមៗ ថា គេមានសេចក្តីចម្រើនដោយវឌ្ឍនធម៌ ទំងអារ្យធម៌ត្រឹមថ្នាក់ណា ។

មហោស្រពខ្មែរ ជានាដសិល្បៈរបស់ខ្មែរយើងតាំងជាសិល្បៈដែលកើតមានឡើងតាំងពីរជ្ជកាលព្រះបាទជយវ៌ន្ទនទី ២ គឺព្រះកេតុមាលា, សម័យអង្គរ រវាងពុទ្ធសករាជ ១៣៤៥ ដល់ ១៣៩៧ គ្រិស្តសករាជ ៨០៣ ដល់ ៨៥៥ មកម្ល៉ះ ហើយចម្រើនឡើងជាលំដាប់ដរាបដល់បាន

ជានាដសិល្បៈក្នុងសុីតរបស់ខ្មែរ ជាវប្បធម៌ខ្មែរ បុព្វបុរសរបស់ខ្មែរ យើងបានថែរក្សាវប្បធម៌នេះទុកឲ្យគង់វង្សជាតួដឆារដកបមកដល់យើង ជាកូនចៅសព្វថ្ងៃ ។

ចំណែកគីតសិល្បៈ, ពួកគីតសិល្បៈនអ្នកសំដែងសិល្បៈខាងច្រៀងខ្មែរយើងក៏ឆ្ងាប់ដំនាញខាងច្រៀង មានច្រៀងចាប៉ីជាដើមតាំងពីបុរាណព្រៃងនាយមកតាមលំដាប់រដ្ឋកាល, មានអ្នកច្រៀងចាប៉ីដំនាញ។ ជាច្រើននាក់ ខាងពួកប្រុស។ដូចគេដន្ទ្រា សរ, សុភាព្រហ្ម, តារម្យណុះ ជាដើម ដល់មករដ្ឋកាលព្រះករុណាសុវណ្ណគោដ្ឋ អាឡាក់ប៉ែន, រដ្ឋកាលព្រះករុណាសុវណ្ណគោដ្ឋ ទីងព្រះពជានុគោដ្ឋ ជំនប់សាន់, តារម្យឆ្នុំយ ទីងសូរសៀងភៅ, ខាងពួកស្រី។ នាងសូរ យ៉ែម, សូរ-យ៉ែម, ខូច, វង សារ៉ាយន្ទន, តែមបូផា, តែវសុភាគន ទីងសាអុំដុំខែត្រ ជាដើម សុទ្ធតែជាអ្នកច្រៀងចាប៉ីតគ្នាឬម្នាក់។ យ៉ាងឯក។ ក្រៅតែតារម្យឆ្នុំយមួយជាអ្នកច្រៀងសាយដៀវយ៉ាងល្បីសព្វាញ ចានៅច្រៀងថ្វាយព្រះចៅផែងគ្រងចាងតកផង ចានទទួលសេចក្តីសរសើរជាច្រើន ។

គួរឲ្យស្តាយណាស់ដែលសម័យបច្ចុប្បន្ននេះ ប្រទេសខ្មែរយើងនៅសល់អ្នកច្រៀងចាប៉ីតិចគ្នាពេក ។

ព្រោះហេតុនេះ បានដាំឯកទត្តម ហៅគ្រូសួនធម្មការសិល្បការ
ទីឆ្នាំឯកទត្តម ហៅគ្រូសួនយោសនាការ ធ្វើបច្ចាទីឆ្នាំតរហើយទីឆ្នាំរក្សា
ទុកទូវសិល្បៈខ្មែរ ឲ្យរីកសាយឲ្យគង់វង្ស បានចាត់ហ្វូងកេហារ សែម
ឲ្យច្រៀងចាប៉ីជាភាសាខ្មែរសំឡេងប្រទេសកម្ពុជា នៅថ្ងៃទី ១០ កុម្ភៈ ១៩៥៤
តាមអត្ថបទកំណត់សៀវភៅចម្រៀងជាតិនិយម ដែលបានបោះពុម្ពហើយ
មានផ្សាយសព្វថ្ងៃនេះ ។ (មានត)

ទិគមវិបន:នៃការបរិយាយខាងដើម

កម្ពុជរដ្ឋជាប្រទេស
ធ្លាប់ថ្កើងវិសេសដល់ហាន:
ក្លាសុកខាងលក្ខាជាតិខេមរ.
ដ៏ជាសិល្បៈខ្មែរបុរាណ ។
ពួកខ្មែរសម័យគួរស្រុះគ្នា
ព្យាយាមសិក្សាឲ្យចំណាន
វិជ្ជាសិល្បៈតាំងប៉ុន្មាន
ឲ្យខ្មែរថ្កើងថ្កានតរៀងតយ ។

ការប្រឡងបេក្ខជនដែលក្រសាំងស៊ីន

ដើម្បីជ្រើសឲ្យចូលរៀនក្នុងវិទ្យាល័យជាសិស្សស្នាក់នៅសាលាបាលីជាន់ខ្ពស់

ព្រះញាណកោសលញាណ-ឈឺន រៀបរៀង

ការប្រឡងជ្រើសរើសពួកនិស្សិតបុព្វជិត ដែលមានសញ្ជាបត្រសាលាបាលីវង់ដែនក្រុងស៊ីន ដូចមានតទៅនេះ៖

កាលពីថ្ងៃទី ២៦ ដល់ ២៨ ខែកុម្ភៈ ឆ្នាំ ១៩៥៤ នៅសាលាបាលីវង់វត្តសាកវ័នតេជោ ភ្នំពេញ មានការជួបជុំពួកព្រះសង្ឃមេប្រយោគនិងសិស្សដែលចំរុងប្រឡង ដើម្បីចូលរៀនក្នុងថ្នាក់ជាសិស្សស្នាក់នៅសាលាបាលីជាន់ខ្ពស់ ក្រោមការដឹកនាំរបស់លោកគ្រូ-ឯម អតីតចៅហ្វាយខេត្តឃ្លាំង ហើយជាអធិបតីវង់នៃពុទ្ធសាសនបណ្ឌិត្យដែនក្រុងស៊ីន តាមប្រកាសលោកគ្រូវេណីហ្សិណោពលលេខ ៣៨៥ ចុះថ្ងៃ ២៥ កញ្ញា ឆ្នាំ ១៩៤៣ អនុញ្ញាតឲ្យតាំងក្រសួងពុទ្ធសាសនបណ្ឌិត្យវង់ នៅប្រទេសយៀកណាម ក្រុងស៊ីនប៉ែកខាងត្បូង ។

ការប្រឡងនោះ ធ្វើនៅពេលព្រឹកចាប់ពីម៉ោង ៨ ដល់ម៉ោង ១១ នឹង ៣០ នាទី នឹងវេលាល្ងាចតាំងពីម៉ោង ១៤ ដល់ម៉ោង ១៨ ថ្ងៃខាងលើនោះ, ក្រុមសន្ទិដ្ឋជនមានសមាសភាពដូចតទៅនេះគឺ

១ – ព្រះញាណកោសល ញាណ · ឈឺន វត្តលង្កា អធិបតី

២ – ព្រះគ្រូមុនីសោភ័ណ សេក · នាង វត្តទេណ្ណាលោម សមាជិក

៣- ព្រះបាឡាត់យោសវត្តិត ហ៊ុយ-អ៊ួច វត្តសាកវ័ន សមាជិក

៤- ព្រះមហា វិញ-គៀង ជុំ " ទណ្ឌាលោម "

៥- " ថាប់-ឯក " សាកវ័ន "

៦- " ខេមរិន្ទ " មហាមន្ត្រី "

៧- " ជា-អៀង " លង្កា លេខាធិការ ។

តាំង ៧ អគ្គនេះបានដួបជុំតាមកាលបរិច្ឆេទដូចខាងលើ រួចហើយ ទើបលោកអធិបតីវង្សនៃពុទ្ធសាសនបណ្ឌិត្យ ប្រគល់វិញ្ញាសាប្រឡង តាំង ៥ ប្រយោគ ដែលប្រកបស្រាមបិទភាគល័ខយ៉ាងជិតស្និទ្ធឥតមានរង្គើស ប្រគេនទៅលោកអធិបតីមេប្រយោគ។ ក៏បើកទុកាសប្រឡងសិស្សចំនួន ៤២ រូបដែលអង្គុយតាមលំដាប់លេខរៀងសម្រាប់ខ្លួន តាំងពីលេខ ១ ដល់ ៤២, ទើបលោកមេប្រយោគបើកវិញ្ញាសាបង្ហាញ រួចហើយហៅឲ្យសរសេរតាមសូត្រ, លំដាប់តមកឲ្យសិស្សប្រែថាលីលោកប្រយោគ, អធិប្បាយគាថា, តែងសេចក្តីខ្មែរ, ឆ្លើយចំណោទនព្វន្ត ។ តាំង ៥ ប្រយោគនេះសុទ្ធតែសរសេរតាំងអស់ ឥតមានសួរផ្ទាល់មាត់ទេ ។ ក្រដាសប្រឡងតាំងនោះសឹងបិទនាមសាមីខ្លួនអ្នកប្រឡងយ៉ាងជិតតាមបញ្ញត្តិច្បាប់ ។ លុះសិស្សសរសេរចប់តាំង ៥ ប្រយោគហើយ ក្រមមេប្រយោគពិនិត្យតាមកម្លាំងប្រជ្ញារបស់សិស្ស ដែលដាប់នៅនឹងក្រដាសរួចហើយឲ្យពិន្ទុ ពីសូន្យដល់ម្ភៃ (២០), សិស្សដែលបានពិន្ទុបូកសរុបយ៉ាងតិចត្រឹម ១១០ ពិន្ទុ ទើបទុកជាបានការ ។

លទ្ធផល

បណ្តាសិស្សចាំង ៤២ រូប ដែលបានចូលប្រឡងចាំងពេលព្រឹក ល្ងាចកន្លងថ្ងៃដូចខាងលើ លុះរួចរាល់ហើយ ចំនួនសិស្សដែលមានពិន្ទុគួរដល់ការ មានតែចំនួន ២០ រូប ដូចមានរាយនាមក្នុងបញ្ជី ឧទ្ទិសេចក្តីកត់ហេតុ ជូនទៅលោកអធិបតីវគ្គនៃពុទ្ធសាសនបណ្ឌិត្យសព្វគ្រប់ស្រាប់កន្លងទីនេះ មិនបានសរសេរពាយនាមទៀតទេ ។

សូមសរសើរយោបល់នៃក្រសួងពុទ្ធសាសនបណ្ឌិត្យវគ្គ ឧទ្ទិសមាគមសិក្សាខ្មែរលើយៈទេមរ ដែនកូសំឆ័ស៊ុន ដែលមានលោកឡាំ-ឯម ជាប្រមុខ ចេះរៀបចំធ្វើការបណ្តុះបណ្តាលអក្សរសាស្ត្រ, វប្បធម៌, អារ្យធម៌, រក្សាទំនៀមទម្លាប់របស់ខ្មែរវង្សឲ្យរស់នៅរហូតក្នុងចន្លោត ដរាបដល់សព្វថ្ងៃនេះ ជាអំពើដ៏ប្រសើរវគ្គបានដោយក្រកន្លងលោកមួយ ។

សូមជូនសព្វសាធុការពរ ចំពោះបងប្អូនរួមជាតិដែនកូសំឆ័ស៊ុនចាំង ព្រះសង្ឃគ្រហស្ថ ឲ្យបានសុខចំរើនសព្វៗកាល ។

សួស្តីខ្មែរដែនកូសំឆ័ស៊ុន !

ធ្វើនៅថ្ងៃ ២៨ កុម្ភៈ ១៩៥៤


តម្រងសទ្ធម្ម

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៦ ខែមិថុនា លេខ ៦

ព.ស. ២៤៩៤ – គ.ស. ១៩៥០



ភ្នំពេញសន្ទេសារ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— បកិណ្ណកកថា	ព្រះមហា ដោក- យ៉ិប	៤០៣
— បញ្ញាសជាតក ភាគទី ២ (តមក)	បណ្ឌិតមហា ឈឹម - ស៊ុម	៤១៣
ផ្នែកអក្សរសាស្ត្រ		
— រឿងសៅរ៍សោយ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង- ប៊ម ..	៤៣៥
— រឿងសាមកុក (តមក)	ឧកញ៉ា ឆូ- កន	៤៤២
— ទាលៈនឹងទមយន្តី (តមក)	អ្នកស្រី ស្រ៊ីន - សារីយ៉ាន់	៤៥១
— ដំណឹងតាមខ្យល់ក្នុងកន្ត្រាៈ (តមក)	លោកដេង - ដ្រីវ	៤៥៨
— បរិយាយពីសិល្បៈខ្មែរ លើកទី ៣ - ៤ - ៥ (តចប់)	លោក ជាប - ពិន	៤៦៤
កំណាត់ឧដ្ឋវត្តិការណ៍		
— បុណ្យមាឃបូជានៅសាលាស្រុកក្រូចឆ្មារ.	ព្រះមហា ជា- អ៊ឿន	៤៧៦

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២០០រ.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:		Page
— Pakinnakakatha	*Brah Maha PHOK-YIP*	403
— Pannasajataka vol-II (suite) .	*M. CHHIM-SOUM*	413
PARTIE LITTERAIRE:		
— Le « SAU-SOY » ou l'influence saturnienne (suite)	*Brah Maha PEUNG-PAM*	435
— Histoire de Samkok (suite) . .	*Oknha NOU-KAN*	442
— Nala et Damayanti (suite) . .	*Mme SRIN-SARIS-YANN* . . .	451
— Le souffle du désert (suite) .	*M. PHENG-CHRIV*	458
— Sur les Beaux-Arts khmèrs (suite et fin)	*M. CHAP-PI*	464
NOTES ET CHRONIQUES:		
— Maghapuja à Kroch-Chhmar .	*Brah maha CHEA-ŒUN* . . .	476

Prix d'abonnement annuel (comprenant 12 numéro) 200$

ព្រះមហា ដោក-យិប សិស្សសាលាបាលីជាន់ខ្ពស់

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្សការចំពោះព្រះភគវន្តមុនី ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ (ដោយសេចក្តីគោរព) ។

ឥឡូវនេះ អាត្មាភាពសូមពណ៌នាសេចក្តីកន្លះបត្តិឈ្មោកកថាដូចមានសេចក្តីតទៅនេះ ៖

១ – សុខសុញ្ញតន្តិ ទុក្ខកើតក្នុងលំដាប់នៃសុខ

២ – អជ្ជេវ កិច្ចមាតប្បំ គួរធ្វើសេចក្តីព្យាយាមក្នុងថ្ងៃនេះឲ្យហើយទៅ

៣ – សតិ សព្ភត្ត បត្តិយា សតិគឺបុគ្គលគប្បីប្រាថ្នាក្នុងទីចាំងពួន ។

បណ្តាសត្វចាំងឡាយក្នុងពិភពលោកនេះ មានច្រើនបែបមានប្រភេទផ្សេងៗគ្នា ដោយសញ្ញាតិខ្លះ ដោយភាសាខ្លះ ដោយវណ្ណៈតកូលខ្លះ, បើទុកជាច្រើនដូច្នោះក៏ពិត តែគង់មានការប្រាថ្នាសេចក្តីសុខដូចៗ

គ្នា, សមដូចព្រះពុទ្ធភាសិតក្នុងគម្ពីរធម្មបទ ខុទ្ទកនិកាយថា សុខកាមានិ ភូតានិ "សត្វទាំងឡាយ ជាអ្នកប្រាថ្នាន្ទរសេចក្តីសុខគ្រប់ៗគ្នា" ។ ហេតុដូច្នោះ បានជាសត្វទាំងឡាយ ស្វែងរកសេចក្តីសុខដោយសព្វៗខ្លួន, តែការបាននូវសេចក្តីសុខមិនដូចគ្នាទេ សត្វខ្លះបានយ៉ាងធំធូលាយ សត្វខ្លះបានយ៉ាងកណ្តាល សត្វខ្លះបានយ៉ាងស្តួចស្តើង សត្វខ្លះត្រឡប់ជាបានទុក្ខវិញក៏មាន ។ ចំណែកមនុស្សវិសេសជាងសត្វតិរច្ឆានទាំងឡាយ ព្រោះមានបញ្ញាជាប់មកអំពីកំណើតដែលហៅថា សជាតិកបញ្ញាផង ព្រោះមានបញ្ញាដែលកើតឡើងអំពីការស្តាប់ ការគិតការចាំនែកក្នុងបច្ចុប្បន្នផង ឯសត្វតិរច្ឆានមិនមានបញ្ញានេះឡើយ ទើបធៀបនឹងមនុស្សមិនបាន សូម្បីក្នុងពួកមនុស្សដែលមានបញ្ញាច្រើនជាងសត្វតិរច្ឆាននោះ ក៏នៅមានតិចច្រើនជាងគ្នាជាលំដាប, អ្នកមានបញ្ញាតិចដែលហៅថាពុម្ពជន ធៀបនឹងសុមេធជនគឺជនអ្នកមានប្រាជ្ញាច្រើនពុំបាន ពុម្ពជនកាលបើជួបប្រទះសេចក្តីសុខ ក៏រីករាយសោមនស្សហួសប្រមាណ កាលបើជួបប្រទះសេចក្តីទុក្ខ ក៏ក្តុចចិត្តខ្លោចមនស្សខ្លាំងតែក្ងេចខ្លួន; ចំណែកសុមេធជន មិនដូច្នោះទេ បើពុំជាបានជួបប្រទះសេចក្តីសុខក្តីទុក្ខក្តី, រមែងមិនប្រែសោមនស្សនឹងខូចមនស្សឲ្យហួសប្រមាណ, ព្រោះបុគ្គលនោះយកសេចក្តីសុខទុក្ខនោះមកពិចារណាជាអារម្មណ៍ដោយឧបាយនៃប្រាជ្ញាថា "សេចក្តីសុខទុក្ខនេះ ជា

លោកធម៌ មិនទៀង អាចឲ្យផលផ្ទាស់ប្តូរវេទនាម្តងមួយបែប" ។ សេចក្តីនេះសមដូចវចនប្រៀបធៀបទី ១ ថា: សុខស្សាធិដ្ឋានំ ទុក្ខំ "ទុក្ខកើតក្នុងលំដាប់នៃសុខ" ។

អធិប្បាយថា: ទុក្ខនឹងសុខជាគូនឹងគ្នា រមែងផ្ទាស់ប្តូរវេទនាឲ្យផលម្តងម្កាក់, ដូចកាលក៏ទុក្ខ ដូចកាលក៏សុខ. ទុក្ខនឹងសុខជាធម្មជាតមាននៅប្រចាំតតិធម្មតា, បុគ្គលនឹងច្រានចោលតែសុខដោយចំណែកមួយពុំបាន, ព្រោះខុសនឹងតតិធម្មតា ។

ព្រោះហេតុនោះ ក្នុងខណៈណាដែលបុគ្គលបានសោយសុខ ជាផលហើយ បន្ទាប់អំពីនោះគង់នឹងបានសោយទុក្ខពុំខាន, ដូច្នេះលោដែលជួបប្រទះសុខនឹងទុក្ខ បុគ្គលមិនគួរប្រើសោមនស្ស ឬទោមនស្សឲ្យហួសប្រមាណឡើយ ។ សេចក្តីនេះសមដូច ព្រះគន្ថកត្តាមុនីសាស្តាចារ្យទ្រង់ប្រដៅកុក្កុធាឯក្នុងសាសនមណ្ឌល ឲ្យមានសតិពិចារណាក្នុងលោកធម្មសូត្រថា ឧប្បន្នំ ខោ មេ ឥទំ សុខំ "សុខនេះកើតដល់អាត្មាអញហើយហ្ន៎!" តញ្ច ខោ អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ "តែសុខនោះ មិនទៀងទាត់ ទន់ក្រាយជាទុក្ខវិញ មានសេចក្តីប្រែប្រួលជាធម្មតា" ។ សូម្បីក្នុងវេលាដែលជួបប្រទះនូវសេចក្តីទុក្ខ ក៏ទ្រង់ត្រាស់ប្រដៅឲ្យមានសតិពិចារណាដោយន័យដូចគ្នាថា ឧប្បន្នំ ខោ

មេ តិទំ ទុក្ខំ "ទុក្ខនេះកើតដល់អាត្មាអញហើយហ្ន៎" តញ្ច ភោ អាដិប្បិ សុខំ វិបរិណាមធម្មំ "តែទុក្ខនោះមិនទៀង នឹងក្លាយជាសុខវិញ មានសេចក្តីប្រែប្រួលជាធម្មតា" ។

សុមេធជន កាលបើបានជ្រាបលក្ខណៈសុខទុក្ខយ៉ាងនេះហើយ, សុខទុក្ខក៏មិនអាចគ្របសង្កត់ចិត្តបាន, បើទុកជាគ្របសង្កត់បានខ្លះក៏មិនហួសប្រមាណដូចពុម្មេធជនដែរ, កាលបើសុមេធជនចំប្រព្រឹត្តតាល់តែបន្ទោបង់សោមនស្សនឹងមនស្សបានហើយ, ព្រះអរហំសម្មាសម្ពុទ្ធត្រាស់ថា បរិមុច្ចតិ ទុក្ខស្មាតិ វទាមិ "តថាគត ពោលថា បុគ្គលនោះ រមែងរួចស្រឡះចាកទុក្ខបាន" ។

ការណីយកិច្ច ដែលត្រូវប្រតិបត្តិតាមលំអាននៃលោកធម្មសូត្រដើម្បីឲ្យរួចស្រឡះចាកទុក្ខបាននោះ ត្រូវជាអ្នកមិនខ្ជិលច្រអូស, មានសេចក្តីព្យាយាមមិនលះបង់ធុរៈ ។ សេចក្តីនេះសមដូចពុទ្ធភាសិតក្នុងខុទ្ទកនិកាយ សុត្តន្តបិដកថា វីរិយេន ទុក្ខមច្ចេតិ "បុគ្គលកន្ទងទុក្ខបានព្រោះសេចក្តីព្យាយាម" ។ អធិប្បាយថា សេចក្តីប្រឹងប្រែង ខ្នះខ្នែងឧស្សាហ៍ដែលជាបដិច័ក្ខនឹងសេចក្តីខ្ជិលច្រអូស, គឺការៈជាអ្នកអង់អាចមិនខ្ជាបចំពោះវិវេកធិប្បច្ចុយមនក្តៅនឹងត្រជាក់ជាដើម ដោយចំណែកយ៉ាងមាំថា "អាត្មាអញ នឹងធ្វើករណីយកិច្ចដោយសេចក្តីព្យាយាម មិនលះ

បធំធុរៈត្រាតែបានសម្រេចតាមបំណង" ។ ឯសេចក្តីព្យាយាមនោះចែកជាមាតិកាមាន ៤ ប្រការគឺ សំវរប្បធាន ព្យាយាមសង្រួមបិទទ្វារទាំង ៦ គឺ ភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ, ចិត្ត មិនឲ្យលុះក្នុងអំណាចអកុសលធម៌ ដែលជាហេតុធ្វើឲ្យអន្តរាយព្រហ្មចរិយៈ ១, បហានប្បធាន ព្យាយាមលះបង់អកុសលធម៌ទាំងឡាយដែលកើតឡើងហើយ ឲ្យអស់អំពីសន្តាន ១, ភាវនាបធាន ព្យាយាមចំរើនកុសលធម៌ទាំងឡាយដែលមិនទាន់កើតឡើង ឲ្យកើតឡើង ដែលកើតឡើងហើយឲ្យកាន់តែចំរើនច្រើនឡើង ១, អនុរក្ខនាបធាន ព្យាយាមរក្សាទុកកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយមិនឲ្យសាបសូន្យទៅវិញ ១ ។ តែបើចែកដោយបំប្លែងមកវិញមានត្រឹមតែ ២ ប្រការគឺៈ បហានប្បធាន ១ ភាវនាបធាន ១ ។

បណ្តាសេចក្តីអាក្រក់ទាំងពួង ដែលហៅថាបាប, អកុសល, ទុច្ចរិត, អករណីយកិច្ច, អធម្មចរិយា, វិសមចរិយា នេះជានាមរបស់បហានប្បធាន ត្រូវព្យាយាមលះបង់ចោលទាំងអស់ ។

បណ្តាសេចក្តីល្អទាំងពួងដែលហៅថា បុណ្យ, កុសល, សុចរិត, ករណីយកិច្ច, ធម្មចរិយា, សម្មចរិយា នេះជានាមរបស់ភាវនាបធាន ត្រូវព្យាយាមចំរើនឲ្យកើតឡើងក្នុងខន្ធសន្តានទាំងអស់ ។ សេចក្តី

នេះសមដូចធម្មកាសិតទី ៤ ថា អជ្ជេវ កិច្ចមាតប្បំ .“គួរធ្វើសេចក្តីព្យាយាមក្នុងថ្ងៃនេះឲ្យហើយទៅ កុំបង្អង់ទុកដល់ថ្ងៃស្អែក” ។ អធិប្បាយថា ការណីយកិច្ចដែលត្រូវធ្វើក្នុងបឋមវ័យដូចជាការសិក្សាសិល្បវិជ្ជាការដែលចែកដោយឡែកៗពីគ្នាមានអក្សរសាស្ត្រនិងចតុព្វិធលេខជាដើម, ត្រូវប្រញាប់ធ្វើឲ្យហើយក្នុងបឋមវ័យ ។ ការណីយកិច្ចដែលត្រូវធ្វើក្នុងមជ្ឈិមវ័យ ដូចជាការស្វែងរកទ្រព្យសម្បត្តិជាដើម ត្រូវប្រញាប់ធ្វើឲ្យហើយក្នុងមជ្ឈិមវ័យ ។ ការណីយកិច្ចដែលត្រូវធ្វើក្នុងបច្ឆិមវ័យ ដូចជាការបំពេញបុណ្យកុសល ដែលជាមិត្តដួនដំណើរទៅបរលោកនាយ ត្រូវប្រញាប់ធ្វើឲ្យហើយមុនពេលដែលខ្លួនយើងមានសមត្ថភាពល្មមធ្វើបាន ។ ដែលថា ឲ្យប្រឹងធ្វើការណីយកិច្ចក្នុងលំដាប់វ័យទាំង ៣ នេះ ជាគ្រឿងបំភ្លឺយោបល់ឲ្យប្រឹងធ្វើ មិនគួរបណ្តែតបណ្តោយ តែមិនខាន់សមនឹងបំណងក្នុងធម្មកាសិតនេះទៅឡើយទេ ព្រោះធម្មកាសិតនេះបង្គាប់ឲ្យធ្វើតែម្តងក្នុងថ្ងៃនេះជាដាច់ខាត, នឹងបង្អង់ទៅថ្ងៃស្អែក ឬខានស្អែកពុំគួរ, ព្រោះបុគ្គលមិនអាចកំណត់បាន ស្មានមិនត្រូវថាមច្ចុរាជគឺសេចក្តីស្លាប់នឹងមកដល់ថ្ងៃណា? កាលបើមច្ចុរាជមកដល់ហើយ បុគ្គលមិនអាចនឹងធ្វើសេចក្តីព្យាយាមក្នុងវេលានោះបានទេ, ព្រោះមិនមែនជាវិស័យ ដែលអ្នកណាមួយនឹងជួយការពារដោយវិធីណាមួយបានឡើយ; សមដូចព្រះគាថាក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកថា ជ មិយ្យមានស្ស

ភាវិត្តិ តាណា "សេចក្តីជួយការពារ រមែងមិនមានដល់បុគ្គលអ្នកស្លាប់" ។ បើទុកជាបុគ្គលចេះយកតែនវត្តុ ដ៏មានដំណៀងកាត់ថ្ងៃមិនបានទៅសួរគេប៉ាន់ ឬចេះអង្វរគេដោយពាក្យផ្អែមល្ហែមថា "នែមច្ចុរាជ សូមអ្នកបង្អង់ចាំថ្ងៃក្រោយសិន" ដូច្នេះ មច្ចុរាជមិនអាចទទួលសំណូក ឬទទួលពាក្យអង្វរយើងឡើយ កាលបើដល់ពេលហើយត្រូវតែស្លាប់ ឈប់មិនបាន ។ សេចក្តីនេះសមដូចទេសនាន័យក្នុងមជ្ឈិមនិកាយឧបរិបណ្ណាសកថា ធ ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា "ការឈប់សម្រាកនៃសេចក្តីស្លាប់ ដែលមានសេនាដ៏ច្រើននោះមិនមានឡើយ" ។

ព្រោះហេតុដូច្នោះ បុគ្គលគួរធ្វើសេចក្តីព្យាយាមឲ្យហើយក្នុងថ្ងៃនេះ ដោយសេចក្តីមិនប្រមាទ កាលបើចិត្តជ្រុលជ្រប់ស៊ប់ទៅក្នុងសេចក្តីប្រមាទហើយ ក៏ឈ្មោះថាបើកឱកាសឲ្យអកុសលធម៌ចាំងឆ្លងចូលមកលុកលុយសន្តានរបស់ខ្លួនបាន ។

ម្យ៉ាងទៀត សម្តេចព្រះអនាវរណញ្ញាណ ទ្រង់ប្រៀនប្រដៅក្នុងអប្បមាទកថា ជាអនេកបរិយាយ, ដូចគាសិតបញ្ហាដែលទ្រង់ប្រដៅកុំឲ្យចាំងឆ្លាយក្នុងបរិនិព្វានសម័យថា ហន្ទ ទានិ ភិក្ខវេ អាមន្តយាមិ វោ "ម្នាលភិក្ខុចាំងឆ្លាយ តថាគតសូមជាស់តឿនអ្នកចាំងឆ្លាយ វិយធម្មា

សង្ខារ។ សង្ខារទាំង៣ឲ្យមានការរំនាសទៅជាធម្មតា អ្នកប្បមាទទៀត
សម្បាទេបើ "អ្នកទាំង៣ឲ្យចូរញុំាងសេចក្តីប្រតិបត្តិឲ្យដល់ព្រម គឺ
ចូរញុំាងសិក្ខាទាំង៣គឺ អធិសីលសិក្ខា១ អធិចិត្តសិក្ខា១ អធិប្បញ្ញា-
សិក្ខា១ ឲ្យដល់ព្រមដោយសេចក្តីមិនប្រមាទ" ។

ការមិនប្រមាទនេះ បើពោលដោយសេចក្តីអធិប្បាយ គឺការមិន
ក្លេចភ្លាំងសតិ, សតិនេះមាន៤បការៈច្រើនឲ្យទៅក្នុងគតិលោកនឹងគតិធម៌។
បុគ្គលដែលប្រកបកិច្ចការផ្សេង។ បើមានសតិជាមេបញ្ជាការហើយ កិច្ច
ការនោះ។ រមែងបានផលិតផលយ៉ាងសម្បូណ៌ក្រៃលែងជាងបុគ្គលក្លេច
សតិ; បុគ្គលក្លេចសតិបើប្រកបកិច្ចការអ្វី។ ការនោះ។ ក៏មិនសម្រេចផល
ដោយល្អបានតាមសេចក្តីប្រាថ្នារបស់ខ្លួនទេ; ដូចជារថដែលមិនមាននាយ
សារថីកាន់កាប់ រមែងជ្រុលជ្រួសហួសផ្លូវដូច្នោះឯង; សតិនេះបើមាន
ច្រើនគ្រឹមណា ក៏ជា៤បការៈច្រើនគ្រឹមនោះ; ធម៌ពួកខ្លះកាលបើមាន
ច្រើន រមែងធ្វើឲ្យមានកង្វល់ តែវាមានធម៌ដទៃមែបនែបផងទើបប្រព្រឹត្ត
ទៅដោយស្រួលបួលបាន, ដូចជាសទ្ធា បើមិនប្រកបដោយបញ្ញាផងទេ
អាចក្លាយទៅជាអធិមោក្ខ, បញ្ញាបើមិនប្រកបដោយសទ្ធាទេ អាចក្លាយ
ទៅជាវិបរិតផ្គេសផ្គាស; វីរិយ បើមិនប្រកបដោយសមាធិផងទេ អាច
ធ្វើចិត្តឲ្យរើរាយ; សមាធិបើមិនប្រកបដោយវីរិយៈផងទេ អាចធ្វើចិត្ត
ឲ្យខ្ជិលច្រអូស ។ ធម៌ទាំងអម្បាលនេះត្រូវមានស្មើភាគគ្នា ។ ឯសតិ

មិនដូច្នោះទេ, ជាធម៌មានគុណានុភាពអាចប្រព្រឹត្តទៅបានតែឯកឯង ដោយមិនចាំបាច់មានធម៌អ្វីនោះអែបនែបផងឡើយ រមែងប្រព្រឹត្តទៅបានក្នុងទីទាំងពួង ។ សេចក្តីនេះសមដូចទេសនានយ័ក្នុងគាថាទី ៣ ថា

សតិ សព្ពត្ថ បត្ថិយា "សតិគឺបុគ្គលគប្បីប្រាថ្នាក្នុងទីទាំងពួង" ។

អធិប្បាយថា: ធម្មជាតិមួយយ៉ាង កាលបើបុគ្គលរលឹកហើយ រមែងចប់ចិត្តមិនឲ្យត្រាច់ទៅក្នុងអារម្មណ៍ផ្សេង ។ នឹងញ៉ាំងការណីយកិច្ចដែលបុគ្គលកំពុងធ្វើ កំពុងនិយាយ កំពុងគិត មិនឲ្យភ្លាំងភ្លាត់បានហៅថាសតិ; សតិនេះរមែងមានប្រយោជន៍ដ៏ធូលាយក្នុងទីទាំងពួង ដូចតរិយោបថទាំង ៤ គឺ: ដេក, ដើរ, ឈរ អង្គុយ ត្រូវប្រើសតិជាគ្រឿងរលឹកនៅគ្រប់វេលា; ព្រោះហេតុនោះបានជាក្នុងសំយុត្តនិកាយ សគាថវគ្គលោកពោលសរសើរសតិនេះ ដោយន័យផ្សេង ។ ថា សតិ លោកស្មិំ ជាគរោ សតិជាគ្រឿងរលឹកនៅក្នុងលោក, សតិមតោ សុវេ សេយ្យោ អ្នកមានសតិជាអ្នកប្រសើរគ្រប់ពេល, សតិមតោ សទា ភទ្រំ អ្នកមានសតិជាអ្នកចំរើនគ្រប់ពេល, សតិមា សុខមេធតិ អ្នកមានសតិរមែងដល់នូវសេចក្តីសុខ ។ សតិនេះមានគុណសម្បត្តិដូចពណ៌នាមកយ៉ាងនេះឯង ។

ធម៌ដែលសំដែងមកនេះ បើពោលដោយរួបរួមបានសេចក្តីថា: សុខទុក្ខមិនខ្វៀង រមែងផ្គាស់ប្តូរវេនគ្នាឲ្យផលម្តងមួយបែប, កងពេល

ដែលបុគ្គលបាននោយសុខក្តី ទុក្ខក្តី មិនត្រូវប្រើសោមនស្សនឹងទោម-
នស្សឲ្យហួសប្រមាណ, ការប្រតិបត្តិដើម្បីធ្វើសេចក្តីទុក្ខឲ្យរលត់បាននោះ
ត្រូវអាស្រ័យសេចក្តីព្យាយាម, ក៏សេចក្តីព្យាយាមនោះគប្បីធ្វើឲ្យហើយ
កន្លងពេលដែលខ្លួនយើងមានសមត្ថភាពល្មមធ្វើបាន ដោយសេចក្តីមិន
ប្រមាទ តាមន័យដូចបានរៀបរាប់មកនេះឯង ។

បកិណ្ណកកថា ធម្មទេសនាដែលអាត្មាភាពសំដែងមក ចប់ដោយ
សង្ខេបតាមគួរដល់វេលាត្រឹមតែប៉ុណ្ណេះ ឯវំ ។

មិត្តភ្ជុកប់

កិច្ចការណាមួយ ល្អក៏ មិនល្អក៏ គួរជាទី
ស្អប់ខ្ពើមក៏ ជាទីស្រឡាញ់ពេញចិត្តក៏ បុគ្គល
ណាប្រាប្តាសេចក្តីបំរើនដល់អ្នកណា បើទុកជា
អ្នកនោះមិនសាកស្គរ ក៏ត្រូវតែប្រាប់កិច្ចការនោះ
ដល់អ្នកនោះ ។

បញ្ញាសជាតក

ភាគទី ២

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ បានឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង
កាលដែលនៅជាឧបជ្ឈាយ៍ពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

ចន្ទភ៨ជាតកទី ៨

(និយាយអំពីការលែងសត្វ ប្រគេនទឹកស្រង់ និងប្រទីបប្អូជាសង្ឃ)

លោកអាចារ្យ ម៉ៀរ-ជង្ឃ ប្រែពីបាលី

ន មោបេមីតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ សត្តមោបនំ អារព្ភ កបិលំ ។ *សត្ថា រីអង្គ្គសម្តេចព្រះសព្វញ្ញុពុទ្ធបរមសាស្តាចារ្យ កាលទ្រង់គង់នៅវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធនូវការលែងសត្វ ហើយទ្រង់សំដែងព្រះធម្មទេសនាមានបទព្រះបាលីថា ន មោបេមិ ដូច្នេះជាដើម ។*

មានសេចក្តីដំណាលថា សម័យថ្ងៃមួយ កិត្តិឆ្លាយអង្គុយប្រជុំគ្នាក្នុងសាលាធម្មសភា ពោលពណ៌នាសរសើរបារមីនៃព្រះបរមគតវន្តាចារ្យថា "ព្រះបរមសាស្តាជាម្ចាស់យើងពាល់គ្នា ទ្រង់បំពេញបារមី

ដើម្បីនឹងដោះពួកសត្វទាំងអស់ឲ្យស្ពោះរួចចេញចាកសង្សារទុក្ខ" ។ ភិក្ខុទាំងនោះកំពុងតែនិយាយគ្នាដូច្នេះ ស្រាប់តែសម្តេចព្រះបរមសាស្តាទ្រង់ចេញចាកគន្ធកុដិមកកាន់សាលាធម្មសភា ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ! អម្បាញ់មិញ អ្នកទាំងឡាយដំនុំគ្នានិយាយពីរឿងអ្វី?" ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលដំណើរសេចក្តីដែលខ្លួនប្រជុំគ្នានិយាយ, ទើបព្រះអង្គទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! តថាគតមិនមែនទើបតែនឹងដោះពួកសត្វក្នុងកាលឥឡូវនេះទេ; កាលពីដើមតថាគតនៅជាពោធិសត្វកំពុងបំពេញបារមី មានញាណមិនទាន់ចាស់ក្លា ឃើញនៅក្នុងសមុទ្រជាមួយនឹងពួកឈ្មួញ ក៏ធ្លាប់បានសង្គ្រោះដោះទុក្ខសត្វទាំងឡាយដូច្នេះដែរ" ។ ទ្រង់មានព្រះពុទ្ធដីកាតែប៉ុណ្ណោះ ក៏គង់ស្ងៀម ត្រាតែភិក្ខុទាំងនោះអាចធនា ទើបទ្រង់នាំអតីតនិទានមកសំដែងច្រៀបថា៖

អតីតេ ភិក្ខវេ ពារាណសិយំ ឯកោ វាណិជោ ធនកោ នាម បដិវសតិ ។ ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ! កន្លងកាលកន្លងរំលងបាត់ស្ងាត់ទៅហើយ មានពាណិជម្នាក់ឈ្មោះធនកៈ នៅនគរពារាណសី មានភរិយាឈ្មោះនាងធនញ្ជា, ពាណិជនោះជាធំជាងពួកពាណិជទាំង ៥០០ ។ គ្រានោះ ព្រះពោធិសត្វទ្រង់គង់នៅក្នុងទេវលោកជាន់តាវត្តឹង្ស, លុះអស់ព្រះជន្មាយុ ក៏ច្យុតចាកទីនោះ មកចាប់បដិសន្ធិក្នុងផ្ទៃនៃនាងធនញ្ជា ។ គ្រាដែលនាងមានគភ៌គ្រប់ ១០ ខែ ក៏ប្រើញសុបិន

និមិត្តកងវេលាបច្ចូសសម័យថា មានតាបស ១ រូប ហោះទៅតាមអាកាស
ចាប់មណ្ឌលព្រះចន្ទ្រ កាន់យកមកជាក់លើព្រះហស្តនាង ។ នាង
ភ្ញាក់ចាកនិទ្រាឡើង ក៏ប្រសូតបុត្រហើយនាងមានចិត្តត្រេកអរថា "អញ
បានកូនប្រុសដ៏ប្រសើរ សមដូចសុបិននិមិត្តដែលបានឃើញ" ។ ទើបតេ
ប្រដុំក្រុមញាតិវង្សមកកំណត់នាមឲ្យបុត្រនោះហៅថា ចន្ទកុមារ ព្រោះ
ពេលមុនប្រសូត មាតាយល់សប្តិឃើញបានព្រះចន្ទ្រ ។

លុះដល់ចន្ទកុមារមានវ័យចំរើនធំឡើង មានរូបឆោមលោមពណ៌ស្អ
ស្រស់ដូចមាស ពង្រៀសមរម្យពុំមានគ្គន់ អ្នកផងតែងពាប់អានស្រឡាញ់
ពេញចិត្តរាល់ៗគ្នា លុះបានដន្ទាយុ ១៦ វស្សា ក៏រៀនចេះចប់សព្វ
សិល្បសាស្ត្រគ្រប់យ៉ាង ។ កាលនោះ មានពួកពាណិជ ៥០០ នាក់
កំពុងប្រជុំប្រឹក្សារៀបដំណើរ នឹងទៅជួញដូរស្រែកសុវណ្ណភូមិ ។ ចន្ទកុមារ
ចូលទៅគាបសំពះលាមាតាបិតាថា "បពិត្រអ្នកម្តាយអ្នកអាពុក! ខ្ញុំនឹង
សុំទៅជួញដូរស្រែកសុវណ្ណភូមិ ជាមួយនឹងពួកឈ្មួញទាំងឡាយ" ។
មាតាបិតាបានឮហើយក៏ឃាត់ថា "កូនអើយ! អ្នកកុំចេញចោលយើង
ទៅជួញជាមួយនឹងពួកឈ្មួញឡើយ, កូនអើយ! ធម្មតាសមុទ្រ ច្បូងកាល
ក៏ស្រួល ច្បូងកាលក៏ម៉ន់ស្រួលទេ, ច្រើនតែប្រទះលើសេចក្តីអន្តរាយ,
ចូរកូនអ្នកកុំទៅឡើយ" ហើយពោលន្ទរគាថានេះថា ៖

ហាហា បិយបុត្តក ហាហា បិយហទយក

អា ឆោ បហាយ បុត្តកំ តាតំ អា ឆោ វិ ឆន្ទេហិ

ឧកូនសំឡាញ់អើយ! ឧកូនសំឡាញ់បណ្ដូលចិត្តអើយ! កូនអើយ! អ្នកកុំលះបង់យើងទាំងពីរទៅឡើយ, ម្នាលកូន! អ្នកកុំចោលយើងទាំងពីរណា ។

មហាសត្តជ្ញនស្ដាប់ពាក្យមាតាបិតាហើយ ក៏ឆ្លើយតបទៅវិញយ៉ាងនេះថា "បពិត្រមាតាបិតា! សូមលោកកុំយាត់ទាំងពីរឡើយ, ខ្ញុំជាទន្ទឹងទៅជាមួយពួកឈ្មួញពុំខាន" ។ មាតាបិតាពុំអាចឃាត់កូនបានក៏ព្រមអនុញ្ញាតឲ្យទៅ ។ ចន្ទកុមារក្រាបថ្វាយបង្គំមាតាបិតាដោយបញ្ចង្គប្រតិស្ឋាន ហើយយកទ្រព្យសំភប់ឆ្លើដើមទុន ឡើងកាន់សំពៅទៅជាមួយនឹងពួកឈ្មួញ ក្នុងថ្ងៃមានឫកល្អ, សំពៅត្រូវខ្យល់ខ្លាំងបក់ជាត់មកក៏លឿនរលោរលាំទន្លាំទន្ទេងទៅកណ្ដាលសមុទ្រ ធ្វើដំណើរត្រើយមួយកន្លែងបានឃើញពួកមនុស្សដើរចូលទៅកាន់ផ្សារ ក៏ចុះចាកសំពៅទៅនឹងគេ, បានឃើញពួកមហាជនលក់សត្វរស់ក៏ទិញកណ្ដុរនឹងស្វាគ្រែះជាច្រើនយកមកដាក់សំពៅ, កាលបើបើកសំពៅទៅដល់ត្រើយសមុទ្រមួយកន្លែងដទៃទៀត, មើលទៅឃើញផ្សារដែលមហាជនចេញចូលត្រៀបត្រាក៏ចូលទៅកាន់ផ្សារនោះនឹងគេទៀត, ទិញទន្សាយនឹងពស់ជាច្រើនដាក់សំពៅហើយចេញទៅ ។ ឯពួកឈ្មួញផងគ្នា បានឃើញសត្វទាំងនោះ ក៏សួរថា "នែចន្ទកុមារ! អ្នកទិញសត្វនេះទៅធ្វើអ្វី?" ។

ចន្ទកុមារ ក្រាបថ្វាយបង្គំថា "ខ្ញុំទិញយកទៅលែង" ។ ទើបពួកឈ្មួញនិយាយ
ប្លន់ថា "ម្នាលចន្ទកុមារ! ធម្មតាឈ្មួញ តែចុះមកកាន់សំពៅហើយ
គេតែងប្រឹងប្រែងសង្ឃឹតរកទ្រព្យ, ចុះបើអ្នកឯងទិញតែសត្វតាំងនេះ
យកទៅលែង មិនបង់ខាតសោះហ្ន៎ឬ ឥតអំពើទេឬ? អ្នកឯងល្ងង់ម្ល៉េះ" ។
ចន្ទកុមារឮដូច្នោះហើយ ក៏តបវិញថា "បពិត្រពាណិជតាំងឡាយដ៏ចំរើន
អើយ! ខ្ញុំមិនមែនល្ងង់ទេ, អ្នកវាល់គ្នាទេតើ ជាមនុស្សល្ងង់, ឬនា
ជាខ្ញុំថាដូច្នោះ ព្រោះជនអ្នកលែងសត្វ តែងបានអានិសង្សមានអាយុ
យឺនយូរជាដើមផង បាន់សេចក្តីសរសើរផង, អ្នកក្រាជតាំងឡាយតែង
សរសើរខ្ញុំវិបណ្តាជនដែលលែងសត្វ ថាជនអ្នកលែងសត្វចាត់ជាអ្នកមាន
បុណ្យ តែងបានសោយសេចក្តីសុខផង, ឯអ្នកដែលពុំបានលែងសត្វ
ចាត់ជាអ្នកឥតបុណ្យ តែងជួបប្រទះនឹងសេចក្តីវិនាសធំ ខ្ញុំយល់ដូច្នេះ
បានជាទំនិញសត្វយកទៅលែង" ។ ពួកពាណិជឃាត់ចន្ទកុមារមិនឲ្យ
កំនាំគ្នាធ្វើដំណើរទៅទៀត ។ កាលបើសំពៅលឿនហួសពីនោះទៅ
ព្រះមហាសត្តក្រឡេកទៅខាងឆ្នេរសមុទ្រ បានឃើញភ្នំមួយធំកំនឹកកង
ចិត្តថា "លើភ្នំនេះប្រហែលជាមានសមណៈអ្នករក្សាសីលត្រឹមត្រូវ បើ
អាត្មាអញយកសត្វតាំងនេះទៅលែងក្នុងសំណាក់លោកនោះ ឃើញថា
ជាការគាប់ប្រសើរ" គិតយ៉ាងនេះហើយ ក៏យកសត្វឡើងទៅលើភ្នំ ។

កាលនោះ មានព្រះថេរៈមួយអង្គសព្វព្រះទ័យនៅដោយការសូបស្ងាត់ លោកគង់ចំរើនភាវនាលើភ្នំនោះ ។ ព្រះមហាសត្វបានឃើញព្រះថេរៈនោះ ក៏មានចិត្តរីករាយ ចូលទៅថ្វាយបង្គំដោយបញ្ចង្គប្រតិស្ថានហើយសួរថា "បពិត្រព្រះគុណាដ៏ចំរើន! លោកម្ចាស់មកគង់នៅទីនេះដើម្បីប្រយោជន៍អ្វី?" ។ ព្រះថេរៈបានឮពាក្យមហាសត្វនោះហើយប្រាប់ថា "ម្នាលឧបាសក! អាត្មាមកនៅទីនេះដើម្បីធ្វើវិវេកគឺសេចក្តីសូបស្ងាត់" ។ មហាសត្វឃើញព្រះថេរៈបែកញើសសស្រាក់ពាសពេញខ្លួនក៏ទូលថា "បពិត្រព្រះគុណាដ៏ចំរើន! ខ្ញុំព្រះគុណាចង់ធ្វើបុណ្យ (បន្តិច)" ។ ព្រះថេរៈថា "ចំរើនពរ អ្នកធ្វើចុះ" ។ មហាសត្វទៅដងទឹកបានចំនួន ៨ ក្អមយកមកប្រគេនលោកស្រេច រួចហើយប្រគេនស្វាមួកេសដូប្បច្ច័យបាយទឹក ១ដប្រទីប ៨ ដួងបូជាព្រះថេរៈ, យកអស់ពាំងសត្វដែលខ្លួនទិញនោះមកលែងក្បែរលោក ហើយលើកកំបាំងផ្តួងអញ្ជលីតាំងសេចក្តីប្រាថ្នា ពោលនូវគាថានេះថា ៖

ភន្តេ ថេរ វិរុត្តម សុណាថ មម វិបត្តំ
ពន្ធនា សត្តមោបនំ បុញ្ញកម្មំ កតំ មយា
តំមិនា បុញ្ញកម្មេន ពុទ្ធោ ហោស្សាមនាគតេ
ជាតិឈ្មោះ តរិស្សាមិ សព្ពាវេស្សំ សទេវកំ
ធម្មនាវំ សមារុយ្ហ ឧទ្ធរិស្សាមិ ជនតំ

បពិត្រព្រះកុណាម្ចាស់ដ៏ចំរើន! សូមព្រះគុណាម្ចាស់ស្តាប់ ភាក្យខ្ញុំព្រះកុណា។ ធ្វើបុណ្យលែងសត្វ ឲ្យរួចពីចំណង់នេះ សូមឲ្យបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាល ឆ្លងរួចពីអន្ទង់គឺជាតិដោយខ្លួនឯង ហើយចម្ងឹងពួកមនុស្សនឹងទៅតាឲ្យឆ្លងដោយសារបាននេះផង សូមឲ្យខ្ញុំបានជិះធម្មនាវ (សំពៅពោលគឺធម៌) បើកស្រង់ឆ្លងពួកបណ្តាជនផង ។

បើវោ តស្ស វិបត្តិ សុត្វា ព្រះថេរៈបានឮដូច្នោះហើយ ក៏តែកាយសោមនស្សស្មោះសរត្រេកអរ អនុមោទនាពោលនូវគាថានេះថា ៖

យំ យញ្ញ បដិបត្តិ តុយ្ហំ តំ តំ សព្ពំ សមិជ្ឈតុ
តវមិនា បុញ្ញកម្មេន ពុទ្ធោ ហោហិ អនាគតេ
ជាត្យណ្ណវំ តរិត្វាន សត្តានហិ មហាជនំ
ធម្មនាវំ សមារុយ្ហ បាបុណិស្សសិ និព្វានំ

សេចក្តីប្រាថ្នាឯណាដែលអ្នកតាំងឡើងហើយ សេចក្តីប្រាថ្នានោះចូរសម្រេចគ្រប់ប្រការចុះ, ដោយអំណាចបុញ្ញកម្មនេះ ចូរឲ្យអ្នកបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលចុះ, ចូរអ្នកបានឆ្លងអន្ទង់គឺជាតិ ហើយចម្ងឹងមហាជនឲ្យឆ្លងដោយសារ

ផងចុះ, អ្នកប្រាកដជានឹងបានឡើងជិះធម្មនាវ បើកបរ
សំដៅទៅដល់ត្រើយគឺព្រះនិព្វានពុំខាន ។

មហាសត្វបានធ្វើបុណ្យប៉ុណ្ណេះហើយ ក៏ធ្វើប្រទក្សិណថ្វាយបង្គំ
ព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន លាយាគាចុះចាកភ្នំ ឡើងជិះសំពៅទៅ
ជាមួយនឹងពួកពាណិជ ដល់ពាក់កណ្តាលសមុទ្រ សំពៅក៏ឃ្លោងយ៉ាង
ខ្លាំងដោយកំលាំងខ្យល់កាច ។ ព្រះមហាសត្វបានជ្រាបថា "សំពៅមុខ
ជានឹងផ្ទាយកណ្តាលសាគរ" ក៏បរិភោគភេជនាហារផ្សេង ។ ដ៏មាន
ឧជារស ហើយយកសំពត់សមកជ្រលក់ប្រេងពួតឲ្យស្រស់ស្អាតយ៉ាង
ខ្លាប់ ។ មហាជនតាំងឡាយកតិតព័យខ្លាចស្លាប់ក៏ស្រែកទ្រហោយំខ្យឹក
ខ្យួលរាល់ៗគ្នា ។ ព្រះមហាសត្វដើរទៅឯក្បាលសំពៅ ឡើងលើដងក្តោង, កាលសំពៅលិចផុតហើយ ក៏លោតផ្លោះរំលងហ្វូងមច្ឆៈហែលរួច
ទៅ ។ ឯជនដទៃៗសឹងជាចំណីសត្វទឹកមានត្រីជាដើម ។

ថ្ងៃនោះជាថ្ងៃឧបោសថ, មហាសត្តត្រេកឡែកមើលទៅអាកាស
ដឹងច្បាស់ថាជាថ្ងៃឧបោសថ ក៏ខ្ពុរមាត់ដោយទឹកថ្លៃ សមាទាន
ឧបោសថសីល ។

គ្រានោះ ចួនជាព្រះមហាកស្សបត្ថេរកន្លងដែនសុវណ្ណភូមិ ទ្រង់ប្រឈួន
ដោយព្រះរោគបៀតបៀន ក៏ទ្រង់ព្រះវិនិច្ឆ័យទៅក្នុងថ្ងៃនោះ ។ ឯនាង
ទេពធីតាឈ្មោះមណិមេខលា ដែលលោកចាលមហាភជតាំង ៤ តាំងឲ្យ

ជាអ្នករក្សាសមុទ្រ ។ នាងទេពធីតានោះ មានសេចក្តីរំពឹងគិតថា "អាត្មាអញនឹងហោះទៅរកំដរមើលមហាសមុទ្រ" ហើយក៏ហោះសំដៅទៅមហាសមុទ្រនោះ ឃើញមហាសត្វកំពុងតែហែលទឹក ហើយស្រាជាបទព្រះគាថានេះថា ៖

កោយំ មញ្ញេ សមុទ្ទស្មឹ អបស្សំ តិរមារុយ្ហ
កឹ តុំ អត្តវសំ ញត្វា ឯវឹ វាយមសេ ភូសំ

អ្នកណានេះ មកហែលកណ្តាលសមុទ្រធំលឺងលើយមិនយល់គោរត្រីយ៉ាងនេះ? អ្នកបានដឹងច្បាស់ជ្រួចម្តេចបានជាប្រឹងព្យាយាមតាំងម្ល៉េះ? ។

មហាសត្វបានឮសំដីនាងទេពធីតានោះក៏តបទៅថា ៖

អហំ ឥសម្ម វិត្តុំ លោកស្មឹ ទេវតេ តុំ សុណោហិ មេ
យេ បមជ្ជន្តិ លោកស្មឹ ពហូ បាបសមាកុលា
បាបា តេ អតិក្កមិត្វា តេ គហេត្វា អមុញ្ចិហំ
អត្តានំ បញ្ញកម្មេន តរន្តោ សោហិ អាកុលោ
គម្ភីរតោ សមុទ្ទតោ យថាសត្តិ យថាពលំ
វិយ្ហាម្ភេបិ សាគរន្តិ តុរំ បស្សាមិ ទេវតេ

បពិត្រទេវតា, -ចូរនាងស្តាប់ខ្ញុំ ខ្ញុំជាអ្នកពិចារណាឃើញ
កិច្ចវត្តដែលត្រូវប្រព្រឹត្តក្នុងលោក, ជនទាំងឡាយឯណាជា
អ្នកធ្វេសប្រហែសច្រើន ច្របូកច្របល់ដោយបាបកម្មក្នុងលោក
នេះ, ខ្ញុំបានដឹកនាំជនទាំងឡាយនោះឲ្យកន្ទងផុតចាកបាប,
ខ្ញុំជាអ្នកទូលាយដោយបុញ្ញកម្មរបស់ខ្លួន ប្រឹងហែលឆ្លង
ចាកសមុទ្រដ៏ជ្រាលជ្រៅ តាមសេចក្តីអាច តាមកម្លាំង,
បពិត្រនាងទេពធីតា! ខ្ញុំសាត់អណ្តែតមកកើតក្នុងសមុទ្ររបស់
នាង ហើយបានច្បងនឹងនាង ។

នាងមណិមេខលា បានឮដូច្នោះ ក៏មានចិត្តសោមនស្សត្រេកអរ
ចុះទៅបីបមថ្វាយព្រះពោធិសត្វដូចជាគេក្រែសោះអោបចាប់ផ្តាំ ហោះ
ទៅអាកាសសំដៅទៅកាន់ទ្វីបក្នុងដែនសុវណ្ណភូមិ ដាក់ព្រះពោធិសត្វ
លើផែនសិលាជាមង្គលប្រគល់ឲ្យទេវតាក្នុងទ្វីបចាប់ថែរក្សា ហើយ
នាងចៀសចេញពីនោះបាត់ទៅ ។

ចំណែកខាងពួកអាមាត្យទាំងឡាយ បានធ្វើសរីរកិច្ច ថ្វាយព្រះ
ភ្លើងព្រះបរមសពតាមប្រពៃណី បានបង្ហើយកិច្ចជាស្រេច ។ ឯព្រះ
មហាក្សត្រនោះ មានព្រះពជធីតា ១ ព្រះអង្គ នាមនាងសិម្ពលី ។ ក្នុងថ្ងៃ
ទី ៧ ចាប់ពីថ្ងៃដែលបង្ហើយកិច្ចនោះមក ពួកព្រាហ្មណ៍ព្រឹទ្ធបុរោហិតភរី
សេនាបតីទាំងឡាយប្រជុំប្រឹក្សាគ្នាថា "ឥឡូវនេះ នឹងរកអ្នកណាមួយ
ដែលមានបុណ្យច្រើន ល្មមសមគួរដល់ព្រះពជធីតាគ្មានសោះ, បើដូច្នេះ

តើយើងនឹងធ្វើដូចម្តេច?" ។ ពួកព្រាហ្មណ៍ឆ្លើយឡើងថា "ត្រូវផ្សងបុស្សវេថមើល, បើបុស្សវេថទៅចំអ្នកណា, អ្នកនោះជាមនុស្សមានបុណ្យសមនឹងព្រះពុទ្ធគា នឹងជាទីពឹងពាក់ព័ន្ធក់អាស្រ័យនៃយើងពល់គ្នាបាន" ។ ការប្រជុំ ក៏បានយល់ព្រមតាមបែបនេះ ។ កាលនោះ ពួកព្រាហ្មណ៍ក៏ចាត់ចែងតែងបុស្សវេថ រៀបគ្រឿងបូជា រចនាដោយទន់ជាយនឹងទន់ដុងប្រគំដេញដំតូរ្យតន្ត្រីមានអង្គ ៥ មានក្បួនហែជាលំដាប់លំដោយទៅតាមគ្រោយបុស្សវេថនោះ ។ បុស្សវេថប្រទក្សិណទីក្រុងហើយក៏ចេញអំពីក្រុងសំដៅទៅខ្នាន ។ កាលនោះ ព្រះមហាសត្វកំពុងតែល្ហិតល្ហៃ អស់កំលាំងតាំងពីកណ្តាលសមុទ្រ ទទួរផុតព្រះសិរសានិត្រាលក់ទៅ ។ បុស្សវេថទៅដល់ផែនកម្ពលសិលា ដែលព្រះមហាសត្តផ្ទំ ក៏ប្រទក្សិណហើយវង់ចំកែ្សព្រះបាទ ។ ព្រាហ្មណ៍ម្នាក់បានឃើញមហាសត្តកំពុងលក់ ក៏នឹកថា "អ្នកនេះមានបុណ្យមែនឬទេ? អញនឹងពិនិត្យឲ្យដឹងសិនអេះ" ។ ទើបព្រាហ្មណ៍ពិនិត្យមើលលក្ខណៈគ្រង់ព្រះបាទ បានដឹងជាក់ថា "អ្នកនេះមានបុណ្យខ្ពាំងណាស់ អាចសោយពុទ្ធសម្បត្តិគ្រប់គ្រងទ្វីបចំនួន ៤ បាន" កាលដឹងដូច្នេះហើយក៏បង្អាប់ពួកភ្នែងឲ្យលេងតូរ្យតន្ត្រីអឺងអាប់ស័ព្ទកងរំពង ហើយអញ្ជើញមហាសត្តថា "បពិត្រអ្នកមានបុណ្យច្រើន ជាម្ចាស់! ពុទ្ធសម្បត្តិត្រូវបានព្រះអង្គហើយ, សូមព្រះអង្គទទួលដំណែង ជាព្រះពុទ្ធរបស់យើងខ្ញុំចុះ

ឲ្យាយ ក្នុងកាលឥឡូវនេះ" ។ មហាសត្តបានឮហើយ ក៏ក្រោកឡើង អង្គុយពែនក្នែនសួរព្រាហ្មណ៍ថា "ម្នាលព្រាហ្មណ៍ដ៏ចំរើន! ចុះស្តេចរបស់អ្នកទៅណា?" ។ ព្រាហ្មណ៍ឆ្លើយថា "សូមទ្រង់ព្រះមេត្តាប្រោស! ព្រះអង្គទ្រង់ទិវង្គតហើយ" ។ មហាសត្តសួរថា "ព្រះអង្គឥតព្រះព្រះរាជបុត្រា-បុត្រីទេឬ?" ។ ព្រាហ្មណ៍ឆ្លើយថា "បពិត្រព្រះសម្មតិទេព! ព្រះរាជបុត្រាគ្មានទេ មានតែព្រះរាជបុត្រី ១ អង្គ" ។ ព្រះមហាសត្ត ក៏ព្រមទទួលរាជសម្បត្តិ ។ ទើបព្រាហ្មណ៍ទាំងអាមាត្យទាំងឲ្យាយ អញ្ជើញព្រះអង្គឡើងគង់ព្រះរាជរថ ដ៏វិចិត្រថ្កើងថ្កានមានបរិវារណែនណាន់តាន់តាប ហែហមនាំព្រះអង្គមកនគរ ។ លុះដល់ទីក្រុងហើយ ស្តេចឡើងលើប្រាសាទគង់លើរាជាសនៈ ក្រោមស្វេតច្ឆត្រដែលគេលើកឡើងចាំងថ្ងាយ, អាមាត្យទាំងឲ្យាយថ្វាយរាជសម្បត្តិព្រមទាំងព្រះនាមថា ព្រះបាទចន្ទរាជ ហើយនាំនាង សិម្ពលីទេវីជាស្ត្រីចំបងជាងពួកស្រី ១៦ ពាន់ មកតាំងជាព្រះអគ្គមហេសី ។ ព្រះនាង សិម្ពលីនោះ បានជាទីសំណប់សព្វព្រះរាជហឫទ័យនៃព្រះរាជាជាងស្រីឯទៀត ។ ទាំងអស់ ។ ព្រះកិត្តិយសរបស់ព្រះរាជា ក៏រមែងចំរើនខ្ពស់ខ្ពស្តាយឡើងជាលំដាប់ ។ ចាប់តាំងពីទ្រង់ទទួលរាជសម្បត្តិជាមហាក្សត្រមក ទ្រង់ប្រកបដោយធម៌ដ៏ស្មើ មិនប្រើអាជ្ញាសស្តាវុធ មានព្រះទ័យខ្ពស់ខ្ពាយដោយបុញ្ញកម្ម ទ្រង់បរិច្ចាគមហាទានសព្វវេលា

ទ្រង់អញ្ជើញព្រះបរមកដឋិតានទីឯព្រះរោជដនទី ពីនគរពោធណាសីមក ទ្រង់ទំនុកបំរុងដោយសុខសួស្តីសិរីភោគ ។

ថ្ងៃ ១ ទ្រង់មានព្រះរាជប្បាទ័យរីករាយដោយបីតិ ចាប់ក្តីកនឹកដល់សត្វដែលទ្រង់ដោះលែងថា "ខ្ញុ! បុណ្យរបស់អញនេះ សម្រេចផលពាន់ហាន់ណាស់តើ!" ។

គ្រានោះ ដោយផលានិសង្ស ដែលព្រះអង្គបានដងទឹក ៨ ភ្នម ប្រគេនព្រះថេរៈស្រស់ លើកំពូលភ្នំ, លុះបានសោយរាជសម្បត្តិកាលណា ពួកទេព្តាតែងទៅដងទឹកយ៉ាងថ្លា មានភ្ញៀវគ្រអូប ចំនួន ៨ ម៉ឺន ៤ ពាន់ភ្នម ពីស្រះអនោតត្តមកថ្វាយស្តេចស្រស់ ត្រង់ព្រះឈាន រៀងរាល់ថ្ងៃ ។ ដោយអានុភាពនៃការបូជាប្រទីប ៨ ដួង ពួកទេព្តាតែងទ្រទ្រង់ប្រទីប ៨ ម៉ឺន ៤ ពាន់បូជារាល់ៗថ្ងៃ ។ ដោយអានុភាពនៃការដោះលែងសេក ពួកសេក ៨ ម៉ឺន ៤ ពាន់ តែងនាំយកស្រូវសាលីអំពីព្រៃហេមពាន្ត មកបូជាព្រះអង្គរាល់ៗថ្ងៃ ។ ដោយអានុភាពនៃការដោះលែងខ្លាឃ្មុំ, ពួកខ្លាឃ្មុំ ៨ ម៉ឺន ៤ ពាន់តែងនាំយកផ្លាំងឆ្ងាយមានផ្លាចង្កឹលណាជាដើម អំពីព្រៃហិមពាន្តមកថ្វាយព្រះអង្គ ។ ដោយអានុភាពនៃការដោះលែងកណ្តុរ, ពួកកណ្តុរ ៨ ម៉ឺន ៤ ពាន់តែងនេះសេកស្រូវសាលីថ្វាយព្រះអង្គ ។ ដោយអានុភាពនៃការដោះលែងស្វាក្រែះ មានពួកស្វាក្រែះចំនួន ៨ ម៉ឺន ៤ ពាន់ ទៅបេះផលាផលផ្សេងៗ អំពីព្រៃ

ហ៊ាមភាន្ត យកមកបូជាព្រះអង្គ៧ល់ៗថ្ងៃ ។ ដោយអានុភាពនៃការដោះលែង១នេ្ល ពួក១នេ្ល ៨ ម៉ឺន ៤ ពាន់តែង៧ៅបេះផ្លែ១ទុម្ពរ យកមកបូជាព្រះអង្គ៧ល់ៗថ្ងៃ ។ ដោយអានុភាពនៃការដោះលែង៧ស់, ពួក៧ស់ ៨ ម៉ឺន ៤ ពាន់៧ៅតាំកែវមណីអំពីសមុទ្រ យកមកថ្វាយព្រះអង្គ ។ សត្វទាំង៧ាយ តែង៧ាំជង្វាយអំពិទិសផ្សេង។ មកថ្វាយព្រះអង្គសព្វ។ ថ្ងៃ ។ ពួកខេ្មាជនៃ ក៏នាំយកគ្រឿងសក្ការបូជាមកថ្វាយព្រះអង្គ ។ ទាំងស្តេច ១០១ ព្រះអង្គកង់សកលជម្ពូទ្វីប ក៏សឹងនាំយកគ្រឿងជង្វាយមកថ្វាយបូជាព្រះមហាសត្វ ។ តាំងតែពីនេ្ល៉ងដំបូងនេះ ព្រះមហាសត្វ នេ្ល៉ងប្រកបដោយព្រះយសខ្ពង់ខ្ពស់អស្ចារ្យ ។ លុះចំណេរមកខាង៨្រោយ ព្រះនាង៧សិម្ពលីទេវី នេ្ល៉ងប្រសូតព្រះពជបុត្រា ១ ព្រះអង្គ ត្រូមព្រះញាតិវង្សថ្វាយព្រះនាមថា មហ៊ាលកុមារ ។

ឯព្រះមហាសត្វ នេ្ល៉ងសោយពជ្ឈជាសុខអស់កាលយូរលង់កង់សុវណ្ណភូមិ លុះដល់នេ្ល៉ងព្រះជក ក៏មានចំណង់ចង់បរិច្ចាគសត្តសតកមហាទាន ទើបនេ្ល៉ងត្រាស់ហៅអាមាត្យឈ្មោះសេនាគុត្ត មកបង្គាប់ថា "ម្នាលប្រស្តែង! ឥឡូវនេះ យើង៧ឹង៧ឲ្យសត្តសតកមហាទាន, ចូរប្រស្តែង៧្បៀបចាត់ចែង៧ប់ ៧ មុខ កង ១ មុខ ៧០០ គឺដំរី ៧០០ សេះ ៧០០ រថ ៧០០ ខ្ញុំស្រី ៧០០ ខ្ញុំប្រុស ៧០០ គោឈ្មោល ៧០០ គោញី ៧០០ ព្រមទាំង៧្រឿងអាហារគោជនផ្សេង។ ឲ្យបានជា

ប្រញាប់" ។ សេនាគុត្តអាមាត្យ ចានទទួលចាត់ការតាមព្រះបង្គាប់ ហើយត្រឡប់មកក្រាបបង្គំទូលព្រះមហាសត្ត. ព្រះអង្គទ្រង់ស្តេចទៅកាន់ រោងទាន ទ្រង់ព្រះរាជទានសត្តសតកមហាទាន ។ កាលនោះ មានពួកខ្ញុំព្រះយោសនាប្រាប់ដល់ពួកស្តេចនឹងសួមកងសកលជម្ពូទ្វីបថា "ឥឡូវនេះព្រះបាទចន្ទរាជ កំពុងព្រះរាជទានទ្វារមហាទាន អ្នកទាំងឡាយចូរទៅទទួលយកកុបង្គំ" ។ កងថ្ងៃដែលទ្រង់ព្រះរាជទាននោះ មានពួកស្តេចមកពីទិសផ្សេង ។ ដោយទៅតាទុកាត មកទទួលយកនាងនារី ហើយចៀសចេញទៅ ។ ពួកសួមយាចកអ្នកកំសត់ មកអំពីទិសផ្សេង ។ ក៏ទទួលយកទ្រព្យធនរៀងរាល់អាត្មា ហើយចៀសចេញទៅ ។ ព្រះមហាសត្ត ទ្រង់ទតព្រះនេត្រយល់ពួកសួមយាចកទទួលព្រះរាជទាន ហើយត្រឡប់ទៅវិញ ក៏មានព្រះរាជហឫទ័យរីករាយស្មោះសរត្រេកអរលើសលន់ពន់ពេក ។

គ្រានោះដោយតេជានុភាពនៃទាន ដែលព្រះពោធិសត្តទ្រង់បានបំពេញ ក៏កើតឡើងមហាប្រឹថពីកម្រាស់ ២៤០.០០០យោជន៍ បញ្ចេញកម្បនាទញាប់ញ័រខ្លាំងគ្រាមដូចជំរំចុះប្រេង, ទាំងភ្នំសិនេរុជាស្តេចបព្វតក៏រង្គត់គោរទន់លូនល្ហាសដូចជាបុងដំបងទន់ផ្តៅ បែរសំដៅទៅកេនគរសុវណ្ណភូមិ, ទាំងសមុទ្រសាគរក៏រវើរវាយទឹកក្តឹកក្តួលលេចបោកបែកផ្លាត្រែង, ទាំងព្រះពុំណាក៏បង្អុរចុះគគុកគគឹកពន្លឺកមហិមា ផ្ទេរកបន្ទោរក្តឹ

ក្នែតក្រហមច្រាលជាលច្រាត់ខ្នាត់រស្មី, តាំងពីផែនដីផ្នែពសុធា រហូត
ដល់ព្រហ្មលោក សឹងមានការអស្ចារ្យកោលាហល់អំពល់តែបែប ១ ដូច
គ្នា, ទាំងអាសនារបស់សម្តេចអមរិន្ទ្រតន្ត្រីធិពជ ក៏សំដែងអាការក្តៅ
រំជួលស្ទុះស្ទាប់រសាប់រសល់ សក្កទេវរាជនឹកពិចារណាឃើញហេតុ
ពិចារណាមើលហេតុកេទ សង្កេតជ្រាប់ច្បាស់ថា "ចន្ទកុមារនេះ
ជាពុទ្ធង្កុរបណ្តាលសពិជ្ញ ស្តេចកំពុងបរិច្ចាគសត្តសតកមហាទាន,
បើដូច្នេះ គួរអញចុះទៅឯមនុស្សលោកសិនអែះ" លុះទ្រង់ព្រះចិន្តាដូច្នេះ
ហើយ ក៏ទ្រង់ឡើងគង់ក្រោសាទរេជយន្តទ្រង់ទតមើលសត្វលោក ហើយ
ហោះ (ចុះចាកឋានសួគ៌ទេវលោក) មកសន្ធិតនៅខាងមុខក្រាសាទ
ព្រះមហាសត្ត ។ ព្រះចន្ទកុមារជន្មទ្រង់មានព្រះរាជឧស្សាហ៍ត្រាស់សួរទៅ
ព្រះឥន្ទ្រាធិពជ ដោយបទព្រះគាថានេះថា៖

កិំ វិមានំ បុរេ បិតំ ទេវបុត្តោ សិយាគតោ
តញ្ច អហិ ន ជានាមិ តុំ មេ អក្ខាហិ បុច្ឆិតោ

វិមានអ្វីមកនៅពីមុខខ្ញុំ? ប្រហែលជាទេវបុត្តចុះមកទេដឹង?
ខ្ញុំពុំបានស្គាល់អ្នកឡើយ! កាលខ្ញុំសួរអ្នកហើយ សូមអ្នក
ប្រាប់ខ្ញុំកុំខាន! ។

តំ សុត្វា សក្កោ ព្រះឥន្ទ្រាធានស្តាប់សព្ទព្រះរាជឧស្សាហ៍ត្រាស់ពោធិសត្វ
ហើយ ឆ្លើយថា៖

สกฺโกหมสฺมิ ទេវិន្ទោ អាគតោ តវ សន្តិកេ
ទានកម្មេន បុញ្ញេន តុយ្ហំ ទានានុមោទរេ

ខ្ញុំឈ្មោះសក្កៈ ជាចមរទេវតា មកកាត់ព្រះអង្គដើម្បីអនុមោទនាត្រកអរចំពោះទានរបស់ព្រះអង្គ ។

ព្រះតម្រាស់ព្រះពុទ្ធដីកាយ៉ាងនេះហើយ ទើបត្រាស់សរសើរព្រះពោធិសត្វតៈ៧ខ្ទៃតថៈ

សព្វេ ជិតា តេ បច្ចយា យេ ទិព្វា យេ ច មានុសា
ព្រហ្មយានមនោកម្មំ សត្តេ តេ តំ វិបច្ចតុ
តទាសិ យំ ភិសនកំ តទាសិ លោមហំសនំ
មហាទានេ បទិនម្ហិ មេទនី សមកម្បថ
ធិន្នាទិតា តេ បភវី សក្កោ តេ តិទិវិង្គតោ
សមន្តា វិជ្ជុតា អាគ្គ គិរីនំ វ បតិស្សុតា
តស្ស តេ អនុមោទន្តិ ឧភោ នារទបព្វតា
ឥន្ទោ ព្រហ្មា បជាបតិ សោមោ យមោ វេសវ្ហវរោ
សព្វេ ទេវានុមោទន្តិ ទុក្ករំ ហិ ករោតិ សោ
ទុទ្ទទំ ទទមានានំ ទុក្ករំ កម្មកុព្វតំ

អសង្ខ្យោ នាឝុភ្ឝន្តិ សតំ ធម្មោ ទុរន្វយោ
តស្មា សតញ្ច អសតញ្ច ទានា ហោតិ ឝតោ គតិ
អសង្ខ្យោ ឝរយំ យន្តិ សង្ខ្យោ សគ្គបរាយនោ

សត្រែវគោះបីជាទេវតាក្តី ជាមនុស្សក្តី ព្រះអង្គបានឈ្នះសព្វគ្រប់អស់ហើយ មនោកម្មដែលជាយានដ៏ប្រសើរ ចូរសម្រេចផលដល់ព្រះអង្គកន្លងហានសួគ៌ចុះ ។ មហាទានដែលព្រះអង្គឲ្យហើយ ធ្វើឲ្យកើតសេចក្តីគិតគន់យល់ភ្ញាក់ព្រឺ-ពេមព្រឺសែ្អក ធ្វើឲ្យផែនដីញាប់ញ័រខ្លុំខ្លារ មហាប្រឹថពីកំកេរកើតរំពើកពុះសូរសំឡេងដល់ហានសួគ៌ ផ្កែកបន្ទោរសន្ធោសន្ធៅច្រាលផ្អៅគ្រប់ទិសទីគ្រប់ដំបន់ ភ្លើរន្ទាលជាលច្រាត់ព័ទ្ធកុំទាំងឡាយ នារទបព៌តទាំង ២ សឹងតែកអរវីកពយចំពោះព្រះអង្គ, ព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះបជាបតី ព្រះចន្ទ្រ ព្រះយមរាជនឹងស្តេចវេស្សវ័ណ ព្រមទាំងទេវតាទាំងឡាយ សុទ្ធសឹងរីកពយអនុមោទនាគ្រប់ៗគ្នា, ព្រោះព្រះអង្គបានធ្វើអំពើដ៏ក្រៃ; ពួកសប្បុរសរមែងឲ្យរបស់ដែលគេឲ្យដោយក្រៃ រមែងធ្វើអំពើដែលគេធ្វើដោយក្រៃ ពួកអសប្បុរសធ្វើតាមមិនបាន ព្រោះធម៌របស់សប្បុរសពួកអសប្បុរសប្រព្រឹត្តតាមបានដោយក្រៃ ហេតុនោះ គតិ

របស់ពួកសប្បុរសនឹងពួកអសប្បុរស រមែងផ្សេងគ្នាតាំងពីកន្លែងនេះទៅ គឺពួកអសប្បុរសទៅកាន់នរក ពួកសប្បុរសទៅកាន់ឋានសួគ៌ ។

លុះព្រះឥន្ទ្រទទួលអនុមោទនាយ៉ាងនេះហើយ ក៏ទូន្មានព្រះមហាសត្តថា "បពិត្រមហាពាជ តាំងពីថ្ងៃនេះទៅ សូមព្រះអង្គកុំធ្វើបុណ្យឲ្យទានកុំមានសេចក្តីធ្វេសប្រហែសឡើយ" ។ សម្តេចសក្កទេវរាជពោលពាក្យគ្រើនរំឭកដល់ព្រះមហាសត្តប៉ុណ្ណេះហើយ ក៏ស្តេចទៅកាន់ទេវលោកវិញហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ សម្តេចព្រះសាស្តាទ្រង់ប្រកាសសេចក្តីនោះ ទ្រង់ត្រាស់ដូច្នេះថា៖

តទំ វត្វាន មឃវា ទេវរាជា សុជម្បតិ
បង្ករញ្ញោវាទំ ទត្វា សគ្គកាយំ អុបក្កមិ

សម្តេចមឃវៈជាព្រះស្វាមីនៃនាងសុជាតា ទ្រង់ប្រទានឧវាទដល់ព្រះបាទបុរាណហើយ ក៏ស្តេចត្រឡប់ទៅកាន់ទេវលោកវិញ ។

តាំងពីកាលនោះមក ព្រះពោធិសត្វមិនដែលប្រហែសធ្វេសក្នុងការបុណ្យឡើយ, ទ្រង់សោយរាជសម្បត្តិមានទេព្វារក្សាឥតមានរោគាពាធមកយ៉ាងបៀតបៀន ទ្រង់ធ្វើបុណ្យឲ្យទានជាដើម ដរាបដល់អស់

ព្រះជន្មាយុសោយព្រះទិវង្គតរលត់សង្ខារ ឋានទៅកើតក្នុងឋានសួគ៌ជាន់តុសិតបិតុក្ខឹរិមានមាសកំពស់ ១២ យោជន៍ មានពពួកស្រីអប្សរបវរកញ្ញាចោមរោមជាបរិវារ ។

សម្តេចព្រះបរមសាស្តា ទ្រង់ប្រកាសន័យវេចក្តីនោះឲ្យជាក់ច្បាស់ទើបទ្រង់ត្រាស់ថា៖

តតោ បទ្មរាធិបោ ទានំ ទត្វាន ខត្តិយោ
កាយស្ស ភេទា សប្បញ្ញោ សគ្គំ សោ ឧបបជ្ជិតិ

កាលនោះ ព្រះបាទចន្ទភាជ ជាអធិបតីនៃនរជនទ្រង់ធ្វើទានហើយ ព្រះមហាក្សត្រទ្រង់ប្រកបដោយព្រះប្រាជ្ញា លុះបែកកាយទំលាយខន្ធហើយ ស្តេចកំឡើងទៅកើតនាឋានសួគ៌ទេវលោក ។

សម្តេចព្រះបរមសាស្តា ទ្រង់នាំចន្ទភាជជាតកនេះមកហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! តថាគតមិនមែនទើបតែទំនៅលែងសត្វទាំងឡាយក្នុងកាលឥឡូវនេះឡើយ, កាលពីដើមដែលតថាគតនៅជាពោធិសត្វកំពុងបំពេញបារមី ក៏ធ្លាប់លែងសត្វដូច្នេះដែរ" ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ទើបទ្រង់ត្រាស់ប្រកាសសច្ចធម៌ទាំង ៤ ប្រការ, កាលចប់សច្ចធម៌ កិក្ខុត្រៃបិដូរបូបដែលបានស្តាប់ធម៌ទេសនា

សឹងបានសម្រែចគុណវិសេសមានសោតាបត្តិផលជាដើម តាម
បនិស្ស័យ
ក់សនាវៀងៗខ្លួន ។

សម្តេចព្រះបរមសាស្តា ទ្រង់ប្រដុំជាតកគ្រាស់នូវគាថាខាងចុង
នេះដូច្នេះថា៖

មណិមេខលា ទេវធីតា ឧប្បលវណ្ណា ច ថេរិកា
តទា សោ សីលសម្បន្នោ សារីបុត្តោ តទាធិបិ
តទា មហិលកុមារោ រាហុលោ មម ឱរសោ
សិម្ពលី នាម សា ទេវី រាហុលមាតា យសោធរា
រាជមាតា ច សា នារី មហោមាយា តទាធិបិ
ធនញ្ចោ នាម វាណិជោ បិតា សុទ្ធោទនោ អហុ
ជម្ពុទីបេ ច រាជានោ អហេសុំ ពុទ្ធបរិសា
បន្នរាជា នរាធិបោ លោកនាថោ វិ សព្ពញ្ញូ
ភវិត្តោ សាធវោ តុម្ហេ ឯវំ ជានេថ ជាតកំ

នាងទេវធីតាឈ្មោះមណិមេខលា បានមកកើតជានាង
ឧប្បលវណ្ណាថេរី, ព្រះថេរៈដ៏មានសីលចរិយាណាពីកាលនោះ
ឥឡូវនេះបានមកកើតជាកិកុឈ្មោះ សារីបុត្ត, មហិលកុមារ
កដ៏កាលនោះ ឥឡូវនេះបានមកកើតជាពហុលកុមារជាឧរស
ទ្ធ

របស់តថាគត, នាងសិម្ពលីទេវី ចានមកកើតជានាងយសោធរាជាមាតានៃកហុល, ឯព្រះវរាហជដនន្ធី ឥឡូវនេះចានមកកើតជាព្រះនាងមហាមាយា, នាយតាណិជឈ្មោះធនកៈ ចានមកកើតជាព្រះវរបិតា ព្រះនាមសុទ្ធោទនៈ, ពួកក្សត្រកន្ធជម្ពុទ្វីប ចានមកជាពួកពុទ្ធបរិស័ទ, ឯព្រះចាតុមហារាជជាអធិបតីលើជនកន្ធកាលនោះ គឺអង្គតថាគត ជាសព្វញ្ញុពុទ្ធជាទីពឹងនៃសត្វលោកនេះឯង; អ្នកទាំងឡាយជាសប្បុរសដ៏ចំរើន ចូរចងចាំទុកនូវជាតកនេះ យ៉ាងនេះចុះ ។

ចប់ចន្លោងជាតក ទី ៨ តែប៉ុណ្ណោះ

ទោសនៃការសេពគប់អ្នកក្រៃកំ

សាធុជនឆ្លាក់ខ្លួនទៅជាអ្នកមិនមានបិត្តប្រសើរ ព្រោះទោសនៃការសេពគប់អសប្បុរស, ចូរមើលពីស្មៈ ត្រឡប់ទៅជាចោរលួចគោ ព្រោះតែការសេពគប់ទុយ៌ោធន៍ ព្រោះហេតុនោះ សប្បុរសលោកវៀរចាកការសេពគប់បុគ្គលថោកទាប ។

បញ្ចតន្ត្រៈ

ទឿនសៅរ៍សោយ

(សិសោរជាតក)

ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរង់វត្តបទុមវតី ក្រុងភ្នំពេញ
រៀបរៀងតាមទម្រាយសាស្ត្រាស្លឹករឹត

(តមក)

ពិទូរ្យសូរ្យតាន សង្ឃារពេជ្រពាន ច្រើនរៃគ្រែអន័គ្ឃ
អនេកគណនា ត្រៀបត្រាឥតអាក់ នាំចូលគគាក់
កុញ្ជរកមហិមា ។ មាសពេជ្រទាំងឡាយ ត្បូងរ័តន៍ធើតនាយ
ដែលដាំនៅទា. សង្ឃារប្អូមកុដ ពិសុទ្ធថ្លៃថ្លា
គ្រាន់តែប៉ះគ្នា ផ្ទុះជ្រោយដោយដី ។ ថ្វាយហើយនិត្យនៅ
បំរើគាល់ហ្អៅ ព្រះបាទចក្រី ខ្ញុះទៅខ្ញុះមក
សព្វថ្ងៃប្រក្រតី ខ្ញុបខ្ញាចបារមី នរបតីមហិមា ។
រីអស់អ្នកធ្វំ អម្បាលដែលចាំ រាជវាំងក្សត្រា
បបួលគ្នារើស មាសពេជ្រនោះណា ១ ថ្ងៃបាន៧
៧ នាឡិម្នាក់ ។ សឹងតែត្រែកអរ ក្នុងចិត្តសាទរ
និយាយពាក់ពាក់ រើសយកសឹងត្បូង តែវាកងមាសច្រាក់
តុំហ៊ានលួចលាក់ នាំយកទៅថ្វាយ ។ រីឯព្រះបាទ
សិសៅរ៍នរនាថ ក្សត្រថ្ងៃពណ្ណរាយ ព្រះអង្គតុំយក

ទ្បើមកចែកចាយ អស់អ្នកចាំដ៏ឡាយ នោះវិញទីនៃ ។
ឯមហាក្សត្រា ស្តេចមានអស្សពាហន៍ សេះអាជានេយ្យ
ជាព្រះទីនាំដ៏ សម្រាប់ក្សត្រថ្លៃ ចាំដ៏ពីរប្រពៃ
កំឡាំដ៏ស្មើឧឡារ ។ មួយនោះឈ្មោះថា តំបក.អស្សពាហន៍
មួយទៀតថ្លើដ៏ថ្កល់ ឈ្មោះមហាលទ: ឫទ្ធិស័ក្តិសោតសល់
ក្សត្រថ្លៃនិរមល សព្វព្រះហឫទ័យ ។ បើទ្រង់ចង់ទៅ
ប្រពាតលេងនៅ ពាក់ពន្ធគនៃ ស្តេចក៏ឡើងគង់
តំបកមះនោម័យ ជ្រៃកដីទៅវៃ ដល់ដូចចិន្តា ។
ស្តេចទតសព្វសាយ ពាក់ពន្ធគនាយ សប្បាយមហិមា
ស្រេចហើយមហាក្សត្រ ចក្រពត្តិវាជ ឡើងគង់អស្សពាហន៍
ជ្រៃកដីលឿនក្រៃ ។ ហួសមកដល់អាយ ក្សត្រថ្លៃពណ្ណាយ
ទឹកកន្ទឹប្ញទ័យ ចង់ទៅប្រពាត ហោមពាន្ធនាយនៃ
ស្តេចបរមនោម័យ ដល់ព្រៃហោមពាន្ត ។ ដល់ស្រែចពុំលង់
ក្សត្រថ្លៃវរវង្ស ទ្រង់ទតកំសាន្ត ក្រែសាលព្រះទ័យ
កន្លងព្រៃហោមពាន្ត ថ្នាក់ថ្កល់ទិហាន ទើបបានដល់ស្រះ ។
រីស្រះនោះណា មានទឹកជ្រៅថ្លា ត្រចង់ត្រចះ
ផេងធំខ្ពស់ឡាយ សប្បាយពេកណាស់ រីឯនាមស្រះ
ឈ្មោះអនោតត្ត ។ ក្បែរនោះព្រះបាទ សិសៅរនាថ

ក្សត្រថ្ងៃវារតែន៍ ផ្ទាស់ពរពស្ត្រា លីលាចុះថ្នាត់
ស្រង់ស្រោចបំបាត់ ទុក្ខកង់អង្គច្បាណ ។ មើលមានឈូកច្រាល
ផ្ការីកវន្ទាល ដេរដាសពាសហាន ច្រៃនៃក្រៃបាកដ
កំណត់មែនមាន ពីនោះទៅបាន ដល់ឈូកសសល់ ។
ពីនោះទៅទៀត សុទ្ធសឹងត្រកៀត កញ្ចែតទន្សល
មែនមានថ្ងៃថ្ងា ត្រៀបត្រាចល់ ពីនោះទៅដល់
សុទ្ធសឹងក្រចាប់ ។ ព្រលឹតលំចង់ ផ្ការីកត្រយង់
កន្ទង់ហើរហាប់ ក្រៃបកេសរផ្កា អ៊ូអាអឺងអាប់
ទំដោយស្រទាប់ ជញ្ជាបកេសរ ។ ក្សត្រថ្ងៃប្រសើរ
ស្តេចទតមៀងមើល បុប្ផាបវារ សប្បាយហ្ឫទ័យ
ក្នុងស្រះបោក្ខរ ស្រោចហើយស្តេចចរ ឡើងពីគង្គា ។
ស្តេចឡើងមនោម័យ ក្សត្រាណក្សត្រជៀសជ័យ បើកបរលីលា
រីសេះតិបក: កម្ចាំងមហិមា នាំអង្គក្សត្រា
ដល់កំងថ្ងៃនោះ ។ ទើបស្តេចយាត្រា ចុះចាកអស្សពាហន៍
ហើយទ្រង់យាងឆ្ពោះ ឡើងលើប្រាសាទ សីហាទតតម្ពោះ
សុខសាន្តស្ងាត់ស្ងោះ ក្នុងព្រះទយា ។ បើព្រះសិរីសៅរ៍
ស្តេចទឹកចង់ទៅ ទតស្ងាត់សូន្យ ស្តេចយកអាជានេយ្យ
ប្រពៃនាមា . មហាលទ:អស្សពាហន៍ ជិះហោះច្រៀវច្រៃ ។

ព្រះអង្គមហាក្សត្រ ខៀងគតសម្បត្តិ ស្ថានសួគ៌នោះនៃ
មើលប្រាសាទមាស ទុកាសភ្លឺក្រៃ រុងរឿងប្រពៃ
រម្ងាលប្រាលផ្លេវ ។ ស្តែងស្តេចគតខៀង ព្រះនេត្រាធ្មៀង
រៀងៗខ្លួនទៅ យល់ប្រាសាទប្រាក់ ដោយថ្នាក់ជាន់នៅ
ភ្លឺផ្លេកសន្ធៅ ព្រៃងព្រាយពេកក្រៃ ។ កែវកងប្រាក់មាស
ដេរដាសព្រេញពាស ព្រៃព្រំថ្ងាថ្លៃ សុទ្ធសឹងល្អល្អះ
ស្អេកស្កុះក្រាស់ក្រៃ មើលមានខៀនស្បៃ ដម្លូទេសទុំ ។
ស្តេចគតស្រីសួគ៌ ប្រសើរគាប់គួរ សុទ្ធសឹងក្រមុំ
ល្អល្អះស្អេញល្អៅ ស្រដៅកុះកុំ ដោយពួកដោយក្រុម
ព្រេញព្រហ្មចារី ។ តូចធំតូចចះ ស្រលួតស្រឡះ
ស្រស់ត្រចិមប្រិយ ទ្រូមើទ្រមម ស្រទន់ស្រស់ស្រី
ស្រស់ស្រលពិសី ទ្រូទេសទឹងវង ។ ល្អាសល្អន់កាយា
គន់ទៅកត្តា ផ្លូវផង់បំព្រង ដូចចន្ទបូណ៌មី
ស្រស់ស្រីឥតហ្មង មើលមិនមានគ្នង គួរឲ្យស្នេហា ។
ព្រះចាទក្សេមក្សាន្ត ស្តេចគតសួគ៌ស្ថាន មហារាជិកា
ហើយហួសទៅឰ ស្ថានត្រៃត្រឹង្សា ទ្បើងទៅយាមា
តុសិតសួគ៌នាយ ។ ស្តេចគតសព្វគ្រប់ ច្រាំមួយដណ្តប់
ស្ថានសួគ៌តណ្ហាយ សប្បាយហ្ចប់ក្ស័យ ក្សត្រថ្ងៃធ្លោមធាយ

ក្សេមក្សាន្តសប្បាយ ឥតឯគណនា ។ ស្រែចហើយព្រះអង្គ
ក្សត្រក្សាន្តវរវង្ស ស្តេចវិលលីលា សេះនាំហោះមក
ចុះចាកស្ទូគ៌ា ដល់នគរ នៅនាថ្ងៃនោះ ។
អស់មុខមន្ត្រី សេនាសេនីយ គង់គាល់ចំពោះ
អភ័យាយស្រឡាំ ក្រមុំកំឡោះ គង់គាល់ស្មានស្មោះ
ជាប់ជាប្រក្រតី ។ មានទាំងមហោស្រព ទាំងថ្ងៃទាំងយប់
សព្វសូរដន្ត្រី ឮលាន់រណ្តំ សេពសមទុំយប៉ី
ត្រែស័ង្ខវែងខ្លី រនាតពាតគង ។ ព្រះបាទសិសៅវ៍
ស្តេងស្តេចគង់នោ សោយពាជ្យគ្រប់គ្រង សុខសាន្តប្រក្រតី
ឥតបីមានហ្នង ថ្កើងយសកន្ទុង លែងស្តេចនានា ។
ស្តេចទ្រង់ទសពិធ ពាជធម៌ដោយក្រឹត្យ ពុំមានឃ្លាតឃ្លា
រក្សាសីល ៥ សីល ៨ ណា ព្រះទ័យសទ្ធា
ធ្វើបុណ្យឲ្យទាន ។ ចែកចាយអស់ទ្រព្យ គ្រប់គ្រឿងប្រជាប់
សម្រាប់មែនមាន ឯសុមយ៉ាចក ពុតអត់ឃ្លាន
តែងចូលយកទាន សព្វថ្ងៃប្រក្រតី ។ ស្តេចតែងសង្ឃឹត
ប្រតិបត្តិពុំឃ្លាត សព្វសីល ៨ តាមដោយទម្ងាប់
ពីបុរាណឱ្យ ដូចជាពោធិ – សត្វត្រៃឥន្ទាយណា ។
ព្រះចៅមហាក្សត្រ សោយពាជ្យសម្បត្តិ សុខសាន្តមហិមា

ភស្តុតាសសម្បុរ ហៀរហូរកោតា ចោរឱ្យក្តីណា
ពុំមានឡើយហោង ។

មានកាល ១ ថ្ងៃ ភត្តិសម័យ ក្សត្រថ្ងៃច្បាស់ច្បង
ចរបូលបន្ទំ មនោរម្យតហ្មង លង់លក់ជាម្តង
ភត្តិនោះណា ។ ស្តេចទ្រង់យល់សប្តិ និមិត្តជាអត -
មង្គលរមហិមា ដូចជាកំពូល ច្រាសាទថ្ងៃថ្ងា
ចាក់ចែកពីគ្នា ធ្លាក់ចុះដល់ដី ។ ទើបព្រះពជា
តើនចាកនិទ្រា កណ្តាលភត្តិ គន់គិតរំពឹង
រឹងភ័យអស់ក្តី ព្រួយណាស់ចក្តី ក្រៀមក្រំកក្តា ។
ព្រះអង្គគន់គិត ដ្បិតយល់និមិត្ត ហាក់ថ្ងៃកន្ទេះណា
រន្ធត់អស់អង្គ ស្រយង់កាយា . ព្រួយព្រះចិត្តា
ក្នុងភត្តិយប់ ។ លុះព្រឹកព្រាងព្រះ សុរិយារឿងរះ
ព្រះអង្គគិតថប់ ចុះចាកសយនា ក្សត្រាសញ្ជប់
ថប់ហើយរឹងថប់ ផ្កុកៗមមៃ ។ . ស្តេចទ្រង់ចិន្តា
គិតត្រង់ថប់ថា នុសប្តិនេះនៃ នឹងកើតជាហេតុ
កេទអាក្រក់ក្រៃ វិបរិតចង្រៃ ដល់អញដឹងក៏ ។
ឬមួយនឹងទៅ ត្រូវនាងស្រែ៧ កវិយាអញណា
ប៉ុន្តែនឹងអន្តរាយ ដល់នគរ ឬកស្តេចជា -

មាត្យមុខមន្ត្រី ។ ជាន់ជាជ្រែជាសាខ ប្រសើរស្អាងស្អាត
ជាក់ជ្វាក់ដល់ដី ឬមានកលិយុគ កើតទុក្ខអ្វី ។
ឬដល់ក្ស័យដី - រឹតម្តេចទៅអើយ ។ ព្រះអង្គរឹងថប់
គិតដៅទៅគ្រប់ ឥតឯមានស្បើយ កង់ព្រះហ្ឫទ័យ
ក្សត្រៃថ្ងៃត្រាណត្រើយ ផ្អែកផ្អៀងគេសតើយ សញ្ជប់កក្តា ។
ពេលនោះឯងហោង វិបល្យាស ៥ ភង កើតដល់រាជា
១ គឺក្តួលក្តៅ ហ្មង់សៅចិត្តា ២ គឺកាយា
មានញើសហូរភ្លុយ ។ ៣ គឺកាយា សៅហ្មង់វណ្ណា
៤ គឺព្រះកាយ រន្ធត់ស្ងោរស្ងប់ ចំប្រប់សព្វសាយ
៥ គឺវៃបក្សាយ ងងឹតនេត្រា ។ ព្រះបាទចមកព
តក់ស្លុតចំប្រប់ សាយសព្វរោមា រំជួលអស់អង្គ
ស្រយង់កាយា ត្រាស់ប្រើអមច្ចា ទៅហៅគ្រូពេទ្យ ។
ក្សត្រិណានោះអមច្ច ចង្គុំវន្ទា ក្សត្រាពណ្ណាយ
រួតរត់ដល់ទៅ លំនៅហោរានាយ ស្រែកជាប់ពីឆ្ងាយ
ជ្រុតប្រើប្រញាប់ ។ ថាវៃហោរា ស្តេចមានបញ្ជា
“ឲ្យទៅធាប់ៗ កុំបង្អង់នៅ ចូលទៅប្រញាប់”
ហោរាស្តែងស្តាប់ ចាប់យកដំរា ។ ដ៏សក្តារឆន
ប្រដាប់ប្រៀបរៀបខ្លួន ស្រេចហើយយាត្រា រួតរត់មកដល់
មណ្ឌលជ្រាង្គជ្រា - សាទហើយម្ដីមា ត្រាបថ្វាយបង្គំ ។ (មានត)

ឧកញ៉ាវិបុលរាជសេនា ង្ហួ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ទំនងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

កណ្ឌទី ១៩

តាំងពីឡើងពីនឹងតាំងសុំនរួមគំនិតគ្នានឹងសម្លាប់ចូរ្ហ រហូតដល់ក្លួនអ៊ូសម្លាប់ គឺ-មៅ, តៀវហ៊ុយសម្លាប់គ្រប់គ្រួគឺ-មៅ ឡើងមានសេចក្តីព្រួយខ្លាចចូរ្ហ ។

ឡើងពីទទួលពាក្យតាំងសុំនហើយកាលណា នឹងធ្វើការអ្វី ។ ក៏ឲ្យគិតខ្លាចចូរ្ហនឹងមិនទុកចិត្ត ទើបភ្លែងធ្វើបន្ទាយខ្លួនយកឈើមកច្រុះធ្វើជាសម្រាសរបងជាំសួនច្បារបន្ទៃបង្ការគ្រប់មុខរៀងរាល់ថ្ងៃ ។ ក្លួនអ៊ូ, តៀវហ៊ុយនិយាយនឹងឡើងពីថា ការណ៍ដែលត្រូវគិត ម្តេចមិនរិះគិត? បងមកធ្វើដូចជាមនុស្សថោកទាបដូច្នេះមិនគួរសោះ ដែលបងធ្វើដូច្នេះតើជាប្រយោជន៍អ្វី? ។ ឡើងពីតបថា ប្អូនតាំង ២ មិនបានដឹងដល់គំនិតដែលបងគិតនោះទេ កុំមកស្តីបន្ទោសឲ្យវេរចិត្តគំនិតឡើយ ។ ក្លួនអ៊ូ, តៀវហ៊ុយ ក៏ឈប់សៀម ។

ថ្ងៃមួយនោះ មានមនុស្សនាំរឿងទៅនិយាយប្រាប់ចូតូថា ឡៅពី ធ្វើចម្ការដាំច្បារសួនខ្លួនឯងសព្វ ៗ ថ្ងៃ ។ ចូតូក៏ប្រើទៅជូនពីរតៀវលៀវ ហើយនឹងតាហានចំនួន ២០ នាក់ទៅអញ្ជើញឡៅពី ។ ទៅដល់, តៀវលៀវចូលទៅក្នុងផ្ទះឡៅពី មិនឃើញគួនអ៊ូតៀវហ៊ុយ ឃើញតែឡៅពីកំពុងដាំបន្លែក្នុងច្បារសួន ក៏ចូលទៅជំរាបឡៅពីថា មហាឧបរាជឲ្យខ្ញុំមកអញ្ជើញលោកទៅ ។ ឡៅពីភ័យស្មុតក្នុងចិត្តក៏សាកសួរថា មហាឧបរាជឲ្យមកហៅខ្ញុំដោយមានការអ្វី? ។ ទៅដូចថា មានការអ្វីខ្ញុំបាទក៏ពុំអាចដឹង ។ ឡៅពីមិនហានមានកំរៀបខ្លួនទៅជាមួយនឹងទៅដូ, តៀវលៀវ ។ ចូតូឃើញឡៅពីទៅដល់ក៏ចំអនថា អ្នកនៅផ្ទះសព្វថ្ងៃនេះធ្វើការធំមាំមួនណាស់ ។ ឡៅពីឮចូតូថាដូច្នោះ នឹកស្មានក្រែងចូតូដឹងសេចក្តីក៏ភ័យស្មុតក្នុងចិត្តស្ងៀមនៅ មិនធ្វើឃើញតបថាដូចម្តេចសោះ ។ ចូតូក៏ចាប់ដឹកដៃឡៅពីនាំចុះទៅក្នុងសួនច្បារខាងក្រោយផ្ទះ ហើយនិយាយថា អ្នកនៅផ្ទះរិះគិតធ្វើសួនដំណាំដាំបន្លែបង្ការ ប្រហែលសួនច្បារបស់យើងដែរឬ? ។ ឡៅពីយល់ថា ចូតូមិនមែនដឹងដល់កំហុស្រាលក្នុងចិត្តធ្វើឃើញតបថា ខ្ញុំបាទមកទីពឹងជ្រកកោនបុណ្យលោកសព្វថ្ងៃនេះមិនមានការអ្វីនឹងធ្វើឲ្យពេញកំឡាំង បានជាធ្វើសួនច្បារតែអផ្សុក តែនឹងបានធ្វើឲ្យពេញមុខដូចសួនច្បារបស់លោកក៏ទេ ។

ចូតូអង្គុយនិយាយលេងជាមួយនឹងឡៅពី កំប្រឡែកឃើញផ្ទៃកន្ទុត ១ ដើមកំចង្អុលឲ្យឡៅពីមើលហើយថា កាលយើងទៅច្បាំងនឹង

តៀវស៊ីវ៉ា ឪហានទាំងពួងស្រែកទឹកណាស់ យើងក៏គិតកលៗបាយ បញ្ឆោតថា ឲ្យៗសឹ្បាហ៍ខំដើរបន្តិចទៅទៀតចុះ នឹងបានជួបប្រទះព្រៃកន្ទុតផ្លែច្រែនណាស់នៅឯមុខ ឪហានទាំងអស់បានពួកចេញឈ្មោះផ្លែកន្ទុតជាមួយ ក៏ហូរចេញទឹកមាត់គ្រប់ៗគ្នា ណាវដែលស្រែកទឹកនោះក៏អន់ស្រែកទៅវិញ ។

ខ្ញុំពីសរសើរបូតូថា ប្រាជ្ញាឈ្លាសវៃនៃលោកនឹងរកនរណាស្មើគ្មាន ។ បូតូក៏អញ្ជើញខ្ញុំពីឲ្យអង្គុយលើកៅអីក្នងទីសួនត្រជាក់ហើយសេពសុភស៊ីផ្លែកន្ទុតនោះជាកំសាន្តសប្បាយ ។

កាលបូតូនឹងខ្ញុំពីផឹកស្រាស៊ីផ្លែកន្ទុតជាមួយគ្នានោះ. ក៏បណ្តាលខ្យល់ក្បុះសង្ឃរាមេឃងងឹតធ្លាក់ភ្លៀងរំលា ឪហានទាំងមនុស្សម្នាស្រែកថា ម្តេចសំដែងរិទ្ធិលើអាកាសបានជាកើតអស្ចារ្យដូច្នេះ ។ បូតូនឹងខ្ញុំពីបានឮមនុស្សម្នាស្រែកដូច្នោះ ក៏ងើយមើលទៅលើអាកាសឃើញមេឃងងឹតខ្លាំងក៏ដឹងថា ម្តេចសំដែងរិទ្ធិ បូតូបង់ដឹងប្រាជ្ញាខ្ញុំពីទើបក្តែងសួរថាអ្នកដឹងឬទេ គឺម្តេចសំដែងរិទ្ធិបានជាងងឹតដូច្នេះ? ឯរិទ្ធិម្តេចនោះតើមានប៉ុន្មានយ៉ាង? ។ ខ្ញុំពីក្តែងធ្វើជាមិនដឹងថា ម្តេចសំដែងរិទ្ធិមានប៉ុន្មាន។ ខ្ញុំពុទមិនអាចដឹងទេ ។ បូតូថា ម្តេចសំដែងរិទ្ធិនោះ ន៏ងធ្វើឲ្យធំឲ្យតូចដូចម្តេចក៏ចេះតែបាន បើនឹងហោះឡើងទៅលើអាកាស ហើយសំដែងរិទ្ធិផ្សេង ។ នោះអាកាសនោះចង្អៀតក្តីខ្លួយក្តីក៏អាចធ្វើឲ្យទៅតាមរិទ្ធិបាន

សូម្បីនឹងហោះចុះក្នុងផ្ទៃមហាសមុទ្រ ធ្វើរន្ធឲ្យរូបកាយនោះតូចទៅបូល ទៅជ្រកនៅក្រោមបាតក្អមក៏បាន ឯទេសៈកាលៈនេះជារដូវក្តៅឯងបានជាម្ចាស់ដែងរិទ្ធីដូច្នេះ ។បមាដូចជាមនុស្សមានសតិបញ្ញាជ្រៅទូលាយ បើនឹងធ្វើការក៏គ្រេគិតតាមសេចក្តីសមគួរ ទោះបីឃើញថាការនោះធំ ក៏ធ្វើឲ្យធំ បើការនោះតូចក៏ប្រមាណការធ្វើឲ្យតូចទៅ សព្វថ្ងៃនេះនរណាខ្លះដែលមានសតិបញ្ញាដូចម្ចាស់ដែងរិទ្ធីនោះ? ចូរអ្នកអធិប្បាយឲ្យច្បាស់មកចុះ ។ ឮពាក្យក្តែងតបថា ខ្ញុំបាទមិនសូវមានបញ្ញាទេ ដែលនឹងបានបុណ្យសក្តិជាមន្ត្រីខ្ញុំរាជការប៉ុណ្ណេះ ក៏ព្រោះគុណមហាឧបរាជជួយទូលស្តីឲ្យខ្ញុំបាទក៏បានសេចក្តីសុខរៀងមក ដែលនឹងដឹងថា អ្នកឯណាមានសតិបញ្ញាជ្រៅជ្រះទូលាយដូចម្ចាស់ដែងរិទ្ធីនោះ ដំរែះខ្ញុំបាទគិតមិនដល់ទេ ។ បូតូបានឮដូច្នោះក៏ត្អូញថា គំនិតនឹងដំរែះប្លាជ្ញារបស់អ្នកមានប្រាកដហេតុម្តេចអ្នកក្តែងចរចាបន្ទាបបន្ទោកខ្លួនដូច្នេះ ទោះបីមិនមានបញ្ញាគិតឲ្យឃើញរហូតទៅបាន ក៏គង់មានឮថាស់ប្បុរិប្បញាណនិយាយហើយនឹងដឹងថា អ្នកនេះអ្នកនោះជាមនុស្សមានសតិខ្លះទៅដែរ ។ ឮពាក្យក្តែងថា ខ្ញុំបាទបាននឹកឃើញថា សព្វថ្ងៃនេះអ៊ួនស៊ីតចៅហ្វាយស្រុកឡាំយ៉ុងមានសតិបញ្ញាឆ្លៀវឆ្លាតណាស់ សេនាឥសាននាំគ្នាចូលក៏មានថ្លៃដៃខ្លាំងឮតែច្រើន ពាំងស្បៀងអាហារក៏បរិបូណ៌ ។ បូតូបានឮដូច្នោះក៏អស់សំណើចហើយតបថា អ៊ួនស៊ីតនោះមានឧបមាដូចសពនៅកងរណ្តៅ,

ដែលនឹងពាប់ថាមានសតិបញ្ញានោះមិនត្រូវសោះ តែគំនិតមារយោគអ្នន-
ស៊ុតនោះ ខ្ញុំនឹងចង់យកមកកំចាន់ដោយងាយណាស់ ។

ខ្ញុំពីថា អាណាខែត្រនៅទិសខាងដើងខ្ញុំបានឃើញថា អ្នកនេសៀវ
ចៅហ្វាយស្រុកគីជីវ ជាបងអ្នកស៊ុតនោះ ក៏មានពួជជានាហ្នឹងតៗ គ្នា
មក ៣-៤ ដំណាហើយ តម្លៃវអ្នកនេសៀវក៏បរប្រមូលសេនាគាហានបាន
ច្រើន តាំងមានទីប្រឹក្សាក៏ច្រើននាក់ ខ្ញុំបានពិគ្រោះមើលទៅឃើញថា
អ្នកនេសៀវមានសតិបញ្ញាមុតមាំធំជ្រៅទូលាយ ។ ចូរឆ្លងថា អ្នកនេសៀវនោះ
ជាមនុស្សឆ្កួតបុណ្យស័ក្តិណាស់ មានតែសេចក្តីខ្វាច គិតការអ្វីបង់
ច្រើនបានតិច ដែលនឹងពាប់ថាជាមនុស្សមានសតិបញ្ញានោះមិនត្រូវ ។
ខ្ញុំពីថា ខ្ញុំពៀវចៅហ្វាយស្រុកគេងដីវមានស្រុកធំៗ ឡើងជាចំណុះ
ដល់ ៩ មណ្ឌល ចិត្តថ្លើមក៏ល្អជាមនុស្សប្រសកយកពាប់អានពួកមាក មាន
សេនាគាហានក៏ច្រើន ខ្ញុំបានយល់ឃើញថាជាមនុស្សមានសតិបញ្ញា
បានជាធ្វើការឲ្យគេចុះបូលជាច្រើនដូច្នេះ ។

ចូរឆ្លងថា ខ្ញុំពៀវនោះមានពួកមាកច្រើនក៏មែន តែជាមនុស្សមិន
មានសេចក្តីសត្យសុចរិត ចានតែមាត់ផ្អែម ទើងពាប់ថាជាមនុស្សមានសតិ
បញ្ញាក៏មិនត្រូវ ។ ខ្ញុំពីថា ស៊ុនសិកចៅហ្វាយស្រុកកាំងតាំងនោះ
នៅក្នុងកំពែរមានកម្លាំងខ្លាំងពូកែសេនាគាហានក៏ច្រើន ខ្ញុំបានឃើញ
ថាជាមនុស្សមានគំនិតមារយោគមាំមួន ត្រូវតុកជាសេនាម្នាក់មានថ្លើដែ

ខ្ញុំឯងពួកគែ ។ ចូរឆ្លូថា ស៊ុនសិកនោះមានថ្លៃដែជាប្រមាណ ដោយសារ
បានតាហានរបស់ស៊ុនគឿនជាបិតាទុកជាកម្ចាំងតមក ទើបកំរើបចិត្ត,
ដែលនឹងពាប់ថាជាមនុស្សមានគំនិតគិតល្អ នោះយើងមិនទាន់ឃើញផង
ទេ ។ ឡៅពីថា ខាងអាណាខែត្តទិសឯលិចនោះ ខ្ញុំបានឃើញ
ឡៅដៀងចៅហ្វាយស្រុកសែឈួន មានសតិបញ្ញា ហើយជាពូជ
ព្រះមហាក្សត្រមកអំពីមុន ។

ចូរឆ្លូតបថា ជាពូជព្រះមហាក្សត្រក៏មែន តែជាមនុស្សមិនចេះគិត
ការអ្វីសោះ ឧបមាដូចសុនខ្ចាំទ្វារផ្ទះ ដែលនឹងពាប់ថាជាមនុស្សមាន
សតិបញ្ញានោះក៏មិនមែន ។

ឡៅពីទើបសួរថា តៀវស៊ីវ ១, តៀវឡ ១, ហាន់ស៊ុយ ១ ទាំង ៣
នាក់នេះលោកយល់ឃើញយ៉ាងម្តេច ? ។ ចូរឆ្លូបានឮដូច្នោះក៏ទះដៃអស់
សំណើចហើយថា ឯតៀវស៊ីវ, តៀវឡ, ហាន់ស៊ុយនោះ ជាមនុស្ស
មានតែឈ្មោះ នឹងលើកយកសេចក្តីគិតការអ្វីជាប្រាកដគ្មានសោះ អ្នក
យកមកនិយាយធ្វើអ្វីឲ្យពេយមាត ឯមនុស្សដែលមានសតិបញ្ញានោះ បើ
នឹងគិតការអ្វីក៏ជ្រៅជ្រួលាយពេកពាប់អ.នអ្នកទាំងពួង ឧបមាដូចបុគ្គល
លេបតែវដ៏ជាធំពួកទុកក្នុងនោះ បើនឹងទៅទីស្ងាត់ឯណា ពោះជាពេលយប់
ងងឹតក៏លិចប្រុះធ្លុះទៅដោយពន្លឺស្មើតែវ បើនឹងគិតការអ្វីក៏ដឹងច្បាស់ការ
ធ្ងន់ការស្រាលបាននឹងបង់ ចេះចែកវិលែកមិនឲ្យអ្នកឯណាកន្ទុងដឹងដល់
គំនិតប្រាជ្ញ ទើបគេពាប់ហៅថាអ្នកមានសតិបញ្ញាជ្រៅជ្រួលាយ ។

ឡៅតីបានស្តាប់ដូច្នោះទើបក្លែងតបថា សព្វថ្ងៃនេះនឹងរកអ្នកឯណាឲ្យមានសតិបញ្ញាដូចមហាឧបរាជថានោះគ្មានសោះ ។ ចូឆូថា សព្វថ្ងៃនេះយើងសំឡឹងមើលអ្នកមានសតិបញ្ញានោះសូន្យហើយ មានតែខ្លួនអ្នកនឹងខ្ញុំ ២ នាក់ប៉ុណ្ណោះ ។ ឡៅតីឮចូឆូថាដូច្នោះ ក៏ធ្វើជាស្ងុតរន្ធត់ចិត្តធ្លាក់ចង្កើះរបូតចេញពីដៃទួលឮសំឡេងរន្ទះផ្គរ ឡៅតីក៏ធ្វើភ័យក្លាក់យកដៃទប់ត្រចៀក ។ ចូឆូឃើញដូច្នោះក៏អស់សំណើចហើយថា តើតមកជាកូនប្រុស ហេតុម្តេចក៏ភ័យខ្លាចនឹងសំឡេងផ្គរដូច្នេះ ។ ឡៅតីថាបូរាណដំណាលទុកមកថា បើមានផ្គរន្ទះឲ្យរាំងរក្សាខ្លួនឲ្យណាស់ ។ ចូឆូមិនបានដឹងកលក៏អស់សង្ឃឹយ ទឹកតែក្នុងចិត្តថា "ឡៅតីជាមនុស្សខ្លាចណាស់ នឹងគិតធ្វើការធំតទៅមិនបាន" តាំងពីថ្ងៃនោះតមកចូឆូក៏មិនមានរឯងវែកខ្លាចគំនិតប្រាជ្ញាឡៅតី ។

ឯគួនអ៊ូនឹងតៀវហ៊ុយដែលទៅហាត់ប្រាញ់ផ្លូនោះ លុះត្រឡប់មកមិនបានឃើញឡៅតី ក៏សួរមនុស្សក្នុងផ្ទះថា បងយើងទៅណា ? ។ មនុស្សបំរើក៏ប្រាប់ថា ចូឆូឲ្យមកអញ្ជើញទៅយូរហើយ ។ គួនអ៊ូ, តៀវហ៊ុយឮថាដូច្នោះ ក៏ភ័យស្ងុតស្មារតីខ្មាក់ធ្លាចាប់យកក្រប៉ាវរៀសវៃទៅតាមឡៅតី លុះទៅដល់ទ្វារផ្ទះចូឆូ អ្នកចាំទ្វារឃាត់មិនឲ្យចូល គួនអ៊ូ, តៀវហ៊ុយក៏មិនស្តាប់ដើរចូលទៅក្នុងផ្ទះចូឆូ ដឹងថាចូឆូនាំឡៅតីទៅអង្គុយក្នុងសួនច្បារ គួនអ៊ូ, តៀវហ៊ុយក៏តាមទៅ ។ ឯចូឆូកំពុងអង្គុយធឹកស្រា

ជាមួយនឹងខ្លៅពីក្រឡេងយើញគួនអ៊ូ, តៀវហ៊ុយកាន់ក្រប៉ដើរចូលមក ក៏សួរថា អ្នកចាំង ២ កាន់ក្រប៉ដើរចូលមកធ្វើអ្វី? ។ គួនអ៊ូ, តៀវហ៊ុយ ឆ្លើយថា ខ្ញុំបាទដឹងថាមហាឧបាជហៅខ្លៅពីមកបរិភោគលេងនៅទីនេះ បានជាខ្ញុំបាទមកកាំក្រប៉ជូនឲ្យលោកមើលកំសាន្ត ។

ចូធូថា អ្នកឯងមកធ្វើដូច្នេះ ដូចមានរឿងក្នុងចុតហ្វាយកត់ហេតុ ឬកណាកាលគ្រាព្រះចៅឈប៉ាអង គិតប្រទូសរ៉ាយព្រះចៅខ្លៅចាំង ព្រះ ចៅឈប៉ាអងអញ្ជើញព្រះចៅខ្លៅចាំងទៅសោយក្រយាស្ងោយ ហើយ គិតកល់ទុយឲ្យហាន់ដួងចេញកាំក្រប៉ បំណងនឹងប្រទូសរ៉ាយព្រះចៅ ខ្លៅចាំង ហួនគុយប្អូនថ្លៃព្រះចៅខ្លៅចាំង យើញហាន់ដួងកាំក្រប៉ចូល មកជិតក៏មិនខុកចិត្ត ទើបនិយាយថា "ឯក្មេងក្រប៉នោះ នឹងកាំតែ ម្នាក់ឯងមិនក្អមើលទេ យើងនឹងចេញកាំទល់ទើបល្អ" ហើយហួនគុយ ក៏ហូតក្រប៉ក្រែកខ្លៀងកាំផង ហាន់ដួងលើកក្រប៉ខ្លៀងនឹងកាប់ព្រះចៅ ខ្លៅចាំង ហួនគុយក៏យកក្រប៉រងជាប់ ជានជាព្រះចៅខ្លៅចាំងមិន មានសេចក្តីអន្តរាយ; ឯខ្លួនយើងគ្រានេះ នឹងបានគិតប្រទូសរ៉ាយខ្លៅពី ឲ្យដួចព្រះចៅឈប៉ាអងគិតប៉ងនឹងប្រទូសរ៉ាយព្រះចៅខ្លៅចាំងដូច្នោះ ក៏ទេ ដែលអ្នកនឹងមកធ្វើដូច្នេះមិនគួរ ។

គួនអ៊ូ, តៀវហ៊ុយឆ្លើយថា ខ្ញុំបាទមិនមែនគិតធ្វើដូច្នោះទេ បើលោក នៅសង្ស័យហើយខ្ញុំបាទក៏មិនកាំ ។ ចូធូក៏ប្រើមនុស្សបំរើមនុស្សចាក់ស្រា

ឲ្យគួនអ៊ូ, តៀវហ៊ុយផឹក ។ លុះពេលរសៀល ឡៅពី, គួនអ៊ូ, តៀវហ៊ុយ ក៏គំនាប់លាចូធូនាំគ្នាត្រឡប់ទៅផ្ទះវិញ ។ គួនអ៊ូនិយាយនឹងឡៅពីថា ខ្ញុំត្រឡប់មកពីហាត់ចាញ់ធ្នូដឹងថា ចូធូឲ្យហៅលោកទៅ ខ្ញុំបាទភ័យណាស់ គិតសង្ស័យថា ចូធូនឹងធ្វើលោកយ៉ាងម្តេចមិនដឹង ទើបនាំគ្នាស្រែកទៅតាមលោក ។ ឡៅពីក៏អធិប្បាយវាយវឿងឲ្យគួនអ៊ូ, តៀវហ៊ុបស្តាប់គប់ប្រការថា ចូធូនាំទៅផឹកស្រាស៊ីផ្លែកន្ធតកង់សួន ។ គួនអ៊ូថា ដែលចូធូធ្វើដូច្នេះ បងនឹងយល់ឃើញដូចម្តេចខ្លះ? ។ ឡៅពីថា បងគិតធ្វើសួនច្បារដាំបន្ទៃបង្ការ ក្រែងដើម្បីនឹងឲ្យចូធូអស់សេចក្តីសន្ទុះសង្ស័យថា យើងផុតសេចក្តីរិះគិតការអ៊ូហើយ កាលចូធូបបួលស៊ីលៀងនិយាយសរសើរថា បងមានដំរេះក្រែងជា ខ្ញុំលឺសំឡេងផ្គរន្ទះបងធ្វើហាក់ជាភ្ញាក់ធ្លាក់ចង្កើះពីដៃ ហើយយកដៃខ្ទប់ត្រចៀក ចូធូក៏អស់សេចក្តីសង្ស័យ ។ គួនអ៊ូ តៀវហ៊ុយថា បងរិះគិតធ្វើចំបាយដូច្នេះល្អណាស់ ។

(មានត)

ជាលៈនឹងទមយន្តី

រឿងព្រេងប្រទេសឥណ្ឌៀ

អ្នកស្រីត្រពែង-សារីយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីភាសាបាលីមកជាភាសាខ្មែរ

(តមក)

ព្រះអគ្គមាស់ប៉ុស្ការៈ មានបន្ទូលនឹងកាលីថាៈ "ព្រះឥន្ទ្រាធិរាជនៅថែរក្សាព្រះបាទនាលៈ, ព្រះឥន្ទ្រាធិរាជមានអានុភាពជាងឯង" ។ កាលីតបទៅព្រះអគ្គមាស់ប៉ុស្ការៈវិញថាៈ "ប្រាកដមែនហើយ ព្រះឥន្ទ្រាធិរាជទំនុកបំរុងព្រះបាទនាលៈ ពីព្រោះស្តេចគោតមសាសនាណាស់ហើយដកបណាតែទ្រង់បានប្រព្រឹត្តដោយចិត្តស្មោះស្ម័គ្រតាមប្រពៃណីដកបនោះព្រះឥន្ទ្រស្ថិតនៅជាមួយនឹងទ្រង់ជានិច្ច, ប៉ុន្តែ បើទ្រង់ធ្វេសប្រហែសឬប្រព្រឹត្តល្មើសវេលាណា ព្រះឥន្ទ្រនឹងចេញចោលព្រះអគ្គមិនខាន ពេលនោះព្រះបាទនាលៈនឹងធ្លាក់មកនៅក្នុងកណ្តាប់ដៃយើង, បើដូច្នេះចូរទ្រង់ស៊ូអំណត់តទៅទៀត កុំអាលបណ្តោយឲ្យព្រះទ័យធ្លាក់ទៅដល់អស់សេចក្តីសង្ឃឹម" ។ ប៉ុន្តែព្រះអគ្គមាស់ប៉ុស្ការៈ លែងដៀវាក្យកាលីទៀត ។ ចួនកាលដោយនឹកឃើញគ្នានរំពឹងនឹងបានសោយរាជ្យក្នុងប្រទេសនិសធៈ ទ្រង់តូចព្រះទ័យដល់ទៅទ្រង់ព្រះកន្សែង ។

*

* *

វគ្គ ទី ១៥

ថ្ងៃមួយ ព្រះបាទ នាល: ព្រះនាង ទមយន្តី នឹង ព្រះរាជបុត្រ ទាំង ពីរ នាំ គ្នា លេង បរបាញ់ សត្វ ។ ព្រះបាទ នាល: ឆ្កែ ជា សង្ឃ ព្រះនាង ទមយន្តី នឹង ព្រះរាជបុត្រ ឆ្កែ ជា ព្រាន ។ មិន យូរ ប៉ុន្មាន ល្បែង នោះ នាំ ឲ្យ សប្បាយ អស្ចារ្យ ព្រះរាជបុត្រា ខ្ញុំ បញ្ចេញ សេចក្តី ក្អាហាន ទោះ ឮ សូរ សង្ឃ គ្រហឹម សម្បើម យ៉ាង ណា ក៏ នៅ តែ ចូល លុក ។ ឯ ព្រះរាជបុត្រ ខ្ញុំ វិល ឃ្លាស ណាស់ ព្រះនាង ប៉ុន ប្រសប់ ឆ្កែ អន្ទាក់ យ៉ាង ចំណាន ទុក ជាក់ សង្ឃ បើ សង្ឃ ជាប់ អន្ទាក់ ហើយ មិន ងាយ នឹង ចេញ រួច ។ ព្រះបាទ នាល: នឹង ព្រះនាង លុះ ឃើញ ស្នា ព្រះហស្ត ព្រះរាជបុត្រ ដូច្នោះ ខ្ញុំ សព្វ ព្រះរាជ ហឫទ័យ ពន់ពេក ។ សង្ឃ នឹង ព្រាន ប្រដេញ គ្នា ពេញ តែ ទ្រព្យ ន នៅ ពេល ដែល ព្រាន ចាប់ ក្បាល សង្ឃ បាន ខ្ញុំ ព្រះ សំរួល លះ ន់ ព្រំ ពង ។

ព្រះ អាទិត្យ ផ្លែ ឈើ សំយុង ទៅ ទិស បស្ចិម ប៉ុន្តែ ល្បែង នៅ តែ លេង តទៅ ទៀត ។ បន្តិច ទៅ ភក្តី ទម្លាក់ ស្បែ ភ្លៅ គ្រប ផែន ដី ងងឹត សូន្យ ; កាល នោះ ព្រះនាង ទមយន្តី គិត ខ្វាច ព្រះរាជបុត្រ អស់ កម្លាំង ក៏ នាំ ព្រះរាជ-បុត្រ ចូល ទៅ ក្នុង ច្រាស ទ ព្រះបាទ នាល: ខ្ញុំ យាង ចូល វែ តែ យាង តាំង ស្តាយ ល្បែង ។ ព្រះបាទ នាល: ខ្ញុំ មាន សេចក្តី រីក រាយ ឆ្ងល់ ដោយ បាន ពិនិត្យ ឃើញ ព្រះរាជបុត្រ មាន សេចក្តី ក្អាហាន ឆ្ងល់ ជា ពៃរ៍ ខ្លាត ។ ប្រពៃ ហលជា ព្រះបាទ នាល: ខ្ញុំ មិន ដែល ជួប នូវ សេចក្តី រីក រាយ ដូច ថ្ងៃ នេះ ។

នៅយប់នោះ ព្រះអគ្គមាស់ប៉ុស្ការៈយើញកាលីមកទៀត, អាទិទេព សើចបញ្ចេញចិត្តសាហាវហើយនិយាយទៅកាន់ទ្រង់ថា: "ប៉ុស្ការៈ! ប៉ុស្ការៈ! ប៉ុស្ការៈ! ទ្រង់មុខតែបានសប្បាយហើយ បងទ្រង់ទើបតែនឹងចាប់ត្តលើសលើពួកអមតបុរស" ។

- "បងខ្ញុំមិនមែនដូច្នោះទេ ឯងការខ្ញុំទៀតហើយ" ។

- "ទេ ព្រះចាទនាលៈរាល់តែលេងកំសាន្តនឹងព្រះពាជបុត្រ ខាល់តែក្មេងពេលសូត្រធម៌មិនមស្សការព្រះអាទិទេព ។ នឹងថយចោលព្រះចាទនាលៈមិនខាន" ។

ព្រះអគ្គមាស់ប៉ុស្ការៈ ស្តាប់ពាក្យកាលីហើយក៏មានសេចក្តីត្រេកអរពន់ពេក ហើយពោលហឹម ។ ថា: "ស្តេចសោយពាជ្យ! អញជានស្តេចសោយពាជ្យ!" ។

អាទិទេពនិយាយទៀតថា: "ឥឡូវត្រូវទ្រង់ស្តាប់បង្គាប់យើង: ស្អែកនេះ កុំក្មេងទៅចាំស្តាត់ផ្លូវស្តេច, យើងមិនដឿថា ក្នុងខណៈនេះព្រះចាទនាលៈប្រកែកទៀតទេ" ។

- "ខ្ញុំស្តាប់ឯង ខ្ញុំស្តាប់បង្គាប់ឯង ដែលជាអាទិទេពមានឫទ្ធិ" ព្រះអគ្គមាស់ប៉ុស្ការៈអរណាស់ សើចផង លោតផង ហើយនិយាយតិចៗផងថា: "អញជាស្តេចសោយពាជ្យ! អញធ្វើជាស្តេចសោយពាជ្យ!" ។

*
* *

វគ្គទី ១៦

ស្អែកឡើងព្រះអង្គម្ចាស់ប៊ុស្ការៈ ទ្រង់យាងទៅជិតស្ពេច ហើយទូលថា: "ប្រហែលជាទ្រង់ទើបនឹងដំនុំការណ៍អ្វីមួយដ៏សំខាន់ឬ? ព្រោះព្រះភមបែបដូចជាអស់ព្រះកាយពល តើព្រះអង្គសព្វព្រះរាជហឫទ័យនឹងលេងជាមួយទូលព្រះបង្គំបានមួយស្របក់ឬទេ? នុ៎ះហ្នឹងល្អក់ឡាក់" ។

ព្រះចៅទនាល:ទ្រង់បែបរួញរាមួយស្របក់ រួចមានព្រះបន្ទូលថា: "ល្អកឡាក់! បងធ្លាប់លេងឈ្នះកាលពីមុន ហើយបងមានលេងយូរណាស់មកហើយ ដូច្នេះប្អូនមកលេងជាមួយនឹងបង ប៊ុស្ការៈចូរយកគ្រាប់ល្អកឡាក់មក" ។ ពួកអ្នកតាមហែព្រះអង្គទាំងប៊ុន្មាន នាំគ្នាធ្វើនឹងការសម្រេចព្រះទ័យរបស់ទ្រង់ ។ ព្រះចៅទនាល:ទ្រង់គង់ចាប់យកគ្រាប់ល្អកឡាក់ ហើយមានព្រះបន្ទូលថា: "បងដាក់ចិញ្ចៀននេះ!" ហើយទ្រង់ចោះចិញ្ចៀនមួយដ៏វិចិត្រ ទៅមុខព្រះអង្គម្ចាស់ប៊ុស្ការៈ។ ឡើងគង់នៅខាងមុខព្រះចៅទនាល: ដោយគ្មានប្រញាប់ប្រញាល់ទេ ។ នៅពីក្រោយព្រះចៅទនាល: ព្រះអង្គម្ចាស់ទតឃើញកាលី ទ្រង់យល់ថាមានតែទ្រង់មួយទេដែលមើលឃើញអាទិទេព ។ លុះលេងបន្តិចទៅចិញ្ចៀននេះ ចានទៅលើព្រះហស្តព្រះអង្គម្ចាស់ប៊ុស្ការៈ ។

ព្រះចៅទនាល:មានបន្ទូលថា: "ទើបតែចាញ់ម្តងទេ បងគង់តែឈ្នះវិញ ដល់ក្តារក្រោយ, យើងលេងម្តងទៀត" ។

ម្ដងនេះព្រះបាទ នាលៈ ដោះកងដែលទ្រង់ទៅព្រះសូរង្គដាក់ភ្នាល់, ទ្រង់ចាប់ឡុកឡាក់បោះទៅ, ព្រះអគ្គមហេសីប៉ុស្ការៈបោះក្រោយ កងនោះក៏បានទៅព្រះអគ្គមហេសីប៉ុស្ការៈ ។ ព្រះបាទនាលៈមានបន្ទូលថា "លេងទៀត" ។

ព្រះបាទនាលៈចេះតែលេង ។ ពាល់តែចាញ់អស់គ្រឿងអលង្ការនឹងសស្ត្រាវុធទាំងប៉ុន្មានដែលជាប់នៅនឹងព្រះអង្គ ។ បន្ទាប់មក ទ្រង់ក្រោកឡើងហើយមានព្រះបន្ទូលទៅកាន់ព្រះអនុជថា "ឯងហេងណាស់ល្ងង់នេះ ឯងយកគ្រឿងមាសពេជ្រនឹងសស្ត្រាវុធនេះទៅចុះ ស្អែកប្រហែលជាបងមានវាសនាល្អ មើលទៅ" ។

ព្រះពជាស្តេចយាងទៅជិតព្រះនាងទមយន្តី ដែលទ្រង់សំកុកចាំព្រះអង្គដោយទ្រង់ព្រះកន្សែងផង ។

* * *

វគ្គទី ១៧

ថ្ងៃបន្ទាប់មក ក្រោយពីការប្រឹក្សារដ្ឋមន្ត្រី ព្រះនាងទមយន្តីវង់ចាំព្រះកស្តាទៀត លុះព្រះនាងទន្ទឹងមើលផ្លូវមិនឃើញ ស្តេចយាងមកសោះ ព្រះនាងគិតថា: "ព្រះស្វាមីអញប្រហែលជាវង្វេងនឹងទ្រង់ ប៉ុស្ការៈដូចពីមុនមិញទៀតហើយ, យី! អ្នកកំណាចនេះនឹងក្ងេចអញទេដឹង?

ឥឡូវនេះ តែព្រះកស្តាចេញឆ្ងាយពីអញ។ ចេះតែមានចិត្តព្រួយ ចុះស្តេចកំណាចនេះនៅធ្វើអ្វីក្នុងព្រះរាជមន្ទីរដែលរចនាដោយទឹកមាសនោះ?" ។

ព្រះនាងមានបន្ទូលហៅនាងមលវិកា (Malavika) ដែលជាស្នំដ៏ទន់ ហើយប្រាប់ថា: "មលិកា! ចូរឯងទៅមើល តើស្តេចវៀលធ្វើអ្វី បើឯងឃើញស្តេចកំពុងលេងជាមួយព្រះអនុជ ចូរឯងក្រាបទូលព្រះអង្គ កុំលាក់សេចក្តីព្រួយរបស់អញចំពោះទ្រង់, ខ្ញុំព្រួយចិត្តពេកណាស់ នាងមលវិកាជាទីពេញចិត្តអើយ! ចូរឯងរត់ឲ្យឆាប់ ទៅនាំស្តេចជាទីស្រឡាញ់ដែលបោះបង់ចោលខ្ញុំ មកឲ្យខ្ញុំវិញ" ។

នាងមលវិកាក៏ធ្វើតាមបង្គាប់ព្រះនាង, ព្រះរាជបុត្រទាំងពីរព្រះអង្គក៏យាងចូលមករកព្រះមាតា ។ ព្រះនាងទ្រង់ថ្នមនុបកូនហើយមានព្រះបន្ទូលថា: "កូនសំឡាញ់ម្តាយ! បិតាកូននៅឯណា? ម្តាយព្រួយចាប់ផ្តើមណាស់, កូនសំឡាញ់នុបម្តាយមកកូន! ម្តាយត្រូវការនឹងស្នូរស្នាលរបស់កូន" ។

ព្រះនាងទ្រង់ប្រទងចាំព្រះសណ្តាប់ន្ទូរសំនួរទាំងឡាយ "ម្តេចបាននាងមលវិកាត្រឡប់មកវិញ? ទៅរកស្តេចឃើញឬមិនឃើញ? តើបានទូលស្តេចហើយឬនៅ?" ។ បន្តិចស្រាប់តែព្រះនាងមានបន្ទូលសួរថា "មលវិកាឬ?" ។ នាងមលវិកាចូលមកតែឯង ដោយមានទឹកមុខជ្រប់ស្រពោន ហើយទូលព្រះនាងថា: "ទេព្យស៊ីក្សត្រីដ៏ប្រសើរ!

ខ្ញុំម្ចាស់បានឃើញព្រះអង្គ ខ្ញុំម្ចាស់បានឮលព្រះអង្គហើយ ប៉ុន្តែព្រះអង្គ
គ្មានទ្រង់ព្រះសណ្តាប់ខ្ញុំម្ចាស់ទេ, ដឹងជាទ្រង់ឮខ្ញុំម្ចាស់ឮលឬមិនឮទេ,
ទ្រង់ចោះឡុកឡាក់ហាក់ដូចជាមនុស្សវិកលចរិត, ទ្រង់បើកព្រះនេត្រតែ
នៅពេលដែលទ្រង់ដាក់បៃស់ជាកក់ប៉ុណ្ណោះ, ទ្រង់ចេះតែចាញ់ អស់
គ្រឿងមាសពេជ អស់អាវុធពីព្រះអង្គ, ទ្រង់ជាក់ព្រះពំជវថ្ម បានទៅទ្រង់ ប៉ុស្ការ:, ទ្រង់ជាក់សេះ បានទៅប៉ុស្ការ:, ពួកវជ្ជមន្ត្រីនៅ
ឈរមើលទ្រង់ដោយមានសេចក្តីបារម្ភជាខ្លាំង គេបានអង្វរសូមឲ្យទ្រង់
ឈប់ក្រសាល ប៉ុន្តែព្រះករុណាធ្វើជាគជាថ្ងន់, ទ្រង់ចេះតែបាជ័យ
ចាញ់ ហើយទ្រង់ចេះតែក្រសាលតទៅទៀត គេបារម្ភក្រែងទ្រង់រងគ្រោះ
ស្មារតី" ។

ព្រះនាងទមយន្តី ចង់បញ្ចេញសេចក្តីក្លាហាន ទើបទំពប់ទឹក
ព្រះនេត្រហើយទ្រង់យាងដោយស្រួលទៅកាន់ព្រះភជមន្ទីរ ដែល
ព្រះករុណាកំពុងតែចាញ់អស់ទ្រព្យសម្បត្តិ ។ ពួកវជ្ជមន្ត្រីឃើញ
ព្រះនាង ក៏កើតសេចក្តីសង្ឃឹម ។ ព្រះនាងមានបន្ទូលដោយសូរសៀង
ស្រទន់ថា: "ព្រះអង្គជាទីស្នេហាបួន! សូមស្តេចយាងទៅ ព្រះអង្គ
ជាបស្រាប់ហើយថា ខ្ញុំម្ចាស់ស្រឡាញ់ព្រះអង្គណាស់" ។ ព្រះរាជា
ទ្រង់គ្រាន់តែក្រឡេកមើលព្រះនាងដោយភាយមាយ ហើយទ្រង់ចោះ
ឡុកឡាក់ទៀត ។

(មានត)

ដំណឹងតាមខ្សែក្នុងភពផ្កាយ

លោកធែង-ជ្រៃ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាចាវ៉ាមកជាភាសាខ្មែរ

(តមក)

ហេតុនេះ នៅខាងបច្ចិមប្រទេស ក៏ដូចនៅខាងបូព៌ាប្រទេសដែរ បំណងស្រីក្រមុំគ្រប់រូបមិនជាផ្សេងពីគ្នាប៉ុន្មាន ។

កាមភគនៃនារីអាយុដប់ប្រាំបីឆ្នាំ មិនគឺជាបទភាព្យឃ្លោងមួយយ៉ាងល្អបំផុតក្នុងលោក? គឺថាកាមភគនឹងបទភាព្យដូចគ្នា គេមិនចាំបាច់គិតអំពីប្រស្នាអាកាសជាតុមជ្ឈដ្ឋានផ្សេងៗ គ្នាឡើយ, គ្រាមមេឃស្រុកណាក៏ដោយ កាមតណ្ហានឹងចំណង់របស់មនុស្ស មានសភាពដូចគ្នាទាំងអស់ ។ គឺជាសេចក្តីស្នេហានឹងសេចក្តីទុក្ខតែងមានដូចគ្នា ។

នាងអាឥស្សាតា មានរូបសម្បត្តិចង់រកកល់ឆើតជាងប្អូនបន្តិច តែនាងប្រែទៅជាអន់ល្អ មកពីគ្មានសម្ផស្សសម្បត្តិដែលជាវត្ថុមួយដ៏សំខាន់បំផុតខាងស្នេហ៍មុខ ។ សេចក្តីវិបត្តិដែលជាភាវៈនៃនាងតែងធ្វើទឹកមុខឲ្យអន់ចុះទៅជាសោះកក្រែសឥតជាតិ នាំកំឆ៏សេចក្តីចំណង់ឯង។ ទឹងធ្វើសេចក្តីក្លាហានយ៉ាងខ្លាំងឲ្យស្ទុះដំណើរ ។ កាមភគត្រូវប្រែគល់ហានៈខ្លួនទុកឲ្យសេចក្តីអាណិតវិញ ។

នាវីទាំងពីរ មួយដឹកមួយ នាំគ្នាត្រាច់តាមមាគ៌ាដ៏ចង្អៀត មាន
សុទ្ធតែដើមកប្បាសព្រៃនឹងស្មៅអណ្តាសដុះក្បែរខាង ។ ហ្វូងពពែស្តុម
រជឿត ឃើញតែធ្ងំធ្ងន រត់ត្រឹកៗ ពីមុខនាង ងាកចោចស្មៅធ្វើងស្តាំស៊ី
បណ្តើរ ។ នាង ឡឺឡា កំពុងដេញពពែ ស្រែកច្រៀងទំនុកមួយយ៉ាង
ពីកេះគួរអាណោចអធម្ម ដូចជាអ្នកគង្វាលពពែឯទៀតធ្លាប់ច្រៀងបណ្តើរ
ពពែដែរ គឺជាទំនុកតែឮកាលណាបណ្តាលឲ្យរលឹកស្រុកកំណើត នឹង
នាំឲ្យកើតមានសេចក្តីត្រេកអរ ។ បម្រែងនេះហាក់ដូចជាហើរទៅហើរ-
មកតែក្នុងវាលកន្តារៈ នឹងលើវាលខ្នងភ្នំនៃបូពាប្រទេស តាំងពីប៉ុន្មាន
សតវត្សមកហើយ គឺថ្ងៃអំពីវាលខ្សាច់ដ៏ក្តៅ នៅក្រោមចំហាយព្រះ
អាទិត្យ នឹងសេចក្តីត្រជាក់ក្បែរក្បាន្តក្នុងកន្តារវនភូមិ ។

គឺជាទំនុកកាព្យមួយដែលច្រៀងតាំងពីដើមដល់ចុង ដោយប្រើសំ-
ឡេងតែមួយបែប ទំនុកនេះតែងធ្វើឲ្យអ្នកដែលប្រកបដោយការសង្វេគ
ច្រើនជាប់ចិត្តនិយាយមិនកើត មានសេចក្តីរីករាយជាសុខុមភាព ត្រម
តាំងសេចក្តីព្រួយបន្ទុម។ គឺដូចជាខ្យល់ផ្អែមលាយជូរចត់ បើនិយាយ
ដោយសង្ខេប គឺជាវេជ្ជាតិនៃជីវភាពមួយយ៉ាងដែលប្រកបដោយសេចក្តី
បំណងមិនចេះពេញនឹងសេចក្តីសុខស្រួលចាប់មិនជាប់ ។

ចំណែកនាង ឡឺឡា កំពុងតែច្រៀង ដោយសូរសៀងដ៏ពីរោះបរិសុទ្ធ
រលាក់បញ្ចេញរទាក់ដូចវាយ៉ាក់ចេញពីជ្រោះ ស្រាប់តែឮសូរសេះ-

ផាយ ។ នាវីចាំងពីរត្រាណខ្ចង់ក៏ក្លាក់ត្រែត ។ សេះកាន់តែផាយជិតមក ។ សូរជើងសេះខ្លាំងពេក ស្ទើរបេីកដីផ្លូវដីរឹង ។ នាង-អាឥស្សាគា ជាស្រីស្គាល់តែព្រួយនឹងសេចក្តីលំបាក ស៊ុះចាប់ទុបត្រដួងឆ្អឹងជាប់ ញាក់សាច់ខ្លែក ឥតញែងចិត្តមុខដិត ហើយស្រែកថា: "ឡីឡា! អញក័យណាស់! អញក័យណាស់! គេមកធ្វើទុក្ខយើងហើយ" ។

នាង ឡីឡា ថ្កាប់ថា: "កុំក័យអីបង! ប្រហែលអ្នកដំណើរ ឬក៏អ្នកជិះសេះវង្វើងផ្លូវទេ" ។

ខណៈនោះ ស្រាប់តែឃើញសេះមួយសន្ធុត មានមនុស្សម្នាក់ពាក់ខ្នស់ល្មម ជិះនៅពីលើ លេចចេញមកត្រង់ផ្លូវបត់ ។

ឃើញដូច្នោះ នាង ឡីឡា កិតក័យខ្លាំងទំរ៉ែស្រក ព្រោះឃើញសំលៀកបំពាក់ជារបៀបអឺរុប នាងដឹងថាអ្នកបរទេស គឺមនុស្សដែលជនជាតិអាព៉ាច់តែងស្អប់ខ្ពើមជាទីបំផុត ។ នាងតាញក្រមាបិទមុខភ្លាម ចាប់តាញដៃបងមកថ្កាប់ថា: "មក! យើងតួន! ឆាប់ឡើង! យើងត្រូវតួន!" ។

ពពែបែកខ្ញែកគ្នាអស់ នាវីពីរនាក់ទុបគ្នាទៅវិញទៅមក នាំគ្នាតួនទៅខាងក្រោយគុម្ពផ្កាកូឡាបដើមយ៉ាងរហ័ស តែអ្នកជិះសេះបានឃើញស្តើចាំងពីរបួចស្រេច ។

អ្នកនេះបង្អន់ល្បឿនសេះ ឥតឮឡើយ ។ ហើយបានចូលសំដៅគុម្ពឈើដែលយុវតីកំសត់ទាំងពីរនៅជិតនោះ ដោយនឹកស្មានថាជាសាសន៍រ៉ូម៉ាំងមកវាយធ្វើទុក្ខ ។ លុះចូលទៅជិត នៅប្រហែលពីរ បីម៉ែត្រទើបដល់អ្នកដំណើរលោតចុះពីខ្នងសេះភ្លែត ។ រស្មីព្រះអាទិត្យដែលជិតចូលនៅចាំងមកចំមុខគេ មានភាពបៃតងស្រស់ ។ អ្នកដំណើរនេះ គឺតួអ៊ីស្មាអ៊ីល បេនអៃយ៉ាជ ។

អ៊ីស្មាអ៊ីលចូលទៅជិតនារីទាំងពីរ យកដៃស្ទាបស្មានាងឡីឡា ហើយសួរដោយមធ្យោបាយថា: "ហេតុអីក៏បិទមុខអូន!" ។

នាងក្រមុំមិនឆ្លើយ ។

អ៊ីស្មាអ៊ីល ដណ្តឹងទៀតថា: "អូនឯងកំសត់ណាស់!" ។

បងប្អូនពីរនាក់តែតែឧបត្ថម្ភរុញច្រាន មិនហ៊ានកម្រើក ។

ខណៈនោះ អ៊ីស្មាអ៊ីល ចាប់ឥឡូវសំពត់ដែលបិទមុខចេញ ។ នាងទាំងកមុខរកពួនទៀត អ៊ីស្មាអ៊ីលយកដៃទាំងពីរចាប់មុខបំប្រែមកវិញ ហើយសំឡឹងមួយស្របក់ មិននិយាយអ្វីដោយការប្រជិតខ្ជក់ក្នុងរូបសម្បត្តិដ៏បរិសុទ្ធ ។ គេដឹងថានាងមានភ័យញ័រចំប្រប់ ។

នាងអង្វរថា: "សូមលោកកុំធ្វើបាបយើងខ្ញុំ!" ។

អ៊ីស្មាអ៊ីលឆ្លើយតបថា: "សូមព្រះអាឡស់ជួយនាងឲ្យបានសុខ! បងឈ្មោះអ៊ីស្មាអ៊ីល ជាកូនប្អូនលោកអៃយ៉ាជ ជាកាអ៊ីត អ្នកគ្រប់គ្រង

ក្រែងកាស៊ី កាវ-ប៊ីលី!" ។ រួចអ៊ីស្មាអ៊ីលលែងមុខនាងទៅវិញ ។

ចំណែកនាងកំប៉ាត់កំប្យ ព្រោះដឹងថាកូនជាសាសន៍ជាមួយគ្នា ។ នាងឆ្លើយតបប្រាប់ទៅវិញថា: "ខ្ញុំឈ្មោះឡែឡាជាគណៈអាប៉ាដើរទេស នៃលោកតាម៉ាត្រែកអែលគាឌី" ។ រួចនាងលើកដៃចង្អុលប្រាប់ទីសំ-ណាក់អាស៊ីយ ដែលក្រឡេកទៅមើលឃើញលឺម ។ ដោយពន្លឺព្រះអាទិត្យជិតយប់ ។

នាងឡែឡាប្រាប់បងថា "មិនមែនបច្ចាមិត្តទេ" ។ នាងអាឥស្សាតាក៏ព្រមសុខចិត្តបើកមុខឡើងវិញ ។ អ៊ីស្មាអ៊ីលសួរទៀតថា: "ហ្នឹងបងផងនាងឬ?" ។ នាងឡែឡាឆ្លើយដំកបថា: "ចាបងស្រីខ្ញុំ ឈ្មោះអាឥស្សាតាគាត់ខ្វាក់ភ្នែកទេ" ។ អ៊ីស្មាអ៊ីលមានសេចក្តីអាណិតខ្លាចចិត្ត ។ គេប្រឹងនឹកនិយាយសំដីដែលធ្វើឲ្យកើតចិត្តក្លាហាន ទឹងសំដីជាមិត្តភាព តែពាក្យមិនស្តាប់បង្គាប់គេសោះ គឺមិនព្រមធ្វើតាមគំនិតខាងក្នុង ឃើញតែទាំងប៉ុន្មានទៅជាច្របូកច្របល់លាយឡំគ្នាអស់ រកនិយាយមិនកើត នៅតែគំនិតមួយទេដែលធំជាងគេ ដែលធ្វើឲ្យជាកំហួសក្នុងចិត្តរបស់គេ គឺសេចក្តីស្នេហាចំពោះរូបសម្បត្តិរបស់នាងក្រមុំ ប្រែកបដោយទឹកមុខថ្លាស្រស់ដ៏បរិសុទ្ធ នៅព្រហ្មចារិយ៍ ។

អ៊ីស្មាអ៊ីលដែលមិនអាចទប់ទល់នឹងសម្ផស្សសម្បត្តិនេះ មិនមែនដូចបណ្តាជនខ្វះកូនស្រែកទេ គឺមកពីមិនបានជាគិតប្រឹងពុក ព្រោះគេ

អាស្រ័យនៅក្នុងបច្ចឹមប្រទេសជាយូរឆ្នាំ ។ គេបានប្រទះនារីមួយរូប ស្អាតនៅក្បែរវាលកន្ទារៈនេះ គឺជាការណ៍មួយដែលនាំឲ្យគេព្រឺព្រួចក្នុងដួងវិញ្ញាណត្រមាំងតប់ប៉ាម៉ល់ផង ។

រួចស្រាប់តែសេចក្តីធ្លុតកើតមានដល់ចិត្តគេភ្លាម ព្រោះនឹកឃើញដល់អង្គកាយខាងក្នុងរបស់នាងដែលទទេ សាច់ខ្លីសដូចបណ្តូលចេកយ៉ាងម៉ដ្ឋផង់ ដែលតែងធ្វើឲ្យជនានុជនជ្រប់ចិត្តរំលឹងក្បាលគ្រប់គ្នា តែគម្រែកនេះកើតឡើងមួយភ្លែតដូចផ្លេកបន្ទោរ ហើយក៏ជាត់ទៅវិញ គេនូនក្បាលគំនាប់នាងក្រមុំផែលឡើងលើសេះយ៉ាងប្រញាប់ ហើយបុំផាយសំដៅវាលទ្បាច់កន្ទារៈ ប្រហែលអ៊ីស្មាអ៊ីលខ្ចាចក្រែងទឹកភ្លៀគឺកាមរាគជ្រមុជគេ ដូចជាទឹកជ្រៅជ្រមុជអ្នកដំណើរមាត់សមុទ្រ ប្រហែលខ្ចាចក្រែងគេប្រទុស្តវល់សាយណ្តាសម័យដ៏បរិសុទ្ធ នឹងព្រហ្មចារិយរបស់កុមារីនោះទេដឹង មា្ល៉ងទៀត, ប្រហែលជាមានកុសលចេតសិកណាមួយជាគ្រឿងកាំងចិត្តដែលគេបានហាត់បង្វឹកពីប្រទេសអ៊ីរ៉ុបមក ។

ចំណែកសូរដើងសេះដែលផ្សាយហាក់ដូចជាជាប់នៅក្នុងដួងវិញ្ញាណនៃនាង ឡើងឡាជានិច្ច ។

(មានត)

លើកទី ៣

របស់ល្អោក ជាប-ពិធ

កាលពីថ្ងៃទី ១០ កុម្ភៈ ១៩៥៤ នេះ ខ្ញុំបានបរិយាយពីសិល្បៈខ្មែរ ជូនជាសណ្តាប់ធ្នាប់អ្នករួមជាតិ ជាលើកទី២, ឥឡូវនេះ សូមបរិយាយ ពីសិល្បៈខ្មែរលើកទី ៣ ទៀត មានសេចក្តីដូចតទៅនេះ ៖

នាដសិល្បៈ (សិល្បៈខាងកំ) គីតសិល្បៈ (សិល្បៈខាងច្រៀង) ហើយនឹងតូរ្យាង្គសិល្បៈ (សិល្បៈខាងភ្លេង) ជាសិល្បៈមានលក្ខណៈប្លែក ពីសិល្បៈដទៃ គឺជាសិល្បៈងាយរលត់ជាងសិល្បៈទាំងពួង ។ ចុងក្រោយ ចិត្រសាល វិហារជាដើម ដែលគេសាងសង់ឡើង ហៅថា ស្ថាបនកម្ម, ការគំនូរឬការកាត់ដែលគេគូរឬឆ្លាក់ឡើង ហៅថា វេធនាកម្ម, រូបស្មិត ដែលគេសិតឡើង ហៅថា បដិមាកម្ម, សៀវភៅដែលគេតែងឡើង ហៅថា វណ្ណកម្ម ។ សិល្បៈពួកនេះ កាលគេបានធ្វើឲ្យសម្រេចរូប ពេញលក្ខណៈឡើងហើយ តែងនៅឋិតថេរបានយូរ មិនងាយរលត់ ធាប់ទេ ។ ឯសិល្បៈខាងច្រៀង សិល្បៈខាងកំ សិល្បៈខាងភ្លេងឬ ខាងនាដសិល្បៈ ជាសិល្បៈធាប់រលត់ កាលបើសិល្បៈនជាអ្នកសំដែងបាន សំដែងស្រេចហើយ ក៏ហើយគ្នា គ្រាន់តែការស្តាប់ ការមើល ការចាំ

នៅក្នុងចិត្ត តតអ៊ូនៅសល់ឲ្យយើញឲ្យពុបានទេ បើចង់យើញចង់ពុទៀត ត្រូវតែឲ្យសិល្បិនសំដែងឲ្យមើលឲ្យស្គាប់ជាថ្មី ដែលអាចល្អ ឬអាក្រក់ជាងមុនក៏បាន មិនគង់នៅជាទៀងទាត់ ដូចសិល្បៈខាងគំនូរចម្លាក់ ស្ថិត សៀវភៅទេ ពាងសិល្បិនអ្នកសំដែងសិល្បៈប្រកេទនេះ ក៏ចាញ់ប្រៀបសិល្បិនអ្នកសំដែងសិល្បៈប្រកេទដទៃ ។

អំពីបុរាណមក ព្រះមហាក្សត្រជាអគ្គឧបត្ថម្ភសិល្បៈរបស់ជាតិ ពួកសិល្បិនដែលនៅក្នុងព្រះបរមរាជូបត្ថម្ភ មិនបាច់កង្វល់កង្ខាការចិញ្ចឹមជីវិតឡើយ បើមានសមត្ថភាពក្នុងសិល្បៈរបស់ខ្លួនហើយ ក៏បានជាជនដែលព្រះរាជាទ្រង់ចិញ្ចឹម ទ្រង់ព្រះរាជទានឋានន្តរស័ក្តិតាមសមត្ថភាពរៀងខ្លួន, ព្រោះហេតុនេះបានជាសិល្បៈបេះតែចម្រើនឡើង ដូចព្រះចន្ទខាងខើត ។ ព្រះរាជការៈខាងខំនុកបម្រុងសិល្បៈរបស់ជាតិក្នុងបច្ចុប្បន្ននេះ ធ្លាក់មកជាមុខងាររបស់ជាតិចិញ្ចឹម គឺជាតិត្រូវជាអ្នកទទួលការៈនេះដំនួស, ហេតុនេះយើងគ្រប់រូបដែលរួមគ្នាជាជាតិមួយ ទើបមានមុខងារជាអ្នកត្រូវព្យាយាមរក្សាទុកឯតនូវតំណសិល្បៈរបស់ជាតិស្នងព្រះរាជការៈ ដែលធ្លាក់ចំមកលើយើង, បើជាតិគឺយើងពាងអស់គ្នាមិនអើពើ មិនធ្វើមុខងារនោះជាអ្នកចិញ្ចឹមទេ សិល្បៈរបស់ជាតិក៏រសាត់នៅពុំបាន ត្រូវតែសាបសូន្យទៅដូចព្រះចន្ទខាងរនោច, បើប្រសិនជាសាបសូន្យទៅ ក៏កំហុសរបស់យើងគ្រប់គ្នា ឯបន្ទោសនរណាពុំបានពាងអស់ ត្រូវតែបន្ទោសខ្លួនយើង

ព្រោះការព្យាបាលសិល្បៈដែលជាអារ្យធម៌របស់ជាតិ ឲ្យបានបិតថេរនឹង
ចំរើនល្អនោះស្រេចនៅលើប្រជាជនជាពលរដ្ឋ ។

ប្រទេសខ្មែរយើង ព្រះរាជរដ្ឋាភិបាលបានបង្កើតសាលាបង្រៀន
សិល្បៈខ្មែរខាងផ្នែកវិជ្ជាស្ថាបនកម្ម គឺវិជ្ជាសំណង់ វិជ្ជារចនាកម្ម គឺវិជ្ជា-
គំនូរឬចម្លាក់ វិជ្ជាចង្អាមកម្ម គឺវិជ្ជាស្មិត ព្រមទាំងវិជ្ជាតំបាញ វិជ្ជាជាង
មាស ជាងប្រាក់ ដែលជាសិល្បៈហាវរៈបិតថេរនៅបានយូរ សន្មតឈ្មោះ
សាលានេះថា "សាលាវិចិត្រសិល្បៈខេមរៈ" បានបើកឲ្យយុវជនខ្មែរ
ដែលស្ម័គ្រស្មោះចំពោះសិល្បៈដូចពាយខាងលើ ចូលរៀនបានដោយសេរី
ឈ្មោះថាព្រះរាជរដ្ឋាភិបាលប្រគល់ការនេះ ឲ្យក្រុមសិល្បការព្យាបាល
ជំនួសប្រជាជនរួមជាតិ ដើម្បីរក្សាសិល្បៈខ្មែរតបវេណីខ្មែរ; យុវជនខ្មែរ
ទាំងប្រុសទាំងស្រីបានចូលរៀនវិជ្ជាសំណង់ វិជ្ជាគំនូរ វិជ្ជាចម្លាក់ វិជ្ជា
ស្មិត វិជ្ជាតំបាញ វិជ្ជាជាងមាស វិជ្ជាជាងប្រាក់ ចេះក្លាត់ប្រឡងចេញ
តាមឆ្នាំដែលសាលាកំណត់ទុក បានជាប់សញ្ញាបត្រ បានចេញទៅ
ប្រកបវិជ្ជាជីវៈ ដោយសិល្បៈនេះ តែរៀងរាល់ឆ្នាំមានចំនួនច្រើន នាំឲ្យ
ចំរើនប្រទេសជាតិហើយ; នៅតែផ្នែកគីតសិល្បៈ នាដសិល្បៈ ទឹង
តូរ្យាង្គសិល្បៈដែលជាសិល្បៈរលត់ធាប់នោះ ពុំទាន់មានសាលាបង្រៀន
នៅឡើយ ម្ល៉ោះហើយពួកសិល្បិន គឺពួកអ្នករៀងក៏ចេះតែរៀង
តាមទំនើងខ្លួនក្បាយចាកបទដើម ស្ទើរតែបាត់រូបបទខ្មែរ ដែលជាបទគ្មាប់

មានលំអមកពីបុរាណ, ព្រោះហេតុនេះ បានជាឯកឧត្តមចាំងពីរូប
គឺឯកឧត្តម សម-ញាណ ថៅក្រសួងធម្មការ សិល្បការ នឹងឯកឧត្តម
ច្បាក់ សារិន ថៅក្រសួងយោសនាការ បានសន្ទនាគ្នាអំពីសិល្បៈខ្មែរ
ដូចខ្ញុំពណ៌នាពីមុននោះ បានសម្រេចថានឹងព្យាយាមរក្សាទុកនូវបណ្តើ
គឺតសិល្បៈខ្មែរ ព្រមចាំងពង្រីកឲ្យរីកសាយ ឲ្យចំរើនថែមឡើងទៀត
ដើម្បីរក្សាទុកនូវចម្រៀងខ្មែរ ដែលជាសិល្បៈធាប់រលត់មិនឲ្យរលត់ជាយ
នឹងមិនឲ្យក្លាយថៅជាដទៃ ដែលមិនមែនជាគឺតសិល្បៈខ្មែរ ។

ឯកឧត្តម សម ញាណ រដ្ឋមន្ត្រីក្រសួងធម្មការ សិល្បការ មាន
យោបល់យល់ឃើញថា បើប្រសិនជា "សាលាវិចិត្រសិល្បៈខេមរៈ"
មិនអណ្តែតចុះ អណ្តែតឡើង ម្តងថៅចូលក្រសួងនោះ ម្តងថៅចូល
ក្រសួងនេះ ចាក់ឫសជាប់ទៅតែក្នុងអាវុធារបស់ក្រសួងធម្មការបិតចេះថៅ
ឯកឧត្តមបម្រុងនឹងបង្កើតឲ្យមានសាលាបង្រៀន វិជ្ជាច្រៀង វិជ្ជាកំ វិជ្ជា-
តូរ្យតន្ត្រី នឹងវិជ្ជាមហោស្រព ឲ្យវិជ្ជាទាំងនេះ ចេរមុខថៅកាន់
វឌ្ឍនភាព ដោយមានគាំងសភាមួយ ហៅថា "សភាវឌ្ឍនធម៌"
សម្រាប់ពង្រីកសិល្បៈរបស់ជាតិឲ្យចំរើនដូចអារ្យប្រទេសនានា ។

បញ្ចប់ការបរិយាយត្រឹមប៉ុណ្ណេះ ។

បន្ទាប់ពីនេះ ចានចាត់ហ្វូងវៀហារសែម ឲ្យច្រៀងចាប៉ីតាមអត្ថបទក្នុងសៀវភៅច្រៀងជាតិនិយម ជាភាសាខ្មែរសំឡេងប្រទេសកម្ពុជា នៅថ្ងៃទី ២៥ កុម្ភៈ ១៩៥៤ ជាសណ្តាប់ចង់ចូនរួមជាតិ ដើម្បីរក្សាទុកនូវច្រៀពណីតិតសិល្បៈខ្មែរ ឲ្យតង់វង្សនឹងឲ្យចម្រើនជាតិយ៉ាកាពតទៅ ។

បរិយាយពីសិល្បៈខ្មែរ

លើកទី ៤

របស់លោក ចាប-ពិន

កាលពីថ្ងៃទី ២៥ កុម្ភៈ ១៩៥៤ នេះ ខ្ញុំបានបរិយាយពីសិល្បៈខ្មែរលើកទី ៣ ជូនជាសណ្តាប់ចង់ចូនរួមជាតិហើយ ឥឡូវនេះ សូមបរិយាយពីសិល្បៈខ្មែរលើកទី ៤ ទៀត មានសេចក្តីដូចតទៅនេះ៖

គ្រឿងបរិភោគ គ្រឿងស្លៀកដណ្តប់ ទីលំទីនៅអាស្រ័យ សុទ្ធតែជារបស់ចាំបាច់ដល់ជីវិតមនុស្ស ហើយជារបស់សំខាន់ដែលមនុស្សយើងត្រូវតែមានប្រចាំរូបគ្រប់គ្នា ទាំងជាតិដែលចម្រើន ទំនិមិនខាន់ចម្រើន សូម្បីតែជាតិដែលនៅជាជាតិព្រៃផ្សៃនៅឡើយ ក៏ត្រូវតែមានជាធម្មតា, ប៉ុន្តែជាតិណាដែលធ្វើរបស់អំពាលនេះបានយ៉ាងប្រណីតមានរបៀបរៀបរយល្អជាងជាតិដទៃ គេហៅជាតិនោះថាជាជាតិមានសេចក្តី

ចម្រើនខ្ពស់ គឺវឌ្ឍនធម៌ខ្ពស់ សម្រាប់ជាតិរបស់គេដែលធ្វើឲ្យជាតិគេចម្រើន ។ កិច្ចការរបស់ក្រុមសិល្បករជាកិច្ចការទាក់ទងដោយ វឌ្ឍនធម៌របស់ជាតិ ។

រុតដែលគេស្គាបនាឡើង បានយ៉ាងប្រណីតល្អមានរបៀបរៀបរយនោះ លោកហៅថា "សិល្ប" ហេតុនេះ សិល្បៈទើបជារបស់កើតពីមនុស្សសោងឡើង; បើកើតឡើងឯង។ តាមធម្មជាតិ ដូចផ្កាឈើដែលកើតនៅកន្លែងដើមរាល់ពីកំណើតមក មិនចាត់ជាសិល្បៈទេ, ជាក្បែដែលគេធ្វើជាក់នៅនឹងសំពត់អាវ ឬគ្រឿងស្លៀកដណ្តប់ជាដើម ទើបចាត់ជាសិល្បៈ ។ សិល្បៈបែបនេះហៅថា "សិល្បៈបរយុគ" គឺសិល្បៈដែលប្រែគួបជាមួយនឹងរបស់ដទៃ, សិល្បៈបរយុគធ្វើឲ្យយើងជាអ្នកបានស្លៀកដណ្តប់ល្អ នៅអាស្រ័យល្អ បរិភោគល្អ ដូចអាហារដែលចាត់ការធ្វើឡើងដោយថ្វីដៃដ៏ជំនាញ នឹងមានសេចក្តីប្រណីតល្អ កាលគេធ្វើស្រេចហើយគេទុកជាក់យ៉ាងរៀបរយល្អក្នុងកន្លែងតែមួយ កន្លែងជាន ឬក្នុងកាជន៍ដ៏ស្អាតហ្មត់ចត់ ហើយកាជន៍នោះមានសម្រស់ស្រស់ល្អ ដោយសម្បុរដោយក្បាច់ផ្កាគឺតែកាលក្តែកក៏តែតែធ្វើអាហារនោះ ឲ្យគួរចង់បរិភោគថែមឡើងទៀត, ដែលធ្វើឲ្យល្អដូច្នេះបាន ក៏ដោយសារសិល្បិនជាអ្នកធ្វើនោះមានសមត្ថភាព បានសំដែងចំណេះដែលជាសិល្បៈក្នុងអាហារ នឹងក្នុងកាជន៍នោះ ទើបធ្វើឲ្យអាហារនោះជារបស់គួរចង់បរិភោគនឹងកាជន៍នោះជារបស់គួរចង់ប្រើប្រាស់ទៀបានយ៉ាងជាក់ស្តែង ។

នៅមានសិល្បៈមួយចំពូកទៀតខ្ពស់ជាងសិល្បៈបរយុគ ព្រោះជាសិល្បៈមិនមែនធ្វើឡើងដើម្បីបរិភោគ ដើម្បីប្រើប្រាស់ទេ គឺធ្វើឡើងដើម្បីបន្ទើងចិត្ត (សម្រើបចិត្ត) ដើម្បីលើកទឹកចិត្តមនុស្សឲ្យខ្ពស់ ឲ្យមនុស្សដែលបានឃើញហើយអាចគិតអាចប្រព្រឹត្តតែចំណែកល្អ ។ សិល្បៈបែបនេះ លោកហៅថា "វិចិត្រសិល្បៈ" នានាជាតិគេយល់គេប្រកាន់ថាសិល្បៈប្រភេទនេះជារបស់ខ្ពស់ ព្រោះជាគ្រឿងបញ្ចេញមុខបញ្ចើចក្បែករបស់ជាតិ, សិល្បិនដែលធ្វើសិល្បៈបែបនេះឲ្យមានឡើងយ៉ាងល្អ ឬសំដែងសិល្បៈបែបនេះយ៉ាងល្អបានគេប្រកាន់ថា ជាអ្នកមានកិត្តិយស ។ នាដសិល្បៈ (សិល្បៈខាងរបាំ) ក៏ជាសាខាមួយរបស់វិចិត្រសិល្បៈ ការធ្វើឬសំដែងសិល្បៈបែបនេះក៏ជាការមានកិត្តិយស ។ តែមុននេះអ្នកផងសំគាល់ការច្រៀង ការរាំ ទំនឹការលេងភ្លេង ថាជាការមិនសូវមានដម្លៃ ។ តាមពិត ការច្រៀង ការរាំ ទំនឹការលេងភ្លេង មិនមែនជារបស់ថោកទាបដូចមនុស្សសាម័ញយល់នោះទេ គឺជារបស់ខ្ពង់ខ្ពស់ដែលសាកលលោកតែងលើកដំកើង តែងរាប់អានថាជាសិល្បៈសំខាន់សម្រាប់ប្រទេសជាតិឲ្យកិត្តិយសដល់សិល្បិនអ្នកសំដែងសិល្បៈនេះយ៉ាងប្រសើរ ទំនឹងឲ្យកិត្តិយសដល់ប្រទេសជាតិយ៉ាងខ្ពស់ ។

ពួកទេសចរនៅនានាប្រទេស ដែលគេបានមកកាន់ប្រទេសយើង គេតែងត្រូវការមើលរបាំរបស់យើង មានល្ខោនជាដើមដែលមានត្រម

ជាំងកំ ជាំងជ្រៀង ជាំងក្ងេង ដើម្បីកំសាន្តចិត្តនឹងដើម្បីសាកមើលអារ្យ-ធម៌យើង ថាមានពលកាឥតបន្តស់ត្រឹមណា, ជាំងយើងវិញ កាលបើមានអ្នកបរទេសធំៗ គេមកកាន់ប្រទេសយើង ក៏សំដែងរបាំយើងដែលជាសិល្បៈសម្រែបចិត្តបង្ហាញគេ ដើម្បីជាគ្រឿងកំសាន្តបង្អួតគេជាក្បៀវដែលជាមិត្តនឹងយើង ។ ព្រោះហេតុនេះពួករបាំខ្មែរយើងគួរតែបានទទួលការអប់រម្យជាផ្លូវការ ឲ្យជំនាញឲ្យមានឋានៈខ្ពស់ មានកិត្តិយសសមតាមកាលៈទេសៈកុំឲ្យអន់ជាងរបាំជាតិដទៃ ។

ប្រទេសខ្មែរយើង ព្រះរាជរដ្ឋាភិបាលបានបង្កើតសាលាបង្រៀនជាផ្លូវការសម្រាប់បង្រៀនខ្លួវិជ្ជាសិល្បៈជាំងឡាយហៅថា "សាលាវិចិត្រសិល្បៈខេមរៈ" បានបង្រៀនវិជ្ជាខាងបរយុគសិល្បៈ គឺវិជ្ជាក្បាច់របាំគំនូរ ចម្លាក់ ស្ថិត គ្រឿងតន្ត្រ ស៊ីម៉ង់ មាស ប្រាក់ ទងដំបាញ តាមបែបបុរាណនឹងបែបទំនើបហើយ, នៅតែវិជ្ជាខាងវិចិត្រសិល្បៈ គឺវិជ្ជាមហោស្រព របាំ ចម្រៀង ភ្លេង តន្ត្រីយ៍ ដែលជាសិល្បៈសម្រែបចិត្ត មិនទាន់មានសាលាបង្រៀនជាផ្លូវការនៅឡើយ ។

សព្វថ្ងៃ សាលាវិចិត្រសិល្បៈខេមរៈ នៅក្នុងបន្ទុកក្រសួងធម្មការសិល្បការ, ឯកទត្តម សម-ញ៉ាណ រដ្ឋមន្ត្រីក្រសួងនេះ ទទឹងឯកទត្តមប្រាក់-សានៃ អនុរដ្ឋលេខាទទួលបន្ទុកខាងយោសនាការ បានសន្ទនាគ្នាអំពី

សិល្បៈខ្មែរនិងរកមធ្យោបាយរៀបចំសិល្បៈខ្មែរឲ្យលូតលាស់បម្រើជន ជាន
ចាំដាច់ឲ្យខ្ញុំមកបរិយាយពីសិល្បៈខ្មែរនឹងចាត់ឲ្យហ្លួងវោហារ សែម មក
ច្រៀងចាប៉ីពាល់ថ្វាយសីលជាគម្រប់ ៤ លើក នឹងលើកនេះហើយ, តែតទៅ
ថ្ងៃមុខ ប្រសិនបើលោកព្រះពរជរដ្ឋាភិបាលនឹងជាក់សាលាវិចិត្រសិល្បៈខេមរៈ,
ទៅក្នុងបន្ទុកក្រសួងសិក្សាធិការជាតិវិញ, កាលបើដូច្នេះក្រសួងធម្មការក៏
អស់ការៈកង្វល់រឿងសិល្បៈ, ចាំដាច់ខ្លួនខ្ញុំដែលជាអ្នកបរិយាយពីសិល្បៈដំណួស
ឯកទត្តមាំងពីរូប ក៏អស់បានមកបរិយាយពីរឿងនេះប្រសើរជាមួយបងប្អូនរួមជាតិតទៅទៀត, តែក្រសួងធម្មការសង្ឃឹមនឹងទុកចិត្តលើក្រសួងសិក្សាធិការជាតិ ថាមុខជានឹងព្យាយាមចាត់ការយ៉ាងណាឲ្យការងារវិចិត្រសិល្បៈខ្មែរ បានលូតលាស់បម្រើនឡើងជាងមុនពុំខាន ។

បញ្ចប់ការបរិយាយត្រឹមប៉ុណ្ណេះ ។

បន្ទាប់ពីនេះ បានចាត់ហ្លួងវោហារ សែម ឲ្យច្រៀងចាប៉ីតាមអត្ថបទកង្វល់សៀវភៅច្បាប់ប្រជុំកូនចៅខ្មែរ ពណ៌នាពីជាតិ, សាសនា, មហាក្សត្រ ដែលចាត់ទុកជាទំនុកចម្រៀងជាតិនិយម ដាក់វិទ្យុសម្លេងប្រទេសកម្ពុជា នៅថ្ងៃទី ៣ មីនា ១៩៥៤ ជាសណ្តាប់ធ្នាប់បងប្អូនរួមជាតិ ដើម្បីរក្សាទុកនូវបវេណីតីតសិល្បៈខ្មែរឲ្យគង់វង្ស ទឹងឲ្យបម្រើនជាកិយ្យាភាពតទៅ ។

លើកទី ៥

របស់លោក ចាប-ពិន

ក្នុងនាមឯកឧត្តម សម-ញាណ រដ្ឋមន្ត្រីក្រសួងធម្មការ នឹងការសិក្សាធម៌វិន័យព្រះពុទ្ធសាសនា ខ្ញុំសូមបរិយាយពីប្រវត្តិសិល្បការខ្មែរ មានដំណើរសេចក្តីដូចតទៅនេះ៖

កាលពីថ្ងៃសុក្រទី ៥ មីនា គ.ស. ១៩៥៤ នេះ គណៈរដ្ឋមន្ត្រីបានជួបជុំពិចារណាសេចក្តីព្រាងព្រះរាជក្រឹត្យមួយ ស្តីពីការជាក់ទីចាត់-ការសិល្បការ គឺសាលាវិចិត្រសិល្បៈខេមរៈ ឲ្យទៅនៅក្នុងបន្ទុកក្រសួងសិក្សាធិការជាតិ ។

លទ្ធផលនៃការពិចារណា គណៈរដ្ឋមន្ត្រីបានព្រមព្រៀងជាឯកច្ឆន្ទតាមសេចក្តីព្រាងព្រះរាជក្រឹត្យដូចថ្ងៃខាងលើ ។

នៅពេលជួបជុំពិចារណានោះ ឯកឧត្តម សម ញាណ បានជូនគណៈរដ្ឋមន្ត្រីនូវកំណត់ហេតុពិសេសមួយ ស្តីពីប្រវត្តិសិល្បការ មានសេចក្តីដូចខាងមុខ៖

ប្រវត្តិរបស់សិល្បការនេះ ដូចឯកឧត្តមចាំងឡាយជ្រាបហើយថាបិតនៅពុំទៀងទាត់ទេ ជួនណានៅក្នុងបន្ទុកក្រសួងធម្មការ ប៉ុន្តែពុំបានយឺនយូរ ក៏ត្រូវចេញពីក្រសួងនេះទៅនៅក្នុងបន្ទុកក្រសួងសិក្សា-

ជាតិ នៅពុំបានយូរប៉ុន្មានក៏ត្រឡប់មកនៅក្នុងក្រសួងធម្មការវិញ នាំឲ្យអាក់អន្លួលពុំអាចនឹងពន្លឹកឲ្យធំទូលាយទៅបាន ប៉ុន្តែតាំងពីពេលនេះទៅ សិល្បការនេះ ចេញទៅនៅក្នុងបន្ទុកក្រសួងសិក្សាធិការជាតិ ប្រហែលជាប់ជាយូរអង្វែងតទៅ ។

ហេតុនេះ ទូលបង្គំ ខ្ញុំ សូមលើកយកសិល្បការមកលាតត្រដាងថ្វាយ, ដូនគណៈវដ្ឋមន្ត្រីជ្រាបថា ៖

ទី ១) សិល្បការ ឬសិល្បៈនេះ ចែកជា ២ ប្រភេទ គឺ

ក) ថាវៈសិល្បៈ = សិល្បៈមិនជាយូរលត់ បានខាងក្បាច់រចនាគំនូរ ។ ល ។

ខ) អថាវៈសិល្បៈ = សិល្បៈឆាប់រលត់ បានខាងមហោស្រពឬរបាំ ។ ល ។

ទី ២) សិល្បៈ ចែកជា ២ ប្រភេទទៀត គឺ

ក) បរយុគសិល្បៈ = សិល្បៈប្រកបនឹងវត្ថុដទៃ បានខាងក្បាចរចនាដែលធ្វើជាក់នៅវត្ថុផ្សេង ។ ល ។

ខ) វិចិត្រសិល្បៈ = សិល្បៈដែលវិចិត្រឡើងដើម្បីសម្រើបចិត្ត បានខាងមហោស្រព ឬរបាំ ។ ល ។

ទី ៣) វិចិត្រសិល្បៈ បើហៅតាមចំណែក ។ មាន ៣ យ៉ាង គឺ

ក) ការពាំ ជានាដសិល្បៈ,

ខ) ការច្រៀង ជាគីតសិល្បៈ,

គ) ការលេងភ្លេង ជាតូរ្យង្គសិល្បៈ ។

តែថាបើហៅដោយរួបរួម ថា នាដសិល្បៈ តែម្យ៉ាងក៏ថាន ព្រោះការរាំ តែងតែមានច្រៀង មានភ្លេងតូរ្យតន្ត្រីជាដរាប ។

រួមចាំងអស់នេះ ហៅថា "សិល្បការ" ។ ប្រទេសកម្ពុជាយើង គួរតែរៀបចំសិល្បការចាំងអស់នេះឲ្យបានចម្រើន ដូចបុរាណសម័យ ដែលធ្លាប់ល្បីឈ្មោះមកហើយ ។

ឥឡូវនេះ សិល្បការ ត្រូវដាក់ឲ្យទៅនៅក្នុងបន្ទុកក្រសួងសិក្សាធិការជាតិ តាំងពីថ្ងៃទី ៥ មីនា គ.ស. ១៩៥៤ នេះទៅ, កាលបើសិល្បការបានចូលទៅនៅក្នុងបន្ទុកក្រសួងសិក្សាធិការជាតិហើយ អស់លោកចាំងឡាយជាក្នាក់ងារក្រុមសិល្បការ ក៏ត្រូវអញ្ជើញទៅនៅក្នុងបន្ទុកក្រសួងនោះផង ។

ដូច្នេះ ខ្ញុំសូមជូនដំណើរអស់លោកក្រុមសិល្បការដែលធ្លាប់នៅធ្វើការក្នុងក្រសួងធម្មការជាមួយនឹងខ្ញុំ សូមអស់លោកអញ្ជើញទៅធ្វើការក្នុងក្រសួងសិក្សាធិការជាតិឲ្យបានសេចក្តីសុខសេចក្តីចម្រើនជាកិច្ចការតទៅ ។

បុណ្យមាឃបូជានៅសាលាស្រុកក្រូចឆ្មារ

ទិនដ្ឋាយក្រូចឆ្មារ

ព្រះមហា ជា-អឿន ធិស្សិតសាលាបាលីជាន់ខ្ពស់

រៀបរៀង

សាលាស្រុកក្រូចឆ្មារ កាលពីថ្ងៃអង្គារ ១៤ កើតខែមាឃ ឆ្នាំម្សាញ់ ព.ស. ២៤៩៦ គឺទី ១៦ កុម្ភៈ ឆ្នាំ ១៩៥៤ មានពិធីបុណ្យមាឃបូជា ។ ពួកភ្នាក់ងារប៉ូលិស ចាត់ចែងទីកន្លែងមានគ្រែអាសនៈជាដើម សម្រាប់ប្រជុំពុទ្ធបរិស័ទ ដើម្បីធ្វើសក្ការបូជា ក្នុងគេហដ្ឋានលោកចៅហ្វាយស្រុក មានតាក់តែងទង់ជាតិទង់សាសនា, មេភ្លើងអគ្គិសនីភ្ជាប់ព្រាងពេញទីលានសាលាស្រុក, ហើយមានតាក់តែងកន្លែង ១ ប៉ែកទៀតមិនដាច់មិនឆ្ងាយពេកទេ ល្មមតែឱ្យភ្លើងទៅដល់ ជាកន្លែងសម្រាប់ច្រៀងស្តែលេងល្ខោនកំសាន្ត ក្រោយពេលទេសនា មានរបាយន្តយោសនា ១ ទៀតរបស់កុមារពេទ្យ បន្ទរពាក្យសំឡេងថាសម៉ាស៊ីនភ្លេងគ្រហឹងអឺងកង ។ លុះពួកពុទ្ធបរិស័ទជួបជុំគ្នាហើយ ទើបអាចារ្យសម្រាប់បុណ្យតាំងឆ្លើមសូត្រធម្មនមស្សការធ្វើវត្តព្រះបន្ទាប់មកអាពធនាសីល - ត្រហ្វាតាមបែបបទ ។ ក្នុងទីសន្និបាតនេះ ព្រះញាណកោសល ញ្ញាណ - ឈឿន ឆ្លើមសំដែងធម៌ទេសនា ជាស្រទន់សេចក្តីដែលមានខ្លឹមសារ គឺសំដែងអំពីជាតិ - សាសនា - មហាក្សត្រិយ៍

នាំទៅជាការណ៍ប្រៀបធៀបគតិលោកគតិធម៌ ពីពេះក្បោះក្បាយគួរឲ្យ
ចង់ស្តាប់ ដោយពេលសំឡេងគ្មានសន្ទសព្ទ ចាប់តាំងពីម៉ោង ២១
ដល់ម៉ោង ២៣ យប់ទើបចប់ ។ បន្ទាប់មកពួកល្ខោនប្រុស ។ លេង
កំសាន្តរហូតដល់ម៉ោង ១ - ២ អធ្រាត្រទើបលើកលែង ។

ដល់ម៉ោង ១០ ព្រឹកថ្ងៃ ១៩ កើតខែមាឃ ទី ១៧ កុម្ភៈ ឆ្នាំ ១៩៥៤
លោកស្រី កឹង - ពូន បានចាត់ចែងភោជនប្រគេនព្រះសង្ឃច្រើនអង្គ
ធាន់កងសាលាស្រុកនោះ ។

មុនពេលធាន់ ព្រះសង្ឃដែលនិមន្តមកពីវត្តនានាមានលោកគ្រូ
អនុគណស្រុកក្រូចឆ្នាំរជាប្រធាន បានសូត្រធម្មិកត្តានុមោទនា ។
វេលានោះព្រះញាណកោសល ញាណ - ឈឹន ផ្លៀតយកឱកាសនេះ
ផ្តាំទៅលោកគ្រូអនុគណដោយថេរដីកាថា ‘‘សូមទោសលោកគ្រូម្ចាស់!
ការសូត្រធម្មិអម្បាញ់មិញនេះ មិនមានរបៀបចុះសំរុងគ្នាសោះ ខំនឹង
ជាវៀនតាមវត្តខ្មុសគ្នា; ការណ៍ដែលមិនចុះរបៀបគ្នានេះ ខ្ញុំករុណា
ស្តាយណាស់, សូមលោកគ្រូជ្រាបថា ពុទ្ធសាសនបណ្ឌិត្យ សាលាបាលី
ផ្នែកខ្មែរ ភជការអនុញ្ញាតតាំងឲ្យមានឡើងដើម្បី
បណ្តុះផ្លូវសិក្សាឲ្យលូតលាស់ ចំពោះនឹងឲ្យការប្រតិបត្តិមានរបៀបរៀបរយ
តែបែបជួបគ្នា; សព្វថ្ងៃនេះ ព្រះករុណាជាម្ចាស់ជីវិត ទឹងរាជរដ្ឋាភិបាល
កំពុងខ្នះខ្នែងដោយមុឺងម៉ាត់ណាស់, សូមលោកគ្រូគ្រែនរំលឹកឲ្យកិក្ខុ

សាមណេរស្រែកនេះ ចូលទៅរៀនសូត្រនឹងគេ ប្តូរគ្នាគាំងសាលា ចាលីវង សាលាធម្មវិន័យគ្រប់ៗវត្តឡើង ទើបជាការងាយស្រួលដល់ការចេះដឹង នឹងប្រតិបត្តិតាម ។ មួយវិញទៀត កាលបើមានឧកាសជួបជុំគ្នាមួយដងមួយគ្រា ដូចយ៉ាងថ្ងៃនេះត្រូវសូត្រធម៌ជារបៀបកណ្តាលតាមបែបបទសាលាចាលីដែលពាជការបានរៀបចំនោះវិញទើបស្រួលព្រោះមានសៀវភៅគម្ពីរសុទ្ធតែអ្នកចាជ្ជបានពិនិត្យផ្ទៀងផ្ទាត់ហើយស្រាប់ ងាយដឹងងាយយល់បានបុណ្យច្រើនផង ពីរោះស្តាប់ផង ហើយជាការស្រួលដល់អស់លោកមន្ត្រីខេត្ត - ស្រុកឃុំខ្វះ សូត្រតាមផងបានដឹកអស់លោកចាំងនោះច្រើនចេះចាំតាមសៀវភៅគឺហិបតិបត្តិ សូមលោកអាចារ្យសម្រាប់វត្តនានាចំជួយដំកុំដំកើង រក្សាតម្កល់ព្រះពុទ្ធសាសនាតម្កល់មន្ត្រីខេត្ត-ស្រុក - ឃុំ ឲ្យមានថ្កុំថ្កល់ខ្ពង់ខ្ពស់សមហានៈជាប្រទេសឯកពាជ្យ, ចាំងអស់លោកអ្នកមន្ត្រីសាលាខេត្ត ស្រុក - ឃុំ ទៀតសោតសុំឲ្យធ្វើការប្រុងប្រយ័ត្នចាត់ចែងនឹងព្រះសង្ឃគ្រហស្ថ ដើម្បីឲ្យកើតសេចក្តីស្និទ្ធស្នាលរាប់រកគ្នាទៅទៀត” ។

លំដាប់នោះ លោកនួន ទីយោក្សត្រផុតលេខនៅសាលាស្រុកត្រពាំង ព្រឹទ្ធបុលោ ឧមី - ជាន់ នឹងមន្ត្រីស្រុកចាំងៗបាយ បានប្រគេនពរសេចក្តីសាធុការតបវិញថា «ព្រះគុណអើយ! ថវរដីការំលឹកផ្តាំផ្ញើនេះពីរោះណាស់ ។ យើងខ្ញុំសូមទទួលចាំទុកតទៅ” ។

បន្ទាយក្រួចឆ្មារ កាលនៅថ្ងៃ ១៩ កើតខែមាឃ ឆ្នាំ ១ ក្នុងឆ្នាំ ១៩៤៤ មានគាហានតាំងនាយភូច - ធំជាច្រើននាក់ រៀបចំទីកន្លែង-បុណ្យយ៉ាងខ្ពស់អធិកអធម្ម ដូចនៅសាលាស្រុកដែរ មានទីកន្លែងសម្រាប់លេងល្បែនកំសាន្ត មានវេយ្យាយោសនាកុមារពេទ្យ ចាក់ថាសម៉ាស៊ីនភ្លេងពុះសូរសំឡេងគ្រាងគ្រឹក មានពួកឈ្មួញលក់ដូរបែបផែងៗជាច្រើនពេញតាំងបន្ទាយចង្អៀតជ្រៀតដើងគ្នាដើរស្ទើរតែពុំរួច ។

ឯបន្ទាយក្រួចឆ្មារនេះមាន ២ ថ្នាក់ គឺថ្នាក់លើនឹងថ្នាក់ក្រោម ។ តាំងពីរថ្នាក់នេះ សឹងពោរពាសដោយពួកសប្បុរសប្រុស - ស្រីចាស់ក្មេងខ្ចាន់ខ្ចាប់ត្រៀបត្រាតាំងជាន់លើជាន់ក្រោម ។ មានព្រះសង្ឃចំរើនព្រះបរិត្ត ចំនួន ២១ សំដែងធម៌ទេសនា ។ ក្នុងទីសន្និបាតនេះ ក៏ព្រះញាណកោសល ញាណ - ឈឺង ទេសនាទៀត គឺលោកសំដែង

១ . អំពីវិធីមាឃបូជា ត្រមតាំងនាំគាហាណ៍ដ៏ជ្រាលជ្រៅ ដែលមានកង្វិតគម្ពីរមេហាបទានិញ្ញាសូត្រ មកប្រៀបធៀបផលនៃការធ្វើសក្ការៈបូជា ជាបវេណីធម៌មួយសម្រាប់អ្នកកាន់ពុទ្ធសាសនា គួរធ្វើដោយសុទ្ធចិត្តពល់ៗរូប ។

២ . អំពីបែបបទសណ្តាប់ធ្នាប់កងយោធាគាហាន ត្រមតាំងអធិប្បាយអំពីឧត្តមគតិ លទ្ធផលនឹងកើតមានកើយកិច្ចដែលកងយោធាត្រូវតែបំពេញយ៉ាងខ្ជួលឃ្លាយ ដោយការអន់អាចតស៊ូខានពុំបាន ដរាបដល់អវសានក្នុងជីវិតរៀងៗខ្លួន ។

៣ .- អំពីជនអ្នកមានសេចក្តីកតញ្ញូកតវេទី ដឹងគុណធ្វើតបគុណលោក ព្រមទាំងអធិប្បាយប្រៀបធៀបហេតុផលដ៏ខ្ពង់ខ្ពស់ ដែលអ្នកដឹងគុណត្រូវទទួលមុំណោយ ទាំងក្នុងឥធលោកបរលោក ដោយមានភ័ស្តុតាងជាច្រើនរឿង មកពន្យល់ដោយថេរដីកាពីរោះផ្អែមល្ហែម គួរឲ្យកើតសេចក្តីជ្រះថ្លាក្រៃលែង ។ ចាប់តាំងពីមោង ២១ ដល់មោង ៦២ ទើបចប់ ។

លុះចប់ហើយពួកពុទ្ធបរិស័ទសូត្រប្រកាសផ្សាយផលបន្តគ្នា បន្ទាប់អំពីនោះ ពួកល្ខោនភំលេងតំសាន្តរហូតដល់យប់ជ្រៅ ឮសូរសំឡេងហ៊ោកញ្ជ្រៀវអឺងកងទាំងបន្ទាយក្រុងធ្នារ ។

ដល់ព្រឹកឡើងលោក ទុម - ផាន់ អ្នកស្រីនឹងពួកសប្បុរសដួបជុំជាក់ចាត្រព្រះសង្ឃ ១០៨ អង្គ ។ បន្ទាប់មក ពួកជាងថតរូបមកថតរូបឧត្តមបុរសទាំង ៤ នាក់គឺ ព្រះតេជគុណ ព្រះញាណកោសលញាណឈឺន, លោកស្រី - ណាល់ ចៅហ្វាយស្រុកក្រុងធ្នារ, លោក ទុម - ផាន់ នាយព្រិន្ទុចាលៅ, លោកមហាជា - អឿន និស្សិតសាលាចាលីជាន់ខ្ពស់ ពុកជាអនុស្សាវរីយ៍ ។
